# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

### «វិភង្គបករណ៍»

ទុតិយភាគ

៥

ព. ស. ២៥៥៧

# សម្មោហវិនោទនី

«វិភង្គបករណ៍»

ទុតិយភាគ

៥

ព. ស.

២៥៥៧

# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ «វិភង្គបករណ៍»

## ទុតិយភាគ

## ៥

អមដោយៈ

ព្រះអភិធម្មបិដកខ្មែរ ទុតិយភាគ ៨០-៨១

សម្មោហវិនោទនី អដ្ឋកថាបាលី ភាគ ២

សម្មោហវិនោទនី អត្ថយោជនា ភាគ ២

ផ្ដើមប្រែរៀបរៀងតាមច្បាប់ដើម

ដោយខ្ញុំព្រះករុណាខ្ញុំបាទ សុន្ទរ៍ សាមឿន

ព. ស. ២៥៥៧ គ. ស. ២០១៣

# សេចក្ដីបញ្ជាក់

*គម្ពីរ* **អដ្ឋកថាព្រះអភិធម្ម** *ជាពាក្យអធិប្បាយសេចក្ដីក្នុងព្រះអភិ-ធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគ គឺ*

**១.បឋមភាគ** *ឈ្មោះ* **អដ្ឋសាលិនី** *អធិប្បាយគម្ពីរ* ***ធម្មសង្គណី***

**២.ទុតិយភាគ** *ឈ្មោះ* **សម្មោហវិនោទនី** *អធិប្បាយគម្ពីរ* ***វិភង្គ***

**៣.តតិយភាគ** *ឈ្មោះ* **បរមត្ថទីបនី** *អធិប្បាយគម្ពីរ* ***បញ្ចបករណ៍*** *តាំងពី* ***ធាតុកថា*** *រហូតដល់ចប់គម្ពីរ* ***បដ្ឋាន*** *ទាំងអស់ ។*

*បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ។ ឯសៀវភៅដែលលោកអ្នកកំពុងអាននេះ ជាគម្ពីរអដ្ឋ-កថា* ***អភិធម្មបិដក ទុតិយភាគ ៥*** *កើតឡើងដោយស្នាព្រះហស្ដនៃ* ***ព្រះពុទ្ធឃោសាចារ្យ*** *ជាជនជាតិឥណ្ឌា បានរចនានៅឯប្រទេសសិរីលង្កា ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធជាង ៩០០ឆ្នាំ ។ ឯរូបខ្ញុំផ្ទាល់វិញគ្រាន់តែជាអ្នកផ្ដើមប្រែសម្រួលរៀបរៀង ជាបណ្ដោះអាសន្ន សម្រាប់អ្នកដែលត្រូវការសិក្សារៀនសូត្រតែប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ខ្ញុំ* ***សូមបញ្ជាក់*** *និងសូមទោសជាមុន ចំពោះអ្នកអាន និងអ្នកសិក្សាជាទីគោរពថា ខ្ញុំពុំមានសមត្ថភាពនៃការចេះដឹងគ្រប់គ្រាន់ ដូចសេចក្ដីនៃធម៌ដែលមាននៅ*

ក្នុងសៀវភៅនេះទេ ថែមទាំងសមត្ថភាពនៃការប្រែសម្រួល និងរៀបរៀង នេះទៀត មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ ការខុសឆ្គាំឆ្គងទាំងនុ៎ះ មានដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ តែខ្ញុំយល់ឃើញថា **មានប្រសើរជាងគ្មាន** ព្រោះសៀវភៅដែលរងនូវព្រះអភិធម្មបិដកបែបនេះ មិនទាន់ដែលមានគ្រប់គ្រាន់ក្នុងប្រទេសយើងទេ ដូច្នេះ យើងក៏អាចឧទាហរណ៍បានថា ៖

* សម័យណា ដែលមានភាពអន្ធការ សូម្បីតែពន្លឺអំពិលអំពែក ក៏អាចភ្លឺបានដែរ ។

* សម័យណា គ្មានដើមឈើ គេក៏អាចយកដើមល្ហុង ធ្វើជាដើមឈើបានដែរ ។ ល ។ (ស្រីហិតោបទេស) ។

ព្រោះហេតុដូច្នេះ ខ្ញុំសូមផ្ញើនូវគម្ពីរនេះ ដល់លោកអ្នកសិក្សា និងវិញ្ញូជនទាំងឡាយ ជួយកែសម្រួល សម្រាប់សិក្សាតរៀងទៅ ។ ដើម្បីសម្រួលដល់ការបូកសរុបមតិកែតម្រូវ ក្នុងអត្ថបទនេះ សូមមេត្តាជ្រាបដូចតទៅ ៖

១-សូមសរសេរឈ្មោះ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំ ដែលកែសម្រេចនៅលើក្រដាសដែលផ្ញើមក ។

២-ចុះលេខទំព័រ បន្ទាត់ ក្នុងតារាងលេខ ១ និងលេខ ២ ។ ចំពោះសេចក្តី ពាក្យ ឃ្លា ឬអក្ខរាវិរុទ្ធត្រង់ណា ដែលយល់ថា មិនទាន់ត្រឹមត្រូវ សូមសរសេរចុះក្នុងតារាងលេខ ៣ ។ ចំណែកពាក្យដែលយល់ថា គួរកែមកជាយ៉ាងណាវិញនោះ សូមសរសេរចុះក្នុងតារាងលេខ ៤ ។

៣-ប្រសិនបើ ការកែតម្រូវនោះ មានឯកសារបញ្ជាក់ សូមចុះឈ្មោះឯកសារនោះ ក្នុងតារាងលេខ ៥ ។

៤-នៅក្នុងតារាងលេខ ៦ សម្រាប់បញ្ជាក់បន្ថែម ចំពោះករណីពិសេសណា ដែលប្រាថ្នាចង់បញ្ជាក់បន្ថែម ។

៥-សូមផ្ញើកំណែមកខ្ញុំតាមរយៈគណៈកម្មការដែលមានអាសយដ្ឋានដូចនៅក្នុងសៀវភៅនេះស្រាប់ ។

* ប្រសិនបើ នៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀង អក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣

ខ្ញុំព្រះករុណា ខ្ញុំបាទ **សុន្ទរ៍ សាមៀន**

សូមអរព្រះគុណ និងអរគុណ

# តារាងកែតម្រូវ “ឮ”

## នាមឈ្មោះអ្នកជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួល

## អដ្ឋកថាទុតិយភាគ ៥ នេះ មាន ៖

១. ភិក្ខុអគ្គធីរោ **គង់ សុមិត្ត**

២. សាមណេរចន្ទប្បញ្ញោ **សាំ ចន្ទធីរ៍**

៣. ភិក្ខុអភិធម្មជោតិបាលោ **ម៉ុន សាយ**

៤. ភិក្ខុ **សៅ ប៊ុនថេង**

៥. ភិក្ខុ **ឡេង យ័ន្ត**

៦. លោកធម្មាននោ **ស្នួង សឿ**

៧. ភិក្ខុរក្ខិតធម្មោ **ច្រាក់ សាន**

៨. លោកជោតញ្ញាណោ **ខ៉េត សុផាន់**

៩. ភិក្ខុអភយត្ថេរោ **យឹម នឿន**

១០. ភិក្ខុបញ្ញាបជ្ជោតោ **ប៊ុត វណ្ណៈ**

១១. ភិក្ខុ **ឆោម វិបុល**

១២. ភិក្ខុសទ្ធាបព្វជិតោ **ចៅ សុជាតិ**

១៣. សាមណេរ **ផាន់ នី**

១៤. ភិក្ខុ **ឌី ប៊ុនថា**

១៥. ភិក្ខុ **សរ ពលរិទ្ធិ៍**

១៦. ភិក្ខុ **អ៊ិន សំអឿន**

១៧. ភិក្ខុ **ប៊ិច វណ្ណៈ**

១៨. ភិក្ខុ **សន នន់**

១៩. ឧបាសក **សំរោង វ័ណ្ណ**

២០. ភិក្ខុ **ឡុង ចក់**

២១. ភិក្ខុ **ឱម សារិម**

២២. ភិក្ខុ **សៅ នោ**

២៣. ភិក្ខុ **ឈុំ ចាន់**

២៤. ភិក្ខុ **យ៉ន សេងហាន**

២៥. សាមណេរ **យិន សាវឿន**

២៦. សាមណេរ **ង៉ាន សារិទ្ធ**

២៧. សាមណេរ **វង្ស សាវឿន**

២៨. សាមណេរ **គង់ ចាន់ថន**

២៩. សាមណេរ **ហាប់ ប៊ុនហួត**

៣០. សាមណេរ **កៅ ទឹម**

៣១. សាមណេរ **សៅ សេន**

៣២. សាមណេរ **សឹម សឿង**

៣៣. លោក **សឹម រតនៈ**

៣៤. លោក **ទ៉ូច សុខុម**

៣៥. លោកគ្រូ **លី សុទី**

៣៦. លោកឧទ្ទិជាតិកោ **ថៃ ភិរម្យ**

៣៧. លោក **លឹម លឿម** ហៅ ព្រែក

៣៨. លោក **ម៉ម ឈុំ**

៣៩. លោក **ខៀវ ណារិន្ទ** ។

## អ្នកមានឧបការៈក្នុងការរៀបចំធម្មទាននេះ

- *លោកបញ្ញាបទីបោ* ***ព្រឿង ប៊ុនធឿន***
- *លោកឧទ្ទិជាតិកោ* ***ថៃ ភិរម្យ***
- *ឧបាសិកា* ***លី ស៊ីវថូ*** *ជាដើម*
- *ឧបាសិកា* ***ថុន ស៊ូគី*** *ជាដើម*
- *ភិក្ខុសាមណេរ* ***វត្តគិរីរម្យចាស់*** *ជាដើម*
- *ឧបាសិកា* ***អ៊ឺ សរុន****ជាដើម*
- *លោក* ***ហេង សុវណ្ណារ៉ា***
- *ឧបាសក* ***ស្រួច ចាន់ណា*** *និងក្រុមគ្រួសារ ។*

*ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា ថ្លែងអំណរគុណយ៉ាង*

ជ្រាលជ្រៅ ចំពោះសន្តានចិត្តដ៏ល្អរបស់គុណម្ចាស់ ញាតិញោមជាពុទ្ធបរិស័ទ ទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួល ព្រមទាំងចំណាយរូបិយវត្ថុជាដើម ដើម្បីជំរុញឲ្យអត្ថបទនៃគម្ពីរនេះ ចេញជារូបរាងឡើង ។

បន្ទាប់ពីបឋមភាគ ៣ នេះទៅ ខ្ញុំនឹងដំណើរការបោះពុម្ពនូវទុតិយភាគ ៦ ជាបន្តទៀត ។

អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ ញាតិញោមទាំងក្នុង និងក្រៅប្រទេស មេត្តាជួយឧបត្ថម្ភ ដើម្បីបូជាធម៌ តាមកម្លាំងសទ្ធា ។

ម្យ៉ាងទៀត បើព្រះគុណម្ចាស់ ញាតិញោមត្រូវការចូលប្រាក់ ដើម្បីថតចម្លងជាធម្មទាន ឬយកផ្ទាល់ខ្លួន ឬក៏យកទៅតម្កល់តាមវត្តនានា សូមមេត្តាទាក់ទងតាមរយៈទូរសព្ទដូចខាងក្រោមនេះ ៖

០៩២ ៩០ ៨២ ៦៥

០៩៧ ២៣ ៣០ ២១៥

០១៦ ៤៦ ៥២ ៣៤

# ឧទ្ទិសកថា

*ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង និងក្រៅប្រទេស,* ***អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន*** *រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ* ***ហ៊ុន សែន*** *ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗ ស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស និងក្រៅប្រទេស មានលោកគ្រូ អគ្គបណ្ឌិត* ***ប៊ុត សាវង្ស*** *ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូមទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗ រូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។*

***ដោយអំណាចនៃមហាកុសលផលធម្មទាននេះ សូមឱ្យ ៖***

*-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ*

*-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា*

*-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ*

*-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ៕*

..........................................................................................................................................................................................

**តារាងកែតម្រូវ** ថ្ងៃទី ....... ខែ ..... ឆ្នាំ ...

**ទុតិយភាគ ៥** ឈ្មោះ ..........................

សម្រាប់បោះពុម្ពបន្ត អាសយដ្ឋាន ..................

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ឯកសារយោង | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |

# សម្មោហវិនោទនី អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**

**អារម្ភកថា (របស់អ្នកតែង)** ..... ..... ..... ..... ..... ..... ..... ..... ... ១


## ១.ខន្ធវិភង្គនិទ្ទេស

**ពណ៌នាអំពីសុត្តន្តភាជនិយ** ..... ..... ..... ..... ..... ..... ..... ..... ... ២


## ១.រូបនិទ្ទេស

សម្ដែងអំពីខន្ធសព្ទ .... .... .... .... .... .... .... .... .... .... .... ..... ..... ២

អធិប្បាយរូបក្ខន្ធ .... .... .... .... .... .... .... .... .... .... .... ...... ..... ៦

សម្ដែងអំពីសេចក្ដីក្ដៅ .... .... .... .... ..... ..... ..... ...... ..... ..... ..... ៩

សម្ដែងអំពីសេចក្ដីហេវ .... .... .... .... ..... ..... ..... ...... ..... ..... .... ៩

សម្ដែងអំពីសេចក្ដីស្រេកទឹក .... .... .... .... ..... ..... ..... ...... ...... ១០

សម្ដែងអំពីរូបជាអតីតៈជាដើម .... .... .... .... ..... ..... ..... ..... ... ១៤

សម្ដែងអំពីរូប ២ យ៉ាង .... .... .... .... .... .... .... .... .... .... .... ... ១៥

សម្ដែងអំពីរូបហីនទុកនិទ្ទេស .... .... .... .... .... .... .... .... .... ..... ១៨

សម្ដែងអំពីនិទ្ទេសបទនៃរូបប្រណីត .... .... .... .... .... .... .... .... ... ២០

សម្ដែងអំពីទូរទុករូបនិទ្ទេស .... .... .... .... .... .... .... .... ..... ..... ២៧


## ២. វេទនាខន្ធនិទ្ទេស

សម្ដែងអំពីនិទ្ទេសនៃវេទនាគ្រោតគ្រាត និងល្អិត .... .... .... .... .... ៣២

សម្តែងអំពីមតិរបស់អាចារ្យ .... .... .... .... .... .... .... .... .... ..... ៣៤
សម្តែងអំពីវេទនាទូរទុកនិទ្ទេស .... .... .... .... .... .... .... .... ...... ៤២

**៣. សញ្ញាខន្ធនិទ្ទេស ...... ...... ..... ..... ..... ..... ..... ..... ..... ៤៥**
**៤. សង្ខារក្ខន្ធនិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... .... ៤៨**
**៥. វិញ្ញាណក្ខន្ធនិទ្ទេស ..... ...... ..... ..... ..... ..... ..... ...... ៤៩**
សម្តែងអំពីបកិណ្ណកៈក្នុងបញ្ចក្ខន្ធ ១៦ យ៉ាង .... .... .... .... .... ...... ៤៩
សម្តែងអំពីការកើតឡើងលើកដំបូងរបស់ខន្ធ ៥ .... .... .... .... ...... ៥០
សម្តែងអំពីការកើតមុន និងកើតក្រោយ .... .... .... .... .... .... ..... ៥៤
សម្តែងអំពីការកំណត់កាលរបស់ខន្ធ ៥ .... .... .... .... .... .... .... .... ៥៦
សម្តែងអំពីការកើតឡើងខណៈជាមួយគ្នា តែរលត់ខណៈផ្សេងគ្នា .... ៦១
សម្តែងអំពីការកើតឡើងខណៈផ្សេងគ្នា រលត់ខណៈជាមួយគ្នា .... ... ៦២
សម្តែងអំពីការកើតព្រមគ្នា រលត់ព្រមគ្នា .... .... .... .... .... ..... .... ៦៥
សម្តែងអំពីការកើតខណៈផ្សេងគ្នា រលត់ខណៈផ្សេងគ្នា .... .... .... ... ៦៥
សម្តែងអំពីខន្ធដែលជាអតីតៈជាដើម .... .... .... .... .... .... .... ..... ៦៧
សម្តែងអត្ថនៃការវិនិច្ឆ័យខន្ធ ៥ .... .... .... .... .... .... .... .... .... ៦៨
សម្តែងអំពីការវិនិច្ឆ័យដោយលំដាប់ .... .... .... .... .... .... .... ...... ៦៨
សម្តែងអំពីសេចក្តីប្លែកគ្នា .... .... .... .... .... .... .... .... .... ..... .... ៧០
សម្តែងអំពីសេចក្តីមិនខ្វះ មិនលើស .... .... .... .... .... .... .... ...... ៧១

សម្តែងអំពីសេចក្តីឧបមា .... .... .... .... .... .... .... .... .... .... ..... ៧៣
សម្តែងអំពីការគប្បីឃើញដោយឧបមា ២ យ៉ាង .... .... .... .... ...... ៧៥
ពណ៌នាអំពីអភិធម្មភាជនិយ
សម្តែងអំពីរូបក្ខន្ធនិទ្ទេស .... .... .... .... .... .... .... .... .... .... ..... ៨២
សម្តែងអំពីវេទនាខន្ធនិទ្ទេស .... .... .... .... .... .... .... .... .... ...... ៨៣
សម្តែងអំពីទេសនាតាមអធ្យាស្រ័យបុគ្គល .... .... .... .... .... .... .... ៨៥
សម្តែងអំពីទេសនាវិលាស .... .... .... .... .... .... .... .... .... .... .... ៨៦
សម្តែងអំពីការកំណត់មហាវារៈ ៤ .... .... .... .... .... .... .... .... .... ៨៦
សម្តែងអំពីការពណ៌នាអត្ថក្នុងវេទនាខន្ធ .... .... .... .... .... .... ..... ៨៨
សម្តែងអំពីអាការៈ ៣ យ៉ាង .... .... .... .... .... .... .... .... .... ..... ៩០
សម្តែងអំពីសញ្ញាខន្ធនិទ្ទេស .... .... .... .... .... .... .... .... ..... ..... ៩៧
ពណ៌នាអំពីបញ្ហាបុច្ឆកៈ ..... ..... ..... ..... ..... ..... ...... ៩៨

## ២. អាយតនវិភង្គនិទ្ទេស

ពណ៌នាអំពីសុត្តន្តភាជនិយ ..... ..... ..... ..... ..... ..... ..... ..... ១០១
សម្តែងអំពីការវិនិច្ឆ័យដោយអត្ថ ..... .... .... .... .... .... .... ...... ១០១
សម្តែងអំពីការវិនិច្ឆ័យដោយលក្ខណៈ .... .... .... .... .... .... .... .... ១០៦
សម្តែងអំពីការវិនិច្ឆ័យដោយសេចក្តីមានត្រឹមតែប៉ុណ្ណោះ .... .... ... ១០៦

សម្ដែងអំពីការវិនិច្ឆ័យដោយលំដាប់ .... .... .... .... .... .... .... .... ១០៧

សម្ដែងអំពីការវិនិច្ឆ័យដោយសង្ខេប និងពិស្ដារ .... .... .... .... ..... ១០៩

សម្ដែងអំពីការវិនិច្ឆ័យដោយជាធម៌គប្បីឃើញ .... .... .... .... ..... ១១០

អធិប្បាយអាយតនៈដោយត្រៃលក្ខណ៍ .... .... .... .... .... .... ..... ១១២

**ពណ៌នាអំពីអភិធម្មភាជនិយ ..... ..... ..... ..... ..... ..... ..... ១១៨**

**ពណ៌នាអំពីបញ្ហាបុច្ឆកៈ ..... ..... ..... ..... ..... ..... ... ១២៥**


## ៣. ធាតុវិភង្គនិទ្ទេស


**ពណ៌នាអំពីសុត្តន្តភាជនិយ ..... ..... ..... ..... ..... ..... ....១២៧**

បឋវីធាតុនិទ្ទេស ២ យ៉ាង ... .... .... .... .... .... .... ..... ..... ..... ១២៨

បឋវីធាតុនិទ្ទេសខាងក្នុង .... .... .... .... .... .... .... ..... ..... ..... ១២៩

សម្ដែងអំពីឧគ្គហកោសល្យ ៧ យ៉ាង .... .... .... .... ... .... .... ... ១៣១

សម្ដែងអំពីមនសិការកោសល្យ ១០ យ៉ាង .... .... .... .... .... ..... ១៣២

សម្ដែងអំពីវិធីមនសិការ **កេសា** (សក់ទាំងឡាយ) ... .... .... .... ១៣៣

សម្ដែងអំពីវិធីមនសិការ **លោមា** (រោមទាំងឡាយ) ... .... ..... . ១៣៤

សម្ដែងអំពីវិធីមនសិការ **នខា** (ក្រចកទាំងឡាយ) ... .... ..... .... ១៣៤

សម្ដែងអំពីវិធីមនសិការ **ទន្តា** (ធ្មេញទាំងឡាយ) ... .... .... ..... ១៣៥

សម្ដែងអំពីវិធីមនសិការ **តចោ** (ស្បែក) .... .... .... .... ..... ...... ១៣៦

សម្ដែងអំពីវិធីមនសិការ **មំសំ** (សាច់) ... .... .... .... .... ..... ..... ១៣៦

សម្ដែងអំពីវិធីមនសិការ **ឧទរិយំ** (សរសៃទាំងឡាយ) .... ... ..... ១៣៧
សម្ដែងអំពីវិធីមនសិការ **អដ្ឋិ** (ឆ្អឹង) ... .... .... .... .... .... ..... .. ១៣៧
សម្ដែងអំពីវិធីមនសិការ **អដ្ឋិមិញ្ជំ** (ខួរក្នុងឆ្អឹង) ... .... .... .... ...... ១៣៩
សម្ដែងអំពីវិធីមនសិការ **វក្កំ** (ទាច) ... .... .... .... .... .... ..... ... ១៣៩
សម្ដែងអំពីវិធីមនសិការ **ហទយំ** (បេះដូង) ... .... .... .... .... ..... ១៤០
សម្ដែងអំពីវិធីមនសិការ **យកនំ** (ថ្លើម) ... .... .... .... .... .... ..... ១៤១
សម្ដែងអំពីវិធីមនសិការ **កិលោមកំ** (វាវ) ... .... .... .... ..... ..... ១៤១
សម្ដែងអំពីវិធីមនសិការ **បិហកំ** (ក្រពះ) ... .... .... .... .... ..... .. ១៤២
សម្ដែងអំពីវិធីមនសិការ **បប្ផាសំ** (សួត) ... .... .... .... .... ..... ... ១៤៣
សម្ដែងអំពីវិធីមនសិការ **អន្តំ** (ពោះវៀនធំ) ... .... .... .... .... ... ១៤៣
សម្ដែងអំពីវិធីមនសិការ **អន្តគុណំ** (ពោះវៀនតូច) .... ..... ..... ... ១៤៤
សម្ដែងអំពីវិធីមនសិការ **ឧទរិយំ** (អាហារថ្មី) .... ..... .... ..... ..... ១៤៤
សម្ដែងអំពីវិធីមនសិការ **ករីសំ** (អាហារចាស់) .... .... .... .... ..... ១៤៥
សម្ដែងអំពីវិធីមនសិការ **មត្ថលុង្គំ** (ខួក្នុងក្បាល) .... .... .... ..... .. ១៤៦
**បឋវីធាតុនិទ្ទេសខាងក្រៅ ..... ..... ..... ..... ..... ..... .... ១៤៦**
**អាបោធាតុនិទ្ទេសខាងក្នុង ..... ..... ..... ..... ..... ..... ... ១៤៨**
សម្ដែងអំពីវិធីមនសិការ **បិត្តំ** (ទឹកប្រមាត់) .... ..... ..... .... ..... ១៤៩

## មាតិកាធម៌


សម្តែងអំពីវិធីមនសិការ **សេម្ហំ** (ស្លេស្ម) ..... ..... .... .... ..... ..... ១៥០

សម្តែងអំពីវិធីមនសិការ **បុព្វោ** (ខ្ទុះ) ... .... .... .... .... .... ...... ១៥១

សម្តែងអំពីវិធីមនសិការ **លោហិតំ** (ឈាម) ... .... .... .... ..... .. ១៥២

សម្តែងអំពីវិធីមនសិការ **សេទោ** (ញើស) ... .... .... .... .... ....... ១៥៣

សម្តែងអំពីវិធីមនសិការ **មេទោ** (ខ្លាញ់ខាប់) ... .... .... .... ..... ១៥៣

សម្តែងអំពីវិធីមនសិការ **អស្សុ** (ទឹកភ្នែក) ... .... .... .... .... ..... ១៥៤

សម្តែងអំពីវិធីមនសិការ **វសា** (ខ្លាញ់រាវ) ... .... .... .... .... .... ..១៥៥

សម្តែងអំពីវិធីមនសិការ **ខេឡោ** (ទឹកមាត់) ... .... .... .... ..... .. ១៥៥

សម្តែងអំពីវិធីមនសិការ **សិង្ឃាណិកា** (ទឹកសំបោរ) ... .... .... .... ១៥៦

សម្តែងអំពីវិធីមនសិការ **លសិកា** (ទឹករំអិល) ... .... .... .... ...... ១៥៧

សម្តែងអំពីវិធីមនសិការ **មុត្តំ** (ទឹកមូត្រ) ... .... .... .... .... ..... ..១៥៧

**អាបោធាតុនិទ្ទេសខាងក្រៅ ..... ..... ..... ..... ..... ១៥៨**

**តេជោធាតុនិទ្ទេសខាងក្នុង ..... ..... ..... ..... ..... ១៥៩**

សម្តែងអំពីវិធីមនសិការតេជោធាតុ ... .... .... .... .... .... ..... ..... ១៦០

**តេជោធាតុនិទ្ទេសខាងក្រៅ ..... ..... ..... ..... ..... ១៦១**

**វាយោធាតុនិទ្ទេសខាងក្នុង ..... ..... ..... ..... ..... ១៦២**

សម្តែងអំពីវិធីមនសិការវាយោធាតុ ... .... .... .... .... .... ...... ១៦៣

**វាយោធាតុនិទ្ទេសខាងក្រៅ ..... ..... ..... ..... ..... ១៦៤**

**អាកាសធាតុនិទ្ទេសខាងក្នុង ..... ..... ..... ..... ..... ១៦៦**

**អាកាសធាតុនិទ្ទេសខាងក្រៅ ..... ..... ..... ..... ..... ១៦៧**

វិញ្ញាណធាតុនិទ្ទេស ..... ..... ..... ..... ..... ..... .. ១៦៨
ធាតុនិទ្ទេស ៦ ន័យទី ២ ..... ..... ..... ..... ..... .. ១៧០
ធាតុនិទ្ទេស ៦ ន័យទី ៣ ..... ..... ..... ..... ...... ១៧២
ពណ៌នាអំពីអភិធម្មភាជនិយ ..... ..... ..... ..... ..... ...... ១៧៩
សម្ដែងអំពីការវិនិច្ឆ័យដោយអត្ថ ... .... .... .... .... .... .... ..... ... ១៧៩
សម្ដែងអំពីការវិនិច្ឆ័យដោយលក្ខណៈជាដើម ... .... .... .... .... .... ១៨១
សម្ដែងអំពីការវិនិច្ឆ័យដោយលំដាប់ ... .... .... .... .... .... .... ..... ១៨១
សម្ដែងអំពីការវិនិច្ឆ័យដោយមានចំនួនប៉ុណ្ណោះ ... .... .... .... .... . ១៨២
សម្ដែងអំពីការវិនិច្ឆ័យដោយការរាប់ ... .... .... .... .... .... .... ..... ១៨៦
សម្ដែងអំពីការវិនិច្ឆ័យដោយបច្ច័យ ... .... .... .... .... .... .... ..... ១៨៧
សម្ដែងអំពីការវិនិច្ឆ័យដោយជាធម៌គួរឃើញ ... .... .... .... .... ..... ១៨៧
ពណ៌នាអំពីបញ្ហាបុច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ១៩១

## ៤. សច្ចវិភង្គនិទ្ទេស

ពណ៌នាអំពីសុត្តន្តភាជនិយពោលដោយទ្ទេសវារៈ ..... ..... ..... .. ១៩២
សម្ដែងអំពីការវិនិច្ឆ័យដោយការវិភាគ ... .... .... .... .... .... ..... ១៩៣
សម្ដែងអំពីការវិនិច្ឆ័យដោយការវិគ្រោះសព្ទ .... .... .... .... ..... ១៩៥
សម្ដែងអំពីការវិនិច្ឆ័យដោយប្រភេទមានលក្ខណៈជាដើម .... ... .... ១៩៨
សម្ដែងអំពីការវិនិច្ឆ័យដោយអត្ថ .... .... .... .... .... .... ..... ..... .. ២០០

សម្ដែងអំពីការវិនិច្ឆ័យដោយការរើអត្ថ .... .... .... .... .... .... ..... ២០២

សម្ដែងអំពីការវិនិច្ឆ័យដោយមិនខ្វះ មិនលើស .. .... .... .... .... .... ២០៣

សម្ដែងអំពីការវិនិច្ឆ័យដោយលំដាប់ ...... .... .... .... ..... .... ..... .. ២០៥

សម្ដែងអំពីការវិនិច្ឆ័យដោយកិច្ចនៃញាណក្នុងអរិយសច្ច .... ..... .... ២០៦

សម្ដែងអំពីការវិនិច្ឆ័យដោយប្រភេទនៃធម៌ដែលរាប់បញ្ចូលខាងក្នុង ២០៨

សម្ដែងអំពីការវិនិច្ឆ័យដោយឧបមា .... .... .... .... .... .... .... ..... ២០៩

សម្ដែងអំពីការវិនិច្ឆ័យដោយចតុក្កៈ (ពួក ៤) ... .... .... .... .... .... ២១០

សម្ដែងអំពីការវិនិច្ឆ័យដោយសុញ្ញតា (សូន្យ) ..... .... .... .... .... ២១២

សម្ដែងអំពីការវិនិច្ឆ័យដោយជាធម៌តែម្យ៉ាងជាដើម ... .... .... .... ២១៤

សម្ដែងអំពីការវិនិច្ឆ័យដោយសភាគ និងវិសភាគ .... .... .... .... .. ២១៩

**ពណ៌នាអំពីនិទ្ទេសវារៈ ..... ..... ..... ..... ..... ..... ..... ២២១**

សម្ដែងអំពីទុក្ខអរិយសច្ច .... .... .... .... .... .... ..... ..... .... ..... ២២១

សម្ដែងអំពីជាតិនិទ្ទេសដោយសម្មតិកថា .... .... .... .... .... ..... ... ២២៤

សម្ដែងអំពីជាតិនិទ្ទេសដោយបរមត្ថកថា .... .... .... .... .... ..... .. ២២៧

**គប្បីជ្រាបអត្ថនៃជាតិជាទុក្ខ ..... ..... ..... ..... ..... ..... .. ២២៨**

សម្ដែងអំពីទុក្ខមានការចុះកាន់គភ៌ជាមូល ..... ..... ..... ..... ..... ... ២២៩

សម្ដែងអំពីទុក្ខមានការបរិហារគភ៌ជាមូល ..... .... ..... ..... .... ..... ២២៩

សម្ដែងអំពីទុក្ខមានសេចក្ដីវិបត្តិនៃគភ៌ជាមូល .... .... ..... ..... ..... ២៣០

សម្ដែងអំពីទុក្ខមានការប្រសូតិជាមូល .... .... .... .... .... .... ..... ២៣០

សម្ដែងអំពីទុក្ខមានការចេញចាកគភ៌ជាមូល .... .... .... .... ..... .. ២៣០

សម្ដែងអំពីទុក្ខមានសេចក្ដីព្យាយាមរបស់ខ្លួនជាមូល .... ..... ២៣១

សម្ដែងអំពីទុក្ខមានសេចក្ដីព្យាយាមរបស់អ្នកដទៃជាមូល ..... ..... ២៣១

សម្ដែងអំពីជរានិទ្ទេស .... .... .... .... .... .... ..... ..... .... ..... ... ២៣៤

សម្ដែងអំពីជរា ២ យ៉ាង .... .... .... .... .... .... ..... ..... ..... .... ២៣៦

**គប្បីជ្រាបអត្ថនៃជរាជាទុក្ខ ..... ..... ..... ..... ..... ..... ២៣៨**

សម្ដែងអំពីមរណនិទ្ទេសដោយសម្មតិ .. .... .... .... .... .... .... ..... ២៤០

សម្ដែងអំពីមរណនិទ្ទេសដោយបរមត្ថ .... .... .... .... .... .... ..... .. ២៤០

**គប្បីជ្រាបវិនិច្ឆ័យអត្ថនៃមរណៈជាទុក្ខ ..... ..... ..... ..... .... ២៤៣**

សម្ដែងអំពីទុក្ខទាំង ៣ ដូចជាសត្រូវ ៣ នាក់ .... .... .... .... ..... ២៤៣

សម្ដែងអំពីសោកនិទ្ទេស .... .... .... .... .... .... .... ..... .... ..... .. ២៤៥

**គប្បីជ្រាបអត្ថនៃសេចក្ដីសោកជាទុក្ខ ..... ..... ..... ..... ..... ២៤៨**

សម្ដែងអំពីបរិទេវនិទ្ទេស .... .... .... .... .... .... .... .... ..... ...... ២៥១

**គប្បីជ្រាបអត្ថនៃបរិទេវៈជាទុក្ខ ..... ...... ..... ..... ..... ..... ២៥២**

**គប្បីជ្រាបអត្ថនៃទុក្ខជាទុក្ខជាដើម ..... ..... ..... ...... ...... ២៥៣**

សម្ដែងអំពីឧបាយាសនិទ្ទេស .... .... .... ..... ..... ..... .... ..... ..... ២៥៥

**គប្បីជ្រាបអត្ថនៃឧបាយាសៈជាទុក្ខ ..... ...... ..... ..... ...... ២៥៦**

សម្ដែងអំពីការប្រៀបធៀបទុក្ខ ៣ យ៉ាង ..... ..... ..... ..... .... .... ២៥៧

សម្ដែងអំពីអប្បិយសម្បយោគទុក្ខនិទ្ទេស ..... .... .... .... .... ...... ២៥៧

សម្ដែងអំពីបិយវិប្បយោគទុក្ខនិទ្ទេស .... .... .... .... .... .... .... ... ២៦០

សម្ដែងអំពីឥច្ឆានិទ្ទេស .... .... .... .... .... .... .... ..... ..... .... .... ២៦២
សម្ដែងអំពីឧបាទានក្ខន្ធនិទ្ទេស ..... .... .... .... .... ..... ..... .... .... ២៦៥
គប្បីជ្រាបអត្ថនៃខន្ធទាំងឡាយជាទុក្ខ ..... ..... ..... ..... ..... ២៦៥

## ពណ៌នាអំពីនិទ្ទេសវារៈ

សម្ដែងអំពីសមុទយសច្ច ..... ..... ..... .... .... .... .... ..... .... ..... ២៦៧

## ពណ៌នាអំពីនិទ្ទេសវារៈ

សម្ដែងអំពីនិរោធសច្ច .. .... .... .... .... .... .... .... ..... .... .... ... ២៧១
ធម៌ដែលជាវេវចនៈនឹងព្រះនិព្វាន ២៦ ..... .... .... .... .... .... .... ២៧៣

## ពណ៌នាអំពីនិទ្ទេសវារៈ

សម្ដែងអំពីមគ្គសច្ច ..... ..... ..... .... .... .... ..... ..... .... ..... ..... ២៧៥
សម្ដែងអំពីធម៌ ៨ យ៉ាងដោយលំដាប់ ..... ..... ..... .... .... .... .... ២៧៨
សម្ដែងអំពីសម្មាទិដ្ឋិនិទ្ទេស ..... ..... ..... ..... ..... ..... ..... .... .... ២៨១
សម្ដែងអំពីសម្មាសង្កប្បនិទ្ទេស ..... ..... ..... ..... ..... ..... .... ..... ២៨៤
កម្មដ្ឋានដែលជាសត្រូវចំពោះអកុសលវិតក្កៈ ៣ .... .... .... .... .... ២៨៦
សម្ដែងអំពីសម្មាវាចានិទ្ទេស ..... ..... ..... .... .... .... .... ..... .... ២៨៧
សម្ដែងអំពីសម្មាកម្មន្តនិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ២៨៨
សម្ដែងអំពីសម្មាអាជីវនិទ្ទេស .... ..... ..... ..... .... .... .... ..... .... ២៨៨
សម្ដែងអំពីសម្មាវាយាមនិទ្ទេសជាដើម ..... ..... ..... ..... ..... ..... ២៨៩
សម្ដែងអំពីសម្មាសមាធិនិទ្ទេស .... .... .... .... .... .... ..... ..... ..... ២៩០

សម្តែងអំពីមគ្គដែលជាលោកិយ និង លោកុត្តរ ..... ..... ..... ...... ២៩២
សម្តែងអំពីមគ្គទាំងវិជ្ជា ទាំងចរណៈជាដើម ..... ..... ..... ..... ...... ២៩៤
**ពណ៌នាអំពីអភិធម្មភាជនិយ ..... ..... ..... ..... ..... ..... .. ២៩៥**
សម្តែងអំពីការវិនិច្ឆ័យក្នុងនិទ្ទេសវារៈ ..... .... .... .... .... .... ..... ២៩៦
សម្តែងអំពីបដិបទាដែលប្រកបដោយអង្គមគ្គ ៥ ជាដើម ..... ...... ២៩៧
សម្តែងអំពីបដិបទា ៦០.០០០ ន័យ .... .... ..... ..... ..... ..... ..... ២៩៧
**ពណ៌នាអំពីបញ្ហាបុច្ឆកៈ ..... ..... ..... ..... ..... ..... ..... ២៩៩**

## ៥. ឥន្ទ្រិយវិភង្គនិទ្ទេស

**ពណ៌នាអំពីអភិធម្មភាជនិយ ..... ..... ..... ..... ..... ..... .. ៣០០**
សម្តែងអំពីសេចក្តីសម្គាល់របស់ឥន្ទ្រិយ៍ ២២ ..... ..... ..... ..... ..... ៣០០
សម្តែងអំពីការវិនិច្ឆ័យដោយអត្ថ .... .... .... .... .... ..... ..... ...... ៣០២
សម្តែងអំពីការវិនិច្ឆ័យដោយលក្ខណៈជាដើម ..... ..... ..... .... .... ៣០៤
សម្តែងអំពីការវិនិច្ឆ័យដោយលំដាប់ ..... ..... ..... ..... .... .... .... ៣០៥
សម្តែងអំពីការវិនិច្ឆ័យដោយសេចក្តីផ្សេងគ្នា និងមិនផ្សេងគ្នា .... ... ៣០៦
សម្តែងអំពីការវិនិច្ឆ័យដោយកិច្ច .... .... .... ..... ..... ..... .... ..... ៣០៧
សម្តែងអំពីការវិនិច្ឆ័យដោយភូមិ .... .... .... .... ..... ..... .... ..... ៣០៨
**ពណ៌នាអំពីបញ្ហាបុច្ឆកៈ ..... ..... ..... ..... ..... ..... ..... ៣១០**

# អក្សរសង្ខេប

## ដែលប្រើក្នុងអដ្ឋកថា ទុតិយភាគ ៥ នេះ

| | | |
|---|---|---|
| អភិ. | = | អភិធម្មបិដក |
| អំ. ចតុក្ក. | = | អង្គុត្តរនិកាយ ចតុក្កនិបាត |
| អំ. ឆក្ក. | = | អង្គុត្តរនិកាយ ឆក្កនិបាត |
| អំ. តិក. | = | អង្គុត្តរនិកាយ តិកនិបាត |
| អំ. បញ្ចក. | = | អង្គុត្តរនិកាយ បញ្ចកនិបាត |
| ខុ. ចូឡ. | = | ខុទ្ទកនិកាយ ចូឡវគ្គ |
| ខុ. ជា. | = | ខុទ្ទកនិកាយ ជាតក |
| ខុ. ធ. | = | ខុទ្ទកនិកាយ ធម្មបទ |
| ខុ. បដិ. | = | ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ |
| ខុ. សុ. | = | ខុទ្ទកនិកាយ សុត្តនិបាត |
| ទី. សី. | = | ទីឃនិកាយ សីលក្ខន្ធវគ្គ |
| ទី. បា. | = | ទីឃនិកាយ បាដិកវគ្គ |
| ទី. ម. | = | ទីឃនិកាយ មជ្ឈិមបណ្ណាសក |
| ម. ឧ. | = | មជ្ឈិមនិកាយ ឧបរិបណ្ណាសក |
| ម. ម. | = | មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក |
| ម. មូ. | = | មជ្ឈិមនិកាយ មូលបណ្ណាសក |
| វិនយ. | = | វិនយបិដក |
| សំ. ខន្ធ. | = | សំយុត្តនិកាយ ខន្ធវារវគ្គ |

| | | |
|---|---|---|
| សំ. សគា. | = | សំយុត្តនិកាយ សគាថវគ្គ |
| សំ. ម. | = | សំយុត្តនិកាយ មហាវារវគ្គ |
| សំ. ស. | = | សំយុត្តនិកាយ សគាថវគ្គ |
| សំ. សឡា. | = | សំយុត្តនិកាយ សឡាយតនវគ្គ |
| សម្មោ. អត្ថ. | = | សម្មោហវិនោទនី អត្ថយោជនា ។ |

# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ «វិភង្គបករណ៍»

## ទុតិយភាគ ៥

## ព. ស. ២៥៥៧

# សម្មោហវិនោទនី

# អដ្ឋកថាព្រះអភិធម្មបិដក

# ទុតិយភាគ ៥

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

**អារម្ភកថា** (របស់អ្នកតែង)

ព្រះសម្មាសម្ពុទ្ធជានាថៈ ទ្រង់ឃើញសច្ចៈទាំង ៤ ទើបទ្រង់ប្រកាសព្រះធម្មសង្គណី ៤ កណ្ឌ (គឺចិត្តុប្បាទកណ្ឌ រូបកណ្ឌ និក្ខេបកណ្ឌ និងអត្ថុទ្ធារកណ្ឌ) ទ្រង់ជានាយកប្រកបដោយធម៌របស់ព្រះពុទ្ធ ១៨ ប្រការ, ទ្រង់ជាព្រះបរមសាស្តា សម្តែងព្រះវិភង្គមួយណា ដោយអំណាចនៃវិភង្គ ១៨ ប្រការ មានខន្ធវិភង្គជាដើម ក្នុងលំដាប់នៃព្រះអភិធម្មធម្មសង្គណីនោះឯង ។ ឥឡូវនេះ លំដាប់នៃសំវណ្ណនា ព្រះវិភង្គនោះដល់ព្រមហើយ ព្រោះហេតុនោះ ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) ដោះស្រាយន័យនៃអដ្ឋកថាបុរាណហើយនឹងរៀបរៀង **អដ្ឋកថាព្រះវិភង្គ** នោះ ។ សូមសាធុជនទាំងឡាយចូរតាំងចិត្ត ធ្វើសេចក្តីគោរពព្រះសទ្ធម្ម [១] ហើយស្តាប់អដ្ឋកថាវិភង្គនោះចុះ ៕

---

[១] ពាក្យថា ព្រះសទ្ធម្មនេះ បានដល់ បរិយត្តិសទ្ធម្ម ( អត្ថយោជនា ) ។

# ១. ខន្ធវិភង្គនិទ្ទេស

## ពណ៌នាអំពីសុត្តន្តភាជនិយ [២]

## ១-រូបនិទ្ទេស

ពាក្យថា **ខន្ធ ៥** គឺ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណ-ក្ខន្ធ នេះ ឈ្មោះថា សុត្តន្តភាជនិយ ក្នុងខន្ធវិភង្គដែលជាវិភង្គដើម នៃវិភង្គប្ប-ករណ៍ ។ បណ្តាពាក្យទាំងនោះ ពាក្យថា **៥** ជាពាក្យកំណត់ចំនួន ។ ដោយពាក្យថា **៥** នោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្តែងថា ខន្ធទាំងឡាយមិនតិចជាងនោះ មិនច្រើនជាងនោះ (គឺមានត្រឹមតែប៉ុណ្ណោះ); ពាក្យថា **ខន្ធ** ជាពាក្យសម្តែងដល់ធម៌ ដែលទ្រង់សម្តែងទុក ៕

## អំពីខន្ធសព្ទ

ក្នុងព្រះបាលីខន្ធវិភង្គនោះ សព្ទថា **ខន្ធ** នេះ ប្រើក្នុងឋានៈច្រើន គឺក្នុងឋានៈថា គំនរ (រាសិម្ហិ) ក្នុងឋានៈថាគុណ (គុណេ) ក្នុងឋានៈថា បញ្ញត្តិ (បណ្ណត្តិយំ) ក្នុងសេចក្តីជាពាក្យជាប់មាត់ (រុឡ្ហិយំ) ។

ពិតមែន ឈ្មោះថា ខន្ធ ដោយឋានៈថា គំនរ ដូចក្នុងប្រយោគ មានពាក្យជាដើមថា "ម្នាលភិក្ខុទាំងឡាយ ការកាន់យកប្រមាណនៃទឹកក្នុងមហាសមុទ្រថា មានទឹកប៉ុណ្ណោះអាឡ្ហកៈ ឬប៉ុណ្ណោះរយអាឡ្ហកៈ ឬថាប៉ុណ្ណោះពាន់អាឡ្ហកៈ

---

[២] ពាក្យថា សុត្តន្តភាជនីយ៍ គឺពាក្យចែកដោយន័យដែលទ្រង់សំដែងទុកក្នុងព្រះសូត្រ ។

ឬក៏ប៉ុណ្ណោះសែនអាឡ្ហកៈ មិនមែនធ្វើបានដោយងាយទេ, តាមពិត រមែងដល់ការរាប់ថា ជាមហាឧទកក្ខន្ធ (គំនរទឹកធំ) ដែលនរណា១ មិនគប្បីរាប់បាន គប្បីប្រមាណ មិនបានឡើយ សូម្បីយ៉ាងណា" [៣] ដូច្នេះ ព្រោះថា មិនមែនទឹកតិចតួចគឺជាទឹកចំនួនច្រើនមែនពិត ទើបគេហៅថា **ឧទកក្ខន្ធ** (គំនរទឹក) ។ មួយទៀតធូលីមិនមែនមានប្រមាណតិចតួច គេក៏ហៅថា **រជក្ខន្ធ** (គំនរធូលី), គោមានប្រមាណមិនតិចតួច គេក៏ហៅថា **គវក្ខន្ធ** (ហ្វូងគោ) ពលមានប្រមាណមិនតិចគេក៏ហៅថា **ពលក្ខន្ធ** (កងពល), បុណ្យមានប្រមាណមិនតិច គេក៏ហៅថា **បុញ្ញក្ខន្ធ** (គំនរបុណ្យ), ព្រោះធូលីពិតជាមានច្រើន ទើបលោកហៅថា **រជក្ខន្ធ**, គោពិតជាមានចំនួនច្រើន ទើបលោកហៅថា **គោវក្ខន្ធ**, ពលមានប្រមាណច្រើន និងបុណ្យមានចំនួនច្រើន ទើបលោកហៅថា **ពលក្ខន្ធ** និង **បុញ្ញក្ខន្ធ** ។

ម្យ៉ាងទៀត ឈ្មោះថា **ខន្ធ** ដោយឋានៈថា **គុណ** ដូចក្នុងប្រយោគមានពាក្យជាដើមថា "***សីលក្ខន្ធោ*** = គុណ គឺសីល ***សមាធិខន្ធោ*** = គុណ គឺសមាធិ" [៤]; ក៏ឈ្មោះថា **ខន្ធ** ដោយឋានៈថា បញ្ញត្តិ ដូចក្នុងខនេះថា "ព្រះមានព្រះភាគជាម្ចាស់បានទតព្រះនេត្រឃើញកំណាត់ឈើធំ (មហន្តំ ទារុក្ខន្ធំ)

---

[៣] អំ. ចតុក្ក., អំ. ឆក្ក. ពាក្យថា **អាឡ្ហកៈ** ជាឈ្មោះកំណត់រាប់ដោយការវាល់របស់ ដូច ៤ កណ្ដាប់ដៃ ជា ១ ទូកដៃ, ២ ទូកដៃ ជា ១ ក្បង់, ២ ក្បង់ ជា ១ នាឡិ, ៤ នាឡិ ជា ១ អាឡ្ហកៈ ។

[៤] ទី. បា.។

[៥] សំ. សឡា.។

អណ្តែតតាមស្ទឹងគង្គាទៅ” [៥] ; ឈ្មោះថា **ខន្ធ** ដោយសេចក្តីថា **ជាពាក្យជាប់មាត់** ដូចក្នុងប្រយោគមានពាក្យជាដើមថា **“យំ ចិត្តំ មនោ មនសំ** ។បេ។ **វិញ្ញាណំ វិញ្ញាណក្ខន្ធោ** យ៉ាងណា” [៦] ។

ខន្ធនេះឯង ទ្រង់សំដៅយកដោយឋានៈថា **គង** ក្នុងអធិការនេះ ព្រោះឈ្មោះថា អត្ថនៃខន្ធនេះ មានសេចក្តីថា ជាពំនូក ជាក្រុម ជាដុំ ជាគង; ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ខន្ធទាំងឡាយមានលក្ខណៈជាគងគំនរ; សូម្បីនឹងពោលថា “អត្ថនៃខន្ធនេះ មានសេចក្តីជាកោដ្ឋាសៈ (ចំណែក)” ដូច្នេះក៏គួរ; ព្រោះមនុស្សក្នុងលោក បុលបំណុលគេមកហើយ កាលត្រូវម្ចាស់បំណុលទា ក៏និយាយថា “ពួកយើងនឹងឱ្យ ២ ខន្ធ (២ ចំណែក), ៣ ខន្ធ (៣ ចំណែក)” ។

សូម្បីកាលពោលថា “ខន្ធទាំងឡាយមានលក្ខណៈជាកោដ្ឋាសៈ គឺជាចំណែក” ដូច្នេះ ក៏គួរ; ដោយប្រការដូច្នេះ ពាក្យហៅថា **រូបក្ខន្ធ** ក្នុងសុត្តន្តភាជនីយ៍នេះ ទើបបានដល់ គំនរនៃរូប ចំណែកនៃរូប; ពាក្យថា **វេទនាខន្ធ** ក៏បានដល់ គំនរនៃវេទនា ចំណែកនៃវេទនា ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបអត្ថនៃខន្ធ មានសញ្ញាខន្ធជាដើមដោយន័យនេះ ។

---

[៦] អភិ. ។

[៧] រូប ២៩ គឺ អាយតនៈខាងក្នុង និងខាងក្រៅ ១០ និងសុខុមរូប ១៥ ។

[៨] រូប ៩៦ គឺ កម្មជរូប បានដល់ ចក្ខុទសកៈ សោតៈ ឃានៈ ជិវ្ហា កាយទសកៈ ឥត្ថីភាវទសកៈ បុរិសភាវទសកៈ រួមជា ៧០ និងសុទ្ធដ្ឋករូប ៨ កើតអំពីចិត្ត ឧតុ អាហារ រួមជា ២៤, សទ្ទរូប ២ កើតអំពីចិត្ត និងឧតុ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បានប្រមូលរូបទាំងអស់ ធ្វើឱ្យជាគំនរនៃរូប មានប្រភេទយ៉ាងនេះ គឺចំណែកនៃរូប ២៥ [៧] និងចំណែកនៃរូប ៩៦ [៨] ដែលទ្រង់ចែកទុកក្នុងឱកាស ១១ យ៉ាង មានរូបដែលកើតពីអតីតៈ អនាគត និងបច្චុប្បន្នជាដើម ដោយព្រះតម្រាស់ដែលត្រាស់ថា "**មហាភូតរូប ៤** និងរូបដែលអាស្រ័យមហាភូតរូប ៤" , ហើយទ្រង់សម្ដែងថា ឈ្មោះថា ***រូបក្ខន្ធ*** ទុកដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ម្យ៉ាងទៀត ទ្រង់ប្រមូលវេទនាទាំងអស់នោះ ធ្វើឱ្យជាកងនៃវេទនា ដែលប្រព្រឹត្តទៅក្នុងរូប ៤ ដែលទ្រង់ចែកទុកក្នុងភូមិ ១១ កន្លែងនោះនុ៎ះឯងថា "**សុខ‑វេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា**" ហើយទ្រង់សម្ដែងថា ឈ្មោះថា វេទនាខន្ធ; ហើយទ្រង់ប្រមូលសញ្ញាទាំងអស់នោះ ធ្វើឱ្យជាគំនរនៃសញ្ញា ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលទ្រង់ចែកទុកក្នុងឱកាស ១១ ពួកនោះនុ៎ះឯងថា "សញ្ញាកើតឡើងអំពី **ចក្ខុសម្ផស្ស** ។ល។ សញ្ញាកើតឡើងអំពី **មនោសម្ផស្ស**" ដូច្នេះ, ទើបទ្រង់សម្ដែងថា ឈ្មោះថា សញ្ញាខន្ធ; ក៏ទ្រង់ប្រមូលសង្ខារទាំងអស់នោះ ធ្វើឱ្យជាគំនរនៃចេតនា ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលទ្រង់ចែកទុកក្នុងឱកាស ១១ កន្លែងនោះនុ៎ះឯងថា "ចេតនាកើតពីចក្ខុសម្ផស្ស ។ល។ ចេតនាកើតពីមនោសម្ផស្ស" ដូច្នេះ, ទើបទ្រង់សម្ដែងថា ឈ្មោះថា **សង្ខារក្ខន្ធ**; ទ្រង់ប្រមូលវិញ្ញាណទាំងអស់នោះ ធ្វើឱ្យជាគំនរនៃចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលទ្រង់ចែកទុកក្នុងឱកាស ១១ ពួកនោះនុ៎ះឯងថា "**ចក្ខុវិញ្ញាណ, សោតវិញ្ញាណ, ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ, កាយវិញ្ញាណ, មនោធាតុ, មនោវិញ្ញាណ**

ធាតុ” ទើបទ្រង់សម្ដែងថា ឈ្មោះថា **វិញ្ញាណក្ខន្ធ** ។

ម្យ៉ាងវិញទៀត ក្នុងអធិការនៃខន្ធ ៥ នេះ សូម្បីរូបទាំងអស់ដែលកើតអំពីសមុដ្ឋានទាំង ៤ (គឺកម្ម ចិត្ត ឧតុ និងអាហារ) ឈ្មោះថា **រូបក្ខន្ធ**, វេទនាដែលកើតព្រមជាមួយចិត្ត ៨៩ មានកាមាវចរកុសលចិត្ត ៨ ជាដើម ឈ្មោះថា **វេទនា-ខន្ធ**, សូម្បីសញ្ញាក៏ឈ្មោះថា **សញ្ញាខន្ធ**, ធម៌មានសម្ផស្សជាដើម ក៏ឈ្មោះថា **សង្ខារក្ខន្ធ**, ចិត្ត ៨៩ ឈ្មោះថា **វិញ្ញាណខន្ធ** គប្បីជ្រាបការកំណត់ធម៌ក្នុងខន្ធ ៥ យ៉ាងនេះ ដោយប្រការដូច្នេះឯង ៕

## អធិប្បាយរូបក្ខន្ធ

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ មានសេចក្ដីប្រាថ្នានឹងទ្រង់សម្ដែងចែកនូវខន្ធមានរូបក្ខន្ធជាដើមនោះ ទើបត្រាស់ពាក្យមានពាក្យជាដើមថា **តត្ថ កតមោ រូបក្ខន្ធោ** = ក្នុងខន្ធ ៥ នោះ រូបក្ខន្ធតើដូចម្ដេច ? ។

គប្បីជ្រាបវិនិច្ឆ័យ**ក្នុងខន្ធវិភង្គនោះ** ដូច្នេះ ៖

បទថា “**តត្ថ** = ខន្ធ ៥ នោះ” ; បទថា **កតមោ** ជាកថេតុកម្យតា-បុច្ឆា; បទថា “**រូបក្ខន្ធោ** = រូបក្ខន្ធ” ជាបទសម្ដែងធម៌ដែលទ្រង់លើកឡើងជាបុច្ឆា; ព្រះភគវាកាលនឹងទ្រង់ចែករូបក្ខន្ធក្នុងពេលឥឡូវនេះ ទើបត្រាស់ព្រះតម្រាស់មានជាដើមថា “**យំ កិញ្ចិ រូបំ** = រូបយ៉ាងណានីមួយ” ។ បណ្ដាបទទាំងនោះ បទថា “**យំ កិញ្ចិ** = យ៉ាងណានីមួយ” ជាបទដែលទ្រង់កាន់យក

ដោយអំណាចដែលមិនសល់ ។ បទថា **"រូបំ** = រូប" ជាបទកំណត់ធម៌ដែលទាក់-ទងដោយបទថា **"យំ កិញ្ចិ រូបំ"** សូម្បីទាំងពីរយ៉ាងនេះ រមែងជាហេតុដែលទ្រង់ធ្វើការកំណត់យករូប ដោយមិនមានចំណែកសេសសល់ ។

**សួរថា** ក្នុងរូបក្ខន្ធនោះ ធម៌ដែលឈ្មោះថា *រូប* ដោយអត្ថថា ដូចម្តេច ?

ឆ្លើយថា ក៏ឈ្មោះថា *រូប* ដោយអត្ថថា វិនាស (**រុប្បនដ្ឋេន**); សមពិតដូចព្រះតម្រាស់ដែលត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុអ្វីពួកអ្នកទើបហៅថារូបទៅវិញ, ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដែលរូបរមែងវិនាសទៅ ខ្លួនឯង" ព្រោះហេតុដូច្នោះ ទើបហៅថារូប; រូបរមែងវិនាសទៅ ព្រោះហេតុអ្វី ? រមែងវិនាសទៅព្រោះត្រជាក់ខ្លះ, ព្រោះក្តៅខ្លះ, ព្រោះសេចក្តីឃ្លានខ្លះ, ព្រោះសេចក្តីស្រេកទឹកខ្លះ, ព្រោះសម្ផស្ស របោម មូស ខ្យល់ កម្តៅ និងសត្វវារលូនខ្លះ, ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដែលរូបរមែងវិនាសទៅខ្លួនឯង ព្រោះហេតុដូច្នោះ ទើបហៅថា *រូប*"[៩] ។

ក្នុងព្រះតម្រាស់ទាំងនោះ ពាក្យថា **កឹ** ជាការណបុច្ឆា (សួរដល់ហេតុ) អធិប្បាយថា ពួកលោកហៅថារូបព្រោះហេតុអ្វី ?, គឺឈ្មោះថា រូបនោះ ដោយហេតុអ្វី ? ។ **ឥតិ**សព្ទក្នុងបទថា **រុប្បតិ** នេះ ជាសព្ទលើកហេតុឡើងសម្តែង, អធិប្បាយថា ព្រោះហេតុដែលរូបតែងតែវិនាសទៅ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា រូប ។ ក៏បទថា **រុប្បតិ** មានអធិប្បាយថា រូបរមែងកម្រើក ជាបច្ច័យ

---

[៩] សំ. ខន្ធ. ។

តែងតែប៉ះទង្គិច ជាបច្ច័យ រមែងបៀតបៀន គឺរមែងបែកធ្លាយ, ដោយឋានៈនេះមានប្រមាណប៉ុណ្ណេះ រូបដែលព្រះភគវាត្រាស់ហើយ ដោយអត្ថថា វិនាសទៅដោយប្រការដូច្នេះ, សូម្បីនឹងពោលថា ឈ្មោះថា រូបដោយសេចក្ដីវិនាសទៅជាលក្ខណៈដូច្នេះក៏គួរ, ព្រោះរូបនេះមានការវិនាសទៅជាលក្ខណៈ ។

មួយទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យមានជាដើមថា **រូបរមែងវិនាសទៅព្រោះភាពត្រជាក់ខ្លះ,សម្ដែងអំពីភាពត្រជាក់ជាមុនសិន** សេចក្ដីដែលរូបវិនាសទៅ ប្រាកដក្នុងលោកន្តរនរក, ពិតមែន នរកមួយៗ ក្នុងចន្លោះគ្រប់ៗ ៣ ចក្រវាឡ មានប្រមាណ ៨.000 យោជន៍, នៅខាងក្រោមមិនមានផែនដី, ខាងលើមិនមានព្រះចន្ទព្រះអាទិត្យ ដួងប្រទីប ពន្លឺកែវមណី, ងងឹតស្លុបជានិច្ច, ឈ្មោះថា **លោកន្តរនរក**; អត្តភាពរបស់សត្វដែលកើតក្នុងលោកន្តរនរកនោះ មានប្រមាណ ៣ គាវុត, សត្វពួកនោះនឹងមានក្រចកទាំងឡាយ វែងក្រាស់ តោងត្រង់ជើងភ្នំសំយុងក្បាលចុះ ដូចសត្វប្រចៀវ, កាលណាវារំកិលខ្លួនទៅដល់ហត្ថបាសរបស់គ្នានឹងគ្នា, កាលនោះ ពួកវានឹងសម្គាល់ថា “ពួកយើងបានអាហារហើយ” ម្នាក់ៗក៏នាំគ្នាខ្វល់ខ្វាយក្នុងវត្ថុដែលខ្លួនសម្គាល់ថាជាអាហារនោះ ទើបដេញតាមគ្នាទៅពទ្ធជុំវិញ ហើយភ្លាត់ធ្លាក់ចុះ ទៅក្នុងទឹកដែលទ្រផែនដី, កាលត្រូវត្រជាក់បក់ថែមហើយ ថែមទៀត ឱ្យកាន់តែធ្ងន់ វាក៏នឹងដាច់ធ្លាក់ចុះទៅក្នុងទឹក ដូចផ្លែស្រគំទុំដូច្នោះ ។ គ្រាន់តែធ្លាក់ចុះប៉ុណ្ណោះ វាក៏មានស្បែក សរសៃ សាច់ និងឆ្អឹង ត្រូវទឹកអាស៊ីត ត្រជាក់ កាត់ទម្លាយជាចំណិតៗ ដូចដុំម្សៅដែលគេដាក់ក្នុងខ្លាញ់ដែរ; សេចក្ដីបែកធ្លាយទៅនៃរូបប្រាកដក្នុងលោកន្តរនរក ដោយសេចក្ដីត្រជាក់

យ៉ាងនេះ; សេចក្ដីបែកធ្លាយនៃរូបនេះ ប្រាកដក្នុងប្រទេសទាំងឡាយ ដែលមានភាពត្រជាក់កើត អំពីទឹកសន្សើមធ្លាក់ សូម្បីក្នុងតំបន់ទាំងឡាយ មានតំបន់រស់នៅ ឈ្មោះថា មហឹសកៈ ជាដើមក៏ដូចគ្នាដែរ; ព្រោះហៅថា សត្វទាំងឡាយក្នុងប្រទេសនោះ មានរាងកាយត្រូវភាពត្រជាក់ទម្លាយ កាត់ផ្ដាច់ហើយរមែងដល់សូម្បីការអស់ទៅនៃជីវិតដូច្នេះ ៕

## សម្ដែងអំពីសេចក្ដីក្ដៅ

សេចក្ដីដែលរូបបែកធ្លាយទៅប្រាកដហើយក្នុងអវីចិមហានរក; ពិតណាស់ក្នុងអវីចិមហានរកនោះ សត្វនរករមែងសោយទុក្ខយ៉ាងខ្លាំង ក្នុងពេលត្រូវកម្ម-ករណ៏មានការឱ្យដេកចុះលើផែនដីលោហៈ ដែលក្ដៅហើយចងរឹតទុកដោយគ្រឿងចង ៥ យ៉ាងជាដើម ៕

## សម្ដែងអំពីសេចក្ដីហេវ

សេចក្ដីដែលរូបវិនាសទៅប្រាកដហើយ ក្នុងបិត្តិវិស័យ (កំណើតប្រេត) និងក្នុងវេលាកើតទុព្ភិក្ខភ័យ (ទុរភិក្ស); ពិតមែន ពួកសត្វក្នុងកំណើតប្រេត ឈ្មោះថា យកដៃកាន់អាមិសយ៉ាងណានីមួយ ដាក់ចូលទៅក្នុងមាត់មិនបាន មានរហូត ២-៣ ពុទ្ធន្តរ ពោះខាងក្នុង បីដូចជាដើមឈើ មានប្រហោងដែលភ្លើងឆេះទូទៅ,

ក្នុងវេលាកើតទុរភិក្ស ឈ្មោះថា សត្វទាំងឡាយ អ្នកមិនបានសូម្បីត្រឹមតែទឹកបាយហើយ ដល់សេចក្តីស្លាប់ទៅ រាប់ប្រមាណមិនបាន ៕

## សម្តែងអំពីសេចក្តីស្រេកទឹក

សេចក្តីដែលរូបបែកធ្លាយទៅ ប្រាកដហើយ ក្នុងអសុរកាយទាំងឡាយ មាន**កាលកញ្ជិកាសូរ**ជាដើម; ពិតមែន សត្វទាំងឡាយ ក្នុងពួកកាលកញ្ជិកាសូរជាដើមនោះ រមែងមិនអាចបានតំណក់ទឹកត្រឹមតែញ៉ាំងផ្ទៃឱ្យសើម ឬត្រឹមតែឱ្យសើម អណ្តាតអស់ ២-៣ ពុទ្ធន្តរក៏គ្មានដែរ; សូម្បីពួកខ្លះ ដែលទៅដល់ស្ទឹង ដោយគិតថា “ពួកយើងនឹងផឹកទឹក” ដូច្នេះ ទឹកនោះ ក៏រីងស្ងួត ក្លាយទៅជាខ្សាច់ និងភក់នៃស្ទឹងទៅ; សូម្បីពួកខ្លះដែលត្រាច់ទៅដល់មហាសមុទ្រ មហាសមុទ្រក៏ក្លាយជាថ្មដា; សត្វពួកនោះទើបមានកាយស្គមស្គាំង ខ្សោយត្រាច់រង្គត់ទៅទាំងសេចក្តីទុក្ខយ៉ាង ខ្លាំងក្លាកំពុងគ្របសង្កត់ ។

បានឮថា កាលកញ្ជិកាសូរមួយ មិនអាចអត់ធន់សេចក្តីស្រេកឃ្លានបាន ទើបចុះទៅកាន់ស្ទឹងធំដែលមានជម្រៅ និងទទឹងមួយយោជន៍ៗ; ក្នុងកន្លែងដែលកាលកញ្ជិកាសូរនោះ ចុះទៅហើយទឹករីងស្ងួត, ជាផ្សែងហុយទ្រលោម, ដូចដើរលើថ្មដាដែលក្តៅចែសដូច្នោះ; កាលអសុរកាយនោះបានឮសម្លេងទឹកហើយ រត់ឆ្លេរឆ្លា ទៅខាងនេះ ខាងនោះ នៅរហូតដល់រាត្រីភ្លឺឡើង ។ ក្នុងខណៈពួកភិក្ខុ ៣០ រូប ដែលត្រាច់ទៅបិណ្ឌបាតជាវត្ត កំពុងត្រាច់រកភិក្ខាចារ តាំងពីព្រឹកបាន

ឃើញគេ ទើបសួរថា "ម្នាលសប្បុរស អ្នកជានរណា ?" ; អសុរកាយនោះឆ្លើយថា "ខ្ញុំជាប្រេតលោកម្ចាស់" ។

ពួកភិក្ខុ: តើអ្នកស្វែងរកអ្វី ?

អសុរកាយ: រកទឹកផឹកលោកម្ចាស់ ។

ពួកភិក្ខុ: ស្ទឹងនេះមានទឹកពេញ តើអ្នកមិនឃើញឬ ?

អសុរកាយ: លោកម្ចាស់ វាមិនសម្រេចដល់ខ្ញុំទេ ។

ពួកភិក្ខុ: បើយ៉ាងនោះ អ្នកចូរដេកត្រង់ឆ្នេរស្ទឹងចុះ, ពួកអាត្មានឹងចាក់ទឹកចុះក្នុងមាត់របស់អ្នក; អសុរកាយនោះក៏ដេកផ្ងារលើឆ្នេរខ្សាច់; ពួកភិក្ខុបាននាំគ្នាយកបាត្រដល់ទៅ ៣០ បាត្រ ដួសទឹកមកចាក់ចុះក្នុងមាត់របស់អសុរកាយ; កាលភិក្ខុពួកនោះធ្វើយ៉ាងនេះ វេលាភិក្ខាចារ ក៏ជិតចូលមកដល់; ទើបពួកភិក្ខុនិយាយថា "ដល់វេលាភិក្ខាចាររបស់អាត្មាហើយសប្បុរស, អ្នកបានសេចក្តីពេញចិត្តខ្លះទេ ?" ដូច្នេះ; អសុរកាយនោះឆ្លើយថា "លោកម្ចាស់ បើថា ទឹកមានត្រឹមតែមួយទូកដៃ ពីទឹកដែលចាក់ចុះដោយបាត្រដល់ទៅ ៣០ បាត្រ របស់ព្រះគុណម្ចាស់ចូលទៅក្នុងបំពង់ករបស់ខ្ញុំដោយការធ្វើរបស់មនុស្សបានសោត, សូមកុំឱ្យរួចផុតអំពីអត្តភាពជាប្រេតឡើយ" ។ សេចក្តីបែកធ្លាយទៅនៃរូបប្រាកដហើយក្នុងបិត្តិវិស័យព្រោះសេចក្តីស្រេកទឹក ដោយប្រការដូច្នេះ ។

**ហេតុដែលរូបវិនាសព្រោះសម្ផស្សរបោម និងមូសប្រាកដហើយ ក្នុងប្រទេសដែលច្រើនដោយរបោម និងមូសជាដើម** ។ មួយទៀត ក្នុងអធិការនេះ ពាក្យថា **របោម** បានដល់ រុយក្បាលលឿង ។ ពាក្យថា **មកសា** បានដល់ មូសនោះឯង ។ ពាក្យ

ថា ខ្យល់ គប្បីជ្រាបដោយអំណាចនៃខ្យល់ មានខ្យល់ក្នុងពោះ និងខ្យល់ខាងក្រោយខ្នងជាដើម ។

ពិតមែន រោគខ្យល់កើតឡើងក្នុងរាងកាយហើយ រមែងទម្លាយដៃ ជើង និងខាងក្រោយខ្នងជាដើម, ធ្វើឱ្យជាមនុស្សខ្វាក់, ជាមនុស្សគម, ជាមនុស្សខ្វិន ។

បទថា “**អាតបោ** = កម្តៅ” បានដល់ កម្តៅព្រះអាទិត្យ, ភាពនៃរូបដែលបែកធ្លាយទៅដោយកម្តៅនោះប្រាកដហើយ ក្នុងផ្លូវកន្តារមានសមុទ្រខ្សាច់ជាដើម ។ បានឮថា មានស្ត្រីម្នាក់ត្រឡប់ថយក្រោយ ពីពួករទេះ នាពេលរាត្រីក្នុងសមុទ្រខ្សាច់ កាលព្រះអាទិត្យគោចរទៅដល់ពាក់កណ្តាល (ថ្ងៃត្រង់) មិនអាចនឹងដាក់ជើងត្រង់កន្លែងខ្សាច់កំពុងក្តៅបាន ទើបដាក់កញ្ជើពីលើក្បាលចុះហើយជាន់, កាលមិនអាចឈរលើកញ្ជើ ព្រោះសេចក្តីក្តៅខ្លាំង ក៏ដាក់សំពត់សាដក លើកញ្ជើនោះហើយជាន់, សូម្បីសំពត់សាដកនោះ ក្តៅទូទៅហើយ ក៏ចាប់កូនតូច ដែលបីពមកឱ្យដេកផ្កាប់មុខជាន់លើកូនតូច ដែលកំពុងស្រែកយំ ព្រមជាមួយគ្នានោះ កូនតូចក៏បានធ្វើកាលកិរិយា (ស្លាប់) ក្នុងទីនោះនុ៎ះឯង ព្រោះកម្តៅនាំឱ្យក្រហល់ក្រហាយហើយ ។

ពាក្យថា “**សរីសបា** = សត្វលូន” បានដល់ សត្វទាំងឡាយមានខ្លួនវែងយ៉ាងណានីមួយ ត្រាច់លូនទៅ, ហេតុដែលរូបបែកធ្លាយទៅ ព្រោះសម្ផស្សនៃសត្វពួកនោះ បណ្ឌិតគប្បីជ្រាបដោយអំណាចក្នុងពេលដែលត្រូវអសិរពិសខាំជាដើម ។

ឥឡូវនេះ ព្រះភគវាទ្រង់ប្រាថ្នានឹងរួបរួមសូម្បីរូបទាំងអស់ដែលមាន ២៥ និង ៩៦ ចំណែក ដែលទ្រង់រួបរួមទុកដោយបទថា “**យំ កិញ្ចិ រូបំ** = រូបយ៉ាង

ណានីមួយ” ចូលក្នុងចំណែកនៃរូបដែលជាអតីតៈជាដើមមកសម្ដែង ទើបត្រាស់ពាក្យថា “**អតីតានាគតប្បច្ចុប្បន្នំ** = រូបជាអតីតៈ អនាគត និងបច្ចុប្បន្ន” តអំពីនោះ ទ្រង់ប្រាថ្នានឹងបែងចែករូបនោះនុ៎ះឯង ធ្វើឱ្យជាទុកៈ ៤ ទុកៈ មានអជ្ឈត្តទុកៈជាដើមមកសម្ដែង ទើបត្រាស់ពាក្យជាដើមថា “**អជ្ឈត្តំ វា ពហិទ្ធា វា** = រូបខាងក្នុង ឬរូបខាងក្រៅ” តអំពីនោះ កាលនឹងទ្រង់ប្រមូលរូបសូម្បីទាំងអស់នោះ ដែលទ្រង់កំណត់ទុកក្នុង ១១ ចំណែក មកសម្ដែងរួមជាចំណែកជាមួយគ្នា ទើបត្រាស់ពាក្យថា “**តទេកជ្ឈំ** = រូបនោះ រួមចំណែកតែមួយ” ។

បណ្ដាបទទាំងនោះ បទថា **តទេកជ្ឈំ** ញែកចេញជា **តំ ឯកជ្ឈំ**; បទថា **អភិសញ្ញូហិត្វា** = ប្រមូលមក ។ បទថា **អភិសង្ខិបិត្វា** បានដល់ ធ្វើការបំប្រួញ; ពាក្យនេះត្រាស់អធិប្បាយទុកថា ក៏រូបមានប្រការដូចពោលហើយនោះ សូម្បីទាំងអស់បណ្ឌិតហៅថា *រូបក្ខន្ធ* ព្រោះរួមជាកងតែមួយក្នុងភាវៈតែម្យ៉ាង ពោលគឺសេចក្ដីជារូបដែលវិនាសទៅ បែកធ្លាយទៅជាលក្ខណៈដូច្នេះ; ដោយពាក្យអធិ-ប្បាយនេះ រមែងជាការណ៍ដែលត្រាស់សូម្បីរូបទាំងអស់ក្នុងលក្ខណៈ នៃការបែកធ្លាយទៅនេះថា *រូបក្ខន្ធ* ព្រោះការចូលដល់ភាវៈជាកង (គំនររូប) ដូច្នេះ; ព្រោះថា ក៏ឈ្មោះថា *រូបក្ខន្ធ* ដទៃក្រៅអំពីរូបរកមិនមាន ។ ក៏រូបយ៉ាងណា, សូម្បីធម៌មានវេទនាជាដើមក៏ឈ្មោះថា *វេទនាខន្ធ* ជាដើមដូច្នោះដែរ ព្រោះការចូលដល់ភាវៈជាគំនរ ក្នុងលក្ខណៈ មានការសោយអារម្មណ៍ជាលក្ខណៈជាដើម; ព្រោះថា ក៏ឈ្មោះថា **វេទនាខន្ធ**ជាដើម ដទៃក្រៅពីវេទនាជាដើម មិនមានទេ ៕

## សម្តែងអំពីរូបជាអតីតៈជាដើម

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់កាលនឹងទ្រង់សម្តែងចែករូប ដែលទ្រង់ចាត់ចូលក្នុងឱកាសមួយៗ ឱ្យជាចំណែកៗ ទើបត្រាស់ពាក្យមានជាដើមថា **“តត្ថ កតមំ រូបំ អតីតំ** = ក្នុងរូបក្ខន្ធនោះ រូបជាអតីតៈ តើដូចម្តេច ?” ។

បណ្តាបទទាំងនោះ បទថា **តត្ថ** ជាបទសត្តមីវិភត្តិ ក្នុងមាតិកាតាមដែលទ្រង់ចាត់តាំងទុកក្នុងឱកាស ១១ យ៉ាង; ពាក្យនេះទ្រង់ត្រាស់អធិប្បាយថា ៖ ពាក្យថា រូបអតីតៈដែលត្រាស់ទុកក្នុងមាតិកាតាមដែលទ្រង់តាំងទុក ដោយន័យមានជាដើមថា **“អតីតានាគតប្បច្ចុប្បន្នំ”** ; រូបនោះ តើដូចម្តេច ? ។ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងបុច្ឆាទាំងអស់ដោយឧបាយយ៉ាងនេះ ។

បទទាំងឡាយមានពាក្យជាដើមថា **អតីតំ និរុទ្ធំ** រូបណាកន្លងទៅហើយ រលត់ទៅហើយ ជាពាក្យដែលត្រាស់ទុកក្នុងការពណ៌នាបទភាជនិយអតីតត្តិកៈនៃនិក្ខេបកណ្ឌនេះឯង ។

ពាក្យថា **ចត្តារោ ច មហាភូតា** នេះ ជាពាក្យសម្តែងសភាវៈរបស់រូបដែលត្រាស់ថា **អតីតៈ** ។ មួយទៀត ក្នុងអធិការនេះ ពាក្យដែលខ្ញុំពោលហើយយ៉ាងណា, ពាក្យដែលពោលទុកក្នុងទីគ្រប់កន្លែងគប្បីជ្រាបដូច្នោះចុះ ។ ដោយពាក្យនេះ ព្រះមានព្រះភាគជាម្ចាស់រមែងទ្រង់សម្តែងថា មហាភូតរូប និងរូបអាស្រ័យមហាភូតរូប ធ្វើរូបនេះឱ្យជារូបអតីតៈខ្លះ ធ្វើរូបនេះឱ្យជារូបអនាគតខ្លះ ។ល។ ធ្វើឱ្យជារូបឆ្ងាយ និងរូបជិតខ្លះ ព្រោះថា ក៏ឈ្មោះថា រូបដទៃក្រៅពីមហាភូតរូប និងរូបដែលអាស្រ័យមហាភូតរូបហើយមិនមានទេ ។

ម្យ៉ាងទៀត ខថា "**អតីតំសេន សង្គហិតំ** = រូបដែលសង្គ្រោះចូលដោយចំណែកអតីតៈ" បានដល់ រូបដែលសង្គ្រោះដោយចំណែកអតីតៈនោះឯង រមែងធ្វើការរាប់បាន ។ **សួរថា** រូបអ្វី ? ឆ្លើយថា មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ គប្បីជ្រាបអត្ថក្នុងទីទាំងពួងដូច្នេះដែរ ។ សូម្បីបទអធិប្បាយអំពីរូបដែលជាអនាគត និងបច្ចុប្បន្ន ក៏មានសេចក្តីតាមដែលពោលទុកហើយ ខាងក្រោយនោះឯង ៕

## សម្តែងអំពីរូប ២ យ៉ាង

ក៏រូបនេះ ឈ្មោះថា ជាអតីតៈ អនាគត និងបច្ចុប្បន្នមាន ២ យ៉ាង គឺ

**-រូបដោយបរិយាយនៃព្រះសូត្រ ១**

**-រូបដោយនិទ្ទេសនៃព្រះអភិធម្ម ១**។

សម្តែងអំពីបរិយាយនៃព្រះសូត្រ ទ្រង់កំណត់រូបដែលជាអតីតៈ អនាគត និង បច្ចុប្បន្ននោះទុកដោយភព ។ ពិតមែន រូបដែលកើតក្នុងភពអតីតៈ ចាប់ផ្តើមតាំងពីបដិសន្ធិ (ក្នុងភពបច្ចុប្បន្ន) ឬរូបទាំងអស់ដែលកើតហើយក្នុងភពបន្តបន្ទាប់ទៅ ឬរូបដែលកើតហើយក្នុងភពទីបំផុតនៃសែនកោដិកប្បក៏ដោយ ឈ្មោះថា រូបអតីតៈដោយពិត ។ រូបដែលនឹងកើតក្នុងភពអនាគត ចាប់ផ្តើមតាំងពីចុតិហើយ ឬរូបដែលនឹងកើតក្នុងភពបន្តបន្ទាប់ទៅ ឬថារូបទាំងអស់ដែលនឹងកើតក្នុងទីបំផុតនៃភពសែនកោដិកប្បក៏ដោយ ឈ្មោះថា **រូបអនាគតដោយពិត** ។ រូបដែលកំពុងប្រព្រឹត្តទៅក្នុងចន្លោះចុតិ និងបដិសន្ធិ (តាំងពីកើតដល់ស្លាប់ក្នុងភព

បច្ចុប្បន្ន) ឈ្មោះថា **រូបបច្ចុប្បន្ន**។

ចំណែកក្នុងនិទ្ទេសនៃព្រះអភិធម្ម ទ្រង់កំណត់រូបដោយខណៈ; ដោយខណៈនៃរូបមាន ៣ យ៉ាង គឺ ឧប្បាទក្ខណៈ (ខណៈកើត), ឋិតិខណៈ (ខណៈតាំងនៅ), ភង្គខណៈ (ខណៈបែកធ្លាយ); រូបដែលដល់ខណៈទាំង ៣ នេះ រលត់ទៅ ឬរូបដែលរលត់ក្នុងខណៈជិតៗ ឬថារូបទាំងអស់រលត់ក្នុងខណៈទីបំផុតនៃសែនកោដិ-កប្បក៏ដោយ ឈ្មោះថា រូបអតីតៈនោះឯង, រូបទាំងអស់ដែលនៅមិនដល់ខណៈទាំង ៣ ឬនៅមិនដល់ដោយត្រឹមតែខណៈនៃចិត្តមួយដួង ឬក៏នៅមិនដល់ខណៈក្នុងទីបំផុតនៃសែនកោដិកប្បក៏ដោយ ឈ្មោះថា រូបអនាគតនោះឯង; តែរូបដែលដល់នូវខណៈទាំង ៣ នេះហើយ ឈ្មោះថា រូបបច្ចុប្បន្ន ។

ក្នុងបរិយាយនៃព្រះសូត្រ និងក្នុងនិទ្ទេសនៃព្រះអភិធម្មនោះ សូម្បីរូបនេះនឹងមានការចែកតាមព្រះសូត្រ (សុត្តន្តភាជនិយ) ក៏ពិតមែនហើយ, ក៏ប៉ុន្តែ គប្បីជ្រាបថា រូបដែលជាអតីតៈ អនាគត និងបច្ចុប្បន្ន សម្រេចហើយដោយនិទ្ទេសនៃព្រះអភិធម្មប៉ុណ្ណោះឯង ។

ម្យ៉ាងទៀត ព្រោះថា រូបនេះឈ្មោះថា រូបអតីតៈ ដោយចំណែកទាំង ៤ ដោយអំណាច **អទ្ធា ១ សន្តតិ ១ សម័យ ១ និងខណៈ ១**; ជារូបអនាគត និងជារូបបច្ចុប្បន្ន ក៏ដោយចំណែកទាំង ៤ ដូចគ្នាដែរ ។

**សម្តែងអំពីអំណាចនៃអទ្ធាជាមុនសិន** រូបក្នុងកាលមុនបដិសន្ធិ ក្នុងភពមួយរបស់បុគ្គលម្នាក់ ឈ្មោះថា **រូបអតីតៈ**, រូបខាងមុខពីចុតិ ឈ្មោះថា **រូបអនាគត**, រូបក្នុងចន្លោះទាំងពីរនោះ ឈ្មោះថា **រូបបច្ចុប្បន្ន**; **សម្តែងអំពីអំណាចសន្តតិ** រូបដែល

មានឧតុជាមួយគ្នា ចំណែកស្មើគ្នាជាសមុដ្ឋាន និងរូបដែលមានអាហារដូចគ្នាជាសមុដ្ឋាន សូម្បីកំពុងប្រព្រឹត្តទៅដោយអំណាចនៃការកើតតមកពីខាងដើម ឈ្មោះថា រូបបច្ចុប្បន្ន, រូបដែលមានឧតុ និងអាហារមិនស្មើជាមួយនឹងសមុដ្ឋាន ដែលកើតពីរូបបច្ចុប្បន្នមុននោះ ឈ្មោះថា រូបអតីតៈ, រូបដែលមានឧតុ និងអាហារមិនស្មើគ្នា មានសមុដ្ឋានកើតក្រោយបច្ចុប្បន្ន ឈ្មោះថា រូបអនាគត; ចិត្តជរូប (គឺរូបកើតពីចិត្ត) មានវីថិជាមួយគ្នា មានជវនៈតែមួយ និងសមាបត្តិតែមួយ ឈ្មោះ ថា **រូបបច្ចុប្បន្ន**, ចិត្តជរូប ដែលកើតមុនរូបបច្ចុប្បន្ននោះ ឈ្មោះថា **រូបអតីតៈ**, ចិត្ត-ជរូបដែលកើតក្រោយ រូបបច្ចុប្បន្ន ឈ្មោះថា **រូបអនាគត**; រូបដែលមានកម្មជាសមុដ្ឋាន មិនមានប្រភេទអតីតៈជាដើម ដោយអំណាចសន្តតិតែម្យ៉ាងដោយចំពោះ, តែគប្បីជ្រាបប្រភេទនៃ រូបអតីតៈជាដើម របស់រូបដែលមានកម្មជាសមុដ្ឋាននោះ ដោយអំណាចនៃឧបត្ថម្ភករូប ឧតុជរូប អាហារជរូប និងចិត្តជរូបទាំងនោះឯង; **សម្តែងអំពីអំណាចនៃសម័យ** រូបដែលកំពុងប្រព្រឹត្តទៅ ដោយអំណាចការបន្តក្នុងសម័យទាំងឡាយ មានគ្រា យាម ពេលព្រឹក ល្ងាច យប់ និងពេលថ្ងៃជាដើម តែម្យ៉ាង សម័យនោះ ឈ្មោះថា **រូបបច្ចុប្បន្ន**, រូបដែលកើតមុនសម័យនោះ ឈ្មោះថា **រូបអតីតៈ**, រូបដែលកើតក្រោយសម័យនោះ ឈ្មោះថា **រូបអនាគត** ។ **ពោលអំពីអំណាចនៃខណៈ** រូបដែលរាប់បញ្ចូលដោយខណៈទាំង ៣ មានឧប្បាទក្ខណៈជា-ដើម ឈ្មោះថា **រូបបច្ចុប្បន្ន**, រូបដែលកើតមុនខណៈទាំង ៣ នោះ ឈ្មោះថា **រូបអតីតៈ**, រូបដែលកើតក្រោយខណៈទាំង ៣ នោះ ឈ្មោះថា **រូបអនាគត** ។

ម្យ៉ាងទៀត រូបដែលមានកិច្ចនៃហេតុ និងបច្ច័យកន្លងទៅហើយ ឈ្មោះថា **រូបអតីតៈ**, រូបដែលមានកិច្ចនៃហេតុសម្រេចហើយ ពីកិច្ចនៃបច្ច័យនៅមិនទាន់សម្រេច ឈ្មោះថា **រូបបច្ចុប្បន្ន**, រូបដែលមានកិច្ចទាំងពីរនៅមិនទាន់មកដល់ ឈ្មោះថា **រូបអនាគត**; ម្យ៉ាងវិញទៀត រូបដែលប្រព្រឹត្តទៅក្នុងខណៈនៃកិច្ចរបស់ខ្លួន ឈ្មោះថា **រូបបច្ចុប្បន្ន**, រូបដែលប្រព្រឹត្តទៅមុនកិច្ចរបស់ខ្លួននោះ ឈ្មោះថា **រូបអតីតៈ**, រូបដែលនឹងប្រព្រឹត្តទៅខាងក្រោយកិច្ចរបស់ខ្លួននោះ ឈ្មោះថា **រូបអនាគត**; ក៏ក្នុងនិទ្ទេសនៃរូបជាអតីតត្តិកៈនេះ កថាសម្ដែងអំពីលក្ខណៈជាដើម ជាកថាមិនអស់ជើង (ដោយត្រង់ទេ), ដែលនៅសល់ មានបរិយាយអស់ជើង; ក្នុងកថាទាំងពីរនោះ និប្បរិយាយកថា (កថាមិនអស់ជើង) ទ្រង់បំណងយកក្នុងសុត្តន្តភាជនិយនេះ; សូម្បីនិទ្ទេសនៃបទរូបពួកអជ្ឈត្តទុកៈ មានសេចក្ដីតាមដែលពោល ទុកក្នុងអជ្ឈត្តិកនិទ្ទេសខាងក្រោយនោះឯង ។ រូបគ្រោតគ្រាតជាដើម មានសេចក្ដី ដូចដែលខ្ញុំពោលទុកក្នុងការពណ៌នារូបកណ្ឌនោះឯណោះ ៕

## សម្ដែងអំពីរូបហីនទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃរូបហីនទុកៈតទៅ ៖

បទថា **"តេសំ តេសំ សត្តានំ** = របស់សត្វនោះៗ" នេះ ជាឆដ្ឋីវិភត្តិប្រព្រឹត្តទៅក្នុងសត្វច្រើន; ព្រោះថា កាលបើត្រាស់ថា "របស់សត្វសូម្បីដទៃ របស់សត្វសូម្បីដទៃ" ដូច្នេះ ត្រាស់ហើយរហូតមួយថ្ងៃក្ដី រហូតសែនកប្បក្ដី ក៏រមែងត្រាស់ដោយព្រះតម្រាស់ថា (សត្វនោះៗ) មានប្រមាណប៉ុណ្ណោះ; ព្រោះ

ហេតុនោះ ព្រះសាស្តាកាលបើនឹងទ្រង់កំណត់យកសត្វ ដោយមិនសល់ដោយបទទាំងពីរប៉ុណ្ណោះ ទើបត្រាស់ថា “**តេសំ តេសំ សត្តានំ**” ។ ក៏ដោយបទមានប្រមាណប៉ុណ្ណោះ រមែងសម្រេចការសម្តែងដល់សត្វដទៃ១ សូម្បីទាំងអស់ ។

បទថា “**ឱឡារិកំ** = ដែលគួរមើលងាយ” គឺដែលគេប្រមាថ ។ បទថា “**អវមញ្ញាតំ** = បៀតបៀន” គឺរូបដែលគេបង្អាប់, ដែលនរណា១ ដឹងហើយ ក៏មិនប្រកាសថា រូបខ្លះ ។ បទថា “**ហីឡិតំ** = គួរខ្ពើម” គឺរូបដែលបោះចោល, បោះបង់ចោល ដោយអត្ថថា មិនគួរកាន់យក, អាចារ្យពួកខ្លះពោលថា “រូបដែលគួរខ្ពើម” ក៏មាន; បទថា “**បរិភូតំ** = គួរដំណិះ” គឺដែលគេដំណិះ ដោយពោលពាក្យថា “ប្រយោជន៍អ្វីដោយរូបនេះទៅ!” ។ បទថា “**អចិត្តីកតំ** = មិនគួរលើកតម្កើង” គឺរូបដែលមិនគួរគោរព ។ បទថា “**ហីនំ** = អន់” គឺរូបដែលលាមក ។ បទថា “**ហីនមតំ** = ដែលគេដឹងថាអន់” គឺរូបដែលគេដឹងគ្នាថាថោកថយ បានដល់ រូបដែលគេព្រមគ្នាហើយធ្វើឱ្យលាមក ។ បទថា “**ហីនសម្មតំ** = សន្មតគ្នាថាអន់” គឺរូបដែលសន្មតគ្នាក្នុងលោកថា អាក្រក់ ឬរូបដែលមនុស្សថោកទាបសន្មតគ្នា ដូចគូថដែលសត្វមានលាមកជាអាហារសន្មតគ្នា; បទថា “**អនិដ្ឋំ** = មិនគួរប្រាថ្នា” គឺរូបដែលមិនគួរស្រឡាញ់, ឬរូបដែលគេមិនស្វែងរក ដើម្បីត្រូវការនឹងបាន; បើនរណា១ នឹងគប្បីស្វែងរករូបនោះ, ក៏គប្បីស្វែងរកចុះ; តែថា រូបដែលមិនគួរប្រាថ្នានេះឯង ជាឈ្មោះរបស់អារម្មណ៍នោះ ។ បទថា “**អកន្តំ** = មិនគួរស្រឡាញ់” គឺរូបដែលមិនគួរប្រាថ្នា, ឬរកសិរីមិនបាន ។ បទថា “**អមនាបំ** = មិនគួរពេញចិត្ត” គឺរូបដែលមិនជាទីសប្បាយចិត្ត; ពិតមែន

រូបដូច្នោះ រមែងមិនជាទីត្រជាក់សប្បាយចិត្ត; ម្យ៉ាងទៀត មានវិគ្រោះថា **មនំ អប្បាយតិ វឌ្ឍេតីតិ មនាបំ ន មនាបំ អមនាបំ** = រូបណារមែងញ៉ាំងចិត្តឱ្យឆ្អែត គឺឱ្យចម្រើន ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា មនាបៈ (ញ៉ាំងចិត្តឱ្យឆ្អែត), រូបដែលមិនញ៉ាំងចិត្តឱ្យឆ្អែត ឈ្មោះថា អមនាបៈ ។

ម្យ៉ាងវិញទៀត រូបឈ្មោះថា មិនគួរប្រាថ្នា ព្រោះវៀរចាកសម្បត្តិ, រូបដែលមិនគួរប្រាថ្នានោះ មានអកុសលកម្មជាសមុដ្ឋានដោយចំណែកមួយ ក្នុងរូបទាំងឡាយដែលមានកម្មជាសមុដ្ឋាន; ក៏ឈ្មោះថា **អកន្តំ** = រូបដែលមិនគួរ ស្រឡាញ់ ព្រោះមិនមានហេតុនៃសេចក្តីសុខ ។ ក៏ឈ្មោះថា **អមនាបំ** = រូបដែលមិនគួរពេញចិត្ត ព្រោះជាហេតុនៃសេចក្តីទុក្ខ ។

បទថា "**រូបា សទ្ទា** = រូប សម្លេង" ជាដើមនេះ ជាពាក្យសម្តែងភាវៈរបស់រូបអាក្រក់នោះ; ពិតណាស់ ព្រះអង្គទ្រង់ចែកកាមគុណ ៥ ដែលមិនគួរប្រាថ្នា ដោយអំណាចនៃរូបដែលកើតពីអកុសលកម្មទុកក្នុងបទនេះ; ព្រោះថា រូបដែលកើតពីកុសលកម្ម ឈ្មោះថា មិនគួរប្រាថ្នាមិនមានទេ, រូបទាំងអស់ដែលកើតពីកុសលកម្ម ជារូបដែលគួរប្រាថ្នាទាំងអស់ ៕

## និទ្ទេសនៃបទរូបប្រណីត

គប្បីជ្រាបដោយន័យផ្ទុយគ្នាពីន័យដែលខ្ញុំពោលទុកហើយ; តែក្នុងបទនេះ ព្រះអង្គទ្រង់ចែកកាមគុណ ៥ ដែលគួរប្រាថ្នាដោយអំណាចនៃរូប ដែលកើតពីកុសលកម្ម ។ ព្រោះថា រូបដែលកើតពីកុសលកម្ម ឈ្មោះថា រូបដែលមិនគួរប្រាថ្នា

រមែងមិនមាន, រូបទាំងអស់គួរប្រាថ្នាមែនពិត ។ ក៏ក្នុងរូបកើតពីកម្មយ៉ាងណា, សូម្បីក្នុងរូបទាំងឡាយ ដែលមានឧតុជាសមុដ្ឋានជាដើម ក៏យ៉ាងនោះដែរ រមែងជារូបដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា, បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ចែកចំពោះឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ទុកក្នុងទុកៈនេះ ដោយប្រការដូច្នេះ ។

នេះជាកថាមានអត្ថស្មើគ្នារបស់អាចារ្យទាំងឡាយជាមុនសិន ។

ចំណែកអាចារ្យវិតណ្ឌវាទីពោលថា ឈ្មោះថា **ឥដ្ឋារម្មណ៍** និង**អនិដ្ឋារម្មណ៍** ដែលព្រះអង្គទ្រង់ចែកទុកចំពោះតែមួយចំណែកមិនមាន, ព្រះអង្គទ្រង់ត្រាស់ធម៌នោះទុក ដោយអំណាចសេចក្ដីពេញចិត្តរបស់សត្វនោះៗ; ដូចយ៉ាងដែលត្រាស់ថា **“មហាបពិត្រ ទីបំផុតនៃសេចក្ដីពេញចិត្ត តថាគតពោលថាជាកំពូលនៃបញ្ចកាមគុណ; មហាបពិត្រ រូបឯណាជាទីពេញចិត្តរបស់បុគ្គលពួកខ្លះ, រូបទាំងនោះ មិនជាទីពេញចិត្តរបស់បុគ្គលពួកខ្លះ គេពេញចិត្ត មានសេចក្ដីត្រិះរិះបរិបូណ៌ដោយរូបឯណា, រូបដទៃពីនោះនឹងក្រៃលែងជាង ឬប្រណីតជាង គេក៏មិនប្រាថ្នា, រូបទាំងនោះជាយ៉ាងក្រៃលែងសម្រាប់គេ, រូបទាំងនោះជាកំពូលសម្រាប់គេ; មហាបពិត្រ សម្លេងឯណា..., ក្លិន ឯណា..., រសឯណា..., ផោដ្ឋព្វៈឯណាជាទីពេញចិត្តរបស់មនុស្សពួកខ្លះ, ផោដ្ឋព្វៈទាំងនោះ ជាទីពេញចិត្តរបស់មនុស្សពួកខ្លះ មិនជាទីពេញចិត្តរបស់មនុស្សពួកខ្លះ”** [១០] ជាដើម ។ ដោយព្រះតម្រាស់យ៉ាងនេះ បុគ្គលពួកមួយរមែងពេញចិត្ត រមែងរីករាយក្រៃលែងនូវបញ្ចកាមគុណមានរូបជាដើមនោះឯង, គេរមែងញ៉ាំងលោភៈ ឱ្យកើតឡើងក្នុង

---

[១០] សំ. សគា. (សេចក្ដីក្នុងអដ្ឋកថាបាត់ទៅច្រើន) ។

បញ្ចកាមគុណមានរូបជាដើមនោះ; បុគ្គលពួកមួយរមែងក្រោធ រមែងថ្នាំងថ្នាក់, រមែងញ៉ាំងទោសៈឱ្យកើតឡើងក្នុងបញ្ចកាមគុណមានរូបជាដើមនោះ; រូបជាដើមទាំងនោះ រមែងគួរប្រាថ្នា រមែងគួរស្រឡាញ់ រមែងពេញចិត្តដល់មនុស្សពួកខ្លះ, តែមិនជាទីគួរប្រាថ្នា មិនគួរស្រឡាញ់ និងមិនគួរពេញចិត្តដល់មនុស្សពួកខ្លះ; ម្យ៉ាងទៀត មនុស្សពួកខ្លះ រមែងប្រកាន់ដោយចំណែកខាងស្តាំ (ការគោរព) ថា "រូបទាំងនេះ គួរប្រាថ្នា គួរស្រឡាញ់ និងគួរពេញចិត្ត" , តែមួយពួកទៀតប្រកាន់រូបទាំងនោះឯង ដោយចំណែកខាងឆ្វេង (មិនគោរព) ដោយគិតថា "រូបទាំងនេះ មិនគួរប្រាថ្នា មិនគួរស្រឡាញ់ មិនគួរពេញចិត្ត" ព្រោះហេតុដូច្នោះ ឈ្មោះថា រូបដែលជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ដែលទ្រង់ចែកដោយចំពោះ ទើបមិនមាន ។ មែនពិត សូម្បីពួកសត្វជន្លេន ក៏រមែងជាវត្ថុគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្តរបស់ពួក អ្នកបច្ចន្តប្រទេស; តែថា ជាវត្ថុគួរខ្ពើមយ៉ាងក្រៃលែង របស់ពួកអ្នកនៅក្នុងមជ្ឈិមប្រទេស ។ ម្យ៉ាងទៀត សាច់របស់បក្សីក្ងោកជាដើម រមែងជាវត្ថុគួរប្រាថ្នារបស់បុគ្គលអ្នកនៅក្នុងមជ្ឈិមប្រទេសទាំងនោះ, តែជាទីខ្ពើមរអើមរបស់បុគ្គលក្រៅនេះ ។

គប្បីសួរលោកអាចារ្យវិតណ្ឌវាទីនោះថា "ក៏លោកពោលឡើងថា ឈ្មោះថា រូបជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ចែកទុកចំពោះតែម្យ៉ាងមិនមាន" ដូច្នេះ ឬអាចារ្យវិតណ្ឌវាទីនោះ ក៏នឹងពោលថា "មែនហើយ ខ្ញុំពោលថា "មិនមាន" ។ បើបញ្ហាយ៉ាងនោះ មានបីដងទៀត គួរសួរថា "ធម្មតាព្រះនិព្វាន ជាឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍" ដូច្នេះ ។ អាចារ្យវិតណ្ឌវាទី

កាលបើជ្រាបក៏នឹងប្រាប់ថា ឥដ្ឋារម្មណ៍ ។ កាលបើអាចារ្យវិតណ្ឌវាទីនោះ មិនគប្បីតបអាចារ្យសកវាទី ក៏មិនគប្បីប្រាប់, តែព្រះនិព្វានជាឥដ្ឋារម្មណ៍តែម្យ៉ាងគត់; គប្បីពោលតទៅថា ក៏លោកប្រាប់សេចក្ដីនេះថា បុគ្គលពួកមួយ កាលបើមាននរ-ណាៗ ពោលដល់គុណរបស់ព្រះនិព្វានហើយ ក៏សួរទាំងក្រោធថា លោកពោលសរសើរព្រះនិព្វាន ក្នុងព្រះនិព្វាននោះ មានបាយ ទឹក កម្រងផ្កាឈើរបស់ក្រអូបគ្រឿងលាប ទីដេក គ្រឿងស្លៀកដណ្ដប់ មានកាមគុណ ៥ សម្រេចព្រមហើយ ឬកាលបើគេពោលថា មិនមែន ក៏នឹងគប្បីពោលថា កុំឡើយ ដោយព្រះនិព្វានរបស់លោកដូច្នេះ កាលបើបុគ្គលនោះពោលសរសើរព្រះនិព្វានតទៅទៀត ក៏ក្រោកឡើងយកដៃមូលត្រចៀកទាំងពីរដូច្នេះពិតមែនឬ ? ក៏ដោយអំណាចនៃសេចក្ដីនេះនិព្វានក្នុងវាទៈរបស់លោក នឹងឈ្មោះថា ជាអនិដ្ឋារម្មណ៍ក៏ដោយ, សូម្បីយ៉ាងនោះ នរណាៗ ក៏មិនគប្បីកាន់យកនិព្វាននោះថា ជាអនិដ្ឋារម្មណ៍យ៉ាងនោះទេព្រោះបុគ្គលនេះ រមែងសម្ដែងអំពីពាក្យសម្គាល់ដែលវិបរិត្តថា ក៏អារម្មណ៍នោះឯង ជាទីគួរប្រាថ្នាដល់មនុស្សពួកខ្លះ, មិនគួរប្រាថ្នាដល់មនុស្សពួកខ្លះ ដោយសេចក្ដីសម្គាល់វិបល្លាស (សញ្ញាវិបល្លាស) តែអារម្មណ៍គួរប្រាថ្នា និងមិនគួរប្រាថ្នា ដែលព្រះមានព្រះភាគត្រាស់ចែកទុកដោយចំពោះ រមែងមាន ។

**សួរថា** ព្រះអង្គទ្រង់ចែកដោយអំណាចនៃនរណា ?

ឆ្លើយថា ដោយអំណាចនៃសត្វអ្នកជាកណ្ដាល ។

ពិតមែន ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍នេះ ព្រះអង្គទ្រង់មិនបានចែកដោយអំណាចនៃឥស្សរជនអ្នកធំក្រៃលែង ដូចព្រះបាទមហាសម្មតៈ ព្រះបាទមហាសុ-

ទស្សនៈ និងព្រះបាទធម្មាសោកជាដើមឡើយ; ព្រោះថា ពួកជនទាំងនោះ មានអារម្មណ៍ សូម្បីជាទិព្វដែលមិនគួរគាប់ចិត្តប្រាកដ; ទ្រង់ក៏នៅមិនបានចែកដោយអំណាចនៃបុគ្គលអ្នកមានទុក្ខលំបាកយ៉ាងក្រៃលែង ដែលរកបាយ និងទឹកបានដោយលំបាក; ព្រោះជនអ្នកមានទុក្ខលំបាកយ៉ាងក្រៃលែងទាំងនោះ សូម្បីតែបាយចុងអង្ករសល់ សូម្បីរសសាច់ស្អុយ ក៏ជាអាហារយ៉ាងឆ្ងាញ់ក្រៃលែង ដូចនឹងអមតរសដែរ ។ តែព្រះអង្គទ្រង់ចែកដោយអំណាចនៃជនជាន់កណ្តាល, ដូចប្រធានពួកមហាអាមាត្យ សេដ្ឋី កុដុម្ពិក៍ និងឈ្មួញជាដើម គ្រាខ្លះ បាននូវឥដ្ឋារម្មណ៍ គ្រាខ្លះក៏បាននូវអនិដ្ឋារម្មណ៍; ព្រោះថា ជនជាន់កណ្តាលបែបនេះ រមែងអាចដើម្បីកំណត់ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍បាន ។

តែព្រះចូឡាភយត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា ៖

ធម្មតាថា ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍កំណត់បានដោយអំណាចនៃវិបាកប៉ុណ្ណោះ, មិនកំណត់បានដោយអំណាចនៃជវនចិត្តឡើយ; តែជវនចិត្តរមែងរីករាយក្នុងឥដ្ឋារម្មណ៍ រមែងថ្នាំងថ្នាក់ក្នុងឥដ្ឋារម្មណ៍ រមែងរីករាយក្នុងអនិដ្ឋារម្មណ៍ រមែងថ្នាំងថ្នាក់ក្នុងអនិដ្ឋារម្មណ៍នោះឯង ដោយសញ្ញាវិបល្លាស ។ ក៏ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍នេះ រមែងកំណត់ដោយអំណាចនៃវិបាកចំណែកមួយប៉ុណ្ណោះ; ព្រោះថា នរណាៗ មិនអាចបោកបញ្ឆោតកន្លងវិបាកចិត្តបានឡើយ; បើអារម្មណ៍ ជារបស់គួរប្រាថ្នា, កុសលវិបាករមែងកើតឡើង; បើជារបស់ដែលមិនគួរប្រាថ្នា, អកុសលវិបាករមែងកើតឡើង ។ ពិតមែន ពួកមិច្ឆាទិដ្ឋិឃើញព្រះពុទ្ធ ឬព្រះសង្ឃ ឬក៏ឃើញអារម្មណ៍ដ៏ឱឡារិក មានមហាចេតិយជាដើម រមែងបិទភ្នែកចេញ រមែងដល់

ការទោមនស្ស, ឮសម្លេងសម្ដែងធម៌ ក៏រមែងបិទត្រចៀកចេញ ក៏ពិតមែនហើយ; ក៏ប៉ុន្តែថា វិញ្ញាណទាំងឡាយមានចក្ខុវិញ្ញាណ និងសោតវិញ្ញាណជាដើម របស់ពួកមិច្ឆាទិដ្ឋិទាំងនោះ រមែងជាកុសលវិបាកប៉ុណ្ណោះ; សត្វទាំងឡាយ មានសូករៈ (ជ្រូក) ជាដើម បរិភោគលាមក ហិតក្លិនលាមកហើយ ក៏កើតសេចក្ដីពេញចិត្តថា "យើងនឹងបានទំពាស៊ី" ដូច្នេះ ក៏ពិតមែនហើយ, ប៉ុន្តែក្នុងការឃើញលាមក ចក្ខុវិញ្ញាណរបស់វា ក៏ជាអកុសលវិបាកប៉ុណ្ណោះ, ក្នុងការហិតក្លិន ឃានវិញ្ញាណរបស់ វាក៏ជាអកុសលវិបាក, ក្នុងការលិទ្ធរស ជិវ្ហាវិញ្ញាណរបស់វា ក៏ជាអកុសលវិបាកប៉ុណ្ណោះ; សូករៈដែលត្រូវគេចង ឱ្យដេកលើទីដេកដ៏ប្រសើរ រមែងស្រែកខ្លាំង, តែទោមនស្សរបស់វា រមែងកើតក្នុងជវនចិត្តប៉ុណ្ណោះ ដោយសញ្ញាវិបល្លាស កាយវិញ្ញាណរបស់វា រមែងជាកុសលវិបាកមែនពិត ។

**សួរថា** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះភាវៈនៃអារម្មណ៍នោះជាឥដ្ឋារម្មណ៍ ។

ម្យ៉ាងទៀត គប្បីជ្រាបហេតុដែលអារម្មណ៍គួរប្រាថ្នា និងមិនគួរប្រាថ្នាសូម្បីដោយអំណាចទ្វារ ។ ពិតមែន គំនរអាចម៍ដែលដូចជាអាចម៍គោ មានសម្ផស្សជាសុខ ជាអនិដ្ឋារម្មណ៍ក្នុងចក្ខុទ្វារ និងឃានទ្វារ, ជាឥដ្ឋារម្មណ៍ក្នុងកាយទ្វារ; កាលបើព្រះបាទចក្រពត្តិត្រូវគេបៀតបៀនដោយកែវមណី ត្រូវគេធ្វើឱ្យតក់ស្លុត លើកលំពែងមាស និងកែវមណី; ឯលំពែងមាសជាឥដ្ឋារម្មណ៍ក្នុងចក្ខុទ្វារ, ជាអនិដ្ឋារម្មណ៍ក្នុងកាយទ្វារ ។ ព្រោះហេតុអ្វី ? ព្រោះការកើតឡើងនៃទុក្ខធំ ។

ឥដ្ឋារម្មណ៏ និងអនិដ្ឋារម្មណ៏យ៉ាងនេះ រមែងកំណត់ដោយវិបាកប៉ុណ្ណោះដោយចំណែកមួយ ។

ក្នុងពាក្យថា **"តំ តំ វា បន"** បានដល់ ដូច **តំ វា បនកន័យ** [11] នេះ បណ្ឌិតមិនគប្បីសម្លឹងមើលន័យដែលពោលទុកក្នុងពេលមុនទេ ។ ព្រោះក្នុងទីដែលព្រះមានព្រះភាគជាម្ចាស់មិនទ្រង់ចែកអត្ថឱ្យយល់ដោយសម្មតិ [12] , តែទ្រង់ចែកឱ្យយល់ដោយបុគ្គល, ព្រោះហេតុនោះ ដោយអំណាចនៃ **តំតំវាបនកន័យ** នោះឯងទើបព្រះមានព្រះភាគទ្រង់ត្រាស់ហេតុដែលរូបគ្រោតគ្រាត និងរូបប្រណីត ព្រោះអាស្រ័យការប្រៀបធៀបដោយចំពោះបុគ្គល ។

ពិតណាស់ រូបរបស់ពួកសត្វនរក ឈ្មោះថា រូបគ្រោតគ្រាតជាទីបំផុត, ព្រោះប្រៀបធៀបជាមួយរូបរបស់ពួកសត្វនរកនោះ; រូបរបស់នាគ និងសុបណ្ណគ្រុឌក្នុងសត្វតិរច្ឆានទាំងឡាយ ឈ្មោះថា ប្រណីត, រូបរបស់នាគ និងសុបណ្ណទាំងនោះនៅជារូបគ្រោតគ្រាត, ព្រោះប្រៀបជាមួយរូបប្រេតទាំងឡាយ ទើបឈ្មោះថាប្រណីត ។ សូម្បីរូបរបស់ពួកប្រេតទាំងនោះ ក៏នៅតែជារបស់គ្រោតគ្រាត, ព្រោះប្រៀបជាមួយរូបអ្នកជនបទនោះ, រូបរបស់អ្នកជនបទ ទើបឈ្មោះថា **ប្រណីត** ។ សូម្បីរូបរបស់អ្នកនៅជនបទនោះ ជារូបគ្រោតគ្រាត ព្រោះប្រៀបជាមួយរូបមេ

---

[11] សំដៅដល់ន័យដែលពោលសរុបសេចក្ដីចំពោះរឿងនោះៗ ។

[12] ពាក្យថា **សម្មតិ** ក៏គឺបញ្ញត្តិ ដែលទូលំទូលាយ ចែកបុគ្គលដោយចំពោះជាឧបាទានប្បញ្ញត្តិ, ក្នុងព្រះអភិធម្ម ពាក្យថា **បុគ្គល** និងពាក្យថា **សត្វ** ជាវេវចនៈនឹងគ្នា ។

ស្រុក, រូបរបស់មេស្រុកទាំងឡាយ ទើបឈ្មោះថា **ជារូបប្រណីត** ។ សូម្បីរូបពួកមេស្រុកទាំងនោះ ក៏ជារូបគ្រោតគ្រាត ព្រោះប្រៀបជាមួយរូបអភិបាលខេត្ត, រូបរបស់អភិបាលខេត្ត ទើបឈ្មោះថា **ជារូបប្រណីត** ។ សូម្បីរូបរបស់អភិបាលខេត្តទាំងនោះ ក៏នៅជារូបគ្រោតគ្រាត, ព្រោះប្រៀបជាមួយម្ចាស់ប្រទេសរាជ (ស្តេចផែនដី) រូបរបស់ប្រទេសរាជទាំងឡាយ ទើបឈ្មោះថា **ជារូបប្រណីត**។ សូម្បីរូបប្រទេសរាជនោះ ក៏នៅជារូបគ្រោតគ្រាត, ព្រោះប្រៀបជាមួយរូបព្រះបាទចក្រពត្តិ, រូបរបស់ព្រះបាទចក្រពត្តិ ទើបឈ្មោះថា **ជារូបប្រណីត** ។ សូម្បីរូបព្រះបាទចក្រពត្តិនោះ ក៏នៅជារូបគ្រោតគ្រាត, ព្រោះប្រៀបជាមួយរូបរបស់ភូម្មទេវតា, រូបរបស់ភូម្មទេវតា ទើបឈ្មោះថា **ជារូបប្រណីត** ។ សូម្បីរូបរបស់ពួកភូម្មទេវតាទាំងនោះ នៅជារូបគ្រោតគ្រាត, ព្រោះប្រៀបជាមួយរូបស្តេចចាតុម្មហារាជ រូបរបស់ស្តេចចាតុម្មហារាជ ទើបឈ្មោះថា **ជារូបប្រណីត** ។ រូបរបស់ស្តេចចាតុម្មហារាជទាំងនោះ ក៏នៅជារូបគ្រោតគ្រាត, ព្រោះប្រៀបជាមួយរូបពួកទេវតាជាន់តាវតិង្ស រូបរបស់ពួកទេវតាជាន់តាវតិង្ស ទើបឈ្មោះថា **ជារូបប្រណីត** ។ល។ ក៏រូបរបស់ទេវតាអកនិដ្ឋ ទើបឈ្មោះថា **ជារូបប្រណីត** ជាទីបំផុត ៕

## សម្តែងអំពីទូរទុករូបនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃទូរទុករូប (រូបជិត និងឆ្ងាយ) តទៅ ៖

រូបដែលជាឥត្ថិន្ទ្រិយជាដើម ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ចែកទុកក្នុងពេលក្រោយនោះឯង; តែក្នុងទុកៈនេះទ្រង់ត្រាស់នូវ**សុខុមរូប** (រូបល្អិត) ថា **ជា**

**ទូររូប** (រូបឆ្ងាយ) ព្រោះជារូបដែលមានលក្ខណៈយល់បានដោយលំបាក ដោយអត្ថថា កំណត់ជាអារម្មណ៍បានដោយលំបាក, ត្រាស់ឱឡារិករូប (រូបគ្រោតគ្រាត) ថា **ជាសន្តិកេរូប** (រូបជិត) ព្រោះជារូបដែលមានលក្ខណៈយល់បានងាយ ដោយអត្ថថា កំណត់ជាអារម្មណ៍បានងាយ ។ ព្រះមានព្រះភាគជាម្ចាស់ មិនទ្រង់ប្រកបថា "រូបនេះ ហៅថា រូបឆ្ងាយ" សូម្បីក្នុងពេលទ្រង់ប្រកប ដែលមានករំឡឹកាវាហារជាទីបំផុតនោះឯង; ព្រោះហេតុអ្វី ? ព្រោះឈ្មោះថា រូបឆ្ងាយមានពីរយ៉ាង គឺឆ្ងាយដោយលក្ខណៈ និងឆ្ងាយដោយឱកាស ។

ក្នុងរូបឆ្ងាយទាំងពីរយ៉ាងនោះមិនត្រាស់ពាក្យថា **រូបឆ្ងាយទុកដោយលក្ខណៈទេ**; តែត្រាស់រូបឆ្ងាយនោះទុកដោយឱកាស; ព្រោះហេតុនោះ ទើបមិនត្រាស់ទុកថា រូបឆ្ងាយ ព្រោះព្រះមានព្រះភាគមិនបានទ្រង់ប្រាថ្នានឹងសម្តែងឱឡារិករូបថា ជារូបឆ្ងាយដោយឱកាស ទើបត្រាស់ពាក្យមានជាអាទិ៍ថា "**យំ វា បនញ្ញំបិ** = សូម្បីរូបដទៃណាក៏ដោយ" សូម្បីក្នុងនិទ្ទេសនៃសន្តិកបទ ក៏មានន័យដូចគ្នានេះដែរ ។

ក្នុងព្រះបាលីនោះ បទថា **អនាសន្នេ** ចែកបទថា **ន អាសន្នេ** បានដល់ក្នុងទីដែលមិនជិត ។ បទថា **អនុបកដ្ឋេ** = ក្នុងទីមិនជិត ។ បទថា **ទូរេ** = ក្នុងទីឆ្ងាយ, បទថា **អសន្តិកេ** = ក្នុងទីដែលមិនមែនជិត; បទថា "**ឥទំ វុច្ចតេ រូបំ ទូរេ** = នេះហៅថា រូបឆ្ងាយ" នេះ ត្រាស់សុខុមរូប ១៥ យ៉ាង ហៅថា រូបឆ្ងាយ ដោយលក្ខណៈ, តែត្រាស់ឱឡារិករូប ១០ យ៉ាង ហៅថា រូបឆ្ងាយដោយឱកាស ដោយអំណាចនៃវេវចនកន័យ; និទ្ទេសនៃសន្តិកបទមានអត្ថងាយមែនពិត ។

បទថា **“ឥទំ ទុច្ចតិ រូបំ សន្តិកេ** = នេះហៅថារូបជិត” នេះ ត្រាស់ឱឡារិករូប ១០ យ៉ាង ហៅថា រូបជិតដោយលក្ខណៈ, តែត្រាស់សុខុមរូប ១៥ យ៉ាងហៅថា រូបជិតដោយឱកាស ដោយអំណាចនៃយេវាបនកន័យនេះ ។

**សួរថា** ក៏រូបដែលឈ្មោះថា ជិត និងឆ្ងាយ ដោយអំណាចនៃឱកាសតាំងពីត្រឹមណា ?

ឆ្លើយថា សូម្បីបុគ្គលពោយដោយពាក្យសម្ដីប្រក្រតី ១២ ហត្ថ ឈ្មោះថាឧបចារៈ គឺជិតចំពោះការស្ដាប់, រូបខាងក្នុងនៃឧបចារៈ គឺជិតចំពោះការស្ដាប់បទនោះ ឈ្មោះថា **រូបជិត**, លើសពីនោះទៅ ឈ្មោះថា **រូបឆ្ងាយ**; បណ្ដារូបជិត និងរូបឆ្ងាយនោះ **សុខុមរូប** មានក្នុងទីឆ្ងាយសូម្បីដោយលក្ខណៈ ដោយឱកាស; តែសុខុមរូបដែលមាននៅក្នុងទីជិត ឈ្មោះថា ជារូបជិតដោយឱកាសប៉ុណ្ណោះ, មិនឈ្មោះថា រូបជិតដោយលក្ខណៈឡើយ ។ **ឱឡារិករូប**ដែលនៅក្នុងទីជិត ឈ្មោះថាជារូបជិត ដោយលក្ខណៈផង ដោយឱកាសផង ។ ឱឡារិករូបដែលនៅឆ្ងាយ ដោយឱកាសតែម្យ៉ាង, មិនមែនឆ្ងាយដោយលក្ខណៈឡើយ ។

ក្នុងបទថា **តំ តំ វា បន** នោះ មិនគប្បីមើលន័យដែលមាននៅខាងដើមទេ; ព្រោះន័យខាងដើមជាន័យដែលទ្រង់ចែកសម្រេចហើយ; តែក្នុងទីនេះ ទ្រង់មិនបានចែករូបឆ្ងាយដោយលក្ខណៈទេ ទ្រង់ចែករូបឆ្ងាយដោយឱកាសតែម្យ៉ាង; ព្រោះទ្រង់សម្ដែងរូបឆ្ងាយ និងរូបជិតដោយការប្រៀបធៀបគ្នា ក្នុងខន្ធវិភង្គ-និទ្ទេសនេះ ។

ពិតណាស់ រូបរបស់ខ្លួនឈ្មោះថា **រូបជិត**, រូបរបស់អ្នកដទៃសូម្បីកើតខាងក្នុងផ្ទៃ ក៏ឈ្មោះថា **រូបឆ្ងាយ** ។ រូបរបស់អ្នកកើតក្នុងផ្ទៃ ក៏ឈ្មោះថា **រូបជិត**, រូបរបស់បុគ្គលដទៃដែលឈរនៅខាងក្រៅឧបចារៈ ឈ្មោះថា **រូបឆ្ងាយ** ។ រូបរបស់បុគ្គលដទៃ ដែលដេកលើគ្រែជាមួយគ្នា ឈ្មោះថា **រូបជិត**, រូបរបស់បុគ្គលដេកនៅខាងក្រៅ ឈ្មោះថា **រូបឆ្ងាយ**; រូបក្នុងបរិវេណ ឈ្មោះថា **រូបជិត**, រូបខាងក្រៅបរិវេណ ឈ្មោះថា **រូបឆ្ងាយ**, រូបខាងក្នុងសង្ឃារាម ឈ្មោះថា **រូបជិត**, រូបខាងក្រៅសង្ឃារាម ឈ្មោះថា **រូបឆ្ងាយ** ។ រូបខាងក្នុងសីមា ឈ្មោះថា **រូបជិត**, រូបខាងក្រៅសីមា ឈ្មោះថា **រូបឆ្ងាយ**; រូបខាងក្នុងស្រុក និងខេត្តក្រុង ឈ្មោះថា **រូបជិត**, រូបដែលនៅខាងក្រៅស្រុក និងខេត្តក្រុងឈ្មោះថា **រូបឆ្ងាយ** ។ រូបខាងក្នុងជនបទ ឈ្មោះថា **រូបជិត**, រូបខាងក្រៅជនបទ ឈ្មោះថា **រូបឆ្ងាយ** ។ រូបខាងក្នុងសមុទ្រ ឈ្មោះថា **រូបជិត**, រូបខាងក្រៅសមុទ្រ ឈ្មោះថា **រូបឆ្ងាយ** ។ រូបខាងក្នុងចក្រវាឡ ឈ្មោះថា **រូបជិត**, រូបខាងក្រៅចក្រវាឡ ឈ្មោះថា **រូបឆ្ងាយ** ៕

**(នេះជារូបខន្ធនិទ្ទេស)**

## ២. វេទនាខន្ធនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសនៃវេទនាខន្ធជាដើមតទៅ ៖

ខ្ញុំវៀរបទដូចដែលពោលទុករួចក្នុងគ្រាក្រោយ ហើយពណ៌នាចំពោះបទដែលមិនទាន់បានពណ៌នាប៉ុណ្ណោះ ។

បទថា **“យា កាចិ វេទនា** = វេទនាយ៉ាងណានីមួយ” បានដល់ ទ្រង់កាន់យកវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **សុខវេទនា** ជាដើម ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុក ដើម្បីសម្ដែងវេទនាដែលអធិប្បាយទុកដោយអំណាចនៃវេទនាអតីតៈជាដើម ដោយសភាវៈ ។

បណ្ដាវេទនាទាំងឡាយ មានសុខវេទនាជាដើមនោះ សុខវេទនាផ្លូវកាយ និងសុខវេទនាផ្លូវចិត្តមាន; ទុក្ខវេទនាផ្លូវកាយ និងទុក្ខវេទនាផ្លូវចិត្ត ក៏មានដូចគ្នា។ ឯអទុក្ខមសុខវេទនាដែលត្រាស់ថា ប្រព្រឹត្តទៅក្នុងផ្លូវកាយដោយបរិយាយ សំដៅដល់កាយ គឺប្រសាទមានចក្ខុប្រសាទជាដើមក៏មាន, ប្រព្រឹត្តទៅក្នុងផ្លូវចិត្តក៏មាន ។ បណ្ដាវេទនាទាំងនោះ វេទនាដែលប្រព្រឹត្តទៅក្នុងផ្លូវកាយ សូម្បីទាំងអស់ជាកាមាវចរ, ទុក្ខវេទនាផ្លូវចិត្ត ក៏ជាកាមាវចរដូចគ្នា; តែសុខវេទនាដែលប្រកបដោយចិត្តប្រព្រឹត្តទៅក្នុងភូមិ ៣; អទុក្ខមសុខវេទនាប្រព្រឹត្តទៅក្នុងភូមិ ៤; គប្បីជ្រាបការណ៍ដែលវេទនា សូម្បីមានប្រការទាំងអស់នោះ ជាអតីតៈជាដើម ដោយអំណាចនៃសន្តតិ និងដោយអំណាចនៃខណៈជាដើម ។

បណ្ដាវេទនាទាំងនោះ **សម្ដែងអំពីអំណាចសន្តតិ** វេទនាដែលរាប់បញ្ចូលក្នុងវីថិតែមួយជាមួយគ្នា ក្នុងជវ៉នតែមួយជាមួយគ្នា ក្នុងសមាបត្តិតែមួយជាមួយគ្នា និងប្រព្រឹត្តទៅដោយការប្រកបក្នុងអារម្មណ៏តែមួយជាមួយគ្នា ឈ្មោះថា **វេទនាបច្ចុប្បន្ន**, វេទនាមុនបច្ចុប្បន្ន ឈ្មោះថា **វេទនាអតីតៈ**, វេទនាក្រោយបច្ចុប្បន្ន ឈ្មោះថា **វេទនាអនាគត** ។ **សម្ដែងអំពីអំណាចនៃខណៈជាដើម** វេទនាដែលរាប់បញ្ចូលដោយខណៈទាំង ៣ គឺ វេទនាដែលជាកណ្ដាល ខាងដើម និងខាងចុង ដែលកំពុងធ្វើកិច្ច

របស់ខ្លួន ឈ្មោះថា **វេទនាបច្ចុប្បន្ន**, វេទនាមុននោះ ឈ្មោះថា **វេទនាអតីតៈ**, វេទនាក្រោយបច្ចុប្បន្ននោះ ឈ្មោះថា **វេទនាអនាគត** ។ ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់នាំនិទ្ទេសនេះមក ព្រោះសំដៅយកវេទនាអតីតៈជាដើម ដោយអំណាចនៃខណៈជាដើម ៕

## សម្តែងអំពីនិទ្ទេសនៃវេទនាគ្រោតគ្រាត និង ល្អិត

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃវេទនាគ្រោតគ្រាត និងល្អិតតទៅ ៖

បទថា "**អកុសលា វេទនា** = អកុសលវេទនា" ជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីទ្រង់សម្តែងវេទនាគ្រោតគ្រាត និងល្អិតដោយជាតិ ។

បទថា "**ទុក្ខវេទនា ឱឡារិកា** = ទុក្ខវេទនាដែលគ្រោតគ្រាត" ជាដើម ត្រាស់ដើម្បីទ្រង់សម្តែងវេទនាគ្រោតគ្រាត និងល្អិតដោយសភាវៈ ។

បទថា "**អសមាបន្នស្ស វេទនា** = វេទនារបស់អ្នកមិនចូលសមាបត្តិ" ជាដើម ត្រាស់ដើម្បីទ្រង់សម្តែងវេទនាគ្រោតគ្រាត និងល្អិតដោយបុគ្គល ។

បទថា "**សាសវា** = វេទនាដែលមានអាសវៈ" ជាដើម ត្រាស់ដើម្បីទ្រង់សម្តែងវេទនាគ្រោតគ្រាត និងល្អិតដោយលោកិយ និងលោកុត្តរ ។

បណ្តាវេទនាទាំងនោះ **អកុសលវេទនាជាមុនសិន** ឈ្មោះថា **ជាវេទនាគ្រោត-គ្រាត ដោយអត្ថថា លំបាកចិត្ត និងដោយអត្ថថា មានទុក្ខជាវិបាក**, **វេទនាដែលជាកុសល** ឈ្មោះថា **វេទនាល្អិត** ដោយអត្ថថា មិនមានការខ្វល់ខ្វាយ និងដោយអត្ថថា មានសេចក្តីសុខជាវិបាក, **វេទនាដែលជាអព្យាកតៈ** ឈ្មោះថា **វេទនាល្អិត** ដោយអត្ថថា

មិនមានសេចក្តីឧស្សាហ៍ និងដោយអត្ថថា មិនមានវិបាក ។ វេទនាដែលជាកុសល និងវេទនាដែលជាអកុសល ឈ្មោះថា **វេទនាគ្រោតគ្រាត** ដោយអត្ថថា មានឧស្សាហ៍ និងដោយអត្ថថា មានវិបាក ។ វេទនាដែលជាអព្យាកតៈ ឈ្មោះថា **វេទនាល្អិត** ដោយន័យដែលពោលហើយនោះឯង ។

**ទុក្ខវេទនា** ឈ្មោះថា វេទនាគ្រោតគ្រាត ដោយអត្ថថា មិនមានសេចក្តីត្រេកអរ និងដោយអត្ថថាជាទុក្ខ, សុខវេទនា ឈ្មោះថា **វេទនាល្អិត** ដោយអត្ថថា មានសេចក្តីត្រេកអរ និងដោយអត្ថថាជាសុខ, **អទុក្ខមសុខវេទនា** ឈ្មោះថា **វេទនាល្អិត** ដោយអត្ថថា **ស្ងប់** និងដោយអត្ថថា **ប្រណីត**។ **សុខវេទនា** និង**ទុក្ខវេទនា** ឈ្មោះថា វេទនាគ្រោតគ្រាត ដោយអត្ថថា ញាប់ញ័រ និងដោយអត្ថថា ផ្សាយចេញទៅ ។ ពិតណាស់ សូម្បីសុខវេទនាក៏រមែងញាប់ញ័រ រមែងផ្សាយចេញទៅ, សូម្បីទុក្ខវេទនាក៏ដូចគ្នា; ព្រោះសុខវេទនាកាលកើត រមែងញុំាងសរីរៈទាំងអស់ ឱ្យញាប់-ញ័រ ឱ្យរំភើប ឱ្យស្រស់ស្រាយ ឱ្យរីករាយ ឱ្យត្រេកអរ ទើបកើតឡើង ដូចស្រោចទឹកដោយឆ្នាំងទឹកត្រជាក់ ។ ទុក្ខវេទនាកាលកើតឡើង រមែងដូចជាវេលាដែលដាក់ភាជនៈក្តៅទុកខាងក្នុង និងដូចយកគុកភ្លើងស្មៅដុតនៅខាងក្រៅ ទើបកើតឡើង ។ តែអទុក្ខមសុខវេទនា ឈ្មោះថា វេទនាល្អិត ដោយន័យដែលពោលមកហើយ ។

វេទនារបស់បុគ្គលមិនចូលសមាបត្តិ ឈ្មោះថា **វេទនាគ្រោតគ្រាត** ព្រោះការណ៍ដែលបុគ្គលនោះ មានចិត្តរវើរវាយទៅកាន់អារម្មណ៍ផ្សេង, វេទនារបស់បុគ្គលអ្នកចូលសមាបត្តិ ឈ្មោះថា **វេទនាល្អិត** ព្រោះបុគ្គលនោះ ប្រព្រឹត្តទៅក្នុងនិមិត្តមានអារម្មណ៍តែម្យ៉ាង ។ វេទនាមានអាសវៈ ឈ្មោះថា **វេទនាគ្រោតគ្រាត**

ព្រោះការកើតឡើងនៃអាសវៈជាហេតុ; ក៏ឈ្មោះថា វារៈនៃអាសវៈ រមែងមានសភាពគ្រោតគ្រាតតែម្យ៉ាង ។ វេទនាមិនមានអាសវៈ ឈ្មោះថា **វេទនាល្អិត** ដោយបរិយាយផ្ទុយគ្នាជាមួយពាក្យដែលពោលមកហើយ ៕

## សម្តែងអំពីមតិរបស់អាចារ្យ

បណ្តាវេទនាគ្រោតគ្រាត និងល្អិតទាំងនោះ អាចារ្យមួយរូបមិនឈ្លាសក្នុងកុសលត្តិកៈ, មិនឈ្លាសក្នុងវេទនាតិកៈ, អាចារ្យនោះប្រាថ្នានឹងរក្សាកុសលត្តិកៈ រមែងទម្លាយវេទនាតិកៈ, ប្រាថ្នានឹងរក្សាវេទនាតិកៈ រមែងទម្លាយកុសលត្តិកៈ ។ អាចារ្យមួយរូបប្រាថ្នានឹងរក្សាតិកៈ រមែងទម្លាយធម្មភូមិដទៃ, អាចារ្យមួយរូប រមែងមិនទម្លាយ តើយ៉ាងណា ? ក៏ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកក្នុងវេទនាតិកៈថា "សុខវេទនា និងទុក្ខវេទនា ជាវេទនាគ្រោតគ្រាត, អទុក្ខមសុខវេទនា ជាវេទនាល្អិត" ដូច្នេះ, ព្រះតម្រាស់នោះ អាចារ្យមួយរូបរមែងជំទាស់ថា អទុក្ខមសុខ-វេទនាទាំងអស់ មិនមែនជាវេទនាល្អិត ព្រោះថា អទុក្ខមសុខវេទនានោះជាកុសលក៏មាន, ជាអកុសលក៏មាន, ជាអព្យាកតៈក៏មាន; បណ្តាអទុក្ខមសុខវេទនាទាំង ៣ ប្រភេទនោះ វេទនាដែលជាកុសល និងអកុសលជាវេទនាគ្រោតគ្រាត, វេទនាជាអព្យាក្រឹត ជាវេទនាល្អិត, ព្រោះហេតុអ្វី ? ព្រោះហេតុដែលវេទនានោះមានមកក្នុងព្រះបាលីពួកកុសលត្តិកៈ ដោយអាការៈយ៉ាងនេះ អាចារ្យនោះ ឈ្មោះថារក្សាកុសលត្តិកៈ, តែទម្លាយវេទនាតិកៈ ។

សូម្បីព្រះតម្រាស់ដែលត្រាស់ទុកក្នុងកុសលត្តិកៈថា "កុសលវេទនា និងអកុសលវេទនា ឈ្មោះថា **វេទនាគ្រោតគ្រាត,** អព្យាកតវេទនា ឈ្មោះថា វេទនាល្អិត" ដូច្នេះ, ព្រះតម្រាស់នោះ អាចារ្យមួយរូបជំទាស់ថា អព្យាកតៈទាំងអស់មិនមែនវេទនាល្អិតទេ; ព្រោះថា អព្យាកតវេទនានោះ ជាសុខវេទនាក៏មាន, ជាទុក្ខក៏មាន, មិនទុក្ខ មិនសុខក៏មាន ។ បណ្ដាអព្យាកតវេទនាទាំង ៣ ប្រភេទនោះ អព្យាកតវេទនាដែលជាសុខ និងជាទុក្ខ **ជាវេទនាគ្រោតគ្រាត,** អព្យាកតៈដែលជាអទុក្ខមសុខ ជាវេទនាល្អិត; ព្រោះហេតុអ្វី ? ព្រោះហេតុដែលអព្យាកតវេទនានោះមានមកក្នុងព្រះបាលីក្នុងវេទនាត្តិកៈ; ដោយអាការយ៉ាងនេះ វេទនាត្តិកៈជាការណ៍ដែលអាចារ្យរក្សាហើយ, តែទម្លាយកុសលត្តិកៈ ។

ក៏អាចារ្យអ្នកមិនពិចារណាមើលវេទនាត្តិកៈ ក្នុងទីនៃកុសលត្តិកៈដែលមានមកហើយ មិនក្រឡេកមើលកុសលត្តិកៈក្នុងទីនៃវេទនាត្តិកៈដែលមានមក ហើយពោលថា វេទនាគ្រោតគ្រាត និងវេទនាល្អិត ដោយលក្ខណៈនៃកុសលត្តិកៈរបស់ធម៌មានកុសលជាដើម ដោយលក្ខណៈនៃវេទនាត្តិកៈរបស់វេទនា មានសុខវេទនាជា-ដើម ឈ្មោះថា រមែងមិនទម្លាយ ។

ម្យ៉ាងទៀត ក្នុងព្រះតម្រាស់ដែលត្រាស់ក្នុងកុសលត្តិកៈថា "វេទនាដែលជាកុសល និងអកុសលជាវេទនាគ្រោតគ្រាត, អព្យាកតវេទនាជាវេទនាល្អិត" ដូច្នេះ ។ ព្រោះហេតុនោះឯង អាចារ្យពួកមួយរមែងពោលថា "វេទនាដែលជាកុសល សូម្បីជាលោកុត្តរវេទនា ក៏ឈ្មោះថា **វេទនាគ្រោតគ្រាត,** វេទនាជាវិបាកដោយហោចទៅ សូម្បីវេទនាដែលកើតព្រមជាមួយគ្នានឹងទ្វិបញ្ចវិញ្ញាណ ក៏ឈ្មោះ

ថា **វេទនាល្អិតដែរ"** ។ អាចារ្យនោះធ្វើលោកុត្តរវេទនាដែលស្ងប់ប្រណីតបែបនេះ ឱ្យឈ្មោះថា **វេទនាគ្រោតគ្រាត,** ធ្វើនូវវេទនាដែលសម្បយុត្តដោយទ្វិបញ្ចវិញ្ញាណ ដែលជាអហេតុកៈ ដែលថោកទាបអន់ថយ ឱ្យឈ្មោះថា **វេទនាល្អិត** ប្រាថ្នានឹងរក្សាតិកៈ ដូច្នេះ ឈ្មោះថា **រមែងទម្លាយធម៌ភូមិដទៃ** ។ តែអាចារ្យអ្នកពោលប្រកបដោយកុសល ក្នុងភូមិនោះៗ និងដោយវិបាកក្នុងភូមិនោះ ឈ្មោះថា **រមែងមិនទម្លាយ** ។

បណ្ដាន័យទាំងនោះ មានន័យដែលគប្បីជ្រាបដូចតទៅ ៖

ពិតណាស់ អាចារ្យពោលដោយទំនងនេះថា ក៏វេទនាដែលជាកាមាវចរកុសល ជាវេទនាគ្រោតគ្រាត, វេទនាដែលជាកាមាវចរវិបាក **ជាវេទនាល្អិត**; វេទនាដែលជារូបាវចរ អរូបាវចរ និងលោកុត្តរកុសល **ជាវេទនាគ្រោតគ្រាត,** វេទនាដែលជារូបាវចរ អរូបាវចរ និងលោកុត្តរវិបាក **ជាវេទនាល្អិត,** ឈ្មោះថា រមែងមិនទម្លាយ ។

**តែព្រះចូឡនាគត្ថេរ** អ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា "ក្នុងអកុសលមិនគួរយកឈ្មោះវេទនាថា **គ្រោតគ្រាត និងល្អិតទេ**; ព្រោះអកុសលនោះ មានសភាពគ្រោតគ្រាតដោយចំណែកមួយប៉ុណ្ណោះ; សូម្បីក្នុងលោកុត្តរ ក៏មិនគួរកាន់យកសេចក្ដីថា វេទនានោះ ជាវេទនាគ្រោតគ្រាត និងល្អិត; ព្រោះលោកុត្តរនោះ មានសភាពល្អិតតែម្យ៉ាង" ដូច្នេះ ។ ពួកអន្តេវាសិកបាននាំពាក្យនេះ មកប្រាប់ដល់ព្រះចូឡាភយត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដកថា "ព្រះថេរៈលោកពោលយ៉ាងនេះ" ។

**ចំណែកព្រះចូឡាភយត្ថេរ** អ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា ព្រះសម្មាសម្ពុទ្ធត្រាស់ព្រះអភិធម្មទុកក្នុងឋានៈ ដែលមានមករបស់បទមួយក្ដី ពីរក្ដី ឈ្មោះថា

មិនបានទ្រង់ប្រទានន័យក្នុងឋានៈដែលគួរប្រទាន រមែងមិនមាន, ឈ្មោះថា មិនទ្រង់ធ្វើន័យក្នុងឋានៈដែលគួរធ្វើក៏មិនមាន; តែភិក្ខុរូបខ្លះក្នុងព្រះធម្មវិន័យនេះចេះតែព្រាច់និយាយថា "ខ្ញុំជាអាចារ្យ" កាលនឹងលើកវេទនាក្នុងកុសល ជាវេទនាគ្រោតគ្រាត និងល្អិតឡើងក៏រង្កៀស; តែព្រះសម្មាសម្ពុទ្ធទ្រង់លើកវេទនាទាំងនោះជាវេទនាគ្រោតគ្រាត និងល្អិតឡើង សូម្បីក្នុងលោកុត្តរដូច្នេះ, ក៏ឯគ្រាពោលយ៉ាងនេះហើយ ទើបលើកយកព្រះសូត្រនេះមកពោលថា "បពិត្រព្រះអង្គដ៏ចម្រើន ក្នុងបដិបទាទាំង ៤ នេះ ជាបដិបទាប្រតិបត្តិលំបាក ត្រាស់ដឹងយឺត នេះហៅថាបដិបទាអាក្រក់ ដោយហេតុទាំងពីរមែនពិត គឺព្រោះសេចក្តីលំបាក និងព្រោះត្រាស់ដឹងយឺត" ដូច្នេះ [១៣] ។ តាមពិត ក្នុងព្រះសូត្រនេះ ត្រាស់បដិបទា ៤ ទុកជាបដិបទាលាយគ្នា ទាំងលោកិយ ទាំងលោកុត្តរ ។

ក្នុងបទថា **តំ តំ វា បន** នេះ មិនគប្បីសម្លឹងដល់ន័យខាងដើម, បណ្ឌិតគប្បីពោលដោយអំណាចនៃ **តំតំវាបនកន័យ** ប៉ុណ្ណោះ ។

ពិតណាស់ វេទនាដែលជាអកុសលមាន ២ យ៉ាង គឺវេទនាដែលកើតព្រមជាមួយលោភៈ និងវេទនាដែលកើតព្រមជាមួយទោសៈ; ក្នុងវេទនាទាំង ២ នោះ វេទនាដែលកើតព្រមជាមួយទោសៈ ជាវេទនាគ្រោតគ្រាត, ដែលកើតព្រមជាមួយលោភៈ ជាវេទនាល្អិត; សូម្បីវេទនាដែលកើតព្រមជាមួយទោសៈ ក៏មាន ២ យ៉ាងដែរ គឺអនិយតវេទនា និងនិយតវេទនា ។ បណ្តាវេទនាទាំង ២ នេះ និយតវេទនា

---

[១៣] ទី. បា. ។

ជាវេទនាគ្រោតគ្រាត, អនិយតវេទនា ជាវេទនាល្អិត; ម្យ៉ាងទៀត អនិយតវេទនា គឺវេទនាដែលតាំងនៅរហូតកប្ប ជាវេទនាគ្រោតគ្រាត, អនិយតវេទនាមិនតាំងនៅរហូតកប្ប ជាវេទនាល្អិត ។ សូម្បីវេទនាដែលតាំងនៅរហូតកប្ប បើជាអសង្ខារិក ក៏ជាវេទនាគ្រោតគ្រាត, បើជាសសង្ខារិក ក៏ជាវេទនាល្អិត ។

សូម្បីវេទនាដែលកើតព្រមជាមួយលោភៈក៏មាន ២ យ៉ាង គឺ ទិដ្ឋិគតសម្បយុត្ត និងទិដ្ឋិគតវិប្បយុត្ត, ក្នុងវេទនាទាំង ២ នោះ វេទនាដែលប្រកបដោយសេចក្តីយល់ឃើញខុស ជាវេទនាគ្រោតគ្រាត, វេទនាដែលមិនប្រកបដោយសេចក្តីយល់ឃើញខុស ជាវេទនាល្អិត; សូម្បីវេទនាដែលប្រកបដោយសេចក្តីយល់ឃើញខុស បើជានិយតៈ ក៏ជាវេទនាគ្រោតគ្រាត, បើជាអនិយតៈ ក៏ជាវេទនាល្អិត; សូម្បីវេទនាដែលប្រកបដោយ សេចក្តីយល់ឃើញខុសនោះ បើជាអសង្ខារិក ក៏ជាវេទនាគ្រោតគ្រាត, បើជាសសង្ខារិក ក៏ជាវេទនាល្អិត ។ ពោលដោយបំប្រួញ វេទនាណាដល់អកុសល ហើយឱ្យវិបាកច្រើន, វេទនានោះ ជាវេទនាគ្រោតគ្រាត, ដែលឱ្យវិបាកតិច ជាវេទនាល្អិត; ចំណែកវេទនាដែលជាកុសលហើយ ឱ្យវិបាកតិច ជាវេទនាគ្រោតគ្រាត, ដែលឱ្យវិបាកច្រើន ជាវេទនាល្អិត ។

ក្នុងកុសល ៤ យ៉ាង វេទនាដែលជាកាមាវចរកុសល ជាវេទនាគ្រោតគ្រាត, វេទនាដែលជារូបាវចរកុសល ជាវេទនាល្អិត; សូម្បីវេទនាដែលជារូបាវចរកុសលនោះ ក៏ជាវេទនាគ្រោតគ្រាត, វេទនាដែលជាអរូបាវចរកុសល ជាវេទនាល្អិត ។ សូម្បីវេទនាដែលជាអរូបាវចរកុសល ជាវេទនាគ្រោតគ្រាត, វេទនាដែល ជាលោកុត្តរ ជាវេទនាល្អិត ។ នេះជាន័យដែលមិនផ្សេងគ្នា ក្នុងភូមិទាំង ៤ មែនពិត ។

**តែពោលដោយន័យដែលផ្សេងគ្នា** វេទនាដែលជាកាមាវចរមាន ៣ យ៉ាង គឺ **ដោយអំណាចនៃទានមយៈ, សីលមយៈ និងភាវនាមយៈ** ។

បណ្ដាវេទនាទាំង ៣ នោះ វេទនាសម្រេចដោយការឱ្យទាន ជាវេទនាគ្រោតគ្រាត, វេទនាដែលសម្រេចដោយការរក្សាសីល ជាវេទនាល្អិត ។ សូម្បីវេទនាដែលសម្រេចដោយការរក្សាសីលនោះ ក៏នៅជាវេទនាគ្រោតគ្រាត, វេទនាដែលសម្រេចដោយភាវនានោះ ជាវេទនាល្អិត; សូម្បីវេទនាដែលសម្រេចដោយភាវនានោះ ក៏មាន ២ យ៉ាង គឺ ជាទុហេតុកៈ (ប្រកបដោយហេតុ ២) និងតិហេតុកៈ (ប្រកបដោយហេតុ ៣); ក្នុងវេទនា ២ យ៉ាងនោះ វេទនាដែលប្រកបដោយហេតុ ២ ជាវេទនាគ្រោតគ្រាត វេទនាដែលប្រកបដោយហេតុ ៣ ជាវេទនាល្អិត; សូម្បីវេទនាដែលប្រកប ដោយហេតុ ៣ ក៏មាន ២ យ៉ាង គឺជាសសង្ខារិក និងអសង្ខារិក ។ បណ្ដាវេទនាទាំង ២ នោះ វេទនាដែលជាសសង្ខារិក ជាវេទនាគ្រោតគ្រាត, ដែលជាអសង្ខារិក ជាវេទនាល្អិត ។ ក្នុងរូបាវចរ វេទនាដែលកើតព្រមជាមួយកុសលក្នុងបឋមជ្ឈាន ជាវេទនាគ្រោតគ្រាត, វេទនាដែលកើតព្រមជាមួយកុសលក្នុងទុតិយជ្ឈាន ។ល។ វេទនាដែលកើតព្រមជាមួយកុសលក្នុងចតុត្ថជ្ឈាន ជាវេទនាល្អិត; វេទនាដែលកើតព្រមជាមួយកុសល សូម្បីក្នុងចតុត្ថជ្ឈាននោះ ក៏នៅជាវេទនាគ្រោតគ្រាត, វេទនាដែលកើតព្រមជាមួយកុសលក្នុងអាកាសានញ្ចាយតនៈ ជាវេទនាល្អិត, វេទនាដែលកើតព្រមជាមួយកុសលក្នុងអាកាសានញ្ចាយតនៈនោះ ក៏នៅជាវេទនាគ្រោតគ្រាត ។ល។ វេទនាដែលកើតព្រមជាមួយកុសល សូម្បីក្នុងនេវសញ្ញានាសញ្ញាយតនៈ ជាវេទនាល្អិត ។

វេទនាដែលកើតព្រមជាមួយកុសល សូម្បីក្នុងនេវសញ្ញានាសញ្ញាយតនៈនោះ ក៏នៅជាវេទនាគ្រោតគ្រាត, វេទនាដែលកើតព្រមជាមួយវិបស្សនា ជាវេទនាល្អិត; សូម្បីវេទនាដែលកើតព្រមជាមួយវិបស្សនានោះ ក៏នៅជាវេទនាគ្រោតគ្រាត, វេទនាដែលកើតព្រមជាមួយសោតាបត្តិមគ្គ ជាវេទនាល្អិត; សូម្បីវេទនាដែលកើតព្រមជាមួយសោតាបត្តិមគ្គនោះ ក៏នៅជាវេទនាគ្រោតគ្រាត ។ល។ វេទនាដែលកើតព្រមជាមួយអរហត្តមគ្គ ជាវេទនាល្អិត ។

ក្នុងវិបាក ៤ យ៉ាងនោះ វេទនាដែលជាកាមាវចរវិបាក ជាវេទនាគ្រោតគ្រាត, វេទនាដែលជារូបាវចរវិបាក ជាវេទនាល្អិត; សូម្បីវេទនាដែលជារូបាវចរវិបាកនោះ ក៏នៅជាវេទនាគ្រោតគ្រាត ។ល។ វេទនាដែលជាលោកុត្តរវិបាក ជាវេទនាល្អិត ។ នេះជាន័យដែលមិនផ្សេងគ្នាជាមុនសិន ។

**តែបើពោលដោយន័យដែលផ្សេងគ្នា** វេទនាដែលជាកាមាវចរវិបាក ជាអហេតុកៈ (មិនប្រកបដោយហេតុ) ក៏មាន, ដែលជាសហេតុកៈ (ប្រកបដោយហេតុ) ក៏មាន; សូម្បីវេទនាដែលជាសហេតុកៈ ក៏មាន ២ គឺ វេទនាដែលជាទុហេតុកៈ (ប្រកបដោយហេតុ ២) ក៏មាន, ដែលជាតិហេតុកៈ (ប្រកបដោយហេតុ ៣) ក៏មាន ។

បណ្ដាវេទនាទាំងនោះ វេទនាដែលជាអហេតុកៈ ជាវេទនាគ្រោតគ្រាត, ដែលជាសហេតុកៈជាវេទនាល្អិត ។ សូម្បីវេទនាដែលជាសហេតុកៈនោះ ដែលជាទុហេតុកៈ ជាវេទនាគ្រោតគ្រាត, ដែលជាតិហេតុកៈជាវេទនាល្អិត ។ សូម្បីក្នុងវេទនាដែលជាតិហេតុកៈនោះ វេទនាដែលជាសសង្ខារិក ជាវេទនាគ្រោតគ្រាត,

ដែលជាអសង្ខារិក ជាវេទនាល្អិត; វេទនាដែលជាវិបាករបស់បឋមជ្ឈាន ជាវេទនាគ្រោតគ្រាត, វេទនាដែលជាវិបាករបស់ទុតិយជ្ឈាន ជាវេទនាល្អិត ។ល។ វេទនាដែលជាវិបាករបស់ចតុត្ថជ្ឈាន ជាវេទនាល្អិត ។ សូម្បីវេទនាដែលជាវិបាករបស់ចតុត្ថជ្ឈាននោះ ក៏នៅជាវេទនាគ្រោតគ្រាត, វេទនាដែលជាវិបាករបស់អាកាសានញ្ចាយតនៈ ជាវេទនាល្អិត; សូម្បីវេទនាដែលជាវិបាករបស់អាកាសានញ្ចាយតនៈនោះ ក៏នៅតែគ្រោតគ្រាត ។ល។ សូម្បីវេទនាដែលជាវិបាករបស់នេវសញ្ញានាសញ្ញាយតនៈនោះ ក៏នៅជាវេទនាគ្រោតគ្រាត, វេទនាដែលកើតព្រមជាមួយសោតាបត្តិផល ជាវេទនាល្អិត; សូម្បីវេទនាដែលកើតព្រមជាមួយសោតាបត្តិផលនោះ ក៏នៅជាវេទនាគ្រោតគ្រាត, វេទនាដែលកើតព្រមជាមួយសកទាគាមិផល ។ល។ វេទនាដែលកើតព្រមជាមួយអរហត្តផលជាវេទនាល្អិត ។

ក្នុងបណ្ដាកិរិយាទាំង ៣ ភូមិ វេទនាដែលជាកិរិយាក្នុងកាមាវចរ ជាវេទនាគ្រោតគ្រាត, វេទនាដែលជាកិរិយាក្នុងរូបាវចរ ជាវេទនាល្អិត; សូម្បីវេទនាដែលជាកិរិយាក្នុងរូបាវចរនោះ ក៏នៅតែគ្រោតគ្រាត, វេទនាដែលជាកិរិយាក្នុងអរូបាវចរ ជាវេទនាល្អិត ។ នេះជាន័យដែលមិនផ្សេងគ្នាជាមុនសិន ។

**តែបើពោលដោយន័យដែលផ្សេងគ្នា** ក្នុងកាមាវចរកិរិយា ដែលទ្រង់ចែកទុកដោយអំណាចវេទនាដែលជាអហេតុកៈជាដើម វេទនាដែលជាអហេតុកកិរិយា ជាវេទនាគ្រោតគ្រាត, ដែលជាសហេតុកកិរិយា ជាវេទនាល្អិត; សូម្បីវេទនាដែលជាទុហេតុកកិរិយានោះ ក៏នៅជាវេទនាគ្រោតគ្រាត, វេទនាដែលជាតិហេតុកកិរិយា ជាវេទនាល្អិត ។ សូម្បីក្នុងវេទនាដែលជាតិហេតុកកិរិយានោះ វេទនាដែលជាស-

សង្ខារិក ជាវេទនាគ្រោតគ្រាត, ដែលជាអសង្ខារិក ជាវេទនាល្អិត ។ វេទនាដែលជាកិរិយា ក្នុងបឋមជ្ឈាន ជាវេទនាគ្រោតគ្រាត, វេទនាដែលជាកិរិយាក្នុងទុតិយ-ជ្ឈាន ជាវេទនាល្អិត ។ សូម្បីវេទនាដែលជាកិរិយាក្នុងទុតិយជ្ឈាននោះ ក៏នៅជាវេទនា គ្រោតគ្រាត, វេទនាដែលជាកិរិយាក្នុងតតិយជ្ឈាន ។ល។ វេទនាដែលជាកិរិយា ក្នុងចតុត្ថជ្ឈាន ជាវេទនាល្អិត ។ សូម្បីវេទនាដែលជាកិរិយាក្នុងចតុត្ថជ្ឈាននោះ ក៏នៅជាវេទនាគ្រោតគ្រាត, វេទនាដែលជាកិរិយាក្នុងអាកាសានញ្ចាយតនៈជាវេទនាល្អិត; សូម្បីវេទនាដែលជាកិរិយា ក្នុងអាកាសានញ្ចាយតនៈនោះ ក៏នៅតែគ្រោតគ្រាត, វេទនាដែលជាកិរិយាក្នុងវិញ្ញាណញ្ចាយតនៈ ។ល។ វេទនាដែលជាកិរិយា ក្នុងនេវសញ្ញានាសញ្ញាយតនៈ ជាវេទនាល្អិត ។ វេទនាណាគ្រោតគ្រាត, វេទនានោះអន់ថយ ។ វេទនាណាល្អិត, វេទនានោះប្រណីត ៕

## សំដែងអំពីវេទនាទូរទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃវេទនាទូរទុកៈ (ឆ្ងាយ និងជិត) តទៅ ៖

វេទនាជាអកុសល ឈ្មោះថា វេទនាឆ្ងាយ, វេទនាដែលជាកុសល និងអព្យាកតៈ ដោយអត្ថថា មិនស្មើគ្នា និងដោយអត្ថថា មិនជាប់ទាក់ទងគ្នា; បណ្ឌិតគប្បីជ្រាបវេទនាជាសភាពឆ្ងាយ ក្នុងបទទាំងពួង ដោយន័យនេះដែរ ។

ពិតណាស់ ប្រសិនបើមនុស្ស ៣ នាក់ អ្នកប្រកបព្រមគ្នាដោយវេទនា ដែលជាអកុសលជាដើម និងប្រកបព្រមដោយវេទនាមានទុក្ខវេទនាជាដើម អង្គុយលើ

ត្រែជាមួយគ្នាសោត, វេទនាទាំងនោះ សូម្បីរបស់បុគ្គលនោះ ក៏ឈ្មោះថា **ឆ្ងាយពីគ្នានោះឯង** ដោយអត្ថថា វេទនាមិនស្មើគ្នា និងដោយអត្ថថា មិនជាប់ទាក់ទងគ្នា ។ សូម្បីក្នុងបុគ្គលអ្នកប្រកបព្រមដោយវេទនា របស់បុគ្គលអ្នកចូលសមាបត្តិជាដើម ក៏ មានន័យដូចគ្នានេះដែរ ។

ចំណែកវេទនាដែលជាអកុសល ឈ្មោះថា **វេទនាជិត** ដោយអត្ថថា មានចំណែកស្មើគ្នា និងដោយអត្ថថា ដូចអកុសល; បណ្ឌិតគប្បីជ្រាបវេទនា ជាសភាវៈជិតក្នុងបទទាំងពួងដោយន័យនេះ ។ ក៏បើបុគ្គល ៣ នាក់ អ្នកប្រកបព្រមដោយវេទនាមានអកុសលវេទនាជាដើម មនុស្សម្នាក់កើតក្នុងកាមភព, មនុស្សម្នាក់ទៀតកើតក្នុងរូបភព, មនុស្សម្នាក់ផ្សេងទៀត កើតក្នុងអរូបភព; វេទនាទាំងនោះ សូម្បីរបស់បុគ្គលនោះ ឈ្មោះថា វេទនាជិតគ្នាទាំងអស់ ដោយអត្ថថា ស្មើគ្នា និងដោយអត្ថថា ស្រដៀងគ្នា ។ សូម្បីក្នុងបុគ្គលអ្នកប្រកបព្រមដោយវេទនា មានកុសល-វេទនាជាដើម ក៏ន័យនេះដែរ ។

ខថា **តំ តំ វា បន** នេះ មិនគប្បីសម្លឹងមើលន័យដែលពោលទុកក្នុងកាលមុន ។ ក៏គប្បីសម្តែងអំពីអំណាចនៃ **តំតំវាបនកន័យ** នេះឯង, តែកាលនឹងពោលមិនគួរលើកយកវេទនាជិត ពីវេទនាឆ្ងាយ, តែគប្បីយកវេទនាឆ្ងាយ ពីវេទនាជិត; ព្រោះវេទនាដែលជាអកុសលមាន ២ យ៉ាង គឺ វេទនាដែលសហគតៈដោយលោភៈ និងសហគតៈដោយទោសៈ; ក្នុងវេទនាពីរពួកនេះ **វេទនាដែលសហគតៈដោយលោភៈ**

ឈ្មោះថា **វេទនាជិត** ព្រោះកើតព្រមជាមួយលោភៈ, ឈ្មោះថា **វេទនាឆ្ងាយ** ព្រោះកើតព្រមជាមួយទោសៈ; **សូម្បីវេទនាដែលសហគតៈដោយទោសៈ** ឈ្មោះថា **វេទនាជិត** ព្រោះកើតព្រមជាមួយទោសៈ, ឈ្មោះថា **វេទនាឆ្ងាយ** ព្រោះកើតព្រមជាមួយលោភៈ; សូម្បីវេទនាសហគតៈដោយទោសៈដែលជានិយតៈ [១៤] ឈ្មោះថា **វេទនាជិត** ព្រោះមានសភាពទៀងទាត់, ឈ្មោះថា **អនិយតៈ** ព្រោះមានសភាពមិនទៀងយ៉ាងនោះ ។ គប្បីជ្រាបវេទនាគ្រប់ចំណែកថា ជាវេទនាជិត ដោយវេទនាដែលជាចំណែកនោះនុ៎ះឯង និងវេទនាក្រៅនេះ គប្បីជ្រាបថា ជាវេទនាឆ្ងាយពីចំណែកក្រៅនេះ បណ្ដោយតាមវេទនាទាំងពួងដែលផ្សេងគ្នា ដោយវេទនាដែលតាំងនៅរហូតកប្ប វេទនាដែលជាអសង្ខារិក សសង្ខារិក និងវេទនាដែលផ្សេងដោយធម៌មានទិដ្ឋិគតសម្បយុត្តជាដើម ក្នុងចិត្តដែលកើតព្រមជាមួយលោភៈជាដើម ដោយអំណាចនៃពាក្យដែលខ្ញុំឱ្យពិស្ដារក្នុងនិទ្ទេសនៃឱឡារិកទុកៈនោះឯង ៕

## ចប់វេទនាខន្ធនិទ្ទេស

[១៤] ពាក្យថា និយតៈ សំដៅដល់ការទៀងទាត់ គឺកើតជាប់តគ្នាអស់កាលយូរ ដូចក្នុងនរក ។

## សញ្ញាខន្ធនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសនៃសញ្ញាខន្ធតទៅ ៖

បទថា "**យា កាចិ សញ្ញា** = សញ្ញាយ៉ាងណាមួយ" នេះ ព្រះមានព្រះភាគ ទ្រង់កាន់យកសញ្ញាដែលប្រព្រឹត្តទៅក្នុងភូមិ ៤; បទថា "**ចក្ខុសម្ផស្សជា សញ្ញា** = សញ្ញាកើតពីចក្ខុសម្ផស្ស" ជាដើម ត្រាស់ដើម្បីសម្តែងសញ្ញាដែលទ្រង់លើកឡើងសម្តែងដោយអំណាចនៃសញ្ញា ដែលជាអតីតៈជាដើម ដោយសភាវៈ ។

បណ្តាសញ្ញាទាំងនោះ សញ្ញាដែលកើតពីចក្ខុសម្ផស្ស ឬក្នុងចក្ខុសម្ផស្ស ឈ្មោះថា **ចក្ខុសម្ផស្សជាសញ្ញា** ។ សូម្បីក្នុងសញ្ញាដ៏សេស ក៏ន័យនេះដែរ; ក៏ក្នុងសញ្ញាទាំង ៦ នេះ សញ្ញា ៥ យ៉ាងខាងដើម មានចក្ខុបសាទជាដើម ជាទីអាស្រ័យកើតដោយចំពោះ **មនោសម្ផស្សជាសញ្ញា** (សញ្ញាកើតពីមនោសម្ផស្ស), មានហទយវត្ថុជាទីអាស្រ័យកើតខ្លះ, មិនមានហទយវត្ថុជាទីអាស្រ័យកើតខ្លះ; សូម្បីសញ្ញាទាំងអស់ ក៏ឈ្មោះថា ប្រព្រឹត្តទៅក្នុងភូមិ ៤ ដែរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឱឡារិកទុកនិទ្ទេស បទថា "**បដិឃសម្ផស្សជាសញ្ញា** = សញ្ញាកើតពីបដិឃសម្ផស្ស" សេចក្តីថា សម្ផស្សដែលប៉ះនឹងចក្ខុបសាទជាដើម ដែលជាបដិឃៈឱ្យជាទីអាស្រ័យហើយកើត ព្រោះប្រារព្ធរូបជាដើម ដែលជាសប្បដិឃៈហើយកើតឡើង ឈ្មោះថា **បដិឃសម្ផស្ស** ។ សញ្ញាកើតពីបដិឃសម្ផស្សនោះ ឬកើតក្នុងបដិឃសម្ផស្សនោះ ឈ្មោះថា បដិឃសម្ផស្សជា ។ សូម្បីពាក្យថា សញ្ញាដែលកើតពីចក្ខុសម្ផស្ស ។ល។ សញ្ញាដែលកើតពីកាយសម្ផស្សដូច្នេះ ក៏ជាឈ្មោះរបស់បដិឃសម្ផស្សនោះៗ ឯង ដោយវត្ថុ (ទីអាស្រ័យកើត) ។ សូម្បីពាក្យថា

**“រូបសញ្ញា ។ល។ ផោដ្ឋព្វសញ្ញា”** ដូច្នេះ ក៏ជាឈ្មោះរបស់ បដិឃសញ្ញានោះ៧ ឯង ដោយអារម្មណ៍; ក៏ប៉ុន្តែ ពាក្យថា “បដិឃសញ្ញា” នេះ ជាឈ្មោះរបស់សញ្ញា ទាំងដោយវត្ថុ ទាំងដោយអារម្មណ៍ ។ ពិតណាស់ សញ្ញានេះ ត្រាស់ហៅថា សញ្ញាដែលកើតពីបដិឃៈ ព្រោះអាស្រ័យវត្ថុដែលជាសប្បដិឃៈ (ប្រព្រឹត្តទៅដោយការប៉ះខ្ទប់) និងប្រារព្ធអារម្មណ៍ដែលជាសប្បដិឃៈ ហើយកើតឡើង ។ សូម្បីពាក្យថា **មនោសម្ផស្សជា** ក៏ជាឈ្មោះរបស់បដិឃសញ្ញានេះ ដោយបរិយាយដូចគ្នា ។ ព្រោះថា ចក្ខុវិញ្ញាណ ឈ្មោះថា **មនោ**, សម្ផស្សកើតឡើង ព្រមជាមួយមនោនោះ ឈ្មោះថា **មនោសម្ផស្ស** ។ សញ្ញាកើតក្នុងមនោសម្ផស្សនោះ ឬកើតពីមនោសម្ផស្សនោះ រមែងមាន ព្រោះហេតុនោះ ទើបឈ្មោះថា **មនោសម្ផស្សជា**; សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្හាវិញ្ញាណ និងកាយវិញ្ញាណ ក៏ឈ្មោះថា មនោដូចគ្នា ។ ផស្សៈកើតព្រមជាមួយមនោនោះ ឈ្មោះថា **មនោសម្ផស្ស**, សញ្ញាកើតក្នុងមនោសម្ផស្សនោះ ឬកើតពីមនោសម្ផស្សនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **មនោសម្ផស្សជា**; សូម្បីពាក្យថា សញ្ញាដែលកើតពីអធិវចនសម្ផស្សដូច្នេះ ក៏ឈ្មោះថា ជារបស់មនោ-សម្ផស្សជានេះ ដោយបរិយាយនោះឯង ។ ព្រោះថា មាននាមក្ខន្ធ ៣ គឺវេទនា សង្ខារ និងវិញ្ញាណ ជាសភាវៈវិលទៅខាងក្រោយដោយខ្លួនឯង ទើបធ្វើឈ្មោះសញ្ញាដែលកើតព្រមជាមួយខ្លួនថា សញ្ញាកើតពីអធិវចនសម្ផស្ស ។

តែកាលបើពោលដោយនិប្បរិយាយ (ដោយត្រង់) សញ្ញាដែលប្រព្រឹត្តទៅក្នុងបញ្ចទ្វារ ឈ្មោះថា សញ្ញាដែលកើតពីបដិឃសម្ផស្ស, សញ្ញាដែលប្រព្រឹត្តទៅក្នុងមនោទ្វារ ឈ្មោះថា សញ្ញាដែលកើតពីអធិវចនសម្ផស្ស; បណ្ដាសញ្ញាទាំងពីរ

នោះ សញ្ញាដែលប្រព្រឹត្តទៅតាមផ្លូវបញ្ចទ្វារ សូម្បីនរណា ៗ សម្លឹងមើលហើយ ក៏អាចដឹងបាន ព្រោះហេតុនោះ សញ្ញាដែលប្រព្រឹត្តទៅតាមបញ្ចទ្វារនោះ ទើបឈ្មោះថា សញ្ញាគ្រោតគ្រាត ។ ពិតមែន មនុស្សទាំងឡាយឃើញបុគ្គលអ្នកត្រេកអរខ្លាំងហើយ ក៏អាចដឹងថា "បុគ្គលនេះត្រេកអរខ្លាំងហើយ" ឬឃើញបុគ្គលក្រោធខ្លាំងហើយ ក៏អាចដឹងថា "បុគ្គលនេះក្រោធខ្លាំងហើយ" ដូច្នេះ ។

ក្នុងសេចក្តីនេះមានរឿងជាឧទាហរណ៍តទៅ ៖

បានឮថា ស្ត្រីពីរនាក់កំពុងអង្គុយត្បាញអំបោះខាងក្នុងស្រុក; ភិក្ខុកំឡោះ ២ រូបត្រាច់ទៅក្នុងស្រុក ភិក្ខុមួយរូបដើរខាងមុខ បានមើលស្ត្រីម្នាក់, ស្ត្រីក្រៅនេះសួរស្ត្រីនោះថា "ព្រោះហេតុអ្វីហ្ន៎ ! ភិក្ខុកំឡោះនេះទើបមើលនាង" ដូច្នេះ; នាងឆ្លើយថា ភិក្ខុនេះមិនមែនមើលខ្ញុំដោយចិត្តដែលជាវិសភាគារម្មណ៍ (ចិត្តដែលសម្បយុត្តដោយរាគៈ) ទេ តែសម្លឹងមើលដោយសម្គាល់ថាជាប្អូនស្រី; កាលភិក្ខុទាំងពីររូបមួយ រូបបិណ្ឌបាតក្នុងស្រុកហើយ ក៏មកអង្គុយក្នុងរោងឆាន់ ភិក្ខុក្រៅនេះ ទើបសួរថា "លោកសម្លឹងមើលស្ត្រីម្នាក់នោះឬ ?" ; លោកឆ្លើយថា ករុណាទាន ! ខ្ញុំសឡឹងមើលមែន ។ លោកសម្លឹងមើលដើម្បីប្រយោជន៍អ្វី ? ភិក្ខុនោះឆ្លើយថា ខ្ញុំសម្លឹងមើលនាង ដោយគិតថា នាងដូចជាប្អូនស្រីរបស់ខ្ញុំ; ដោយអាការៈយ៉ាងនេះ សញ្ញាដែលប្រព្រឹត្តទៅតាមបញ្ចទ្វារ បណ្ឌិតគប្បីជ្រាបថា សូម្បីនរណា ៗ សម្លឹងមើលហើយ ក៏គប្បីជ្រាបបាន; ក៏សញ្ញានេះឯងមានបសាទវត្ថុប៉ុណ្ណោះ; តែអាចារ្យពួកខ្លះសម្តែងថា ព្រោះសញ្ញានោះប្រព្រឹត្តទៅដោយជវ័ន ។

សញ្ញាដែលប្រព្រឹត្តទៅតាមមនោទ្វារ ជាសញ្ញាល្អិត ព្រោះសេចក្តីដែល

សញ្ញានោះ បុគ្គលគប្បីសួរបុគ្គលដទៃសូម្បីអង្គុយលើគ្រែជាមួយគ្នា ឬតាំងជាមួយគ្នាដែលកំពុងគិត ឬត្រិះរិះថា “លោកគិត ឬត្រិះរិះអ្វី” ដូច្នេះ ទើបជ្រាបបានដោយអំណាចនៃពាក្យប្រាប់របស់បុគ្គលនោះ ។ ពាក្យដ៏សេសដូចគ្នា ជាមួយនឹងវេទនាខន្ធនោះឯង ។ **នេះជាសញ្ញាខន្ធនិទ្ទេស** ៕

## សង្ខារក្ខន្ធនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យសង្ខារក្ខន្ធនិទ្ទេសតទៅ ៖

បទថា “**យេ កេចិ សង្ខារា** = សង្ខារណានីមួយ” នេះ ទ្រង់កំណត់សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា “**ចក្ខុសម្ផស្សជា ចេតនា** = ចេតនាដែលកើតអំពីចក្ខុសម្ផស្ស” ជាដើម ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុក ដើម្បីសម្ដែងសង្ខារដែលទ្រង់លើកឡើងសម្ដែងដោយអំណាចនៃសង្ខារ ដែលជាអតីតៈជាដើម ដោយសភាវៈ ។ បទថា “**ចក្ខុសម្ផស្សជា** = កើតពីចក្ខុសម្ផស្ស” ជាដើម មានសេចក្ដីតាមដែលពោលហើយនោះឯង ។ ពាក្យថា “**ចេតនា**” នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដោយអំណាចជាប្រធាននៃសង្ខារ ទាំងខាងដើម និងខាងចុង; ព្រោះសង្ខារ ៤ មកក្នុងព្រះបាលីកើតឡើងព្រមជាមួយចក្ខុវិញ្ញាណ ដោយទីបំផុត ទាំងខាងដើម ទាំងខាងចុង; បណ្ដាសង្ខារទាំងនោះ ចេតនា ឈ្មោះថា ជាប្រធាន, ព្រោះប្រាកដដោយអត្ថថា ប្រមូល; ព្រោះហេតុនោះ ចេតនានេះប៉ុណ្ណោះទ្រង់កាន់យកហើយ; ក៏សង្ខារដែលសម្បយុត្តដោយចេតនានោះ រមែងជាហេតុដែលទ្រង់កាន់យកហើយ ក៏ព្រោះចេតនានោះ ព្រះអង្គទ្រង់កាន់យកហើយនោះឯង;

សូម្បីក្នុងទីនេះ ចេតនា ៥ ខាងដើម មានចក្ខុបសាទជាដើម ជាទីអាស្រ័យកើតតែម្យ៉ាង; ចេតនាកើតពីមនោសម្ផស្ស មានហទយវត្ថុដែលជាទីអាស្រ័យកើតខ្លះ, មិនមានវត្ថុជាទីអាស្រ័យកើតខ្លះ; ចេតនាទាំងអស់ ជាចេតនាប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ពាក្យដ៏សេស ដូចនឹងវេទនាខន្ធនោះដែរ ។ **នេះជាសង្ខារក្ខន្ធនិទ្ទេស** ៕

## វិញ្ញាណក្ខន្ធនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃវិញ្ញាណក្ខន្ធតទៅ ៖

បទថា "**យំ កិញ្ចិ វិញ្ញាណំ** = វិញ្ញាណយ៉ាងណាមួយ" នេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់កាន់យកវិញ្ញាណដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា "**ចក្ខុ~វិញ្ញាណំ** = ចក្ខុវិញ្ញាណ" ជាដើម ព្រះអង្គត្រាស់ដើម្បីសម្តែងវិញ្ញាណដែលទ្រង់លើកឡើងសម្តែងដោយអំណាចនៃវិញ្ញាណដែលជាអតីតៈជាដើម ដោយសភាវៈ ។ ក្នុងព្រះបាលីនេះ វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម មានចក្ខុបសាទវត្ថុជាដើម ជាទីអាស្រ័យកើតមែនពិត ។ មនោវិញ្ញាណមានហទយវត្ថុជាទីអាស្រ័យកើតខ្លះ, មិនមានហទយវត្ថុជាទីអាស្រ័យកើតខ្លះ; វិញ្ញាណទាំងអស់ជាវិញ្ញាណប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ពាក្យដ៏សេសដូចគ្នានឹងវេទនាខន្ធនោះដែរ ។ **នេះជាវិញ្ញាណក្ខន្ធនិទ្ទេស** ៕

## សម្តែងអំពីបកិណ្ណកៈក្នុងបញ្ចខន្ធ ១៦ យ៉ាង

ឥឡូវនេះ គប្បីជ្រាបបកិណ្ណកៈក្នុងខន្ធទាំង ៥ ដោយអាការៈ ១៦ យ៉ាង គឺ

១~ **សមុគ្គមតោ** ដោយការកើតគ្រាដំបូង

២. **បុព្វាបរតោ** ដោយការកើតមុន និងក្រោយ

៣. **អទ្ធានបរិច្ឆេទតោ** ដោយការកំណត់កាល

៤. **ឯកុប្បាទនានា និរោធតោ** ដោយការកើតខណៈជាមួយគ្នា រលត់ខណៈផ្សេងគ្នា

៥. **នានុប្បាទឯកនិរោធតោ** ដោយការកើតខណៈផ្សេងគ្នា រលត់ព្រមគ្នា

៦. **ឯកុប្បាទឯកនិរោធតោ** ដោយការកើតព្រមគ្នា រលត់ព្រមគ្នា

៧. **នានុប្បាទនានានិរោធតោ** ដោយការកើតមិនព្រមគ្នា រលត់មិនព្រមគ្នា

៨. **អតីតានាគតប្បច្ចុប្បន្នតោ** ដោយធម៌ ជាអតីតៈ អនាគត និងបច្ចុប្បន្ន

៩. **អជ្ឈត្តិកពាហិរតោ** ដោយជាធម៌ខាងក្នុង និងខាងក្រៅ

១០. **ឱឡារិកសុខុមតោ** ដោយជាសភាពគ្រោតគ្រាត និងល្អិត

១១. **ហីនបណីតតោ** ដោយធម៌ថោកទាប និងប្រណីត

១២. **ទូរសន្តិកតោ** ដោយធម៌ឆ្ងាយ និងធម៌ជិត

១៣. **បច្ចយតោ** ដោយបច្ច័យ

១៤. **សមុដ្ឋានតោ** ដោយសមុដ្ឋាន

១៥. **បរិនិប្ផន្នតោ** ដោយសេចក្ដីសម្រេច

១៦. **សង្ខតតោ** ដោយជារបស់តាក់តែង ៚

## សម្ដែងអំពីការកើតឡើងដំបូងរបស់ខន្ធ ៥

បណ្ដាបកិណ្ណកៈទាំងនោះ ពាក្យថា **ដោយការកើតឡើងគ្រាដំបូង** ការកើតឡើងគ្រាដំបូងមាន ២ យ៉ាង គឺ ការកើតគ្រាដំបូងរបស់គព្ភសេយ្យកសត្វ (អ្នក

ដេកនៅក្នុងគភ៌) និងការកើតឡើងគ្រាដំបូងរបស់ឱបបាតិកសត្វ ។ បណ្ដាការកើត ២ យ៉ាងនោះ គប្បីជ្រាប**ការកើតឡើងគ្រាដំបូងរបស់គព្ភសេយ្យកសត្វ**យ៉ាងនេះ ពិតណាស់ ខន្ធ ៥ របស់គព្ភសេយ្យកសត្វ រមែងកើតព្រមគ្នា មិនមុន មិនក្រោយ ក្នុងខណៈបដិសន្ធិ ។ ខនេះ លោកពោលថា សេចក្ដីបន្តនៃរូប ពោលគឺកលលៈដែលប្រាកដក្នុងខណៈនោះ ជារបស់បន្តិចបន្តួចមានត្រឹមតែសត្វតូច និងគប្បីផឹកបានដោយសេចក្ដីព្យាយាមមួយគ្រាប៉ុណ្ណោះ ហើយពោលទៀតថា "នោះក៏នៅច្រើនជាងផង, គឺប្រេងត្រឹមតែមួយដំណក់ដែលហូរចេញពីចុងរបស់ម្ជុលតូច ដែលជ្រលក់ក្នុងប្រេងហើយលើកឡើង" ដូច្នេះ ។ សូម្បីដំណក់ប្រេងនោះ លោកក៏បដិសេធហើយពោលថា "កាលគេចាប់សក់មួយសរសៃលើកឡើង អំពីប្រេងនោះហើយមានត្រឹមតែដំណក់ប្រេងដែលហូរចេញត្រង់ចុងសក់នោះ" សូម្បីដំណក់ប្រេងនោះដែលបដិសេធហើយពោលថា "កាលពុះសរសៃសក់របស់អ្នកស្រុកជនបទនេះចេញជា ៨ ចំណែក សរសៃសក់របស់អ្នកឧត្តរកុរុទ្វីប មានប្រមាណប៉ុនចំណែកមួយ ពី ៨ ចំណែកនោះ; កលលៈនោះ ក៏ត្រឹមតែជាដំណក់ ដែលតាំងនៅត្រង់ចុងសក់របស់អ្នកស្រុកឧត្តរកុរុទ្វីបនោះ ដែលគេលើកឡើងអំពីប្រេងថ្លា" ; សូម្បីប្រេងថ្លានោះ លោកក៏បដិសេធ ហើយពោលថា "នោះក៏នៅច្រើនណាស់, ធម្មតារោមទ្រាយជាធម្ម-ជាតិល្អិត, កលលៈនោះមានត្រឹមតែដំណក់ញើស ដែលហូរចេញត្រង់ចុងរបស់រោមមួយសរសៃ ដែលគេជ្រលក់ក្នុងប្រេងល្ងថ្លាហើយលើកឡើង" ដូច្នេះ ។ ក៏កលលៈនោះឯង ថ្លាស្អាត មិនល្អក់ គឺបរិសុទ្ធ ស្មើដោយដំណក់ប្រេងល្ងថ្លា; ខនេះសមដូចពាក្យដែលលោកពោលទុកថា ៖

**តិលតេលស្ស យថា ពិន្ទុ សប្បិមណ្ឌោ អនាវិលោ**
**ឯវំ វណ្ណប្បដិភាគំ កលលន្តិ បវុច្ចតិ**

ដំណក់ប្រេងល្ង ដូចទឹកដោះថ្លាមិនល្អក់ យ៉ាងណា,

លោកពោលថា កលលរូបក៏មានចំណែកប្រៀបដូចរូបពណ៌ដែរ ។

ក្នុងសន្តតិរូបតិចតួចយ៉ាងនេះនៅមានសន្តតិរូបដែលជាប្រធាន ៣ ក្រុម គឺ វត្ថុទសកៈ ១, កាយទសកៈ ១, ភាវទសកៈ ដោយអំណាចនៃឥត្ថិន្ទ្រិយរបស់ស្ត្រី និង ដោយអំណាចនៃបុរិសិន្ទ្រិយរបស់បុរស ១; បណ្ដាសន្តតិរូបទាំង ៣ នោះ រូបនេះ គឺ វត្ថុរូប ១, មហាភូតរូប ៤ ដែលជាទីអាស្រ័យរបស់វត្ថុរូបនោះ និងវណ្ណៈ គន្ធៈ រសៈ ឱជា រួមជា ៤ ដែលអាស្រ័យមហាភូតរូបនោះ និងជីវិតរូប ១ ឈ្មោះថា វត្ថុ-ទសកៈ; រូបនេះ គឺកាយប្រសាទ ១, មហាភូតរូប ៤ ដែលជាទីអាស្រ័យរបស់ កាយប្រសាទនោះ វណ្ណៈ គន្ធៈ រសៈ ឱជា ៤ ដែលអាស្រ័យមហាភូតរូបនោះ និង ជីវិតរូប ១ ឈ្មោះថា **កាយទសកៈ**; រូបនេះ គឺឥត្ថីភាវៈរបស់ស្ត្រី និងបុរិសភាវៈ របស់បុរស ១, មហាភូតរូប ៤ ដែលជាទីអាស្រ័យភាវរូបនោះ វណ្ណៈ គន្ធៈ រសៈ ឱជា ៤ ដែលអាស្រ័យមហាភូតរូបនោះ និងជីវិតរូប ១ ឈ្មោះថា **ភាវទសកៈ** ។ កម្មជរូប (រូបកើតអំពីកម្ម) ក្នុងបដិសន្ធិរបស់គព្ភសេយ្យកសត្វ កំណត់ដោយខ្ពស់ បំផុតមាន ៣០ គត់ ឈ្មោះថា រូបក្ខន្ធ ដោយប្រការដូច្នេះ ។ ក៏វេទនាដែលកើត ព្រមជាមួយបដិសន្ធិចិត្ត ឈ្មោះថា **វេទនាខន្ធ**; សញ្ញា... ឈ្មោះថា **សញ្ញាខន្ធ** សង្ខារ... ឈ្មោះថា **សង្ខារក្ខន្ធ**; **បដិសន្ធិចិត្ត** ឈ្មោះថា **វិញ្ញាណក្ខន្ធ**, ខន្ធ ៥ ក្នុងខណៈបដិសន្ធិ **របស់គព្ភសេយ្យកសត្វ** ជាសភាពបរិបូរហើយ ដោយប្រការដូច្នេះ; តែថា បដិសន្ធិ

របស់បណ្ឌកៈ (នបុំសកបដិសន្ធិ) រមែងផុតចាកភាវទសកៈ, មានកម្មជរូប ២០ គត់ ដោយអំណាចនៃទសកៈទាំង ២ ឈ្មោះថា **រូបក្ខន្ធ**; ធម៌ មានវេទនាខន្ធជាដើម មានប្រការតាមដែលពោលហើយនោះឯង ខន្ធ ៥ ក្នុងខណៈបដិសន្ធិរបស់គព្ភសេយ្យកសត្វ ស្ងួម្បីយ៉ាងនេះដោយប្រការដូច្នេះ ក៏ឈ្មោះថា បរិបូរហើយ ។ ក្នុងឋានៈនេះ បណ្ឌិតគួរពោលបវេណីរបស់រូបដែលមានសមុដ្ឋាន ៣ ផង ។

ក៏ឈ្មោះថា ការកើតឡើងគ្រាដំបូងរបស់សត្វអ្នកជាឱបបាតិកៈ លោកសម្ដែងទុកដោយមិនបានពោលដល់បវេណី ៣ នោះ ។

ពិតណាស់ ក្នុងខណៈបដិសន្ធិរបស់សត្វ អ្នកជាឱបបាតិកៈមានអាយតនៈបរិបូរ គឺមានរូបសន្តតិដែលជាប្រធាន ៧ ក្រុម បានដល់ កម្មជរូបតាមដែលពោលហើយខាងដើម ៣ និងចក្ខុទសកៈ សោតទសកៈ ឃានទសកៈ និងជិវ្ហាទសកៈ **រមែងកើតឡើង** ។ បណ្ដាកម្មជរូប ៧ ក្រុមនោះ ចក្ខុទសកៈជាដើម ប្រៀបដូចនឹងកាយ-ទសកៈនោះដែរ; តែភាវទសកៈរមែងមិនមានដល់ឱបបាតិកសត្វ អ្នកមិនមានភេទ; ដោយអាការយ៉ាងនេះ កម្មជរូបដែលឈ្មោះថា **រូបក្ខន្ធ** របស់ឱបបាតិកសត្វ ដែលមានអាយតនៈបរិបូរ ទើបមាន ៧០ គត់ខ្លះ, ៦០ គត់ខ្លះ; ធម៌ មានវេទនាខន្ធជាដើម មានប្រការតាមដែលពោលហើយនោះឯង ខន្ធ ៥ ក្នុងខណៈបដិសន្ធិរបស់ឱបបាតិកៈ រមែងបរិបូរណ៍ហើយដោយប្រការដូច្នេះ ។ នេះឈ្មោះថា ការកើតឡើងគ្រាដំបូងរបស់ឱបបាតិកសត្វ ។

គប្បីជ្រាបខន្ធ ៥ **ដោយការកើតឡើងគ្រាដំបូង** យ៉ាងនេះសិន ៕

## សម្ដែងអំពីការកើតឡើងមុន និងកើតក្រោយ

ពាក្យថា **ដោយការកើតឡើងមុន និងកើតក្រោយ** មានពាក្យសួរថា ក៏ខន្ធ ៥ របស់គព្ភសេយ្យកសត្វដែលកើតឡើងមិនមុន មិនក្រោយយ៉ាងនេះ រូបរមែងញ៉ាំងរូបឱ្យ តាំងឡើងមុន ឬអរូបរមែងញ៉ាំងរូបឱ្យតាំងឡើងមុន ? ។ ឆ្លើយថា រូបនោះឯងរមែងញ៉ាំងរូបឱ្យតាំងឡើង, អរូបមិនបានញ៉ាំងរូបឱ្យតាំងឡើងទេ; ព្រោះហេតុអ្វី ? ព្រោះសេចក្ដីដែលបដិសន្ធិចិត្ត ញ៉ាំងរូបឱ្យកើតឡើងមិនបានឡើយ ។

ពិតណាស់ ចិត្ត ១៦ ដួង គឺបដិសន្ធិចិត្តរបស់សត្វទាំងអស់ ១, ចុតិចិត្តរបស់ព្រះខីណាស្រព ១, ទ្វិបញ្ចវិញ្ញាណ ១០, អរូបវិបាកចិត្ត ៤ ញ៉ាំងរូបឱ្យតាំងឡើងមិនបាន ។

បណ្ដាចិត្តទាំង ១៦ ដួងនោះ បដិសន្ធិចិត្តដំបូង រមែងញ៉ាំងរូបឱ្យតាំងឡើងមិនបាន ព្រោះវត្ថុទុព្វល ១, ព្រោះភាពមិនតាំងមាំ ១, ព្រោះមានបច្ច័យមិនគ្រប់គ្រាន់ ១, ព្រោះជាចិត្តចូលមកថ្មី ១; ពោលដោយធម្មតា ហេតុទាំង ៤ នេះ វត្ថុដែលកើតព្រមជាមួយបដិសន្ធិចិត្ត ជាសភាពទុព្វលក្នុងខណៈកើតឡើង ព្រោះហេតុដូច្នេះ បដិសន្ធិចិត្តនោះ ទើបឈ្មោះថា ញ៉ាំងរូបឱ្យតាំងឡើងមិនបាន ព្រោះភាវៈនៃវត្ថុជារបស់ទុព្វល ។

ម្យ៉ាងទៀត បុរសដែលកំពុងធ្លាក់ទៅក្នុងជ្រោះ រមែងមិនអាចជាទីពឹងដល់មនុស្សដទៃបានយ៉ាងណា, សូម្បីចិត្តនេះ ក៏យ៉ាងនោះដែរ ជាចិត្តមិនតាំងមាំ ហាក់បីដូចកំពុងធ្លាក់ទៅក្នុងជ្រោះ ព្រោះត្រូវកម្មច្រានទៅ; ព្រោះហេតុនោះ បដិសន្ធិចិត្តនោះ ទើបឈ្មោះថា ញ៉ាំងរូបឱ្យតាំងឡើងមិនបាន សូម្បីហេតុដែលមិនតាំងមាំ

ព្រោះត្រូវកម្មច្រានទៅ ដោយប្រការដូច្នេះ ។

ម្យ៉ាងវិញទៀត បដិសន្ធិចិត្តកើតឡើងមិនមុន មិនក្រោយជាមួយវត្ថុ (រូប), វត្ថុរបស់បដិសន្ធិចិត្តនោះ ទើបមិនអាចជាបច្ច័យ (បុរេជាតប្បច្ច័យ) ដែលកើតមុន; តែបើគប្បីអាច ក៏នឹងមិនគប្បីញ៉ាំងរូបឱ្យតាំងឡើងបានដែរ; សូម្បីក្នុងខណៈដែលវត្ថុកើតមុន អាចដើម្បីជាបច្ច័យ ជាប្រវេណីបន្តនៅរហូតនោះ ចិត្តដែលមិនសាបសូន្យចាកចំណែកប្រកបប៉ុណ្ណោះ ទើបញ៉ាំងរូបឱ្យតាំងឡើងបាន ។ ពិតណាស់បើចិត្តញ៉ាំងរូប ឱ្យតាំងឡើងបានក្នុងខណៈដែលតាំងនៅ (ឋិតិខណៈ) ឬក្នុងភង្គ-ខណៈ, សូម្បីបដិសន្ធិចិត្ត ក៏នឹងគប្បីញ៉ាំងរូបឱ្យតាំងឡើងបាន ។ តែថាចិត្តរមែងញ៉ាំងរូបឱ្យតាំងឡើងក្នុងខណៈទាំងពីរនោះមិនបាន ។ ដូចយ៉ាងគុម្ពផ្សិតកាលដុះឡើងអំពីផែនដី រមែងនាំយកអាចម៍ដីមកផង យ៉ាងណា, ចិត្តក៏ដូច្នោះដែរ អាស្រ័យ (អញ្ញមញ្ញនិស្សយៈ) វត្ថុដែលកើតមុន (កើតគ្រាដំបូង) ហើយកាន់យករូប ៨ យ៉ាង តាំងឡើងក្នុងឧប្បាទក្ខណៈ; តែរូប (វត្ថុ) ដែលកើតមុន (គ្រាដំបូង) ក្នុងខណៈបដិសន្ធិមិនអាចជាបច្ច័យបាន, ព្រោះហេតុដូច្នោះ បដិសន្ធិចិត្ត ទើបឈ្មោះថាញ៉ាំងរូបឱ្យតាំងឡើងមិនបាន សូម្បីព្រោះសេចក្ដីខ្វះខាតនៃបច្ច័យ ។

ម្យ៉ាងវិញទៀត បុគ្គលអ្នកមកថ្មីដល់ប្រទេស ដែលខ្លួននៅមិនធ្លាប់មក រមែងមិនអាចនិយាយដល់មនុស្សដទៃៗ ថា "ម្នាលអ្នកដ៏ចម្រើន ពួកលោកចូរមកក្នុងស្រុកចុះ ខ្ញុំនឹងឱ្យបាយ ទឹក របស់ក្រអូប និងកម្រងផ្កាឈើជាដើម ដល់ពួកលោក" ដូច្នេះ ព្រោះសេចក្ដីដែលស្រុកនោះ មិនមែនវិស័យ (គឺមិននៅក្នុងអំណាច) របស់ខ្លួន ព្រោះភាពនៃខ្លួនមិនបានជាធំក្នុងស្រុកនោះ យ៉ាងណា, បដិ-

សន្ធិចិត្ត ជាចិត្តត្រាច់ចរមកថ្មីក៏ដូច្នោះដែរ, ព្រោះហេតុដូច្នោះ ទើបបដិសន្ធិចិត្តនោះ ញុំាងរូបឱ្យតាំងឡើងមិនបាន ព្រោះជាអ្នកមកថ្មី; ពុំនោះសោត កម្មជរូប ៣០ គត់ កាន់យកឋាននៃរូប ដែលមានចិត្តជាសមុដ្ឋានតាំងនៅហើយ សូម្បីព្រោះហេតុ ដូច្នោះ ទើបបដិសន្ធិចិត្ត មិនញុំាងរូបឱ្យកើតឡើង ។

ក៏ចុតិចិត្តរបស់ព្រះខីណាស្រព ក៏មិនញុំាងរូបឱ្យតាំងឡើង ព្រោះឫសនៃ វដ្តៈ (មូលវដ្តៈ) របស់លោកស្ងប់ហើយ; ពិតមែន ព្រះខីណាស្រពនោះមានឫស នៃវដ្តៈក្នុងភពទាំងពួងស្ងប់ហើយ មិនគួរកើតឡើង, ឈ្មោះថា ខ្សែស្រឡាយនៃការ កើតឡើងទៀត មិនបានមានឡើយ ។ តែព្រះសោតាបន្នវៀរ ៧ ភពចេញហើយ ភពទី ៨ របស់លោកមានឫសនៃវដ្តៈនោះស្ងប់ហើយ; ព្រោះហេតុដូច្នោះ ចុតិចិត្ត របស់ព្រះសោតាបន្ននោះ ទើបញុំាងរូបឱ្យតាំងឡើងបាន ៧ ភព ។ ព្រះសកទាគាមី ញុំាងរូបឱ្យតាំងឡើងបាន ២ ភព, ព្រះអនាគាមីញុំាងរូបឱ្យតាំងឡើងបាន ១ ភព; ចុតិរបស់ព្រះខីណាស្រពញុំាងរូបឱ្យតាំងឡើងមិនបានឡើយ ព្រោះភពដែលជាមូល នៃវដ្តៈក្នុងភពទាំងពួងបានស្ងប់ហើយ ។

ម្យ៉ាងទៀត អង្គឈានក្នុងទ្វិបញ្ចវិញ្ញាណទាំងឡាយមិនមាន, អង្គមគ្គ ក៏ មិនមាន, ហេតុក៏មិនមាន, ព្រោះហេតុនោះ ចំណែកប្រកប (អង្គ) របស់ចិត្ត រមែងជាវត្ថុទុព្វល ហេតុនោះ សូម្បីទ្វិបញ្ចវិញ្ញាណទាំងនោះ ទើបញុំាងរូបឱ្យតាំង ឡើងមិនបាន ព្រោះសេចក្ដីដែលអង្គរបស់ចិត្តជាសភាពទុព្វល ។

អរូបវិបាកចិត្ត ៤ រមែងញុំាងរូបឱ្យតាំងឡើងមិនបាន ព្រោះរូបក្នុងភពនោះ មិនមាន; មិនមែនអរូបវិបាកចិត្ត ៤ ប៉ុណ្ណោះ ដែលញុំាងរូបមិនឱ្យតាំងឡើងទេ,

សូម្បី ចិត្តដទៃ១ ៤២ ដួង គឺកាមាវចរកុសលចិត្ត ៨, អកុសលចិត្ត ១០, កិរិយាចិត្ត ៩, អរូបកុសលចិត្ត ៤, អរូបកិរិយាចិត្ត ៤, មគ្គចិត្ត ៣ និងផលចិត្ត ៤ ដែលកើតក្នុងភពនោះ ក៏ញុំាងរូបឱ្យតាំងឡើងមិនបាន ព្រោះក្នុងអរូបភពនោះ មិនមានរូប; បដិសន្ធិចិត្តរមែងឱ្យរូបតាំងឡើងមិនបាន ដោយប្រការដូច្នេះ ។

ក៏ឧតុរមែងឱ្យរូបដំបូងតាំងឡើង; **សួរថា** ឈ្មោះថា ឧតុនេះ គឺអ្វី ? ឆ្លើយថា តេជោធាតុខាងក្នុងកម្មជរូប ៣០ គត់ ដែលកើតឡើងក្នុងខណៈបដិសន្ធិ ។ តេជោធាតុនោះដល់ខណៈហើយ ក៏ញុំាងរូប ៨ យ៉ាងឱ្យតាំងឡើង ។ម្យ៉ាងទៀត ក៏ឈ្មោះថា ឧតុនេះរលត់យឺត, ចិត្តរលត់រហ័ស, កាលបើឧតុរូបនៅតាំងនៅនោះ ឯងចិត្តក៏កើតរលត់ដល់ ១៦ ដួង; បណ្ដាចិត្ត ១៦ ដួងនោះ ភវង្គចិត្តដួងដំបូង ដែលដាច់ចាកបដិសន្ធិចិត្ត ញុំាងរូប ៨ យ៉ាង ឱ្យតាំងឡើងក្នុងឧប្បាទក្ខណៈមែនពិត; តែកាលណានឹងមានការកើតឡើងនៃសំឡេង, កាលនោះ ឧតុរូប និងចិត្ត ក៏ញុំាងរូបឈ្មោះថា **សទ្ទនវកៈ** = រូបកើតពីសំឡេងមាន ៩ នឹងឱ្យតាំងឡើង ។ សូម្បីកពឡិង្ការាហារ ដល់ឋានៈហើយ ក៏ញុំាងរូប ៨ យ៉ាងឱ្យតាំងឡើង ។ **សួរថា** កពឡិង្ការាហាររបស់គព្ភសេយ្យកសត្វនោះនឹងមកពីទីណា ? ឆ្លើយថា នឹងមកពីមាតា ។

សូម្បីដំណើរនេះ ក៏សមគ្នានឹងព្រះតម្រាស់ដែលត្រាស់ថា ៖

**យញ្ចស្ស ភុញ្ជតិ មាតា អន្នបានញ្ច ភោជនំ**
**តេន សោ តត្ថ យាបេតិ មាតុ កុច្ឆិគតោ នរោ**

មាតារបស់សត្វក្នុងគភ៌នោះ បរិភោគបាយ ទឹក
ភោជន យ៉ាងណា, នរៈអ្នកនៅក្នុងផ្ទៃរបស់មាតានោះ

ក៏ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយអាហារនោះ ក្នុងគភ៌នោះដែរ ។

ទារកអ្នកនៅក្នុងគភ៌ រមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយឱជានៃបាយ និងទឹកដែលមាតាលេបចូលទៅ ដោយប្រការដូច្នេះ ។ ឱជានេះដល់ឋានៈជាទីតាំងនៅហើយ ក៏ញុំាងរូប ៨ យ៉ាងឱ្យតាំងឡើងបាន ។

**សួរថា** ក៏ឱជានោះជារបស់គ្រោតគ្រាត, វត្ថុជារបស់ល្អិត មិនមែនឬ (តើ) នឹងតាំងនៅក្នុងវត្ថុនោះបានយ៉ាងណា ? ឆ្លើយថា គ្រាដំបូងមិនតាំងនៅទេ, តែកាលកន្លងទៅ ១ សប្តាហ៍ ឬ ២ សប្តាហ៍ ទើបតាំងនៅបាន; តែឱជានោះ នឹងតាំងនៅមុន ឬក្រោយ ក៏តាមតែវេលានោះ, កាលណាឱជានៃបាយ និងទឹករបស់នោះៗ ដែលមាតាបរិភោគលេបចូលទៅ ក៏នឹងតាំងនៅក្នុងសរីរៈរបស់ទារក, កាលនោះរូប ៨ ក៏តាំងឡើង ។

សូម្បីឱបបាតិកសត្វអ្នកកើតក្នុងទីមានខាទនីយៈ និងភោជនីយៈដែលវិបាកតាក់តែងទុកតាមប្រក្រតី កាលកាន់យកអាហារទាំងនោះ បរិភោគលេប ខណៈឱជាធ្លាក់ដល់ទីជាទីតាំងនៅ ក៏ញុំាងរូបឱ្យតាំងឡើង ។ ឱបបាតិកសត្វខ្លះ កើតក្នុងព្រៃមិនមានបាយ និងទឹក, មានការហេវខ្លាំង, ទើបយកអណ្តាតក្រឡេវទឹកមាត់របស់ខ្លួនលេបចូលទៅ; ខណៈឱជាធ្លាក់ដល់ទីជាទីតាំងនៅរបស់ឧបបាតិកៈនោះ ក៏ញុំាងរូបឱ្យតាំងឡើងសូម្បីក្នុងទីនោះ; ដោយអាការយ៉ាងនេះ បណ្តារូប ២៥ កោដ្ឋាសៈ (ចំណែក) រូប ២ យ៉ាង គឺតេជោធាតុ និងកពឡិង្ការាហារប៉ុណ្ណោះ រមែងញុំាងរូបឱ្យតាំងឡើង; សូម្បីអរូប (គឺនាមធម៌) វិញ ធម៌ គឺចិត្ត និងចេតនាកម្ម ២ យ៉ាងប៉ុណ្ណោះ រមែងញុំាងរូបឱ្យតាំងឡើង ។ បណ្តារូប និងនាមធម៌ទាំងនោះ រូបជាស-

ភាវៈទុព្វលក្នុងឧប្បាទក្ខណៈ និងភង្គខណៈ, ជាសភាវៈមានកម្លាំងក្នុងខណៈតាំងនៅ ព្រោះហេតុនោះ រូបដែលមានកម្លាំងនោះ ទើបឱ្យរូបតាំងឡើងក្នុងខណៈនៃការតាំងនៅ (ឋិតិខណៈ); ចិត្តជាសភាពទុព្វលក្នុងការតាំងនៅ (ឋិតិខណៈ) និងភង្គខណៈ, មានកម្លាំងតែក្នុងឧប្បាទក្ខណៈប៉ុណ្ណោះ; ព្រោះហេតុនោះ ចិត្តនោះ ទើបញ៉ាំងរូបឱ្យតាំងឡើងក្នុងឧប្បាទក្ខណៈប៉ុណ្ណោះ ។ ចេតនាកម្មរលត់ហើយ ទើបជាបច្ច័យបាន ។ ព្រោះកម្មដែលបុគ្គលធ្វើទុកហើយក្នុងអតីតៈ សូម្បីក្នុងទីបំផុតនៃសែនកោដិកប្ប ក៏ជាបច្ច័យក្នុងពេលឥឡូវនេះបានដែរ; កម្មដែលធ្វើក្នុងកាលឥឡូវនេះ ក៏នឹងជាបច្ច័យក្នុងអនាគត សូម្បីទីបំផុតនៃសែនកោដិកប្បនោះឯង ។

គប្បីជ្រាបខន្ធ ៥ **ក្នុងការកើតមុន និងកើតក្រោយ** ដូចពណ៌នាមកដូច្នេះ ៕

## សម្តែងអំពីការកំណត់កាលរបស់ខន្ធ ៥

ពាក្យថា **ដោយកំណត់កាល** នេះ **សួរថា** រូបតាំងនៅយូរប៉ុនណា ?; អរូប (នាម) តាំងនៅយូរប៉ុនណា ? ឆ្លើយថា រូបមានការប្រែប្រួលយូរ, រលត់យឺត; អរូប (នាម) ប្រែប្រួលរហ័ស, រលត់ក៏រហ័ស; កាលរូបនៅមាននោះឯង ចិត្តកើតរលត់ទៅ ១៦ ដួង; ក៏ប៉ុន្តែថា រូបនោះរលត់ទៅព្រមជាមួយចិត្តដួងទី ១៧; ប្រៀបដូចបុរសគិតថា "យើងនឹងឱ្យផ្លែឈើធ្លាក់" ទើបយកឈើដំបងខ្លីចោលមែកឈើ, ផ្លែ និងស្លឹកឈើទាំងឡាយ ក៏គប្បីរបូតចាកទងព្រមគ្នាមែនពិត, បណ្តាផ្លែឈើ និងស្លឹកឈើនោះ ផ្លែទាំងឡាយរមែងធ្លាក់ដល់ដីមុនជាង ព្រោះផ្លែឈើ ជារបស់ធ្ងន់, ស្លឹកទាំងឡាយក៏គប្បីធ្លាក់ទៅខាងក្រោយ ព្រោះជារបស់ស្រាលយ៉ាង

ណា, សេចក្តីប្រាកដនៃរូបធម៌ និងអរូបធម៌ ក្នុងខណៈជាមួយគ្នាក្នុងបដិសន្ធិ ដូច វេលាដែលស្លឹក និងផ្លែទាំងឡាយរបូតចាកទងក្នុងខណៈជាមួយគ្នា ដោយការចោល កំណាត់ឈើ ក៏យ៉ាងនោះដែរ; កាលដែលរូបតាំងនៅនោះឯង ចិត្តក៏រលត់ទៅ ១៦ ដួង ដូចកាលផ្លែធ្លាក់ចុះដល់ផែនដីមុនជាង ព្រោះផ្លែជារបស់ធ្ងន់; កាលដែលរូប រលត់ព្រមជាមួយចិត្តដួងទី ១៧ ដូចកាលដែលស្លឹកធ្លាក់ ទៅដល់ផែនដីខាង ក្រោយ ព្រោះស្លឹកទាំងឡាយជារបស់ស្រាល ។

បណ្តារូប និងចិត្តទាំងនោះ សូម្បីរូបរលត់យឺត ប្រែប្រួលយូរ; ចិត្តរលត់ រហ័ស ប្រែប្រួលរហ័ស ក៏ពិតមែនហើយ; ក៏ប៉ុន្តែថា រូបនេះចោលអរូប (នាម) ហើយ ក៏មិនអាចប្រព្រឹត្តទៅបាន ឬអរូបលះចោលរូបហើយ ក៏មិនអាចប្រព្រឹត្តទៅ បាន, សូម្បីការប្រព្រឹត្តទៅរបស់រូប និងអរូបទាំងពីរ មានប្រមាណប៉ុនគ្នាមែនពិត; ក្នុងខនេះ គប្បីជ្រាបឧបមាដូចតទៅនេះ ៖

បុរសម្នាក់មានជើងខ្លី, បុរសម្នាក់ទៀតមានជើងវែង; កាលអ្នកទាំងពីរ នោះដើរផ្លូវរួមគ្នា ម្នាក់ជើងវែងឈានជើងមួយជំហាន, ម្នាក់ជើងខ្លីក្រៅនេះ នឹង ឈានជើងទៅ ១៦ ជំហាន, ក្នុងកាលឈានទៅគ្រាទី ១៦ របស់មនុស្សជើងខ្លី ម្នាក់ ជើងវែង ក៏នឹងអូសជើងរបស់ខ្លួនទាញមកធ្វើជំហានឱ្យឈានទៅព្រមគ្នា; ដោយ ប្រការដូច្នេះ សូម្បីមនុស្សម្នាក់ ក៏មិនអាចប្រព្រឹត្តកន្លងនូវមនុស្សម្នាក់ទៅបាន; ការទៅរបស់មនុស្សទាំងពីរ ទើបឈ្មោះថា មានប្រមាណប៉ុនគ្នានោះឯង យ៉ាង ណា; សេចក្តីឧបមេយ្យនេះ គប្បីជ្រាបយ៉ាងនោះចុះ ។ ព្រោះថា អរូប ដូចមនុស្ស ជើងខ្លី, រូបដូចមនុស្សជើងវែង ។ កាលរូបនៅមាននោះឯង ចិត្តក្នុងអរូប (នាម)

ធម៌ ក៏កើតរលត់ ១៦ ដួង ដូចវេលាដែលមនុស្សជើងវែង ឈានទៅមួយជង, មនុស្សជើងខ្លីក្រៅនេះ ឈានទៅ ១៦ ជង ។ កាលដែលរូបរលត់ព្រមជាមួយចិត្ត ១៧ ដួង ដូចបុគ្គលជើងខ្លី អូសជំហានរបស់ខ្លួនទាញ ១៦ ជំហាន បុរសជើងវែង ឈានទៅ ១ ជំហានដូច្នោះ កាលដែលអរូបមិនលះរូប, រូបមិនលះអរូបប្រព្រឹត្តទៅ ដោយប្រមាណប៉ុនគ្នា ដូចកាលដែលបុរសពីរនាក់ មិនលះចោលនូវគ្នានឹងគ្នា ដើរ ទៅដោយប្រមាណព្រមគ្នានោះឯង ។

គប្បីជ្រាបខន្ធ ៥ ដោយការកំណត់កាលយ៉ាងនេះ ៕

## សម្តែងអំពីការកើតខណៈជាមួយគ្នា តែរលត់ខណៈផ្សេងគ្នា

ពាក្យថា **ការកើតខណៈជាមួយគ្នា តែរលត់ផ្សេងខណៈគ្នា** (របស់ខន្ធ ៥) នេះ បណ្ឌិតគប្បីសម្តែងដោយវៀរកម្មជរូបដួងចុងក្រោយ[១៥] ; ពិតណាស់ បដិសន្ធិ-ចិត្ត ជាចិត្តដួងទី ១, ចិត្តដួងទី ២ ជាភវង្គ, ដួងទី ៣ ជាភវង្គ ។ល។ ដួងទី ១៦ ក៏ជាភវង្គ ។ បណ្តាចិត្តទាំង ១៦ ដួងនោះ មួយដួងៗ មាន ៣ ខណៈ ដោយ អំណាចនៃឧប្បាទក្ខណៈ ឋិតិខណៈ និងភង្គខណៈ; ក្នុងខណៈនៃចិត្តទាំង ៣ ដួងនេះ ចិត្តមួយដួងៗ មានកម្មជរូបកើតឡើងតែ ៣០ ខណៈគត់; បណ្តាកម្មជរូបទាំងនោះ កម្មជរូបដែលតាំងឡើងក្នុងឧប្បាទក្ខណៈរបស់បដិសន្ធិចិត្ត រមែងរលត់ក្នុងឧប្បាទ-ក្ខណៈរបស់ភវង្គចិត្តដួងទី ១៧ មែនពិត ។ កម្មជរូបដែលតាំងឡើងក្នុងឋិតិខណៈ

---

[១៥] កម្មជរូបដួងចុងក្រោយនោះ គឺរាប់កម្មជរូបតាំងពីបដិសន្ធិចិត្តទៅ ១៧ ខណៈ ចិត្តភង្គខណៈរបស់ចិត្តដួងនេះ រលត់ព្រមនឹងកម្មជរូប (ចូរមើលបរិច្ឆេទទី ៤ នាមវីថិ និងរូបវីថិ) ។

របស់បដិសន្ធិចិត្ត និងរលត់ទៅក្នុងឋិតិខណៈ របស់ភវង្គចិត្តដួងទី ១៧ នោះឯង ។ កម្មជរូបដែលតាំងឡើងក្នុងភង្គខណៈរបស់បដិសន្ធិចិត្ត និងរលត់ទៅក្នុងភង្គខណៈ របស់ភវង្គចិត្តដួងទី ១៧ នោះឯង ។

ដោយអាការយ៉ាងនេះ គប្បីធ្វើភវង្គចិត្តដួងទី ២ (បដិសន្ធិចិត្តជាទី ១) ប្រកបជាមួយចិត្តដួងទី ១៧ របស់ខ្លួនៗ នោះឯងហើយពង្រីកន័យតទៅ ។ ចិត្ត ១៦ ដួង មានកម្មជរូប ១ ដួងៗ ៣ រួមជាកម្មជរូប ៤៨ រូប ដោយប្រការដូច្នេះ ។ នេះឈ្មោះថា បវេណី គឺខ្សែស្រឡាយរបស់កម្មជរូប ៤៨ រូប ។ ក៏បវេណី គឺខ្សែស្រឡាយរបស់កម្មជរូប ៤៨ រូបនេះឯង រមែងប្រព្រឹត្តទៅ សូម្បីដល់អ្នកកំពុងបរិភោគ អ្នកទំពាស៊ី, អ្នកដេកលក់, អ្នកប្រមាទទាំងពេលយប់ ទាំងពេលថ្ងៃ, ដូចខ្សែនៃទឹកស្ទឹង កំពុងប្រព្រឹត្តទៅដូច្នោះឯង ។

គប្បីជ្រាបខន្ធ ៥ **មានការកើតខណៈជាមួយគ្នា រលត់ផ្សេងខណៈគ្នាយ៉ាងនេះ ។**

## សម្តែងអំពីការកើតឡើងខណៈផ្សេងគ្នា រលត់ខណៈជាមួយគ្នា

**សេចក្តីដែលខន្ធ ៥ កើតខណៈផ្សេងគ្នា រលត់ខណៈជាមួយគ្នា ៖**

បណ្ឌិតគប្បីសម្តែងដោយកម្មជរូប ដែលកើតក្រោយបដិសន្ធិចិត្ត; បណ្ដាកម្មជរូបទាំងនោះ កាលមានវារៈចិត្ត ១៦ ដួង ក្នុងទីបំផុតនៃអាយុសង្ខារ ក៏គប្បីប្រកបកម្មជរូបជា ២ ពួក គឺកម្មជរូបដែលកើតជាមួយចិត្ត ១៦ ដួងខាងដើម ជាមួយកម្មជរូបដែលកើតជាមួយចិត្ត ១៦ ដួងខាងចុង រួមជាមួយគ្នា; ពិតមែនហើយ កម្មជរូប ៣០ គត់ដែលតាំងឡើងក្នុងឧប្បាទក្ខណៈ របស់បដិសន្ធិចិត្តក្នុងកម្មជរូប

ដែលកើតជាមួយចិត្ត ១៦ ដួងខាងដើម រមែងរលត់ក្នុងឧប្បាទក្ខណៈរបស់បឋមចិត្ត (បដិសន្ធិចិត្ត) ក្នុងកម្មជរូបដែលកើតជាមួយចិត្ត ១៦ ដួង ខាងចុងនោះឯង ។

កម្មជរូប ៣០ គត់ ដែលតាំងឡើងក្នុងឋិតិខណៈ នៃបឋមចិត្តខាងដើម, រមែងរលត់ទៅក្នុងឋិតិខណៈនៃបឋមចិត្តខាងចុងនោះឯង ។ កម្មជរូប ៣០ គត់ ដែលតាំងឡើងក្នុងភង្គខណៈរបស់បឋមចិត្តខាងដើម រមែងរលត់ទៅក្នុងភង្គខណៈរបស់បឋមចិត្តខាងចុងដូចគ្នា ។

ចំណែកកម្មជរូប ៣០ គត់ ដែលតាំងឡើងក្នុងឧប្បាទក្ខណៈរបស់ភង្គចិត្តដួងទី ២ (ដែលកើតរលត់តគ្នាមក) ។ល។ របស់ចិត្តដួងទី ១៦ ក្នុងកម្មជរូបដែលកើតពីចិត្ត ១៦ ដួងខាងដើម រមែងរលត់ទៅក្នុងឧប្បាទក្ខណៈរបស់ចុតិចិត្ត មែនពិត, ឋិតិខណៈរបស់ចិត្តដួងទី ២ នោះ រមែងរលត់ទៅក្នុងឋិតិខណៈរបស់ចុតិចិត្តនោះឯង, ដែលកើតក្នុងភង្គខណៈរបស់ចិត្តដួងទី ២ នោះ ក៏រលត់ទៅក្នុងភង្គខណៈរបស់ចុតិចិត្តដូចគ្នា ។ ខាងមុខពីនេះ ការបន្តរបស់កម្មជរូបរមែងមិនប្រព្រឹត្តទៅ; ប្រសិនបើនឹងប្រព្រឹត្តទៅទៀតសោត សត្វទាំងឡាយក៏នឹងឈ្មោះថា ជាអ្នកមិនអស់ មិនសាបសូន្យ មិនចាស់ មិនស្លាប់ ។

ម្យ៉ាងទៀត ក្នុងការរលត់ភង្គខណៈរបស់ចុតិចិត្តនេះ ពាក្យថា រូបដែលកើតឡើងក្នុងឧប្បាទក្ខណៈរបស់ចិត្តដួងទី ១ រមែងរលត់ទៅក្នុងឧប្បាទក្ខណៈរបស់ចិត្តដួងដទៃ ដោយន័យមានជាអាទិ៍ថា “រូបដែលកើតរមែងរលត់ទៅក្នុងឧប្បាទក្ខណៈ

របស់ភង្គចិត្តដួងទី ១៧” ដូច្នេះ ព្រោះខ្ញុំពោលទុកមកក្នុងអដ្ឋកថានោះ [១៦] ពាក្យនោះ រមែងផុតចាកព្រះបាលីនេះថា “**យស្ស កាយសង្ខារោ និរុជ្ឈតិ តស្ស ចិត្តសង្ខារោ និរុជ្ឈតីតិ អាមន្តា** = កាយសង្ខារកំពុងរលត់ដល់បុគ្គលណា, ចិត្តសង្ខារកំពុងរលត់ដល់បុគ្គលនោះឬ ? ឆ្លើយថា ត្រូវហើយ” [១៧] ដូច្នេះ ។ ខុសយ៉ាងណា ព្រោះកាយសង្ខារ គឺខ្យល់អស្សាសៈ និងបស្សាសៈមានចិត្តជាសមុដ្ឋាន ។ ក៏រូបដែលមានចិត្តជាសមុដ្ឋានកើតឡើងក្នុងឧប្បាទក្ខណៈរបស់ចិត្តហើយ រមែងតាំងនៅរហូតដល់ចិត្ត ១៦ ដួងដទៃទៀតកើតឡើង, រមែងរលត់ទៅព្រមជាមួយចិត្តដួងទីបំផុតទាំងអស់នៃចិត្តទាំង ១៦ ដួងនោះ; ព្រោះហេតុនោះ កាយសង្ខារនោះ កើតព្រមជាមួយចិត្តណា ក៏រលត់ព្រមជាមួយចិត្តដួងទី ១៧ ចាប់ផ្ដើមពីចិត្តនោះ មិនមែនរលត់ក្នុងឧប្បាទក្ខណៈ ឬឋិតិខណៈរបស់ចិត្តណាៗ, សូម្បីនឹងកើតក្នុងឋិតិខណៈ ឬភង្គខណៈ ក៏មិនមែនដែរ; នេះជាធម្មតារបស់រូបដែលមានចិត្តជាសមុដ្ឋាន; ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា “**អាមន្តា** = ត្រូវហើយ” ព្រោះរលត់ក្នុងខណៈជាមួយគ្នានឹងចិត្តសង្ខារដោយពិតប្រាកដ ។

ក៏ការកំណត់ខណៈ (ខណនិយម) របស់រូបដែលមានចិត្តជាសមុដ្ឋាន ដែលខ្ញុំពោលនេះជាការកំណត់ខណៈ, សូម្បីដល់រូបដែលមានកម្មជាដើមជាសមុដ្ឋាននេះ

---

[១៦] “**ឯកស្ស ចិត្តស្ស ឧប្បាទក្ខណេយេវ ឧប្បន្នំ រូបំ អញ្ញស្ស ឧប្បាទក្ខណេ និរុជ្ឈតិ** = រូបកើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្តតែមួយប៉ុណ្ណោះ តែរមែងរលត់ទៅក្នុឧប្បាទក្ខណៈនៃចិត្តដទៃ” ។

[១៧] អភិ. ។

ក៏ដូចគ្នា; ព្រោះហេតុនោះ បណ្ឌិតគប្បីប្រកបសេចក្ដីក្នុងអធិការនេះ ដោយន័យនេះប៉ុណ្ណោះថា "កម្មជរូបដែលកើតព្រមជាមួយបដិសន្ធិចិត្ត រមែងរលត់ព្រមជាមួយចិត្តដួងទី ១៧ ចាប់ផ្ដើមពីបដិសន្ធិនោះ, កម្មជរូបដែលកើតក្នុងឋិតិខណៈរបស់បដិសន្ធិចិត្ត រមែងរលត់ទៅក្នុងឧប្បាទក្ខណៈរបស់ចិត្ត ដួងទី ១៨, កម្មជរូបដែលកើតក្នុងភង្គខណៈរបស់បដិសន្ធិចិត្ត ដល់ខណៈតាំងនៅរបស់ចិត្តដួងទី ១៨ ហើយ ក៏រលត់ទៅ" ដូច្នេះ ។ ក៏ខាងមុខពីនេះទៅ ការបន្តរបស់រូបដែលមាន ឧតុជាសមុដ្ឋានប៉ុណ្ណោះ រមែងតាំងនៅក្នុងសរីរៈនោះ, សរីរៈរមែងជារបស់ដែលបុគ្គល គប្បីពោលថា "ពួកលោកចូរយកសរីរៈនេះទៅដុតចុះ" ដូច្នេះ ។ គប្បីជ្រាបថា ខន្ធ ៥ **កើតខណៈផ្សេងគ្នា រលត់ខណៈជាមួយគ្នា** ដោយប្រការដូច្នេះ ៕

## សម្ដែងអំពីការកើតព្រមគ្នា រលត់ព្រមគ្នា

ក៏ពាក្យថា **ដោយការកើតព្រមគ្នា រលត់ព្រមគ្នា** សេចក្ដីថា រូបកើតព្រមជាមួយរូប រលត់ព្រមជាមួយរូប, អរូបកើតព្រមជាមួយអរូប រលត់ព្រមជាមួយអរូប; គប្បីជ្រាបថា **ខន្ធ ៥ កើតព្រមគ្នា និងរលត់ព្រមគ្នា** ដោយប្រការដូច្នេះ ៕

## សម្ដែងអំពីការកើតខណៈផ្សេងគ្នា រលត់ខណៈផ្សេងគ្នា

**ក៏សេចក្ដីដែលខន្ធ ៥ កើតខណៈផ្សេងគ្នា រលត់ខណៈផ្សេងគ្នា** បណ្ឌិតគប្បី

សម្តែងដោយសន្តតិរូប ៤ [១៨] ; ពិតណាស់ សន្តតិរូបទាំង ៤ ក្នុងចំណែកនោះៗ របស់សរីរៈនេះ ខាងលើពីបាទជើងឡើងទៅ, ខាងក្រោមពីចុងសក់ចុះមក មានស្បែកពាសដោយជុំវិញ រមែងប្រព្រឹត្តទៅដោយសភាពជាក្រុម ជាដុំ ។ សូម្បីសន្តតិរូប ៤ នោះប្រព្រឹត្តទៅយ៉ាងនេះ ក៏គប្បីកំណត់សភាពដែលរូបទាំងនោះ មានការកើតឡើងជាដើមមិនបាន; **ដូចពួកកណ្ដៀរ ឬស្រមោចក្រហម កាលបុគ្គលសំឡឹងមើល ក៏ហាក់ដូចជាជាប់ជាមួយគ្នា, តែមិនបានជាប់ជាមួយគ្នាទេ; ព្រោះក្នុងទីជិតក្បាលរបស់ស្រមោច ១ នឹងមានក្បាលខ្លះ, ពោះខ្លះ, ជើងខ្លះ, របស់សត្វដទៃៗ ក្នុងទីជិតរបស់ពោះស្រមោច ១ វានឹងមានក្បាលខ្លះ, ពោះខ្លះ របស់ស្រមោចក្រហមដទៃៗ, ក្នុងទីជិតជើងរបស់ស្រមោច ១ ក៏នឹងមានក្បាលខ្លះ ពោះខ្លះ ជើងខ្លះ របស់ខ្លួនស្រមោចដទៃៗ យ៉ាងណា; សូម្បីសន្តតិរូប ៤ ក៏យ៉ាងនោះដែរ,** ក្នុងឧប្បាទក្ខណៈរបស់សន្តតិរូប ១ នឹងមានឧប្បាទក្ខណៈខ្លះ ឋិតិខណៈខ្លះ ភង្គខណៈខ្លះ របស់សន្តតិរូបដទៃៗ, ក្នុងឋិតិខណៈរបស់សន្តតិរូប ១ នឹងមានឧប្បាទក្ខណៈខ្លះ ឋិតិខណៈខ្លះ ភង្គខណៈខ្លះ របស់សន្តតិរូបដទៃៗ, ក្នុងភង្គខណៈរបស់សន្តតិរូប ១ នឹងមានឧប្បាទក្ខណៈខ្លះ ឋិតិខណៈខ្លះ ភង្គខណៈខ្លះ របស់សន្តតិរូបដទៃៗ ។ គប្បីជ្រាបថា **ខន្ធ ៥ កើតខណៈផ្សេងគ្នា រលត់ខណៈផ្សេងគ្នា** ក្នុងសន្តតិរូប ៤ នេះ ដោយប្រការដូច្នេះ ៕

---

[១៨] សន្តតិរូប ៤ គឺ កម្មជរូប = រូបកើតពីកម្ម ១, ចិត្តជរូប = រូបកើតពីចិត្ត ១, ឧតុជរូប = រូបកើតពីរដូវ ១, អាហារជរូប = រូបកើតពីអាហារ ១ ។

## សម្តែងអំពីខន្ធដែលជាអតីតៈជាដើម

ក៏ខន្ធ ៥ ដែលជាអតីតៈជាដើមមានទូរទុកៈ (រូបឆ្ងាយ និងរូបជិត) ជាទីបំផុតមកក្នុងព្រះបាលីទាំងអស់; **សូម្បីបច្ច័យ និងសមុដ្ឋានទាំងឡាយ** ខ្ញុំក៏ពោលទុកក្នុងពេលក្រោយដោយន័យមានជាអាទិ៍ថា **“កម្មជំ កម្មប្បច្ចយំ ឧតុសមុដ្ឋានំ** = រូបកើតពីកម្ម មានកម្មជាបច្ច័យ មានឧតុកើតពីកម្មជាសមុដ្ឋាន” [១៩] ជាដើម ។

ក៏សូម្បីខន្ធទាំង ៥ **ជាធម្មជាតិសម្រេចហើយ** ពីកម្មជាបច្ច័យ មានឧតុកើតពីកម្មជាសមុដ្ឋាន, មិនមែនជាធម្មជាតិមិនសម្រេចហើយ; **ជាសង្ខតៈប៉ុណ្ណោះ**, មិនមែនជាអសង្ខតៈ; ម្យ៉ាងទៀត ខន្ធ ៥ នោះ ឈ្មោះថា ធម្មជាតិសម្រេចហើយយ៉ាងនោះឯងមែនពិត; ព្រោះបណ្ដាសភាវធម៌ទាំងឡាយ ព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះ ជាធម៌មិនសម្រេចពីបច្ច័យ, ជាធម៌មិនកើតឡើងហើយ ។ **សួរថា** ក៏និរោធសមាបត្តិ នាម និងបញ្ញត្តិយ៉ាងណា ? ឆ្លើយថា និរោធសមាបត្តិនរណា១ មិនគប្បីហៅថា ជាលោកិយៈ លោកុត្តរៈ ឬសង្ខតៈ អសង្ខតៈ ជាធម្មជាតិសម្រេចហើយ ឬមិនសម្រេចហើយ; តែថា និរោធសមាបត្តិនោះ ជាធម្មជាតិដែលបុគ្គលឱ្យសម្រេចបាន មិនមែនមិនសម្រេចបានទេ ព្រោះជាធម៌ដែលព្រះអរិយបុគ្គល គប្បីចូលដោយសមាបត្តិ; នាម និងបញ្ញត្តិ ក៏យ៉ាងនោះដែរ; ព្រោះសូម្បីនាម និងបញ្ញត្តិនោះ រមែងមិនបានឈ្មោះដែលផ្សេងដោយលោកិយជាដើម; តែជាសភាពដែលបុគ្គលឱ្យសម្រេចហើយ មិនមែនមិនសម្រេចទេ; ព្រោះកាលបុគ្គលនឹងតាំងឈ្មោះ ទើបកាន់យកមែនពិត ៗ

---

[១៩] ច្បាប់ភូមាថា **កម្មជំ កម្មប្បច្ចយំ កម្មប្បច្ចយឧតុសមុដ្ឋានំ** ។

## សម្ដែងអត្ថនៃការវិនិច្ឆ័យខន្ធ ៥

អ្នកប្រាជ្ញលុះជ្រាបខន្ធ ៥ ដោយបកិណ្ណកៈយ៉ាងនេះហើយ ដើម្បីសេចក្ដីជំនាញនៃឈាន ក្នុងខន្ធទាំង ៥ នេះទៀត គប្បីជ្រាបន័យនៃការវិនិច្ឆ័យដោយប្រពៃ, ដោយលំដាប់ ដោយសេចក្ដីប្លែកគ្នា, ដោយមិនខ្វះ មិនលើស, ដោយឧបមា, ដោយគប្បីឃើញឧបមា ២ យ៉ាង និងដោយការសម្រេចប្រយោជន៍ដល់អ្នកឃើញ ៕

## សម្ដែងអំពីការវិនិច្ឆ័យដោយលំដាប់

ក្នុងន័យនៃការវិនិច្ឆ័យទាំង ៦ នោះ លំដាប់ក្នុងខថា **ដោយលំដាប់** នេះ មានច្រើនយ៉ាងគឺ

- **ឧប្បត្តិក្កមោ** លំដាប់នៃការកើត
- **បហានក្កមោ** លំដាប់នៃការលះបង់
- **បដិបត្តិក្កមោ** លំដាប់នៃការបដិបត្តិ
- **ភូមិក្កមោ** លំដាប់នៃភូមិ
- **ទេសនាក្កមោ** លំដាប់នៃទេសនា ។

ក្នុងលំដាប់ទាំង ៥ នោះ លំដាប់នៃការកើតឡើងមានជាអាទិ៍យ៉ាងនេះថា “**បឋមំ កលលំ ហោតិ, កលលា ហោតិ អព្ពុទំ** = រូបគ្រាដំបូងជាកលលៈ, បន្ទាប់ពីកលលៈ ជាអព្ពុទៈ” [២០] ។ លំដាប់នៃការលះ មានជាអាទិ៍យ៉ាងនេះថា

---

[២០] សំ. ស. ។

[២១] អភិ. ៧៨ ។

[២២] ម. មូ., ខុ. បដិ. ។

**“ឧស្សនេន បហាតព្វា ធម្មា, ភាវនាយ បហាតព្វា ធម្មា** = សភាវធម៌ទាំងឡាយ ដែលគប្បីលះដោយសោតាបត្តិមគ្គមាន, សភាវធម៌ទាំងឡាយដែលគប្បីលះដោយភាវនា គឺអរិយមគ្គខាងលើ ៣ រមែងមាន”[២១] ។ លំដាប់នៃការបដិបត្តិមានជាអាទិ៍យ៉ាងនេះថា **“សីលវិសុទ្ធិ ចិត្តវិសុទ្ធិ”**[២២] ។ លំដាប់នៃភូមិ មានជាអាទិ៍យ៉ាងនេះថា **“ ធម៌ជាកាមាវចរ ជារូបាវចរ”**[២២] ។ លំដាប់នៃទេសនា មានជាអាទិ៍យ៉ាងនេះថា **“សតិប្បដ្ឋាន ៤ សម្មប្បធាន ៤”**[២៤] ឬថា **“ទានកថា សីលកថា”** ដូច្នេះ ។ បណ្ដាលំដាប់ទាំង ៥ នោះ ក្នុងទីនេះលំដាប់នៃការកើតឡើង រមែងមិនគួរឡើយ ព្រោះខន្ធជាសភាវៈមិនកើតឡើង ដោយការកំណត់សេចក្ដីបន្តមកដូចរូបកលលៈជាដើម; លំដាប់នៃការលះមិនគួរ ព្រោះសភាពដែលខន្ធជាកុសលនិងអព្យាក្រឹតដែលព្រះអរិយៈមិនគប្បីលះ; លំដាប់នៃការបដិបត្តិក៏មិនគួរ ព្រោះខន្ធដែលជាអកុសលជាធម្មជាតិមិនគប្បីបដិបត្តិ លំដាប់នៃភូមិក៏មិនគួរ ព្រោះវេទនាជាដើម ជាធម៌រាប់បញ្ចូលក្នុងភូមិ ៤ ។

តែថា **លំដាប់នៃទេសនា** រមែងគួរ, ព្រោះថា ព្រះមានព្រះភាគជាម្ចាស់ព្រះអង្គប្រាថ្នាក្នុងប្រយោជន៍ទ្រង់មានព្រះបំណងរំដោះវេនេយ្យជនណា ដែលធ្លាក់ទៅក្នុងការប្រកាន់ខន្ធ ៥ ថាជាអត្តា ចាកការប្រកាន់ថាជាអត្តា ដោយការសម្ដែងញែក **ឃនៈ** (ដុំ) ដែលប្រជុំគ្នា ដើម្បីសេចក្ដីកាន់យកដោយងាយរបស់ជននោះ ទើបព្រះភគវាទ្រង់សម្ដែងរូបក្ខន្ធដ៏គ្រោតគ្រាតមុន ដែលជាអារម្មណ៍របស់វិញ្ញាណ មាន

---

[២៣] ទី. បា. ។

[២៤] ទី. សី. ១៤, ម. មូ. ។

ចក្ខុវិញ្ញាណជាដើម ដោយមិនផ្សេងគ្នា ។ តអំពីនោះ ក៏ទ្រង់សម្ដែងវេទនាដែលដឹងព្រម ដែលមានរូបគួរប្រាថ្នា និងមិនគួរប្រាថ្នាជាអារម្មណ៏, ទ្រង់សម្ដែងសញ្ញាដែលកាន់ យកដោយអាការៈនៃអារម្មណ៏របស់វេទនាយ៉ាងនេះថា **"យំ វេទេតិ តំ សញ្ជានាតិ** = សោយនូវអារម្មណ៏ណា ក៏ចាំបាននូវអារម្មណ៏នោះ" ទ្រង់សម្ដែងសង្ខារទាំងឡាយដែលតាក់តែងដោយអំណាចនៃសញ្ញា, ទ្រង់សម្ដែងវិញ្ញាណដែលជាទីអាស្រ័យ និងជាធំរបស់ខន្ធមានវេទនាខន្ធជាដើមទាំងនោះ ។ គប្បីជ្រាបន័យនៃការវិនិច្ឆ័យដោយលំដាប់ដូច្នេះសិន ៕

## សម្ដែងអំពីសេចក្ដីប្លែកគ្នា

ខថា **ដោយសេចក្ដីប្លែកគ្នា** គឺសេចក្ដីប្លែកគ្នានៃខន្ធ និងឧបាទានក្ខន្ធ; ក៏អ្វីទៅជាការប្លែកគ្នានៃខន្ធ និងឧបាទានក្ខន្ធទាំងនោះ ? បណ្ដាខន្ធទាំងនេះ ខន្ធទាំងឡាយត្រាស់ទុកដោយមិនប្លែកគ្នាទេ, ឧបាទានក្ខន្ធទាំងឡាយ ត្រាស់ទុកឱ្យប្លែកគ្នា ដោយជាខន្ធមានអាសវៈ និងជាទីតាំងរបស់ឧបាទាន, ដូចយ៉ាងដែលត្រាស់ថា **"ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងខន្ធ ៥ និងឧបាទានក្ខន្ធ ៥ ទាំងនេះ, អ្នកទាំងឡាយចូរស្ដាប់; ម្នាលភិក្ខុទាំងឡាយ ក៏ខន្ធ ៥ តើយ៉ាងណា ? ម្នាលភិក្ខុទាំងឡាយ រូបយ៉ាងណានីមួយដែលជាអតីតៈ អនាគត និងបច្ចុប្បន្ន ។បេ។ ឬថា រូបជិត, ម្នាលភិក្ខុទាំងឡាយ នេះហៅថា រូបក្ខន្ធ; វេទនាយ៉ាងណានីមួយ ។បេ។ វិញ្ញាណយ៉ាងណានីមួយ ដែលជាអតីតៈ អនាគត ឬបច្ចុប្បន្ន ។បេ។ ឬវិញ្ញាណជិត, ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិញ្ញាណក្ខន្ធ; ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងនេះ យើងហៅថា ខន្ធ ៥ ។ ម្នាលភិក្ខុទាំងឡាយ ក៏ឧបាទានក្ខន្ធ ៥ តើយ៉ាងណា ? ម្នាលភិក្ខុទាំងឡាយ រូបយ៉ាង ណានីមួយដែលជាអតីតៈ**

**អនាគត និងបច្ចុប្បន្ន ។លៗ។ ឬរូបជិត មានអាសវៈជាទីតាំង នៃឧបាទាន, នេះហៅថា ឧបាទានក្ខន្ធ គឺរូប; វេទនាយ៉ាងណានីមួយ ។លៗ។ វិញ្ញាណយ៉ាងណានីមួយដែលជាអតីតៈ អនាគត ឬបច្ចុប្បន្ន ។លៗ។ ឬវិញ្ញាណជិត មានអាសវៈជាទីតាំងនៃឧបាទាន, ធម៌ទាំងនេះ តថាគតហៅថា ឧបាទានក្ខន្ធ គឺវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ ទាំងនេះ ហៅថា ឧបាទានក្ខន្ធ ៥”**[២៥] ។

ម្យ៉ាងទៀត ក្នុងខន្ធ ៥ និងឧបាទានក្ខន្ធទាំង ៥ នេះ នាមក្ខន្ធ ៤ មានវេទនាជាដើម ដែលមិនមានអាសវៈក៏មាន, ដែលមានអាសវៈក៏មាន យ៉ាងណា, រូបក្ខន្ធមិនមែនជាយ៉ាងនោះទេ; ក៏ព្រោះសេចក្ដីដែលរូបនេះ គួរជាខន្ធ ដោយអត្ថថា ជាគំនរ, ព្រោះហេតុដូច្នោះ ទើបត្រាស់ទុកក្នុងពួកខន្ធទាំងឡាយ ក៏ព្រោះហេតុដែលខន្ធទាំងនោះ គួរជាឧបាទានក្ខន្ធ ដោយអត្ថថា ជាគំនរ និងដោយអត្ថថា មានអាសវៈ, ព្រោះហេតុដូច្នោះ ទើបត្រាស់ខន្ធពួកនោះទុកក្នុងឧបាទានក្ខន្ធ; ចំណែកនាមក្ខន្ធមានវេទនាជាដើម ដែលមិនមានអាសវៈ ត្រាស់ទុកក្នុងពួកខន្ធ, ដែលមានអាសវៈ ត្រាស់ទុកក្នុងឧបាទានក្ខន្ធ; ក៏ក្នុងខថា **ឧបាទានក្ខន្ធ** នេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ខន្ធដែលមានឧបាទានជាអារម្មណ៍ ឈ្មោះថា ឧបាទានក្ខន្ធ; តែក្នុងអធិការនេះ ព្រះអង្គទ្រង់ប្រាថ្នារួមខន្ធទាំងនោះ សូម្បីទាំងអស់ថាជាខន្ធ ៕

## សម្ដែងអំពីសេចក្ដីមិនខ្វះ មិនលើស

ក៏ខថា **ដោយសេចក្ដីមិនខ្វះ មិនលើស** នេះ **សួរថា** ព្រោះហេតុអ្វី ព្រះមានព្រះ

[២៥] សំ. ខន្ធ. ។

ភាគជាម្ចាស់ទើបត្រាស់ថា ខន្ធមានតែ ៥ ប៉ុណ្ណោះ មិនខ្វះ មិនលើសដូច្នេះ ។ ឆ្លើយថា ព្រោះទ្រង់សង្គ្រោះសង្ខតធម៌ទាំងអស់ ដែលមានចំណែកស្មើគ្នា ចូលជាពួកជាមួយគ្នា ព្រោះវត្ថុជាគ្រឿងយឹតយូរ គឺខ្លួន និងរបស់ដែលជាប់ដោយខ្លួននេះ មានខន្ធ ៥ ជាយ៉ាងក្រៃលែង និងព្រោះសេចក្ដីដែលធម៌ដទៃៗ ក៏មិនក្រៅពីខន្ធ ៥ នោះទេ ។

ពិតមែន ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សង្គ្រោះសង្ខតធម៌ មានប្រភេទមិនមែនតិច ចូលដោយអំណាចន័យដែលមានចំណែកស្មើគ្នា រូបក៏ជាខន្ធមួយដោយអំណាចនៃការសង្គ្រោះរូប ដែលមានចំណែកស្មើគ្នា ចូលជាពួកជាមួយគ្នា, វេទនា ក៏ជាខន្ធមួយដោយអំណាចនៃការសង្គ្រោះវេទនា ដែលមានចំណែកស្មើគ្នាទុកជាពួកជាមួយគ្នា; សូម្បីក្នុងសញ្ញាខន្ធជាដើមក៏ន័យនេះដែរ; ព្រោះហេតុដូច្នោះទើបត្រាស់ខន្ធថា មានតែ ៥ ប៉ុណ្ណោះ ព្រោះទ្រង់សង្គ្រោះសង្ខតធម៌ទាំងអស់ ដែលមានចំណែកស្មើគ្នាទុកជាពួក ជាមួយគ្នា ។ម្យ៉ាងទៀត វត្ថុនៃការប្រកាន់ថា ជាខ្លួន ជារបស់ជាប់ដោយខ្លួននេះ គឺខន្ធ ៥ នេះ មានរូបជាដើម ជាយ៉ាងក្រៃលែង; សេចក្ដីនេះ សមនឹងព្រះតម្រាស់ដែលត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ទិដ្ឋិ (សេចក្ដីយល់ឃើញខុស) អាស្រ័យរូប ហើយប្រកាន់រូប រមែងកើតឡើងយ៉ាងនេះថា **ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តា វេទនាយ ។បេ។ សញ្ញាយ ។បេ។ សង្ខារេសុ ។បេ។ វិញ្ញាណេ សតិ, វិញ្ញាណំ ឧបាទាយ វិញ្ញាណំ អភិនិវេសស្ស ឯវំ ទិដ្ឋិ ឧប្បជ្ជតិ ឯតំ មម ឯសោហមស្មិ**

**ឯសោ មេ អត្តា** = នេះជារបស់យើង នេះជាយើង នេះជាអត្តារបស់យើង' ; កាលបើវេទនាមាន ។ល។ កាលបើសញ្ញាមាន ។ល។ កាលបើសង្ខារទាំងឡាយមាន ។ល។ កាលបើវិញ្ញាណមាន ទិដ្ឋិអាស្រ័យវិញ្ញាណប្រកាន់វិញ្ញាណ រមែងកើតឡើងយ៉ាងនេះថា 'នេះរបស់យើង, នេះជាយើង, នេះជាអត្តារបស់យើង"[២៦] ដូច្នេះ ។ ព្រោះហេតុនោះ ទើបត្រាស់ខន្ធទុក ៥ ប៉ុណ្ណោះ សូម្បីព្រោះវត្ថុនៃការប្រកាន់ខ្លួន និងរបស់ជាប់ជាមួយខ្លួន ក៏មានខន្ធ ៥ នេះ ជាយ៉ាងក្រៃលែង ។

ម្យ៉ាងទៀត ធម្មក្ខន្ធ ៥ មានសីលក្ខន្ធជាដើមដទៃៗ ណាដែលត្រាស់ទុក, សូម្បីធម្មក្ខន្ធទាំងនោះ[២៧] ក៏ដល់ការរួមចុះក្នុងខន្ធ ៥ នេះ ព្រោះសេចក្ដីដែលខន្ធរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ; ព្រោះហេតុនោះ ទើបត្រាស់ថា ខន្ធមាន ៥ ប៉ុណ្ណោះ ព្រោះសេចក្ដីដែលធម៌ដទៃៗ មិនផុតចាកខន្ធនោះ គប្បីជ្រាបន័យនៃការវិនិច្ឆ័យដោយ **មិនខ្វះ មិនលើស** មានប្រការដូច្នេះ ។

## សម្ដែងអំពីសេចក្ដីឧបមា

ក៏ក្នុងខថា **ដោយសេចក្ដីឧបមា** នេះ រូបូបាទានក្ខន្ធ ប្រៀបដូចរោគ ព្រោះជាទីនៅរបស់វិញ្ញាណូបាទានក្ខន្ធ ដែលប្រៀបដូចមនុស្សឈឺ ដោយអំណាចនៃវត្ថុ ទ្វារ និងអារម្មណ៍, វេទនូបាទានក្ខន្ធប្រៀបដូចការឈឺចាប់ ព្រោះជាទោសជាតិបៀតបៀន, សញ្ញូបាទានក្ខន្ធប្រៀបដូចសមុដ្ឋានរបស់ជម្ងឺ ព្រោះជាដែនកើតនៃវេទនា

---

[២៦] សំ. ខន្ធ. ។

[២៧] សីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិខន្ធ វិមុត្តិញ្ញាណទស្សនក្ខន្ធ ។

ដែលសម្បយុត្តដោយកិលេសមានរាគៈជាដើម ដោយអំណាចនៃកាមសញ្ញាជាដើម នោះទាំងស្រុង, សង្ខារូបាទានក្ខន្ធ ប្រៀបដូចសេពអសប្បាយ ព្រោះជាដើមហេតុនៃការឈឺ គឺតួវេទនា, សមដូចដែលត្រាស់ទុកថា **“រូបំ រូបត្តាយ សង្ខតំ អភិ-សង្ខរោន្តិ ឲបេឲ ភិក្ខវេ តស្មា សង្ខារាតិ វុច្ចន្តិ** = ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា សង្ខារ ព្រោះអត្ថថា តាក់តែងសង្ខតធម៌ គឺរូប ដោយសេចក្តីជារូប តាក់តែងសង្ខតធម៌ គឺវេទនា ដោយសេចក្តីជាវេទនា តាក់តែងសង្ខតធម៌ គឺសញ្ញា ដោយសេចក្តីជាសញ្ញា តាក់តែងសង្ខតធម៌ គឺសង្ខារទាំងឡាយ ដោយសេចក្តីជាសង្ខារ តាក់តែងសង្ខតធម៌ គឺវិញ្ញាណ ដោយសេចក្តីជាវិញ្ញាណ” [២៨] ។ ម្យ៉ាងទៀត កាយវិញ្ញាណដែលជាវិបាកសហគតៈដោយទុក្ខកើតឡើងហើយ ព្រោះការធ្វើ គឺការសន្សំអកុសលកម្មទុកហើយ ព្រោះហេតុនោះ វិញ្ញាណូបាទានក្ខន្ធ ទើបប្រៀបដូចមនុស្សឈឺ ព្រោះភាពមិនរួចផុតដោយការឈឺ គឺតួវេទនា ។

ម្យ៉ាងទៀត ឧបាទានក្ខន្ធទាំង ៥ នោះ មានឧបមាដូចបុគ្គលអ្នកត្រាច់ទៅ, ដូចការណៈ គឺហេតុ, ដូចកំហុស, ដូចមនុស្សបង្កហេតុ, ដូចអ្នកមានកំហុស [២៩] និងប្រៀបដូចភាជនៈ, ដូចភោជន, ដូចម្ហូប, ដូចអ្នកទំពាអាហារ, ដូចអ្នកបរិភោគ; គប្បីជ្រាបន័យនៃការវិនិច្ឆ័យខន្ធ ៥ ដោយសេចក្តីឧបមាដូចពណ៌នាមកនេះឯង ៕

---

[២៨] សំ. ខ. ។

[២៩] គង់នឹងប្រៀបធៀបថា រូប ដូចបុគ្គលអ្នកត្រាច់ទៅ, វេទនា ដូចការធ្វើរបស់បុគ្គលនោះ, សញ្ញា ដូចសេចក្តីខុស (សញ្ញាវិបល្លាស), សង្ខារ ដូចអ្នកបង្កហេតុ, វិញ្ញាណ ដូចអ្នកមានកំហុស បានទទួលទោសយ៉ាងណាក្តី លោកមិនអធិប្បាយទុកទេ (អ្នកប្រែជាន់មុន) ។

## សម្ដែងអំពីការគប្បីឃើញដោយឧបមា ២ យ៉ាង

ខថា **ដោយគប្បីឃើញដោយឧបមា ២ យ៉ាង** នេះ បណ្ឌិតគប្បីជ្រាបន័យនៃការវិនិច្ឆ័យក្នុងខន្ធ ៥ នេះ សូម្បីដោយឧបមា ២ យ៉ាងនេះ គឺដោយសង្ខេប និងដោយពិស្ដារ ។ ក៏កាលពោលដោយសង្ខេប ឧបាទានក្ខន្ធ ៥ បណ្ឌិតគប្បីឃើញដោយសេចក្ដីដែលដូចជាសត្រូវអ្នកយាដាវតាមន័យដែលត្រាស់ ទុកហើយក្នុង**អាសីវិសូបមសូត្រ**, ដោយជាភារៈ (របស់ធ្ងន់) ដោយអំណាចនៃ**ភារសូត្រ**, ដោយភាពជាអ្នកទំពាស៊ី ដោយអំណាចនៃ**ខជ្ជនីយបរិយាយសូត្រ** និងដោយសេចក្ដីជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ជាសង្ខតៈ ជាអ្នកសម្លាប់ដោយអំណាចនៃ**យមកសូត្រ** ។ ចំណែកដោយសេចក្ដីពិស្ដារក្នុងឧបាទានក្ខន្ធ ៥ នេះ គប្បីឃើញរូប ដូចដុំពពុះទឹក, គប្បីឃើញវេទនា ដូចក្រពេញទឹក, គប្បីឃើញសញ្ញា ដូចថ្ងៃបណ្ដើរកូន គប្បីឃើញសង្ខារទាំងឡាយ ដូចដើមចេក, គប្បីឃើញវិញ្ញាណ ដូចជាកលមាយា, សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា ៖

**ផេណបិណ្ឌូបមំ រូបំ  វេទនា បុព្វុឡូបមា**
**មរីចិកូបមា សញ្ញា  សង្ខារា កទលូបមា**
**មាយូបមញ្ច វិញ្ញាណំ  ទេសិតា អិច្ចពន្ធុនា**

ព្រះពុទ្ធជាម្ចាស់ ព្រះអង្គមានផៅពង្សដូច
ជាព្រះអាទិត្យ ទ្រង់សម្ដែងរូបប្រៀបដូចដុំពពះទឹក,
វេទនា ប្រៀបដូចក្រពេញទឹក សញ្ញា ប្រៀបដូចថ្ងៃ
បណ្ដើរកូន, សង្ខារទាំងឡាយ ប្រៀបដូចដើមចេក

និងវិញ្ញាណ ប្រៀបដូចកលមាយា [៣០] ។

ក្នុងព្រះបាលីទាំងនោះ គប្បីជ្រាបន័យឧបាទានក្ខន្ធ ៥ មានរូបជាដើម ដូចជាដុំពពុះទឹកជាដើមយ៉ាងនេះ ៖ ដូចយ៉ាងថា ដុំពពុះទឹកជារបស់មិនមានសារៈ យ៉ាងណា, រូបក៏យ៉ាងនោះដែរ មិនមានសារៈ ព្រោះវៀរចាកសារៈ គឺភាពជារបស់ទៀង, វៀរចាកសារៈ គឺភាពយឺនយូរ, វៀរចាកសារៈ គឺភាពជាអត្តាដោយពិត ។ ម្យ៉ាងទៀត ដុំនៃពពុះទឹកនោះ នរណា។ មិនអាចដើម្បីនឹងកាន់យក ដោយគិតថា "យើងនឹងធ្វើបាត្រ ឬថាសដោយដុំនៃពពុះទឹកនេះ" ដូច្នេះ, សូម្បីកាន់យក ក៏មិនឱ្យសម្រេចប្រយោជន៍នោះបាន រមែងបែកធ្លាយទៅ យ៉ាងណា, រូបក៏យ៉ាងនោះដែរ នរណា។ មិនអាចនឹងកាន់យកថា "រូបនេះជារបស់ទៀង, យឺតយូរ" ឬថា "រូបនេះជា យើង រូបនេះជារបស់យើង" , សូម្បីកាន់យករូប ក៏មិនតាំងនៅយ៉ាងនោះ, រមែងជារបស់មិនទៀង, ជាទុក្ខ, ជាអនត្តា, ជាអសុភទាំងអស់; ព្រោះហេតុនោះ រូបនោះទើបហាក់ដូចជាដុំនៃពពុះទឹកនោះមែនពិត ។

ម្យ៉ាង ដុំនៃពពុះទឹកមានតូច មានធំ ជាក្រុមជាប់គ្នា ដោយទីតមិនមែនតិច ជាទីអាស្រ័យនៅរបស់សត្វមានពស់ទឹកជាដើមច្រើន យ៉ាងណា, សូម្បីរូបក៏យ៉ាងនោះដែរ គឺមានបែបតូច បែបធំជាក្រុមជាប់តគ្នាដោយទីតមិនមែនតិច; ត្រកូលនៃកិមិជាតិ (ដង្កូវ) ៨០ ត្រកូលរមែងនៅពពាក់ពពូនក្នុងរូបដែលមានសភាពបែបនេះមែនពិត; រូបនោះ។ ឯង ជាផ្ទះកើតខ្លះ, ជាវច្ចកុដិខ្លះ ជារោងព្យាបាលខ្លះ, ជាព្រៃស្មសានខ្លះ របស់ត្រកូលកិមិជាតិទាំងនោះ; ពួកត្រកូលកិមិជាតិទាំងនោះ នឹងមិន

---

[៣០] សំ. ខន្ធ. ។

នៅក្នុងទីដទៃហើយធ្វើការចេញចាកផ្ទៃជាដើម; រូបនោះ ក៏ឈ្មោះថា ហាក់ដូចជាដុំនៃពពុះទឹក ដោយប្រការដូច្នេះឯង ។

ម្យ៉ាងទៀត ដុំនៃពពុះទឹកផ្ដើមឡើងមានប្រមាណប៉ុនផ្លែពុទ្រាហើយ មានប្រមាណប៉ុនកំពូលភ្នំដោយលំដាប់ក៏មាន យ៉ាងណា, សូម្បីរូបក៏យ៉ាងនោះដែរ ផ្ដើមឡើងមានប្រមាណប៉ុនកលលៈប៉ុណ្ណោះ ហើយមានប្រមាណមួយព្យាម ដោយលំដាប់ក៏មាន, មានប្រមាណប៉ុនវត្ថុទាំងឡាយមានកំពូលភ្នំជាដើម ដោយអំណាចនៃសត្វមានគោ ក្របី និងដំរីជាដើមក៏មាន, មានប្រមាណច្រើនរយយោជន៍ ដោយអំណាចនៃសត្វមានត្រី និងអណ្ដើកជាដើមក៏មាន រូបនោះ ក៏ឈ្មោះថា ដូចជាដុំនៃពពុះទឹកដោយប្រការយ៉ាងនេះឯង ។

ម្យ៉ាងវិញទៀត ដុំនៃពពុះទឹកគ្រាន់តែតាំងឡើងរមែងបែកទៅក៏មាន, តាំងឡើងនៅតូចមួយ រមែងបែកទៅក៏មាន; កាលមិនបែកទៅក្នុងចន្លោះ, តែដល់សមុទ្រហើយ ក៏រមែងត្រូវបែកទៅដោយមិនត្រូវសង្ស័យយ៉ាងណា, រូបក៏យ៉ាងនោះដែរ រមែងបែកទៅក្នុងពេលជាកលលៈក៏មាន, រមែងបែកទៅក្នុងពេលជាអព្ពុទៈជាដើមក៏មាន; តែកាលមិនបែកទៅក្នុងចន្លោះ សូម្បីអស់រយនៃឆ្នាំក៏ដោយ សម្រាប់សត្វអ្នកមានប្រមាណនៃអាយុមួយរយឆ្នាំ ក៏ត្រូវបែកធ្លាយទៅ ដោយពិតប្រាកដ; រមែងជាចុណ្ណវិចុណ្ណ (ខ្ទេចខ្ទី) ទៅក្នុងមាត់នៃសេចក្ដីស្លាប់ សូម្បីដោយអាការៈយ៉ាងនេះ រូបក៏ឈ្មោះថា ដូចជានឹងដុំនៃពពុះទឹក ។

ម្យ៉ាងវិញសោត ក្រពេញទឹកមិនមានខ្លឹម យ៉ាងណា, សូម្បីវេទនាក៏យ៉ាងនោះដែរ; ក៏ក្រពេញទឹកមិនមានកម្លាំង ចូលដល់ភាពជារបស់ដែលកាន់យកមិនបាន

យ៉ាងណា, នរណា។ មិនអាចកាន់យកក្រពេញទឹកដើម្បីធ្វើផែនក្តា ឬអាសនៈបាន, សូម្បីកាន់យកហើយ វាក៏នឹងបែកទៅភ្លាម យ៉ាងណា, សូម្បីវេទនា ក៏យ៉ាងនោះដែរ ជារបស់មិនមានកម្លាំង ជារបស់កាន់យកមិនបាន, នរណា។ មិនអាចប្រកាន់វេទនាថា ទៀង ឬយឺនយូរ, សូម្បីកាន់យកហើយ ក៏មិនតាំងនៅដូចយ៉ាងនោះបាន; សូម្បីវេទនាដែលបុគ្គលកាន់យកមិនបានយ៉ាងនេះ ឈ្មោះថា ដូចជាក្រពេញទឹក ។

ពុំនោះសោតទេ ក្រពេញទឹករមែងកើតឡើង និងបែកធ្លាយទៅក្នុងលំដាប់នៃទឹកនោះ។ ជារបស់មិនតាំងនៅយូរ យ៉ាងណា, សូម្បីវេទនា ក៏យ៉ាងនោះដែររមែងកើតឡើង និងរលត់ទៅ, ជារបស់មិនតាំងនៅយូរ គឺវេទនានោះដែលបណ្ឌិតគប្បីរាប់បានសែនកោដិខណៈ កើតឡើងហើយ ក៏រលត់ទៅមួយជួរខណៈនៃការផ្ទាត់ម្រាមដៃមួយដង ។

បើពុំដូច្នោះទេ ក្រពេញទឹកអាស្រ័យហេតុ ៤ គឺ ផ្ទៃទឹក ១, ដំណក់ទឹក ១, ការទទឹកនៃទឹក ១ និងខ្យល់ធ្វើឱ្យព្រោង ១, ទើបកើតឡើងយ៉ាងណា សូម្បីវេទនាក៏យ៉ាងនោះដែរ អាស្រ័យហេតុ ៤ យ៉ាង គឺ វត្ថុ ១ អារម្មណ៍ ១ គ្រឿងចងនៃកិលេស ១ និងការប៉ះខ្ទប់របស់ផស្សៈ ១ ទើបកើតឡើង; វេទនានោះ ឈ្មោះថាប្រៀបដូចជាក្រពេញទឹក ដោយប្រការដូច្នេះឯង ។

**សូម្បីសញ្ញា** ក៏ឈ្មោះថា **ប្រៀបដូចជាថ្ងៃបណ្តើរកូន** ដោយអត្ថថា មិនមានសារៈ = **អសារកដ្ឋេន**, និងដោយអត្ថថា ចូលដល់ភាវៈជារបស់ដែលបុគ្គលកាន់យកមិនបាន = **អគយ្ហុបគដ្ឋេន**; ព្រោះនរណា។ មិនអាចកាន់យកថ្ងៃបណ្តើរកូននោះមក ដើម្បីផឹក ឬដើម្បីងូត ឬក៏ដាក់ឱ្យពេញភាជនៈបាន; ម្យ៉ាងទៀត ថ្ងៃបណ្តើរកូន

រមែងប្រែប្រួលទៅ, គឺរមែងប្រាកដដូចកម្លាំងរលកទឹកកើតឡើងឯង យ៉ាងណា; សូម្បីសញ្ញាដែលផ្សេងដោយការសម្គាល់ថាមានពណ៌ខៀវជាដើម ក៏យ៉ាងនោះដែរ រមែងខុសប្លែកប្រែប្រួលទៅ ដើម្បីត្រូវការឱ្យសោយអារម្មណ៍ របស់ពណ៌ខៀវជាដើម ក៏យ៉ាងនោះដែរ ។

ម្យ៉ាងវិញទៀត ថ្ងៃបណ្ដើរកូនរមែងកន្លង (បោកបញ្ឆោត) មហាជនឱ្យពោលថា "ទីនោះហាក់ដូចបឹងពេញ ដូចស្ទឹងពេញប្រៀបប្រាកដហើយ" យ៉ាងណា, សូម្បីសញ្ញាក៏យ៉ាងនោះដែរ រមែងកន្លង (បោកបញ្ឆោត) ឱ្យពោលថា "នេះពណ៌ខៀវ នេះស្រស់ស្អាត នេះជាសុខ នេះជារបស់ទៀង" ។ សូម្បីក្នុងពណ៌លឿងជាដើមក៏ន័យនេះដែរ ។ សញ្ញាឈ្មោះថា ប្រៀបដូចថ្ងៃបណ្ដើរកូន សូម្បីដោយការបោកបញ្ឆោតផ្សេងៗ មានប្រការដូច្នេះ ។

សូម្បីសង្ខារទាំងឡាយ ក៏ឈ្មោះថា **ប្រៀបដូចដើមចេក** ព្រោះអត្ថថា មិនមានសារៈ (**អសារកដ្ឋេន**) និងដោយអត្ថថា គប្បីកាន់យកមិនបាន; ដូចយ៉ាងថា នរណាៗ មិនអាចកាន់យកអ្វីៗ ពីដើមចេកតូចនាំទៅធ្វើប្រយោជន៍ដល់សម្ភារៈទាំងឡាយ មានបង្កង់ និងដំបូលជាដើម, សូម្បីបង្អោនចូលទៅហើយ ក៏មិនមានដោយប្រការដូច្នេះ យ៉ាងណា, សូម្បីសង្ខារទាំងឡាយ ក៏យ៉ាងនោះដែរ នរណាៗ មិនអាចដើម្បីកាន់យក ដោយអំណាចនៃភាពទៀងជាដើម, សូម្បីកាន់យកហើយ ក៏មិនប្រព្រឹត្តទៅដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ដើមចេករមែងជាទីប្រជុំរបស់ស្រទាប់ច្រើន យ៉ាងណា, សូម្បីសង្ខារក្ខន្ធ ក៏ជាទីប្រជុំរបស់ធម៌ច្រើនយ៉ាងដូច្នោះដែរ ។ ម្យ៉ាងវិញទៀត ដើមចេក

មានលក្ខណៈផ្សេងគ្នា គឺពណ៌របស់ធាងស្លឹកខាងក្រៅម្យ៉ាង, ពណ៌របស់ស្រទាប់ខាងក្នុង១ បន្ទាប់ពីនោះ ក៏ម្យ៉ាងយ៉ាងណា; សូម្បីសង្ខារក្ខន្ធ ក៏យ៉ាងនោះដែរ គឺទ្រង់ប្រមូលលក្ខណៈរបស់ផស្សៈទុកម្យ៉ាង, កងនៃធម៌ មានចេតនាជាដើមទុកម្យ៉ាង ហើយត្រាស់ថា ជាសង្ខារក្ខន្ធប៉ុណ្ណោះ សង្ខារក្ខន្ធនោះ ឈ្មោះថា ប្រៀបដូចដើមចេក ដោយប្រការដូច្នេះឯង ។

**សូម្បីវិញ្ញាណក្ខន្ធ** ក៏ឈ្មោះថា **ប្រៀបដូចកលមាយា** ព្រោះអត្ថថា មិនមានសារៈ និងព្រោះអត្ថថា ចូលទៅកាន់យកមិនបាននោះឯង = **អគយ្ហូបគន្តេន**; ដូចមាយាជារបស់ប្រែប្រួលមានការប្រាកដឡើងរហ័ស យ៉ាងណា, វិញ្ញាណក៏យ៉ាងនោះដែរ; ព្រោះវិញ្ញាណនោះ ជារបស់ប្រែប្រួលលឿនជាង ប្រាកដលឿនសូម្បីជាងកលមាយានោះ; ព្រោះថា មាយានោះរមែងដូចជាមនុស្សមកហើយ ដើរទៅ ឈរនៅ អង្គុយនៅ ដោយចិត្តដួងនោះនុ៎ះឯង; តែចិត្តក្នុងវេលាដើរមក ក៏ម្យ៉ាង, ក្នុងវេលាដើរទៅ ក៏ម្យ៉ាង; សូម្បីយ៉ាងនេះ វិញ្ញាណទើបឈ្មោះថា ប្រៀបដូចកល-មាយា ។

ម្យ៉ាងទៀត មាយារមែងកន្លង (បោកបញ្ឆោត) មហាជនឱ្យកាន់យកវត្ថុយ៉ាងណានីមួយថា “នេះមាស នេះប្រាក់ នេះកែវមុក្តា” ជាដើម; សូម្បីវិញ្ញាណក៏បោកបញ្ឆោតមហាជន ឱ្យប្រកាន់ធ្វើដូចជាកំពុងមក កំពុងទៅ កំពុងឈរ កំពុងអង្គុយ ដោយចិត្តដួងនោះ១ ឯង, តែចិត្តក្នុងវេលាមក ក៏ម្យ៉ាង, ក្នុងវេលាទៅ ក៏ម្យ៉ាង; សូម្បីយ៉ាងនេះ វិញ្ញាណ ក៏ឈ្មោះថា **កលមាយា** ។

ម្យ៉ាងវិញទៀត ពោលដោយពិសេស បណ្ឌិតគប្បីជ្រាបអជ្ឈត្តិករូប (រូប

ខាងក្នុង) ដែលជាសុភារម្មណ៍ក្តី ដែលជាអារម្មណ៍ប្រសើរក្តី ថាជាអសុភ (មិនស្អាត); គប្បីឃើញវេទនាថាជាទុក្ខ ព្រោះមិនផុតចាកភាពជាទុក្ខទាំង ៣, គប្បីឃើញសញ្ញា និងសង្ខារទាំងឡាយថាជាអនត្តា ព្រោះភាពជារបស់ដែលបុគ្គលគប្បីឱ្យតាំងនៅមិនបាន គប្បីឃើញវិញ្ញាណថា ជារបស់មិនទៀង ព្រោះមានការកើតឡើង និងសាបសូន្យជាធម្មតា; **កាលបុគ្គលឃើញយ៉ាងនេះ ទើបសម្រេចប្រយោជន៍**, ក៏ការសម្រេចប្រយោជន៍ ២ យ៉ាង រមែងមានដល់បុគ្គលអ្នកឃើញដោយអំណាចនៃសេចក្តីដោយសង្ខេប និងដោយពិស្តារ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យសេចក្តីដោយសង្ខេប និងដោយពិស្តារនោះ; តើយ៉ាងណា ? **គឺពោលដោយសង្ខេបជាមុនសិន** កាលបុគ្គលកំពុងឃើញឧបាទានក្ខន្ធ ៥ ដោយសភាពជាសត្រូវ មានសត្រូវដែលកំពុងយារដាវជាដើម រមែងមិនក្តៅក្រហាយព្រោះខន្ធ ៥; **ក៏កាលពោលដោយពិស្តារ** កាលបុគ្គលឃើញនូវអារម្មណ៍មានរូបារម្មណ៍ជាដើម ដោយសភាវៈប្រៀបដូចជាដុំនៃពពុះទឹកជាដើម រមែងមិនជាអ្នកឃើញខន្ធ ដែលមិនមានសារៈ ថាជាខន្ធមានសារៈឡើយ ។

**តែកាលពោលដោយពិសេស** កាលឃើញនូវរូបខាងក្នុងដោយសេចក្តីថាជារបស់មិនស្អាត កំណត់ដឹងនូវកវឡិង្ការាហារ, រមែងលះវិបល្លាសក្នុងវត្ថុដែលមិនស្អាតថាស្អាត; រមែងឆ្លងផុតចាកកាមោឃៈ, រមែងឃ្លាតចាកកាមយោគ, ជាអ្នកមិនមានកាមាសវៈ, រមែងទម្លាយកាយគន្ថៈ [៣១] គឺអភិជ្ឈា, រមែងមិនប្រកាន់មាំនូវកាមុបាទាន ។ កាលឃើញវេទនាដោយសេចក្តីជាទុក្ខ រមែងកំណត់ដឹងនូវផស្សា-

---

[៣១] កាយគន្ថៈ កិលេសជាគ្រឿងចងកាយ, កាយក្នុងទីនេះ សំដៅដល់ រូប និងនាម (ខន្ធ ៥) ។

ហារ, រមែងលះវិបល្លាសក្នុងទុក្ខថាជាសុខ, រមែងឆ្លងផុតភវោឃៈ, រមែងឃ្លាតចាកភវយោគ, ជាអ្នកមិនមានភវាសវៈ រមែងទម្លាយកាយគន្ថៈ គឺព្យាបាទ, រមែងមិនប្រកាន់មាំនូវសីលព្វតុបាទាន ។ កាលឃើញសញ្ញា និងសង្ខារទាំងឡាយ ដោយសភាពជាអនត្តា រមែងកំណត់ដឹងមនោសញ្ចេតនាហារ, រមែងលះវិបល្លាសក្នុងវត្ថុដែលមិនមែនអត្តា ថាជាអត្តា, រមែងឆ្លងផុតទិដ្ឋោឃៈ, រមែងឃ្លាតចាកទិដ្ឋិយោគ, ជាអ្នកមិនមាន ទិដ្ឋាសវៈ, រមែងទម្លាយកាយគន្ថៈ គឺការប្រកាន់ថា វត្ថុនេះពិត, រមែងមិនប្រកាន់ មាំនូវអត្តវាទុបាទាន ។ **កាលឃើញវិញ្ញាណដោយសេចក្តីមិនទៀង រមែងកំណត់ដឹងវិញ្ញាណាហារ,** រមែងលះវិបល្លាសក្នុងវត្ថុដែលមិនទៀង ថាទៀង, រមែងឆ្លងផុត អវិជ្ជោឃៈ, រមែងឃ្លាតចាកអវិជ្ជាយោគ, ជាអ្នកមិនមានអវិជ្ជាសវៈ, រមែងទម្លាយ កាយគន្ថៈ គឺសីលព្វតបរាមាសៈ, រមែងមិនប្រកាន់មាំនូវទិដ្ឋុបាទាន ។ **ព្រោះការឃើញខន្ធ ៥ ដោយអំណាចនៃភាវៈជាអ្នកសម្លាប់ជាដើមយ៉ាងនេះ មានអានិសង្សច្រើន, ព្រោះហេតុដូច្នោះ អ្នកប្រាជ្ញគប្បីជ្រាបខន្ធទាំងឡាយ ដោយអំណាចនៃភាពជាអ្នកសម្លាប់ជាដើមចុះ** ៕

**(ពណ៌នាសុត្តន្តភាជនិយចប់)**

# ពណ៌នាអភិធម្មភាជនិយ

## សម្តែងអំពីរូបក្ខន្ធនិទ្ទេស

ឥឡូវនេះ ជាអភិធម្មភាជនិយ គឺន័យដែលទ្រង់ចែកអភិធម្ម; ក្នុងអភិធម្មភាជនិយនោះ បណ្ឌិតគប្បីជ្រាបនិទ្ទេសនៃរូបក្ខន្ធ ដោយន័យដែលខ្ញុំឱ្យពិស្តារទុកក្នុង

រូបកណ្ឌ (នៃអដ្ឋសាលិនី អដ្ឋកថា ធម្មសង្គណី) ក្នុងពេលមុននោះចុះ ៕

## សំដែងអំពីវេទនាខន្ធនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃវេទនាខន្ធតទៅ ៖

បទថា **"ឯកវិធេន"** កែជា **ឯកកោដ្ឋាសេន** = ចំណែកមួយ ។

បទថា **"ផស្សសម្បយុត្តោ"** ញែកបទជា **ផស្សេន សម្បយុត្តោ** = សម្បយុត្តដោយផស្សៈ; វេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ សូម្បីទាំងអស់បានដល់វេទនាក្នុងហេតុទុកៈ [៣២] គឺសហេតុទុកវេទនា ជាវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤, ដែលជាអហេតុកវេទនា ជាកាមាវចរតែម្យ៉ាង; គប្បីជ្រាបវេទនាដែលត្រាស់ដោយបទនៃកុសលជាដើមដោយឧបាយនេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សំម្តែងវេទនាខន្ធនេះតែម្យ៉ាងដោយជាធម៌សម្បយុត្តដោយផស្សៈ, ទ្រង់សំម្តែងវេទនា ១ ពួក មាន ២ យ៉ាង ដោយជាវេទនាដែលប្រកបដោយហេតុ និងមិនប្រកបដោយហេតុ, ទ្រង់សម្តែងវេទនា ១ ពួក មាន ៣ យ៉ាង ដោយការកើត, ទ្រង់សម្តែងវេទនា ១ ពួក មាន ៤ យ៉ាង ដោយភាពផ្សេងគ្នានៃភូមិ, ទ្រង់សម្តែងវេទនា ១ ពួកមាន ៥ យ៉ាង ដោយភាពជាឥន្ទ្រិយ; បណ្តាវេទនាទាំង ៥ នោះ វេទនាដែលជាសុខិន្ទ្រិយ និងទុក្ខិន្ទ្រិយអាស្រ័យកាយបសាទកើតឡើង ជាកាមាវចរតែម្យ៉ាង, វេទនាដែលជាសោមនស្សិ-ន្ទ្រិយប្រព្រឹត្តទៅក្នុងភូមិ ៣ អាស្រ័យវត្ថុទី ៦ កើតឡើងក៏មាន, មិនអាស្រ័យវត្ថុ

---

[៣២] ហេតុកៈ គឺវេទនាដែលជាសហេតុកៈ និងអហេតុកៈ ។

ទី ៦ កើតឡើងក៏មាន ។ វេទនាដែលជាទោមនស្សិន្ទ្រិយអាស្រ័យវត្ថុទី ៦ កើតឡើង ជាកាមាវចរ ។ វេទនាដែលជាឧបេក្ខិន្ទ្រិយប្រព្រឹត្តទៅក្នុងភូមិ ៤ គឺអាស្រ័យបសាទ ៤ មានចក្ខុបសាទជាដើមកើតឡើងក៏មាន, អាស្រ័យវត្ថុទី ៦ កើតឡើងក៏មាន, មិនអាស្រ័យវត្ថុកើតឡើងក៏មាន; ទ្រង់សម្តែងវេទនា ១ ពួក មាន ៦ យ៉ាងដោយវត្ថុ; បណ្តាវេទនាទាំង ៦ នោះ វេទនា ៥ ខាងដើមអាស្រ័យបសាទ ៥ មានចក្ខុបសាទជាដើមកើតឡើង ជាកាមាវចរតែម្យ៉ាង, វេទនាទី ៦ មិនអាស្រ័យវត្ថុកើតឡើងក៏មាន, អាស្រ័យវត្ថុដែលប្រព្រឹត្តទៅក្នុងភូមិ ៤ កើតឡើងក៏មាន ។ ទ្រង់សម្តែងវេទនា ១ ពួក ៧ យ៉ាង ក្នុងវេទនា ៦ យ៉ាងនោះ ដោយញែកវេទនាដែលកើតពីមនោសម្ផស្ស ។ ទ្រង់សម្តែងវេទនាពួកទី ៨ ក្នុងវេទនា ៧ យ៉ាងនោះដោយញែកវេទនាដែលកើតពីកាយសម្ផស្ស, ទ្រង់សម្តែងវេទនាពួក ៩ ដោយប្រភេទនៃវេទនា ដែលកើតពីផស្សៈនៃមនោវិញ្ញាណធាតុក្នុងប្រភេទនៃវេទនា ៧ យ៉ាង, ទ្រង់សម្តែងវេទនាពួក ១០ ដោយប្រភេទនៃវេទនាដែលកើតពីសម្ផស្សនៃមនោវិញ្ញាណធាតុ ក្នុងប្រភេទនៃវេទនា ៨ យ៉ាង ។

ពិតណាស់ ក្នុងវេទនាទាំងនេះ **មនោសម្ផស្សជា វេទនា** ក្នុងប្រភេទនៃវេទនាពួក ៧ ញែកជា ២ គឺ **មនោធាតុសម្ផស្សជា វេទនា និងមនោវិញ្ញាណធាតុសម្ផស្សជាវេទនា** ។ ក្នុងប្រភេទនៃវេទនាពួក ៨ ញែកជា ២ គឺ សុខកើតពីកាយសម្ផស្ស ១, ទុក្ខកើតពីកាយសម្ផស្ស រួមជាមួយមនោសម្ផស្សជាវេទនានោះ ១ ។ ក្នុងប្រភេទនៃវេទនាពួក ៩ បានដល់ មនោវិញ្ញាណធាតុសម្ផស្សជា វេទនា តាមដែលត្រាស់ទុកក្នុងប្រភេទនៃវេទនា ៧ ទ្រង់ញែកជា ៣ ដោយអំណាចនៃកុសលជាដើម ។ ក្នុងវេទនា-

ខន្ធ ១០ យ៉ាង បានដល់ មនោវិញ្ញាណធាតុសម្ផស្សជាវេទនា តាមដែលត្រាស់ទុកក្នុងវេទនាខន្ធ ៨ ទ្រង់ញែកជា ៣ ដោយអំណាចនៃកុសលជាដើមនោះឯង; ក៏ក្នុងវេទនាខន្ធនេះ ព្រះមានព្រះភាគត្រាស់វេទនាប្រកបដោយកុសលត្តិកៈដើម្បីធ្វើបទឱ្យពេញប៉ុណ្ណោះ; តែក្នុងប្រភេទនៃវេទនាពួក ៧ ពួក ៨ និងពួក ៩ ដើម្បីត្រូវការប្រទានន័យ ទើបប្រទានន័យទុកក្នុងឋានៈដែលគួរប្រទាន; ព្រោះសម្លឹងដល់ព្រះអភិធម្ម ព្រះតថាគតឈ្មោះថា ទ្រង់មិនបានប្រទានន័យទុកក្នុងឋានៈដែលគួរប្រទានមិនបានមាន, នេះជាវារៈមួយក្នុងទុកមូលជាមុនសិន ។

ពិតណាស់ ព្រះសាស្តាកាលទ្រង់ចែកវេទនាខន្ធ ក្នុងអភិធម្មភាជនិយនេះ ទ្រង់កាន់យកធម៌ពួកតិកៈ (ពួក ៣) ដាក់ក្នុងធម៌ពួកទុកៈ (ពួក ២) ខ្លះ, ទ្រង់កាន់យកធម៌ពួកទុកៈដាក់ក្នុងធម៌ពួកតិកៈខ្លះ, ទ្រង់កាន់យកធម៌ពួក ៣ និងពួក ២ ហើយនាំមកតាមទំនងនៃធម៌ដែលឱ្យផ្តើមឡើងទាំង ២; រមែងទ្រង់សម្តែងវេទនា-ខន្ធ ដោយច្រើនយ៉ាង សូម្បីក្នុងទីទាំងពួង ក៏ទ្រង់សម្តែងវេទនាពួក ៧, វេទនាពួក ២៤, វេទនាពួក ៣០ និងវេទនាច្រើនយ៉ាង; ព្រោះហេតុអ្វី ? ព្រោះទ្រង់សម្តែងតាមអធ្យាស្រ័យរបស់បុគ្គល និងដើម្បីសេចក្តីពីរោះនៃទេសនា (ទេសនាវិលាស) ៕

## សម្តែងអំពីទេសនាតាមអធ្យាស្រ័យបុគ្គល

ពិតណាស់ ទេវបុត្រពួកណាក្នុងទេវបរិស័ទ ដែលអង្គុយដើម្បីនឹងស្តាប់ធម៌ រមែងអាចដើម្បីចាក់ធ្លុះព្រះតម្រាស់ ដែលព្រះសាស្តាទ្រង់កាន់យកធម៌ពួកតិកៈដាក់ចូលក្នុងធម៌ពួកទុកៈហើយទើបសម្តែង, ព្រះអង្គទ្រង់សម្តែងធ្វើដូចនោះ ដោយ

អំណាចនៃអធ្យាស្រ័យរបស់ទេវបុត្រទាំងនោះ; ទេវបុត្រពួកណា អាចដើម្បីចាក់ធ្លុះធម៌ ដែលត្រាស់ដោយអាការៈយ៉ាងដទៃ, ក៏ទ្រង់សម្ដែងដោយអាការៈនោះដល់ទេវបុត្រទាំងនោះ, នេះជា**អធ្យាស្រ័យរបស់បុគ្គល** ក្នុងកាលដែលទ្រង់ទេសនាវេទនាខន្ធនេះ ៕

## សម្ដែងអំពីទេសនាវិលាស

ក៏ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់អាចដើម្បីសម្ដែងវេទនាខន្ធ ដោយប្រការដែលកាន់យកធម៌ពួកតិកៈដាក់ក្នុងធម៌ពួកទុកៈ ឬធម៌ពួកទុកៈដាក់ក្នុងធម៌ពួកតិកៈ ឬក៏ឱ្យធម៌ពួកតិកៈ និងទុកៈទាំង ២ ចម្រើនឡើង ឬថាន័យដែលទ្រង់សម្ដែងវេទនាមួយពួកៗ ៧ យ៉ាងជាដើម បានតាមប្រាថ្នានោះៗ ព្រោះភាពដែលព្រះអង្គមានអារម្មណ៍ច្រើន*, សូម្បីដោយហេតុនោះ ទើបទ្រង់សម្ដែងដោយអាការៈយ៉ាងនេះ, នេះឈ្មោះថា **ទេសនាវិលាស** របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ៕

## សម្ដែងអំពីការកំណត់មហាវារៈ ៤

ក្នុងអភិធម្មភាជនិយនោះ បណ្ឌិតគប្បីជ្រាបមហាវារៈទាំង ៤ នេះជាមុន គឺវារៈដែលព្រះអង្គទ្រង់កាន់យកវេទនាខន្ធ ក្នុងធម៌ពួកតិកៈ ដាក់ក្នុងធម៌ពួកទុកៈ ហើយទើបសម្ដែង ឈ្មោះថា **ទុកមូលកវារៈ**, វារៈដែលទ្រង់កាន់យកវេទនា ក្នុង

---

* ព្រោះហេតុតែព្រះអង្គមានទេព្យកោសល្យច្រើន (អ្នកជម្រះ) ។

ធម៌ពួកទុកៈ ទុកក្នុងធម៌ពួកតិកៈហើយសម្ដែងទុក ឈ្មោះថា **តិកមូលកវារៈ**, វារៈដែលទ្រង់ញុំាងវេទនាក្នុងពួកតិកៈ និងទុកៈទាំង ២ ឱ្យចម្រើនហើយសម្ដែងទុក ឈ្មោះថា **ឧភតោវឌ្ឍិតកវារៈ**, វារៈមានជាអាទិ៍ថា **"សត្ត វិធេន"** ក្នុងទីបំផុត ឈ្មោះថា **ពហុវិធវារៈ** ។

បណ្ដាមហាវារៈទាំង ៤ នោះ ក្នុង **ទុកមូលកវារៈ ៩៥០ វារៈ** មានវារៈដែលប្រកបតិកៈទី ១ ក្នុងទុកៈទី ២ ដោយការនាំវេទនាតិកៈ បីតិត្តិកៈ សនិទស្សនត្តិកៈ ក្នុងតិកៈទាំងឡាយចេញ ព្រមជាមួយទុកៈមួយៗ ដែលបាននៅក្នុងទុកៈទាំងឡាយ ហើយប្រកបតិកៈ ១៩ ដ៏សេស ដែលនៅមានជាដើម សូម្បីវារៈទាំងអស់នោះទ្រង់បំប្រួញត្រាស់ទុកក្នុងព្រះបាលី សម្ដែងធម៌ ដែលគួរសម្ដែងក្នុងទីនោះៗ ក៏សម្រាប់បុគ្គលដែលមិនឱ្យស្រពេចស្រពិលគួរជ្រាបដោយពិស្ដារ សូម្បីក្នុង **តិកមូលកវារៈ** ក៏មានវារៈ ៩៥០ វារៈ មានវារៈនៃការប្រកបទុកៈទី ២ ជាមួយតិកៈទី ១ ជាដើម ដោយនាំទុកៈដំបូងជាដើម ដែលមិនបានក្នុងទុកៈទាំងឡាយចេញសិន ប្រកបចំពោះទុកៈ ៥០ មានសហេតុកទុកៈជាដើមដែលនៅមានសេសជាមួយនឹងតិកៈមួយៗ ដែលមានក្នុងតិកៈទាំងឡាយ; សូម្បីវារៈទាំងអស់នោះត្រាស់ទុកក្នុងព្រះបាលី ទ្រង់សម្ដែងដោយបំប្រួញដែលគួរសម្ដែងក្នុងទីនោះៗ; ក៏កាលបុគ្គលអ្នកមិនឱ្យមានសេចក្ដីស្រពេចស្រពិល គួរជ្រាបដោយពិស្ដារ ។

ក្នុង **ឧភតោវឌ្ឍិតកវារៈ** ត្រាស់ថា មានវារៈ ១៩ វារៈ គឺមានវារៈប្រកបតិកៈទី ១ និងទុកៈទី ២ ជាដើម ប្រកបតិកៈ១៩ ដែលបានហើយដោយទុកៈទាំងឡាយ ១៩ ដែលបានដោយការធ្វើទុកៈទីពីរ ក្នុងប្រភេទនៃវេទនាពួក ២ និង

បឋមត្តិកៈ សូម្បីក្នុងប្រភេទនៃវេទនាមួយពួកៗ មាន ៣ ឱ្យជាដើម ។ នេះជាមហាវារៈ ទី ៣ ឈ្មោះថា **ឧភតោវឌ្ឍិតកវារៈ** ព្រោះញ៉ាំងទុកៈទាំង ២ ដោយអំណាចនៃទុកៈ និងតិកៈឱ្យចម្រើនហើយ ។

ក្នុងនិទ្ទេសនៃវេទនាពួក ៧ របស់ពហុវិធវារៈ ត្រាស់វារៈសម្តែងអំពីវេទនាពួក ៧ ទុកៈ ១៩ វារៈ ប្រកបជាមួយភូមិ ៤ ព្រមជាមួយនឹងតិកៈ ១៩ ដែលមាននៅដល់ គ្រប់តិកៈចាប់ផ្តើមតាំងពីដើម ។ សូម្បីក្នុងនិទ្ទេសនៃវេទនាពួក ២៤ ក៏ត្រាស់វារៈ ១៩ វារៈ ដោយអំណាចនៃតិកៈទាំងនោះនុ៎ះឯង; ក្នុងពហុវិធវារៈ (សម្តែងអំពីវេទនាខន្ធ មានពួកច្រើនយ៉ាង) ក៏ត្រាស់ទុកយ៉ាងនោះ ។ **វារៈពោលអំពីដោយវេទនាពួក** ៣០ ជាប្រភេទតែមួយប៉ុណ្ណោះ ព្រោះហេតុដូច្នោះ សូម្បីវារៈទាំងអស់ទើបជា ៥៨ វារៈ; នេះជាការពណ៌នាព្រះបាលីក្នុងវេទនាខន្ធ ដោយអំណាចនៃការកំណត់វារៈជាមុនសិន ៕

## សម្តែងអំពីការពណ៌នាអត្ថក្នុងវេទនាខន្ធ

ឥឡូវនេះ ជាការពណ៌នាអត្ថក្នុងវេទនាខន្ធ; និទ្ទេសនៃវេទនាខន្ធពួក ៧ ក្នុងវេទនាខន្ធនោះមានសេចក្តីងាយទាំងអស់; មែនពិត ក្នុងនិទ្ទេសនៃវេទនាខន្ធពួក ២៤ បណ្ឌិតគប្បីជ្រាបថា វេទនាខន្ធដែលជាកុសលរមែងមាន **ព្រោះចក្ខុសម្ផស្ស ជាបច្ច័យ** ដោយអំណាចនៃកាមាវចរកុសលចិត្ត ៨ ដួង; គប្បីជ្រាបវេទនាខន្ធដែលជាអកុសលដោយអំណាចនៃអកុសលចិត្ត ១២ ដួង ។ គប្បីជ្រាបវេទនាខន្ធដែលជាអព្យាកតៈដោយចិត្ត ២៤ ដួង គឺមនោធាតុ ៣, អហេតុកមនោវិញ្ញាណធាតុ ៣,

មហាវិបាក ៨ និងកាមាវចរកិរិយា ១០ ។

បណ្ដាចិត្តទាំងនោះ កុសលចិត្ត ៨ និងអកុសលចិត្ត ១២ រមែងបាន (គឺរមែងប្រព្រឹត្តទៅ) ដោយអំណាចនៃជវន, កិរិយាមនោធាតុ ១ រមែងបានដោយអំណាចនៃអាវជ្ជនៈ; មនោធាតុវិបាក ២ រមែងបានដោយអំណាចនៃសម្បដិច្ឆន្នៈ, មនោវិញ្ញាណធាតុដែលជាវិបាក ៣ រមែងបានដោយអំណាចនៃសន្តីរណៈ និងតទាលម្ពណៈ, កិរិយាអហេតុកមនោវិញ្ញាណធាតុ ១ រមែងបានដោយអំណាចនៃវោដ្ឋព្វនៈ, មហាវិបាកចិត្ត ៨ រមែងបានដោយអំណាចនៃតទាលម្ពណៈ, កិរិយាចិត្ត ៩ រមែងបានដោយអំណាចនៃជវន ។ សូម្បីក្នុងសោតៈ ឃានៈ ជិវ្ហា និងកាយទ្វារ ក៏ន័យនេះដែរ ។

ក៏បទក្នុងមនោទ្វារ បទថា "**អត្ថិ កុសលោ** = ជាកុសលក៏មាន" នេះ ត្រាស់ទុកដោយអំណាចនៃកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា "**អត្ថិ អកុសលោ** = ជាអកុសលក៏មាន" ត្រាស់ទុកដោយអំណាចនៃអកុសល ១២ ។ បទថា "**អត្ថិ អព្យាកតោ** = ជាអព្យាកតៈក៏មាន" ត្រាស់ទុកដោយអំណាចនៃចិត្តុប្បាទ ៣៤ គឺកាមាវចរវិបាក ១១, កិរិយា ១០, រូបាវចរកិរិយា អរូបាវចកិរិយា ៩ និងសាមញ្ញផល ៤ ។

បណ្ដាចិត្តុប្បាទទាំងនោះ កុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ (២១ ប្រភេទ) និងអកុសល (១២ ប្រភេទ) រមែងបាន (គឺរមែងប្រព្រឹត្តទៅ) ដោយអំណាចនៃជវន អហេតុកមនោវិញ្ញាណធាតុដែលជាកិរិយា រមែងបានដោយអាវជ្ជនៈ ១, វិបាកចិត្ត ១១ រមែងបានដោយអំណាចនៃតទាលម្ពណៈ កិរិយាដែលប្រព្រឹត្ត

ទៅក្នុងភូមិ ៣ (គឺកាមាវចរ ៤ រមែងប្រព្រឹត្តទៅក្នុងរូបាវចរារូបាវចរ ៩) និង សាមញ្ញផល ៤ រមែងបានដោយអំណាចនៃជវនៃប៉ុណ្ណោះ ចិត្តុប្បាទទាំងនោះសមគួរដើម្បីនឹងតាំងទុក ដោយវេទនាខន្ធទាំងឡាយមានវេទនាខន្ធពួក ៧ ជាដើមយ៉ាងណានីមួយ, តែថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់តាំងចិត្តទាំងនោះទុកក្នុងវេទនាពួក ៣០ ហើយសម្តែង ជាការពន្យល់បានដោយងាយ, ព្រោះហេតុដូច្នោះ ទើបទ្រង់តាំងចិត្តទាំងនោះ សម្តែងវេទនាពួក ៣០ នោះ ។

ក៏ចិត្តក្នុងចក្ខុទ្វារ (មានចំនួន ៤៤ ដួង) សូម្បីទាំងអស់នេះ រមែងបានដោយអាការៈ ៣ គឺ ឧបនិស្សយកោដិ (រឿងរបស់ឧបនិស្ស័យ) ១, ដោយអំណាចនៃការឈានកន្លង (កិលេស) ១ និងដោយអំណាចនៃភាវនា ១; សូម្បីក្នុងសោតទ្វារ និងមនោទ្វារ ក៏រមែងបានដោយអាការៈ ៣ យ៉ាង ដូច្នោះដែរ; តែឃានៈ ជិវ្ហា និងកាយទ្វារ គប្បីជ្រាបថា រមែងបានដោយអាការៈ ២ យ៉ាង គឺដោយអំណាចនៃការឈានកន្លង និងដោយអំណាចនៃភាវនា ។

## សម្តែងអំពីអាការៈ ៣ យ៉ាង

រមែងបានដោយអាការៈ ៣ តើយ៉ាងណា ?

គឺភិក្ខុក្នុងធម្មវិន័យនេះ ត្រាច់ចារិកទៅកាន់វិហារ ឃើញមណ្ឌលកសិណ ទើបសួរថា "នេះឈ្មោះអ្វី ?" កាលគេឆ្លើយថា មណ្ឌលកសិណដូច្នេះ ទើបសួរទៀតថា "ពួកគេធ្វើអ្វីដោយមណ្ឌលកសិណនេះឬ ?" ; ពេលនោះ ពួកភិក្ខុទើបឆ្លើយប្រាប់លោកថា "ភិក្ខុចម្រើនមណ្ឌលកសិណនេះ ញ៉ាំងឈានទាំងឡាយឱ្យ

កើត ចម្រើនវិបស្សនា មានសមាបត្តិជាបាទហើយពន្លុះអរហត្ត” ដូច្នេះ កុលបុត្រ (អ្នកបួសដោយសទ្ធា) ដល់ព្រមដោយការតាំងចិត្ត[៣៣] មិនបានកំណត់ថា “នេះជាភារៈធ្ងន់” ដូច្នេះ មានតែគំនិតគិតថា **“សូម្បីយើងក៏គួរញ៉ាំងគុណនេះឱ្យកើតឡើង; ទើបគិតថា ក៏គុណនេះដែលអ្នកដេកលក់ មិនអាចដើម្បីនឹងឱ្យកើតឡើងបាន, យើងគួរធ្វើសេចក្ដីព្យាយាមជម្រះសីលឱ្យហ្មត់ចត់តាំងពីខាងដើម”** ទើបញ៉ាំងសីលឱ្យបរិសុទ្ធ; បន្ទាប់ពីនោះ ក៏តាំងមាំក្នុងសីល, កាត់បលិពោធ ១០, ជាអ្នកសន្ដោសត្រេកអរដោយត្រៃចីវរយ៉ាងក្រៃលែង; ធ្វើវត្តបដិបត្តិចំពោះអាចារ្យ និងឧបជ្ឈាយ៍; រៀនកម្មដ្ឋាន ធ្វើកសិណបរិកម្ម ញ៉ាំងសមាបត្តិឱ្យកើត ចម្រើនវិបស្សនា មានសមាបត្តិជាបទដ្ឋានហើយពន្លុះអរហត្តផល ។ ក្នុងការពន្លុះអរហត្តនោះ ចក្ខុវិញ្ញាណជាបច្ច័យដ៏មានកម្លាំងដល់ការកើតវេទនាប្រព្រឹត្តទៅក្នុងភូមិ ៤ យ៉ាងនេះ គឺ វេទនាក្នុងការបរិកម្មសូម្បីទាំងអស់ជាកាមាវចរ; វេទនាក្នុងសមាបត្តិ ៨ ជារូបាវចរ; វេទនាក្នុងមគ្គនិងផលជាលោកុត្តរ ព្រោះហេតុនោះ វេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទើបឈ្មោះថា មានចក្ខុសម្ផស្សជាបច្ច័យ ចិត្តក្នុងចក្ខុទ្វាររមែងបានដោយអំណាចនៃឧបនិស្ស័យយ៉ាងនេះសិន ។

ម្យ៉ាងទៀត កាលរូបមកកាន់គន្លងចក្ខុហើយ កុលបុត្រអ្នកតាំងនៅក្នុងការពិចារណាយ៉ាងនេះថា “សេចក្ដីត្រេកអរកើតឡើងហើយដល់យើងក្នុងអារម្មណ៍ដែលគួរប្រាថ្នា, បដិឃៈកើតឡើងហើយដល់យើងក្នុងអារម្មណ៍ ដែលមិនគួរប្រាថ្នា, មោហៈកើតឡើងហើយដល់យើង ក្នុងខណៈដែលមិនឃើញតាមការពិត, ក៏មានៈ

---

[៣៣] **អជ្ឈាសយសម្បន្នោ** ។

កើតឡើងហើយដល់យើងអ្នកមានការជាប់ក្នុងអារម្មណ៍ផ្សេងៗ, ទិដ្ឋិកើតដល់យើង អ្នកមានការប្រកាន់ខុស, ឧទ្ធច្ចៈកើតដល់យើង អ្នកមានចិត្តរវើរវាយ, វិចិកិច្ឆាកើតដល់យើងដែលគ្មានចិត្តសន្និដ្ឋាន (តាំងនៅស៊ប), អនុស័យកើតដល់យើង អ្នកមានកិលេសខ្លាំងក្លា" ដូច្នេះ ដឹងការកើតឡើងនៃកិលេសរបស់ខ្លួនហើយ ទើបគិតថា "កិលេសទាំងនោះចម្រើនឡើងដល់យើងហើយ នឹងប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស, ណ្ហើយចុះ យើងនឹងសង្កត់វាចេញ" ទើបត្រិះរិះថា "ក៏បុគ្គលអ្នកដេកលក់មិនអាចសង្កត់កិលេសបាន, យើងគួរផ្ដើមធ្វើសេចក្ដីព្យាយាម ដើម្បីជម្រះសីលឱ្យបរិសុទ្ធតាំងពីដើមមែនពិត" ទើបបដិបត្តិដោយន័យ ដែលបានពោលហើយ នោះឯងរមែងពន្លុះអរហត្តបាន ។ ក្នុងការពន្លុះអរហត្តនោះ វេទនាដែលឈានកន្លង កិលេសដែលកើតឡើងក្នុងរូបារម្មណ៍ប្រព្រឹត្តទៅយ៉ាងនេះថា សូម្បីបរិកម្មវេទនា ទាំងអស់ជាកាមាវចរ, វេទនាដែលប្រព្រឹត្តទៅក្នុងសមាបត្តិ ៨ ជារូបាវចរារូបាវចរ, វេទនាដែលប្រព្រឹត្តទៅក្នុងមគ្គ និងផល ជាលោកុត្តរ ព្រោះហេតុនោះ វេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទើបឈ្មោះថា កើតឡើងមានចក្ខុសម្ផស្សជាបច្ច័យ; **ចិត្តក្នុងចក្ខុទ្វាររមែងបានដោយអំណាចនៃការឈានកន្លង** (កិលេស) យ៉ាងនេះ ។

ម្យ៉ាងវិញទៀត កាលរូបមកកាន់គន្លងចក្ខុទ្វារហើយ កុលបុត្រម្នាក់ រមែងផ្ដើមតាំងកំណត់យ៉ាងនេះថា **"រូបនេះអាស្រ័យអ្វី ?** ; តពីនេះ ក៏នឹងជ្រាបរូប (រូបារម្មណ៍) នោះថា "អាស្រ័យភូត (មហាភូតរូប)" ហើយក៏កំណត់មហាភូតរូប ៤ និងឧបាទាយរូប (គឺរូបអាស្រ័យនូវមហាភូតរូប ៤) ថា ត្រឹមតែ**ជារូប** និងកំណត់ធម៌ទាំងឡាយមានរូបនោះជាអារម្មណ៍ថា ត្រឹមតែ**ជាអរូប** (គឺនាម); តពីនោះ ក៏

កំណត់នាមរូបព្រមទាំងបច្ច័យហើយលើកឡើងកាន់យកលក្ខណៈ ៣ ពិចារណាសង្ខារទាំងឡាយ ដោយលំដាប់នៃវិបស្សនា រមែងពន្លុះអរហត្តបាន ។ ក្នុងការពន្លុះអរហត្តនោះ វេទនាដែលកើតឡើងពិចារណារូបារម្មណ៍យ៉ាងនេះថា "បរិកម្មវេទនាសូម្បីទាំងអស់ជាកាមាវចរ" វេទនាដែលប្រព្រឹត្តទៅក្នុងសមាបត្តិ ៨ ជារូបាវចរារូបាវចរ, វេទនាក្នុងមគ្គ និងផលជាលោកុត្តរដូច្នេះ, ព្រោះហេតុនោះ វេទនានេះទើបឈ្មោះថា កើតឡើងមានចក្ខុសម្ផស្សជាបច្ច័យ; ចិត្តក្នុងចក្ខុទ្វារ រមែងបាន **ដោយអំណាចនៃភាវនា**យ៉ាងនេះ ។

ភិក្ខុមួយរូបបានស្តាប់ថា "បានឮថា បុគ្គលធ្វើបរិកម្មកសិណ ញុំាងសមាបត្តិឱ្យកើតឡើងហើយចម្រើនវិបស្សនា មានសមាបត្តិជាបទដ្ឋានហើយ រមែងពន្លុះអរហត្ត" ដូច្នេះ; កុលបុត្រអ្នកដល់ព្រមដោយអធ្យាស្រ័យ (គឺការតាំងចិត្ត) មិនបានកំណត់ថា "រឿងនេះជាភារៈធ្ងន់" ទើបត្រិះរិះថា "សូម្បីយើង ក៏គួរញុំាងគុណនេះឱ្យកើតឡើងបាន" ហើយក៏បដិបត្តិដោយន័យមុននោះឯង រមែងពន្លុះបាន ។ ក្នុងការពន្លុះអរហត្តនោះ សោតវិញ្ញាណ ឈ្មោះថាជាបច្ច័យដ៏មានកម្លាំង ព្រោះការកើតឡើងនៃវេទនាប្រព្រឹត្តទៅក្នុងភូមិ ៤ យ៉ាងនេះ សូម្បីបរិកម្មវេទនាទាំងអស់ ជាកាមាវចរ, វេទនាដែលប្រព្រឹត្តទៅក្នុងសមាបត្តិ ៨ ជារូបាវចរារូបាវចរ, វេទនាក្នុងមគ្គ និងផល ជាលោកុត្តរ, ព្រោះហេតុនោះ វេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទើបឈ្មោះថា មានសោតសម្ផស្សជាបច្ច័យ; **ចិត្តក្នុងសោតទ្វារ រមែងបានដោយអំណាចនៃឧបនិស្ស័យ**យ៉ាងនេះឯង ។

ម្យ៉ាងទៀត កាលសំឡេងមកកាន់គន្លងសោតទ្វារ កុលបុត្រម្នាក់រមែងផ្ដើមកំណត់យ៉ាងនេះថា "សំឡេងនេះអាស្រ័យអ្វី ?" ជាដើម ពាក្យទាំងអស់នេះគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងចក្ខុទ្វារនោះឯង ។ វេទនាដែលកើតឡើង រមែងពិចារណាសទ្ទារម្មណ៍យ៉ាងនេះហើយ ព្រោះហេតុនោះ វេទនានោះទើបឈ្មោះថា កើតឡើង ព្រោះមានសោតសម្ផស្សជាបច្ច័យ, ចិត្តក្នុងសោតទ្វាររមែងបានដោយអំណាចនៃភាវនាយ៉ាងនេះ ។

ម្យ៉ាងវិញទៀត ពាក្យទាំងអស់ថា ឃានៈ ជិវ្ហា និងកាយទ្វារ មកកាន់គន្លងនៃក្លិនជាដើមជាអារម្មណ៍ សេចក្ដីត្រេកអរក្នុងអារម្មណ៍ដែលគួរប្រាថ្នាកើតឡើងហើយដល់យើងជាដើម គប្បីជ្រាបដោយន័យដែលពោលហើយក្នុងចក្ខុទ្វារនោះឯង។ វេទនាដែលប្រព្រឹត្តទៅឈានកន្លងកិលេស ដែលកើតឡើងក្នុងគន្ធារម្មណ៍ជាដើមយ៉ាងនេះហើយ ព្រោះហេតុនោះ វេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទើបឈ្មោះថា មានឃានៈ ជិវ្ហា កាយសម្ផស្សជាបច្ច័យ; ចិត្តទាំងឡាយរមែងបានក្នុងទ្វារ ៣ ដោយអំណាចនៃការ**ឈានកន្លង** (កិលេស) យ៉ាងនេះ ។

តែពាក្យទាំងអស់ថា "កាលក្លិនជាដើមមកកាន់គន្លងឃានទ្វារជាដើមហើយ កុលបុត្រម្នាក់ រមែងផ្ដើមកំណត់យ៉ាងនេះថា នេះក្លិន, នេះរស, នេះផោដ្ឋព្វៈ, តើវាអាស្រ័យអ្វី" ជាដើម គប្បីជ្រាបដោយន័យដូចដែលពោលទុកក្នុងចក្ខុទ្វារនោះដែរ ។ វេទនាដែលកើតឡើងពិចារណាក្លិនជាដើម ជាអារម្មណ៍យ៉ាងនេះ, ព្រោះហេតុនោះ វេទនានេះទើបឈ្មោះថា មានឃានៈ ជិវ្ហា និងកាយសម្ផស្សជាបច្ច័យ; ចិត្តទាំងឡាយ រមែងបាន**ដោយអំណាចនៃភាវនា**យ៉ាងនេះ ។

ក៏ចិត្តក្នុងមនោទ្វារ (មាន ៦៧ ដួង) រមែងបានដោយអាការសូម្បីទាំង ៣ ។

ពិតណាស់ កុលបុត្រពួកខ្លះឃើញជាតិ (ការកើត) ដោយសភាពភ័យខ្លាច; រមែងឃើញជរា ព្យាធិ មរណៈ ដោយសភាពភ័យខ្លាច; គ្រាឃើញដោយសភាពភ័យខ្លាច ហើយក៏គិតថា "យើងគួរផុតចាកជាតិ ជរា ព្យាធិ និងមរណៈ, ក៏ប៉ុន្តែថា **ធម្មតាបុគ្គលអ្នកដេកលក់ហើយ** មិនអាចដើម្បីនឹងផុតចាកជាតិជាដើមបាន, យើងគួរធ្វើសេចក្តីព្យាយាមជម្រះសីល ឱ្យបរិសុទ្ធតាំងពីដើមមែនពិត" ដូច្នេះ ហើយបដិបត្តិដោយន័យដែលពោលទុកក្នុងចក្ខុទ្វារនោះឯង ក៏រមែងបានពន្លុះ អរហត្ត ។ **ក្នុងការពន្លុះអរហត្តនោះ** ជាតិ ជរា ព្យាធិ និងមរណៈជាបច្ច័យមានកម្លាំង ព្រោះការកើតនៃវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ យ៉ាងនេះថា "សូម្បីបរិកម្មវេទនាទាំងអស់ជាកាមាវចរ, វេទនាប្រព្រឹត្តទៅក្នុងសមាបត្តិ ៨ ជារូបាវចរ, អរូបាវចរ, វេទនាក្នុងមគ្គ និងផលជាលោកុត្តរ" ដូច្នេះ, ព្រោះហេតុនោះ វេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទើបឈ្មោះថា មានមនោសម្ផស្សជាបច្ច័យ; ចិត្តក្នុងមនោទ្វារ រមែងបាន **ដោយអំណាចនៃឧបនិស្ស័យ** យ៉ាងនេះសិន ។

ពាក្យទាំងអស់ថា "ក៏កាលធម្មារម្មណ៍មកកាន់គន្លងមនោទ្វារជាដើម" គប្បីជ្រាបដោយន័យដែលពោលទុកហើយ ក្នុងចក្ខុទ្វារនោះឯង ។ វេទនាដែលឈានកន្លងកិលេសដែលកើតឡើងក្នុងធម្មារម្មណ៍យ៉ាងនេះហើយ ព្រោះហេតុនោះ វេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទើបឈ្មោះថា មានមនោសម្ផស្សជាបច្ច័យ; ចិត្តក្នុងមនោទ្វាររមែងបាន**ដោយអំណាចនៃការឈានកន្លងកិលេស**យ៉ាងនេះ ។

ម្យ៉ាងទៀត កាលធម្មារម្មណ៍មកកាន់គន្លងមនោទ្វារហើយ កុលបុត្រម្នាក់រមែងផ្ដើមកំណត់យ៉ាងនេះថា “**ធម្មារម្មណ៍នេះអាស្រ័យអ្វី ?**” ; ជ្រាបហើយថា “**អាស្រ័យវត្ថុ**” ; ក៏ពិចារណាថា “**វត្ថុអាស្រ័យអ្វី ?**” ជ្រាបហើយថា “**អាស្រ័យមហាភូតរូប**” ដូច្នេះ; ទើបលោកកំណត់មហាភូតរូប ៤ និងឧបាទាយរូបថាត្រឹមតែជា**រូប**, រមែងកំណត់ធម៌ ដែលមានរូបនោះជាអារម្មណ៍ថា **អរូប** (នាម); តពីនោះក៏កំណត់នាមរូបព្រមទាំងបច្ច័យលើកឡើងកាន់ត្រៃលក្ខណ៍ ពិចារណាសង្ខារទាំងឡាយ ដោយលំដាប់នៃវិបស្សនាហើយរមែងពន្លុះអរហត្ត ។ **ក្នុងការពន្លុះអរហត្តនោះ** វេទនានេះ គឺដែលកើតឡើងហើយ ពិចារណាអារម្មណ៍យ៉ាងនេះថា “សូម្បីបរិកម្មវេទនាទាំងអស់ជាកាមាវចរ, វេទនាដែលប្រព្រឹត្តទៅក្នុងសមាបត្តិ ៨ ជារូបាវចរារូបាវចរ, វេទនាក្នុងមគ្គ និងផល ជាលោកុត្តរ” ឈ្មោះថា កើតឡើង ព្រោះមានមនោសម្ផស្សជាបច្ច័យ; ចិត្តក្នុងមនោទ្វារ រមែងបាន **ដោយអំណាចនៃភាវនាយ៉ាងនេះ** ។

ក៏វេទនាទាំង ៦ យ៉ាង គឺវេទនាដែលកើតពីចក្ខុសម្ផស្ស ។ល។ វេទនាដែលកើតឡើងពីមនោសម្ផស្សដូច្នេះ ព្រះមានព្រះភាគត្រាស់ហើយ ក្នុងទីបំផុតនៃវារៈសូម្បីទាំងអស់ មានវារៈនៃវេទនាពួក ២៤ ជាដើម, វេទនាទាំងនោះ ត្រាស់ដោយអំណាចនៃបច្ចយធម៌ដែលសម្បយុត្តគ្នាដូច្នេះឯង ៕

**ចប់វេទនាខន្ធនិទ្ទេស**

## អំពីសញ្ញាខន្ធនិទ្ទេស

សូម្បីសញ្ញាខន្ធជាដើម ក៏គប្បីជ្រាបដោយឧបាយយ៉ាងនេះ [៣៤] ។

ពិតណាស់ ក្នុងនិទ្ទេសនៃសញ្ញាខន្ធរមែងបាន សូម្បីវេទនាតិកៈ និងបីតិត្តិកៈ ក្នុងតិកៈទាំងឡាយដោយសព្វគ្រប់, សូម្បីធម៌ក្នុងសុខសហគតទុកៈជាដើម ក៏រមែងបានសូម្បីក្នុងទុកៈទាំងឡាយដែរ ។

**ក្នុងនិទ្ទេសនៃសង្ខារក្ខន្ធ** ព្រះមានព្រះភាគជាម្ចាស់ មិនបានត្រាស់ពាក្យថា សម្បយុត្តដោយផស្សៈ ព្រោះសូម្បីផស្សៈក៏ជាធម៌រាប់បញ្ចូលក្នុងសង្ខារក្ខន្ធដែរ, តែត្រាស់ពាក្យថា “**ចិត្តសម្បយុត្តោ** = សម្បយុត្តដោយចិត្ត” ឯក្នុងនិទ្ទេសនៃខន្ធ នេះ ធម៌ទាំងឡាយសូម្បីមានហេតុទុកៈជាដើម រមែងបានក្នុងទុកៈទាំងឡាយ; ធម៌ពួកតិកៈ ហាក់ដូចជាសញ្ញាខន្ធនោះឯង ។

ក្នុងនិទ្ទេសនៃសញ្ញាខន្ធ ព្រះមានព្រះភាគជាម្ចាស់ទ្រង់មិនបានត្រាស់សេចក្តីដែលវិញ្ញាណជាធម៌កើតពីចក្ខុសម្ផស្សជាដើម, តែត្រាស់ពាក្យថា “**ចក្ខុវិញ្ញាណំ** = ចក្ខុវិញ្ញាណ” ជាដើម; ព្រោះនរណា។ មិនអាចដើម្បីសម្តែងថា “**វិញ្ញាណកើតពីមនោសម្ផស្ស**” ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ ដូចគ្នានឹងពាក្យដែលពោលហើយក្នុងសញ្ញាខន្ធនោះឯង ។

ក៏សូម្បីក្នុងនិទ្ទេសនៃខន្ធទាំង ៣ នោះ បានធម៌ពួកតិកៈ និងទុកៈច្រើនជាងនិទ្ទេសនៃវេទនាខន្ធ, បណ្ឌិតគប្បីជ្រាបប្រភេទនៃវារៈដោយអំណាចនៃធម្មត្តិកៈ និង

---

[៣៤] គឺដូចវេទនាខន្ធ ។

ទុកៈនោះចុះ ៕

**ពណ៌នាអភិធម្មភាជនិយចប់**

## ពណ៌នាអំពីបញ្ហាបុច្ឆកៈ

ឥឡូវនេះ ជាបញ្ហាបុច្ឆកៈ (ពួកសួរបញ្ហា); ក្នុងបញ្ហាបុច្ឆកៈនោះ បណ្ឌិតគប្បីជ្រាបក្នុងការសួរបញ្ហាថា "ព្រះមានព្រះភាគជាម្ចាស់ត្រាស់សួរបញ្ហាធម៌ណាដែលបាន និងមិនបាន ដោយន័យមានជាអាទិ៍ថា "**បញ្ចន្នំ ខន្ធានំ កតិ កុសលា, កតិ អកុសលា, កតិ អព្យាកតា** = បណ្ដាខន្ធ ៥ ខន្ធណាជាកុសល, ខន្ធណាជាអកុសល, ខន្ធណាជាអព្យាក្រឹត" នោះ, ក្នុងការវិសជ្ជនា ព្រះអង្គទ្រង់លើកធម៌ដែលបានប៉ុណ្ណោះឡើងសម្ដែងដោយន័យមានជាអាទិ៍ថា "**រូបក្ខន្ធោ អព្យាកតោ** = រូបក្ខន្ធ ជាអព្យាកតៈ" ដូច្នេះ ។ ក៏ក្នុងទីណា១ ព្រះអង្គទ្រង់មិនកំណត់ថា "ជាខន្ធមួយ" ឬថា "ជាខន្ធពីរ", ក៏នឹងទ្រង់តាំងតន្តិ (បែបផែន) ទុកដោយន័យ មានជាអាទិ៍ថា "**សិយា ឧប្បន្នា សិយា អនុប្បន្នា** = ខន្ធ ៥ ជាឧប្បន្នៈក៏មាន ជាអនុប្បន្នៈក៏មាន", ក្នុងទីនោះ១ គប្បីជ្រាបនូវការកាន់យកខន្ធសូម្បីទាំង ៥ ។ ការចែកកុសលជាដើមរបស់ខន្ធដ៏សេសទាំងនោះ ខ្ញុំពោលទុកក្នុង**អដ្ឋកថាធម្មសង្គហៈ** [៣៣] ក្នុងកាលមុននោះហើយ ។

ក៏ក្នុងអារម្មណត្តិកៈទាំងឡាយ ខន្ធ ៤ រមែងជាបរិត្តារម្មណ៍ដល់បុគ្គល អ្នក

---

[៣៥] អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណី ។

ត្រេកអរ អ្នកអន់ចិត្ត អ្នកឈ្លក់វង្វេង អ្នកសង្រួម អ្នកពិចារណា និងអ្នកពិចារណាឃើញព្រោះប្រារព្ធកាមាវចរធម៌ ៥៥ ដួង, **ជាមហគ្គតារម្មណ៍** ដល់បុគ្គលអ្នកត្រេកអរ អ្នកអន់ចិត្ត អ្នកឈ្លក់វង្វេង អ្នកសង្រួម និងអ្នកផ្តើមកំណត់ ព្រោះប្រារព្ធរូបាវចរ-ធម៌ និងអរូបាវចរធម៌ ២៧ ដួង, នឹងជាអប្បមាណារម្មណ៍ ដល់បុគ្គលអ្នកពិចារណាមគ្គ ផល និងនិព្វាន, តែជានវត្តព្វារម្មណ៍ [៣៤] (អារម្មណ៍បញ្ញត្តិ) ក្នុងវេលាដែលពិចារណាបញ្ញត្តដូច្នេះឯង ។

ខន្ធទាំង ៤ នោះឯង **ជាមគ្គារម្មណ៍** ក្នុងវេលាដែលព្រះសេក្ខៈ និងអសេក្ខៈពិចារណាមគ្គ, **ជាមគ្គហេតុកៈ** (មានមគ្គជាហេតុ) ដោយហេតុដែលកើតព្រមគ្នាក្នុងខណៈនៃមគ្គ, **ជាមគ្គាធិបតិ** ដោយអារម្មណាធិបតី ក្នុងវេលាពិចារណាធ្វើមគ្គឱ្យធ្ងន់ (ធំ), ម្យ៉ាងទៀត ខន្ធ ៤ **ជាមគ្គាធិបតី** ដោយអធិបតីដែលកើតព្រមគ្នារបស់បុគ្គលអ្នកចម្រើនមគ្គមានវីរិយៈជាធំ ឬមានវិមំសាជាធំ; តែឈ្មោះថា **ជានវត្តព្វារម្មណ៍** ដល់បុគ្គលអ្នកចម្រើនមគ្គ មានឆន្ទៈជាធំ ឬមានចិត្តជាធំ ។

ក៏ខន្ធ ៤ **ជាអតីតារម្មណ៍** ដល់បុគ្គលអ្នកត្រេកអរ អ្នកថ្នាំងថ្នាក់ អ្នកឈ្លក់វង្វេង អ្នកសង្រួម និងអ្នកផ្តើមកំណត់ ព្រោះប្រារព្ធខន្ធ ធាតុ និងអាយតនៈ ដែលកន្លងហើយ, **ជាអនាគតារម្មណ៍** ដល់បុគ្គលអ្នកត្រេកអរ ជាអ្នកប្រារព្ធធម៌ មានខន្ធជាដើម ដែលមិនទាន់មកដល់ **ជាបច្ចុប្បន្នារម្មណ៍** ដល់បុគ្គលទាំងនោះឯង អ្នកប្រារព្ធ

---

[៣៦] **អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណី ។**

ធម៌ទាំងនោះឯង ដែលកើតឡើងចំពោះមុខ ។ **ជានវត្តព្វារម្មណ៍** ដល់បុគ្គលអ្នកពិចារ-ណា បញ្ញត្តិ ឬព្រះនិព្វាន ។

ម្យ៉ាងទៀត ខន្ធ ៤ គប្បីជ្រាបថា **ជាអជ្ឈត្តារម្មណ៍** ដល់បុគ្គលអ្នកត្រេកអរ អ្នកថ្វាំងថ្នាក់ អ្នកឈ្លក់វង្វេង អ្នកសង្រួម និងអ្នកផ្ដើមកំណត់ ព្រោះប្រារព្ធខន្ធ ធាតុ និងអាយតនៈរបស់ខ្លួន, **ជាពហិទ្ធារម្មណ៍** ដល់បុគ្គលអ្នកប្រារព្ធខន្ធ ធាតុ និងអាយ-តនៈ របស់បុគ្គលពួកដទៃហើយប្រព្រឹត្តទៅយ៉ាងនោះ, **ជាពហិទ្ធារម្មណ៍**នោះឯង សូម្បីក្នុងកាលដែលពិចារណាបញ្ញត្តិ និងព្រះនិព្វាន, **ជាអជ្ឈត្តពហិទ្ធារម្មណ៍** ដល់បុគ្គលអ្នកប្រព្រឹត្តទៅយ៉ាងនោះ ក្នុងអជ្ឈត្តធម៌តាមកាល, ក្នុងពហិទ្ធាធម៌តាមកាល; ជា **នវត្តព្វារម្មណ៍** ក្នុងកាលនៃអាកិញ្ចញ្ញាយតនៈ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងចែកខន្ធវិភង្គនេះ ចេញជា ៣ បរិ-វដ្ដៈ[៣៧] ដោយអំណាចនៃសុត្តន្តភាជនិយជាដើម ដោយប្រការដូច្នេះ ។ ក៏ក្នុងបរិ-វដ្ដៈសូម្បីទាំង ៣ មានបរិច្ឆេទតែមួយប៉ុណ្ណោះ; ព្រោះរូបក្ខន្ធជាកាមាវចរតែម្យ៉ាង ក្នុងទីទាំងពួង, ខន្ធ ៤ ប្រព្រឹត្តទៅក្នុងភូមិ ៤ ព្រះអង្គត្រាស់ទុកលាយគ្នាទាំង លោកិយ ទាំងលោកុត្តរដូច្នេះឯង ៕ ✤

**ចប់ការពណ៌នាបញ្ហាបុច្ឆកៈ**

**ចប់ខន្ធវិភង្គនិទ្ទេសទី ១**

**នៃសម្មោហវិនោទនី អដ្ឋកថាវិភង្គ**

---

[៣៧] ការវិលទៅ ៣ យ៉ាង ។

# ២. អាយតនវិភង្គនិទ្ទេស

## ពណ៌នាអំពីសុត្តន្តភាជនិយ

ឥឡូវនេះព្រះមានព្រះភាគជាម្ចាស់កាលនឹងទ្រង់សម្ដែងសុត្តន្តភាជនិយក្នុងអាយតននិទ្ទេស ដែលតលំដាប់ពីខន្ធវិភង្គនិទ្ទេសនោះមុន ទើបត្រាស់ព្រះបាលីថា **"ទ្វាទសាយតនានិ ចក្ខាយតនំ រូបាយតនំ** = អាយតនៈ ១២ គឺចក្ខាយតនៈ រូបាយតនៈ" ជាដើម; ក្នុងអាយតនៈទាំងនោះ គប្បីជ្រាបដោយន័យក្នុងបាលីមុត្តកៈជាមុនថា ៖

**អត្ថលក្ខណតាវត្ត　　កមសង្ខេបវិត្ថារា**

**តថា ទដ្ឋព្វតោ ចេវ　　វិញ្ញាតព្វោ វិនិច្ឆយោ**

បណ្ឌិតគប្បីជ្រាបការវិនិច្ឆ័យ ដោយអត្ថ ១,
ដោយលក្ខណៈ ១, ដោយសេចក្ដីមានត្រឹមតែប៉ុណ្ណោះ
១, ដោយលំដាប់ ១, ដោយសង្ខេប ១, ដោយពិស្ដារ
១, ដោយជាធម៌ដែលបណ្ឌិតគប្បីឃើញ ១ ៕

### សម្ដែងអំពីការវិនិច្ឆ័យដោយអត្ថ

ក្នុងពាក្យវិនិច្ឆ័យទាំងនោះ គប្បីជ្រាបអត្ថដែលប្លែកគ្នាជាមុនថា ៖

១. **ចក្ខតីតិ ចក្ខុ** [៣៨] ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា រមែងឃើញ, អធិប្បាយថា រមែងពេញចិត្ត គឺធ្វើឱ្យរូបជាក់ច្បាស់ ។

២. **រូបយតីតិ រូបំ** ឈ្មោះថា **រូប** ព្រោះអត្ថថា រមែងឱ្យប្រាកដ, អធិប្បាយថា រូបកាលដល់វិការនៃវណ្ណៈ រមែងសម្ដែងភាវៈរបស់ខ្លួនទៅកាន់ហឫទ័យ ។

៣. **សុណាតីតិ សោតំ** ឈ្មោះថា **សោតៈ** ព្រោះអត្ថថា បានឮ

៤. **សិប្បតីតិ សទ្ទោ** ឈ្មោះថា **សទ្ទៈ** ព្រោះអត្ថថា ចេញទៅ គឺផ្សាយចេញទៅ

៥. **ឃាយតីតិ ឃានំ** ឈ្មោះថា ឃានៈ ព្រោះអត្ថថា **ហិត** ។

៦. **គន្ធយតីតិ គន្ធោ** ឈ្មោះថា **គន្ធៈ** ព្រោះអត្ថថា ផ្សាយក្លិន, គឺរមែងសម្ដែងទីនៅរបស់ខ្លួនឱ្យប្រាកដ ។

៧. **ជីវិតំ អវ្ហាតីតិ ជិវ្ហា** ឈ្មោះថា **ជិវ្ហា** ព្រោះអត្ថថា នាំមកនូវជីវិត

៨. **រសន្តិ តំ សត្តាតិ រសោ** ឈ្មោះថា **រស** ព្រោះអត្ថថា ជាទីត្រេកអរ,

---

[៣៨] **ចក្ខុវិញ្ញាណធិដ្ឋិតំ ហុត្វា សមវិសមំ ចក្ខតី អាចិក្ខន្តំ វិយ ហោតីតិ ចក្ខុ** = រូបណាជាទីតាំងនៅនៃចក្ខុវិញ្ញាណ រមែងឃើញប្រចក្ស គឺរមែងហាក់ដូចជានឹងប្រាប់អារម្មណ៍ដែលល្អ និងមិនល្អ (**សមវិសមំ**) ព្រោះហេតុដូច្នោះ រូបនោះ ទើបឈ្មោះថា ចក្ខុ បានដល់ ចក្ខុបសាទ ឬហៅថា ភ្នែក, ពាក្យដែលជាឈ្មោះរបស់ភ្នែកមានច្រើនយ៉ាងដូច **ចក្ខុ អក្ខិ នយនំ លោចនំ ទិដ្ឋិ ទស្សនំ បេក្ខនំ អច្ឆិ បម្ហំ បមុខំ** ដូចគាថាប្រព័ន្ធទុកថា ៖

**ចក្ខុន្តិ នយនំ នេត្តំ លោចនំ ទិដ្ឋិ ទស្សនំ**

**បេក្ខនំ អច្ឆិ បម្ហន្តុ បមុខន្តិ បវុច្ចតិ ។**

(ចាកធាតុប្បទីបិកា)

គឺជាទីពេញចិត្តរបស់សត្វទាំងឡាយ ។

**៩. កុច្ឆិតានំ សាសវធម្មានំ អាយោតិ កាយោ** ឈ្មោះថា **កាយ** ព្រោះអត្ថថា កន្លែងកើតរបស់ធម៌ មានអាសវៈដែលបណ្ឌិតគួរខ្ពើម; ពាក្យថា **អាយោ** គឺជាទីកើត ។

**១០. ផុសិយតីតិ ផោដ្ឋព្វំ** ឈ្មោះថា **ផោដ្ឋព្វៈ** ព្រោះអត្ថថា ដែលកាយរមែងពាល់ត្រូវ ។

**១១. មនុយតីតិ មនោ** ឈ្មោះថា **មនៈ** ព្រោះអត្ថថា រមែងដឹង ។

**១២. អត្តនោ លក្ខណំ ធារយន្តីតិ ធម្មា** ឈ្មោះថា **ធម៌** ព្រោះអត្ថថា រមែងទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ។

បើពោលដោយមិនប្លែកគ្នា គប្បីជ្រាបថា ក៏ឈ្មោះថា **អាយតនៈ** ព្រោះជាគ្រឿងត = **អាយតនតោ** ១, ព្រោះផ្សាយធម៌ដែលជាទីកើតនៃអាសវៈទាំងឡាយ = **អាយានំ តននតោ** ១, ព្រោះនាំទៅកាន់សង្សារតទៅទៀត = **អាយតស្ស ច នយនតោ** ១ ។

ពិតណាស់ ក្នុងអាយតនៈទាំងឡាយ មានចក្ខុ និងរូបជាដើម មានអធិប្បាយទុកថា ធម៌ទាំងឡាយ គឺចិត្ត និងចេតសិក មានអារម្មណ៍តាមទ្វារនោះៗ រមែងចម្រើនឡើង រមែងតាំងឡើង រមែងបន្ត រមែងពង្រីកទៅដោយកិច្ច មានការសោយអារម្មណ៍ជាដើមរបស់ខ្លួនៗ នេះជាពាក្យអធិប្បាយខទី ១ ។

ក៏កាលបើធម៌ដែលជាអាយ (គឺជាទីកើតរបស់អាសវៈមាន) ធម៌ គឺចិត្ត និងចេតសិកទាំងនោះ ក៏រមែងផ្សាយទៅ, គឺរមែងញ៉ាំងធម៌ ដែលជាអណ្ដូងកើត

នៃអាសវៈនេះឱ្យធំទូលាយ នេះជាពាក្យអធិប្បាយខទី ២ ។

ក៏អាយតនៈទាំងនេះរមែងនាំ គឺរមែងឱ្យប្រព្រឹត្តទៅមួយខ្សែទៅកាន់សង្សារ-ទុក្ខដ៏វែងអន្លាយមកពីអតីតៈ ប្រព្រឹត្តកន្លងទៅក្នុងសង្សារដែលមានពីខាងដើម និងខាងចុងដឹងមិនបាន ឱ្យវិលត្រឡប់មិនបាន, នេះជាពាក្យអធិប្បាយខទី ៣; ដោយប្រការដូច្នេះ សូម្បីធម៌ទាំងអស់នេះ ទើបត្រាស់ហៅឈ្មោះថា **អាយតនៈ** ព្រោះជាគ្រឿងត ព្រោះជាការផ្សាយធម៌ ដែលជាអណ្ដូងកើតនៃអាសវៈទាំងឡាយ និងព្រោះនាំទៅកាន់សង្សារដ៏វែងអន្លាយតទៅ ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា **អាយតនៈ** ព្រោះអត្ថថា **ជាទីនៅ** = និវាសនដ្ឋានដ្ឋេន; ព្រោះអត្ថថា ជាអណ្ដូង = **អាករដ្ឋេន**, ព្រោះអត្ថថា **ជាទីប្រជុំ** = **សមោសរណដ្ឋេន**, ព្រោះអត្ថថា **ជាលំនៅកើត** = **សញ្ជាតិទេសដ្ឋេន** និងព្រោះអត្ថថា **ជាការណៈ** = **ការណដ្ឋេន** ។

ពិតយ៉ាងនោះមែន វោហារផ្លូវលោកគេហៅ**ទីនៅអាស្រ័យថា** **អាយតនៈ** ដូចក្នុងប្រយោគមានជាអាទិ៍ថា "**ឥស្សរាយតនំ** = ជាទីនៅរបស់ឥស្សរៈ, **វាសុ-ទេវាយតនំ** = ទីនៅរបស់ព្រះវាសុទេព" ។ អាករៈ គឺអណ្ដូងកើត ហៅថា អា-យតនៈ ដូចក្នុងប្រយោគមានជាអាទិ៍ថា "**សុវណ្ណាយតនំ** = អណ្ដូងមាស, **រតនា-យតនំ** = អណ្ដូងរតនៈ" ; ក៏វោហារក្នុងសាសនាហៅទីប្រជុំថា **អាយតនៈ** ដូចក្នុងប្រយោគមានជាអាទិ៍ថា "**មនោរមេ អាយតនេ, សេវន្តិ នំ វិហង្គមា** = កាលអាយតនៈ គឺទីប្រជុំដែលជាទីរីករាយនៃចិត្តមានហើយ, ពួកសត្វបក្សីក៏នាំគ្នាទៅអា-ស្រ័យដើមឈើនោះ" [៣៩] ។ លំនៅកើតហៅថា អាយតនៈ ដូចប្រយោគមានជាអាទិ៍ថា "**ទក្ខិណាបថោ គុន្នំ អាយតនំ** = ទក្ខិណាបទ គឺផ្លូវទិសខាងក្រោមរបស់

តណ្ហា ជាលំនៅកើតរបស់គោទាំងឡាយ” ។ **ការណៈ** ហៅថា **អាយតនៈ** ដូចក្នុងប្រយោគមានជាអាទិ៍ថា “**តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ អាយតនេ** = កាលបើអាយតនៈ គឺហេតុជាគ្រឿងរឭកមាន លោកក៏នឹងពន្លុះផល ក្នុងចុតូបបាតញ្ញាណនោះៗ ដោយពិតប្រាកដ” [៤០] ។

ក៏ធម៌ គឺចិត្ត និងចេតសិកពួកនោះៗ រមែងអាស្រ័យនៅក្នុងអាយតនៈទាំងឡាយ មានចក្ខ្វាយតនៈជាដើម ព្រោះការប្រព្រឹត្តជាប់ដោយចក្ខុជាដើមនោះ ព្រោះហេតុនោះ អាយតនៈមានចក្ខុជាដើម ទើបឈ្មោះថា **ជានិវាសស្ថាន** គឺជាទីនៅអាស្រ័យរបស់ចិត្ត និងចេតសិកទាំងនោះ ។ម្យ៉ាងទៀត ចិត្ត និងចេតសិកទាំងនោះ ពាសពេញក្នុងអាយតនៈទាំងឡាយមានចក្ខុជាដើម ព្រោះអាស្រ័យចក្ខុជាដើមនោះ និងព្រោះសេចក្ដីដែលមានរូបជាដើមនោះជាអារម្មណ៍, ព្រោះហេតុនោះ អាយតនៈទាំងឡាយ មានចក្ខុជាដើម ឈ្មោះថា **ជាអាករៈ** គឺជាអណ្ដូងកើតរបស់ចិត្ត និងចេតសិកទាំងនោះ ។ ម្យ៉ាងវិញទៀត ចក្ខុជាដើម ឈ្មោះថា **ជាទីប្រជុំ** (សមោសរណដ្ឋាន) របស់ចិត្ត និងចេតសិកទាំងនោះ ព្រោះជាទីប្រជុំ ដោយអំណាចជាវត្ថុ ទ្វារ និងអារម្មណ៍ក្នុងអាយតនៈនោះៗ ឯង ។ ពុំនោះសោត អាយតនៈទាំងឡាយ មានចក្ខ្វាយតនៈជាដើមជាលំនៅកើតរបស់ចិត្ត និងចេតសិកទាំងនោះ ព្រោះកើតក្នុងអាយតនៈនោះៗ ឯង ដោយសេចក្ដីជាទីអាស្រ័យ (និស្សយប្បច្ច័យ) និងជាអារម្មណ៍ (អារម្មណប្បច្ច័យ) របស់ចិត្ត និងចេតសិកទាំងនោះ ។ បើពុំដូច្នោះទេ អាយតនៈទាំងឡាយ មានចក្ខ្វាយតនៈជាដើម ជាហេតុ (ការណៈ) របស់ចិត្ត និងចេតសិក

---

[៣៩-៤០] អំ. បញ្ចក. ។

ទាំងនោះ ព្រោះសេចក្តីដែលអាយតនៈទាំងឡាយ មានចក្ខាយតនៈជាដើមនោះ មិនមានចិត្ត និងចេតសិក ក៏មិនមែនដែរ ។

ធម៌ទាំងនោះហៅថា **អាយតនៈ** សូម្បីដោយហេតុទាំងនេះ គឺព្រោះអត្ថថា **ជាទីអាស្រ័យ**, ព្រោះអត្ថថា **ជាអាការ** ព្រោះអត្ថថា **ជាទីប្រជុំ** ព្រោះអត្ថថា **ជាលំនៅកើត** ព្រោះអត្ថថា **ជាហេតុ** ដោយប្រការដូច្នេះ, ព្រោះហេតុនោះ ពោលដោយអត្ថតាមដែលពោលមក ចក្ខុនោះផង អាយតនៈនោះផង ទើបឈ្មោះថា **ចក្ខាយតនៈ** ។ ល ។ ធម៌ទាំងនោះផង ជាអាយតនៈផង ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មាយតនៈ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអាយតនៈទាំងនេះ ត្រឹមតែប៉ុណ្ណោះសិនចុះ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយលក្ខណៈ

ក៏ខថា **ដោយលក្ខណៈ**នោះ គឺគប្បីជ្រាបវិនិច្ឆ័យក្នុងអាយតនៈនោះ ដោយលក្ខណៈ មានចក្ខុលក្ខណៈជាដើម; ក៏ប៉ុន្តែ លក្ខណៈនៃអាយតនៈមានចក្ខុជាដើមនោះ គប្បីជ្រាបដោយន័យដែលពោលទុក ក្នុងនិទ្ទេសនៃរូបក្ខន្ធខាងក្រោយនោះឯង ៕

## សម្តែងអំពីការវិនិច្ឆ័យដោយសេចក្តីមានតែប៉ុណ្ណោះ

ខថា **ដោយសេចក្តីមានតែប៉ុណ្ណោះ** បានដល់ សេចក្តីមានចំនួនត្រឹមតែប៉ុណ្ណោះ; ពាក្យនេះ មានអធិប្បាយថា ៖ ប្រសិនបើមានអ្នកសង្ស័យសួរថា ក៏អាយតនៈមានចក្ខាយតនៈជាដើម ក៏ជាធម៌នោះឯង; កាលបើបែបនេះ ព្រះអង្គមិនបានត្រាស់ថា ធម្មាយតនៈប៉ុណ្ណោះទេ, តែត្រាស់អាយតនៈ ១២ យ៉ាងដូច្នេះ ព្រោះហេតុអ្វី ?

ខនេះ គួរដល់សេចក្តីសង្ស័យថា ដែលត្រាស់ទុក ១២ យ៉ាង ព្រោះទ្រង់កំណត់ទ្វារ និងអារម្មណ៍ដែលជាទីកើតឡើងនៃវិញ្ញាណកាយ ៦ [៤១] ។

ពិតណាស់ ក្នុងអាយតនវិភង្គនេះ មានប្រភេទនៃអាយតនៈទាំងនោះ ដោយកំណត់សេចក្តីជាទ្វារ និងសេចក្តីជាអារម្មណ៍របស់វិញ្ញាណកាយ ៦ មានត្រឹមតែប៉ុណ្ណេះ, ព្រោះហេតុនោះ ទើបត្រាស់ថា អាយតនៈមាន ១២; ព្រោះថា ចក្ខាយតនៈនោះឯង ជាទ្វារកើតឡើងរបស់វិញ្ញាណកាយ ដែលរាប់បញ្ចូលក្នុងវិថីរបស់ចក្ខុវិញ្ញាណ និងរូបាយតនៈនោះឯង ក៏ជាអារម្មណ៍; ម្យ៉ាងទៀត អាយតនៈក្រៅនេះ ជាទ្វារកើតឡើងដល់វិញ្ញាណកាយក្រៅនេះ; តែអាយតនៈដែលជាឯកុទ្ទេសនៃមនាយតនៈ ពោលគឺភវង្គចិត្តនោះឯង ជាទ្វារកើតឡើងរបស់វិញ្ញាណកាយទី ៦ និងធម្មាយតនៈដែលមិនទូទៅជាអារម្មណ៍; ព្រោះហេតុនោះ ទើបត្រាស់អាយតនៈទុក ១២ ព្រោះកំណត់ទ្វារកើតឡើង និងអារម្មណ៍របស់វិញ្ញាណកាយ ៦ ទុកដោយប្រការដូច្នេះ ។ គប្បីជ្រាបការវិនិច្ឆ័យរបស់អាយតនៈនោះ **ដោយសេចក្តីមានតែប៉ុណ្ណេះ** យ៉ាងនេះ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយលំដាប់

ខថា **ដោយលំដាប់** សេចក្តីថា ក្នុងលំដាប់ទាំងឡាយមានលំដាប់នៃការកើតឡើងជាដើម តាមដែលពោលទុកហើយក្នុងកាលមុន [៤២] លំដាប់នៃទេសនាប៉ុណ្ណោះ

[៤១] វិញ្ញាណកាយ គឺគំនរនៃវិញ្ញាណមាន ៦ យ៉ាង ។

រមែងគួរសូម្បីក្នុងអាយតនវិភង្គនេះ ។ ព្រោះថា បណ្ដាអាយតនៈទាំងឡាយ ដែលជាខាងក្នុង ចក្ខាយតនៈឈ្មោះថា រមែងប្រាកដ; ព្រោះសេចក្ដីដែលឃើញបាន និងខ្ទប់បានជាអារម្មណ៍, ព្រោះហេតុនោះ ទើបទ្រង់សម្ដែងចក្ខាយតនៈមុន; តពីនោះ ក៏ទ្រង់សម្ដែងសោតាយតនៈជាដើម មានរូបដែលឃើញមិនបាន និងខ្ទប់បានជាអារម្មណ៍ ។

ក៏បណ្ដាអាយតនៈទាំងឡាយដែលនៅខាងក្នុង ព្រះអង្គទ្រង់សម្ដែងចក្ខាយតនៈ និងសោតាយតនៈមុន ព្រោះសេចក្ដីដែលអាយតនៈទាំង ២ នោះ ជាធម៌មានឧបការៈច្រើន ព្រោះជាហេតុឱ្យកើតទស្សនានុត្តរិយៈ (ការឃើញដ៏កំពូល) និងសវនានុត្តរិយៈ (ការបានស្ដាប់ដ៏កំពូល); តពីនោះ ក៏ទ្រង់សម្ដែងអាយតនៈ ៣ មានឃានាយតនៈជាដើម ក្នុងទីបំផុតទ្រង់សម្ដែងមនាយតនៈទុក ព្រោះសេចក្ដីដែលធម៌សូម្បីទាំង ៥ ក៏ជាអារម្មណ៍ជាទីត្រាច់ទៅ (របស់មនាយតនៈនោះ) ដែរ ។

ម្យ៉ាងទៀត ក្នុងអាយតនៈទាំងឡាយដែលជាខាងក្រៅ ព្រះអង្គទ្រង់សម្ដែងអាយតនៈមានរូបាយតនៈជាដើម ក្នុងលំដាប់របស់អាយតនៈខាងក្នុងនោះៗ ព្រោះភាពជាអារម្មណ៍របស់ចក្ខាយតនៈជាដើម ។ ម្យ៉ាងវិញទៀត គប្បីជ្រាបលំដាប់នៃអាយតនៈទាំងឡាយយ៉ាងនេះឯង សូម្បីដោយការកំណត់ហេតុកើតឡើងរបស់វិញ្ញាណ; ខនេះសមដូចព្រះបាលីដែលត្រាស់ថា **“ចក្ខុវិញ្ញាណរមែងកើតឡើង**

---

[៤២] លោកពោលទុកលំដាប់ ៥ គឺ **ឧប្បត្តិក្កមោ** = លំដាប់នៃការកើត, **បហានក្កមោ** = លំដាប់នៃការលះ, **បដិបត្តិក្កមោ** = លំដាប់នៃការបដិបត្តិ, **ភូមិក្កមោ** = លំដាប់នៃភូមិ, **ទេសនក្កមោ** = លំដាប់នៃការទេសនា ។

**ព្រោះអាស្រ័យចក្ខុ និងរូប ។ ល ។ មនោវិញ្ញាណរមែងកើតឡើង ព្រោះអាស្រ័យមនៈ និងធម៌ទាំងឡាយ”** [៤៣] ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអាយតនៈទាំងនេះ ដោយលំដាប់យ៉ាងនេះ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយសង្ខេប និងដោយពិស្តារ

ខថា **ដោយសង្ខេប និងដោយពិស្តារ** សេចក្តីថា ក៏បើពោលដោយសង្ខេប ព្រោះសេចក្តីដែលមនាយតនៈ និងធម្មាយតនៈចំណែកមួយ ព្រះអង្គសង្គ្រោះចូលជានាម, អាយតនៈដ៏សេសពីនោះ ទ្រង់សង្គ្រោះចូលជារូប, សូម្បីអាយតនៈទាំង ១២ គ្រាន់តែជា**នាម និងរូប**ប៉ុណ្ណោះ; តែកាលពោលដោយពិស្តារ បណ្តាអាយតនៈទាំងឡាយដែលជាខាងក្នុង **ចក្ខ្វាយតនៈ** គ្រាន់តែជាចក្ខុបសាទ ដោយអំណាចនៃការកើតមុន, តែបើពោលដោយអំណាចនៃបច្ច័យ គតិ និកាយ និងបុគ្គល ជាអនន្តប្រភេទ (មានប្រភេទរកកំណត់មិនបាន); អាយតនៈ ៤ មានសោតាយតនៈជាដើម ក៏ជាអនន្តប្រភេទដូចគ្នា ។ មនាយតនៈ មាន ៨១ ប្រភេទ ដោយប្រភេទនៃកុសល អកុសល វិបាក កិរិយា និងវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣, តែកាលបើពោលដោយប្រភេទនៃវត្ថុ និងបដិបទាជាដើម ក៏ជាអនន្តប្រភេទ ។ រសាយតនៈដែលជារូបក្ខន្ធ ពោលដោយប្រភេទនៃសមុដ្ឋានមាន ៤ ប្រភេទ, សទ្ទាយតនៈ (អាយតនៈ គឺសម្លេង) ពោលដោយសមុដ្ឋានមាន ២ ប្រភេទ; តែបើពោលដោយប្រភេទសភាគ និងវិសភាគហើយ សូម្បីអាយតនៈទាំងអស់ ក៏ជាអនន្តប្រភេទ ។

---

[៤៣] ម. ឧ. ។

ផោដ្ឋព្វាយតនៈមាន ៣ ប្រភេទ ដោយអំណាចនៃបឋវីធាតុ តេជោធាតុ និងវាយោធាតុ, តែកាលបើពោលដោយសមុដ្ឋានមាន ៤ ប្រភេទ, កាលបើពោលដោយសភាគ និងវិសភាគជាអនន្តប្រភេទ ។ ធម្មាយតនៈ ជាអនន្តប្រភេទ ដោយអំណាចនៃធម្មារម្មណ៍ប្រព្រឹត្តទៅក្នុងភូមិ ៣ ដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យអាយតនៈដោយសង្ខេប និងដោយពិស្តារយ៉ាងនេះ ៕

## សំម្តែងអំពីការវិនិច្ឆ័យដោយជាធម៌គប្បីឃើញ

ក៏ក្នុងខថា **ដោយធម៌ដែលបណ្ឌិតគប្បីឃើញ** នេះ សេចក្តីថា អាយតនៈទាំងអស់នោះឯង គប្បីឃើញដោយការនៅមិនទាន់មកដល់ (អនាគមនតោ) និងដោយការមិនចេញទៅ (អនិគ្គមនតោ) ។

ពិតណាស់ អាយតនៈទាំងនោះកាលមុនពីការកើតឡើង រមែងមកពីទីណាៗ ក៏មិនមែនទេ, សូម្បីក្រោយពីសេចក្តីរលត់ហើយ នឹងទៅកាន់ទីណាៗ ក៏មិនមែនដែរ; តាមពិតនោះ កាលមុនពីការកើតឡើងនៃអាយតនៈទាំងនេះនៅមិនបានភាវៈរបស់ខ្លួនដោយចំពោះ, ក្រោយពីការរលត់ទៅ ក៏មានភាវៈរបស់ខ្លួនរលត់អស់ហើយ; ហេតុដែលវាប្រព្រឹត្តទៅបានខាងដើម ខាងចុង និងត្រង់កណ្តាល ក៏ព្រោះការប្រព្រឹត្តទៅនៃបច្ច័យ; ព្រោះហេតុដូច្នោះ គប្បីជ្រាបអាយតនៈទាំងឡាយ ដោយការនៅមិនមកដល់ និងដោយការមិនចេញទៅ ។ ម្យ៉ាងទៀត គប្បីជ្រាបអាយតនៈទាំងនោះ ដោយសេចក្តីមិនកម្រើកទៅ (**និរីហតោ**) និងមិនមានសេចក្តីព្យាយាម (**អព្យាបារតោ**); ពិតមែន អាយតនៈទាំងឡាយមានចក្ខាយតនៈ និងរូបាយតនៈ

ជាដើម នឹងបានមានសេចក្ដីគិតយ៉ាងនេះថា "ឱហ្ន៎ ! ឈ្មោះថា វិញ្ញាណគប្បីកើតឡើង ព្រោះពួកយើងជួបគ្នា" ដូច្នេះ ក៏មិនមែន, ក៏អាយតនៈទាំងនោះនឹងខ្វល់ខ្វាយ ដើម្បីការកើតឡើងនៃវិញ្ញាណ ដោយសេចក្ដីជាទ្វារ ដោយសេចក្ដីជាវត្ថុ ឬដោយសេចក្ដីជាអារម្មណ៍ក៏មិនមែនដែរ, គឺមិនត្រូវខ្វល់ខ្វាយ ព្យាយាម; តាមពិតវាជារឿងធម្មតាប៉ុណ្ណោះ ដែលវិញ្ញាណកើតមាន ចក្ខុវិញ្ញាណជាដើមនឹងកើតឡើងព្រោះសេចក្ដីដែលអាយតនៈមានចក្ខាយតនៈ និងរូបាយតនៈជាដើមជួបគ្នា; ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបអាយតនៈទាំងឡាយ ដោយសេចក្ដីមិនកម្រើកទៅ និងដោយការមិនមានព្យាយាម ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបអាយតនៈខាងក្នុងដូចផ្ទះទំនេរ ព្រោះវៀរចាកការទៀង, វៀរចាកសេចក្ដីល្អ, វៀរចាកសុខ និងវៀរចាកអត្តភាព, គប្បីជ្រាបអាយតនៈខាងក្រៅ ដូចពួកចោរប្លន់អ្នកស្រុក ព្រោះប៉ះពាល់អាយតនៈខាងក្នុង ។ ខនេះសមដូចព្រះតម្រាស់ដែលត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ចក្ខុត្រូវរូបដែលចូលចិត្ត និងមិនចូលចិត្តប៉ះពាល់"[៤៤] ដូច្នេះ បណ្ឌិតគួរពង្រីកឱ្យពិស្ដារ; ម្យ៉ាងវិញទៀត គប្បីជ្រាបអាយតនៈខាងក្នុង ដូចសត្វ ៦ ប្រភេទ, គប្បីជ្រាបអាយតនៈខាងក្រៅ ដូចការស្វែងរកអាហាររបស់សត្វពួកនោះពិតចុះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាយតនៈទាំងនេះ ដែលជាធម៌គប្បីឃើញ ដោយប្រការដូច្នេះ ៕

---

[៤៤] សំ. សឡា. ។

## អធិប្បាយអាយតនៈដោយត្រៃលក្ខណ៍

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់មានសេចក្តីសង្គ្រោះ នឹងទ្រង់សម្តែងអាការនៃអាយតនៈទាំងនោះ ដែលបណ្ឌិតគប្បីជ្រាបច្បាស់ តាមសេចក្តីពិត ទើបផ្តើមពាក្យមានជាអាទិ៍ថា **“ចក្ខុំ អនិច្ចំ** = ចក្ខុមិនទៀង” ។

បណ្តាអាយតនៈពួកនោះ បណ្ឌិតគប្បីជ្រាប **ចក្ខុ** ឈ្មោះថា មិនទៀង ដោយអត្ថថា មានហើយរកមានមិនបានដូច្នេះជាមុនសិន ។ ឈ្មោះថា សេចក្តីមិនទៀង ដោយហេតុ ៤ យ៉ាង សូម្បីដទៃទៀត គឺដោយមានភាពកើតឡើង និងមានភាពសូន្យទៅជាទីបំផុត ១, ដោយភាពប្រែប្រួលទៅ ១, ដោយភាពជារបស់បណ្តោះអាសន្ន (ខ្ចីគេ) ១, ដោយការបដិសេធភាពទៀង ១ ។

**ចក្ខុទាំងអស់នេះឯង ឈ្មោះថា ជាទុក្ខ** ដោយអត្ថថា (បៀតបៀនឈ្លើចឈ្លី); ម្យ៉ាងទៀត ចក្ខុនេះកើតឡើងហើយ រមែងដល់ការតាំងនៅ (ឋិតិ), កាលតាំង នៅរមែងលំបាកដោយជរា, ដល់ជរាហើយ រមែងក្តៅក្រហាយយ៉ាងពិតប្រាកដ, ព្រោះហេតុនោះ ទើបឈ្មោះថា **ជាទុក្ខ** ព្រោះហេតុទាំង ៤ នេះ គឺដោយសេចក្តីជារបស់បៀតបៀន (ឈ្លើចឈ្លី) ញឹកញយ ១, ដោយសេចក្តីជារបស់អត់ធន់បាន ដោយលំបាក ១, ដោយវត្ថុជាទីតាំងនៅនៃសេចក្តីទុក្ខ ១, ដោយការបដិសេធនូវសេចក្តីសុខ ១ ។

ម្យ៉ាងទៀត ចក្ខុនោះ ឈ្មោះថា **ជាអនត្តា** ដោយអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ។ ម្យ៉ាងវិញទៀត ភាវៈនៃចក្ខុនោះប្រព្រឹត្តទៅក្នុងអំណាចរបស់នរណា។ក្នុងឋានៈទាំង ៣ នេះ គឺចក្ខុនេះកើតឡើងហើយ សូមកុំឱ្យដល់ការតាំងនៅ, ដល់

ការតាំងនៅហើយ ចូរកុំឱ្យចាស់, ដល់ការចាស់ហើយ ចូរកុំឱ្យបែកធ្លាយទៅដូច្នេះ មិនបានទេ, ជារបស់សូន្យទៅចាកវត្ថុដែលប្រព្រឹត្តទៅក្នុងអំណាចនោះ; ព្រោះហេតុនោះ ទើបចក្ខុនោះ ឈ្មោះថាជាអនត្តា ព្រោះហេតុទាំង ៤ នេះ គឺដោយភាពជារបស់សូន្យ ១, ដោយភាពមិនមានម្ចាស់របស់ ១, ដោយជាវត្ថុដែលគួរធ្វើតាមសេចក្តីពេញចិត្តមិនបាន ១, ដោយការបដិសេធចំពោះអត្តា ១ ។

ក៏ឈ្មោះថា មានសេចក្តីប្រែប្រួលទៅតាមធម្មតា ព្រោះមានភព និងគតិផ្សេងៗ ព្រោះសេចក្តីផ្លាស់ប្តូរទៅនៃភពមុន និងភពក្រោយ ព្រោះវៀរចាកភាពជាប្រក្រតី; ពាក្យថា **មានសេចក្តីប្រែប្រួលទៅជាធម្មតា** នេះ ជាវេវចនៈរបស់ពាក្យថា មិនទៀងនោះឯង ។ សូម្បីក្នុងអាយតនៈទាំងឡាយ មានពាក្យថា **រូបមិនទៀង** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ម្យ៉ាងទៀត អាយតនៈទាំងនេះ លើកចក្ខុទុកសិនចុះ, ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មិនទៀង, មិនមែនចក្ខុទេ; តែថា ចក្ខុ ជាចក្ខុផង ជាសភាវៈមិនទៀងផង; ធម៌ដ៏សេសក៏ដូចគ្នា គឺជាទុក្ខ; តែចក្ខុ ជាចក្ខុផង ជាទុក្ខផង, ធម៌ដ៏សេស ជាអនត្តា មិនមែនជាចក្ខុទេ; តែចក្ខុ ជាចក្ខុផង ជាអនត្តាផង; ដូច្នេះ សូម្បីរូបជាដើម ក៏ន័យនេះដែរ ។

**សួរថា** ក៏ក្នុងសុត្តន្តភាជនិយនេះ ព្រះតថាគតទ្រង់សម្តែងលក្ខណៈអ្វី ?

ឆ្លើយថា ទ្រង់សម្តែងអនត្តលក្ខណៈនៃអាយតនៈ ១២ យ៉ាង ។

ពិតណាស់ ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងអនត្តលក្ខណៈ រមែងសម្តែងដោយសេចក្តីមិនទៀងខ្លះ, ដោយសេចក្តីជាទុក្ខខ្លះ ទាំងដោយសេចក្តីមិនទៀង និង

សេចក្តីជាទុក្ខខ្លះ; ក្នុងលក្ខណៈទាំង ៣ នោះ ព្រះអង្គទ្រង់សម្តែងអនត្តលក្ខណៈ ដោយសេចក្តីមិនទៀងក្នុងសូត្រនេះថា **“ម្នាលភិក្ខុទាំងឡាយ បុគ្គលណា គប្បីពោលថា ចក្ខុជាអត្តា, ពាក្យរបស់អ្នកនោះមិនគួរ; ចក្ខុរមែងប្រាកដសូម្បីការកើត និងការរលត់សូន្យ, ក៏វត្ថុណាប្រាកដសូម្បីការកើត សូម្បីការរលត់សូន្យ វត្ថុនោះ របស់បុគ្គលនោះ ត្រូវពោលយ៉ាងនេះថា អត្តារបស់យើងកើតឡើង និងរលត់សូន្យទៅ”** ដូច្នេះ ពាក្យរបស់អ្នកដែលពោលថា “ចក្ខុជាអត្តានោះ ទើបមិនគួរ, ព្រោះហេតុដូច្នោះ ចក្ខុទើបជាអនត្តា”[៤៥] ។

ព្រះអង្គទ្រង់សម្តែងអនត្តលក្ខណៈ ដោយសេចក្តីជាទុក្ខ ក្នុងព្រះសូត្រថា **“ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា, ម្នាលភិក្ខុទាំងឡាយ ក៏បើរូបនេះ នឹងជាអត្តា, រូបនេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ, ឯនរណា។ ក៏គប្បីបានអំណាចក្នុងរូបថា ‘រូបរបស់យើង ចូរជាយ៉ាងនេះទៅ, រូបរបស់យើងចូរកុំជាយ៉ាងនេះឡើយ’, ម្នាលភិក្ខុទាំងឡាយ ក៏ព្រោះ រូបជាអនត្តាដូច្នេះ ទើបរូបប្រព្រឹត្តទៅដើម្បីអាពាធ, នរណា។ មិនគប្បីបានអំណាចក្នុងរូបថា ‘សូមរូបរបស់យើងជាយ៉ាងនេះទៅ’ រូបរបស់យើង កុំបានជាយ៉ាងនេះឡើយ”**[៤៦] ដូច្នេះ ។

ព្រះអង្គទ្រង់សម្តែងអនត្តលក្ខណៈ ទាំងដោយមិនទៀង ជាទុក្ខ ក្នុងព្រះសូត្រទាំងឡាយមានជាអាទិ៍ថា **“ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង, វត្ថុណាមិនទៀង, វត្ថុនោះជាទុក្ខ; វត្ថុណាជាទុក្ខ, វត្ថុនោះជាអនត្តា; វត្ថុណាជាអនត្តា, វត្ថុនោះ គប្បីឃើញដោយសម្មាបញ្ញា** (ដ៏ប្រពៃ) **តាមសេចក្តីពិតយ៉ាងនេះថា ‘នោះមិនមែនរបស់យើង, នោះមិនមែនយើង, នោះមិនមែនជាអត្តារបស់យើង”**[៤៧] ដូច្នេះ ។

---

[៤៥] ម. ឧ. ។ [៤៦] វិនយ. ៦។ [៤៧] សំ. ខន្ធ.។

**សួរថា** ទ្រង់សម្ដែងយ៉ាងនេះ ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសេចក្ដីមិនទៀង និងព្រោះសេចក្ដីជាទុក្ខយ៉ាងពិតប្រាកដ ។

ពិតណាស់ កាលបើចាន ពែង និងផ្តិល ឬវត្ថុណានីមួយធ្លាក់ពីដៃបែកហើយ ជនទាំងឡាយរមែងនិយាយថា "ឱ ! វាមិនទៀង" សេចក្ដីមិនទៀង ឈ្មោះថាប្រាកដហើយយ៉ាងនេះ; ក៏កាលបើជម្ងឺមានបូសជាដើមតាំងឡើងក្នុងអត្តភាពហើយ ឬត្រូវវត្ថុទាំងឡាយមានបន្លាជាដើមមុតហើយ ក៏រមែងពោលថា "ឱទុក្ខអ្វីម្ល េះ ទេ !" ដូច្នេះ ឈ្មោះថា ទុក្ខប្រាកដហើយមែនពិត ។

អនត្តលក្ខណៈ មិនប្រាកដ ងងឹតងងុល មិនច្បាស់លាស់ ចាក់ធ្លុះបានដោយលំបាក សម្ដែងបានដោយលំបាក ធ្វើឱ្យយល់បានដោយលំបាក ។ តែអនិច្ចលក្ខណៈ និងទុក្ខលក្ខណៈ ព្រះតថាគតទាំងឡាយ នឹងទ្រង់ឧប្បត្តិឡើងក៏ដោយ មិនទ្រង់ឧប្បត្តិក៏ដោយ រមែងប្រាកដ, អនត្តលក្ខណៈវៀរចាកការកើតឡើងនៃព្រះពុទ្ធជាម្ចាស់ហើយរមែងមិនប្រាកដ, **រមែងប្រាកដតែក្នុងពុទ្ធុប្បាទប៉ុណ្ណោះ** ។

ពិតណាស់ តាបស និងបរិព្វាជកទាំងឡាយ អ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន សូម្បីសរភង្គសាស្ដាជាដើម រមែងអាចពោលថា "**អនិច្ចំ ទុក្ខំ**" បានដែរ, តែមិនអាចនឹងពោលថា **អនត្តាបាន**ទេ; សូម្បីពួកតាបសជាដើមនោះ អាចពោលពាក្យថា **អនត្តា** ក្នុងបរិស័ទដែលប្រជុំគ្នាហើយក៏ដោយ, បរិស័ទដែលប្រជុំគ្នាក៏គប្បីចាក់ធ្លុះមគ្គនិងផល; ព្រោះការប្រកាសឱ្យដឹងអនត្តលក្ខណៈមិនមែនជាវិស័យរបស់នរណា។ ដទៃទេ, ជាវិស័យរបស់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ; អនត្តលក្ខណៈនេះទើបមិនប្រាកដហើយ ដោយប្រការដូច្នេះ; ព្រោះហេតុដូច្នោះ ព្រះសាស្ដាកាលនឹង

ទ្រង់សម្តែង**អនត្តលក្ខណៈ** ទើបទ្រង់សម្តែងដោយសេចក្តីមិនទៀងខ្លះ, **ដោយសេចក្តីជាទុក្ខខ្លះ, ដោយសេចក្តីមិនទៀងខ្លះ ទាំងជាទុក្ខខ្លះ**; តែអាយតនវិភង្គនេះ គប្បីជ្រាបថា ទ្រង់សម្តែងអាយតនៈនោះ ទាំងដោយសេចក្តីមិនទៀង ទាំងដោយសេចក្តីជាទុក្ខ ។

**សួរថា** ក៏លក្ខណៈទាំងនេះ រមែងមិនប្រាកដ **ព្រោះមិនមនសិការអ្វី ? មិនចាក់ធ្លុះអ្វី ?** និងមិនដែលមានអ្វីមកបិទបាំងទុក ? ។ ឆ្លើយថា **ក៏អនិច្ចលក្ខណៈ** រមែងមិនប្រាកដ ព្រោះមិនមានមនសិការ មិនចាក់ធ្លុះការកើតឡើង និងសេចក្តីសាបសូន្យទៅ និងព្រោះសន្តតិបិទបាំងទុក ។ ទុក្ខលក្ខណៈរមែងមិនប្រាកដ ព្រោះមិនមានមនសិការ មិនចាក់ធ្លុះសេចក្តីគាបសង្កត់រឿយៗ និងព្រោះឥរិយាបថទាំងឡាយ បិទបាំងទុក អនត្តលក្ខណៈរមែងមិនប្រាកដ ព្រោះមិនមានមនសិការ មិនចាក់ធ្លុះដោយចែកធាតុផ្សេងៗ និងព្រោះឃនសញ្ញាបិទបាំងទុក ។

ក៏ព្រះយោគាវចរកំណត់ការកើតឡើង និងការសាបសូន្យទៅ ដកសន្តតិចេញបានហើយ **អនិច្ចលក្ខណៈ** រមែងប្រាកដដោយកិច្ចតាមសេចក្តីពិត; មនសិការរមែងគាបសង្កត់រឿយៗ ផ្លាស់ប្តូរឥរិយាបថបានហើយ **ទុក្ខលក្ខណៈ**រមែងប្រាកដដោយកិច្ចតាមសេចក្តីពិត; កាលចែកធាតុផ្សេងៗ ហើយធ្វើការញែកសេចក្តីជាដុំ **អនត្តលក្ខណៈ** រមែងប្រាកដដោយកិច្ចតាមសេចក្តីពិត ។

ម្យ៉ាងទៀត ក្នុងអធិការនេះ គប្បីជ្រាបការវិភាគ (បែងចែកនេះ) គឺ៖

**អនិច្ចំ** ការមិនទៀង

**អនិច្ចលក្ខណំ** លក្ខណៈមិនទៀងទាត់

**ទុក្ខំ** សេចក្តីទុក្ខ

**ទុក្ខលក្ខណំ** លក្ខណៈនៃទុក្ខ

**អនត្តា** មិនមែនអត្តា

**អនត្តលក្ខណំ** លក្ខណៈនៃអនត្តា ។

បណ្តាវិភាគទាំង ៦ នោះ ពាក្យថា **អនិច្ចំ** បានដល់ ខន្ធ ៥ ។ ព្រោះហេតុអ្វី ? ព្រោះសេចក្តីដែលខន្ធទាំង ៥ មានសេចក្តីប្រែប្រួលទៅដោយការកើត និងដោយការសាបសូន្យទៅ, ឬថា ព្រោះមានហើយត្រឡប់ជាមិនមានវិញ ។ សភាពនៃខន្ធ ៥ មានសេចក្តីប្រែប្រួលទៅដោយការកើត និងការសាបសូន្យទៅ ឬថា សេចក្តីប្រែប្រួលនៃអាការ (លក្ខណៈ) ពោលគឺមានហើយ ត្រឡប់ជាមិនមានវិញ ឈ្មោះថា **អនិច្ចលក្ខណៈ** ។

បញ្ចក្ខន្ធនោះឯង ឈ្មោះថា **ទុក្ខ** ព្រោះព្រះបាលីថា "វត្ថុណាមិនទៀង, វត្ថុនោះជាទុក្ខ" ដូច្នេះ ។ ព្រោះហេតុអ្វី ? ព្រោះមានការគាបសង្កត់រឿយៗ; អាការ (គឺលក្ខណៈ) ដែលគាបសង្កត់រឿយៗ ឈ្មោះថា ទុក្ខលក្ខណៈ ។

ក៏បញ្ចក្ខន្ធនោះឯង ឈ្មោះថា **អនត្តា** ព្រោះព្រះបាលីថា "វត្ថុណាជាទុក្ខ វត្ថុនោះជាអនត្តា" ដូច្នេះ ។ ព្រោះហេតុអ្វី ? ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ។ អាការ (គឺលក្ខណៈ) ដែលមិនប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ឈ្មោះថា អនត្តលក្ខណៈ; ព្រោះហេតុនោះ **អនិច្ចំ ទុក្ខំ** និង **អនត្តា** ទើបជាម្យ៉ាង; **អនិច្ចលក្ខណៈ ទុក្ខលក្ខណៈ** និង **អនត្តលក្ខណៈ** ទើបជាម្យ៉ាង ។

ពិតណាស់ ពាក្យថា ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ នេះ សូម្បីទាំងអស់ ឈ្មោះថា **មិនទៀង ជាទុក្ខ ជាអនត្តា,** តែវិការៈ (ការប្រែប្រួល) នៃអាការ (លក្ខណៈ) មានប្រការតាមដែលពោលមកហើយ ឈ្មោះថា **អនិច្ចលក្ខណៈ ទុក្ខ-លក្ខណៈ និងអនត្តលក្ខណៈ**ដូច្នេះឯង ។

ម្យ៉ាងទៀត ពោលដោយសង្ខេបក្នុងអាយតនវិភង្គនេះ អាយតនៈ ១២ ជាកាមាវចរ; អាយតនៈ ២ (គឺមនាយតនៈ និងធម្មាយតនៈ) ប្រព្រឹត្តទៅក្នុងភូមិ ៣ វារៈអំពីការពិចារណាគប្បីជ្រាបថាត្រាស់ទុកក្នុងអាយតនៈទាំងអស់នោះឯង ៕

**ចប់វណ្ណនាសុត្តន្តភាជនិយ**

## ពណ៌នាអំពីអភិធម្មភាជនិយ

ព្រះមានព្រះភាគជាម្ចាស់ត្រាស់អាយតនៈទាំងឡាយទុក (ក្នុងសុត្តន្តភាជ-នីយ៍) ក្នុងពេលក្រោយ ដោយសេចក្ដីជាអាយតនៈ គួរថា **"ចក្ខាយតនំ រូបា-យតនំ** = ចក្ខាយតនៈ រូបាយតនៈ" ជាដើម ដើម្បីជាប្រយោជន៍ ជាឧបការៈដល់យោគាវចរទាំងឡាយ អ្នកចម្រើនវិបស្សនា យ៉ាងណា, ក្នុងព្រះអភិធម្មភាជនិយមិនបានត្រាស់យ៉ាងនោះទេ, សូម្បីទ្រង់ប្រាថ្នាសម្ដែងសភាវៈ អាយតនៈ ខាងក្នុង និងអាយតនៈខាងក្រៅ ដោយអាការ (លក្ខណៈ) ទាំងពួង ទើបត្រាស់ដោយអំណាចនៃការកំណត់អាយតនៈខាងក្នុង និងខាងក្រៅ យ៉ាងនេះថា **"ចក្ខាយតនំ សោតាយតនំ** = ចក្ខាយតនៈ សោតាយតនៈ" ជាដើម ។

ក្នុងនិទ្ទេសវារៈនៃអាយតនៈទាំងនោះ គប្បីជ្រាបពាក្យថា បណ្ដាអាយតនៈ

ទាំង ១២ នោះ **ចក្ខាយតនៈតើយ៉ាងណា**ដូច្នេះជាដើម ដោយន័យដែលពោលទុកក្នុងពេលក្រោយនោះឯង ។ តែក្នុងពាក្យដែលត្រាស់ទុកក្នុងនិទ្ទេស នៃធម្មាយតនៈថា "**តត្ថ កតមា អសង្ខតា ធាតុ, រាគក្ខយោ ទោសក្ខយោ មោហក្ខយោ** = ក្នុងអាយតនៈទាំងនោះ អសង្ខតធាតុតើដូចម្ដេច ? ការអស់រាគៈ ទោសៈ និងមោហៈជាដើម មានអធិប្បាយដូចតទៅនេះ ៖

បទថា "**អសង្ខតា ធាតុ** = អសង្ខតធាតុ" បានដល់ ព្រះនិព្វានដែលមានអសង្ខតជាសភាវៈ (ធម៌ដែលបច្ច័យប្រជុំតាក់តែងមិនបានជាសភាវៈ), តែព្រោះអាស្រ័យនិព្វាននេះ កិលេសទាំងឡាយមានរាគៈជាដើម រមែងអស់ទៅ ព្រោះហេតុដូច្នោះ ទើបត្រាស់ថា "**ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈ**" ។ នេះជាពាក្យអធិប្បាយសេចក្ដីដែលដូចគ្នា របស់អាចារ្យទាំងឡាយ ក្នុងនិទ្ទេសនៃអភិធម្មភាជនិយនេះ ។

តែអាចារ្យវិតណ្ឌវាទីពោលថា "**ធម្មតាថា និព្វានដោយចំពោះតែម្យ៉ាងដោយឡែកមិនមាន, មានតែនិព្វាន គឺការអស់ទៅនៃកិលេសទាំងអស់**" ដូច្នេះ ។ តែកាលបើមានអ្នកតវ៉ាថា "កាលបើយ៉ាងនោះ ចូរនាំសូត្រមក ក៏នឹងអាង **ជម្ពុខាទកសូត្រ**[៤៨] នេះថា 'ម្នាលលោកសារីបុត្រ ដែលហៅថា **និព្វានំ និព្វានំ**" ដូច្នេះ, អាវុសោ និព្វានតើយ៉ាងណា ?, អាវុសោ ការអស់រាគៈ ទោសៈ និងមោហៈនេះឯង ហៅថានិព្វាន ហើយពោលពាក្យដែលគួរពោល ដោយព្រះសូត្រនេះថា "ធម្មតានិព្វានដោយចំពោះមិនមានទេ, មានតែនិព្វាន គឺការអស់កិលេសប៉ុណ្ណោះ" ដូច្នេះ ។

---

[៤៨] សំ. សឡា. ។ [៤៩] សំ. សឡា. ។

គប្បីតវ៉ាលោកអាចារ្យវិតណ្ឌវាទីថា "ក៏សេចក្តីដូចជាព្រះសូត្រនេះឬ ?" លោកអាចារ្យវិតណ្ឌវាទីនឹងឆ្លើយថា មិនមែនទេ ! សេចក្តីដែលផុតចាកសូត្រទៅមិនបានមានឡើយ ។

លំដាប់នោះ គប្បីពោលនឹងលោកអាចារ្យវិតណ្ឌវាទីថា "សូត្រនេះ លោកនេះអាងមកពីមុន; សូមឱ្យនាំសូត្របន្ទាប់មកសម្តែង" ។ ទើបអាចារ្យវិតណ្ឌវាទីនាំសូត្រឈ្មោះដែលជាបន្ទាប់ទៅនៃសូត្រនោះមកសម្តែងយ៉ាងនេះថា "ម្នាលអាវុសោសារីបុត្រ ដែលលោកហៅថា អរហត្ត អរហត្ត, ម្នាលអាវុសោ អរហត្ត តើយ៉ាងណា ?; ម្នាលអាវុសោ ការអស់រាគៈ ទោសៈ និងមោហៈ នេះហៅថា អរហត្ត"[៤៩] ។

កាលអាចារ្យវិតណ្ឌវាទីនាំសូត្រនេះមក ជនទាំងឡាយក៏ពោលនឹងអាចារ្យវិតណ្ឌវាទីនេះថា "ធម៌ដែលរាប់បញ្ចូលនឹងធម្មាយតនៈ ឈ្មោះថា **និព្វាន**; នាមក្ខន្ធ ៤ ឈ្មោះថា **អរហត្ត**; ព្រះធម្មសេនាបតីអ្នកធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន កាលបើមានអ្នកសួរដល់ព្រះនិព្វានខ្លះ សួរដល់អរហត្តខ្លះ ក៏ពោលដល់ការអស់កិលេសប៉ុណ្ណោះ; ក៏និព្វាន និងព្រះអហត្តដូចគ្នា ឬផ្សេងគ្នាយ៉ាងណា ? និព្វានដូចគ្នា ឬផ្សេងគ្នាចូរលើកទុកសិនចុះ, ក្នុងទីនេះ សេចក្តីដែលលោកធ្វើឱ្យល្អិតពេកទៅបានការអ្វី លោកមិនដឹងព្រះនិព្វានតែដូចគ្នា ឬផ្សេងគ្នានោះទេឬ ? កាលលោកដឹងហើយក៏ជាការល្អមិនមែនឬ ?, លោកអាចារ្យវិតណ្ឌវាទីត្រូវគេសួរញយៗ យ៉ាងនេះ ក៏មិនអាចពោលឱ្យខុសទៅចាកសេចក្តីពិត ក៏នឹងពោលថា "អរហត្ត ព្រះអង្គក៏ត្រាស់ថា ការអស់រាគៈ ទោសៈ និងមោហៈ ព្រោះភាពនៃព្រះអរហត្តនោះ កើតឡើងក្នុងទីបំផុតនៃការអស់រាគៈជាដើម" ។

លំដាប់នោះ ជនទាំងឡាយក៏ពោលនឹងអាចារ្យវិតណ្ឌវាទីនោះថា "លោកធ្វើកម្មធំហើយ, សូម្បីឱ្យសំណួកហើយឱ្យពោលយ៉ាងនោះ, តែត្រឡប់ទៅជានិយាយយ៉ាងនេះវិញ; ក៏និព្វាននេះព្រះមានព្រះភាគជាម្ចាស់ ទ្រង់ចែកទុក ទ្រង់ត្រាស់ទុកយ៉ាងណា, លោកចូរកំណត់និព្វាននេះឯង យ៉ាងនោះចុះ; ព្រោះអាស្រ័យនិព្វានហើយ កិលេសមានរាគៈជាដើម រមែងអស់ទៅ ព្រោះហេតុនោះ ទើបត្រាស់ថា 'និព្វាន គឺការអស់រាគៈ ទោសៈ និងមោហៈ" ដូច្នេះ; ព្រោះសូម្បីពាក្យទាំង ៣ នេះ ក៏ជាឈ្មោះរបស់ព្រះនិព្វានដូចគ្នាដែរ ។

បើពោលយ៉ាងនេះ ប្រាប់សេចក្តីយល់គ្នាបាន, នោះជាការល្អ; បើនៅមិនយល់ ក៏គប្បីឱ្យធ្វើសភាវៈកំណត់; តើធ្វើយ៉ាងណា ? គឺគប្បីសួរជាមុនយ៉ាងនេះថា "ឈ្មោះថា ការអស់រាគៈ**ជាការអស់ទៅនៃរាគៈតែម្យ៉ាង**, ឬជាការអស់ទៅនៃទោសៈ និងមោហៈដែរ, ឈ្មោះថា **ការអស់ទោសៈ** ជាការអស់ទៅនៃទោសៈតែម្យ៉ាង ឬថាជាការអស់ទៅនៃរាគៈ និងមោហៈដែរ, ឈ្មោះថា **ការអស់មោហៈ** ជាការអស់ទៅនៃមោហៈតែម្យ៉ាង ឬជាការអស់ទៅនៃរាគៈ និងទោសៈដែរ" ដូច្នេះ ។

ពិតប្រាកដណាស់ អាចារ្យវិតណ្ឌវាទីនោះនឹងពោលថា "ឈ្មោះថា ការអស់រាគៈ ជាការអស់ចំពោះរាគៈតែម្យ៉ាង ឈ្មោះថា ការអស់ទោសៈ ជាការអស់ចំពោះទោសៈតែម្យ៉ាង ឈ្មោះថា ការអស់មោហៈ គឺជាការអស់ចំពោះមោហៈតែម្យ៉ាង" ដូច្នេះ ។

លំដាប់នោះ គប្បីពោលនឹងអាចារ្យវិតណ្ឌវាទីថា ៖ "ក្នុងវាទៈរបស់លោក ការអស់រាគៈជានិព្វាន ១, ការអស់ទោសៈជានិព្វាន ១, ការអស់មោហៈ ជានិព្វាន

១, ការអស់អកុសលមូល ៣ យ៉ាង និព្វានក៏មាន ៣ យ៉ាង, ការអស់ឧបាទាន ៤ ក៏មាននិព្វាន ៤ យ៉ាង, ការអស់នីវរណៈ ៥ យ៉ាង ក៏មាននិព្វាន ៥ យ៉ាង, ការអស់កងនៃតណ្ហា ៦ យ៉ាង ក៏មាននិព្វាន ៦ យ៉ាង, ការអស់អនុស័យ ៧ យ៉ាង ក៏មាននិព្វាន ៧ យ៉ាង, ការអស់មិច្ឆត្តៈ ៨ យ៉ាង ក៏មាននិព្វាន ៨ យ៉ាង, ការអស់ធម៌ដែលជាមូលនៃតណ្ហា ៩ យ៉ាង ក៏មាននិព្វាន ៩ យ៉ាង, ការអស់សំយោជនៈ ១០ យ៉ាង ក៏មាននិព្វាន ១០ យ៉ាង, ការអស់កិលេស ១៥០០ យ៉ាង និព្វានក៏មានតែគ្រប់យ៉ាង, ព្រោះហេតុនោះ និព្វានទើបមានច្រើន; ក៏និព្វានរបស់លោកមិនមានប្រមាណ" ដូច្នេះ ។

ក៏បុគ្គលមិនកាន់យកយ៉ាងនេះ ក៏នឹងពោលថា កិលេសទាំងឡាយមានរាគៈជាដើម អាស្រ័យព្រះនិព្វានហើយក៏អស់ទៅ, ព្រោះហេតុនោះ ព្រះនិព្វាន ទើបមានតែម្យ៉ាងប៉ុណ្ណោះ គឺការអស់រាគៈ ទោសៈ និងមោហៈ; ព្រោះការអស់អកុសលមូល សូម្បីទាំង ៣ នេះ ក៏ជាឈ្មោះរបស់ព្រះនិព្វានដែរ; សូមលោកយល់យ៉ាងនេះតែថា ពួកជនដទៃសូម្បីពោលយ៉ាងនេះហើយ អាចារ្យវិតណ្ឌវាទី ក៏នៅតែកំណត់មិនបាន, ក៏គប្បីធ្វើការអធិប្បាយ ព្រះនិព្វានដោយប្រៀបជាមួយនឹងរបស់គ្រោតគ្រាត។; អធិប្បាយយ៉ាងណា ? គឺថាសត្វអ្នកល្ងង់ខ្លៅសូម្បីមានខ្លាឃ្មុំ ខ្លាដំបង ម្រឹគ និងស្វាជាដើម ក៏ត្រូវកិលេសរុកទន្ទ្រានហើយ រមែងសេពវត្ថុ (មេថុន); កាលដល់ទីបំផុតនៃការសេពរបស់សត្វពួកនោះ កិលេសទាំងឡាយក៏ស្ងប់; ក្នុងវាទៈរបស់លោក ពួកសត្វមានខ្លាឃ្មុំ ខ្លាដំបង ម្រឹគ និងសត្វស្វាជាដើម ក៏ឈ្មោះថា អ្នកដល់និព្វានហើយ, និព្វានរបស់លោកគ្រោតគ្រាតហ្ន៎ ! ជារបស់គ្រោតគ្រាត អាក្រក់,

នរណា១ មិនអាចដើម្បីផ្ចង់ត្រចៀក (ស្តាប់) បាន ។

ម្យ៉ាងទៀត អាចារ្យវិតណ្ឌវាទីរមែងមិនទទួលបែបនេះ ក៏ត្រូវពោលថា កិលេសទាំងឡាយមានរាគៈជាដើមអស់ទៅ ព្រោះអាស្រ័យព្រះនិព្វាន ព្រោះហេតុនោះ ព្រះនិព្វានទើបមានតែម្យ៉ាងប៉ុណ្ណោះ គឺការអស់រាគៈ ទោសៈ និងមោហៈ, ព្រោះថា ការអស់អកុសលសូម្បីទាំង ៣ នេះ ក៏ជាឈ្មោះរបស់ព្រះនិព្វានប៉ុណ្ណោះ លោកចូរកាន់យកដោយអាការយ៉ាងនេះចុះ ។

តែសូម្បីគេពោលយ៉ាងនេះហើយ អាចារ្យវិតណ្ឌវាទីនោះនៅកំណត់មិនបាន, ក៏គួរអធិប្បាយ សូម្បីដោយគោត្រភូ; អធិប្បាយយ៉ាងណា ? គឺថា គប្បីសួរអាចារ្យវិតណ្ឌវាទីយ៉ាងនេះជាមុនថា "លោកពោលថា ឈ្មោះថា គោត្រភូមានឬ?"; អាចារ្យវិតណ្ឌវាទីក៏នឹងឆ្លើយថា "មែន ខ្ញុំតែងតែពោល" ដូច្នេះ ហើយទើបពោលនឹងអាចារ្យវិតណ្ឌវាទីថា "ក្នុងខណៈនៃគោត្រភូ កិលេសទាំងឡាយអស់ទៅហើយ ឬកំពុងអស់ ឬនឹងអស់" ដូច្នេះ ។ អាចារ្យវិតណ្ឌវាទី ក៏នឹងពោលថា "កិលេសទាំងឡាយនៅមិនអស់ទៅ មិនមែនកំពុងអស់ទៅទេ ក៏ប៉ុន្តែថា នឹងអស់ទៅ" ដូច្នេះ ។ សួរទៀតថា ក៏គោត្រភូមានអ្វីជាអារម្មណ៍ ? ឆ្លើយថា មាននិព្វានជាអារម្មណ៍ ។ ក្នុងខណៈនៃគោត្រភូរបស់លោក កិលេសទាំងឡាយនៅមិនទាន់អស់ទៅ មិនមែនកំពុងអស់ តាមដែលពិតនឹងត្រូវតែអស់; កាលកិលេសទាំងឡាយនៅមិនទាន់អស់ទៅ លោករមែងបញ្ញត្តិការអស់ទៅនៃកិលេសថាជានិព្វាន, កាលនៅមិនទាន់លះអនុស័យ លោករមែងបញ្ញត្តិការលះអនុស័យថាជានិព្វាន, ពាក្យនោះ១របស់លោកមិនសមឡើយ ។

ក៏ពាក្យយ៉ាងនេះ អាចារ្យវិតណ្ឌវាទីក៏នៅមិនកាន់យក ក៏នឹងត្រូវពោលថា "កិលេសទាំងឡាយមានរាគៈជាដើមអស់ទៅ ព្រោះអាស្រ័យព្រះនិព្វាន ព្រោះហេតុនោះ ព្រះនិព្វានទើបមានតែម្យ៉ាង គឺការអស់រាគៈ ទោសៈ និងមោហៈ; ការអស់អកុសលមូល សូម្បីទាំង ៣ នេះ ក៏ជាឈ្មោះរបស់ព្រះនិព្វាន លោកកាន់យកយ៉ាងនេះ" ដូច្នេះ ។

សូម្បីគេពោលយ៉ាងនេះ ក៏អាចារ្យវិតណ្ឌវាទីនៅតែកំណត់មិនបាន, ក៏គួរធ្វើអធិប្បាយ **ដោយមគ្គ**; អធិប្បាយយ៉ាងណា ? គឺគប្បីសួរលោកអាចារ្យវិតណ្ឌ-វាទីយ៉ាងនេះសិនថា "លោកពោលឈ្មោះថា មគ្គឬ ?" លោកក៏នឹងឆ្លើយតបថា "មែន ! យើងតែងតែពោល" ។ សួរទៀតថា "ក្នុងខណៈនៃមគ្គ កិលេសទាំងឡាយអស់ទៅហើយ ឬកំពុងអស់ ឬថានឹងអស់" ដូច្នេះ ។

កាលអាចារ្យវិតណ្ឌវាទីដឹង ក៏នឹងឆ្លើយតបថា "ក្នុងខណៈនៃមគ្គមិនគួរនឹងពោលថា កិលេសទាំងឡាយអស់ហើយ ឬថានឹងអស់ តែគួរនឹងពោលថា 'កិលេសទាំងឡាយកំពុងអស់ទៅ" ដូច្នេះ ។

ក៏គួរប្រឆាំងលោកអាចារ្យវិតណ្ឌវាទីថា "ប្រសិនបើ ព្រះនិព្វានប្រភេទណាញុំាងកិលេសឱ្យអស់ទៅនៅមានដល់មគ្គយ៉ាងនេះ, កិលេសដែលអស់ទៅ យ៉ាងណានៅមានដោយមគ្គយ៉ាងនេះសោត, ក៏មគ្គនឹងធ្វើព្រះនិព្វានកាលណា ដែលញុំាងកិលេសឱ្យអស់ទៅឱ្យជាអារម្មណ៍ ហើយញុំាងកិលេសពួកណា ឱ្យអស់ទៅ; ព្រោះហេតុដូច្នោះ លោកកុំឱ្យកាន់យកយ៉ាងនេះឡើយ; ក៏កិលេសមានរាគៈជាដើមអស់ទៅ ព្រោះអាស្រ័យព្រះនិព្វាន ព្រោះហេតុដូច្នោះ នឹងពោលថា ព្រះនិព្វានមានតែ

ម្យ៉ាងប៉ុណ្ណោះ គឺការអស់រាគៈ ទោសៈ និងមោហៈ; សូម្បីអកុសលមូលទាំង ៣ នេះ ដែលអស់ទៅ ក៏ជាឈ្មោះរបស់ព្រះនិព្វានប៉ុណ្ណោះ” ដូច្នេះ ។

លុះពោលយ៉ាងនេះហើយ ក៏ពោលនឹងអាចារ្យវិតណ្ឌវាទីនោះយ៉ាងនេះថា “លោកអាចារ្យរមែងពោលថា ‘**អាស្រ័យ អាស្រ័យឬ** ?” អាចារ្យវិតណ្ឌវាទី ក៏នឹងនិយាយថា “មែន ! ខ្ញុំពោល” ។ សួរទៀតថា “ពាក្យថា ឈ្មោះថា **អាស្រ័យ**” ដូច្នេះនេះ លោកបានមកអំពីណា ? លោកក៏នឹងឆ្លើយតបថា បានមកអំពីសូត្រ; លោកចូរនាំសូត្រមក ។ ទើបនាំសូត្រមកថា “**អវិជ្ជា** និង**តណ្ហា** អាស្រ័យព្រះនិព្វានហើយចេញទៅក្នុងព្រះនិព្វាននោះ អស់ទៅក្នុងព្រះនិព្វាននោះ និងមិនដល់សេចក្តីជាអ្វីៗ ក្នុងទីណាៗ; កាលពោលយ៉ាងនេះហើយ បរវាទី (អ្នកមានវាទៈក្នុងលទ្ធិខាងក្រៅព្រះសាសនា) ក៏នឹងដល់សេចក្តីជាអ្នកតុណ្ហីភាពនោះឯង ។

សូម្បីក្នុងអភិធម្មភាជនិយនេះ អាយតនៈ ១០ ជាកាមាវចរ ចំណែកអាយតនៈ ២ គប្បីជ្រាបថា ប្រព្រឹត្តទៅក្នុងភូមិ ៤ គឺច្របូកច្របល់គ្នាទាំងលោកិយទាំងលោកុត្តរដូច្នេះឯង ៕

**ចប់វណ្ណនាអភិធម្មភាជនិយ**

## ពណ៌នាអំពីបញ្ហាបុច្ឆកៈ

ក្នុងបញ្ហាបុច្ឆកៈ សូម្បីក្នុងអាយតនវិភង្គនេះ អាយតនៈណាដែលបាន, អាយតនៈណាដែលមិនបាន, ព្រះអង្គត្រាស់សួរអាយតនៈនោះទាំងអស់ ហើយទ្រង់វិស្សជ្ជនាដោយអំណាចនៃអាយតនៈដែលបានប៉ុណ្ណោះ; មិនមែនក្នុងទីនេះតែម្យ៉ាង

ទេ, សូម្បីក្នុងបញ្ហាបុច្ឆកៈទាំងអស់ ក៏ន័យនេះដែរ ។

ក៏អាយតនៈទាំងអស់ក្នុងទីនេះ គប្បីជ្រាបសេចក្ដីដែលអាយតនៈ ១០ ជាអព្យាកតៈ ដោយសេចក្ដីជារូប; គប្បីជ្រាបសេចក្ដីដែលអាយតនៈ ២ ជាកុសលជាដើមដូចខន្ធ ៤ ក្នុងវិភង្គ; ព្រោះខន្ធ ៤ ជាធម៌មានបច្ច័យផង ជាសង្ខតៈផងទាំងអស់មែនពិត, តែធម្មាយតនៈមានមកហើយថា “គប្បីជា**អប្បច្ច័យ**ក៏មាន គប្បីជា**អសង្ខតៈ**ក៏មាន” ។

ម្យ៉ាងទៀត ក្នុងអារម្មណត្តិកៈ ធម្មាយតនៈជាអនារម្មណ៍ គឺសុខុមរូបរមែងចូលគ្នា និងចំណែកនៃអារម្មណ៍ជានវត្តព្វារម្មណ៍ (អារម្មណ៍ដែលមិនគប្បីពោល); ក៏សេចក្ដីប្លែកគ្នាក្នុងអាយតនវិភង្គនេះដូច្នេះ គឺធម្មាយតនៈនោះឯង មិនមានអារម្មណ៍, ឯធម្មារម្មណ៍ជានវត្តព្វារម្មណ៍ (គឺអារម្មណ៍ដែលគប្បីពោលមិនបាន) ដោយមិនជាបរិត្តារម្មណ៍ជាដើម ។ ពាក្យដ៏សេស ក៏ដូចគ្នាដែរ ។

អាយតនៈ ២ សូម្បីក្នុងទីនេះ ក៏ដូចខន្ធ ៤ គឺពាក្យទាំងអស់ថា កាលបុគ្គលអ្នកមានចិត្តត្រេកអរ អ្នកមានចិត្តប្រទូសរ៉ាយ អ្នកមានចិត្តវង្វេង អ្នកសង្រួម អ្នកពិចារណា និងអ្នកពិចារណាឃើញថា មានបរិត្តារម្មណ៍ ក៏ប្រារព្ធនូវកាមាវចរធម៌ ៥៥ ប្រព្រឹត្តទៅ ហាក់ដូចជាពាក្យដែលពោលទុកក្នុងខន្ធទាំងឡាយដូច្នោះដែរ ៕

**ចប់អាយតនវិភង្គនិទ្ទេសទី ២**

## ៣. ធាតុវិភង្គនិទ្ទេស

## សម្តែងអំពីសុត្តន្តភាជនិយ

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់បំប្រួញធាតុទាំងអស់ទុកក្នុងធាតុទាំង ៦ ពួក ទើបទ្រង់សម្តែងសុត្តន្តភាជនិយ ដោយពួកធាតុ ៦ រួមជា ៣ ពួក ក្នុងធាតុវិភង្គដែលជាលំដាប់តពីអាយតនវិភង្គនោះ ទើបត្រាស់ពាក្យ មានជាអាទិ៍ថា "**ឆ ធាតុយោ** = ធាតុពួក ៦" ។

បណ្តាបទទាំងនោះ បទថា "**ឆ** = ៦" ជាពាក្យកំណត់ចំនួន ។

បទថា **ធាតុយោ** ជាពាក្យសម្តែងធម៌ ដែលទ្រង់កំណត់ទុក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងឡាយ មានបទថា **បឋវីធាតុ** ជាដើមតទៅ ៖

បទថា **អត្ថា ធាតុ** មានសេចក្តីសម្គាល់ថាជាសភាវៈ, ឈ្មោះថា អត្តាជា**របស់សូន្យ** មានសេចក្តីសម្គាល់ថា មិនមែនសត្វ ព្រោះហេតុនោះ ដោយអត្ថដែលអធិប្បាយមកនេះ ធាតុ គឺ**បឋវី** (ដី) នោះឯង ឈ្មោះថា **បឋវីធាតុ** (ធាតុដី) ដោយអត្ថថា មានសភាពសូន្យ និងមិនមែនសត្វ ។ សូម្បីធាតុមានអាបោធាតុជាដើម ក៏ន័យនេះដែរ ។ បណ្ឌិតគប្បីជ្រាបបទសមាសក្នុងពាក្យថា បឋវីធាតុទាំងនេះយ៉ាងនេះហើយ គប្បីជ្រាបអត្ថ (សេចក្តីសម្គាល់) តទៅ ៖

ពាក្យថា "**បឋវីធាតុ** = ធាតុដី" បានដល់ ធាតុរឹង ។

ពាក្យថា "**អាបោធាតុ** = ធាតុទឹក" បានដល់ ធាតុរាវ ។

ពាក្យថា "**តេជោធាតុ** = ធាតុភ្លើង" បានដល់ ធាតុក្តៅ ។

ពាក្យថា "**វាយោធាតុ** = ធាតុខ្យល់" បានដល់ ធាតុកម្រើក ។

ពាក្យថា **“អាកាសធាតុ** = ធាតុ គឺរបស់ប្រហោង” បានដល់ ធាតុដែលផស្សះ (ពាល់ត្រូវ) មិនបាន ។

ពាក្យថា **“វិញ្ញាណធាតុ** = ធាតុ គឺវិញ្ញាណ” បានដល់ ធាតុដែលដឹងច្បាស់ ៕

## បឋវីធាតុនិទ្ទេស ២ យ៉ាង

បទថា **“បឋវីធាតុ ទ្វយំ** = បឋវីធាតុ ២ យ៉ាង” បានដល់ បឋវីធាតុនេះ មាន ២ យ៉ាង អធិប្បាយថា ឈ្មោះថា បឋវីធាតុ មិនមានតែម្យ៉ាងប៉ុណ្ណោះ, តែមាន ២ យ៉ាង ដោយញែកជាបឋវីធាតុ ខាងក្នុង និងបឋវីធាតុ ខាងក្រៅ; ដោយហេតុ នោះឯង ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **“អត្ថិ អជ្ឈត្តិកា, អត្ថិ ពាហិរា** = បឋវីធាតុ ខាងក្នុងក៏មាន, បឋវីធាតុ ខាងក្រៅក៏មាន” ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **“អជ្ឈត្តិកា** = ខាងក្នុង” បានដល់ ការរាប់បន្តបន្ទាប់ក្នុងស្ថានរបស់សត្វ គឺទីនៅក្នុងដែនជាទីកើតក្នុងខ្លួន ។ ពាក្យថា **“ពាហិរា** = ខាងក្រៅ” បានដល់ ការរាប់បន្តបន្ទាប់ក្នុងសន្តាន (ការរាប់ភ្ជាប់) របស់សង្ខារ គឺដែលមិនជាប់ដោយឥន្ទ្រិយ៍ ។ ពាក្យថា **“អជ្ឈត្តំ បច្ចត្តំ** = ជាខាងក្នុងចំពោះខ្លួន” នេះ សូម្បីទាំង ២ ក៏ជាឈ្មោះរបស់ធាតុ ដែលនៅខាងក្នុងដែនជាទីកើតក្នុងខ្លួននោះឯង ។

ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងបឋវីធាតុ នោះដោយអាការ (លក្ខណៈ) នៃភាវៈរបស់ខ្លួន ទើបត្រាស់ពាក្យថា **“កក្ខឡំ** = មាំមួន” ជាដើម ។ បណ្ដាពាក្យ

ទាំងនោះ ពាក្យថា "**កក្ខឡំ** = មាំមួន" បានដល់ ធម្មជាតិដែលរឹង ។ ពាក្យថា "**ខរិគតំ** = រឹងប៉ឹង" បានដល់ ធម្មជាតដែលគគ្រើម ។ ពាក្យថា "**កក្ខឡត្តំ** = សេចក្ដីមាំមួន" បានដល់ ភាវៈដែលរឹង ។ ពាក្យថា "**កក្ខឡភាវោ** = ភាវៈដែលរឹង" បានដល់ សភាវៈដែលរឹង ។

ពាក្យថា "**អជ្ឈត្តំ ឧបាទិន្នំ** = ឧបាទិន្នករូបដែលជាខាងក្នុង" បានដល់ ឧបាទិន្នករូប ពោលគឺរូបខាងក្នុងជាដែនកើតក្នុងខ្លួន, រូបដែលតាំងនៅក្នុងសរីរៈឈ្មោះថា ឧបាទិន្នកៈ; ពិតមែន រូបដែលតាំងនៅក្នុងសរីរៈ នឹងមានកម្មជាសមុដ្ឋានក៏មាន ឬមិនមានកម្មជាសមុដ្ឋានក៏មាន, ទ្រង់សំដៅយករូបដែលតាំងនៅក្នុងសរីរៈជាឧបាទិន្នកៈខ្លះ, ជាអនុបាទិន្នកៈខ្លះនោះឯង ។ តែដើម្បីទ្រង់សម្ដែងថា រូបដែលតាំងនៅក្នុងសរីរៈទាំងអស់នោះ ក៏ជាឧបាទិន្នករូប ដោយអំណាចនៃរូបដែលមានចិត្តគ្រប់គ្រង ដែលត្រូវតណ្ហា និងទិដ្ឋិប្រកាន់ទុកនោះពិតៗ ទើបត្រាស់ពាក្យថា "**អជ្ឈត្តំ ឧបាទិន្នំ**" ជាដើម ៕

## បឋវីធាតុនិទ្ទេសខាងក្នុង

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រាថ្នា និងសម្ដែងបឋវីធាតុ នោះពិតៗ ដោយអំណាចនៃវត្ថុ ទើបត្រាស់ពាក្យថា "**សេយ្យថីទំ កេសា លោមា**" ជាដើម ។

ក្នុងព្រះបាលីនោះ ពាក្យថា **សេយ្យថីទំ** ជានិបាត ។ ពាក្យថា **“សេយ្យថីទំ”** នេះ មានអធិប្បាយថា បឋវីធាតុ ដែលជាខាងក្នុង, តើយ៉ាងណា ? ឬថា រូបដែលនៅខាងក្នុងជារបស់ចំពោះខ្លួន ឈ្មោះថាជាធម្មជាតរឹងនោះ តើដូចម្ដេច ?

ពាក្យថា **“កេសា លោមា”** ជាដើម ជាពាក្យសម្ដែងប្រភេទនៃបឋវីធាតុដែលជាខាងក្នុងនោះ ដោយអំណាចជាវត្ថុ, មានពាក្យអធិប្បាយទុកយ៉ាងនេះថា ៖ ឈ្មោះថា **កេសា** (សក់ទាំងឡាយ) នៅខាងក្នុងជាឧបាទិន្នករូប ជារបស់តាំងនៅក្នុងសរីរៈ មានភាពរឹងជាលក្ខណៈ ជាកោដ្ឋាសៈ (ចំណែក) មួយដោយឡែកក្នុងសរីរៈនេះ ។ ឈ្មោះថា **លោមា** = រោមទាំងឡាយ ។ល។ ឈ្មោះថា **ករីសំ** = អាហារចាស់ ។ **មត្ថលុង្គំ** (ខួរក្នុងក្បាល) សូម្បីមិនបានត្រាស់ទុកក្នុងធាតុវិភង្គនេះ, តែព្រះអង្គក៏លើកឡើងឆ្ពោះទៅកាន់បាលីក្នុងបដិសម្ភិទាមគ្គ ឈ្មោះថា **មត្ថលុង្គំ** ដែលនាំមកហើយ ជារបស់ខាងក្នុង ជាឧបាទិន្នករូប តាំងនៅក្នុងសរីរៈ មានភាពរឹងជាលក្ខណៈ ជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ ។ សូម្បីក្នុងទឹកប្រមាត់ជាដើម ក្នុងនិទ្ទេសនៃអាបោធាតុជាដើមខាងមុខ ក៏មានន័យដូចគ្នានេះដែរ ។

**សួរថា** ដោយពាក្យថា **សេយ្យថីទំ កេសា** ជាដើមនេះ ទ្រង់សម្ដែងអ្វី ?

ឆ្លើយថា ទ្រង់សម្ដែងមនសិការធាតុ ។

**សួរថា** ក៏កុលបុត្រអ្នកប្រាថ្នានឹងធ្វើកម្មដ្ឋាន ក្នុងមនសិការធាតុនេះហើយ ផ្ដើមវិបស្សនាដើម្បីពន្លុះព្រះអរហត្តដែលជាប្រយោជន៍ខ្ពង់ខ្ពស់ គប្បីធ្វើយ៉ាងណា ?

ឆ្លើយថា គប្បីជម្រះចតុប្បារិសុទ្ធិសីលឱ្យបរិសុទ្ធ ។ ព្រោះថា **ការចម្រើនកម្មដ្ឋាន រមែងសម្រេចដល់បុគ្គលអ្នកមានសីល**, វិធីធ្វើការជម្រះចតុប្បារិសុទ្ធិសីលនោះ

គប្បីជ្រាបដោយន័យដែលពោលទុកក្នុងវិសុទ្ធិមគ្គនោះចុះ ។ ក៏កុលបុត្រ អ្នកមានសីលបរិសុទ្ធហើយតាំងនៅក្នុងសីល គប្បីកាត់បលិពោធ (សេចក្ដីកង្វល់) ខាងដើម ១០ យ៉ាង; វិធីកាត់បលិពោធ សូម្បីទាំង ១០ នោះ ក៏គប្បីជ្រាបដោយន័យ ដែលពោលទុកនៅក្នុងវិសុទ្ធិមគ្គនោះឯង, កាលកុលបុត្រអ្នកកាត់បលិពោធហើយ គប្បីរៀនយកកម្មដ្ឋានមនសិការធាតុ សូម្បីអាចារ្យអ្នកឱ្យ កាលអន្តេវាសិករៀនកម្មដ្ឋានមនសិការធាតុ ក៏គប្បីប្រាប់ឧគ្គហកោសល្យ ៧ យ៉ាង [៥០] និងមនសិការកោសល្យ ១០ យ៉ាង; សូម្បីអន្តេវាសិក ក៏គួរស្វាធ្យាយក្នុងសំណាក់នៃអាចារ្យឱ្យច្រើន ហើយធ្វើកម្មដ្ឋានឱ្យជំនាញអស់សេចក្ដីស្នេហ៍ស្នាញ ។ ខនេះសមដូចលោក ពោលទុកក្នុងអដ្ឋកថាថា "ភិក្ខុអ្នកចម្រើនកម្មដ្ឋាន ជាអ្នកប្រាថ្នាដើម្បីនឹងផុតចាកជរា និងមរណៈ គប្បីប្រាថ្នាឧគ្គហកោសល្យ ដោយអាការ ៧ យ៉ាង, គប្បីប្រាថ្នាមនសិការកោសល្យដោយអាការ ១០ យ៉ាង" ៕

## សម្ដែងអំពីឧគ្គហកោសល្យ ៧ យ៉ាង

បណ្ដាឧគ្គហកោសល្យ និងមនសិការកោសល្យទាំងនោះ កុលបុត្រគប្បីប្រាថ្នាឧគ្គហកោសល្យ ក្នុងកម្មដ្ឋានមនសិការធាតុទាំងនេះ គឺ

- **វចសា** ដោយវាចា ១
- **មនសា** ដោយចិត្ត ១
- **វណ្ណតោ** ដោយពណ៌ ១

[៥០] អ្នកឆ្លាតក្នុងការរៀន ៧ យ៉ាង ។

**‐សណ្ឋានតោ** ដោយសណ្ឋាន ១

**‐ទិសតោ** ដោយទិស ១

**‐ឱកាសតោ** ដោយឱកាស ១

**‐បរិច្ឆេទតោ** ដោយបរិច្ឆេទ ១ ៕

## សម្តែងអំពីមនសិការកោសល្ល ១០ យ៉ាង

កុលបុត្រគប្បីប្រាថ្នាមនសិការកោសល្យដោយអាការទាំង ១០ នេះ គឺ

**១‐អនុបុព្វតោ** ដោយលំដាប់

**២‐នាតិសីឃតោ** ដោយមិនលឿនពេក

**៣‐នាតិសណិកតោ** ដោយមិនយឺតពេក

**៤‐វិក្ខេបបដិពាហនតោ** ដោយហាមការរវើរវាយ

**៥‐បណ្ណត្តិសមតិក្កមតោ** ដោយឈានកន្លងបញ្ញត្តិ

**៦‐អនុបុព្វមុញ្ចនតោ** ដោយលះលំដាប់

**៧‐លក្ខណតោ** ដោយលំដាប់នៃលក្ខណៈ

**៨‐៩‐១០‐តយោ ច សុត្តន្តា** ដោយសូត្រទាំង ៣ [៥១] ។

សូម្បីកោសល្យទាំង ២ នឹងជាក់ច្បាស់ក្នុងសតិប្បដ្ឋានវិភង្គខាងមុខ; ក៏កុល‐បុត្រអ្នកមានកម្មដ្ឋានដែលរៀនយកយ៉ាងនោះ គប្បីវៀរសេនាសនៈដែលមានទោស ១៨ យ៉ាង តាមដែលពោលទុកក្នុងវិសុទ្ធិមគ្គ, នៅក្នុងសេនាសនៈដែលប្រកបដោយ

[៥១] អធិចិត្តសូត្រ សីតិភាវសូត្រ និងពោជ្ឈង្គកោសល្លសូត្រ ។

អង្គ ៥, សូម្បីខ្លួនឯង ក៏ប្រកបដោយអង្គនៃភិក្ខុ អ្នកប្រកបដោយព្យាយាម ៥ យ៉ាង [៥២] ត្រឡប់ពីបិណ្ឌបាតក្នុងវេលាខាងក្រោយភត្តហើយ ចូលទៅកាន់ទីឱកាសដ៏ស្ងាត់ មនសិការកម្មដ្ឋាន; ក៏កុលបុត្រនោះកាលមនសិការ គប្បីមនសិការកោដ្ឋាសៈតែគ្រប់យ៉ាង ក្នុងបណ្ដាកោដ្ឋាសៈទាំងឡាយ មានសក់ជាដើម ដោយអំណាចនៃ **វណ្ណៈ សណ្ឋាន ទិស ឱកាស** និង **បរិច្ឆេទ** ក្នុងកាលជាទីបំផុត គប្បីឱ្យមនសិការប្រព្រឹត្តទៅយ៉ាងនេះ ៖

## សម្ដែងអំពីវិធីមនសិការ កេសា (សក់ទាំងឡាយ)

ធម្មតា **កេសា** គឺសក់ទាំងឡាយនេះកើតក្នុងស្បែកហ៊ុមលលាដ៍ក្បាល; ក្នុងសក់ទាំងឡាយនោះ ព្រះយោគីគប្បីមនសិការថា បណ្ដាស្មៅដីរ [៥៣] ទាំងឡាយដែលដុះលើដំបូក ដំបូករមែងមិនដឹងថា **"ស្មៅដីរទាំងឡាយដុះលើយើង"** , សូម្បីស្មៅដីរទាំងឡាយ ក៏មិនដឹងថា **"ពួកយើងដុះលើដំបូក"** យ៉ាងណា, ស្បែកហ៊ុមលលាដ៍ក្បាលក៏យ៉ាងនោះដែរ រមែងមិនដឹងថា **"សក់ទាំងឡាយកើតលើយើង"** , សូម្បីសក់ទាំងឡាយវិញ ក៏មិនដឹងថា **"ពួកយើងដុះក្នុងស្បែកហ៊ុមលលាដ៍ក្បាល"** ; ធម៌ទាំងឡាយនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះ

---

[៥២] ១-មានសទ្ធា, ២-មានរោគតិច ជាអ្នកអត់ធន់, ៣-ជាអ្នកមិនអួតអាង មិនមានមាយា, ៤-មានសេចក្ដីព្យាយាមមិនរួញរា, ៥-មានបញ្ញា មានភាពអាចឃើញការកើត និងការរលត់ (ចាកព្រះត្រៃបិដក) ។

[៥៣] អត្ថយោជនា ពន្យល់ថា បានដល់ ស្មៅស្បូវភ្លាំង ឬស្មៅទឹក ។

ថា សក់ទាំងឡាយជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## សម្តែងអំពីវិធីមនសិការ លោមា (រោមទាំងឡាយ)

**លោមា** រោមទាំងឡាយ កើតក្នុងស្បែកដណ្តប់សរីរៈ; ក្នុងរោមទាំងឡាយនោះ ព្រះយោគីគប្បីមនសិការថា បណ្តាស្មៅស្បូវភ្លាំងទាំងឡាយ ដែលកើតក្នុងទីសុញ្ញាគារ (ផ្ទះទទេ) ស្ថានទីសុញ្ញាគាររមែងមិនដឹងថា **"ស្មៅស្បូវភ្លាំងទាំងឡាយដុះលើយើង"**, សូម្បីស្មៅស្បូវភ្លាំងវិញ ក៏មិនដឹងថា **"ពួកយើងកើតក្នុងទីសុញ្ញាគារ"** យ៉ាងណា, ស្បែកដែលហ៊ុមសរីរៈ ក៏យ៉ាងនោះដែរ រមែងមិនដឹងថា "រោមទាំងឡាយកើតឡើងលើយើង", សូម្បីរោមទាំងឡាយ ក៏មិនដឹងថា "ពួកយើងកើតក្នុងស្បែកហ៊ុមសរីរៈ"; ធម៌ទាំងឡាយនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា រោមទាំងឡាយដែលជាកោដ្ឋាសៈមួយ ដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## សម្តែងអំពីវិធីមនសិការ នខា (ក្រចកទាំងឡាយ)

**នខា** ក្រចកទាំងឡាយ កើតត្រង់ចុងម្រាមទាំងឡាយ; ក្នុងក្រចកទាំងឡាយនោះ ព្រះយោគីគប្បីមនសិការថា ពួកក្មេងៗ យកកំណាត់ឈើតូចៗ ចាក់គ្រាប់ស្រគំលេង កំណាត់ឈើតូចៗ ទាំងឡាយរមែងមិនដឹងថា "គ្រាប់ស្រគំតាំងនៅ

ក្នុងពួកយើង" សូម្បីគ្រាប់ស្រគីវិញ ក៏រមែងមិនដឹងថា "ពួកយើងតាំងនៅក្នុងកំណាត់ឈើតូចៗ ទាំងឡាយ" យ៉ាងណា; ម្រាមដៃក៏យ៉ាងនោះដែរ រមែងមិនដឹងថា "ក្រចកទាំងឡាយកើតឡើងត្រង់ចុងម្រាមរបស់យើង" សូម្បីក្រចកទាំងឡាយវិញ ក៏មិនដឹងថា "ពួកយើងកើតត្រង់ចុងម្រាមដៃទាំងឡាយ" ។ ធម៌ទាំងឡាយនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ក៏ឈ្មោះថា ក្រចកទាំងឡាយដែលជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## **សំដែងអំពីវិធីមនសិការ ធន្តា** (ធ្មេញទាំងឡាយ)

**ទន្តា** ធ្មេញទាំងឡាយ កើតត្រង់ឆ្អឹងចង្កាទាំងឡាយ; ក្នុងធ្មេញទាំងឡាយនោះ ព្រះយោគីគប្បីមនសិការថា កាលនាយជាងយកជ័រស្អិតយ៉ាងណានីមួយ ភ្ជាប់ត្បាល់ថ្មតាំងទុកលើសសរ ត្បាល់ថ្មរមែងមិនដឹងថា **"សសរទាំងឡាយតាំងនៅលើពួកយើង"** សូម្បីសសរវិញក៏មិនដឹងថា "ពួកយើងតាំងនៅត្រង់ត្បាល់ទាំងឡាយ" យ៉ាងណា, ឆ្អឹងចង្កាទាំងឡាយក៏យ៉ាងនោះដែរ រមែងមិនដឹងថា "ធ្មេញទាំងឡាយកើតត្រង់ពួកយើង" ; សូម្បីពួកធ្មេញនោះវិញក៏មិនដឹងថា "ពួកយើងកើតត្រង់ឆ្អឹងចង្កាទាំងឡាយ" ; ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ធ្មេញទាំងឡាយ ជាកោដ្ឋាសៈមួយ ដោយឡែកក្នុងសរីរៈនេះមិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង

ឈ្មោះថា **បឋវីធាតុ** ៕

## **សម្តែងអំពីវិធីមនសិការ តចោ** (ស្បែក)

**តចោ** ស្បែក តាំងនៅហ៊ុមព័ទ្ធសរីរៈទាំងអស់ ក្នុងស្បែកដែលតាំងនៅហ៊ុមព័ទ្ធសរីរៈទាំងអស់នោះ ព្រះយោគីគប្បីមនសិការថា កាលពិណធំដែលហ៊ុមដោយស្បែកគោស្រស់ ពិណធំរមែងមិនដឹងថា“យើងត្រូវហ៊ុមដោយស្បែកគោស្រស់” , សូម្បីស្បែកគោស្រស់វិញ ក៏មិនដឹងថា “ពិណធំត្រូវយើងហ៊ុមព័ទ្ធ” យ៉ាងណា, សរីរៈក៏យ៉ាងនោះដែរ រមែងមិនដឹងថា “យើងត្រូវស្បែកហ៊ុមព័ទ្ធ” ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ស្បែកដែលជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## **សម្តែងអំពីវិធីមនសិការ មំសំ** (សាច់)

**មំសំ** សាច់ នៅជាប់នឹងរាងឆ្អឹង; ក្នុងសាច់នោះ ព្រះយោគីគប្បីមនសិការថា កាលជុំជីស្អិតធំមកលាបជាប់នូវជញ្ជាំងផ្ទះ ជុំជីស្អិតធំ រមែងមិនដឹងថា “ជញ្ជាំងផ្ទះត្រូវយើងលាបជាប់ទុក” សូម្បីជញ្ជាំងវិញ ក៏មិនដឹងថា“យើងត្រូវជុំជីស្អិតធំលាបជាប់ទុក” យ៉ាងណា, រាងឆ្អឹងក៏យ៉ាងនោះដែរ រមែងមិនដឹងថា “យើងត្រូវលាបជាប់ដោយចម្រៀកសាច់ ៩០០ ចំណិត” សូម្បីសាច់ក៏មិនដឹងថា “រាងឆ្អឹងត្រូវលាបជាប់ទុក” ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា;

ព្រោះហេតុនោះ ឈ្មោះថា សាច់ជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## សម្តែងអំពីវិធីមនសិការ នហារូ (សរសៃទាំងឡាយ)

**នហារូ** សរសៃទាំងឡាយ ចងរឹតឆ្អឹងទាំងឡាយខាងក្នុងសរីរៈ; ក្នុងសរីរៈនោះ ព្រះយោគីគប្បីមនសិការថា កំណាត់ឈើក្នុងខ្ទមទាំងឡាយ រមែងជារបស់ដែលគេយកវល្លិ៍មកចងគួចទុក កំណាត់ឈើទាំងឡាយក្នុងខ្ទម រមែងមិនដឹងថា "ពួកយើងត្រូវវល្លិ៍ចងជាបាច់ទុក" យ៉ាងណា, ឆ្អឹងទាំងឡាយ ក៏យ៉ាងនោះដែរ រមែងមិនដឹងថា "ពួកយើងត្រូវសរសៃចងរឹតទុក" សូម្បីសរសៃទាំងឡាយ ក៏មិនដឹងថា "ឆ្អឹងទាំងឡាយ ត្រូវពួកយើងចងរឹតទុក" ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា សរសៃទាំង-ឡាយ ជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## សម្តែងអំពីវិធីមនសិការ អដ្ឋិ (ឆ្អឹង)

បណ្តាឆ្អឹងទាំងឡាយ ឆ្អឹងកែងជើងទ្រទុកនូវឆ្អឹងភ្នែកគោ, ឆ្អឹងថ្នាំងភ្នែកគោយកស្មងជើងតាំងទុក, ឆ្អឹងស្មងជើងយកឆ្អឹងភ្លៅតាំងទុក, ឆ្អឹងភ្លៅយកឆ្អឹងចង្កេះតាំងទុក, ឆ្អឹងចង្កេះយកឆ្អឹងជើងក្រោយតាំងទុក, ឆ្អឹងជើងក្រោយយកឆ្អឹងកតាំងទុក,

ឆ្អឹងកយកឆ្អឹងសីសៈតាំងទុក, ឆ្អឹងសីសៈតាំងនៅខាងលើ-ក, ឆ្អឹងកតាំងនៅលើឆ្អឹងខ្នង, ឆ្អឹងខ្នងតាំងនៅលើឆ្អឹងចង្កេះ, ឆ្អឹងចង្កេះតាំងនៅលើឆ្អឹងភ្លៅ, ឆ្អឹងភ្លៅតាំងនៅលើឆ្អឹងស្មង, ឆ្អឹងស្មងតាំងនៅលើឆ្អឹងភ្នែកគោ, ឆ្អឹងភ្នែកគោតាំងនៅលើឆ្អឹងកែង ។

ក្នុងបណ្តាឆ្អឹងទាំងឡាយនោះ ព្រះយោគីគប្បីមនសិការថា បណ្តាវត្ថុទាំង-ឡាយដែលគរផ្តុំគ្នានៅលើឥដ្ឋ ចំណាំងឈើ និងអាចម៍គោជាដើម វត្ថុដែលនៅខាងក្រោមៗ រមែងមិនដឹងថា “ពួកយើងយកវត្ថុខាងលើៗ ឡើងតាំងទុក” សូម្បីវត្ថុខាងលើៗ ក៏មិនដឹងថា “ពួកយើងតាំងនៅខាងក្រោមៗ” យ៉ាងណា, ឆ្អឹងកែងក្រោមវិញក៏មិនដឹងថា “យើងលើកឆ្អឹងភ្នែកគោតាំងទុក” ឆ្អឹងភ្នែកគោវិញ ក៏មិនដឹងថា “យើងលើកឆ្អឹងភ្លៅតាំងទុក” , ឆ្អឹងភ្លៅក៏មិនដឹងថា “យើងលើកឆ្អឹងចង្កេះតាំងទុក” , ឆ្អឹងចង្កេះវិញ ក៏មិនដឹងថា “យើងលើកឆ្អឹងខ្នងតាំងទុក” ឆ្អឹងខ្នងវិញ ក៏មិនដឹងថា “យើងលើកឆ្អឹងកតាំងទុក” ឆ្អឹងកវិញ ក៏មិនដឹងថា “យើងយកឆ្អឹងសីសៈតាំងទុក” , ឆ្អឹងសីសៈវិញក៏មិនដឹងថា “យើងតាំងនៅលើឆ្អឹងក” ឆ្អឹងកវិញក៏មិនដឹងថា “យើងតាំងនៅលើឆ្អឹងខ្នង” ឆ្អឹងខ្នងវិញ ក៏មិនដឹងថា “យើងតាំងនៅលើឆ្អឹងចង្កេះ” , ឆ្អឹងចង្កេះវិញ ក៏មិនដឹងថា “យើងតាំងនៅលើឆ្អឹងភ្លៅ” ឆ្អឹងភ្លៅវិញក៏មិនដឹងថា “យើងតាំងនៅលើឆ្អឹងស្មង” ឆ្អឹងស្មងវិញ ក៏មិនដឹងថា “យើងតាំងនៅលើឆ្អឹងភ្នែកគោ” ឆ្អឹងភ្នែកគោវិញ ក៏មិនដឹងថា “យើងតាំងនៅលើឆ្អឹងកែង” ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ឆ្អឹងជាកោដ្ឋាសៈមួយ ដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង

**បឋវីធាតុ ៕**

## **សម្តែងអំពីវិធីមនសិការ អដ្ឋិមិញ្ជំ** (ខួក្នុងឆ្អឹង)

**អដ្ឋិមិញ្ជំ** ខួក្នុងឆ្អឹង តាំងនៅក្នុងឆ្អឹងពួកនោះៗ; ខួក្នុងឆ្អឹងទាំងនោះ ព្រះយោគីគប្បីមនសិការថា កាលបុគ្គលយកវល្លិ៍ផ្តៅទឹមួយជាដើម ហើយដាក់ចូលទៅក្នុងបំពង់ឫស្សីជាដើម បំពង់ឫស្សីជាដើមរមែងមិនដឹងថា "វល្លិ៍ផ្តៅជាដើមចូលដាក់ទុកក្នុងពួកយើង" , សូម្បីវល្លិ៍ផ្តៅជាដើមវិញ ក៏មិនដឹងថា "ពួកយើងតាំងនៅក្នុងបំពង់ឫស្សីជាដើម" យ៉ាងណា, ឆ្អឹងទាំងឡាយក៏ដូច្នោះដែរ រមែងមិនដឹងថា "ខួក្នុងឆ្អឹងតាំងនៅខាងក្នុងរបស់ពួកយើង" សូម្បីខួក្នុងឆ្អឹងវិញ ក៏មិនដឹងថា "យើងតាំងនៅខាងក្នុងរបស់ឆ្អឹងទាំងឡាយ" ; ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ខួក្នុងឆ្អឹងជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## **សម្តែងអំពីវិធីមនសិការ វក្កំ** [៥៤] (ទាច)

**វក្កំ** ទាច តាំងនៅឡោមព័ទ្ធសាច់បេះដូងដែលចងទុកដោយសរសៃធំ មានគល់ជាមួយគ្នា ចេញពីបំពង់កតូចមួយហើយញែកចេញជា ២; ក្នុងទាចនោះ ព្រះយោគីគប្បីមនសិការថា កាលផ្លែស្វាយមួយគូជាប់នៅនឹងទង ទងស្វាយរមែងមិន

---

[៥៤] ពាក្យថា វក្កំ ប្លែកគ្នានឹងតម្រងបស្សាវៈ, តែបច្ចុប្បន្នប្រែថា ទាច ។

ដឹងថា "ផ្លែស្វាយមួយគូជាប់នៅជាមួយគ្នា" , សូម្បីផ្លែស្វាយមួយគូក៏មិនដឹងថា "យើងជាប់នៅជាមួយទង" យ៉ាងណា, សូម្បីសរសៃធំទាំងនោះ ក៏ដូចគ្នាដែរ រមែងមិនដឹងថា "ទាចជាប់នៅជាមួយនឹងយើង" សូម្បីទាចវិញ ក៏មិនដឹងថា "យើងជាប់នៅជាមួយទងសរសៃធំ" , ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ទាចជាកោដ្ឋាសៈមួយ ដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## សម្តែងអំពីវិធីមនសិការ ហទយំ (បេះដូង)

**ហទយំ** បេះដូង អាស្រ័យតាំងនៅត្រង់កណ្តាលគ្រោងឆ្អឹងទ្រូងខាងក្នុងសរីរៈ; ក្នុងបេះដូងនោះ ព្រះយោគីគប្បីមនសិការថា កាលចំណិតសាច់អាស្រ័យតាំងនៅខាងក្នុងគ្រោងរបស់រថ (រាងកាយ) ខាងក្នុងរថចាស់ រមែងមិនដឹងថា "ចំណិតសាច់អាស្រ័យយើងហើយតាំងនៅ" សូម្បីចំណិតសាច់ ក៏មិនដឹងថា "យើងអាស្រ័យខាងក្នុងរថចាស់ហើយតាំងនៅ" យ៉ាងណា, ខាងក្នុងគ្រោងឆ្អឹងទ្រូង ក៏យ៉ាងនោះដែរ រមែងមិនដឹងថា "ហទយៈអាស្រ័យយើងហើយតាំងនៅ" សូម្បីហទយៈវិញ ក៏មិនដឹងថា "យើងអាស្រ័យខាងក្នុងគ្រោងឆ្អឹងទ្រូង ហើយតាំងនៅ" ធម៌ពួកនេះវៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ហទយៈជាកោដ្ឋាសៈមួយដោយឡែក ក្នុងសរីរៈនេះមិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## **សម្តែងអំពីវិធីមនសិការ យកនំ** (ថ្លើម)

**យកនំ** ថ្លើមអាស្រ័យតាំងនៅខាងស្តាំ ត្រង់ចន្លោះដោះទាំង ២ ខាងក្នុងសរីរៈ; ក្នុងថ្លើមនោះព្រះយោគីគប្បីមនសិការថា កាលគេខ្ចប់ដុំសាច់មួយគូទុកត្រង់រង្វេលឆ្នាំងបាយ ខាងរង្វេលឆ្នាំងបាយរមែងមិនដឹងថា "ដុំសាច់មួយគូខ្ចប់ទុកក្នុងយើង" សូម្បីដុំសាច់មួយគូ ក៏មិនដឹងថា "យើងត្រូវខ្ចប់ទុកត្រង់រង្វើលឆ្នាំងបាយ" យ៉ាងណា, ចំហៀងខាងចន្លោះដោះទាំងគូ ក៏យ៉ាងនោះដែរ រមែងមិនដឹងថា "ថ្លើមអាស្រ័យយើងតាំងនៅ" , សូម្បីថ្លើមវិញ ក៏មិនដឹងថា "យើងអាស្រ័យនូវចំហៀងផ្នែកខាងស្តាំចន្លោះដោះទាំងគូ" ; ធម៌ពួកនេះ វៀរចាកការគិតនិងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ថ្លើមជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វជាធម្មជាតរឹង ឈ្មោះថា បឋវីធាតុ ៕

## **សម្តែងអំពីវិធីមនសិការ កិលោមកំ** (វាវ)

បណ្តាវាវទាំងឡាយ វាវដែលបិទបាំង (បដិច្ឆន្នកិលោមកំ) ឡោមព័ទ្ធបេះដូង និងថ្លើមតាំងទុក (ម្យ៉ាង),វាវដែលមិនបិទបាំងបេះដូង និងថ្លើម (អប្បដិច្ឆន្នកិលោមកំ) តែហ៊ុមសាច់ខាងក្រោមស្បែកសរីរៈទាំងអស់ តាំងនៅ (ម្យ៉ាង) ។

ក្នុងវាវទាំងនោះ ព្រះយោគីគប្បីមនសិការថា កាលសាច់រុំទុកដោយផ្ទាំងសំពត់ចាស់ សាច់រមែងមិនដឹងថា "យើងត្រូវផ្ទាំងសំពត់ចាស់រុំទុក" សូម្បីផ្ទាំងសំពត់ចាស់ ក៏មិនដឹងថា "សាច់ត្រូវយើងរុំទុក" យ៉ាងណា, ថ្លើម បេះដូង និង

សាច់ក្នុងសរីរៈទាំងអស់ ក៏យ៉ាងនោះដែរ រមែងមិនដឹងថា “យើងត្រូវវាវបិទបាំងទុក” សូម្បីវាវក៏មិនដឹងថា “ថ្លើម បេះដូង និងសាច់ក្នុង សរីរៈទាំងអស់ ត្រូវយើងបិទបាំងទុក” ; ធម៌ពួកនេះវៀរចាកការគិត និងការ ពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា វាវជាកោដ្ឋាសៈមួយដោយ ឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនជាសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## សម្តែងអំពីវិធីមនសិការ បិហកំ [៥៥] (ក្រពះ)

**បិហកំ** ក្រពះអាស្រ័យនៅខាងលើក្រពែងរំអិលហ៊ុមផ្ទៃពោះ ខាងឆ្វេងនៃបេះដូង; ក្នុងក្រពះនោះ ព្រះយោគីគប្បីមនសិការថា កាលដុំអាចម៍គោដាក់អែបក្បែរជង្រុកស្រូវ ជង្រុកស្រូវមិនដឹងថា “ដុំអាចម៍គោអាស្រ័យយើងហើយតាំងនៅ” , សូម្បីដុំអាចម៍គោវិញក៏មិនដឹងថា “យើងអាស្រ័យនៅខាងលើជង្រុក” យ៉ាងណា, ខាងលើក្រពែងរំអិលហ៊ុមផ្ទៃពោះ ក៏យ៉ាងនោះដែរ រមែងមិនដឹងថា “ក្រពះអាស្រ័យយើង ហើយតាំងនៅ” , ឯក្រពះវិញក៏មិនដឹងថា “យើងអាស្រ័យនៅលើក្រពែងរំអិលហ៊ុមផ្ទៃពោះ ហើយតាំងនៅ” , ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ក្រពះជាកោដ្ឋាសៈ មួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនជាសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

---

[៥៥] **បិហកំ** បុរាណប្រែថា ទាច ។

## សម្តែងអំពីវិធីមនសិការ បប្ផាសំ (សួត)

**បប្ផាសំ** សួតព្យួរបិទខាងលើបេះដូង និងថ្លើម តាំងនៅចន្លោះដោះទាំងពីរខាងក្នុងសរីរៈ; ក្នុងសួតនោះ ព្រះយោគីគប្បីមនសិការថា កាលសំបុកបក្សីព្យួរនៅខាងក្នុងជង្រុកស្រូវចាស់ ខាងក្នុងជង្រុកស្រូវចាស់ រមែងមិនដឹងថា "សំបុកសត្វតាំងនៅក្នុងយើង" , សូម្បីសំបុកបក្សីវិញ ក៏មិនដឹងថា "យើងព្យួរនៅខាងក្នុងជង្រុកស្រូវចាស់" យ៉ាងណា, ខាងក្នុងនៃសរីរៈនេះ ក៏យ៉ាងនោះដែរ រមែងមិនដឹងថា "សួតព្យួរនៅក្នុងយើង" សូម្បីសួតវិញក៏មិនដឹងថា "យើងព្យួរនៅខាងក្នុងសរីរៈបែបនេះ" ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា សួត ជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេ-តនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## សម្តែងអំពីវិធីមនសិការ អន្តំ (ពោះវៀនធំ)

**អន្តំ** ពោះវៀនធំ តាំងនៅក្នុងសរីរៈតាំងពីបំពង់កចុះទៅដល់ទ្វារធំជាទីបំផុត; ក្នុងពោះវៀនធំនោះ ព្រះយោគីគប្បីមនសិការថា កាលខ្លួនពស់ដែលគេកាត់សីសៈ ដាក់ក្នុងស្នូកឈាម ស្នូកឈាមរមែងមិនដឹងថា "ខ្លួនពស់គេដាក់ទុកលើយើង" , សូម្បីខ្លួនពស់វិញ ក៏មិនដឹងថា "យើងត្រូវដាក់ទុកក្នុងស្នូកឈាម" យ៉ាងណា, ខាងក្នុងសរីរៈនេះ ក៏យ៉ាងនោះដែរ រមែងមិនដឹងថា **"ពោះវៀនធំតាំងនៅក្នុងយើង"** , សូម្បីពោះវៀនធំវិញ ក៏មិនដឹងថា "យើងតាំងនៅក្នុងសរីរៈ" ; ធម៌ពួកនេះវៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះ

ថា ពោះវៀនធំជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## **សម្តែងអំពីវិធីមនសិការ អន្តគុណំ** (ពោះវៀនតូច)

**អន្តគុណំ ពោះវៀនតូច** តាំងនៅក្នុងចន្លោះពោះវៀនធំដោយរុំព័ទ្ធពោះវៀនធំ ២១ ផ្នត់; ក្នុងពោះវៀនតូចនោះ ព្រះយោគីគប្បីមនសិការថា កាលបុគ្គលយកខ្សែព្រួរដេរមណ្ឌលខ្សែព្រួរសម្រាប់ជូតតាំងទុក មណ្ឌលខ្សែព្រួរសម្រាប់ជូតជើង រមែងមិនដឹងថា **"ខ្សែព្រួរដេរយើងទុក"** , សូម្បីខ្សែព្រួរវិញ ក៏មិនដឹងថា **"ពួកយើងដេរមណ្ឌលខ្សែព្រួរសំរាប់ជូតតាំងទុក"** យ៉ាងណា, ពោះវៀនធំក៏យ៉ាងនោះដែរ រមែងមិនដឹងថា **"ពោះវៀនតូចរុំខ្លួនយើងទុក"** , សូម្បីពោះវៀនតូចវិញ ក៏មិនដឹងថា **"យើងចងពោះវៀនធំតាំងទុក"** ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹង គ្នា; ព្រោះហេតុនោះ ឈ្មោះថា ពោះវៀនតូចជាកោដ្ឋាសៈមួយ ដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## **សម្តែងអំពីវិធីមនសិការ ឧទរិយំ** (អាហារថ្មី)

**ឧទរិយំ អាហារថ្មី** បានដល់ របស់ស៊ី របស់ផឹក របស់ទំពា របស់លិទ្ធដែលនៅក្នុងពោះ; បណ្តាអាហារទាំងនោះ ព្រះយោគីគប្បីមនសិការថា កាលកម្ពតសុនខ (ឆ្កែ) នៅក្នុងស្នូកសុនខ ស្នូកសុនខរមែងមិនដឹងថា "កម្ពតសុនខតាំងនៅក្នុង

យើង” , សូម្បីកម្ពួតសុនខវិញ ក៏មិនដឹងថា “យើងតាំងនៅលើស្លឹកសុនខ” យ៉ាងណា, ពោះក៏យ៉ាងនោះដែរ រមែងមិនដឹងថា **“អាហារថ្មីតាំងនៅក្នុងយើង”** , សូម្បីអាហារថ្មីវិញ ក៏មិនដឹងថា **“យើងតាំងនៅក្នុងពោះ”** ធម៌ពួកនេះវៀរចាកការគិតនិងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា អាហារថ្មីជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹង ឈ្មោះថា **បឋវីធាតុ** ៕

## សម្តែងអំពីវិធីមនសិការ ករីសំ (អាហារចាស់)

***ករីសំ*** អាហារចាស់នៅក្នុងទីបំផុតពោះវៀនធំ ពោលគឺក្រពះអាហារចាស់ដូចជាសម្បកឫស្សីប្រវែង ៨ ធ្នាប់; ក្នុងអាហារចាស់ទាំងនោះ ព្រះយោគីគប្បីមនសិការថា កាលយកដីស្អិតពណ៌លឿងច្របល់ដាក់ក្នុងបំពង់ឫស្សី បំពង់ឫស្សីរមែងមិនដឹងថា **“ដីស្អិតពណ៌លឿងតាំងនៅក្នុងយើង”** , សូម្បីដីស្អិតពណ៌លឿងរមែងមិនដឹងថា **“យើងតាំងនៅក្នុងបំពង់ឫស្សី”** យ៉ាងណា, ក្រពះអាហារចាស់ក៏យ៉ាងនោះដែរ រមែងមិនដឹងថា **“អាហារចាស់តាំងនៅក្នុងយើង”** , សូម្បីអាហារចាស់វិញ ក៏មិនដឹងថា **“យើងតាំងនៅក្នុងក្រពះអាហារចាស់”** ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា អាហារចាស់ដែលជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរឹងឈ្មោះថា **បឋវីធាតុ** ៕

## សម្តែងអំពីវិធីមនសិការ មត្ថលុង្គំ (ខួក្នុងក្បាល)

**មត្ថលុង្គំ** ខួក្នុងក្បាល តាំងនៅក្នុងលលាដ៏ក្បាល; ក្នុងខួនោះ ព្រះយោគី គប្បីមនសិការថា កាលបុគ្គលយកម្សៅដាក់ក្នុងត្រឡោកឃ្លោកចាស់ ត្រឡោក-ឃ្លោកចាស់រមែងមិនដឹងថា **"ដុំម្សៅតាំងនៅក្នុងយើង"** , សូម្បីដុំម្សៅវិញ ក៏មិនដឹងថា **"យើងតាំងនៅក្នុងត្រឡោកឃ្លោកចាស់"** យ៉ាងណា, ខាងក្នុងលលាដ៏ក្បាល ក៏យ៉ាងនោះដែរ រមែងមិនដឹងថា **"ខួតាំងនៅក្នុងយើង"** , សូម្បីខួវិញ ក៏មិនដឹងថា **"យើងតាំងនៅក្នុងលលាដ៏ក្បាល"** ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណា នូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ខួក្នុងក្បាលជាកោដ្ឋាសៈមួយ ដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្ម-ជាតរឹង ឈ្មោះថា **បឋវីធាតុ** ។ ព្រះមានជោគទ្រង់ធ្វើបឋវីធាតុ ឱ្យស្របទៅតាម កោដ្ឋាសៈទាំងឡាយ មានអាបោកោដ្ឋាសៈជាដើម ដោយបទនេះថា "**យំ វា បនញ្ញម្បិ** = ឬក៏ធម្មជាតដទៃណា" ហើយទ្រង់សម្តែងបឋវី ឱ្យជាយេវាបនកន័យ ដោយអំណាចនៃលក្ខណៈ ៕

## សម្តែងអំពីបឋវីធាតុ និទ្ទេសខាងក្រៅ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃបឋវីធាតុ ខាងក្រៅតទៅ ៖

បទថា "**អយោ** = ដែក" បានដល់ លោហៈខ្មៅ ។

បទថា "**លោហំ** = លោហៈ" បានដល់ លោហៈ ៤ ប្រភេទ គឺៈ ជាតិ-លោហៈ ១, វិជាតិលោហៈ ១, កិត្តិមលោហៈ ១ និងបិសាចលោហៈ ១; បណ្តា

លោហៈ ទាំង ៤ នោះ លោហៈទាំង ៧ ប្រភេទនេះ គឺ: **អយោ** = ដែក, **សជ្ឈុ** = ប្រាក់, **សុវណ្ណំ** = មាស, **តិបុ** = សំណប៉ាហាំង, **សីសំ** = សំណ, **តម្ពលោហំ** = លោហៈក្រហម និង**វេកន្តកលោហំ** = លោហៈលឿង ឈ្មោះថា **ជាតិលោហៈ** = ដែកធម្មតា; លោហៈមានលក្ខណៈដូចភ្លុកដំរី ឈ្មោះថា **ទិជាតិលោហៈ**; លោហៈ ៣ យ៉ាង គឺ: កង្សលោហៈ វដ្ដលោហៈ និងអារកូដ ឈ្មោះថា **កិត្តិមលោហៈ**; លោហៈ ៨ គឺ: មោរក្ខកៈ, បុថុកៈ, មលីនកៈ, ចបលកៈ, សេលកៈ, អាដកៈ, តល្លកៈ និងទុសិលោហៈ ឈ្មោះថា **បិសាចលោហៈ**; បណ្ដាលោហៈទាំងនោះ ជាតិលោហៈ ៥ (ខាងដើម) ត្រាស់ទុកមួយផ្នែកក្នុងព្រះបាលី; តែលោហៈដ៏សេសទាំងអស់ និងជាតិលោហៈ ២ ពួកនេះ គឺ: លោហៈក្រហម និងលោហៈលឿង គប្បីជ្រាបថា **លោហៈ** ក្នុងទីនេះ ។

បទថា "**តិបុ** = សំណប៉ាហាំង" បានដល់ សំណប៉ាហាំងស ។ បទថា "**សីសំ**" បានដល់ សំណខ្មៅ ។ បទថា "**សជ្ឈុ** = ប្រាក់" ។ បទថា "**មុត្តា** = កែវមុក្តា" បានដល់ កែវមុក្តាកើតក្នុងសមុទ្រ ។ បទថា "**មណិ** = កែវមណី" សេចក្ដីថា វៀរកែវពិទូរ្យជាដើមចេញ ដែលមានមកក្នុងព្រះបាលីហើយ សូម្បីកែវដ៏សេសទាំងអស់ ឈ្មោះថា **កែវមណី** ដែលផ្សេងដោយកែវមណីជោតិរសជាដើម ។ បទថា "**វេឡុរិយោ** = កែវពិទូរ្យ" បានដល់ កែវមណីមានពណ៌លឿង ដូចសម្បុរឫស្សី ។ បទថា "**សំខោ** = សង្ខ" បានដល់ ខ្យងស័ង្ខកើតក្នុងទន្លេ ។ បទថា "**សិលា** = ថ្ម" បានដល់ សូម្បីថ្មទាំងអស់ ផ្សេងដោយថ្មខ្មៅ ថ្មលឿង ថ្មសជាដើម។ បទថា "**បវាឡំ**" គឺកែវប្រវាឡនោះឯង ។ បទថា "**រជតំ** = ប្រាក់" បានដល់

កហាបណៈ ។ បទថា **"ជាតរូបំ"** បានដល់ មាស ។ បទថា **"លោហិតង្គោ"** បានដល់ កែវមណីក្រហម ។ បទថា **"មសារគល្លំ** = កែវពព្រុស" បានដល់ ពេជ្រភ្នែកឆ្មា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងវត្ថុមានស្មៅជាដើម ព្រឹក្សជាតិដែលមាន ខាងក្រៅរឹង ដោយហោចទៅមានដើមដូងជាដើម ឈ្មោះថា វត្ថុដែលមានខ្លឹមខាងក្នុង ដោយហោចទៅសូម្បីដង្គត់អុស ឈ្មោះថា កំណាត់ឈើ ។ ដុំថ្មដោយប្រមាណប៉ុនគ្រាប់សណ្តែកខៀវរហូតដល់ប៉ុនកដៃ ឈ្មោះថា ក្រួស ។ ក្រួសដែលតូច ជាងគ្រាប់សណ្តែកខៀវចុះមក ហៅថា ខ្សាច់ ។ ពាក្យថា **"ក្បឿង"** បានដល់ ក្បឿងយ៉ាងណានីមួយ ។ ពាក្យថា **"ភូមិ"** បានដល់ ផែនដី ។ ពាក្យថា **"បាសាណោ** = ផែនថ្ម" បានដល់ផ្ទាំងថ្មមានខ្នាតតាំងពីក្តោបមិនជុំឡើងទៅ តែមិនដល់ប្រមាណប៉ុនដំរី ឈ្មោះថា បាសាណៈ, តែតាំងពីប៉ុនដំរីឡើងទៅ ឈ្មោះថា បព្វតៈ (ភ្នំ) ។

ដោយបទថា **"យំ វា បន** = ឬថាធាតុឯណា" នោះ លោករួមយកប្រើថពីដ៏សេស ដែលផ្សេងដោយវត្ថុមានគ្រាប់ត្នោត និងផ្លែដូងជាដើម ។ ដោយពាក្យថា **"យា ច អជ្ឈត្តិកា បឋវីធាតុ យា ច ពាហិរា** = បឋវីធាតុខាងក្នុង និងបឋវីធាតុខាងក្រៅឯណា" នេះ ព្រះមានព្រះភាគទ្រង់សម្តែងបឋវីធាតុសូម្បីទាំង ២ ដោយលក្ខណៈថា ជាបឋវីធាតុដូចគ្នាប៉ុណ្ណោះ ព្រោះអត្ថថា ជាធម្មជាតរឹង ៕

## អាបោធាតុនិទ្ទេសខាងក្នុង

ក្នុងនិទ្ទេសនៃអាបោធាតុជាដើម គប្បីជ្រាបដោយន័យដែលពោលក្នុងពេលក្រោយនោះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"អាបោ អាបោគតំ** = សេចក្តី

ជ្រួតជ្រាប ធម្មជាតដែលរាវ” ជាដើម ឈ្មោះថា **អាពោ** (ការជ្រួតជ្រាប) ដោយអំណាចនៃការតភ្ជាប់; ពាក្យថា “អាបោនោះៗ ឯង” ឈ្មោះថា **អាពោគតំ** (ធម្មជាតដែលរាវ) ព្រោះសេចក្ដីដែលអាបោធាតុនោះៗ ឯង ដល់នូវសភាពនៃអាបោ ។ ដែលឈ្មោះថា **សិនេហោ** (ការស្អិត) ដោយអំណាចនៃស្នេហា; ភាវៈនៃស្នេហានោះៗ ឯង ឈ្មោះថា **សិនេហគតំ** (ធម្មជាតដែលស្អិត) ព្រោះដល់សភាពនៃសេចក្ដីស្អិត ។

បទថា “**ពន្ធនត្តំ រូបស្ស** = ធម្មជាតដែលភ្ជាប់រូប” បានដល់ គ្រឿងចងរបស់អវិនិព្ភោគរូប (រូបញែកចេញជា ៨ រូប) សូម្បីពាក្យថា “**បិត្តំ** = ទឹកប្រមាត់, **សេម្ហំ** = ស្លេស្ម” ជាដើម ព្រះយោគីគប្បីមនសិការដោយអំណាចជាធាតុ នោះៗ ឯង កំណត់យកដោយអំណាចនៃពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ ៕

## សម្ដែងអំពីវិធីមនសិការ បិត្តំ (ទឹកប្រមាត់)

ក្នុងអធិការនៃអាបោធាតុនោះ មានន័យដូចតទៅនេះ ៖

ក្នុងបណ្ដា**ទឹកប្រមាត់ទាំងឡាយ** ទឹកប្រមាត់ដែលមិននៅក្នុងប្លោក (អពទ្ធ-បិត្តំ) តាំងនៅផ្សព្វផ្សាយសរីរៈទាំងអស់ជាប់ដោយជីវិតិន្ទ្រិយ៍, ទឹកប្រមាត់ដែលតាំងនៅក្នុងប្លោក (ពទ្ធបិត្តំ) តាំងនៅក្នុងប្លោករបស់ទឹកប្រមាត់ ។ បណ្ដាទឹកប្រមាត់ទាំង ២ នោះ ព្រះយោគីគប្បីមនសិការថា កាលមានប្រេងបៀមជាប់នំ នំរមែងមិនដឹងថា “ប្រេងបៀមជាប់យើង” សូម្បីប្រេងវិញ ក៏មិនដឹងថា “យើងបៀមជាប់នំ” យ៉ាងណា, សរីរៈក៏ដូចគ្នាដែរ រមែងមិនដឹងថា “ប្រមាត់មិននៅ

ក្នុងប្លោកផ្សព្វផ្សាយហើយតាំងនៅ" សូម្បីទឹកប្រមាត់ដែលតាំងនៅក្នុងប្លោកវិញ ក៏មិនដឹងថា "យើងផ្សព្វផ្សាយនៅក្នុងសរីរៈ" និងដូចសម្បកននោងដែលពេញដោយទឹកភ្លៀង សម្បកននោងរមែងមិនដឹងថា "ទឹកភ្លៀងតាំងនៅក្នុងយើង" សូម្បីទឹកភ្លៀងវិញ ក៏មិនដឹងថា "យើងតាំងនៅក្នុងសម្បកននោង" យ៉ាងណា, ប្លោកប្រមាត់ ក៏យ៉ាងនោះដែរ រមែងមិនដឹងថា "ទឹកប្រមាត់តាំងនៅក្នុងយើង" សូម្បីទឹកប្រមាត់ក្នុងប្លោក ក៏មិនដឹងថា "យើងតាំងនៅក្នុងប្លោករបស់ទឹកប្រមាត់" ធម៌ពួកនេះវៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ទឹកប្រមាត់ជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរាវ មានអាការផ្សារជាប់ ឈ្មោះថា **អាពោធាតុ** ។

## សំដែងអំពីវិធីមនសិការ សេម្ហំ (ស្លេស្ម)

**សេម្ហំ** ស្លេស្ម មានប្រមាត់ពេញមួយកម្បង់តាំងនៅត្រង់ផ្ទៃពោះ; ក្នុងស្លេស្មនោះ ព្រះយោគីគប្បីមនសិការថា កាលអណ្តូងមានគម្របគ្របនៅខាងលើ អណ្តូងទឹករមែងមិនដឹងថា "ផ្ទាំងគម្របតាំងនៅលើយើង" សូម្បីផ្ទាំងគម្របវិញ ក៏មិនដឹងថា "យើងតាំងនៅលើអណ្តូងនេះ" យ៉ាងណា, ផ្ទៃពោះក៏យ៉ាងនោះដែរ រមែងមិនដឹងថា "ស្លេស្មតាំងនៅក្នុងយើង" សូម្បីស្លេស្មវិញក៏មិនដឹងថា "យើងតាំងនៅក្នុងផ្ទៃពោះ" , ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ក៏ឈ្មោះថា ស្លេស្មជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនោះ មិន

មានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរាវ មានអាការផ្សារជាប់ ឈ្មោះថា **អាបោធាតុ** ។

## សម្តែងអំពីវិធីមនសិការ **មុត្តោ** (ទឹកខ្ទុះ)

**មុត្តោ** ទឹកខ្ទុះ មិនតាំងនៅជាប្រចាំ; កាលចំណែកនៃរាងកាយត្រូវបន្លាមុត ការប្រហារ និងរលាកភ្លើងជាដើម ប៉ះខ្ទប់ហើយក្នុងទីណាៗ លោហិត ក៏នឹងកកឡើង, ឬថាដំបៅ និងពកជាដើម ក៏នឹងកើតឡើង, តាំងនៅក្នុងចំណែកនៃរាងកាយនោះៗ មែនពិត; ក្នុងទឹកខ្ទុះនោះ ព្រះយោគីគប្បីមនសិការថា កាលដើមឈើមានជ័រហូរចេញ ដោយអំណាចនៃការប្រហារដោយពូថៅជាដើម ចំណែកនៃដើមឈើដែលត្រូវប្រហារដោយពូថៅជាដើម រមែងមិនដឹងថា "ជ័រដើមឈើតាំងនៅក្នុងពួកយើង" សូម្បីជ័រឈើវិញ ក៏មិនដឹងថា "យើងតាំងនៅក្នុងចំណែកនៃដើមឈើដែលត្រូវគេប្រហារដោយពូថៅជាដើម" យ៉ាងណា, ប្រទេសនៃរាងកាយ សូម្បីត្រូវប៉ះខ្ទប់ដោយដង្គត់ និងបន្លាជាដើម ក៏យ៉ាងនេះដែរ រមែងមិនដឹងថា "ទឹកខ្ទុះតាំងនៅក្នុងពួកយើង" សូម្បីទឹកខ្ទុះវិញ ក៏មិនដឹងថា "យើងតាំងនៅក្នុងប្រទេសនៃរាងកាយទាំងនោះ" ធម៌ពួកនេះវៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា, ព្រោះហេតុនោះ ឈ្មោះថា ទឹកខ្ទុះ ជាកោដ្ឋាសៈមួយដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វជារបស់រាវ មានអាការជ្រួតជ្រាប ឈ្មោះថា **អាបោធាតុ** ។

## សម្តែងអំពីវិធីមនសិការ លោហិតំ (ឈាម)

**លោហិតំ** ឈាមដែលហូរទៅមក តាំងនៅផ្សព្វផ្សាយទៅក្នុងសរីរៈទាំងអស់ ដូចទឹកប្រមាត់ដែលតាំងនៅក្នុងប្លោក, ឈាមដែលឃាំងនៅមានប្រមាណពេញមួយស្បោង ឃាំងនៅខាងក្រោមឋានរបស់ថ្លើម ធ្វើទាច បេះដូង ថ្លើម សួតឱ្យសើម ។ ក្នុងឈាមទាំងនោះ គប្បីជ្រាបវិនិច្ឆ័យឈាមដែលហូរទៅមកដូចគ្នានឹងទឹកប្រមាត់ ដែលមិនបានតាំងនៅក្នុងប្លោកនោះឯង ។ ចំណែកឈាមម្យ៉ាងក្រៅនេះទៀត ព្រះយោគីគប្បីមនសិការថា ទឹកឃាំងនៅក្នុងភាជន៍ថាស ញុំាងដុំដី និងកំណាត់ឈើខាងក្រោមឱ្យសើម វត្ថុមានដុំដី និងកំណាត់ឈើជាដើម រមែងមិនដឹងថា "ពួកយើងទទឹកដោយទឹកហើយតាំងនៅ" សូម្បីទឹកវិញ ក៏មិនដឹងថា "យើងធ្វើដុំដី និងកំណាត់ឈើជាដើម ឱ្យទទឹក" យ៉ាងណា, ទីដែលជាចំណែកខាងក្រោមរបស់ថ្លើមក្តី ចំណែកផ្សេងៗ មានទាចជាដើមក្តី ក៏យ៉ាងនោះដែរ រមែងមិនដឹងថា "ឈាមឃាំងនៅក្នុងយើង, យើងប៉ុណ្ណោះទទឹក" សូម្បីឈាមវិញ ក៏មិនដឹងថា "យើងញុំាងទាចជាដើម ឱ្យទទឹក ញុំាងចំណែកខាងក្រោមរបស់ថ្លើម ឱ្យពេញហើយ" ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ឈាមជាកោដ្ឋាសៈមួយដោយឡែក មិនមានចេតនា ជាអព្យាកតៈជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរាវ មានអាការជ្រួតជ្រាប ឈ្មោះថាអាបោធាតុ៕

## **សម្តែងអំពីវិធីមនសិការ សេទោ** (ញើស)

**សេទោ** ញើស រមែងតាំងនៅពេញ និងហូរចេញតាមរន្ធសក់ និងរន្ធរោម ក្នុងវេលាដែលក្តៅដោយភ្លើងជាដើម; បណ្តាញើសទាំងនោះ ព្រះយោគី គប្បីមនសិការថា កាលបុគ្គលដកក្រឳឈូក ឫសឈូក និងទងផ្កាឈូកឡើងពីទឹក ប្រហោងនៃឫសឈូកជាដើមរមែងមិនដឹងថា "ទឹករមែងហូរចេញពីពួកយើង" , សូម្បីទឹកដែលហូរចេញពីប្រហោង នៃឫសឈូកជាដើមវិញ ក៏រមែងមិនដឹងថា "យើងហូរចេញពីប្រហោងនៃឫសឈូកជាដើម" យ៉ាងណា, រន្ធសក់ និងរន្ធរោម ក៏យ៉ាងនោះដែរ រមែងមិនដឹងថា "ញើសហូរចេញពីពួកយើង" , សូម្បីញើសវិញ ក៏មិនដឹងថា "យើងរមែងហូរចេញពីរន្ធសក់ និងរន្ធរោម" ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ញើសជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរាវ មានអាការផ្សារជាប់ ឈ្មោះថា **អាបោធាតុ** ៕

## **សម្តែងអំពីវិធីមនសិការ មេទោ** (ខ្លាញ់ខាប់)

**មេទោ** ខ្លាញ់ខាប់ ជាខ្លាញ់ខាប់របស់មនុស្សស្គម ផ្សាយទៅកាន់សរីរៈទាំងអស់ របស់មនុស្សធាត់អាស្រ័យសាច់កំភួនជើងហើយតាំងនៅ; បណ្តាខ្លាញ់ខាប់ទាំងនោះ ព្រះយោគីគប្បីមនសិការថា "កាលដុំសាច់ ដែលត្រូវបិទគ្របដោយផ្ទាំងសំពត់ចាស់ មានពណ៌ដូចរមៀត ដុំសាច់រមែងមិនដឹងថា ' ផ្ទាំងសំពត់ចាស់ មានពណ៌ដូចរមៀតអាស្រ័យយើងហើយតាំងនៅ" , សូម្បីផ្ទាំងសំពត់ចាស់វិញ ក៏មិន

ដឹងថា “យើងអាស្រ័យដុំសាច់ហើយតាំងនៅ” យ៉ាងណា, សាច់ក្នុងសរីរៈទាំង អស់ ឬសាច់ត្រយូងចេក (កំភួនជើង) ជាដើម ក៏យ៉ាងនោះដែរ រមែងមិនដឹងថា “ខ្លាញ់ខាប់អាស្រ័យយើង ហើយតាំងនៅ” សូម្បីខ្លាញ់ខាប់វិញ ក៏មិនដឹងថា “យើងអាស្រ័យសាច់ហើយតាំងនៅក្នុងសរីរៈទាំងអស់ ឬត្រង់កំភួនជើងជាដើម” ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ក៏ឈ្មោះថា ខ្លាញ់ខាប់ ជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជារបស់សូន្យ ជាអព្យាកតៈ មិនមែនសត្វ ជាជ័រខាប់ ជាទឹកខាប់ មានអាការជ្រួតជ្រាប ឈ្មោះថា **អាបោធាតុ** ។

## សម្តែងអំពីវិធីមនសិការ អស្សុ (ទឹកភ្នែក)

**អស្សុ** ទឹកភ្នែក ក្នុងវេលាវាហូរចេញ និងដក់នៅពេញរណ្តៅភ្នែកខ្លះ, រមែងហូរចេញខ្លះ; ក្នុងទឹកភ្នែកនោះ ព្រះយោគីគប្បីមនសិការថា កាលប្រហោងនៃផ្លែត្នោតខ្ចីពេញដោយទឹក ប្រហោងនៃផ្លែត្នោតខ្ចីទាំងឡាយ រមែងមិនដឹងថា “ទឹកតាំងនៅក្នុងយើង” , សូម្បីទឹកក៏មិនដឹងថា “យើងតាំងនៅក្នុងប្រហោងផ្លែត្នោតខ្ចីទាំងឡាយ” យ៉ាងណា, រន្ធនៃភ្នែកក៏យ៉ាងនោះដែរ រមែងមិនដឹងថា “ទឹកភ្នែកតាំងនៅក្នុងពួកយើង” , សូម្បីទឹកភ្នែកវិញក៏មិនដឹងថា “យើងតាំងនៅក្នុងរន្ធភ្នែកទាំងពីរ” , ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ទឹកភ្នែកជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិន

មានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតវារ មានអាការជ្រួតជ្រាប ឈ្មោះថា **អាបោធាតុ**៕

## សម្ដែងអំពីវិធីមនសិការ រសា (ខ្លាញ់រាវ)

**រសា** ខ្លាញ់រាវ ជាខ្លាញ់ដែលរាវជ្រួតជ្រាបក្នុងសរីរៈដែលតាំងនៅតាមបាតដៃ បាទជើង ក្ដោងច្រមុះ ថ្ងាស និងចង្កួយស្មា ក្នុងវេលាវាចេញព្រោះការក្ដៅដោយភ្លើងជាដើម; បណ្ដាខ្លាញ់រាវទាំងនោះ ព្រះយោគីគប្បីមនសិការថា ក្នុងបាយដែលបុគ្គលដាក់ចូលទៅហើយ បាយរមែងមិនដឹងថា “ប្រេងជ្រួតជ្រាបពួកយើង ហើយតាំងនៅ” សូម្បីប្រេង ក៏មិនដឹងថា “យើងជ្រួតជ្រាបបាយ ហើយតាំងនៅ” យ៉ាងណា, ប្រទេសនៃបាតដៃជាដើមក៏ដូចគ្នាដែរ រមែងមិនដឹងថា “ខ្លាញ់រាវជ្រួតជ្រាប ហើយតាំងនៅ” សូម្បីខ្លាញ់រាវវិញ ក៏មិនដឹងថា “យើងជ្រួតជ្រាបប្រទេសនៃបាតដៃជាដើមហើយតាំងនៅ” ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ខ្លាញ់រាវជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្ម-ជាតរាវ មានអាការជ្រួតជ្រាប ឈ្មោះថា **អាបោធាតុ** ៕

## សម្ដែងអំពីវិធីមនសិការ ខេឡោ (ទឹកមាត់)

**ខេឡោ** (ទឹកមាត់) កាលមានបច្ច័យ (ហេតុ) ដែលនឹងឱ្យកើតទឹកមាត់យ៉ាងណាមួយ វានឹងហូរចេញចាកថ្ពាល់ទាំងពីរ មកតាំងនៅត្រង់អណ្ដាត; ក្នុងទឹក

មាត់នោះ ព្រះយោគីគប្បីមនសិការថា អណ្តូងជិតទឹកស្ទឹង មានទឹកហូរចេញមកមិនដាច់ខ្សែ ផ្ទៃអណ្តូងរមែងមិនដឹងថា **"ទឹកតាំងនៅក្នុងយើង"** , សូម្បីទឹកវិញក៏យ៉ាងនោះដែរ រមែងមិនដឹងថា "យើងតាំងនៅក្នុងអណ្តូង" យ៉ាងណា, ផ្ទៃអណ្តាតទាំងអស់ ក៏យ៉ាងនោះដែរ រមែងមិនដឹងថា "ទឹកមាត់ហូរចេញពីថ្ពាល់ទាំង ២ មកតាំងនៅលើយើង" , សូម្បីទឹកមាត់វិញ ក៏មិនដឹងថា "យើងហូរចេញពីថ្ពាល់ទាំង ២ មកតាំងនៅលើផ្ទៃអណ្តាត" ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ទឹកមាត់ជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរាវ មានអាការរាវ ឈ្មោះថា **អាបោធាតុ** ៕

## សម្តែងអំពីវិធីមនសិការ សិង្ឃាណិកា (ទឹកសំបោរ)

***សិង្ឃាណិកា*** ទឹកសំបោរក្នុងវេលាដែលវាហូរចេញ, វានឹងតាំងនៅក្នុងក្តោងច្រមុះខ្លះ, ហូរចេញមកខ្លះ; ក្នុងទឹកសំបោរនោះ ព្រះយោគីគប្បីមនសិការថា កាលស្លាបព្រាដែលគេដួសក្នុងភាជនៈដែលពេញដោយទឹកដោះជូរ ស្លាបព្រារមែងមិនដឹងថា "ទឹកដោះជូរតាំងនៅក្នុងយើង" , សូម្បីទឹកដោះជូរវិញ ក៏មិនដឹងថា "យើងតាំងនៅក្នុងស្លាបព្រា" យ៉ាងណា, ក្តោងច្រមុះក៏យ៉ាងនោះដែរ រមែងមិនដឹងថា "យើងតាំងនៅក្នុងប្រហោងច្រមុះ" , សូម្បីប្រហោងច្រមុះវិញ ក៏មិនដឹងថា "ទឹកសំបោរតាំងនៅក្នុងយើង" , ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ទឹកសំបោរជាកោដ្ឋាសៈមួយដោយឡែក

ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្ម-ជាតវារ មានលក្ខណៈជ្រួតជ្រាប ឈ្មោះថា **អាបោធាតុ** ។

## សម្តែងអំពីវិធីមនសិការ លសិកា (ទឹករំអិល)

**លសិកា** ទឹករំអិលធ្វើកិច្ចជ្រើមត្រង់សន្លាក់ឆ្អឹង តាំងនៅត្រង់ទីត ១៨០ ថ្នាំង; ក្នុងទឹករំអិលនោះ ព្រះយោគីគប្បីមនសិការថា កាលគេយកប្រេងមកជ្រើម ភ្លៅរថ ភ្លៅរថរមែងមិនដឹងថា “មានប្រេងជ្រើមយើង” សូម្បីប្រេងវិញ ក៏មិនដឹងថា “យើងស្រក់លើភ្លៅរថ” យ៉ាងណា, សន្លាក់ឆ្អឹងតទាំង ១៨០ ថ្នាំង ក៏យ៉ាងនោះដែរ រមែងមិនដឹងថា “ទឹករំអិលស្រក់លើពួកយើង” , សូម្បីទឹករំអិលវិញ ក៏មិនដឹងថា “យើងស្រក់លើសន្លាក់ឆ្អឹង ១៨០ ថ្នាំង” ; ធម៌ពួកនេះ វៀរចាក ការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ទឹករំអិលមួយ ដោយឡែកក្នុងសរីរៈនេះមិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតវារ មានអាការជ្រួតជ្រាប ឈ្មោះថា **អាបោធាតុ** ។

## សម្តែងអំពីវិធីមនសិការ មុត្តំ (ទឹកមូត្រ)

**មុត្តំ** ទឹកមូត្រតាំងនៅក្នុងប្លោកនោម; ក្នុងទឹកមូត្រនោះ ព្រះយោគីគប្បីមនសិការថា កាលឆ្នាំងខ្ទះផ្ងារមាត់ ត្រូវគេចោលទុកក្នុងទឹកជ្រាំ ឆ្នាំងខ្ទះរមែងមិនដឹងថា “រសទឹកជ្រាំតាំងនៅក្នុងយើង” , សូម្បីទឹកវិញ ក៏មិនដឹងថា “យើងតាំងនៅក្នុងឆ្នាំង” យ៉ាងណា, ប្លោកបស្សាវៈក៏យ៉ាងនោះដែរ រមែងមិនដឹងថា “ទឹក

មូត្រតាំងនៅក្នុងយើង” , សូម្បីទឹកមូត្រវិញ ក៏មិនដឹងថា “យើងតាំងនៅក្នុងប្លោកបស្សាវៈ” ; ធម៌ពួកនេះ វៀរចាកការគិត និងការពិចារណានូវគ្នានឹងគ្នា; ព្រោះហេតុនោះ ឈ្មោះថា ទឹកមូត្រជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតរាវ មានអាការជ្រួតជ្រាប ឈ្មោះថា **អាបោធាតុ** ។

ពាក្យថា **យំ វា បន** នេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់សំដៅយកអាបោធាតុ ក្នុងកោដ្ឋាសៈ ៣ ដ៏សេស ៕

## អាបោធាតុនិទ្ទេសខាងក្រៅ

គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសនៃអាបោធាតុខាងក្រៅតទៅ ៖

រសដែលកើតឡើងព្រោះអាស្រ័យឫសឈើ ឈ្មោះថា មូលរស (រសឫសឈើ) ។ សូម្បីរសទាំងឡាយមានរសកើតពីដើមឈើជាដើម ក៏ន័យនេះដែរ ។ វត្ថុមានទឹកដោះស្រស់ជាដើមជាក់ច្បាស់ហើយមែនពិត; តែក្នុងទីនេះ មិនមានកំណត់ពិតប្រាកដ ដូចក្នុងសិក្ខាបទសម្ដែងអំពីភេសជ្ជៈ ។ ទឹកដោះយ៉ាងណាមួយ ឈ្មោះថា ទឹក ដោះនោះឯង ។ សូម្បីក្នុងបទទាំងឡាយដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។

បទថា “**ភុម្មានិ** = ផែនដី” បានដល់ ទឹកដែលនៅក្នុងអណ្ដូងជាដើម ។

បទថា “**អន្តលិក្ខានិ** = អាកាស” បានដល់ ទឹកភ្លៀងដែលនៅមិនទាន់ធ្លាក់ដល់ផែនដី ។

បទថា **"យំ វា បន** = ក៏ទឹកណា" បានដល់ ហិមៈ (សន្សើម) ទឹកញ៉ាំង កប្បឱ្យវិនាស និងទឹកទ្រទ្រង់ផែនដីជាដើម ចាត់ចូលជាឋានៈក្នុង**យេវាបនកន័យ**ក្នុងទីនេះ ៕

## តេជោធាតុនិទ្ទេសខាងក្នុង

គប្បីជ្រាបវិនិច្ឆ័យ **តេជោធាតុ** តទៅ ៖

ក៏ឈ្មោះថា **តេជោ** (ធាតុភ្លើង) ដោយអំណាចនៃកម្តៅ ។ តេជោនោះ ឯង ឈ្មោះថា **តេជោគតំ** (ធម្មជាតដែលក្តៅ) ព្រោះជាធម្មជាតដែលដល់ភាពជា របស់ក្តៅ ។ បទថា **"ឧស្មា** = ក្តៅឧណ្ហៗ" បានដល់ អាការក្តៅ; ភាពក្តៅ ឧណ្ហៗ នោះឯង ឈ្មោះថា **ឧស្មាគតំ** (ធម្មជាតដែលក្តៅឧណ្ហៗ); ព្រោះធម្មជាត ដល់នូវភាពជាអាការក្តៅ ។ បទថា **"ឧស្មុមំ"** បានដល់ ធម្មជាតអប់កម្តៅ; ធម្ម ជាតដែលអប់កម្តៅនោះឯង ឈ្មោះថា **ឧស្មុមគតំ** ព្រោះដល់នូវភាពអប់កម្តៅ ។

បទថា **"យេន ច"** បានដល់ ធម្មជាតិដែលក្តៅកម្រើកហើយ ។

បទថា **"សន្តប្បតិ** = រមែងក្តៅ" បានដល់ កាយនេះរមែងក្តៅ, គឺកើត កម្តៅឧណ្ហៗ ដោយភាវៈដែលមានភាពចាស់អស់មួយថ្ងៃជាដើម ។

បទថា **"យេន ច ជីរីយតិ** = តេជោធាតុធ្វើឱ្យទ្រុឌទ្រោម" បានដល់ កាយនេះរមែងទ្រុឌទ្រោម, រមែងដល់ការដាច់ឃ្លាតនៃជីវិតិន្ទ្រិយ៍, អស់កម្លាំង និង ភាវៈមានស្បែករួញ និងសក់ស្កូវជាដើម ដោយធាតុណា ។

ពាក្យថា **"យេន ច បរិឌយ្ហតិ** = តេជោធាតុដែលធ្វើឱ្យរោលក្តៅ" បាន ដល់ កាយនេះត្រូវធាតុណាដែលកម្រើកដុតកម្តៅ, ឯបុគ្គលនោះ ក៏នឹងកន្ទក់កន្ទេញ

ថា "យើងក្តៅរោល" ក៏នឹងប្រាថ្នាយកទឹកដោះថ្លាមកជម្រះទាំងរយដង និងខ្លឹមចន្ទន៍ក្រហមជាដើមមកលាប និងខ្យល់ផាត់ពីស្លឹកត្នោត ។

ពាក្យថា **"យេន ច អសិតបីតខាយិតសាយិតំ សម្មា បរិណាមំ គច្ឆតិ** = តេជោធាតុដែលធ្វើឱ្យរបស់ស៊ី របស់ផឹក របស់ទំពា របស់លិទ្ធភ្លក្ស ដល់នូវភាពរលួយហ្មត់ទៅ" សេចក្តីថា របស់ស៊ី មានបាយជាដើមក្តី, របស់ផឹកមានទឹកជាដើមក្តី, របស់ទំពាមានរបស់ទំពាដែលជាម្សៅជាដើមក្តី, របស់លិទ្ធភ្លក្សមានផ្លែស្វាយទុំ ទឹកឃ្មុំ ស្ករអំពៅជាដើមក្តី រមែងដល់អាការ គឺរមែងរលាយទៅដោយរសជាដើម ដោយធាតុណា; ម្យ៉ាងទៀត ក្នុងតេជោធាតុទាំង ៤ នេះ តេជោធាតុ ៣ ខាងដើម មានសមុដ្ឋាន ៤ យ៉ាង, តេជោធាតុខាងក្រោយ មានកម្មជាសមុដ្ឋានតែម្យ៉ាង ។

**ពណ៌នាបទក្នុងតេជោធាតុនេះមានត្រឹមតែប៉ុណ្ណេះ ៕**

## សម្តែងអំពីវិធីមនសិការ តេជោធាតុ

ក៏វិធីមនសិការតេជោធាតុ មានដូចតទៅនេះ ៖

ភិក្ខុក្នុងធម្មវិន័យនេះ រមែងមនសិការថា "កាយនេះរមែងក្តៅ (កក់ក្តៅ) ដោយតេជោធាតុណា, តេជោធាតុនោះជាកោដ្ឋាសៈ (ចំណែក) មួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាអាការធ្វើឱ្យក្តៅ ឈ្មោះថា **តេជោធាតុ**" , រមែងមនសិការថា "កាយនេះរមែងទ្រុឌទ្រោមទៅដោយធាតុណា, រមែងរោលក្តៅ ដោយធាតុណា, រមែងញ៉ាំងរបស់ស៊ី របស់ផឹក របស់ទំពា របស់លិទ្ធភ្លក្ស ឱ្យដល់ការរលួយដោយល្អ ព្រោះធាតុណា,

ធាតុនេះ ជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ មានអាការធ្វើឱ្យក្តៅ ឈ្មោះថា **តេជោធាតុ**” ។

បទថា “**យំ វា បន** = ឬក៏ធាតុណា” សេចក្តីថា ក្នុងសរីរៈនេះ មាន ឧតុ (គឺរដូវ) ប្រភេទមួយជាប្រក្រតី ឧតុនោះក៏រួមចូលក្នុងឋានៈរបស់យេវា-បនកន័យ ។

## តេជោធាតុនិទ្ទេសខាងក្រៅ

ក្នុងនិទ្ទេសនៃតេជោធាតុខាងក្រៅ ភ្លើងមានការឆេះជាអណ្តាតលេចធ្លោឡើង ព្រោះអាស្រ័យឈើ ឈ្មោះថា **កដ្ឋគ្គិ** = ភ្លើងអុស ។ សូម្បីក្នុងពាក្យមានជា-អាទិ៍ថា ភ្លើងពុំនួតឈើជាដើម ក៏ន័យនេះដែរ ។

បទថា “**សង្ការគ្គិ** = ភ្លើងអង្កាម” បានដល់ ភ្លើងដែលបុគ្គលប្រមូលយកអង្កាមមកដុតឱ្យឆេះឡើង ឈ្មោះថា ភ្លើងអង្កាម ។

បទថា “**ឥន្ទគ្គិ**” បានដល់ ភ្លើងអសនីបាត (ភ្លើងរន្ទះ) ។

បទថា “**អគ្គិសន្តាបោ** = កម្តៅនៃភ្លើង” បានដល់ កម្តៅរបស់អណ្តាតភ្លើង ឬរបស់ធ្យូងភ្លើងដែលប្រាសចាកអណ្តាត ។

បទថា “**សុរិយសន្តាបោ** = កម្តៅនៃព្រះអាទិត្យ” បានដល់ កម្តៅថ្ងៃ ។

បទថា “**កដ្ឋសន្និចយសន្តាបោ** = កម្តៅនៃគំនរអុស” បានដល់ កម្តៅក្នុងគំនរអុស ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដែរ ។

បទថា “**យំ វា បន** = ឬក៏ភ្លើងធាតុណា” បានដល់ ភ្លើងឆេះប្រេត,

ភ្លើងដែលដុតកប្បឱ្យវិនាស និងភ្លើងក្នុងនរកជាដើម ក៏រួមចូលក្នុងឋានៈរបស់យេ-វាបនកន័យក្នុងទីនេះ ៕

## វាយោធាតុនិទ្ទេសខាងក្នុង

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ**វាយោធាតុ** តទៅ ៖

ក៏ឈ្មោះថា **វាយោ** ដោយអំណាចនៃការបក់ទៅបក់មក; **វាយោ**នោះឯង ឈ្មោះថា **វាយោគតំ** (ធម្មជាតិដែលបក់ទៅបក់មក) ព្រោះដល់ភាព**ជាវាយោ** ។

បទថា **"ថម្ភិតត្តំ រូបស្ស** = ភាពតឹងរឹងនៃរូប" បានដល់ ភាពតឹងរឹងនៃអវិនិព្ភោគរូប (រូបដែលញែកចាកគ្នាមិនបាន ៨ រូប) ។

បទថា **"ឧទ្ធង្គមា វាតា** = ខ្យល់បក់ឡើងលើ" បានដល់ ខ្យល់បក់ឡើងខាងលើធ្វើឱ្យភើ និងត្អើកជាដើមប្រព្រឹត្តទៅ ។

បទថា **"អធោគមា វាតា** = ខ្យល់បក់ចុះក្រោម" បានដល់ ខ្យល់បក់ចុះខាងក្រោមដែលញ៉ាំងឧច្ចារៈ និងបស្សាវៈជាដើមឱ្យចេញមក ។

បទថា **"កុច្ឆិសយា វាតា** = ខ្យល់ក្នុងពោះ" បានដល់ ខ្យល់ខាងក្រៅពោះវៀនធំទាំងឡាយ ។

បទថា **"កោដ្ឋាសយា វាតា** = ខ្យល់ដេកនៅក្នុងពោះ" បានដល់ ខ្យល់នៅខាងក្នុងពោះវៀន ។

បទថា **"អង្គមង្គានុសារិនោ វាតា** = ខ្យល់បក់ទៅតាមខ្លួន" បានដល់ ខ្យល់ដែលបក់ទៅតាមអវយវៈតូចធំ ក្នុងសរីរៈទាំងអស់ ដោយបក់ទៅតាម

ប្រហោងសរសៃពួរធ្វើឱ្យកើតការបត់ចូល និងបត់ចេញជាដើម ។ បទថា "**សត្ថក-វាតា** = ខ្យល់សាស្ត្រា" បានដល់ ខ្យល់បក់ទៅ ដូចយកកន្ត្រៃកាត់ចំណងត និងសរសៃពួរ ។ បទថា "**ខុរកវាតា** = ខ្យល់ដូចកាំបិតកោរ" បានដល់ ខ្យល់កាត់បេះដូង ដូចការពុះដោយកាំបិតកោរ ។ បទថា "**ឧប្បលកវាតា** = ខ្យល់កន្ទ្រាក់បេះដូង" បានដល់ ខ្យល់ដែលពន្លះសាច់បេះដូងខ្លួនឯង ។

បទថា "**អស្សាសោ** = ខ្យល់ដកដង្ហើមចូល" បានដល់ ខ្យល់ត្រង់ច្រមុះដែលចូលទៅខាងក្នុង ។ បទថា "**បស្សាសោ** = ខ្យល់ដកដង្ហើមចេញ" បានដល់ ខ្យល់ត្រង់ច្រមុះដែលចេញមកខាងក្រៅ ។ ក៏ខ្យល់ខាងក្នុងនេះ ខ្យល់ទាំងអស់ ខាងដើម មានសមុដ្ឋាន ៤, ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ មានចិត្តជាសមុដ្ឋានតែម្យ៉ាង ។

**ការពណ៌នាបទក្នុងធាតុនេះ មានតែប៉ុណ្ណេះ ៕**

## សម្តែងអំពីវិធីមនសិការ វាយោធាតុ

ម្យ៉ាងទៀត វិធីមនសិការមានដូចតទៅនេះ ៖

ភិក្ខុក្នុងសាសនានេះ កំណត់ខ្យល់ទាំងឡាយ ដែលផ្សេងដោយខ្យល់បក់ឡើងលើជាដើម ដោយអំណាចការពិចារណាខ្យល់បក់ឡើងលើជាដើម ហើយមនសិការថា "ក៏ឈ្មោះថា ខ្យល់បក់ខាងលើជាកោដ្ឋាសៈមួយដោយឡែកក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ មានអាការតឹង ឈ្មោះថា **វាយោធាតុ**" ។ សូម្បីខ្យល់ដ៏សេស ក៏ន័យនេះដែរ ។

បទថា "**យំ វា បន** = ឬក៏ខ្យល់ណា" បានដល់ ខ្យល់ដែលបក់ទៅក្នុងកោដ្ឋាសៈ វាយោធាតុដ៏សេស ក៏រាប់បញ្ចូលក្នុងឋានៈរបស់យេវាបនកន័យ ក្នុងទីនេះដែរ ៕

## វាយោធាតុនិទ្ទេសខាងក្រៅ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃវាយោធាតុខាងក្រៅតទៅ ៖

បទថា "**បុរត្ថិមា វាតា** = ខ្យល់ខាងកើត" បានដល់ ខ្យល់ដែលបក់មកពីទិសខាងកើត ។ សូម្បីក្នុងខ្យល់ដែលបក់មកពីទិសខាងលិច ទិសខាងជើង និងទិសខាងត្បូង ក៏មានន័យដូចគ្នានេះដែរ ។

បទថា "**សរជា វាតា** = ខ្យល់មានផង់ធូលី" បានដល់ ខ្យល់បក់ទៅព្រមជាមួយផង់ធូលី ឈ្មោះថា ខ្យល់មានផង់ធូលី ។

បទថា "**អរជា វាតា** = ខ្យល់មិនមានធូលី" បានដល់ ខ្យល់ម្យ៉ាង ប្រាសចាកធូលី ឈ្មោះថា ខ្យល់មិនមានផង់ធូលី ។

បទថា "**សីតា** = ខ្យល់ត្រជាក់" បានដល់ ខ្យល់ដែលមានរដូវត្រជាក់ជាសមុដ្ឋាន តាំងឡើងក្នុងពេលមេឃត្រជាក់ ។

បទថា "**ឧណ្ហា** = ខ្យល់ក្តៅ" បានដល់ ខ្យល់ដែលមានរដូវក្តៅជាសមុ-ដ្ឋាន តាំងឡើងក្នុងពេលមេឃក្តៅ ។

បទថា "**បរិត្តា** = ខ្យល់ខ្សោយ" បានដល់ ខ្យល់បក់ខ្សោយៗ គឺបក់មកល្ហើយៗ ។

បទថា **"អធិមត្តា** = ខ្យល់ខ្លាំង" បានដល់ ខ្យល់ដែលបក់មកខ្លាំងៗ ។

បទថា **"ភារន្តា** = ខ្យល់ខ្មៅ" បានដល់ ខ្យល់ដែលតាំងឡើងក្នុងពេលមេឃខ្មៅ; អាចារ្យមួយពួកពោលថា ពាក្យថា **ខ្យល់ខ្មៅ** នេះ ជាឈ្មោះរបស់ខ្យល់ដែលបក់មកធ្វើឱ្យសម្បុរខ្មៅដូច្នេះក៏មាន ។

បទថា **"វេរម្ភវាតា** = ខ្យល់ខាងលើ"[៥៦] បានដល់ ខ្យល់បក់ទៅលើសពីមួយយោជន៍ ។

បទថា **"បក្ខវាតា** = ខ្យល់ដែលតាំងឡើងអំពីស្លាបសត្វ" បានដល់ខ្យល់ដែលតាំងឡើងអំពីការបក់កម្ទេច ដោយហោចទៅសូម្បីមេរុយ ។

បទថា **"សុបណ្ណវាតា** = ខ្យល់ដែលតាំងឡើងពីគ្រុឌ" បានដល់ ខ្យល់គ្រុឌ; សូម្បីខ្យល់គ្រុឌនេះនឹងជាខ្យល់កើតពីស្លាបក៏ពិតមែនហើយ, ប៉ុន្តែថា លោកក៏កាន់យកចំណែកមួយដោយអំណាចជាខ្យល់ខ្លាំង ។

បទថា **"តាលវណ្ឌវាតា** = ខ្យល់ស្លឹកត្នោត" បានដល់ ខ្យល់ដែលកើតពីស្លឹកត្នោត ឬវត្ថុមានសណ្ឋានមូលយ៉ាងណានីមួយ ។

បទថា **"វិធូបនវាតា** = ខ្យល់ផ្លិត" បានដល់ ខ្យល់ដែលកើតឡើងដោយផ្លិត; ក៏ខ្យល់ដែលកើតពីស្លឹកត្នោត និងខ្យល់ផ្លិតទាំងពីរនេះ ក៏រមែងញុំាងខ្យល់សូម្បីដែលមិនទាន់កើតឡើងឱ្យកើតឡើង, សូម្បីដែលកើតឡើងហើយ ក៏ឱ្យបន្តទៅទៀត ។

បទថា **"យំ វា បន"** នេះ បានដល់ ខ្យល់ដ៏សេស វៀរខ្យល់ដែលមាន

---

[៥៦] ពាក្យថា ***វេរម្ភវាតា*** សំដៅដល់ ខ្យល់ព្យុះធំ (ខ្យល់កំបុតត្បូង) ។

មកក្នុងបាលីហើយរាប់បញ្ចូលក្នុងឋានៈជាយេវាបនកន័យ ៕

## អាកាសធាតុនិទ្ទេសខាងក្នុង

គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសនៃអាកាសធាតុតទៅ ៖

ក៏ឈ្មោះថា **អាកាស** ព្រោះអត្ថថា រមែងភ្ជួរមិនបាន ដោយអត្ថថា ប៉ះខ្ទប់មិនបាន ។ អាកាសនោះឯង ឈ្មោះថា **អាកាសគតំ** (ធម្មជាតដែលរាប់ថាអាកាស) ព្រោះដល់ភាវៈជាអាកាស ។ ក៏ឈ្មោះថា **អឃំ** (ភាពទទេ) ព្រោះជាវត្ថុដែលប៉ះទង្គិចមិនបាន **អឃំ**ហ្នឹងឯងឈ្មោះថា **អឃគតំ** ព្រោះដល់នូវភាពប៉ះទង្គិចមិនបាន ។ បទថា **“វិវរោ** = ប្រហោងទទេ” បានដល់ ប្រហោងក្នុងចន្លោះ ។ ប្រហោងនោះៗឯង ឈ្មោះថា **វិវរគតំ** (ព្រោះជាធម្មជាតដែលរាប់ថាប្រហោងទទេ) ។ បទថា **“អសម្ផុដ្ឋំ មំសលោហិតេហិ** = កន្លែងដែលសាច់ និងឈាម ពាល់ត្រូវមិនបាន” បានដល់ ទីដែលសាច់ និងឈាមមិនជាប់គ្នា ។ ក៏បទថា **“កណ្ណច្ឆិទ្ទំ** = ប្រហោងត្រចៀក” ជាដើមនេះ ជាបទសំដែងប្រភេទធម៌ គឺសាច់ និងឈាមមិនជាប់គ្នានោះៗ ឯង ។ បណ្តាបទទាំងនោះ បទថា **“កណ្ណច្ឆិទ្ទំ”** បានដល់ ប្រហោង គឺប្រហោងក្នុងត្រចៀកជាឱកាស (គឺប្រហោងទទេ) ដែលសាច់ និងឈាមមិនពាល់ត្រូវ ។ សូម្បីក្នុងពាក្យដ៏សេស ក៏ន័យនេះដែរ ។

បទថា **“យេន** [៥៧] = ដោយប្រហោងណា” សេចក្តីថា សត្វរមែងទំពាស៊ីនូវវត្ថុដែលគួរ មានរបស់ទំពាស៊ីជាដើមនេះឱ្យចូលទៅខាងក្នុង ដោយប្រហោងណា; បទថា **“យត្ថ** = ទីណា” សេចក្តីថា អាហារដែលទំពាស៊ីចូលទៅមាន ៤ យ៉ាងនេះឯង រមែងតាំងនៅក្នុងអាកាស (ប្រហោងទទេ) ពោលគឺខាងក្នុងក្រពះយ៉ាងណា ។ បទថា **“យេន** = ដោយប្រហោងណា” សេចក្តីថា សូម្បីអាហារទាំងអស់ ៤ យ៉ាងនោះ ដែលម៉ដ្ឋហើយ រាប់ថាជាកាកសំណល់ រមែងចេញទៅដោយប្រហោងណា, ប្រហោងនោះ ពីពិតានពោះ ដល់ទ្វារធំ មានប្រមាណ ១ ចំ-អាម ៤ ធ្នាប់ ជាទីដែលសាច់ និងឈាមមិនពាល់ត្រូវ គឺជាទីដែលសាច់ និងឈាមមិនជាប់គ្នា គប្បីជ្រាបថា **ជាអាកាសធាតុ** ។

ក្នុងបទថា **“យំ វា បន”** នេះ បានដល់ ប្រហោងទទេទាំងអស់នេះ គឺប្រហោងទទេ ចន្លោះស្បែក សាច់ប្រហោងទទេ ចន្លោះសរសៃ ឆ្អឹងចន្លោះរោមលោករាប់បញ្ចូលក្នុងឋានៈនៃ**យេវាបនកន័យ** ។

## អាកាសធាតុនិទ្ទេសខាងក្រៅ

គប្បីជ្រាបវិនិច្ឆ័យ **អាកាសធាតុនិទ្ទេសខាងក្រៅ** តទៅ ៖

ពាក្យថា **“អសម្ផុដ្ឋំ ចតូហិ មហាភូតេហិ** = កន្លែងដែលមហាភូតរូប

---

[៥៧] បទថា **“យេន”** និងបទថា **“យត្ថ”** ដោយលំដាប់នៃការចែកបទ, ចំណែកក្នុងព្រះត្រៃបិដកប្រែ លោកកាត់ចេញ, តែបើមិនកាត់ចេញ នឹងមានសេចក្តីដែលលោកអដ្ឋកថាចារ្យពោលទុកនេះ ។

ទាំង ៤ មិនពាល់ត្រូវ” នោះ បណ្ឌិតគប្បីជ្រាបថា ជាប្រហោងជញ្ជាំងផ្ទះ ប្រហោងទ្វារជាដើមដែលមហាភូតរូប ៤ មិនជាប់គ្នា ។ កាលព្រះយោគាវចរធ្វើបរិកម្មក្នុងអាកាសណា ឈានពួក ៤ ឬឈានពួក ៥ រមែងកើតឡើង ពាក្យនោះ លោកពោលទុកហើយ ដោយពាក្យជាអាកាសខាងក្រៅនេះ ៕

## វិញ្ញាណធាតុនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសនៃ **វិញ្ញាណធាតុ** តទៅ ៖

ធាតុ ពោលគឺចក្ខុវិញ្ញាណ ឈ្មោះថា ចក្ខុវិញ្ញាណធាតុ ។ សូម្បីក្នុងធាតុដ៏សេស ក៏ន័យនេះដែរ ។ កាលព្រះយោគីកំណត់ធាតុ ៦ នេះ ដោយប្រការដូច្នេះ ធាតុ ១៨ ឈ្មោះថា ជាហេតុដែលកំណត់បានហើយ; បានយ៉ាងណា ? គឺផោដ្ឋព្វធាតុ រមែងជាហេតុដែលលោកកាន់យកដោយសព្ទថា **បឋវី តេជោ និង វាយោ** នោះឯងជាមុន ។ លោកកាន់យកធម្មធាតុដោយសព្ទថា **អាបោធាតុ** និង **អាកាសធាតុ**នោះ, លោកកាន់យក**មនោធាតុ**[៥៨] ដោយសព្ទថា **វិញ្ញាណធាតុ**, ព្រោះសេចក្ដីដែលមនោធាតុនោះ ជាធម៌កើតមុន និងក្រោយរបស់វិញ្ញាណធាតុនោះមែនពិត; ធាតុទាំងឡាយមានចក្ខុវិញ្ញាណធាតុជាដើមមកហើយ ក្នុងព្រះសូត្រនោះឯង, ធាតុ ៩ យ៉ាងដ៏សេស បណ្ឌិតគប្បីនាំមកសំដែង ។

---

[៥៨] មនោធាតុ ៣ គឺ អហេតុកកិរិយា (បញ្ចទ្វារាវជ្ជនចិត្ត) ១ ដួង អហេតុកវិបាក (សម្បដិច្ឆន្នចិត្ត) ២ ដួង ។

ពិតណាស់ ចក្ខុធាតុដែលជាទីអាស្រ័យកើតរបស់ចក្ខុវិញ្ញាណធាតុនោះ និងរូបធាតុដែលជាអារម្មណ៍ របស់ចក្ខុវិញ្ញាណធាតុនោះ ជាធម្មជាតដែលលោកកាន់យកដោយសព្ទថា **ចក្ខុវិញ្ញាណធាតុ** ដោយប្រការដូច្នេះ; សោតធាតុជាដើម ក៏រមែងជាធម្មជាតដែលលោកកាន់យកដោយសព្ទថា សោតវិញ្ញាណធាតុជាដើម សូម្បីធាតុ ១៨ ក៏លោកកាន់យកហើយ ដោយប្រការដូច្នេះដែរ ។

បណ្ដាធាតុ ១៨ នោះ លោកកំណត់រូបធាតុទុក ១០, កំណត់អរូបធាតុទុក ៧, ក្នុងធម្មធាតុ លោកកំណត់យករូបធាតុក៏មាន, កំណត់យកអរូបធាតុក៏មាន; ដោយហេតុនេះ ការកំណត់រូបធាតុទើបមាន ១០ កន្លះ (១០,៥), កំណត់អរូប-ធាតុ ទើបមាន ៧ កន្លះ (៧,៥) ព្រោះហេតុដូច្នោះ ការកាន់យករូបធាតុ និងអរូបធាតុ ឈ្មោះថា លោកពោលហើយ ។ បណ្ឌិតគប្បីសំដែងខន្ធ ៥ ដែលជារូប និងអរូប (យ៉ាងនេះគឺ) ធម៌ដែលជារូប និងអរូបនោះ **ជាទុក្ខសច្ច**, តណ្ហាក្នុងភពមុនដែលជាហេតុឱ្យទុក្ខសច្ចនោះតាំងឡើង **ជាសមុទយសច្ច**; ការមិនប្រព្រឹត្តទៅនៃទុក្ខ-សច្ច និងសមុទយសច្ចទាំង ២ **ជានិរោធសច្ច**, មគ្គដែលជាហេតុ នូវដឹងនិរោធសច្ចនោះ **ជាមគ្គសច្ច** កម្មដ្ឋាន គឺសច្ចៈ ៤ នេះ ដោយប្រការដូច្នេះ គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ធម៌ជានាំគ្រឿងចេញ ព្រោះពន្លះធម៌ដ៏ខ្ពង់ខ្ពស់រហូតដល់ព្រះអរហត្តរបស់ភិក្ខុអ្នកកំណត់ពិចារណាធាតុ ១៨ ។

## ធាតុនិទ្ទេស ៦ ន័យទី ២

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់កាលនឹងទ្រង់សំដែងធាតុ ៦ ន័យទី ២ ទើបត្រាស់ថា **អបរានិ ឆ ធាតុយោ** = ធាតុ ៦ ន័យដទៃទៀតជាដើម ។

ក្នុងព្រះបាលីនោះ ពាក្យថា "**សុខធាតុ ទុក្ខធាតុ** = សុខធាតុ និងទុក្ខធាតុ" បានដល់ សុខ និងទុក្ខដែលអាស្រ័យកាយបសាទទើបកើតឡើង ទ្រង់សំដែងធ្វើឱ្យជារបស់គូគ្នា ដោយអំណាចសេចក្តីជាបដិបក្សនឹងគ្នា; ពិតណាស់ សុខជាបដិបក្ស (ផ្ទុយគ្នា) ចំពោះទុក្ខ; ទុក្ខក៏ជាបដិបក្សចំពោះសុខ ។ ឋានដែលសុខផ្សាយទៅហើយ មានប្រមាណប៉ុនណា (ក្នុងកាយនេះ), ទុក្ខក៏ផ្សាយទៅមានប្រមាណប៉ុណ្ណោះ ។ ឋានដែលទុក្ខផ្សាយទៅហើយ មានប្រមាណប៉ុនណា, សុខក៏ផ្សាយទៅមានប្រមាណប៉ុណ្ណោះ ។

សូម្បីពាក្យថា "**សោមនស្សធាតុ ទោមនស្សធាតុ** = សោមនស្សធាតុ និងទោមនស្សធាតុ" នេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ធ្វើឱ្យជាគូគ្នា ដូចយ៉ាងសុខ និងទុក្ខនោះដែរ ។ ពិតណាស់ សោមនស្សជាបដិបក្សចំពោះទោមនស្ស, ទោ-មនស្ស ក៏ជាបដិបក្សចំពោះសោមនស្ស; ឋានដែលសោមនស្សផ្សាយទៅក្នុងសរីរៈនេះ មានប្រមាណប៉ុនណា, ទោមនស្ស ក៏ផ្សាយទៅមានប្រមាណប៉ុណ្ណោះ; ឋានដែលទោមនស្សផ្សាយទៅ មានប្រមាណប៉ុនណា, សោមនស្ស ក៏ផ្សាយទៅមានប្រមាណប៉ុណ្ណោះ ។

ម្យ៉ាងទៀត ពាក្យថា "**ឧបេក្ខាធាតុ អវិជ្ជាធាតុ** = ឧបេក្ខាធាតុ និងអវិជ្ជាធាតុ" ២ បទនេះ ទ្រង់ត្រាស់ធ្វើឱ្យជាគូនឹងគ្នា ដោយអំណាចនៃធម៌ ជា

ធម្មជាតលាយគ្នា ។ ពិតណាស់ ធាតុទាំង ២ នេះ ជាធាតុស្រដៀងគ្នា ព្រោះជាធាតុមិនច្បាស់លាស់ ។

បណ្ដាធាតុទាំងនោះ កាយធាតុដែលប្រកបជាមួយសុខ និងទុក្ខនោះ ជាទីអាស្រ័យឱ្យកាយវិញ្ញាណកើត ឯផោដ្ឋព្វធាតុដែលជាអារម្មណ៍ប្រកបជាមួយសុខនិងទុក្ខរមែងជាធម្មជាតដែលលោកកាន់យកហើយដោយសព្ទថា សុខទុក្ខធាតុនោះឯង ។ មនោវិញ្ញាណធាតុ ដែលសម្បយុត្តដោយសោមនស្ស និងទោមនស្សនោះរមែងជាធម្មជាតដែលលោកកាន់យកដោយសព្ទថា សោមនស្ស និងទោមនស្ស-ធាតុ; ធម្មធាតុកាន់យកដោយសព្ទថា អវិជ្ជាធាតុ ។ ចក្ខុវិញ្ញាណធាតុ សោត-វិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ និងមនោធាតុ (៣), ឯចក្ខុធាតុនិងរូបធាតុជាដើម ដែលជាវត្ថុ (ទីអាស្រ័យឱ្យវិញ្ញាណកើត) នឹងជាអារម្មណ៍របស់ចក្ខុវិញ្ញាណធាតុជាដើមនោះៗ ឯង ជាការកាន់យកហើយ ដោយសព្ទថាឧបេក្ខាធាតុ ព្រោះហេតុនោះ ធាតុ ១៨ យ៉ាង ទើបជាការកាន់យកហើយ ដោយប្រការដូច្នេះ ។

ឥឡូវនេះ គប្បីជ្រាបពាក្យទាំងអស់មានជាអាទិ៍ថា បណ្ដាធាតុទាំង ១៨ នោះ លោកកំណត់រូបធាតុទុក ១០ យ៉ាង ដោយន័យដែលពោលទុកក្នុងពេលក្រោយនោះឯង; ក៏គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ធម៌ ជាគ្រឿងចេញទៅដល់ភិក្ខុមួយរូប អ្នកពន្ធុះធម៌ដ៏ខ្ពង់ខ្ពស់រហូតដល់ព្រះអរហត្ត ដោយប្រការដូច្នេះ ។

ពាក្យថា **“តត្ថ កតមា សុខធាតុ យំ កាយិកំ សាតំ** = ក្នុងធាតុ ៦ នោះ សុខធាតុ តើយ៉ាងណា ? ការសប្បាយកាយ សប្បាយចិត្ត” ជាដើម មាន

ន័យតាមដែលពោលទុកក្នុងពេលមុននោះឯង ៕

## ធាតុនិទ្ទេស ៦ ន័យទី ៣

គប្បីជ្រាបវិនិច្ឆ័យ **ធាតុនិទ្ទេស ៦ ន័យទី ៣** តទៅ ៖

ពាក្យថា **"កាម"** បានដល់ កាម ២ គឺវត្ថុកាម និងកិលេសកាម; បណ្តាកាមទាំងពីរនោះ ធាតុដែលប្រកបដោយកាមឈ្មោះថា **កាមធាតុ**, កាមធាតុនោះជារបស់កាមវិតក្កៈ (ការត្រិះរិះក្នុងកាម); ធាតុ គឺកាមនោះឯង សំដៅដល់វត្ថុ-កាម ឈ្មោះថា **កាមធាតុ**, ពាក្យនេះ ជាឈ្មោះរបស់កាមាវចរធម៌ ធាតុដែលប្រកបដោយព្យាបាទ ឈ្មោះថា **ព្យាបាទធាតុ**, ពាក្យថា **ព្យាបាទធាតុ** នេះ ជាឈ្មោះរបស់ព្យាបាទវិតក្កៈ (ការត្រិះរិះក្នុងព្យាបាទ); ធាតុ គឺព្យាបាទនោះឯង ឈ្មោះថា **ព្យាបាទធាតុ**, ពាក្យថា **ព្យាបាទធាតុ** នេះ ជាឈ្មោះរបស់បដិឃៈមានអាឃាតវត្ថុ ១០ ប្រការ[៥៩] ។ ធាតុដែលប្រកបដោយវិហិង្សា (សេចក្តីបៀតបៀន) ឈ្មោះថា

---

[៥៩] អាឃាតវត្ថុ ១០ ប្រការ គឺ

១- អាឃាតដោយគិតថា គេធ្លាប់បានធ្វើសេចក្តីវិនាសឱ្យយើង

២- អាឃាតដោយគិតថា គេកំពុងធ្វើសេចក្តីវិនាសឱ្យដល់យើង

៣- អាឃាតដោយគិតថា គេនឹងធ្វើសេចក្តីវិនាសឱ្យដល់យើង

៤- អាឃាតដោយគិតថា គេធ្លាប់បានធ្វើសេចក្តីវិនាសដល់មនុស្សដែលយើងស្រឡាញ់

៥- អាឃាតដោយគិតថា គេកំពុងធ្វើសេចក្តីវិនាសដល់មនុស្សដែលយើងស្រឡាញ់

៦- អាឃាតដោយគិតថា គេនឹងធ្វើសេចក្តីវិនាសដល់មនុស្សដែលយើងស្រឡាញ់ (ត)

**វិហិង្សាធាតុ,** ពាក្យថា "វិហិង្សាធាតុ" នេះ ជាឈ្មោះរបស់វិហិង្សាវិតក្កៈ (សេចក្ដីត្រិះរិះក្នុងការបៀតបៀន); ធាតុ គឺវិហិង្សាវិតក្កៈនោះឯង ក៏ឈ្មោះថា **វិហិង្សាធាតុ,** ពាក្យនេះ ជាឈ្មោះនៃការបៀតបៀនសត្វដទៃ ។

ម្យ៉ាងទៀត វិហិង្សានេះ ព្រោះនៅមិនមក (នៅមិនបានពោលទុក) ក្នុងពេលក្រោយ ទើបគួរជ្រាបដោយការចែកអត្ថជាដើម ដូចតទៅនេះ ៖

ពាក្យថា **"វិហិនន្តិ"** មានវិគ្រោះថា ក៏ឈ្មោះថា **វិហិង្សា** ព្រោះអត្ថថា មានចេតនាជាហេតុឱ្យបៀតបៀនសត្វ ឬសត្វមានសេចក្ដីបៀតបៀន ។ វិហិង្សានោះ បណ្ឌិតគប្បីជ្រាបថា មានសេចក្ដីបៀតបៀនជាលក្ខណៈ ឬមានភាពបដិបក្សចំពោះករុណាជាលក្ខណៈ; មានសេចក្ដីធ្វើឱ្យកើតការព្រឺខ្លាច ក្នុងសន្ដានរបស់សត្វដទៃ ជារស ឬថា មានការកម្ចាត់ករុណា ក្នុងសន្ដានរបស់ខ្លួនជារស; មានការបង្កើតទុក្ខ ជាបច្ចុប្បដ្ឋាន, មានបដិឃៈជាបទដ្ឋាន ។

**"អលោភៈ** = សេចក្ដីមិនលោភ" ហៅថា **នេក្ខម្មៈ** ព្រោះចេញចាកការលោភ, បឋមជ្ឈានក៏ហៅថា **នេក្ខម្មៈ** ព្រោះចេញចាកនីវរណៈទាំងឡាយ, កុសលទាំងអស់ ក៏ហៅថា **នេក្ខម្មៈ** ព្រោះចេញចាកអកុសលទាំងអស់ ។ ធាតុប្រកបដោយ **នេក្ខម្មៈ** ឈ្មោះថា **នេក្ខម្មធាតុ,** ពាក្យថា **នេក្ខម្មធាតុ** នេះ ជាឈ្មោះរបស់នេក្ខម្មវិតក្កៈ;

---

៧- អាឃាតដោយគិតថា គេធ្លាប់ធ្វើគុណប្រយោជន៍ដល់មនុស្សដែលយើងស្អប់

៨- អាឃាតដោយគិតថា គេកំពុងធ្វើគុណប្រយោជន៍ដល់មនុស្សដែលយើងស្អប់

៩- អាឃាតដោយគិតថា គេនឹងធ្វើគុណប្រយោជន៍ដល់មនុស្សដែលយើងស្អប់

១០- អាឃាតក្នុងឋានៈដែលមិនគួរ មានការដើរជំពប់គល់ឈើជាដើម ។

ធាតុ គឺនេក្ខម្មៈហ្នឹងឯង ឈ្មោះថា នេក្ខម្មធាតុ, ពាក្យថា **"នេក្ខម្មធាតុ"** នេះ ជាឈ្មោះនៃកុសលសូម្បីទាំងអស់; ធាតុដែលប្រកបដោយការមិនព្យាបាទ ឈ្មោះថា **អព្យាបាទធាតុ**, ពាក្យថា **អព្យាបាទធាតុ** នេះ ជាឈ្មោះរបស់អព្យាបាទវិតក្កៈ; ធាតុ គឺអព្យាបាទហ្នឹងឯង ជាឈ្មោះរបស់ **អព្យាបាទធាតុ**, ពាក្យនេះជាឈ្មោះរបស់មេត្តា; ធាតុដែលប្រកបដោយការមិនបៀតបៀន ឈ្មោះថា **អវិហិំសាធាតុ**, ពាក្យថា **"អវិហិង្សាធាតុ"** នេះ ជាឈ្មោះរបស់អវិហិង្សាវិតក្កៈ; ធាតុ គឺអវិហឹង្សានោះឯង ជាឈ្មោះរបស់អវិហិង្សាធាតុ; ពាក្យថា **អវិហិង្សា** នេះ ជាឈ្មោះរបស់ករុណា ។

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ប្រាថ្នានឹងសំដែងសេចក្តី (ធាតុ ៦) នោះៗឯង ទើបផ្តើមបទភាជនៈ (បទពង្រីក) ថា **"តត្ថ កតមា កាមធាតុ** = ក្នុង ធាតុ ៦ នោះ កាមធាតុតើដូចម្តេច ?" ដូច្នេះជាដើម ។

ក្នុងព្រះបាលីនោះ បទថា **"បដិសំយុត្តោ** = ប្រកប" ; ក៏ឈ្មោះថា **បដិ-សំយុត្តោ** (ប្រកប) ដោយអំណាចនៃសម្បយោគ [៦០] ។ បទថា **"តក្កោ វិតក្កោ** = សេចក្តីត្រិះរិះ សេចក្តីត្រិះរិះយ៉ាងខ្លាំង" ជាដើម មានសេចក្តីតាមដែលលោកពោលហើយនោះឯង ។ ពាក្យថា **"វិហេឋេតិ** = រមែងបៀតបៀន" គឺរមែងឱ្យទទួលទុក្ខ ។ ពាក្យថា **"ហេឋនា** = ការគំរាមកំហែង" បានដល់ ការបង្កឱ្យកើតសេចក្តីទុក្ខ ដោយការបៀតបៀន មានការប្រហារដោយបាតដៃជាដើម; ការគំរាមកំហែងយ៉ាងខ្លាំង ឈ្មោះថា **វិហេឋនា**; ចេតនាជាហេតុបៀតបៀន ឈ្មោះថា

---

[៦០] សម្បយោគប្រកបដោយអង្គ ៤ គឺ កើតព្រមគ្នា រលត់ព្រមគ្នា មានអារម្មណ៍ជាមួយគ្នា និងមានវត្ថុជាមួយគ្នា ។

**ហិង្សនា** ។ ចេតនាជាហេតុបៀតបៀនដ៏មានកម្លាំង ឈ្មោះថា **វិហិង្សនា** ។ ពាក្យថា **រោសនា** បានដល់ កំហឹង; ពាក្យថា **វិរោសនា** បានដល់ គំនុំដ៏មានកម្លាំង ។ ក្នុងបទទាំងអស់ លោកបន្ថែមបទដោយវិឧបសគ្គ ។ ចេតនាជាហេតុចូលទៅបៀតបៀន ឈ្មោះថា **ឧបឃាត**, ការធ្វើអាក្រក់ឱ្យដល់អ្នកដទៃ ឈ្មោះថា **បរូបឃាត** ។

ចេតនាជាហេតុមានមេត្រី ឈ្មោះថា **មេត្តិ** = ការមានមេត្រី; អាការដែលមានមេត្រី ឈ្មោះថា **មេត្តាយនា** = កិរិយាដែលមានមេត្រី; ភាវៈជារបស់បុគ្គលបរិបូរដោយមេត្តា របស់បុគ្គលអ្នកប្រកបដោយមេត្តា ឈ្មោះថា **មេត្តាយិតត្តំ** = សភាពដែលមានមេត្រី; ការមានចិត្តរួចស្រឡះចាកព្យាបាទ ឈ្មោះថា **ចេតោវិមុត្តិ**; ក្នុងទីនេះ មេត្តាពោលទុក ៣ បទដំបូង ត្រាស់ដល់ឧបចារសមាធិខ្លះ, ដល់អប្បនាសមាធិខ្លះ, បទក្រោយ (**ចេតោវិមុត្តិ**) ត្រាស់មេត្តាទុកដល់អប្បនាប៉ុណ្ណោះ ។

ចេតនាជាហេតុឱ្យអាណិតអាសូរ ឈ្មោះថា **ករុណា** = **ករុណាយន្តិ ឯតាយាតិ** > **ករុណា**; អាការរបស់ករុណា ឈ្មោះថា **ករុណាយនា** = កិរិយាដែលករុណា; ភាពនៃបុគ្គលអ្នកដល់ព្រមដោយករុណា របស់បុគ្គលអ្នកប្រកបដោយសេចក្តីករុណា ឈ្មោះថា **ករុណាយិតត្តំ** = ភាពនៃករុណា; ការមានចិត្តរួចស្រឡះចាកការបៀតបៀន ឈ្មោះថា **ចេតោវិមុត្តិ** ។ សូម្បីក្នុងខនេះ ក៏គប្បីជ្រាបសេចក្តីផ្សេងគ្នានៃឧបចារសមាធិ និងអប្បនាសមាធិដោយន័យមុននោះឯង; ម្យ៉ាងទៀត ក្នុងបទចុងក្រោយសូម្បីទាំង ២ គឺមេត្តា ករុណា ព្រះអង្គត្រាស់ទុកដើម្បីសំដែងសេចក្តីប្លែកគ្នារបស់ចេតោវិមុត្តិ ។

ម្យ៉ាងវិញទៀត បណ្តាធាតុទាំង ៦ នោះ កាមវិតក្កៈ រមែងកើតឡើងក្នុង

សត្វទាំងឡាយខ្លះ, ក្នុងសង្ខារទាំងឡាយខ្លះ; កាមវិតក្កៈសូម្បីកើតឡើងក្នុងសត្វ និងសង្ខារទាំង ២ ជាការទម្លាយកម្មបថដូចគ្នា; តែ**ព្យាបាទ**ក្នុងសត្វទាំងឡាយ តែម្យ៉ាង ក៏ទម្លាយកម្មបថ, ក្រៅពីនេះមិនទម្លាយទេ ។ សូម្បីក្នុងវិហិង្សា ក៏មានន័យដូចគ្នានេះដែរ ។ ក៏ក្នុងអធិការនេះ មានកថា ២ គឺ **សព្វសង្គាហិកកថា** = ពាក្យរួមទុកទាំងអស់ និង **អសម្ភិន្នកថា** = ពាក្យញែកគ្នា ។

ពិតណាស់ សូម្បីព្យាបាទធាតុ និងវិហិង្សាធាតុទ្រង់កាន់យកដោយសព្ទថា កាមធាតុ; ក៏ឯព្យាបាទ និងវិហិង្សាសូម្បីទាំង ២ នេះ ក៏នាំចេញហើយចាកកាម-ធាតុនោះឯង ទើបទ្រង់សំដែងទុក, ព្រោះហេតុនោះ កថានេះគប្បីជ្រាបថា ឈ្មោះថា **សព្វសង្គាហិកកថា** ក្នុងទីនេះជាមុនសិន ។ ចំណែកកថាដែលត្រាស់ទុកថា វៀរព្យាបាទ និងវិហិង្សាធាតុហើយ ធម៌ដ៏សេសសូម្បីទាំងអស់ ជាកាមធាតុប៉ុណ្ណោះនេះ ឈ្មោះថា **អសម្ភិន្នកថា** ។

អព្យាបាទធាតុ និងអវិហិង្សាធាតុ ព្រះអង្គទ្រង់កាន់យកសូម្បីដោយសព្ទថា នេក្ខម្មធាតុនោះឯង; ក៏សេចក្ដីមិនព្យាបាទ និងសេចក្ដីមិនបៀតបៀនសូម្បីទាំង ២ នោះ ព្រះអង្គទ្រង់នាំចេញហើយចាកនេក្ខម្មធាតុមកសំដែង ព្រោះហេតុនោះ កថានេះទើបឈ្មោះថា **សព្វសង្គាហិកកថា** សូម្បីក្នុងទីនេះ ។ កថានេះថា អព្យាបាទធាតុ និងអវិហិង្សាធាតុដ៏សេស ឈ្មោះថា នេក្ខម្មធាតុ ឈ្មោះថា **អសម្ភិន្នកថា** ។

ម្យ៉ាងទៀត ធាតុ ៦ ពួកនេះ ទ្រង់កាន់យកហើយ, ធាតុ ១៨ ក៏ឈ្មោះថាទ្រង់កាន់យកហើយដូចគ្នា; ព្រោះសូម្បីធាតុទាំងអស់នោះ ដែលបុគ្គលនាំចេញហើយចាកកាមធាតុ ក៏បានធាតុ ១៨ ដូចគ្នា ព្រោះហេតុនោះ កាលបើពោលថា

ធាតុពួក ៦ ពួក ៣ ក៏រមែងបានធាតុ ១៨; តែថា មិនកាន់យកធាតុដោយអាការយ៉ាងនេះ ក៏គប្បីជ្រាបក្នុងពួកធាតុ ៦ តែគ្រប់ពួក ធ្វើឱ្យជាពួក ១៨ ដោយន័យដែលពោលហើយ សូម្បីបំពេញធាតុទាំងអស់ ១៨ នោះក៏ដូចគ្នា ក៏នឹងមានតែ ១៨ ប៉ុណ្ណោះ ។ ក្នុងសុត្តន្តភាជនិយនេះ កាមធាតុ ១៦ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មាន ២ ធាតុ ព្រោះហេតុនោះ គប្បីជ្រាបថា វារៈសម្តែងអំពីសម្មសនៈ (ការពិចារណា) ក្នុងអធិការនៃធាតុនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដោយប្រការដូច្នេះ ៕

**(ចប់ការពណ៌នាអំពីសុត្តន្តភាជនិយ)**

## ពណ៌នាអំពីអភិធម្មភាជនិយ

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងសូម្បីនូវធាតុទាំងអស់ក្នុងអភិ-ធម្មភាជនិយដោយសរុបប៉ុណ្ណោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **"អដ្ឋារស ធាតុយោ ចក្ខុធាតុ រូបធាតុ** = ធាតុ ១៨ គឺ ចក្ខុធាតុ រូបធាតុ" ; ក្នុងការពណ៌នាអំពីអភិធម្មភាជនិយនោះ គប្បីជ្រាបវារៈសម្ដែងអំពីឧទ្ទេសជាមុនថា ៖

**អត្ថតោ លក្ខណាទីហិ កមតាវត្វសំខតោ**
**បច្ចយា អថ ទដ្ឋព្វា វេទិតព្វោ វិនិច្ឆយោ**

គប្បីជ្រាបវិនិច្ឆ័យដោយអត្ថ ដោយលក្ខណៈជាដើម ដោយលំដាប់ ដោយចំនួនប៉ុណ្ណោះ ដោយការរាប់ ដោយបច្ច័យ និងដោយជាធម៌ដែលគួរឃើញ ៕

## សម្ដែងអំពីការវិនិច្ឆ័យដោយអត្ថ

បណ្ដាឧទ្ទេសទាំងនោះ ពាក្យថា **ដោយអត្ថ** គប្បីជ្រាបវិនិច្ឆ័យដោយអត្ថដែលប្លែកគ្នារបស់ធម៌មានចក្ខុជាដើម ដោយន័យមានជាអាទិ៍យ៉ាងនេះថា ក៏ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា រមែងមើលឃើញ = **ចក្ខតីតិ ចក្ខុ**; ឈ្មោះថា **រូប** ព្រោះអត្ថថា រមែងសម្ដែងខ្លួនឱ្យប្រាកដ = **រូបយតីតិ រូបំ**; សេចក្ដីដឹង (វិញ្ញាណ) ដោយចក្ខុ ឈ្មោះថា **ចក្ខុវិញ្ញាណ** ដូច្នេះសិន ។

ចំណែកដោយមិនប្លែកគ្នាមានវិនិច្ឆ័យដូច្នេះ ៖

ក៏ឈ្មោះថា **ធាតុ** ព្រោះអត្ថថា រមែងចាត់ចែង, ព្រោះអត្ថថា រមែងទ្រ

ទ្រង់ទុក, ព្រោះអត្ថថា ជាហេតុចាត់ចែង, ព្រោះអត្ថថា ជាហេតុទ្រទ្រង់ទុក ដោយប្រការផ្សេងៗ ឬព្រោះអត្ថថា ជាទីទ្រទ្រង់ទុក ។

ពិតណាស់ ធាតុទាំងឡាយដែលជាលោកិយ៍ ជាធាតុដែលកំណត់ទុកដោយសេចក្ដីជាហេតុ រមែងចាត់ចែងសង្ខារទុកច្រើនប្រការ ដូចធាតុនៃមាស និងប្រាក់ជាដើម ដែលបុគ្គលចាត់ចែងទុកថាជាមាស និងប្រាក់ជាដើម; ម្យ៉ាង ធាតុទាំងឡាយដែលសត្វរមែងទ្រទ្រង់ទុក គឺទទួលរងទុកដូចរបស់ធ្ងន់ដែលបែកទៅ ។ ម្យ៉ាងទៀត ធាតុពួកនេះ ឈ្មោះថា ត្រឹមតែចាត់ចែងទុកប៉ុណ្ណោះ ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច; ម្យ៉ាងវិញទៀត ធាតុពួកនេះជាហេតុឱ្យពួកសត្វទាំងឡាយ ត្រាច់រង្គត់ទៅកាន់សង្សារទុក្ខ; ពុំនោះសោត ធាតុដែលជាហេតុនេះ ជាទីតាំង គឺជាទីញ៉ាំងសង្សារទុក្ខឱ្យស្ថិតនៅក្នុងបណ្ដាចក្ខុជាដើម ធម៌គ្រប់យ៉ាង លោកហៅថា **ធាតុ** ដោយអំណាចនៃអត្ថថា រមែងចាត់ចែង រមែងទ្រទ្រង់ទុកជាដើម នូវសេចក្ដីដែលមានពិតដូចពណ៌នាមកដូច្នេះឯង ។

បើពុំដូច្នោះទេ ឈ្មោះថា អត្តារបស់ពួកអន្យតិរ្ថិយ៍ រមែងមិនមានដោយភាវៈរបស់ខ្លួន យ៉ាងណា, ធាតុពួកនោះរមែងជាយ៉ាងនោះ មិនបានមានទេ; ដែលហៅថា **ធាតុ** ព្រោះអត្ថថា រមែងទ្រទ្រង់ទុកនូវសភាវៈរបស់ខ្លួន = **អត្តនោ សភាវំ ធារេន្តីតិ ធាតុយោ** ប្រៀបដូចចំណែកនៃសិលា មានហរតាល និងមនោសិលាជាដើម ដែលវិចិត្រក្នុងលោក ហៅថា **ធាតុ** យ៉ាងណា, សូម្បី**ធាតុ** (មានចក្ខុធាតុ ជាដើម) នេះ ក៏ហៅថា ធាតុដូចគ្នាដែរ; ព្រោះធាតុដែលវិចិត្រទាំងនេះ ជាអវយវៈដែលគប្បីដឹងបានដោយញាណប៉ុណ្ណោះ ឬថា ក្នុងចំណែកទាំងឡាយ មានរស និង

ឃានជាដើម ដែលកំណត់ដោយលក្ខណៈ ដែលផ្ទុយនូវគ្នានឹងគ្នា ជាចំណែករបស់កាយតាំងឡើង **គឺសរីរៈ** លោកហៅឈ្មោះថា **ធាតុ** យ៉ាងណា, ក្នុងចំណែករបស់អត្តភាព ពោលគឺសូម្បីបញ្ចក្ខន្ធនេះ ក៏គប្បីជ្រាបឈ្មោះថា **ធាតុ** យ៉ាងនេះដែរ; ព្រោះថា ចក្ខុជាដើមនេះ លោកពោលកំណត់ដោយលក្ខណៈផ្សេងគ្នានឹងគ្នា ។

ឬក៏ពាក្យថា **ធាតុ** នេះ គ្រាន់តែជាឈ្មោះរបស់វត្ថុប្រាសចាកជីវៈ; ពិតមែនព្រះមានព្រះភាគជាម្ចាស់ទ្រង់បានសម្ដែងធាតុ ដើម្បីដកសេចក្ដីសម្គាល់ថា មានជីវៈទុកក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា **“ឆ ធាតុរោ អយំ ភិក្ខុ បុរិសោ** = ម្នាលភិក្ខុ មនុស្សនេះមានធាតុ ៦” ; ព្រោះហេតុនោះ ទើបត្រាស់ថា ចក្ខុធាតុ ព្រោះអត្ថថា ជាចក្ខុផង ជាធាតុផង ។ ល ។ ឈ្មោះថា មនោវិញ្ញាណធាតុ ព្រោះអត្ថថា ជាមនោវិញ្ញាណផង ជាធាតុផង ដោយអត្ថតាមដែលបានពោលហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងធាតុនេះ ដោយអត្ថយ៉ាងនេះសិនចុះ ៕

## សម្ដែងអំពីការវិនិច្ឆ័យដោយលក្ខណៈជាដើម

ក៏ពាក្យថា **ដោយលក្ខណៈជាដើម** ក្នុងទីនេះ គប្បីជ្រាបវិនិច្ឆ័យដោយលក្ខណៈជាដើម នៃធម៌មានចក្ខុជាដើមនោះ ដោយន័យតាមដែលពោលទុកក្នុងពេលក្រោយនោះឯង ៕

## សម្ដែងអំពីការវិនិច្ឆ័យដោយលំដាប់

ក្នុងខថា **ដោយលំដាប់** សូម្បីក្នុងទីនេះ បណ្ដាលំដាប់ទាំងឡាយ មាន

លំដាប់នៃការកើតជាដើម តាមដែលពោលទុកមុន លំដាប់ គឺការសម្ដែង(ទេសនា) ប៉ុណ្ណោះសមគួរ; ក៏លំដាប់នៃការសម្ដែងនេះឯង ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកដោយអំណាចនៃការកំណត់តាមលំដាប់ហេតុ និងផល ។ ពិតណាស់ បទ ២ គឺចក្ខុធាតុ និងរូបធាតុនេះ ជាហេតុ, ពាក្យថា ចក្ខុវិញ្ញាណធាតុនេះ ជាផល ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងពួងដោយលំដាប់ដូចពោលមកនេះចុះ ៕

## សម្ដែងអំពីការវិនិច្ឆ័យដោយមានចំនួនប៉ុណ្ណោះ

ខថា **ដោយមានចំនួនប៉ុណ្ណោះ** បានដល់ ដោយចំនួនមានតែប៉ុណ្ណោះ; ពាក្យនេះ មានអធិប្បាយថា ក្នុងបទព្រះសូត្រ និងព្រះអភិធម្មទាំងនោះៗ សូម្បីធាតុដទៃៗ រមែងប្រាកដមានជាអាទិ៍យ៉ាងនេះថា “អាកាសធាតុ, សុភធាតុ, អាកាសានញ្ចាយតនធាតុ, វិញ្ញាណញ្ចាយតនធាតុ, អាកិញ្ចញ្ញាយតនធាតុ, នេវសញ្ញានាសញ្ញាយតនធាតុ, សញ្ញាវេទយិតនិរោធធាតុ, កាមធាតុ, ព្យាបាទធាតុ, វិហិង្សាធាតុ, នេក្ខម្មធាតុ, អព្យាបាទធាតុ, អវិហិង្សាធាតុ, សុខធាតុ, ទុក្ខធាតុ, សោមនស្សធាតុ, ទោមនស្សធាតុ, ឧបេក្ខាធាតុ, អវិជ្ជាធាតុ, អារម្ភធាតុ, និក្ខមធាតុ, បរក្កមធាតុ, ហីនធាតុ, មជ្ឈិមធាតុ, បណីតធាតុ, បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ, អាកាសធាតុ, វិញ្ញាណធាតុ, សង្ខតធាតុ, អសង្ខតធាតុ, លោកជាអនេកធាតុ និងមានធាតុផ្សេងៗ ទៀត”[៦១] ។

---

[៦១] នេះគ្រាន់តែជាតួយ៉ាងប៉ុណ្ណោះ តាមពិតទៅ ធាតុនៅមានច្រើនយ៉ាងទៀត ។

**បើមានពាក្យសួរថា** កាលបើបែបនោះ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់មិនកំណត់ចំនួនធាតុទាំងអស់ ទ្រង់កំណត់ទុកតែ ១៨ ធាតុប៉ុណ្ណោះទៅវិញ ?

ឆ្លើយថា ព្រោះធាតុគ្រប់យ៉ាងមានដោយសភាវៈរួមនៅខាងក្នុងធាតុ ១៨ ប៉ុណ្ណោះ ។

ពិតណាស់ អាកាសធាតុ ក៏គឺរូបធាតុនេះឯង; ក៏សុភធាតុជាធាតុដែលជាប់ដោយរូបធាតុជាដើម; ព្រោះហេតុអ្វី ? ព្រោះជាសុភនិមិត្ត (គ្រឿងសម្គាល់របស់សេចក្ដីល្អ) ; ពិតណាស់ សុភនិមិត្ត ឈ្មោះថា សុភធាតុ ; ឯសុភនិមិត្តនោះ នឹងផុតពីរូបជាដើមក៏មិនមានឡើយ; ម្យ៉ាងទៀត សុភធាតុ ក៏គឺរូបធាតុជាដើម ដែលជាអារម្មណ៍របស់កុសលវិបាកនោះឯង ព្រោះហេតុនោះ ទើបសុភធាតុនេះគ្រាន់តែជារូបធាតុជាដើមនោះឯង ។ ចិត្តក្នុងអាកាសានញ្ចាយតនធាតុជាដើម បានដល់ មនោ-វិញ្ញាណធាតុ, ធាតុដ៏សេសជាធម្មធាតុ ។ ចំណែកសញ្ញាវេទយិតនិរោធធាតុ ដោយសភាវៈរមែងមិនមាន; ព្រោះសញ្ញាវេទយិតនិរោធធាតុនោះ គ្រាន់តែជាការរលត់ធាតុទាំងពីរ (គឺសញ្ញា និងវេទនា) ប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត កាមធាតុគ្រាន់តែជាធម្មធាតុ; ដូចយ៉ាងព្រះតម្រាស់ដែលត្រាស់ទុកថា **“តត្ថ កតមា កាមធាតុ; កាមបដិសំយុត្តោ តក្កោ វ បេ វ មិច្ឆាសង្កប្បោ** = ក្នុងធាតុ ៦ នោះ កាមធាតុតើដូចម្ដេច ? សេចក្ដីត្រិះរិះ សេចក្ដីត្រិះរិះយ៉ាងខ្លាំង ត្រិះរិះដែលប្រកបដោយកាម ។ល។ មិច្ឆាសង្កប្បៈនេះ ហៅថា **កាមធាតុ”** , ពុំនោះសោតទេ កាមធាតុ ក៏គឺធាតុសូម្បីទាំង ១៨ យ៉ាង; ដូចយ៉ាងដែលត្រាស់ទុកថា “ខាងក្រោម រាប់ពីអវីចិនរកជាទីបំផុត ខាងលើកំណត់ត្រឹមទេវតាជាន់បរនិម្មិតវសវត្តីជាទីបំផុត ក្នុងវារៈ

នេះ ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណឯណា ដែលត្រាច់រង្គត់ទៅក្នុងទីនោះ រាប់បញ្ចូលក្នុងខេត្តនេះ ធម៌នេះ លោកហៅថា កាមធាតុ” ។ នេក្ខម្មធាតុ គឺធម្មធាតុនោះឯង ។ ម្យ៉ាងទៀត ព្រោះព្រះបាលីថា “សូម្បីកុសលធម៌ទាំងអស់ ឈ្មោះថា **នេក្ខម្មធាតុ**» នេក្ខម្មធាតុនោះ ក៏រមែងជាមនោវិញ្ញាណធាតុបានដូចគ្នា ។ ព្យាបាទធាតុ វិហិង្សាធាតុ អព្យាបាទធាតុ អវិហិង្សាធាតុ សុខធាតុ ទុក្ខធាតុ សោមនស្សធាតុ ទោមនស្សធាតុ ឧបេក្ខាធាតុ អវិជ្ជាធាតុ អារម្ភធាតុ និក្ខមធាតុ បរក្កមធាតុ ជាធម្មធាតុនោះឯង ។ ហីនធាតុ មជ្ឈិមធាតុ និងបណីតធាតុ គ្រាន់តែជាធាតុ ១៨ ប៉ុណ្ណោះ; ព្រោះចក្ខុជាដើម ដែលជាហីនៈ (អាក្រក់) ឈ្មោះថា ហីនធាតុ, ចក្ខុជាដើមដែលជាមជ្ឈិម និងបណីតៈ ក៏ចាត់ជាមជ្ឈិមធាតុ និង បណីតធាតុ ។

តែពោលដោយនិប្បរិយាយ (ដោយត្រង់) ធម្មធាតុ និងមនោវិញ្ញាណធាតុដែលជាអកុសល **ជាហីនធាតុ,** អកុសល និងអព្យាកតៈទាំងពីរដែលជាលោកិយក្តី ចក្ខុធាតុជាដើមក្តី **ជាមជ្ឈិមធាតុ,** ចំណែកធម្មធាតុ និងមនោវិញ្ញាណធាតុដែលជាលោកុត្តរ **ជាបណីតធាតុ** ។ បឋវីធាតុ តេជោធាតុ វាយោធាតុ ក៏គឺផោដ្ឋព្វធាតុនោះឯង ។ អាបោធាតុ និងអាកាសធាតុ ក៏គឺធម្មធាតុ; វិញ្ញាណធាតុសង្ខេបចូលក្នុងវិញ្ញាណធាតុ ៧ មានចក្ខុវិញ្ញាណធាតុជាដើម ។ ធាតុ ១៧ និងមួយចំណែកនៃធម្មធាតុ **ជាសង្ខតធាតុ,** តែចំណែកមួយនៃធម្មធាតុនោះឯង ជាអសង្ខតធាតុ; ក៏លោកដែលជាអនេកធាតុ និងនានាធាតុ គ្រាន់តែជាប្រភេទនៃធាតុ ១៨ ប៉ុណ្ណោះ

ឯង ។ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ធាតុទុក ១៨ ប៉ុណ្ណោះ ព្រោះធាតុទាំងអស់មានដោយសភាវៈរួមនៅខាងក្នុងនៃធាតុ ១៨ នោះ ដូចបានពណ៌នាមកដូច្នេះឯង ។

ម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ត្រាស់ធាតុទុក ១៨ ប៉ុណ្ណោះ ដើម្បីនឹងដកសេចក្ដីសម្គាល់ថា មានជីវៈរបស់សត្វអ្នកមានសេចក្ដីសម្គាល់ថា មានជីវៈក្នុងវិញ្ញាណដែលមានការដឹងអារម្មណ៍ជាសភាវៈ ។ ពិតណាស់ សត្វទាំងឡាយអ្នកមានសេចក្ដីសម្គាល់ថា មានជីវៈក្នុងវិញ្ញាណ ដែលមានការដឹងអារម្មណ៍ជាសភាវៈ ព្រះមានព្រះភាគទ្រង់ប្រាថ្នាដើម្បីនឹងដកឡើងនូវសេចក្ដីសម្គាល់ថា មានជីវៈ ដែលដេកជាប់នៅអស់កាលដ៏យូរ របស់សត្វពួកនោះ ទើបប្រកាសសេចក្ដីមានប្រមាណច្រើននៃធាតុនោះ ដោយញែកជាចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ និងមនោវិញ្ញាណធាតុ នឹងប្រកាសសភាពនៃធាតុទាំងនោះ ជារបស់មិនទៀង ព្រោះត្រូវប្រព្រឹត្តទៅជាប់ដោយបច្ច័យ មានចក្ខុ និងរូបជាដើម ទើបទ្រង់ប្រកាសធាតុទុក ១៨ យ៉ាង; ម្យ៉ាងវិញទៀត ហេតុអ្វីៗ ដទៃដ៏ក្រៃលែង ដែលព្រះអង្គទ្រង់ប្រកាសធាតុ ១៨ យ៉ាង ដោយអំណាចនៃអធ្យាស្រ័យរបស់វេនេយ្យសត្វ និងដោយអំណាចនៃអធ្យាស្រ័យវេនេយ្យសត្វ ដោយទេសនាដែលមិនខ្លីពេក និងមិនពិស្ដារពេកនេះដោយពិត ។

**ពិតណាស់ ការងងឹតក្នុងហឫទ័យរបស់វេនេយ្យសត្វ នឹងដល់សេចក្ដីសង្ខេបទៅដោយមួយរំពេច ដែលកម្ចាត់បានដោយតេជៈនៃព្រះសទ្ធម្មរបស់ព្រះអង្គបានដោយប្រការណាៗ ព្រះអង្គក៏ទ្រង់ប្រកាសធម៌ដោយន័យដែលខ្លី និងពិស្ដារដោយប្រការនោះៗ ឯង ។**

គប្បីជ្រាបវិនិច្ឆ័យក្នុងធាតុនេះ ដោយចំនួនប៉ុណ្ណោះ មានប្រការយ៉ាងនេះ៕

## សម្តែងអំពីការវិនិច្ឆ័យដោយការរាប់

ខថា **ដោយការរាប់** គឺអំពីជាតិ ចក្ខុធាតុ បានដល់ ចក្ខុប្រសាទ រមែងមានការរាប់ថាជាធម៌តែមួយប៉ុណ្ណោះឯង; សោតធាតុ ឃានធាតុ ជិវ្ហាធាតុ កាយធាតុ រូបធាតុ សទ្ទធាតុ គន្ធធាតុ និងរសធាតុ ក៏ដូចតែគ្នា ដោយអំណាចនៃបសាទមានសោតបសាទជាដើម តែផោដ្ឋព្វធាតុ រមែងដល់ការរាប់ថាជាធម៌ ៣ យ៉ាង ដោយអំណាចនៃបឋវីធាតុ តេជោធាតុ និងវាយោធាតុ ។

ចក្ខុវិញ្ញាណធាតុ រមែងដល់ការរាប់ថាជាធម៌ ២ យ៉ាង ដោយអំណាចនៃវិបាកដែលជាកុសល និងអកុសល ។ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ និងកាយវិញ្ញាណធាតុ ក៏ដល់ការរាប់ថាជាធម៌គ្រប់ ២ យ៉ាងដូចគ្នា ។ តែមនោធាតុរមែងដល់ការរាប់ថាជាធម៌ ៣ យ៉ាង គឺដោយអំណាចជាអាវជ្ជនៈរបស់បញ្ចទ្វារ ១, ដោយអំណាចជាសម្បដិច្ឆន្នៈរបស់កុសលវិបាក ១, របស់អកុសលវិបាក ១; ធម្មធាតុរមែងដល់ការរាប់ថាជាធម៌ ២០ គឺដោយអំណាចនៃអរូបក្ខន្ធ ៣ (វេទនា សញ្ញា និងសង្ខារ) ដោយអំណាចនៃសុខុមរូប ១៦ [៦២] និងដោយអំណាចនៃអសង្ខតធាតុ ១ ។ មនោវិញ្ញាណធាតុ រមែងដល់ការរាប់ថាជាធម៌ ៧៦ យ៉ាង ដោយអំណាចនៃវិញ្ញាណដែលជាកុសល អកុសល និងអព្យាក្រឹតដ៏សេសនោះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងធាតុនេះ ដោយការរាប់យ៉ាងនេះ ៕

---

[៦២] សុខុមរូប ១៦ គឺ អាបោធាតុ ១, ហទយរូប ១, អាហាររូប ១, ជីវិតរូប ១, បរិច្ឆេទរូប ១, ភាវរូប ២, វិញ្ញត្តិរូប ២, វិការរូប ៣, លក្ខណរូប ៤ ។

## សម្តែងអំពីការវិនិច្ឆ័យដោយបច្ច័យ

ខថា **ដោយបច្ច័យ** គប្បីជ្រាបវិនិច្ឆ័យដោយធាតុមានចក្ខុធាតុជាដើម ជាបច្ច័យក្នុងចក្ខុវិញ្ញាណធាតុជាដើម; ក៏ធាតុមានចក្ខុធាតុជាដើមនោះ ជាបច្ច័យនោះនឹងជាក់ច្បាស់ក្នុងនិទ្ទេសវារៈ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយជាធម៌គួរឃើញ

ខថា **ដោយធម៌គួរឃើញ** គប្បីជ្រាបវិនិច្ឆ័យក្នុងធាតុនេះ ដោយជាធម៌ដែលគួរឃើញ; ព្រោះសង្ខតធាតុទាំងអស់តែម្តង គប្បីជ្រាបដោយសេចក្តីថាជារបស់ទទេ និងទីបំផុតខាងដើម និងខាងចុង ដោយសេចក្តីថាជារបស់សូន្យចាកសេចក្តីមាំមួន សេចក្តីល្អ សេចក្តីសុខ ភាពជាអត្តា និងសេចក្តីប្រព្រឹត្តទៅជាប់ ដោយសេចក្តីថាជាបច្ច័យ ។

ក៏បើសម្តែងអំពីសេចក្តីប្លែកគ្នាក្នុងអធិការនៃធាតុនេះ **ចក្ខុធាតុ** គប្បីជ្រាបដូចផ្ទៃស្គរ, **រូបធាតុ** គប្បីជ្រាបដូចគំនរឧស, **ចក្ខុវិញ្ញាណធាតុ** គប្បីជ្រាបដូចសម្លេងស្គរ ។ ម្យ៉ាង **ចក្ខុធាតុ** គប្បីជ្រាបដូចផ្ទៃកញ្ចក់, **រូបធាតុ** គប្បីជ្រាបដូចមុខ, **ចក្ខុ-វិញ្ញាណធាតុ** គប្បីជ្រាបដូចជានិមិត្តរបស់មុខ (ស្រមោលមុខ) ។ ម្យ៉ាងទៀត **ចក្ខុ-ធាតុ** គប្បីជ្រាបដូចដើមអំពៅ និងគ្រាប់ល្ង, **រូបធាតុ** គប្បីជ្រាបដូចគ្រឿងគាប, **ចក្ខុវិញ្ញាណធាតុ** គប្បីជ្រាបដូចទឹកអំពៅ និងប្រេងល្ង ។ ម្យ៉ាងវិញទៀត **ចក្ខុធាតុ** គប្បីជ្រាបដូចឫស្សីនៅខាងក្រោម, **រូបធាតុ** គប្បីជ្រាបដូចឫស្សីនៅខាងលើ, **ចក្ខុ-វិញ្ញាណធាតុ** គប្បីជ្រាបដូចភ្លើង ។ ក្នុង**សោតធាតុជាដើម** ក៏ន័យនេះដែរ ។

ចំណែក **មនោធាតុ** ពោលដោយការកើតឡើង គប្បីជ្រាបដូចការត្រាច់ទៅមុន (កើតមុន) និងត្រាច់ទៅតាម (កើតក្រោយ) នៃចក្ខុវិញ្ញាណធាតុជាដើម; **សម្តែងអំពីធម្មធាតុ វេទនាខន្ធ** គប្បីជ្រាបដូចត្រូវសរ និងព្រួញ, **សញ្ញា** និង**សង្ខារក្ខន្ធ** គប្បីជ្រាបដូចមនុស្សរសាប់រសល់ ព្រោះត្រូវសរ និងព្រួញ គឺវេទនាសិកសៀត ។ ម្យ៉ាងទៀត **សញ្ញា**របស់ពួកបុថុជ្ជន គប្បីជ្រាបដូចការក្តាប់ដៃទទេ ព្រោះកើតសេចក្តីប្រាថ្នាដែលជាទុក្ខ និងដូចសត្វព្រៃមិនកាន់និមិត្តតាមសេចក្តីពិត; **សង្ខារទាំងឡាយ** គប្បីជ្រាបដូចបុរសបោះរបស់ដាក់រណ្តៅបង្កាត់ភ្លើង ព្រោះការបញ្ជូនចិត្តទៅកាន់បដិសន្ធិ, ដូចពួកចោរត្រូវរាជបុរសតាមជាប់ ព្រោះការជាប់តាមជាតិទុក្ខ និងគប្បីជ្រាបដូចគ្រាប់ពូជដើមឈើមានពិស ព្រោះជាហេតុនៃការបន្ត នៃខន្ធដែលនាំមកនូវសេចក្តីវិនាសទាំងពួង ។ **រូប** គប្បីជ្រាបដូចខុរចក្ក (កាំបិតកោរ) ព្រោះជាគ្រឿងសម្គាល់របស់ឧបទ្រវៈនានាគ្រប់ប្រភេទ ។

តែគប្បីជ្រាប**អសង្ខតធាតុ** ដោយសេចក្តីជាអមតៈ ដោយសេចក្តីជាធម៌ស្ងប់ និងជាធម៌ក្សេម; ព្រោះហេតុអ្វី ? ព្រោះជាបដិបក្សចំពោះការវិនាសទាំងមូល ។ មនោវិញ្ញាណធាតុ គប្បីជ្រាបដូចស្វាក្នុងព្រៃធំ ព្រោះសូម្បីបណ្តោយតាមអារម្មណ៍ដែលខ្លួនចាប់ទុកហើយ ក៏ទាញអារម្មណ៍ដទៃឱ្យប្រព្រឹត្តទៅទៀត ហាក់ដូចជាសេះខ្ចក ព្រោះហ្វឹកហាត់បានដោយលំបាក ហាក់បីដូចជាកំណាត់ឈើដែលបោះទៅក្នុងអាកាស ព្រោះនឹងធ្លាក់ទៅក្នុងទីដែលវាពេញចិត្ត និងហាក់ដូចជាអ្នកប៉ិនរាំក្នុងរង្គសាល ព្រោះប្រកបដោយកិលេសមានប្រការផ្សេងៗ ដោយមានលោភៈ និងទោសៈជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសវារៈតទៅ ៖

ពាក្យថា **“ចក្ខុញ្ច បដិច្ច រូបេ ច** = អាស្រ័យចក្ខុបសាទ និងរូបារម្មណ៍” អធិប្បាយថា ព្រោះអាស្រ័យចក្ខុបសាទ និងរូបារម្មណ៍ទាំងពីរនេះផង ព្រោះអាស្រ័យធម៌ដទៃ គឺកិរិយាមនោធាតុ និងខន្ធ ៣ (វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ) ដែលសម្បយុត្តគ្នាផង; ព្រោះចក្ខុ (បសាទ) ជានិស្សយប្បច្ច័យ, រូបជាអារម្មណប្បច្ច័យ, កិរិយាមនោធាតុ (អាវជ្ជនចិត្ត) ជាវិគតប្បច្ច័យ, អរូបក្ខន្ធ ៣ (វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ) ជាសហជាតប្បច្ច័យរបស់ចក្ខុវិញ្ញាណធាតុ; ព្រោះហេតុនោះ ទើបចក្ខុវិញ្ញាណធាតុនេះ ឈ្មោះថា រមែងកើតឡើង ព្រោះអាស្រ័យបច្ច័យទាំង ៤ នេះ ។ សូម្បីក្នុងពាក្យថា **អាស្រ័យសោតបសាទជាដើម** ក៏មានន័យដូចគ្នានេះដែរ ។

បទថា **និរុទ្ធសមនន្តរា** កាត់បទជា **និរុទ្ធាយ សមនន្តរា** = ក្នុងលំដាប់នៃការរលត់របស់ចក្ខុវិញ្ញាណធាតុ ។

បទថា **“តជ្ជា មនោធាតុ** = មនោធាតុស្មើគ្នា” បានដល់ មនោធាតុ ២ យ៉ាង ដោយជាកុសលវិបាក និងអកុសលវិបាក ដែលកើតក្នុងអារម្មណ៍នោះ ធ្វើនាទីទទួលអារម្មណ៍ ។

ខថា **“សព្វធម្មេសុ វា បន បឋមសមន្នាហារោ** = ឬថាការពិចារណាអារម្មណ៍ដែលជាដំបូងក្នុងធម៌ទាំងពួង” សេចក្ដីថា កាលធម៌ទាំងពួងមានចក្ខុវិញ្ញាណជាដើមនេះ នឹងកើតឡើង (មនោធាតុនេះ) ក៏ពិចារណាអារម្មណ៍មុន, ម្យ៉ាងទៀត គប្បីជ្រាបសេចក្ដីក្នុងទីនេះយ៉ាងនេះថា មនោធាតុនេះ ពិចារណា

អារម្មណ៍ ដែលជាដំបូងក្នុងធម៌ទាំងពួង ពោលគឺរបស់ចក្ខុវិញ្ញាណធាតុជាដើម; គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់កាន់យកកិរិយាមនោធាតុ (អាវជ្ជនចិត្ត), ដែលធ្វើកិច្ចពិចារណាអារម្មណ៍តាមបញ្ចទ្វារ ដោយបទថា **សព្វធម្មេសុ វា បន បឋមសមន្នាហារោ** នេះ ។

បិអក្សរ ក្នុងខថា **មនោធាតុយាបិ ឧប្បជ្ជិត្វា និរុទ្ធសមនន្តរា** នេះ មានអត្ថថា ប្រមូលមក; ព្រោះហេតុនោះ ក្នុងទីនេះថា "**មនោធាតុយាបិ មនោវិញ្ញាណធាតុយាបិ** = កាលមនោធាតុក្តី កាលមនោវិញ្ញាណធាតុក្តី" គប្បីជ្រាបសេចក្តីថា កាលមនោធាតុដែលជាវិបាក (សម្បដិច្ឆន្នចិត្ត) កើតឡើងរលត់ទៅហើយ មនោវិញ្ញាណធាតុដែលជាវិបាក (សន្តីរណចិត្ត) ឯណា កើតឡើងធ្វើកិច្ចពិចារណាអារម្មណ៍ជាប់តគ្នាភ្លាម កាលមនោវិញ្ញាណធាតុ ដែលជាវិបាកនោះកើតឡើងហើយរលត់ទៅ មនោវិញ្ញាណធាតុ ដែលជាកិរិយា (វោដ្ឋវនចិត្ត) ឯណា ដែលកើតឡើងធ្វើកិច្ចកំណត់អារម្មណ៍បន្តពីនោះ, កាលមនោវិញ្ញាណធាតុ ដែលជាកិរិយានោះ កើតឡើង រលត់ទៅហើយ មនោវិញ្ញាណធាតុឯណា កើតឡើងធ្វើជវនកិច្ចក្នុងលំដាប់តគ្នា, មនោធាតុ និងមនោវិញ្ញាណធាតុសូម្បីទាំងអស់នោះ ក៏គប្បីជ្រាបថា ត្រាស់ទុក ដោយបទថា **មនោធាតុយាបិ** ដូច្នេះឯង ។

បទថា "**មនញ្ច បដិច្ច** = អាស្រ័យមនោ" បានដល់ ភវង្គចិត្ត ។ បទថា "**ធម្មេ ច** = ធម្មារម្មណ៍" បានដល់ ធម្មារម្មណ៍ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ពាក្យថា **កើតមនោវិញ្ញាណ** បានដល់ ជវនចិត្តកើតព្រមជាមួយការពិចារណា; ក៏ក្នុងឋានៈនេះ ព្រះមហាថេរទាំងឡាយកាន់យកបញ្ហា ដែលពួកលោកបានកាន់យកមក

ហើយ; បានឮថា ព្រះមហាធម្មរក្ខិតត្ថេរ បានចាប់ដៃព្រះទីឃភាណកអភយត្ថេរពោលថា "ក្នុងអាគតស្ថាន ឈ្មោះថា **បដិច្ច** (អាស្រ័យ) ដូច្នេះ មិនគួរធ្វើអាវជ្ជនៈឱ្យវៀក (ខុស) គ្នាទេ, គួរធ្វើអាវជ្ជនៈ ឱ្យអាស្រ័យភវង្គប៉ុណ្ណោះ" ព្រោះក្នុងពាក្យថា **មនោ** នេះ បានដល់ ភវង្គព្រមទាំងអាវជ្ជនៈ ។ ក្នុងពាក្យថា **មនោវិញ្ញាណ** នេះ ក៏បានដល់មនោវិញ្ញាណក្នុងជវ័នដូច្នេះឯង ។

ក៏ក្នុងអភិធម្មភាជនិយនេះ ត្រាស់ធាតុដែលជាកាមាវចរ ១៦ យ៉ាង, ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ លាយគ្នាទាំងលោកិយ និងលោកុត្តរ ២ យ៉ាង ដោយប្រការដូច្នេះ ៕

**ចប់ពណ៌នាអំពីអភិធម្មភាជនិយ**

## ពណ៌នាអំពីបញ្ហាបុច្ឆកៈ

ក៏ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបសេចក្ដីដែលធាតុទាំង ១៨ ជាកុសលជាដើម ដោយទំនងនៃន័យដែលពោលទុកក្នុងពេលក្រោយនោះឯង; ចំណែកក្នុងអារម្មណត្តិកៈទាំងឡាយ ពាក្យថា "**ឆ ធាតុយោ បរិត្តារម្មណា** = ធាតុ ៦ ជាបរិត្តារម្មណ៍" នេះ ព្រះមានព្រះភាគត្រាស់សំដៅយកសេចក្ដីប្រព្រឹត្តទៅ របស់វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម និងមនោធាតុ ក្នុងអារម្មណ៍ ៥ មានរូបារម្មណ៍ជាដើម ដោយចំណែកមួយ; តែគប្បីជ្រាបសេចក្ដីដែលធម្មធាតុ និងមនោវិញ្ញាណធាតុដែលត្រាស់ថា "**ទ្វេ ធាតុយា** = ធាតុ ២" ដូច្នេះ ជាបរិត្តារម្មណ៍ជាដើម ដោយន័យដែលពោលទុកក្នុងមនាយតនៈ និងធម្មាយតនៈនោះឯង ។ សូម្បីក្នុង

បញ្ហាបុច្ឆកៈនេះ ព្រះមានព្រះភាគក៏ត្រាស់ធាតុដែលជាកាមាវចរ ១៦, ប្រព្រឹត្តទៅក្នុងភូមិ ៤ លាយគ្នាទាំងលោកិយ និងលោកុត្តរ ២ យ៉ាង ដូចពណ៌នាមកដូច្នេះ; សូម្បីធាតុវិភង្គនេះ ព្រះមានព្រះភាគជាម្ចាស់ក៏ទ្រង់នាំចេញ ចែកសម្ដែងទុក ៣ បរិវដ្ដៈ (គឺដោយសុត្តន្តភាជនិយ អភិធម្មភាជនិយ និងបញ្ហាបុច្ឆកៈ) ដោយប្រការដូច្នេះឯង ៕

**ចប់ពណ៌នាអំពីបញ្ហាបុច្ឆកៈ**

**ចប់ធាតុវិភង្គនិទ្ទេសទី ៣ ត្រឹមតែប៉ុណ្ណេះ**

## ៤. សច្ចវិភង្គនិទ្ទេស

## ពណ៌នាសុត្តន្តភាជនិយពោលដោយឧទ្ទេសវារៈ

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុង **សច្ចវិភង្គ** ក្នុងលំដាប់នៃធាតុវិភង្គតទៅ ៖

បទថា “**ចត្តារិ** = ៤” ជាពាក្យកំណត់ចំនួន ។ បទថា “**អរិយសច្ចានិ** = អរិយសច្ច” ជាពាក្យសម្ដែងខែធម៌ដែលកំណត់ទុក ។ ក៏គប្បីជ្រាបវិនិច្ឆ័យ ក្នុងឧទ្ទេសវារៈមានពាក្យថា **ទុក្ខំ អរិយសច្ចំ** ជាដើមតទៅ ៖

**វិភាគតោ និព្វចន-　　　លក្ខណាទិប្បភេទតោ**
**អត្ថត្ថុទ្ធារតោ ចេវ　　　អនូនាធិកតោ តថា ។**
**កមតោ អរិយសច្ចេសុ　　　យំ ញាណំ តស្ស កិច្ចតោ**
**អន្តោគធានំ បភេទា　　　ឧបមាតោ ចតុក្កតោ ។**

**សុញ្ញតេកវិធាទីហិ សភាគវិសភាគតោ**
**វិនិច្ឆយោ វេទិតព្វោ វិញ្ញុនា សាសនក្កមេ ។**

បណ្ឌិតអ្នកដឹងច្បាស់ គប្បីជ្រាបវិនិច្ឆ័យក្នុងលំដាប់ពាក្យទូន្មាន ដោយការវិភាគ ១, ដោយការវិគ្រោះសព្ទ ១, ដោយប្រភេទមានលក្ខណៈជាដើម ១, ដោយអត្ថ ១, ដោយការរើអត្ថ ១, ដោយមិនខ្វះ មិនលើស ១, ដោយលំដាប់ ១, ដោយកិច្ចនៃញាណក្នុងអរិយសច្ច ១, ដោយប្រភេទនៃធម៌ដែលរាប់បញ្ចូលខាងក្នុង ១, ដោយឧបមា ១, ដោយចតុក្កៈ (ពួក ៤) ១, ដោយសុញ្ញតា ១, ដោយជាធម៌ដូចគ្នាតែម្យ៉ាងជាដើម ១, ដោយសភាគ និងវិសភាគ ១ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយការវិភាគ

បណ្តាឧទ្ទេសទាំងនោះ ពាក្យថា **ដោយការវិភាគ** បានដល់ អត្ថនៃអរិយសច្ច ៤ មានទុក្ខសច្ចជាដើម ព្រះអង្គទ្រង់ចែកសច្ចៈគ្រប់ ៤ ៗ ប្រការ ជារបស់ពិត ជារបស់មិនខុស មិនជាយ៉ាងដទៃ ដែលកុលបុត្រអ្នកកាលនឹងត្រាស់ដឹងនូវទុក្ខសច្ចជាដើម គប្បីត្រាស់ដឹងបាន; ដូចយ៉ាងដែលត្រាស់ទុកថា “**ទុក្ខ** មានអត្ថថា គាបសង្កត់ = **បីឡនដ្ឋោ**, មានអត្ថថា ដែលបច្ច័យតាក់តែង = **សង្ខតដ្ឋោ**, មានអត្ថថា ឱ្យក្តៅក្រហាយ = **សន្តាបដ្ឋោ**, មានអត្ថថា ប្រែប្រួល = **វិបរិណាមដ្ឋោ**, អត្ថ ៤ យ៉ាងនៃទុក្ខនេះ ជាអត្ថរបស់ទុក្ខសច្ច ជារបស់ពិត ជារបស់មិនខុស មិនជាយ៉ាងដទៃ;

សមុទ័យ មានអត្ថថា ប្រមូលមក = **អាយូហនដ្ឋោ**, មានអត្ថថា ជាហេតុប្រគល់ឱ្យនូវផល = **និទានដ្ឋោ**, មានអត្ថថា ប្រកបទុក = **សំយោគដ្ឋោ**, មានអត្ថថា ជាគ្រឿង កង្វល់ = **បលិពោធនដ្ឋោ** ។ល ។ និរោធ មានអត្ថថា រលាស់ចេញ = **និស្សរណដ្ឋោ**, មានអត្ថថា ស្ងាត់ = **វិវេកដ្ឋោ**, មានអត្ថថា ដែលបច្ច័យតាក់តែងមិនបាន = **អសង្ខតដ្ឋោ**, មានអត្ថថា ជាអមតៈ = **អមតដ្ឋោ** ។ល។ មគ្គ មានអត្ថថា ការនាំចេញ = **និយ្យានដ្ឋោ**, មានអត្ថថា ជាហេតុ = **ហេតុដ្ឋោ**, មានអត្ថថា ជាទស្សនៈ (យល់ឃើញ) = **ទស្សនដ្ឋោ**, មានអត្ថថា ជាអធិបតី = **អធិបតេយ្យដ្ឋោ**, អត្ថ ៤ យ៉ាងនៃមគ្គនេះ ជាអត្ថរបស់មគ្គសច្ច ជារបស់ពិត ជារបស់មិនខុស មិនមែនយ៉ាងដទៃ” ដូច្នេះ ។

ម្យ៉ាងទៀត ព្រះបាលីមានជាអាទិ៍យ៉ាងនេះថា “**ទុក្ខ** មានអត្ថថា បៀតបៀន, មានអត្ថថា ដែលបច្ច័យតាក់តែង, មានអត្ថថា ឱ្យក្តៅក្រហាយ, មានអត្ថថា ប្រែប្រួល ជាអត្ថដែលគួរត្រាស់ដឹង (អភិសមយដ្ឋោ)”[៦៣]; គប្បីជ្រាបសច្ចៈ មានទុក្ខសច្ចជាដើម ដោយអំណាចនៃអត្ថសច្ចៈគ្រប់ ៤ យ៉ាង តាមដែលទ្រង់ចែកទុកយ៉ាងនេះ ដោយប្រការដូច្នេះចុះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសច្ចៈនេះដោយការវិភាគប៉ុណ្ណេះសិន ៕

---

[៦៣] ខុ. បដិ.។

[៦៤] មនុស្សពាលគិតឃើញថា... ជារបស់ទៀង ស្រស់ល្អ ជាសុខ និងជាអត្តា ។

## សម្ដែងអំពីការវិនិច្ឆ័យដោយការវិគ្រោះសព្ទ

ក៏ក្នុងខថា **ដោយការវិគ្រោះសព្ទ និងប្រភេទមានលក្ខណៈជាដើមនេះ** គប្បីជ្រាប សច្ចៈដោយការវិគ្រោះសព្ទជាមុនថា៖

ក្នុងបទថា **ទុក្ខំ** នេះ សព្ទថា **ទុ** នេះរមែងសម្ដែងសេចក្ដីគួរខ្ពើម ។ ពិតណាស់ មនុស្សលោកហៅបុត្រដែលគួរខ្ពើមថា **ទុបុត្តោ** = បុត្រគួរខ្ពើម, ចំណែកសព្ទថា **ខំ** រមែងប្រាកដក្នុងសេចក្ដីទទេ; ព្រោះអាកាសដែលទទេ ហៅថា **ខំ**, ក៏**សច្ចៈទី ១ នេះ** ឈ្មោះថា **កុច្ឆិតំ** = គួរខ្ពើម, ព្រោះជាទីតាំងនៃឧបទ្រវៈមិនមែនតិច, ឈ្មោះថា **តុច្ឆំ** = ទទេ, ព្រោះវៀរចាកសេចក្ដីមាំមួន ភាពស្រស់ សេចក្ដីសុខ និងជាអត្តាដែលជនពាលគិតទុក[៦៤]; ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា **ទុក្ខំ**[៦៥] ព្រោះជារបស់គួរខ្ពើម និងជារបស់ទទេ ។

សព្ទថា **សំ** នេះ ក្នុងពាក្យថា **សមុទយំ** នេះ រមែងសម្ដែងការប្រកបព្រមក្នុងពាក្យជាដើមថា "**សមាគមោ សមេតំ** = ការប្រជុំគ្នា ការរួមគ្នា"[៦៦] សព្ទថា **ឧទ** នេះ រមែងសម្ដែងសេចក្ដីកើតឡើង ដូចក្នុងពាក្យជាដើមថា "**ឧប្បន្នំ ឧទិតំ** = តាំងឡើងហើយ" ។ តែសព្ទថា **អយ**[៦៧] រមែងសម្ដែងដល់ហេតុ[៦៨]; ក៏កាល

---

[៦៥] ពាក្យថា **ទុក្ខំ** នេះ ន័យមួយទៀត ញែកសព្ទថា **ទុ** = បទមុខ និង **ខមធាតុ** លុបទីបំផុតធាតុ (ត) សម្រេចរូបជា **ទុក្ខំ** = ធន់បានលំបាក ។

[៦៦] ទី. ម., អភិ. ។

[៦៧] វិនយ. ១, ខុ. ចូឡ.។

[៦៨] **សមុទយំ** ក្នុងទីនេះ ក៏គឺ សំ + អយ> **សមុទយំ**។

មានការប្រកបដោយបច្ច័យដែលនៅសល់ **សច្ចៈទី ២ នេះ** ក៏ជាហេតុ គឺការកើតឡើងនៃទុក្ខ; ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា **ទុក្ខសមុទយំ** ព្រោះសច្ចៈទី ២ នេះ ជាហេតុកើតទុក្ខ ។

ម្យ៉ាងទៀត សច្ចៈទី ៣ ព្រោះសព្ទថា **និ** រមែងសម្តែងសេចក្តីមិនមាន, និងសព្ទថា **រោធ** រមែងសម្តែងដល់អ្នកត្រាច់រង្គត់ [៦៩]; ព្រោះហេតុនោះ ក្នុងសច្ចៈទី ៣ (និរោធ) នេះ ទើបបានដល់សេចក្តីមិនមានការត្រាច់រង្គត់នៃទុក្ខ ពោលគឺការត្រាច់រង្គត់ទៅក្នុងសង្សារវដ្ត ព្រោះទទេចាកគតិទាំងពួង, ម្យ៉ាងទៀត កាលព្រះយោគាវចរពន្លុះសច្ចៈទី ៣ នោះហើយ សេចក្តីមិនមានការត្រាច់រង្គត់ទៅនៃទុក្ខ ពោលគឺការត្រាច់រង្គត់ទៅក្នុងសង្សារ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **ទុក្ខនិរោធំ** = ទុក្ខនិរោធ ព្រោះជាបដិបក្សចំពោះការត្រាច់រង្គត់នេះ; ម្យ៉ាងទៀត ហៅថា **ទុក្ខនិរោធ** ព្រោះជាបច្ច័យដល់សេចក្តីមិនកើត គឺសេចក្តីស្ងប់ស្ងិទ្ធនៃទុក្ខ ។

ម្យ៉ាងវិញទៀត សច្ចៈទី ៤ នេះ រមែងដំណើរទៅកាន់សេចក្តីរំលត់ទុក្ខ ព្រោះបែរមុខទៅរកព្រះនិព្វាននោះ ដោយអំណាចនៃអារម្មណ៍, និងជាបដិបទាដើម្បីដល់សេចក្តីរំលត់ទុក្ខ, ព្រោះហេតុនោះ ទើបត្រាស់ថា **ទុក្ខនិរោធគាមិនីបដិបទា** ។

---

[៦៩] សព្ទនិរោធ <**និ** = មិនមាន + **រោធ** = ពន្ធនាគារ, សង្សារ> **និរោធ** = មិនមានពន្ធនាគារ មិនមានសង្សារ ។

ក៏ព្រោះព្រះអរិយៈមានព្រះពុទ្ធជាដើម រមែងចាក់ធ្លុះសច្ចៈនេះ ដូច្នេះ សច្ចៈទាំងនេះ ទើបត្រាស់ហៅថា **អរិយសច្ច**; ដូចយ៉ាងព្រះតម្រាស់ ដែលត្រាស់ទុកថា **“ចត្តារិមានិ ភិក្ខវេ អរិយសច្ចានិ; កតមានិ ។ បេ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អរិយសច្ចានិ; អរិយា ឥមានិ បដិវិជ្ឈន្តិ តស្មា អរិយសច្ចានីតិ វុច្ចន្តិ** = ម្នាលភិក្ខុទាំងឡាយ អរិយសច្ចនេះមាន ៤ ប្រការ, ៤ ប្រការ តើអ្វីខ្លះ ? **គឺទុក្ខអរិយសច្ច... ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច** ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ ប្រការនេះឯង; ព្រះអរិយៈទាំងឡាយ រមែងចាក់ធ្លុះនូវអរិយសច្ចទាំងនេះ; ព្រោះហេតុនោះ ទើបតថាគតហៅថា **អរិយសច្ច”** [៧០] ។

ម្យ៉ាងទៀត ក៏ឈ្មោះថា **អរិយសច្ច** ព្រោះអត្ថថា ជាសច្ចៈរបស់ព្រះអរិយៈដូច្នេះខ្លះ; ដូចយ៉ាងដែលត្រាស់ទុកថា **“សទេវកេ ភិក្ខវេ លោកេ ។ បេ ។ សទេវមនុស្សាយ តថាគតោ អរិយោ; តស្មា អរិយសច្ចានីតិ វុច្ចន្តិ** = ម្នាលភិក្ខុទាំងឡាយ តថាគតជាអរិយៈក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្ស; ព្រោះហេតុនោះ ទើបហៅថា **សច្ចៈរបស់ព្រះអរិយៈ”** [៧១] ។

ម្យ៉ាងទៀត ឈ្មោះថា **អរិយសច្ច** ព្រោះសេចក្តីដែលអរិយសច្ចទាំងនោះ ព្រះអរិយៈត្រាស់ដឹងហើយខ្លះ ព្រោះសេចក្តីដែលសម្រេចភាពជាអរិយៈខ្លះ; ដូចយ៉ាងដែលត្រាស់ថា **“ឥមេសំ ខោ ភិក្ខវេ ចតុន្នំ អរិយសច្ចានំ យថាភូតំ អភិសម្ពុទ្ធត្តា តថាគតោ អរហំ សម្មាសម្ពុទ្ធោ អរិយោតិ វុច្ចតិ** = ម្នាលភិក្ខុទាំង

---

[៧០-៧១] សំ. ម. ។

ឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធ លោកហៅថា **អរិយៈ** ព្រោះត្រាស់ដឹងអរិយ-សច្ចទាំង ៤ នេះឯង តាមសេចក្ដីពិត”[៧២] ។

ម្យ៉ាងវិញទៀត ឈ្មោះថា **អរិយសច្ច** ព្រោះអត្ថថា ជាសច្ចៈដែលប្រសើរ; ពាក្យថា **អរិយៈ** នេះ មានអធិប្បាយថា ជារបស់ពិត, ជារបស់មិនខុស, ជារបស់មិនឃ្លៀងឃ្លាត; ដូចយ៉ាងដែលត្រាស់ទុកថា **“ឥមានិ ខោ ភិក្ខវេ ចត្តារិ អរិយសច្ចានិ តថានិ អវិតថានិ អនញ្ញថានិ តស្មា អរិយសច្ចានីតិ វុច្ចន្តិ** = ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នោះឯង ជារបស់ពិត, មិនប្រែប្រួល, មិនជាយ៉ាងដទៃ; ព្រោះហេតុដូច្នោះ ទើបហៅថា **អរិយសច្ច** (សច្ចៈដែលប្រសើរ)”[៧៣] ។ គប្បីជ្រាបវិនិច្ឆ័យក្នុងសច្ចៈនេះ ដោយវិគ្រោះត្រឹមតែប៉ុណ្ណោះ ៕

## សម្ដែងអំពីការវិនិច្ឆ័យដោយប្រភេទមានលក្ខណៈជាដើម

គប្បីជ្រាបការវិនិច្ឆ័យ **ដោយប្រភេទមានលក្ខណៈជាដើម** យ៉ាងណា ? ពិតមែនក្នុងសច្ចៈទាំង ៤ នេះ ៖

### ទុក្ខសច្ច

**-ពាធនលក្ខណំ** មានការបៀតបៀនជាលក្ខណៈ

**-សន្តាបនរសំ** មានការធ្វើឱ្យក្ដៅជារស

**-បវត្តិបច្ចុបដ្ឋានំ** មានបវត្តិជាបច្ចុប្បដ្ឋាន ។

---

៧២-៧៣ សំ. ម. ។

## សមុទយសច្ច

**-បភវលក្ខណំ** មានហេតុជាដែនកើតជាលក្ខណៈ

**-អនុបច្ឆេទករណរសំ** មានការមិនចូលទៅកាត់ផ្ដាច់ជារស

**-បលិពោធបច្ចុប្បដ្ឋានំ** មានបលិពោធជាបច្ចុប្បដ្ឋាន ។

## និរោធសច្ច

**-សន្តិលក្ខណំ** មានសេចក្ដីស្ងប់ជាលក្ខណៈ

**-អច្ចុតិរសំ** មានការមិនច្យុតិជារស

**-អនិមិត្តបច្ចុប្បដ្ឋានំ** មានការមិនមាននិមិត្ត ជាបច្ចុប្បដ្ឋាន ។

## មគ្គសច្ច

**-និយ្យានលក្ខណំ** មានការនាំចេញជាលក្ខណៈ

**-កិលេសប្បហានករណរសំ** មានការប្រហារកិលេសជារស

**-វុដ្ឋានបច្ចុប្បដ្ឋានំ** មានវុដ្ឋាន (គឺការចេញ) ជាបច្ចុប្បដ្ឋាន ។

ម្យ៉ាងទៀត សច្ចៈ ៤ នេះ មានបវត្តិ = ការប្រព្រឹត្តទៅ, មានបវត្តនៈ = ហេតុឱ្យប្រព្រឹត្តទៅ, មាននិវត្តិ = ការត្រឡប់, មាននិវត្តនៈ = ហេតុឱ្យត្រឡប់ជាលក្ខណៈ ដោយលំដាប់ [៧៤] និងមានសង្ខតៈ (គឺធម្មជាតិដែលបច្ច័យតាក់តែង) មានតណ្ហា, មានអសង្ខតៈ (គឺធម្មជាតិដែលបច្ច័យមិនតាក់តែង) មានទស្សនៈ (ការ

---

[៧៤] ពាក្យថា **បវត្តិ** សំដៅដល់ ទុក្ខសច្ចៈ, ពាក្យថា **បវត្តនៈ** សំដៅដល់ សមុទ័យ, ពាក្យថា **និវត្តិ** (ត) សំដៅដល់ និរោធ, ពាក្យថា **និវត្តៈ** សំដៅដល់ មគ្គ ។

ឃើញ) ជាលក្ខណៈតាមលំដាប់ដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យ ដោយប្រភេទ មានលក្ខណៈជាដើម ក្នុងទីនេះ ដោយប្រការដូច្នេះ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយអត្ថ

ក៏ក្នុងខថា **ដោយអត្ថ និងដោយការបើអត្ថ** នេះ គប្បីជ្រាប **ដោយអត្ថជាមុនសិន** ប្រសិនបើមានពាក្យសួរថា អ្វីជាអត្ថរបស់សច្ចៈ ?; ក៏នឹងគប្បីមានពាក្យឆ្លើយយ៉ាងពិស្តារថា ភាវៈណាដែលបុគ្គលពិចារណាដោយបញ្ញាចក្ខុ រមែងមិនវិបរិតដូចកលមាយា, មិនកន្លងភ្នែក, ដូចថ្ងៃបណ្តើរកូន មិនជាសភាវៈដែលនរណា។ រកមិនបានដូចអត្តារបស់ពួកតិរ្ថិយ៍; តាមដែលពិតជាគោចរ (អារម្មណ៍) របស់អរិយញ្ញាណដោយប្រការមានការបៀតបៀន (ទុក្ខសច្ច), មានហេតុជាដែនកើត (សមុទយសច្ច), មានសេចក្តីស្ងប់ (និរោធសច្ច), មានការនាំចេញ (មគ្គសច្ច); ជារបស់ពិតមិនវិបរិត ជារបស់ពិតប្រាកដ, ភាវៈនៃសច្ចៈជារបស់ពិត មិនវិបរិត ជារបស់ពិតដូចជាលក្ខណៈភ្លើង និងដូចជាធម្មតារបស់សត្វលោក (ត្រូវកើត ចាស់ ឈឺ ស្លាប់) នោះ បណ្ឌិតគប្បីជ្រាបថា **ជាអត្ថរបស់សច្ចៈ**; ដូចយ៉ាងដែលត្រាស់ទុកថា **“ឥទំ ទុក្ខន្តិ, ខោ ភិក្ខវេ តថមេតំ អវិតថមេតំ អនញ្ញថមេតំ** = ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះទុក្ខដូច្នេះឯង នោះជារបស់ពិត នោះជារបស់មិនខុស នោះមិនប្រព្រឹត្តទៅដោយប្រការដទៃជាដើម”[៧៥] ។

---

[៧៥] សំ. ម. ។

ម្យ៉ាងទៀត ៖

**នាពាធកំ យតោ ទុក្ខំ ទុក្ខា អញ្ញំ ន ពាធកំ**
**ពាធកត្តនិយាមេន តតោ សច្ចមិទំ មតំ ។**

ក្រៅពីទុក្ខហើយ ខ្លួនបៀតបៀន រមែងមិនមាន ខ្លួនបៀតបៀនដទៃក្រៅពីទុក្ខ ក៏មិនមាន ព្រោះហេតុនោះ ទុក្ខនេះ ទើបបណ្ឌិតដឹងថាជាសច្ចៈ ដោយកំណត់អត្ថថា ជាតួបៀតបៀន ។

**តំ វិនា នាញ្ញតោ ទុក្ខំ ន ហោតិ ន ច តំ តតោ**
**ទុក្ខហេតុនិយាមេន ឥតិ សច្ចំ វិសត្តិកា ។**

វៀរចាកតណ្ហានោះហើយ ទុក្ខរមែងមិនមាន ពីហេតុដទៃ ឯទុក្ខនោះ រមែងមិនមានពីតណ្ហានោះ ក៏មិនមែនទេ ព្រោះហេតុនោះ តណ្ហាផ្សាយទៅក្នុងអារម្មណ៍នោះៗ ទើបបណ្ឌិតដឹងថាជាសច្ចៈ ដោយកំណត់អត្ថថា ជាហេតុនៃទុក្ខ ។

**នាញ្ញា និព្វានតោ សន្តិ សន្តំ ន ច ន តំ យតោ**
**សន្តភាវនិយាមេន តតោ សច្ចមិទំ មតំ ។**

សេចក្ដីស្ងប់ដទៃក្រៅពីព្រះនិព្វាន រមែងមិនមាន, ឯព្រះនិព្វាននោះ វៀរចាកសេចក្ដីស្ងប់ក៏មិនមានដែរ ព្រោះហេតុនោះ ព្រះនិព្វាននេះ ទើបបណ្ឌិតដឹងថា ជាសច្ចៈ ដោយកំណត់អត្ថថា ជាសេចក្ដីស្ងប់ ។

**មគ្គា អញ្ញំ ន និយ្យានំ អនិយ្យានោ ន ចាបិ សោ**
**តច្ឆនិយ្យានភាវត្តា ឥតិ សោ សច្ចសម្មតោ ។**

ក្រៅពីមគ្គហើយ គ្រឿងនាំចេញយ៉ាងដទៃ រមែងមិនមាន សូម្បីមគ្គនោះ មិនមែនជាគ្រឿងនាំចេញក៏មិនមែនដែរ ព្រោះហេតុនោះ មគ្គនោះ បណ្ឌិតគប្បីជ្រាបថា ជាសច្ចៈ ព្រោះអត្ថថា ជាគ្រឿងនាំចេញយ៉ាងពិតៗ ។

**ឥតិ តច្ឆាវិបល្លាស- ភូតភាវំ ចតូសុបិ**
**ទុក្ខាទីសុ វិសេសេន សច្ចត្ថំ អាហុ បណ្ឌិតា ។**

បណ្ឌិតទាំងឡាយពោលភាវៈដែលពិត មិនប្រែប្រួល ជារបស់ពិតក្នុងសច្ចៈទាំង ៤ មានទុក្ខសច្ចជាដើម ដោយមិនប្លែកគ្នាថា ជាអត្ថនៃសច្ចៈ ដោយប្រការដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យសច្ចៈ ដោយអត្ថដូចពណ៌នាមកដូច្នេះឯង ៕

## សម្តែងអំពីការវិនិច្ឆ័យដោយការបើអត្ថ

គប្បីជ្រាបវិនិច្ឆ័យ **ដោយការបើអត្ថ** យ៉ាងណា ? **សច្ចសព្ទ** ក្នុងអធិការនេះ រមែងមិនប្រាកដក្នុងអត្ថមិនមែនតិច; យ៉ាងណា ៖ **សច្ចសព្ទ** រមែងប្រាកដក្នុង**វាចាសច្ច** ដូចក្នុងប្រយោគមានជាអាទិ៍ថា **“សច្ចំ ភណេ ន កុជ្ឈេយ្យ** = បុគ្គលគប្បីពោលពាក្យសត្យៈ មិនគប្បីក្រោធ” [៧៦] ។ ដែលប្រាកដក្នុង**វិរតិសច្ច** ( មុសាវាទ-

[៧៦] ខុ. ធ. ។

វិរតិ) ដូចក្នុងប្រយោគមានជាអាទិ៍ថា **“សច្ចេ ឋិតា សមណព្រាហ្មណា** = សមណព្រាហ្មណ៍អ្នកតាំងនៅក្នុងសច្ចៈ”[៧៧] ។ ដែលប្រាកដក្នុង **ទិដ្ឋិសច្ច** (ពិតក្នុងទិដ្ឋិ) ដូចក្នុងប្រយោគមានជាអាទិ៍ថា **“កស្មា នុ សច្ចានិ វទន្តិ នានា, បវាទិយាសេ កុសលា វទានា** = ព្រោះហេតុអ្វីហ្ន៎ ទើបពួកសមណព្រាហ្មណ៍ពោលសច្ចៈទៅផ្សេង, គឺអាងខ្លួនថា ជាអ្នកឆ្លាតពោលប្រកាន់សច្ចៈច្រើនយ៉ាង”[៧៨] ។ ដែលប្រាកដក្នុង**បរមត្ថសច្ច** គឺនិព្វាន និងមគ្គ ដូចក្នុងប្រយោគមានជាអាទិ៍ថា **“ឯកំ ហិ សច្ចំ ន ទុតិយមត្ថិ** = សច្ចៈមានតែម្យ៉ាង មិនមានពីរយ៉ាងឡើយ”[៧៩] ។ ដែលប្រាកដក្នុង **អរិយសច្ច** ដូចក្នុងប្រយោគមានជាអាទិ៍ថា **“ចតុន្នំ សច្ចានំ កតិ កុសលា** = បណ្តាសច្ចៈ ៤ សច្ចៈដែលជាកុសលមានប៉ុន្មាន ?”[៨០] ; សូម្បីក្នុងទីនេះ សព្ទថា សច្ចៈនេះឯង រមែងប្រព្រឹត្តទៅក្នុងអរិយសច្ច (សច្ចៈដែលប្រសើរ) ។

គប្បីជ្រាបវិនិច្ឆ័យដោយការរើអត្ថក្នុងសច្ចៈនេះដូច្នេះ ៕

## សម្តែងអំពីការវិនិច្ឆ័យ ដោយមិនខ្វះ មិនលើស

ក្នុងខថា **មិនខ្វះ មិនលើស** នេះ បើមានពាក្យសួរថា ក៏ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគជាម្ចាស់ ត្រាស់អរិយសច្ចទុក ៤ ប៉ុណ្ណោះ គឺមិនខ្វះ មិនលើស ? ឆ្លើយថា ព្រោះមិនមានសច្ចៈយ៉ាងដទៃ នឹងនាំចេញពីខណាមួយ ក៏មិនបាន; ពិត

---

[៧៧] ខុ. ជា. ។

[៧៨-៧៩] ខុ. សុ. ។

[៨០] អភិ. ។

ណាស់ សច្ចៈដទៃទៀតក្រៃលែងជាងសច្ចៈទាំង ៤ នេះ ឬថា បណ្តាសច្ចៈទាំង ៤ នេះ នឹងគប្បីនាំចេញទៅត្រឹមតែមួយខ ក៏មិនបានដែរ ។ ដូចយ៉ាងដែលត្រាស់ទុកមានជាអាទិ៍ថា "ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ ក្នុងលោកនេះ គប្បីអាងថា 'ទុក្ខដែលព្រះសមណគោតមសម្តែងទុកនេះ មិនមែនជាអរិយសច្ច, ទុក្ខដទៃជាអរិយសច្ច; យើងនឹងវៀរទុក្ខអរិយសច្ចនេះ ហើយបញ្ញត្តិទុក្ខអរិយសច្ចដទៃ', ខនេះ មិនមែនជាឋានៈដែលមានបានឡើយ" ; ក៏ដូចដែលត្រាស់ទុកមានជាអាទិ៍យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ ក៏សមណៈ ឬព្រាហ្មណ៍ណាមួយ នឹងគប្បីពោលយ៉ាងនេះថា 'នោះមិនមែនទុក្ខអរិយសច្ច, ខទីមួយដែលព្រះសមណគោតមទ្រង់សម្តែងទុក យើងនឹងលះទុក្ខអរិយសច្ចខទីមួយនោះចេញ ហើយបញ្ញត្តិទុក្ខអរិយ-សច្ចខទីមួយយ៉ាងដទៃថ្មី', ខនេះមិនមែនជាឋានៈដែលនឹងមានបានឡើយ"[៨១] ។

ម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់កាលនឹងត្រាស់ប្រាប់សេចក្តីប្រព្រឹត្តទៅនៃទុក្ខ ក៏ត្រាស់ប្រាប់ព្រមទាំងហេតុ និងត្រាស់ប្រាប់ការមិនប្រព្រឹត្តទៅ, ក៏ត្រាស់ប្រាប់ព្រមទាំងឧបាយ (ជាគ្រឿងរំដោះចេញ); ព្រោះហេតុនោះ ទើបត្រាស់អរិយសច្ចទុក ៤ ប៉ុណ្ណោះ ព្រោះសេចក្តីដែលសច្ចៈទាំងនោះមានការប្រព្រឹត្តទៅ = **បវត្តិ**, សេចក្តីមិនប្រព្រឹត្តទៅ = **ន បវត្តិ** និងហេតុនៃការប្រព្រឹត្តទៅ ការមិនប្រព្រឹត្តទៅទាំង ២ ដែលមានសច្ចៈ ៤ នោះយ៉ាងក្រៃលែង ។

ម្យ៉ាងទៀត ព្រះអង្គត្រាស់អរិយសច្ច ៤ ប៉ុណ្ណោះ សូម្បីដោយអំណាចនៃ **បរិញ្ញេយ្យធម៌** = ធម៌ដែលគួរត្រាស់ដឹង, **បហាតព្វធម៌** = ធម៌ដែលគួរលះ, **សច្ឆិ-**

---

៨១ សំ. ម. ។

**កាតព្វធម៌** = ធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់, **ភាវេតព្វធម៌** = ធម៌ដែលគួរចម្រើន និង ត្រាស់ទុក ៤ ទៀត ដោយអំណាចនៃតណ្ហា វត្ថុដែលជាទីអាស្រ័យកើតរបស់តណ្ហា ការរលត់តណ្ហា និងឧបាយជាគ្រឿងរលត់តណ្ហា; ក៏ត្រាស់ទុកសូម្បីទាំង ៤ ដោយអំណាចនៃសេចក្តីអាល័យ ហេតុដែលត្រេកអរក្នុងការអាល័យ ការដកឡើងនូវអាល័យ និងឧបាយជាហេតុដកឡើងនូវអាល័យ ។

គប្បីជ្រាបវិនិច្ឆ័យ ដោយមិនខ្វះ មិនលើស ក្នុងអធិការនេះ មានប្រការដូច្នេះហោង ៕

## សម្តែងអំពីការវិនិច្ឆ័យដោយលំដាប់

ខថា សូម្បី**ដោយលំដាប់** នេះ បានដល់ លំដាប់នៃទេសនានោះឯង; ក៏ក្នុងអរិយសច្ចទាំង ៤ នេះ ទុក្ខសច្ចជាសច្ចៈដែលដឹងបានងាយ ព្រោះជារបស់គ្រោតគ្រាត និងព្រោះជារបស់ទូទៅដល់សត្វទាំងអស់ ដូច្នេះទើបត្រាស់ទុកមុន, សមុទយ-សច្ច ត្រាស់ទុកក្នុងលំដាប់នៃទុក្ខសច្ចនេះ ដើម្បីសម្តែងហេតុរបស់ទុក្ខសច្ចនោះឯង, និរោធសច្ច ត្រាស់ទុកដោយលំដាប់សមុទយសច្ចនោះ ដើម្បីសម្តែងឱ្យ ដឹងថា ព្រោះហេតុរលត់ ផលទើបរលត់, មគ្គសច្ច ត្រាស់ទុកក្នុងទីបំផុត ដើម្បីសម្តែងឧបាយ ជាគ្រឿងពន្លុះនិរោធសច្ចនោះ ។

ម្យ៉ាងវិញទៀត ព្រះមានព្រះភាគត្រាស់នូវទុក្ខមុន ដើម្បីឱ្យកើតសេចក្តីសង្វេគដល់ពួកសត្វអ្នកត្រេកអរ និងប្រាថ្នាសេចក្តីសុខក្នុងភព, ត្រាស់សមុទយៈក្នុងលំដាប់នៃទុក្ខនោះ ដើម្បីឱ្យដឹងថា ទុក្ខនោះតណ្ហាមិនបានសាងហើយ រមែងមិនមាន

ឡើយ, វារមែងមានព្រោះហេតុខាងក្រៅមានព្រះឥស្សរបណ្ដាលជាដើម ក៏មិនមែនដែរ, ដែលពិតវារមែងមានព្រោះតណ្ហានេះ, បន្ទាប់ពីនោះ ក៏ត្រាស់និរោធ ដើម្បីឱ្យកើតសេចក្ដីបញ្ចូនចិត្ត ដោយការឃើញឧបាយជាគ្រឿងបន្សាត់ចេញ ដល់សត្វអ្នកមានចិត្តតក់ស្លុត ដែលស្វែងរកឧបាយជាគ្រឿងចេញចាកទុក្ខ ព្រោះភាពជាអ្នកត្រូវទុក្ខព្រមទាំងហេតុ (តណ្ហា) គ្របសង្កត់ហើយ, តពីនោះ ក៏ត្រាស់មគ្គដែលជាធម៌ឱ្យដល់និរោធ ដើម្បីពន្លឺនិរោធ ។

គប្បីជ្រាបវិនិច្ឆ័យសូម្បីដោយលំដាប់ក្នុងសច្ចៈនោះ ដោយប្រការដូច្នេះ ៕

## សម្ដែងអំពីការវិនិច្ឆ័យ
## ដោយកិច្ចនៃញាណក្នុងអរិយសច្ច

ខថា **ដោយកិច្ចនៃញាណក្នុងអរិយសច្ច** នេះ អធិប្បាយថា គប្បីជ្រាបវិនិច្ឆ័យសូម្បីដោយកិច្ចនៃញាណក្នុងអរិយសច្ច, ពិតណាស់ សច្ចញ្ញាណមាន ២ យ៉ាង គឺ ៖

- **អនុពោធិញ្ញាណ** ញាណត្រាស់ដឹងដោយលំដាប់
- **បដិវេធញ្ញាណ** ញាណដែលចាក់ធ្លុះ ។

បណ្ដាញាណទាំងពីរនោះ **អនុពោធិញ្ញាណ** ជាលោកីយ៍រមែងដំណើរទៅក្នុងនិរោធ និងមគ្គ ដោយអំណាចនៃការរំដោះផុតជាដើម, **បដិវេធញ្ញាណ** ជាលោកុត្តរធ្វើនិរោធឱ្យជាអារម្មណ៍ហើយ ចាក់ធ្លុះសូម្បីសច្ចៈទាំង ៤ ដោយកិច្ច; ដូចយ៉ាងដែលត្រាស់ទុកថា “**យោ ភោចិ ភិក្ខវេ ទុក្ខំ បស្សតិ, ទុក្ខសមុទយម្បិ សោ បស្សតិ, ទុក្ខនិរោធម្បិ បស្សតិ, ទុក្ខនិរោធគាមិនីបដិបទម្បិ បស្សតិ** = ម្នាលភិក្ខុ

ទាំងឡាយ អ្នកណាមួយឃើញទុក្ខ, អ្នកនោះរមែងឃើញសូម្បីទុក្ខសមុទយៈ, រមែងឃើញសូម្បីទុក្ខនិរោធ, រមែងឃើញសូម្បីទុក្ខនិរោធគាមិនីបដិបទា”[៨២] ។ គប្បីពោលពុទ្ធវចនៈ (ក្នុងសូត្រនេះ) សូម្បីទាំងអស់ ។

ម្យ៉ាងទៀត ញាណដែលជាលោកិយក្នុងសច្ចញ្ញាណទាំង ៤ នេះ **ទុក្ខញ្ញាណ** (ញាណក្នុងទុក្ខ) រមែងហាមឃាត់សក្កាយទិដ្ឋិដែលកំពុងប្រព្រឹត្តទៅដោយអំណាចនៃសេចក្តីគ្របសង្កត់ ដោយបរិយុដ្ឋានកិលេស ។ **សមុទយញ្ញាណ** (ញាណក្នុងសមុទយៈ) រមែងហាមឧច្ឆេទទិដ្ឋិ, **និរោធញ្ញាណ** (ញាណក្នុងនិរោធ) រមែងហាមសស្សតទិដ្ឋិ, **មគ្គញ្ញាណ** (ញាណក្នុងមគ្គ) រមែងហាមអកិរិយទិដ្ឋិ ។

ម្យ៉ាងវិញទៀត **ទុក្ខញ្ញាណ** រមែងហាមសេចក្តីបដិបត្តិខុសក្នុងផល ពោលគឺសេចក្តីសម្គាល់ក្នុងបញ្ចក្ខន្ធដែលប្រាសចាកភាពមាំមួន ភាពស្រស់បស់ ភាពសុខ និងអត្តាថា មានភាពមាំមួន មានសេចក្តីសុខ និងមានអត្តា, **សមុទយញ្ញាណ** រមែងហាមសេចក្តីបដិបត្តិខុសក្នុងហេតុ ដែលប្រព្រឹត្តទៅក្នុងការប្រកាន់យ៉ាងក្រៃលែង គឺវត្ថុដែលមិនមែនហេតុថា ជាហេតុ ដោយយល់ថា លោករមែងប្រព្រឹត្តទៅដោយព្រះឥស្សរអ្នកជាប្រធាន ដោយព្រះកាឡៈ និងដោយភាវៈរបស់ខ្លួនឯងជាដើម, **និរោធ-ញ្ញាណ** រមែងហាមសេចក្តីបដិបត្តិខុសក្នុងនិរោធ ដែលប្រកាន់យកក្នុងអរូបលោក និងក្នុងភូមិដែលជាកំពូលនៃលោកជាដើមថាជានិព្វាន[៨៣] , មគ្គញ្ញាណរមែងលះ

---

[៨២] សំ. ម. ។

[៨៣] ពួកឧទកតាបស និងអាឡារតាបស ប្រកាន់អរូបលោកថា ជានិព្វាន ពួកនិគ្រន្ថប្រកាន់ភូមិដែលជាកំពូលនៃលោក (**លោកថូបិកា**) ថា ជានិព្វាន (ចាកមហាដីកា) ។

សេចក្តីបដិបត្តិខុសក្នុងឧបាយដែលប្រព្រឹត្តទៅ ដោយសេចក្តីប្រកាន់ក្នុងវត្ថុដែលមិនបរិសុទ្ធ ដែលផ្សេងដោយកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគថា ជាមគ្គដែលបរិសុទ្ធ; ព្រោះហេតុនោះ បណ្ឌិតទើបប្រព័ន្ធពាក្យគាថានេះទុកថា ៖

**“លោកេ លោកប្បភវេ លោក~ ត្ថគមេ សិវេ ច តទុបាយេ**
**សម្មុយ្ហតិ តាវ នរោ ន វិជានាតិ យាវ សច្ចានិ ។**

នរជន នៅមិនដឹងច្បាស់សច្ចៈទាំងឡាយ ដរាបណា គេក៏រមែងលិចចុះក្នុងលោក (ទុក្ខ) ក្នុងហេតុកើតរបស់លោក (សមុទយៈ) ក្នុងព្រះនិព្វាន ដែលជាទីរលត់ទៅនៃលោក និងក្នុងឧបាយនៃការរលត់លោក (មគ្គ) នេះ ដរាបនោះ” ។

គប្បីជ្រាបវិនិច្ឆ័យ សូម្បីដោយកិច្ចនៃញាណ ក្នុងអរិយសច្ចនេះ ដោយប្រការដូច្នេះ ៕

## សំដែងអំពីការវិនិច្ឆ័យ
## ដោយប្រភេទនៃធម៌ដែលរាប់បញ្ចូលខាងក្នុង

ខថា **ដោយប្រភេទនៃធម៌ដែលរាប់បញ្ចូលខាងក្នុង** សេចក្តីថា ពិតណាស់ វៀរតណ្ហា និងអនាសវធម៌ (ធម៌ដែលមិនមានអាសវៈ) ហើយ ធម៌ទាំងអស់ដ៏សេសរាប់បញ្ចូលខាងក្នុងទុក្ខសច្ច, តណ្ហាវិចរិត ៣៦ រាប់បញ្ចូលខាងក្នុងសមុទយសច្ច ។ និរោធសច្ចមិនមានអ្វីលាយឡំ, ធម៌មានឥទ្ធិបាទ បញ្ចិន្ទ្រិយ៍ បញ្ចពលៈ និងធម្មវិចយសម្ពោជ្ឈង្គៈ ដោយមានសម្មាទិដ្ឋិ ជាប្រមុខ ជាធម៌រាប់បញ្ចូលក្នុងមគ្គសច្ច ។

វិតក្កៈ ៣ មាននេក្ខម្មវិតក្កៈជាដើម ដោយអាស្រ័យសម្មាសង្កប្បៈជាធម៌រាប់បញ្ចូលខាងក្នុង, វចីសុចរិត ៤ ដោយអាស្រ័យសម្មាវាចា ជាធម៌រាប់បញ្ចូលខាងក្នុង, កាយ-សុចរិត ៣ ដោយអាស្រ័យសម្មាកម្មន្តៈ ជាធម៌រាប់បញ្ចូលខាងក្នុងសេចក្តីប្រាថ្នាតិច និងសេចក្តីសន្តោសដោយមានសម្មាអាជីវៈ ជាប្រមុខ ជាធម៌រាប់បញ្ចូលខាងក្នុង ជាមគ្គសច្ច ។ ម្យ៉ាងទៀត ព្រោះសម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈទាំងអស់នេះ ជាអរិយកន្តសីល [៨៤] ព្រោះសីលដែលបុគ្គលគប្បីទទួលដោយដៃ គឺសទ្ធា និងព្រោះសេចក្តីដែលសីលនឹងនៅមាន ក៏ព្រោះសេចក្តីដែលសម្មាវាចាជាដើមទាំងនោះមានសទ្ធិន្ទ្រីយ៍ សទ្ធាពលៈ និងឆន្ទិទ្ធិបាទ ទើបជាធម៌រាប់បញ្ចូលខាងក្នុង, សម្ម-ប្បធាន ៤ វីរិយិទ្ធិបាទ វីរិយិន្ទ្រិយ វីរិយពលៈ និងវីរិយសម្ពោជ្ឈង្គ ដោយអាស្រ័យសម្មាវាយាមៈ ជាធម៌រាប់បញ្ចូលខាងក្នុង សតិប្បដ្ឋាន ៤ សតិន្ទ្រិយ សតិពលៈ និងសតិសម្ពោជ្ឈង្គ ដោយអាស្រ័យសម្មាសតិ ជាធម៌រាប់បញ្ចូលខាងក្នុង, សមាធិ ៣ យ៉ាង គឺសមាធិ មានវិតក្កៈ និងវិចារៈជាដើម ចិត្តសមាធិ សមាធិន្ទ្រីយ៍ សមាធិពលៈ បីតិសម្ពោជ្ឈង្គ បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ ជាធម៌រាប់បញ្ចូលខាងក្នុង គឺរាប់បញ្ចូលក្នុងមគ្គសច្ច ៕

## សម្តែងអំពីការវិនិច្ឆ័យដោយឧបមា

ក៏ក្នុងខថា **ដោយឧបមា** នេះ គប្បីជ្រាបទុក្ខសច្ចដូចរបស់ធ្ងន់, សមុទយសច្ចដូចការកាន់របស់ធ្ងន់, និរោធសច្ច ដូចដាក់របស់ធ្ងន់, មគ្គសច្ច ដូចឧបាយជាគ្រឿង

---

[៨៤] សីលជាទីស្រឡាញ់របស់ព្រះអរិយៈ ។

ដាក់របស់ធ្ងន់ ។ ម្យ៉ាង ទុក្ខសច្ច ដូចរោគ, សមុទយសច្ច ដូចសមុដ្ឋានរបស់រោគ, និរោធសច្ច ដូចសេចក្ដីស្ងប់របស់រោគ, មគ្គសច្ច ដូចជាថ្នាំ ។

ម្យ៉ាងទៀត ទុក្ខសច្ច ប្រៀបដូចភិក្ខាហាររកបានដោយក្រ, សមុទយសច្ច ប្រៀបដូចភ្លៀងមិនល្អ, និរោធសច្ចប្រៀបដូចភិក្ខាហាររកបានដោយងាយ, មគ្គសច្ច ប្រៀបដូចភ្លៀងល្អ ។

ម្យ៉ាងវិញទៀត គប្បីជ្រាបសច្ចៈទាំងនេះ ដោយឧបមាប្រកបដោយមនុស្ស មានពៀរ មានមូលហេតុនៃពៀរ ការដកឡើងនូវពៀរ ឧបាយនៃការដកឡើងនូវពៀរ និងប្រៀបដោយដើមឈើមានពិស ឫសបណ្ដូលរបស់ដើមឈើមានពិស ការកាត់ដើមឈើមានពិស ឧបាយកាត់គល់ដើមឈើមានពិស និងគប្បីជ្រាបដោយមានភ័យ ហេតុដែលមានភ័យ សេចក្ដីរំដោះភ័យ ឧបាយឱ្យរំដោះភ័យ និងគប្បីជ្រាបដោយច្រាំងនេះ ទឹកស្ទឹងធំរបស់ច្រាំងនេះ ច្រាំងនោះ និងអ្នកព្យាយាមឱ្យដល់ច្រាំងនោះនុ៎ះឯង ។

គប្បីជ្រាបវិនិច្ឆ័យដោយឧបមាក្នុងអរិយសច្ចនេះ ដោយប្រការដូច្នេះ ៕

## សម្ដែងអំពីការវិនិច្ឆ័យដោយចតុក្កៈ ( ពួក ៤)

ខថា **ដោយចតុក្កៈ** សេចក្ដីថា ក៏បណ្ដាសច្ចៈ ៤ នេះ ធម៌ដែលជាទុក្ខ, តែមិនមែនទុក្ខអរិយសច្ចក៏មាន; ធម៌ដែលជាអរិយសច្ច, មិនជាទុក្ខក៏មាន; ធម៌ដែលជាទុក្ខ, ជាអរិយសច្ចក៏មាន; ធម៌ដែលមិនជាទុក្ខ និងមិនមែនអរិយសច្ចក៏មាន ។ ក្នុងសមុទយៈជាដើម ក៏ន័យនេះដែរ ។

ក្នុងចតុក្កៈនោះ ធម៌ទាំងឡាយដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផល ទាំងឡាយ ឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ ដោយព្រះបាលីថា “**យំ អនិច្ចំ តំ ទុក្ខំ** = វត្ថុណាមិនទៀង, វត្ថុនោះជាទុក្ខ”[៨៥] , **តែមិនមែនអរិយសច្ច**; និរោធជា អរិយសច្ច, តែមិនមែនជាទុក្ខ; ចំណែកអរិយសច្ចទាំង ២ ក្រៅនេះ (សមុទយៈ និងមគ្គ) គប្បីជ្រាបថាជាទុក្ខ ព្រោះសេចក្ដីមិនទៀង; តែមិនមែនទុក្ខដោយភាវៈ ដែលកុលបុត្រអ្នកប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះមានព្រះភាគជាម្ចាស់កំណត់ ដឹង; ចំណែកឧបាទានក្ខន្ធ ៥ វៀរតណ្ហាហើយ ទាំងជាទុក្ខ ទាំងជាអរិយសច្ច ដោយ ប្រការទាំងពួង; ធម៌ដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផលទាំងឡាយ មិនមែន ទុកដោយភាវៈ ដែលកុលបុត្រអ្នកប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគ ជាម្ចាស់ ដើម្បីកំណត់ដឹង ទាំងមិនមែនអរិយសច្ច ។

---

[៨៥] សំ. ខន្ធ. ។

[៨៦] ក្នុងខសមុទ័យជាដើម កិលេសដែលជាសមុទ័យ (ក្រៅពីតណ្ហា) ជាសមុទ័យ ព្រោះអត្ថថា ធ្វើឱ្យ កើតទុក្ខ, តែមិនមែនជាអរិយសច្ច ដែលជាសមុទ័យ; និរោធ ជាអរិយសច្ច តែមិនមែនជាសមុទ័យ; ទុក្ខ និងមគ្គរួមជាពីរ គប្បីជាសមុទ័យក៏បាន ព្រោះជាបច្ច័យឱ្យកើតផលរបស់ខ្លួន, តែមិនជាសមុទ័យ ដែលជាបហាតព្វធម៌, តណ្ហា + សមុទ័យ = អរិយសច្ច; ធម៌ដែលសម្បយុត្ត ដោយមគ្គ និងសាមញ្ញ ផល មិនជាសមុទ័យ ដែលនឹងត្រូវលះ និងមិនជាអរិយសច្ច (សច្ចវិមុត្តិ) ។

គប្បីជ្រាបការប្រកបក្នុងសមុទយៈជាដើម [៨៦] តាមសមគួរ ហើយវិនិច្ឆ័យក្នុងអរិយសច្ចនេះ ដោយចតុក្កៈ មានប្រការដូច្នេះឯង ៕

## សម្តែងអំពីការវិនិច្ឆ័យដោយសុញ្ញតា (សូន្យ)

ក្នុងខថា **ដោយសុញ្ញតា** និង **ដោយជាធម៌ដូចគ្នាជាដើម** នេះ គប្បីជ្រាបដោយសភាពសូន្យទទេជាមុនសិន ៖ ពិតណាស់ ដោយបរមត្ថ សច្ចទាំងអស់នុ៎ះឯង គប្បីជ្រាបថា ជាសភាពសូន្យទទេ ព្រោះមិនមានអ្នកសោយ, មិនមានអ្នកធ្វើ, មិនមានអ្នករំលត់, មិនមានអ្នកដើរ; ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញប្រព័ន្ធពាក្យគាថានេះទុកថា ៖

**“ទុក្ខមេវ ហិ ន កោចិ ទុក្ខិតោ**
**ការកោ ន កិរិយា វ វិជ្ជតិ**
**អត្ថិ និព្វុតិ ន និព្វុតោ បុមា**
**មគ្គមត្ថិ គមកោ ន វិជ្ជតិ**

សេចក្តីពិត ទុក្ខប៉ុណ្ណោះមាន, តែបុគ្គលណាជាទុក្ខមិនមានទេ; ការធ្វើមាន, តែអ្នកធ្វើគ្មានទេ; សេចក្តីរំលត់មាន, តែបុគ្គលអ្នករំលត់គ្មានទេ; ផ្លូវមាន, តែបុគ្គលអ្នកដើរគ្មានទេ” [៨៧] ដូច្នេះ ។

---

ក្នុងនិរោធ សង្ខារនិរោធ និងនិរោធសមាបត្តិ ជានិរោធ, តែមិនជានិរោធអរិយសច្ច; សមុទ័យ ជាអរិយសច្ច, តែមិនជានិរោធ;ទុក្ខ និងមគ្គទាំងពីរ ជានិរោធក៏បាន, តែមិនជានិរោធអរិយសច្ច; សមុ-ទ័យជាអរិយសច្ច, តែមិនជានិរោធ; ទុក្ខ និងមគ្គទាំងពីរ ជានិរោធក៏បាន ព្រោះជាខណនិរោធ, តែ

ម្យ៉ាង សេចក្ដីសូន្យទទេក្នុងសច្ចៈទាំង ៤ នោះ គប្បីជ្រាបយ៉ាងនេះ គឺសច្ចៈ ២ បទដំបូងសូន្យទទេចាកភាពទៀង សេចក្ដីល្អ សេចក្ដីសុខ និងអត្តា, សន្តិបទ គឺ ព្រះនិព្វានទទេចាកអត្តា មគ្គទទេចាកសេចក្ដីទៀង សេចក្ដីសុខ និងអត្តា ។

ម្យ៉ាងទៀត សច្ចៈ ៣ ក្រៅពីនិរោធ, ឯនិរោធក៏ក្រៅពីសច្ចៈ ៣ ដ៏សេស ។

ម្យ៉ាងវិញទៀត ក្នុងសច្ចៈទាំង ៤ នេះ ហេតុទទេចាកផល ព្រោះមិនមាន ទុក្ខ ក្នុងសមុទយៈ និងមិនមាននិរោធក្នុងមគ្គ, ហេតុមិនទៅរួមជាមួយផល ដូច ប្រក្រតី (ការប្រព្រឹត្ត) [៨៨] របស់លទ្ធិទាំងឡាយមាន**បកតិវាទី**ជាដើម ។ ឯផលវិញ ក៏ទទេចាកហេតុ ព្រោះសេចក្ដីទុក្ខជាមួយនឹងសមុទយៈ, ឯនិរោធជាមួយនឹងមគ្គមិន

---

មិនមែនជានិរោធសច្ច អសង្ខតៈជានិរោធផង ជាអរិយសច្ចធម៌ផង ដែលសម្បយុត្តដោយមគ្គ និង សាមញ្ញផល មិនមែនជានិរោធ និងមិនមែនជាអរិយសច្ច ។

អង្គមគ្គដទៃក្រៅពីអរិយមគ្គ ជាមគ្គដែរ, តែមិនមែនជាអរិយមគ្គទេ; និរោធជាអរិយសច្ច ដែរ, តែមិនជាមគ្គទេ; ទុក្ខ និងសមុទ័យទាំងពីរ ជាមគ្គក៏បាន ព្រោះជាផ្លូវទៅកាន់ភព, តែមិនមែន អរិយមគ្គ ដែលគួរចម្រើនដើម្បីនិរោធ, និរោធគាមិនីបដិបទា ជាមគ្គផង, ជាអរិយសច្ចផង ដោយ ប្រការទាំងពួង; ធម៌ដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផល មិនជាមគ្គ និងមិនជាអរិយសច្ច ឡើយ (ចាកមហាដីកា) ។

[៨៧] ទុក្ខជាសច្ចៈ,ចំណែកបុគ្គលជាបញ្ញត្តិ; សច្ចជាបរមត្ថ, បញ្ញត្តិមិនមែនបរមត្ថ; ការធ្វើសំដៅដល់ តណ្ហាដែលជាហេតុ, មិនបានសំដៅដល់យកបុគ្គលដែលជាបញ្ញត្តិ ។ សេចក្ដីរំលត់ សំដៅយកនិព្វាន, មិនមែនបុគ្គលជាអ្នករំលត់ទេ; ផ្លូវសំដៅដល់មគ្គមានអង្គ ៨ ដែលមានពិត, ចំណែកបុគ្គលអ្នកដើរ មិនមាន ព្រោះមិនមែនជាបុគ្គលទេ ដែលជាអ្នកដើរនោះ ។

[៨៨] លទ្ធិខាងក្រៅ ឈ្មោះថា **បកតិវាទី** មានការយល់ឃើញថា តាមធម្មតាហេតុរួមនៅជាមួយផល តមកទើបញែកចេញដោយឡែក, លទ្ធិសមវាយវាទី ក៏មានន័យដូចគ្នានេះដែរ ។

បានប្រព្រឹត្តទៅជាមួយគ្នាទេ, ផលនោះមិនប្រព្រឹត្តទៅជាមួយនឹងហេតុ, ដូចអណ្ដូ ទាំងពីររបស់លទ្ធិ (បុគ្គល) ទាំងឡាយ មាន**ហេតុផលសមវាយវាទី**ជាដើម ដែលមិនប្រព្រឹត្តទៅជាមួយនឹងហេតុ; ព្រោះហេតុនោះ អ្នកប្រាជ្ញទើបប្រព័ន្ធពាក្យគាថានេះទុកថា ៖

**តយមិធ និរោធសុញ្ញំ តយេន តេនាបិ និព្វុតិ សុញ្ញា**
**សុញ្ញោ ផលេន ហេតុ ផលំបិ តំ ហេតុនា សុញ្ញំ ។**

បណ្ដាសច្ចៈទាំង ៤ នេះ សច្ចៈ ៣ ក្រៅពីនិរោធ, និរោធ (និព្វុតិ) វិញ ក៏សូន្យទទេចាកសច្ចៈ សូម្បីទាំង ៣ នោះ; សច្ចៈ ដែលជាហេតុក្រៅពីសច្ចៈដែលជាផល សូម្បីសច្ចៈដែលជាផលនោះ វិញ ក៏ក្រៅពីសច្ចៈដែលជាហេតុ ។

គប្បីជ្រាបវិនិច្ឆ័យដោយសុញ្ញតា យ៉ាងនេះសិនចុះ ៕

## សម្ដែងអំពីការវិនិច្ឆ័យធម៌មានចំណែកតែម្យ៉ាងជាដើម

ខថា **ដោយជាធម៌មានចំណែកតែម្យ៉ាងជាដើម** សេចក្ដីថា ក៏បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខទាំងអស់នុ៎ះឯង ឈ្មោះថា មានចំណែកតែម្យ៉ាង ព្រោះជាបវត្តិ (គឺជាធម៌វិលទៅក្នុងវដ្ដៈ), ជា ២ យ៉ាង ដោយជានាម និងរូប, ជា ៣ យ៉ាង ដោយញែកជាឧប្បត្តិភព គឺកាមភព រូបភព និងអរូបភព, ជា ៤ យ៉ាង ដោយប្រភេទនៃអាហារ ៤, ជា ៥ យ៉ាង ដោយប្រភេទនៃឧបាទានក្ខន្ធ ៥ ។

សូម្បីសមុទយៈ ឈ្មោះថា មានចំណែកតែម្យ៉ាង ព្រោះជាសភាពឱ្យវដ្ដៈវិលទៅ, ជា ២ យ៉ាង ព្រោះជាធម៌សម្បយុត្តដោយទិដ្ឋិ និងមិនសម្បយុត្តដោយទិដ្ឋិ,

ជា ៣ យ៉ាង ដោយញែកជាកាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា, ជា ៤ យ៉ាង ព្រោះជាទោសដែលមគ្គ ៤ គប្បីលះ, ជា ៥ យ៉ាង ដោយញែកអារម្មណ៍ មានសេចក្តីត្រេកអរក្រៃលែងក្នុងរូបជាដើម, ជា ៦ យ៉ាង ដោយប្រភេទនៃកងតណ្ហា ៦ [៨៩] ។

សូម្បីនិរោធ ឈ្មោះថា មានចំណែកតែម្យ៉ាង ព្រោះជាអសង្ខតធាតុ, តែដោយបរិយាយ (អម) និរោធជា ២ យ៉ាង ព្រោះជាសឧបាទិសេសនិព្វាន និងអនុបាទិសេសនិព្វាន; ជា ៣ យ៉ាង ព្រោះស្ងប់ចាកភពទាំង ៣, ជា ៤ យ៉ាង ព្រោះជាអារម្មណ៍ឱ្យមគ្គ ៤ ពន្លុះ, ជា ៥ យ៉ាង ព្រោះស្ងប់សេចក្តីត្រេកអរក្រៃលែង ៥ (មានរូបារម្មណ៍ជាដើម), ជា ៦ យ៉ាង ដោយប្រភេទនៃការអស់ទៅ របស់កងតណ្ហា ៦ ។

សូម្បីមគ្គវិញ ក៏ឈ្មោះថា មានតែម្យ៉ាង ព្រោះជាធម៌គួរចម្រើន, ជា ២ យ៉ាង ដោយញែកជាសមថៈ និងវិបស្សនា; ម្យ៉ាងទៀត ជា ២ យ៉ាង ដោយប្រភេទនៃទស្សនៈ (សោតាបត្តិមគ្គ) និងភាវនា (មគ្គ ៣ ដ៏សេស), ជា ៣ ដោយប្រភេទនៃធម្មក្ខន្ធ ៣ (មានសីលក្ខន្ធជាដើម); ពិតណាស់ មគ្គនេះ ព្រោះជានិប្បទេសធម៌ [៩០] ទើបសង្គ្រោះ (រាប់បញ្ចូល) ដោយខន្ធ ៣ ដែលជានិប្បទេសនធម៌ [៩១] ដូចក្បាល (មេ) ក្រុងរួមដោយព្រះរាជាណាចក្រដូច្នោះ ។ ដូចយ៉ាងព្រះ**ធម្មទិន្នាថេរី** ពោលដោះបញ្ហា **វិសាខឧបាសកថា** ៖

---

[៨៩] កងនៃតណ្ហា ៦ គឺ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា និងធម្មតណ្ហា ។

[៩០] សំដៅដល់ធម៌ដែលព្រះអង្គទ្រង់សម្តែងទុក ជាចំណែកខ្លះៗ (ចំណែកតូច) ។

[៩១] សំដៅដល់ធម៌ដែលទ្រង់ សម្តែងដោយសព្វគ្រប់ (ធំ) ។

“ម្នាលវិសាខៈអ្នកមានអាយុ ខន្ធ ៣ ព្រះមានព្រះភាគជាម្ចាស់មិនទ្រង់សង្គ្រោះ (កំណត់) ដោយអរិយមគ្គមានអង្គ ៨; ចំណែកអរិយមគ្គមានអង្គ ៨ ព្រះមានព្រះភាគទ្រង់សង្គ្រោះដោយខន្ធ ៣ ដូច្នេះឯង ។ ម្នាលវិសាខៈ សម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ ព្រះអង្គទ្រង់សង្គ្រោះ **ដោយសីលក្ខន្ធ**; ព្រោះសម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ ទ្រង់សង្គ្រោះដោយសមាធិខន្ធ; សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ព្រះអង្គទ្រង់សង្គ្រោះដោយ**បញ្ញាខន្ធ**”[៩២] ព្រោះក្នុងអរិយមគ្គមានអង្គ ៨ នេះ មគ្គ ៣ មានសម្មាវាចាជាដើម ជាសីលតែម្យ៉ាង; ព្រោះហេតុដូច្នោះ មគ្គ ៣ មានសម្មាវាចាជាដើមនោះ ព្រះអង្គទ្រង់សង្គ្រោះ ដោយ**សីលក្ខន្ធ** ដោយកំណើតរបស់ខ្លួន; ព្រោះសូម្បីក្នុងព្រះបាលីព្រះអង្គទ្រង់ធ្វើនិទ្ទេសទុកដោយសត្តមីវិភត្តិថា **“សីលក្ខន្ធេ”** ដូច្នេះក៏ពិតមែនហើយ, ប៉ុន្តែ ក៏គប្បីជ្រាបដោយអំណាចនៃតតិយាវិភត្តិប៉ុណ្ណោះ ។

ម្យ៉ាងទៀត ក្នុងមគ្គ ៣ មានសម្មាវាយាមៈជាដើម សមាធិរមែងមិនអាចសម្រេច[៩៣] (អប្បនា) ដោយសេចក្តីមានអារម្មណ៍តែមួយក្នុងអារម្មណ៍តាមធម្មតារបស់ខ្លួនបាន, តែកាលវីរិយៈញ៉ាំងកិច្ច គឺការផ្គងចិត្តទុកឱ្យសម្រេច និងកាលសតិញ៉ាំងកិច្ច គឺការមិនភាន់ច្រឡំឱ្យសម្រេចហើយ សមាធិក៏រមែងសម្រេចបាន ។ ក្នុងខនោះ មានឧបមាដូច្នេះ ៖

---

[៩២] ម. មូ. ។

[៩៣] សម្មោ. អដ្ឋ. ប្រែថា ប្រព្រឹត្ត ។

ប្រៀបដូចមិត្តសំឡាញ់ ៣ នាក់ ចូលទៅកាន់ឧទ្យាន ដោយបំណងថា ពួកយើងនឹងលេងនក្ខត្តឫក្ស ម្នាក់ឃើញដើមចម្ប៉ាមានផ្ការីកស្កុសស្គាយ សូម្បីលើកដៃទៅបេះ ក៏មិនអាចបេះបាន, បន្ទាប់មក សំឡាញ់ទី ២ ទើបឱនខ្នងឱ្យ; សំឡាញ់ទី ១ នោះ សូម្បីឈរលើខ្នងសំឡាញ់ទី២ហើយញ័រមិនអាចបេះផ្កាបាន, បន្ទាប់មក សំឡាញ់ទី ៣ ក្រៅនេះ ទើបផ្ទៀងចង្កួយស្មាចូលទៅ; សំឡាញ់ទី ១ នោះ ទើបឈរលើខ្នងសំឡាញ់ ១ នាក់ ប្រតោងចង្កួយស្មា សំឡាញ់ ១ នាក់ ទើបបេះផ្កាឈើទាំងឡាយ តាមពេញចិត្ត ប្រដាប់កាយលេងនក្ខត្តឫក្ស យ៉ាងណា; ខឧបមេយ្យនេះ គប្បីជ្រាបដូច្នោះចុះ ។

ពិតណាស់ ធម៌ ៣ មានសម្មាវាយាមៈជាដើម កើតព្រមគ្នា ដូចសំឡាញ់ ៣ នាក់ ចូលទៅកាន់ឧទ្យានព្រមគ្នា, អារម្មណ៍ដូចដើមចម្ប៉ាមានផ្ការីកស្កុសស្គាយ, សមាធិមិនអាចសម្រេចដោយភាពមានអារម្មណ៍តែមួយ ក្នុងអារម្មណ៍តាមធម្មតារបស់ខ្លួនដូចសំឡាញ់ទី ១ សូម្បីឈោងដៃទៅ ក៏មិនអាចបេះបាន, វាយាមៈ (សេចក្តីព្យាយាម) ដូចសំឡាញ់ដែលឱនខ្នងឱ្យ, សតិដូចសំឡាញ់ម្នាក់ដែលឈរឱ្យចង្កួយស្មា ។ បណ្តាសំឡាញ់ទាំង ៣ នាក់នោះ សំឡាញ់ទី ១ នេះ ឈរនៅលើខ្នងសំឡាញ់ ១ នាក់ប្រតោងចង្កួយស្មា សំឡាញ់មួយនាក់ រមែងអាចបេះផ្កាឈើបានតាមប្រាថ្នា យ៉ាងណា, សមាធិក៏យ៉ាងនោះដែរ កាលសេចក្តីព្យាយាមញុំាងកិច្ច គឺការផ្គងចិត្តឱ្យសម្រេច និងកាលសតិញុំាងកិច្ច គឺការមិនភាន់ច្រឡំឱ្យសម្រេចបានឧបការៈហើយ រមែងអាចសម្រេចដោយមានអារម្មណ៍តែមួយ; ព្រោះហេតុនោះ ក្នុងមគ្គទាំង ៣ នេះ មគ្គ គឺសមាធិប៉ុណ្ណោះ ព្រះអង្គទ្រង់សង្គ្រោះ (កំណត់)

ដោយសមាធិខន្ធ ដោយកំណើតរបស់ខ្លួន; ចំណែកមគ្គមានវាយាមៈ និងសតិទ្រង់សង្គ្រោះដោយសមាធិខន្ធ ដោយកិរិយា (គឺជាធម៌មានឧបការៈ) ។

សូម្បីក្នុងសម្មាទិដ្ឋិ និងសម្មាសង្កប្បៈវិញ បញ្ញា (សម្មាទិដ្ឋិ) ក៏មិនអាចវិនិច្ឆ័យថា អារម្មណ៍មិនទៀង ជាទុក្ខ ជាអនត្តា តាមធម្មតារបស់ខ្លួនបាន, តែកាលវិតក្កៈ (សម្មាសង្កប្បៈ) ប៉ះពាល់ហើយតាំងនៅ ក៏អាចកាត់អស់បាន យ៉ាងណា, ប្រៀបដូចហិរញ្ញិក (អ្នកកាន់ប្រាក់) ដាក់កហាបណៈក្នុងដៃ សូម្បីជាអ្នកប្រាថ្នាដើម្បីនឹងត្រួតមើលចំណែករបស់ហិរញ្ញិក ក៏មិនអាចដើម្បីនឹងក្រឡេកភ្នែកវិលទៅជុំវិញបាន, តែការប្រើម្រាមផ្ទាត់ទៅ ក៏អាចដើម្បីមើលខាងនោះ ខាងនេះបាន យ៉ាងណា, បញ្ញាក៏ដូច្នោះដែរ រមែងមិនអាចវិនិច្ឆ័យអារម្មណ៍ដោយសេចក្ដីជារបស់មិនទៀងជាដើម តាមធម្មតារបស់ខ្លួនបាន, តែរមែងអាចវិនិច្ឆ័យអារម្មណ៍ ដែលវិតក្កៈមានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ មានការធ្វើចិត្តឱ្យប៉ះខ្ទប់អារម្មណ៍រឿយៗ ជាកិច្ច ដូចជាប៉ះខ្ទប់ហើយ និងដូចចាប់ផ្ទាត់ទៅមកឱ្យនៅនោះឯង; ព្រោះហេតុដូច្នោះ ក្នុងអធិការនេះ សូម្បីសម្មាទិដ្ឋិនេះប៉ុណ្ណោះ ព្រះអង្គទ្រង់សង្គ្រោះទុកដោយបញ្ញាខន្ធ តាមកំណើតរបស់ខ្លួន; ចំណែកសម្មាសង្កប្បៈជាធម៌ ដែលព្រះអង្គទ្រង់សង្គ្រោះក្នុងបញ្ញាខន្ធដោយកិរិយា; មគ្គរមែងដល់ការសង្គ្រោះ ដោយខន្ធទាំង ៣ នេះ ដោយប្រការដូច្នេះ; ដោយហេតុនោះ ទើបលោកពោលថា “មគ្គមាន ៣ យ៉ាង ដោយប្រភេទនៃខន្ធ ៣” ។ មគ្គមាន ៤ យ៉ាង ដោយអំណាចនៃមគ្គ ៤ មានសោតាបត្តិមគ្គជាដើម ។

ម្យ៉ាងទៀត សច្ចៈទាំងអស់នោះឯងមានតែម្យ៉ាង ព្រោះជាសភាវៈដែល

មានពិត១ ឬព្រោះជាអភិញ្ញេយ្យធម៌ = ធម៌ដែលគប្បីដឹង ។ អភិញ្ញេយ្យធម៌មានពីរយ៉ាង ដោយជាលោកិយ និងលោកុត្តរ ជាសង្ខតៈ និងអសង្ខតៈ; មាន ៣ យ៉ាង ព្រោះថា ធម៌ដែលគប្បីលះដោយទស្សនៈ នឹងជាភាវនា ដោយជាធម៌មិនគប្បីលះដោយទស្សនៈ និងភាវនា នឹងជាធម៌ដែលគប្បីលះក៏មិនមែន, មិនគប្បីលះ ក៏មិនមែន; មាន ៤ យ៉ាង ដោយប្រភេទបរិញ្ញេយ្យធម៌ជាដើមដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអធិការនេះ ដោយជាធម៌តែម្យ៉ាង មានប្រការដូច្នេះ៕

## សម្តែងអំពីការវិនិច្ឆ័យដោយសភាគ និង វិសភាគ

ខថា **ដោយសភាគ និងវិសភាគ** សេចក្តីថា សច្ចៈទាំងអស់នោះឯង ឈ្មោះថា **ជាសភាគ** (គឺមានចំណែកស្មើគ្នានឹងគ្នា) ដោយជារបស់ពិត ដោយជារបស់ទទេចាកអត្តា និងដោយជាវត្ថុដែលចាក់ធ្លុះបានលំបាក; ដូចយ៉ាងដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា “ម្នាលអានន្ទ អ្នកនឹងសម្គាល់ខនោះយ៉ាងណា, យ៉ាងណាហ្ន៎ នឹងធ្វើបានលំបាកជាងគ្នា ឬនឹងឱ្យកើតឡើងបានលំបាកជាងគ្នា, គឺការដែលបាញ់ព្រួញឱ្យចូលទៅជាប់ៗ គ្នា ដោយប្រហោងក្នែកត្នោតតូចពីទីឆ្ងាយបានមិនខុសភ្លាត់ និងការបាញ់ចុងរោមទ្រាយដោយរោមទ្រាយដែលចែកចេញជា ៧ ចំណែក” ; ព្រះអានន្ទក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ការបាញ់ចុងរោមទ្រាយ ដោយឱ្យចុងរោមទ្រាយបែកចេញជា ៧ ចំណែក ធ្វើបានលំបាកជាង នឹងកើតឡើងបានលំបាកជាងព្រះអង្គ” ; លំដាប់នោះឯង ទើបព្រះមានព្រះភាគត្រាស់ថា “ម្នាល

អានន្ទ ជនឯណារមែងចាក់ធ្លុះតាមសេចក្ដីពិតថា នេះជាទុក្ខ ។ ល ។ នេះជាទុក្ខ-និរោធគាមិនីបដិបទា ជនពួកនោះរមែងចាក់ធ្លុះបានដោយលំបាកពិត”[៩៤] ។

ឈ្មោះថា **វិសភាគ** = មានចំណែកមិនស្មើគ្នា ដោយការកំណត់លក្ខណៈរបស់ខ្លួន; ក៏សច្ចៈ ២ ដំបូង ឈ្មោះថា **ជាសភាគ** ព្រោះជារបស់ជ្រាលជ្រៅ ដោយអត្ថថាស្ទាបស្ទង់បានដោយលំបាក ព្រោះជាលោកិយ៍ និងព្រោះការប្រព្រឹត្តទៅជាមួយអាសវៈ, ឈ្មោះថា **ជាវិសភាគ** ព្រោះញែកចេញដោយផល និងហេតុ និងព្រោះជាធម៌ដែលគួរដឹង និងជាធម៌ដែលគួរលះ (**បរិញ្ញេយ្យបហាតព្វកិច្ច**); សូម្បីសច្ចៈ ២ ខាងក្រោយ ក៏ជា**សភាគៗ** គឺមានចំណែកស្មើគ្នា ព្រោះស្ទាប់ស្ទង់បានលំបាក ដោយសេចក្ដីជារបស់ជ្រាលជ្រៅ ព្រោះជាលោកុត្តរ និងព្រោះជាអនាសវៈ, ឯសច្ចៈ ២ ខក្រោយ **ជាវិសភាគ** ព្រោះញែកជាវិសយៈ និងវិសយី[*] និងព្រោះជា **សច្ឆិកាតព្វៈ** = ធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់ និង**ជាភាវេតព្វៈ** = ធម៌ដែលគួរចម្រើន; ម្យ៉ាងទៀត សច្ចៈទី ១ និងទី ៣ ឈ្មោះថា **ជាសភាគគ្នា** ព្រោះអាងដល់ផល, ឈ្មោះថា **វិសភាគគ្នា** ព្រោះជាសង្ខតៈ និងអសង្ខតៈ; ម្យ៉ាងវិញទៀត សច្ចៈទី ២ និងទី ៤ ឈ្មោះថា **ជាសភាគគ្នា** ព្រោះអាងដល់ហេតុ, ឈ្មោះថា **ជាវិសភាគគ្នា** ព្រោះជាកុសល និងអកុសល ដោយចំណែកម្យ៉ាង; ក៏សច្ចៈទី ១ និងទី ៤ ឈ្មោះថា **ជាសភាគគ្នា** ព្រោះជាសង្ខតៈ, ឈ្មោះថា **ជាវិសភាគគ្នា** ព្រោះជាលោកិយ និងលោកុត្តរ; ក៏សច្ចៈទី ២ ទី ៣ **ជាវិសភាគគ្នា** ដោយជានេវសេក្ខានាសេក្ខា និងឈ្មោះថា **វិសភាគ** ព្រោះ

---

[៩៤] សំ. ម. ។

[*] វិសយៈក្នុងទីនេះ គឺ និរោធ, វិសយី គឺមគ្គ ។

ជាសារម្មណ៍ និងអនារម្មណ៍ ( មានអារម្មណ៍ និងមិនមានអារម្មណ៍) ៖

**ឥតិ ឯវំ បការេហិ នយេហិ ច វិចក្ខណោ**
**វិជញ្ញា អរិយសច្ចានំ សភាគវិសភាគតំ ។**

បណ្ឌិតអ្នកឆ្លាតគប្បីដឹងច្បាស់នូវសេចក្តី ដែលអរិយសច្ចទាំងឡាយ ជាសភាគ = មានចំណែកស្មើគ្នា និងវិសភាគ = មានចំណែកមិនស្មើគ្នា, ដោយប្រការ និងដោយន័យទាំងឡាយយ៉ាងនេះចុះ ៕

## ពណ៌នាអំពីនិទ្ទេសវារៈ

## សម្តែងអំពីទុក្ខអរិយសច្ច

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្តែងចំណែក ៤ មានទុក្ខជាដើម ដែលព្រះអង្គទ្រង់លើកឡើងសម្តែងដោយសង្ខេប ទើបផ្តើមនិទ្ទេសវារៈនេះថា **“តត្ថ កតមំ ទុក្ខំ អរិយសច្ចំ ជាតិបិ ទុក្ខា** = ក្នុងអរិយសច្ច ៤ នោះ **ទុក្ខជាអរិយសច្ច** តើដូចម្តេច ? សូម្បីជាតិក៏ជាទុក្ខ” ជាដើម ។

ក្នុងនិទ្ទេសនៃទុក្ខអរិយសច្ចនោះ បណ្ឌិតគប្បីជ្រាប**ជាតិ**, គប្បីជ្រាបអត្ថនៃជាតិជា**ទុក្ខ**; គប្បីជ្រាប**ជរា**, គប្បីជ្រាបអត្ថនៃ**ជរាជាទុក្ខ**; គប្បីជ្រាប**មរណៈ**, គប្បីជ្រាបអត្ថនៃ**មរណៈជាទុក្ខ**; គប្បីជ្រាប**សោក**, គប្បីជ្រាបអត្ថនៃ**សោកជាទុក្ខ**; គប្បីជ្រាប**អត្ថនៃបរិទេវៈ**, គប្បីជ្រាបអត្ថនៃបរិទេវៈជា**ទុក្ខ**; គប្បីជ្រាប**ទុក្ខ**, គប្បីជ្រាបអត្ថនៃទុក្ខជា**ទុក្ខ**; គប្បីជ្រាប**ទោមនស្ស**, គប្បីជ្រាបអត្ថនៃ**ទោមនស្សជា**ទុក្ខ; គប្បីជ្រាប

**ឧបាយាស**, គប្បីជ្រាបអត្ថនៃ**ឧបាយាសជាទុក្ខ**; គប្បីជ្រាប**អប្បិយសម្បយោគ**, គប្បីជ្រាបអត្ថនៃ**អប្បិយសម្បយោគជាទុក្ខ**; គប្បីជ្រាប**បិយវិប្បយោគ**, គប្បីជ្រាបអត្ថនៃ**បិយវិប្បយោគជាទុក្ខ** ។ គប្បីជ្រាប**ឥច្ឆា** (សេចក្ដីប្រាថ្នា), គប្បី**ជ្រាបអត្ថនៃសេចក្ដីប្រាថ្នាជាទុក្ខ**; គប្បីជ្រាប**ខន្ធ**, គប្បីជ្រាបអត្ថនៃ**ខន្ធជាទុក្ខ**; នេះជាមាតិកា ដើម្បីប្រយោជន៍ក្នុងការពោលទុក្ខអរិយសច្ចក្នុងនិទ្ទេសវារៈនោះ ៖

ពិតណាស់ ក៏ឈ្មោះថា ទុក្ខនេះ មានប្រការផ្សេងៗ ជាអនេក; តើដូចម្ដេចខ្លះ ? គឺ

- **ទុក្ខទុក្ខ** ទុក្ខព្រោះអត់ធន់បានដោយលំបាក
- **បរិណាមទុក្ខ** ទុក្ខព្រោះប្រែប្រួល
- **សង្ខារទុក្ខ** ទុក្ខរបស់សង្ខារ
- **បដិច្ឆន្នទុក្ខ** ទុក្ខបិទបាំង
- **អប្បដិច្ឆន្នទុក្ខ** ទុក្ខបើកបង្ហាញ
- **បរិយាយទុក្ខ** ទុក្ខដោយអម
- **និប្បរិយាយទុក្ខ** ទុក្ខដោយត្រង់ ។

បណ្ដាទុក្ខទាំងនោះ ទុក្ខវេទនាដែលប្រព្រឹត្តទៅក្នុងផ្លូវកាយ និងចិត្ត ឈ្មោះថា **ទុក្ខទុក្ខ** ព្រោះជាទុក្ខទាំងដោយសភាវៈ ទាំងដោយឈ្មោះ ។ **សុខវេទនា** ឈ្មោះថា **បរិណាមទុក្ខ** ព្រោះជាហេតុនៃទុក្ខ ដោយការប្រែប្រួល ។ **ឧបេក្ខាវេទនា** និងសង្ខារទាំងឡាយដែលសេសប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា **សង្ខារទុក្ខ** ព្រោះត្រូវសេចក្ដីកើត និងរលត់បៀតបៀន; ក៏សេចក្ដីបៀតបៀននោះ (ដោយការកើត និង

ការរលត់) រមែងមានសូម្បីដល់មគ្គ និងផលទាំងឡាយដូចគ្នា; ព្រោះហេតុនោះ គប្បីជ្រាបថា ធម៌ទាំងនេះ ឈ្មោះថា **សង្ខារទុក្ខ** ដោយអត្ថថា រាប់បញ្ចូលដោយទុក្ខ-សច្ច ។ ការឈឺផ្លូវកាយ និងចិត្ត មានឈឺត្រចៀក ឈឺធ្មេញ សេចក្តីក្តៅក្រហាយកើតពីរាគៈ សេចក្តីក្តៅក្រហាយកើតពីទោសៈជាដើម ឈ្មោះថា **បដិច្ឆន្នទុក្ខ**[៩៥] ព្រោះត្រូវសួរទើបដឹង និងព្រោះឈានចូលទៅដល់ហើយ ក៏មិនប្រាកដ; លោកហៅថា ទុក្ខមិនប្រាកដដូច្នេះខ្លះ ។ ការឈឺ មានត្រូវគេដាក់កម្មករណ៏[*] ៣២ ជាដើមជាសមុដ្ឋាន ឈ្មោះថា **អប្បដិច្ឆន្នទុក្ខ** ព្រោះមិនសួរក៏ដឹងបាន និងព្រោះចូលទៅដល់ហើយ ក៏ប្រាកដ; លោកហៅថា ទុក្ខប្រាកដ ដូច្នេះខ្លះ ។ សូម្បីទុក្ខទាំងអស់មានជាតិជាដើម ដែលមកហើយក្នុងវិភង្គនៃទុក្ខសច្ច វៀរទុក្ខដែលសេស ឈ្មោះថា **បរិយាយទុក្ខ** ព្រោះជាវត្ថុ (ទីកើត) នៃទុក្ខនោះៗ ។ ទុក្ខទុក្ខ ឈ្មោះថា **និប្ប-រិយាយទុក្ខ** ។

បណ្តាទុក្ខទាំងនោះ គប្បីពោលទុក្ខអរិយសច្ច ដែលតាំងទុកក្នុងបទ ២ នេះ គឺ បរិយាយទុក្ខ និងនិប្បរិយាយទុក្ខ; ក៏ធម្មតាអរិយសច្ចនេះ រមែងមានមកក្នុងព្រះបាលី ដោយសង្ខេបខ្លះ, ដោយពិស្តារខ្លះ; ក្នុងទីដែលមកដោយសង្ខេបគួរនឹងពោលដោយសង្ខេបក៏បាន ដោយពិស្តារក៏បាន, តែក្នុងទីដែលមកដោយពិស្តារ សមគួរ

---

[៩៥] **បដិច្ឆន្នទុក្ខ** ដែលថាទុក្ខតាម ផ្លូវកាយ គឺឈឺត្រចៀក ឈឺធ្មេញ សំដៅយកទុក្ខបន្តិចបន្តួច ទើបមិនមាននរណាដឹង ទាល់តែសួរ ទើបដឹង ។

[*] ទារុណកម្ម ។

ពោលដោយពិស្តារប៉ុណ្ណោះ, មិនគួរពោលដោយសង្ខេប; ក្នុងទីនេះ ទុក្ខនេះឯងមកដោយពិស្តារដូច្នេះ គប្បីពោលដោយពិស្តារតែម្យ៉ាង; ព្រោះហេតុដូច្នោះ ពាក្យនេះឯង ដែលខ្ញុំពោលទុកមានជាអាទិ៍ថា "គប្បីជ្រាបជាតិ, គប្បីជ្រាបអត្ថរបស់ជាតិជាទុក្ខ" ដូច្នេះ ព្រោះកាន់យកព្រះបាលីក្នុងនិទ្ទេសវារៈ មានជាអាទិ៍ថា "**តត្ថ កតមំ ទុក្ខំ អរិយសច្ចំ, ជាតិបិ ទុក្ខា** = ក្នុងអរិយសច្ច ៤ នោះ ទុក្ខអរិយសច្ច តើដូចម្តេច ?, សូម្បីជាតិក៏ជាទុក្ខ" ៕

## សម្តែងអំពីជាតិនិទ្ទេសដោយសម្ពន្ធិកថា

បណ្តាទុក្ខអរិយសច្ចនោះ គប្បីជ្រាបពាក្យថា **ជាតិ** ជាដើមសិន ៖

ក៏បណ្ឌិតគប្បីជ្រាបជាតិដោយអំណាចនៃបទភាជនិយនេះថា "**តត្ថ កតមា ជាតិ, យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ** = ក្នុងទុក្ខអរិយសច្ចនោះ ជាតិតើដូចម្តេច ?, ការកើត ការកើតព្រម... ក្នុងពួកសត្វនោះៗ របស់សត្វនោះៗ ឯណា..."[៩៦] ជាដើម ។ ការពណ៌នាអត្ថ ក្នុងនិទ្ទេសនៃជាតិនោះ មានដូចតទៅនេះ ៖

ពាក្យថា "**តេសំ តេសំ សត្តានំ** = របស់សត្វនោះៗ" នេះ ជាអត្ថសម្តែងសេចក្តីទូទៅដល់សត្វមិនមែនតិច ដោយសង្ខេប គឺកាលបើជនពោលពាក្យយ៉ាងនេះថា "ការកើតរបស់ទេវទត្ត, ការកើតរបស់សោមទត្ត" សូម្បីទាំងថ្ងៃរមែងមិនដល់ការកំណត់កាន់យកបាន, រមែងមិនសម្រេចដល់ការសម្តែង ក្នុងសត្វ

---

[៩៦] អភិ. ៨០ ។

ដទៃៗ បានទាំងអស់; តែដោយបទ ២ នេះ សត្វប្រភេទខ្លះ រមែងមិនជាការដែលកំណត់កាន់យកបាន, រមែងមិនសម្រេចការសម្តែងក្នុងសត្វដទៃយ៉ាងណា ក៏មិនបានទេ; ព្រោះហេតុនោះ ទើបត្រាស់ថា "**យា តេសំ តេសំ សត្តានំ** = របស់សត្វពួកនោះៗ ណា" ; ពាក្យថា "**តម្ហិ តម្ហិ** = នោះៗ" នេះ ជាការសម្តែងសេចក្តីទូទៅរបស់សត្តនិកាយមិនមែនតិច ដោយអំណាចនៃគតិ និងជាតិ ។ ពាក្យថា "**សត្ត~និកាយេ**" បានដល់ ក្នុងពួកសត្វ គឺក្នុងក្រុមសត្វ ក្នុងហ្វូងសត្វ ក្នុងប្រជុំសត្វ ។ បទថា **ជាតិ** គឺសព្ទថា ជាតិនេះ មានអត្ថជាអនេក ។

ពិតយ៉ាងនោះមែន សព្ទថា **ជាតិ** នេះ **មកក្នុងភព** ក្នុងប្រយោគនេះថា "**ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ** = រមែងរលឹកបានមួយជាតិខ្លះ ពីរជាតិខ្លះ" [៩៧] ជាដើម; **មកក្នុងនិកាយ** (ពួក) ក្នុងប្រយោគនេះថា "**អត្ថិ វិសាខេ និគន្ថា នាម សមណជាតិ** = ម្នាលនាងវិសាខា សមណនិកាយមួយមាន ឈ្មោះថា និគ្រន្ថ" [៩៨] ; **មកក្នុងបញ្ញត្តិ** ក្នុងប្រយោគនេះថា "**តិរិយា នាម តិណជាតិ នាភិយា ឧគ្គន្ត្វា នភំ អាហច្ច ឋិតា អហោសិ** = តិណជាតិ ឈ្មោះថា **តិរិយា** ឡើងពីនាភីហើយបានតាំងនៅជាប់ផ្ទៃមេឃ" [៩៩] ; **មកក្នុងសង្ខតលក្ខណៈ** ក្នុងប្រយោគនេះថា "**ជាតិ**

---

[៩៧] ទី. សី., វិនយ. ១, ម. ម. ។

[៩៨] អំ. តិក. ។

[៩៩] អំ. បញ្ចក.។

[១០០] អភិ. ។

[១០១] វិនយ. ១, ៤, ៦ ។

**ទ្វីហិ ខន្ធេហិ សង្គហិតា** = ជាតិសង្គ្រោះដោយខន្ធ ២”[១០០] ; **មកក្នុងបដិសន្ធិ** ក្នុងប្រយោគនេះថា **“យំ ភិក្ខវេ មាតុ កុច្ឆិស្មឹ បឋមំ ចិត្តំ ឧប្បន្នំ បឋមំ វិញ្ញាណំ បាតុភូតំ, តទុបាទាយ សាវស្ស ជាតិ** = ម្នាលភិក្ខុទាំងឡាយ ចិត្តដួងដំបូងណាកើតហើយក្នុងឧទរមាតា វិញ្ញាណដួងដំបូងប្រាកដហើយ, បដិសន្ធិនោះៗ ឯង អាស្រ័យចិត្តដែលកើតឡើង និងវិញ្ញាណនោះ”[១០១] ; **មកក្នុងព្រះសូត្រ** ក្នុងប្រយោគនេះថា **“សម្បត្តិជាតោ ខោ អានន្ទ ពោធិសត្តោ** = ម្នាលអានន្ទ ព្រះពោធិសត្វក្នុងពេលដែលប្រសូតិភ្លាម”[១០២] ; **មកក្នុងត្រកូល** ក្នុងប្រយោគនេះថា **“អនុបក្កុដ្ឋោ ជាតិវាទេន** = មិនមាននរណាជំទាស់ តិះដៀលបាន ដោយអាងដល់ត្រកូល”[១០៣] ; **មកក្នុងអរិយសីល** ក្នុងប្រយោគនេះថា **“យតោហំ ភគិនិ អរិយាយ, ជាតិយា ជាតោ** = ម្នាលប្អូនស្រី ចាប់ផ្ដើមតាំងពីយើងកើតហើយក្នុងអរិយជាតិ”[១០៤] ។

តែសព្ទថា **ជាតិ** ក្នុងអធិការនេះ រមែងគួរក្នុងខន្ធដែលកើតគ្រាដំបូងព្រមទាំងវិការ; ព្រោះហេតុដូច្នោះ ពាក្យថា ជាតិនេះ ក្នុងអាការនេះ ទើបជារូបចំពោះខ្លួនដោយសភាវៈថាការកើតរបស់សត្វកំពុងកើត ។ បទដែលទ្រង់ផ្ដើមដោយឧបសគ្គថា **សញ្ជាតិ** ដោយអំណាចនៃការកើតព្រម ។ ឈ្មោះថា **ឱក្កន្តិ** ដោយអំណាចការឈានចុះ (ចូល) ។ ម្យ៉ាងទៀត ឈ្មោះថា **ជាតិ** ព្រោះអត្ថថា ការកើត; ជាតិនោះ ប្រកបទុកដោយអំណាចនៃសត្វអ្នកមានអាយតនៈខ្វះខាត; ឈ្មោះថា **សញ្ជា-**

---

[១០២] ម. ឧ.។

[១០៣] ទី. សី.។

[១០៤] ម. ម. ។

**តិ** ដោយអត្ថថា កើតព្រម; **សញ្ជាតិ**នោះ ប្រកបទុកដោយអំណាចនៃសត្វ អ្នកមានអាយតនះបរិបូណ៌ ។ ឈ្មោះថា **ឱក្កន្តិ** នោះ ដោយអំណាចឈានចុះ; **ឱក្កន្តិ** នោះ ប្រកបទុកដោយអំណាចនៃសត្វអ្នកកើតក្នុងពង និងកើតក្នុងភគ៌; ព្រោះសត្វទាំងនោះរមែងចុះកាន់សំបកពង និងស្បូន; ក៏កាលឈានចុះរមែងចាប់បដិសន្ធិ ដូចសត្វទាំងឡាយអ្នកចូលទៅនៅ ។ ឈ្មោះថា **អភិនិព្វត្តិ** ដោយអត្ថថា កើតក្រៃលែង; អភិនិព្វត្តិសត្វនោះ ប្រកបទុកដោយអំណាចនៃសត្វអ្នកកើតអំពីញើស និងឱបបាតិកសត្វ; ព្រោះសត្វពួកនោះរមែងកើតប្រាកដភ្លាម ។ **នេះជាសម្មតិកថាជាមុនសិន** ៕

## សម្តែងអំពីជាតិនិទ្ទេសដោយបរមត្ថកថា

ឥឡូវនេះ ជាកថាពោលដោយបរមត្ថ; ពិតណាស់ ខន្ធទាំងឡាយនោះឯងរមែង ប្រាកដដោយបរមត្ថ, មិនមែនសត្វ; ក៏ក្នុងព្រះបាលីនោះ បទថា " **ខន្ធានំ** = នៃខន្ធទាំងឡាយ" គប្បីជ្រាបការកាន់យកខន្ធមួយ ក្នុងឯកវោការភព, ខន្ធ ៤ ក្នុងចតុវោការភព, ខន្ធ ៥ ក្នុងបញ្ចវោការភព ។ បទថា "**បាតុភាវោ** = សេចក្ដីប្រាកដ" បានដល់ ការកើតឡើង ។ ក្នុងបទថា " **អាយតនានំ**" នេះ គប្បីជ្រាបការសង្គ្រោះដោយអំណាចនៃអាយតនៈដែលកើតឡើងក្នុងភពនោះ ។ បទថា "**បដិលាភោ** = ការបានចំពោះ" បានដល់ សេចក្ដីប្រាកដក្នុងការបន្តនោះឯង; ព្រោះការប្រាកដនោះៗ ឯង ឈ្មោះថា ការបានចំពោះ ។ ពាក្យថា "**អយំ វុច្ចតិ ជាតិ** = នេះហៅថា ជាតិ" សេចក្ដីថា នេះតថាគតហៅថា ជាតិ ។

ក៏ជាតិនេះឯង ៖

-**តត្ថ តត្ថ ភវេ បឋមាភិនិព្វត្តិ លក្ខណា** មានការកើតមុនក្នុងភព នោះៗ ជាលក្ខណៈ ។

-**និយ្យាតនរសា** មានការប្រគល់ឱ្យជាកិច្ច

-**អតីតភវតោ ឥធ ឧម្មុជ្ជនបច្ចុបដ្ឋានា** មានការឃ្លាតចាកភពអតីតៈ មកកើតឡើងក្នុងភពនេះ ជាបច្ចុប្បដ្ឋាន ។

-**ផលវសេន ទុក្ខវិចិត្តតា បច្ចុបដ្ឋានា វា** ឬមានការវិចិត្រ (រូបរួមទុក) នូវទុក្ខដោយអំណាចនៃផលជាបច្ចុប្បដ្ឋាន ៕

## គប្បីជ្រាបអត្ថនៃជាតិជាទុក្ខ

ឥឡូវនេះ គប្បីជ្រាបខថា **គប្បីជ្រាបអត្ថនៃជាតិជាទុក្ខ,**ពិតណាស់ ជាតិនេះឯង មិនមែនជាទុក្ខដោយឯងៗទេ, តែត្រាស់ទុកថា ព្រោះជាទីតាំងឱ្យទុក្ខកើតឡើង ។

**សួរថា** ក៏ជាតិនេះជាទីតាំងនៃទុក្ខប្រភេទណា ?

ឆ្លើយថា ជាតិនេះជាទីតាំងនៃទុក្ខសូម្បីទាំងអស់នោះ គឺទុក្ខដែលប្រព្រឹត្តទៅក្នុងអបាយ សូម្បីតែព្រះមានព្រះភាគជាម្ចាស់ក៏ទ្រង់ប្រកាសទុក ដោយអំណាចនៃឧបមាក្នុងសូត្រទាំងឡាយ **មានពាលបណ្ឌិតសូត្រជាដើម, និងទុក្ខផ្សេងដោយទុក្ខមានការចុះកាន់គភ៌ជាមូលជាដើម កើតឡើងក្នុងមនុស្សលោក,** កើតឡើងក្នុងសុគតិភូមិ ។ ក្នុងអធិការនេះ គប្បីជ្រាបទុក្ខដែលផ្សេងដោយទុក្ខ មានការចុះកាន់គភ៌ជាមូលជាដើម ដូចតទៅ ៖

## សម្តែងអំពីទុក្ខមានការចុះកាន់គភ៌ជាមូល

ពិតណាស់ សត្វនេះកាលកើតក្នុងផ្ទៃនៃមាតា មិនបានកើតក្នុងទីទាំងឡាយមានផ្កាឧប្បល ផ្កាឈូកក្រហម និងផ្កាឈូកសជាដើមទេ, តាមពិត រមែងកើតក្នុងប្រទេសនៃផ្ទៃដែលគួរខ្ពើមក្រៃលែង ជាការកប់ទុកនៅក្នុងព្រៃធំ គឺវត្ថុដែលមិនស្អាតក្លិនស្អុយយ៉ាងក្រៃពេក ផ្សាយឡើងដោយក្លិនសាកសពផ្សេងៗ ងងឹតសូន្យឈឹងយ៉ាងក្រៃលែង ចង្អៀតដ៏ក្រៃលែងត្រង់កណ្តាលផ្ទៃពោះ និងឆ្អឹងខ្នង ខាងក្រោមក្រពះអាហារថ្មី ខាងលើក្រពះអាហារចាស់ ដូចដង្កូវដែលកើតក្នុងត្រីស្អុយ នំកុម្មាសផ្អូម និងទឹកជ្រាំជាដើម ។ សត្វនោះកើតក្នុងពោះនោះហើយ ត្រូវនៅក្នុងពោះមាតា ១០ ខែ ក្តៅដូចខ្ចប់សាច់អាំងជាដើម ជាប់នៅដូចដុំម្សៅ វៀរចាកអាការមានការបត់ចូល និងបត់ចេញជាដើម សោយនូវទុក្ខមានប្រមាណក្រៃលែង ។ **នេះជាទុក្ខ មានការចុះកាន់គភ៌ជាមូលដោយពិត៕**

## សម្តែងអំពីទុក្ខមានការបរិហារគភ៌ជាមូល

ម្យ៉ាងទៀត សត្វនោះ រមែងសោយទុក្ខឯណា មានប្រមាណដ៏ក្រៃលែងដោយអាស្រ័យសេចក្តីព្យាយាមរបស់មាតាមានការអូសទៅ អូសមក ឱនចុះ ឱនឡើងជាដើម ក្នុងឥរិយាបថទាំងឡាយមានការរអិលដួល ការដើរ ការអង្គុយ ការក្រោកឡើង និងការបង្វិលខ្លួនជាដើមដោយរហ័ស ហាក់បីដូចជាកូនពពែក្នុងការយារដៃរបស់អ្នកលេងសុរា និងហាក់បីដូចជាកូនពស់ក្នុងការលើកដៃរបស់គ្រូពស់, ឯសត្វនោះ រមែងសោយទុក្ខវេទនាយ៉ាងណា គឺក្នុងវេលាដែលមាតាផឹកទឹកត្រជាក់

ក៏ហាក់បីដូចជាកើតក្នុងសីតនរក, ក្នុងវេលាដែលមាតាលេបបបរក្តៅ និងបាយក្តៅជាដើម ក៏ហាក់បីដូចជាភ្លៀងរងើកភ្លើងស្រោចលើដោយជុំវិញ, ក្នុងវេលាដែលមាតាលេបរបស់ប្រៃ និងជូរជាដើម ហាក់បីដូចជាសត្វដល់នូវកម្មករណ៍ ដោយវិធីជះដោយទឹកក្បុង (អាស៊ីត) ជាដើម ។ **នេះជាទុក្ខមានការបរិហារគភ៌ជាមូល** ៕

## សម្តែងអំពីទុក្ខមានការវិបត្តិនៃគភ៌ជាមូល

ម្យ៉ាងទៀត កាលបើមាតារបស់សត្វនោះ មានគភ៌ដេកនៅទទឹង ទុក្ខណារមែងកើតឡើងដោយអាការ មានការកាត់ និងវះជាដើម ក្នុងទីជាទីកើតនៃទុក្ខដែលមិនគួរឃើញ សូម្បីតែមិត្តអាមាត្យ និងសំឡាញ់ជាដើម ។ **នេះជាទុក្ខមានវិបត្តិនៃគភ៌ជាមូល** ៕

## សម្តែងអំពីទុក្ខមានការប្រសូតិជាមូល

ទុក្ខឯណា រមែងកើតឡើងដល់សត្វអ្នកត្រូវខ្យល់កម្មជវាត របស់មាតាកំពុងប្រសូតិ បក់ឱ្យបញ្ច្រាស់ចុះទៅដោយលំដាប់ ចុះកាន់ផ្លូវកំណើត (យោនីមគ្គ) ដ៏គួរឱ្យខ្លាចក្រៃលែង ដូចពួយលំពែងចោលទៅតាមផ្លូវយោនីមគ្គ ដែលចង្អៀតក្រៃលែង ដូចដំរីធំត្រូវរុញចេញតាមប្រហោងមេសោ និងដូចសត្វនរកត្រូវភ្នំគ្របសង្កត់ឱ្យខ្ទេចជាលំអិតទៅ ។ **ទុក្ខនេះ ឈ្មោះថា មានការប្រសូតិជាមូល** ៕

## សម្តែងអំពីទុក្ខមានការចេញចាកគភ៌ជាមូល

ម្យ៉ាងទៀត ទុក្ខឯណា កើតដល់សត្វអ្នកប្រសូតិហើយ ដែលមានសរីរៈ

នៅខ្ចីដូចនឹងដំបៅថ្មី ក្នុងគ្រាដែលគេយកដៃចាប់មុជទឹកជម្រះ និងជូតដោយកំណាត់សំពត់ជាដើម ក៏ហាក់ដូចជានឹងចាក់ និងវះកាត់ដោយមុខម្ជុល និងកាំបិតកោរ ។

**នេះជាទុក្ខមានការចេញចាកគភ៌នៃមាតាជាមូល ៕**

## សម្តែងអំពីទុក្ខមានសេចក្តីព្យាយាមរបស់ខ្លួនជាមូល

ខាងមុខពីនេះទៅ ក្នុងបវត្តិកាល ទុក្ខឯណារមែងមានដល់សត្វអ្នកសម្លាប់ខ្លួនឯងក្តី អ្នកប្រកបសេចក្តីព្យាយាមដោយការធ្វើខ្លួន ឱ្យក្តៅក្រហាយ ឱ្យក្តៅក្រហាយទូទៅ ដោយអំណាចនៃវត្តមានអចេលកវត្តជាដើមក្តី អ្នកអត់អាហារ និងអ្នកចងខ្លួនដោយអំណាចនៃសេចក្តីក្រោធក្តី ។ **នេះជាទុក្ខមានការព្យាយាមរបស់ខ្លួនជាមូល ៕**

## សម្តែងអំពីទុក្ខមានសេចក្តីព្យាយាមរបស់អ្នកដទៃជាមូល

ម្យ៉ាងទៀត ទុក្ខណា រមែងកើតឡើងដល់អ្នកសោយទុក្ខ មានត្រូវគេសម្លាប់ និងចងជាដើមពីអ្នកដទៃ, **នេះជាទុក្ខមានការព្យាយាមរបស់អ្នកដទៃជាមូល** ។

សូម្បីជាតិនេះ ក៏ជាវត្ថុទីតាំងនៃទុក្ខទាំងអស់នេះ ដោយប្រការដូច្នេះ; ព្រោះហេតុដូច្នោះ ទើបលោកពោលពាក្យគាថានេះទុកថា ៖

**“ជាយេថ នោ ចេ នរកេសុ សត្តោ តត្ថគ្គិទាហាទិកមប្បសយ្ហំ**
**លភេថ ទុក្ខំ ន កុហឹ បតិដ្ឋំ ឥច្ចាហ ទុក្ខាតិ មុនីធ ជាតឹ ។**

ប្រសិនបើថា សត្វមិនគប្បីកើតក្នុងនរកសោត គេក៏មិនគប្បី

បានទុក្ខ មានការត្រូវគេដុត ឱ្យឆេះក្នុងនរកនោះជាដើម នរណា។ អត់សង្កត់មិនបាន មិនមានទីពឹងក្នុងទីណា។ ព្រោះហេតុនោះ ទើបព្រះមុនីត្រាស់ការកើតក្នុងលោកនេះថា ជាទុក្ខ ។

**ទុក្ខំ តិរច្ឆេសុ កសាបតោទ-**
**ទណ្ឌាភិឃាដាទិភវំ អនេកំ**
**យន្តំ កថំ តត្ថ ភវេយ្យ ជាតឹ វិនា**
**តហឹ ជាតិ តតោបិ ទុក្ខា ៥**

សេចក្ដីទុក្ខ ក្នុងពួកសត្វតិរច្ឆានមានរំពាត់ខ្សែតី មានជន្លួញ និងលំពែងឈើជាដើម មិនមែនតិច វៀរជាតិចេញហើយ ទុក្ខគប្បីមានក្នុងពួកសត្វបាន យ៉ាងណា សូម្បីព្រោះហេតុនោះ ជាតិទើបឈ្មោះថា ជាទុក្ខក្នុងពួកសត្វនោះ ។

**បេតេសុ ទុក្ខំ បន ខុប្បិបាសា-**
**វាតាតបាទិប្បភវំ វិចិត្តំ**
**យស្មា អជាតស្ស ន តត្ថ អត្ថិ**
**តស្មាបិ ទុក្ខំ មុនិ ជាតិមាហ ៥**

ម្យ៉ាងទៀត ទុក្ខព្រោះស្រេកឃ្លានក្នុងពួកប្រេត មានការកើតពីខ្យល់ និងកម្ដៅថ្ងៃជាដើមមានប្រភេទផ្សេង។ រមែងមិនមានដល់សត្វអ្នកមិនកើតក្នុងពួកប្រេត សូម្បីព្រោះហេតុនោះ លោកអ្នកប្រាជ្ញក៏ពោលថា ជាតិ ( ការកើត) ជាទុក្ខ ។

**និព្វន្ធការេ ច អសយ្ហសីតេ**
**លោកន្តរេ យំ អសុរេសុ ទុក្ខំ**

**ន តំ ភវេ តត្ថ ន ចស្ស ជាតិ**
**យតោ អយំ ជាតិ តតោបិ ទុក្ខា ។**

ម្យ៉ាងទៀត ទុក្ខក្នុងពួកអសុរកាយ ក្នុងលោកន្តរ ដែលត្រជាក់ធន់មិនបាន ងងឹតសូន្យសុង គប្បីមានក្នុងពួកអសុរកាយ ព្រោះមិនមានការកើត ព្រោះហេតុនោះឯង ជាតិនេះ ក៏ឈ្មោះថា ជាទុក្ខ ។

**យញ្ចាបិ គូថនរកេ វិយ មាតុ គព្ភេ**
**សត្តោ វសញ្ចិរមតោ ពហិ និក្ខមញ្ច**
**បប្បោតិ ទុក្ខមតិ ឃោរមិទំបិ នត្ថិ**
**ជាតឹ វិនា ឥតិបិ ជាតិរយំ ហិ ទុក្ខា**

ម្យ៉ាងវិញទៀត សត្វនៅក្នុងគភ៌មាតា ហាក់បីដូចជាគូថនរក ដោយនៅរហូតអស់កាលយូរក្តី, ចេញចាកគភ៌មកនៅខាងក្រៅក្តី រមែងដល់នូវទុក្ខឯណា ដ៏ខ្លាំងក្លា, សូម្បីទុក្ខនេះ វៀរចាកការកើតចេញរមែងមិនមានឡើយ; សូម្បីព្រោះហេតុនោះ ការកើតនោះឯង ឈ្មោះថា **ជាទុក្ខ** ។

**កឹ ភាសិតេន ពហុនា ននុ យំ កុហិញ្ចិ**
**អត្ថីធ កិញ្ចិរបិ ទុក្ខមិទំ កទាចិ**
**នេវត្ថិ ជាតិវិរហេ យទតោ មហេសិ**
**ទុក្ខាតិ សព្វបឋមំ ឥមមាហ ជាតឹ**

ប្រយោជន៍អ្វីដោយការនិយាយច្រើនទៅ សូម្បីទុក្ខណាៗ ក្នុងលោកនេះ ដែលមានក្នុងទីណាៗ នេះ នឹងមិនមានក្នុងទីណាៗ ព្រោះវៀរចាកការកើត មិនមែនឬ ? ព្រោះហេតុនោះ ព្រះមហា-

ឫស្សី ទើបត្រាស់ការកើតនេះថា **ជាទុក្ខមុនទុក្ខទាំងអស់** ៕

## សំម្តែងអំពីជរានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសនៃ**ជរា**តទៅ ៖

បទថា "**ជរា** = ការគ្រាំគ្រា" ជាសេចក្តីចំពោះខ្លួនដោយភាវៈរបស់ខ្លួន ។ បទថា "**ជីរណតា** = ភាវៈដែលគ្រាំគ្រា" ជាសព្ទសម្តែងដល់អាការៈ ។ សព្ទទាំង ៣ មានពាក្យថា "**ខណ្ឌិច្ចំ** = ការដែលធ្មេញបាក់" ជាដើម ជាសព្ទសម្តែងដល់កិច្ច ក្នុងកាលបើកន្លងពេលហួសទៅ, ពីរសព្ទក្រោយជាការអធិប្បាយសេចក្តីតាមប្រក្រតី[១០៥] ។

ពិតណាស់ ជរានេះព្រះមានជោគទ្រង់សម្តែងដោយភាវៈជារបស់ខ្លួន ដោយបទថា **ការគ្រាំគ្រា** នេះ, ព្រោះហេតុនោះ បទថា **ការគ្រាំគ្រា** នេះ ទើបជាអត្ថរូបចំពោះខ្លួនដោយសភាពនៃបទថា **ការគ្រាំគ្រា** នោះ ។ ទ្រង់សម្តែងជរានោះ ដោយអាការ ដោយបទថា "**ជីរណតា** = ការគ្រាំគ្រា" ព្រោះហេតុនោះ សព្ទថា **ជីរណតា** នេះ ទើបជាការអធិប្បាយដល់អាការរបស់ជរានោះ ។

ដោយបទថា "**ខណ្ឌិច្ចំ**" នេះ ព្រះភគវាទ្រង់សម្តែងជរាដោយកិច្ច គឺការធ្វើភាពជាអ្នកមានធ្មេញ និងក្រចកបាក់ ក្នុងកាលដែលកន្លងហួសពេលបាត់ទៅ ។ ដោយបទថា "**បាលិច្ចំ** = ភាពដែលសក់ស្កូវ" នេះ ទ្រង់សម្តែងជរា ដោយកិច្ច គឺការធ្វើភាពជាអ្នកមានសក់ និងរោមស្កូវ ។ ដោយបទថា "**វលិត្តចតា** = ភាពដែល

---

[១០៥] គឺ **អាយុនោ សង្ខានិ** = ការអស់ទៅនៃអាយុ និង**ឥន្ទ្រិយានំ បរិបាកោ** = ការចាស់ទុំនៃឥន្ទ្រិយ ។

ស្បែកជ្រីវជ្រួញ” នេះ ទ្រង់សម្តែងជរាដោយកិច្ច គឺការធ្វើភាពជាអ្នកមានសាច់យារហើយ, ស្បែកយាកហើយ; ព្រោះហេតុនោះ សព្ទទាំង ៣ មានជាអាទិ៍ថា **ខណ្ឌិច្ចំ** = ការដែលធ្មេញបាក់ទាំងនេះ ទើបជាសព្ទសម្តែងកិច្ចក្នុងកាលដែលកន្លងហួសផុតទៅរបស់ជរានោះ ។ ដោយសព្ទ ៣ នោះ ព្រះអង្គទ្រង់សម្តែង **ឆាកដជរា** ថា ជរានោះជាធម្មជាតិប្រាកដហើយ ដោយអំណាចនៃការឃើញភាវៈទាំងនេះ ជារបស់ពិការ; ប្រៀបដូចប្រឡាយទឹក ឬខ្យល់ ឬក៏ភ្លើង រមែងប្រាកដ ព្រោះសេចក្តីដែលស្មៅ និងដើមឈើជាដើមបាក់រលំហើយ ឬត្រូវភ្លើងឆេះ និងផ្លូវដែលប្រព្រឹត្តទៅហើយនោះ មិនមែនទឹកជាដើមនោះឡើយ សេចក្តីនេះយ៉ាងណា, ផ្លូវដើររបស់ជរា ក៏យ៉ាងនោះដែរ រមែងប្រាកដក្នុងទីមានធ្មេញជាដើម ដោយអំណាចលក្ខណៈមានភាវៈដែលបាក់ជាដើម, នរណា១ សូម្បីធ្មេចភ្នែកហើយក៏ដឹង; តែដោយលក្ខណៈមានភាវៈដែលធ្មេញបាក់ជាដើមប៉ុណ្ណោះ, មិនមែនជរា ព្រោះជរាមិនមែនជាវត្ថុដែលគប្បីដឹងច្បាស់ដោយភ្នែកទេ ។

ម្យ៉ាងទៀត ជរានោះ ព្រះអង្គទ្រង់សម្តែងដោយប្រក្រតី ពោលគឺការអស់អាយុ និងការចាស់ទ្រុឌទ្រោមនៃឥន្ទ្រិយមានចក្ខុន្ទ្រិយជាដើម ដែលប្រាកដចំពោះក្នុងកាលកន្លងហួសទៅប៉ុណ្ណោះ ដោយបទទាំងនេះថា “**អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ** = ការអស់នៃអាយុ និងការចាស់ទ្រុឌទ្រោមនៃឥន្ទ្រិយ” , ព្រោះហេតុនោះ ពីរសព្ទក្រោយពួកនេះ គប្បីជ្រាបថា ជាសព្ទអធិប្បាយសេចក្តីតាមប្រក្រតីរបស់ជរានោះ; បណ្តាបទទាំង ២ គឺ (ការអស់ទៅនៃអាយុ និងការចាស់ទ្រុឌទ្រោមនៃឥន្ទ្រិយ) នោះ ព្រោះអាយុរបស់អ្នកដែលដល់ជរាហើយ រមែងអស់

ទៅ; ព្រោះហេតុដូច្នោះ ទើបព្រះមុនីត្រាស់នូវជរាដោយ**ផលូបចារន័យ**ថា “**ការអស់ទៅនៃអាយុ**” ។ ម្យ៉ាងវិញទៀត ព្រោះឥន្ទ្រិយមានចក្ខុន្ទ្រិយជាដើម ក្នុងវេលានៅក្មេងជារបស់ស្រស់ល្អសោភា អាចទទួលវិស័យរបស់ខ្លួនសូម្បីល្អិត បានដោយងាយមែនពិត កាលបើគេដល់ជរាហើយ អន់ហើយ ស្រពាប់ស្រពោន មិនក្លៀវក្លា មិនអាចទទួលវិស័យរបស់ខ្លួនសូម្បីគ្រោតគ្រាតបាន, ព្រោះហេតុដូច្នេះ ទើបព្រះអង្គត្រាស់ថា “**ឥន្ទ្រិយានំ បរិបាកោ** = ការចាស់ទ្រុឌទ្រោមនៃឥន្ទ្រិយ” ដូច្នេះ ដោយផលូបចារន័យមែនពិត ៕

## សម្តែងអំពីជរា ២ យ៉ាង

ក៏សូម្បីជរាទាំងអស់ ដែលទ្រង់លើកឡើងសម្តែងទុកយ៉ាងនេះ មាន ២ យ៉ាង គឺ

**១-បាកដជរា** ជរាដែលប្រាកដ

**២-បដិច្ឆន្នជរា** ជរាដែលមិនប្រាកដ (បិទបាំង) ។

បណ្តាជរាទាំង ២ នោះ ជរាក្នុងរូបធម៌ ឈ្មោះថា **បាកដជរា** ព្រោះសម្តែងភាវៈ មានការបាក់ជាដើមក្នុងអវយវៈមានធ្មេញជាដើម, ចំណែកជរាក្នុងអរូបធម៌ ឈ្មោះថា **បដិច្ឆន្នជរា** ព្រោះមិនសម្តែងការពិការដូចនោះ ។ ក្នុងជរាទាំងពីរនោះ ភាវៈមានភាពជាអ្នកមានធ្មេញបាក់ជាដើមនេះឯង រមែងប្រាកដភាវៈជាអ្នកមានធ្មេញបាក់នោះ ជាវណ្ណៈពណ៌ប៉ុណ្ណោះ ព្រោះសេចក្តីដែលអវយវៈមានធ្មេញជាដើម ដូច្នោះ ជាវត្ថុដែលដឹងបានដោយងាយ បុគ្គលបានឃើញវណ្ណៈពណ៌នោះ ដោយចក្ខុ

ហើយ ក៏គិតដោយមនោទ្វារ រមែងជ្រាបជរាថា “ខន្ធទាំងនេះ ត្រូវជរាប្រហារហើយ” ដូចការក្រឡេកមើលវត្ថុទាំងឡាយមានស្មែងគោជាដើម ដែលចងទុកក្នុងទីជាទីតាំងនៅនៃទឹក ក៏នឹងជ្រាបបានថា ទឹកមាននៅខាងក្រោមដូច្នោះ ។

ជរានេះមាន ២ យ៉ាង គឺ

**១-អវីចិជរា** ជរាមិនមានស្លាកស្នាម

**២-សវីចិជរា** ជរាមានស្លាកស្នាម ។

បណ្ដាជរាទាំងពីរនោះ ជរា (ការចាស់) របស់កែវមណី មាស ប្រាក់ កែវប្រវាឡ ដួងចន្ទ និងដួងអាទិត្យជាដើម ឈ្មោះថា **អវីចិជរា** ព្រោះភាពពិសេសនៃពណ៌ជាដើម ក្នុងចន្លោះៗ ជារបស់ដែលដឹងបានដោយលំបាក ដូចការប្លែកនៃពណ៌ជាដើមរបស់សត្វមានជីវិតក្នុងពួកមន្ទសកៈជាដើម និងវត្ថុមិនមានជីវិតក្នុងពួកនៃផ្កាឈើ និងស្លឹកឈើខ្ចីជាដើម ។ មានអធិប្បាយថា ជានិរន្តរជរា គឺជរាមិនមានចន្លោះ ។ តែជរា (ការចាស់) ក្នុងវត្ថុដទៃៗ ក្រៅពីវត្ថុមានកែវមណីជាដើមនោះ ឈ្មោះថា **សវីចិជរា** ព្រោះការប្លែកនៃពណ៌ជាដើមក្នុងចន្លោះៗ ជាវត្ថុ ដែលដឹងបានដោយងាយ ។

ក្នុងជរាទាំងពីរនោះ **សវីចិជរា** នោះ គប្បីជ្រាបយ៉ាងនេះ ដោយអំណាចនៃឧបាទន្និករូប និងអនុបាទន្និករូប ពិតណាស់ ឈ្មោះថា ធ្មេញ ទឹកនោមក្មេងតូចៗ រមែងកើតមុនដំបូងបង្អស់, ធ្មេញនោះមិនថាវរៈ (មាំទាំ); តែកាលបើធ្មេញបាក់ហើយ ធ្មេញនេះក៏តាំងឡើងទៀត; ធ្មេញ (ពិត) ទាំងនោះមុនដំបូងជាពណ៌ស, រមែងជាពណ៌ខ្មៅក្នុងកាលដែលត្រូវខ្យល់ គឺជរាប៉ះខ្ទប់, ម្យ៉ាងទៀត សក់ មុនដំបូង

រមែងជាពណ៌ក្រហមខ្លះ ខ្មៅខ្លះ សខ្លះ ។ ចំណែកស្បែករមែងមានពណ៌ ក្រហម; កាលបើបុគ្គលកំពុងចម្រើន១ បុគ្គលសក៏នឹងប្រាកដជាពណ៌ស បុគ្គលខ្មៅ ក៏នឹងប្រាកដជាពណ៌ខ្មៅ; តែកាលបើត្រូវខ្យល់ គឺជរាប៉ះខ្ទប់ហើយ ស្បែកនោះ ក៏នឹងចាប់មានស្នាមជ្រួញ ។

សូម្បីស្រូវទាំងអស់ក្នុងវេលាដែលគេសាបព្រោះហើយ រមែងដុះចេញជាពណ៌ស, ខាងក្រោយមកនឹងជាពណ៌ខៀវ; តែក្នុងវេលាត្រូវខ្យល់ គឺជរាខ្ទប់ហើយក៏ជាពណ៌លឿង; នឹងសម្តែងសូម្បីដោយគ្រាប់ស្វាយក៏គួរដូចគ្នា ។ ពាក្យថា **"អយំ វុច្ចតិ ជរា** = នេះឈ្មោះថា ជរា" សេចក្តីថា នេះតថាគត ហៅថា **ជរា** ។

**ក៏ជរានេះឯង** ៖

-**ខន្ធបរិបាកលក្ខណា** មានការទ្រុឌទ្រោមនៃខន្ធ ជាលក្ខណៈ

-**មរណូបនយនរសា** មានការនាំចូលទៅរកសេចក្តីស្លាប់ជាកិច្ច

-**យោព្វនវិនាសបច្ចុប្បដ្ឋានា** មានការវិនាសវ័យកំលោះក្រមុំជាបច្ចុប្បដ្ឋាន ៕

## គប្បីជ្រាបអត្ថនៃជរាជាទុក្ខ

ក៏គប្បីជ្រាបវិនិច្ឆ័យក្នុងខថា **គប្បីជ្រាបអត្ថនៃជរាជាទុក្ខ** នេះ តទៅ ៖

សូម្បីជរានេះខ្លួនឯងមិនជាទុក្ខ, តែព្រះភគវាត្រាស់ថា **ជាទុក្ខ** ព្រោះជាវត្ថុ (ទីតាំង) របស់ទុក្ខ ។

**សួរថា** ជាទីតាំងរបស់ទុក្ខណា ?

ឆ្លើយថាៈ របស់ទុក្ខផ្លូវកាយ និងទុក្ខ (ផ្លូវចិត្ត) គឺទោមនស្ស ។

ពិតណាស់ អត្តភាពរបស់មនុស្សដែលជរាហើយរមែងទុព្វល ដូចរទេះចាស់គ្រាំគ្រា, កាលបើគេព្យាយាមដើម្បីនឹងឈរ ឬទៅ ឬក៏អង្គុយ រមែងកើតទុក្ខផ្លូវកាយយ៉ាងខ្លាំងក្លា ។ កាលបើបុត្រ និងភរិយាមិនបានសង្កេតទុកជាមុន ក៏កើតទោមនស្ស ។ គប្បីជ្រាបជរាជាទុក្ខ ដោយសេចក្តីជាទីតាំងនៃទុក្ខទាំងពីរ មានប្រការដូច្នេះ ។

**ម្យ៉ាងទៀត** លោក ( ប្រព័ន្ធ) គាថាទុកថា ៖

**អង្គានំ សិថិលភាវា ឥន្ទ្រិយានំ វិការតោ**
**យោព្វនស្ស វិនាសេន ពលស្ស ឧបឃាតតោ ។**
**វិប្បវាសា សតាទីនំ បុត្តទារេហិ អត្តនោ**
**អប្បសាទនីយតោចេវ ភិយ្យោ ពាលត្តបត្តិយា ។**
**បប្បោតិ ទុក្ខំ យំ មច្ចោ កាយិកំ មានសំ តថា**
**សព្វមេតំ ជរាហេតុ យស្មា តស្មា ជរា ទុក្ខា ។**

ក៏សត្វរមែងដល់នូវសេចក្តីទុក្ខណា ទាំងផ្លូវកាយទាំងផ្លូវចិត្ត ព្រោះការដែលអវយវៈរខេករខាក, ព្រោះការពិការនៃឥន្ទ្រិយ ព្រោះការវិនាសនៃវ័យ ( កំឡោះ ក្រមុំ), ព្រោះកំពុងត្រូវថយកម្លាំង; ព្រោះប្រាសចាកគុណមានសតិជាដើម ឯបុត្រភរិយារបស់ខ្លួន ក៏មិនជ្រះថ្លា នឹងដល់ភាពជាមនុស្សពាល (វិនាស) យ៉ាងក្រៃលែង, ទុក្ខទាំងអស់នេះ មានជរាជាហេតុ ព្រោះហេតុដូច្នោះ ជរា ទើបជាទុក្ខពិត១ ៕

## សម្តែងអំពីមរណនិទ្ទេសដោយសន្មតិ

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិទ្ទេសនៃមរណៈ** តទៅ ៖

ក៏ឈ្មោះថា **ចុតិ** ដោយអំណាចនៃសត្វអ្នកឃ្លាត (ចាកភព), ពាក្យថា ចុតិនេះ ជាពាក្យពោលធម្មតារបស់ចុតិ ដែលជាខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ។

បទថា **"ចវនតា** = ភាវៈដែលឃ្លាត" ជាបទសម្តែងខែដល់លក្ខណៈដោយពាក្យថាភាវៈ ។

បទថា **"ភេទោ** = ការទម្លាយ" ជាបទអធិប្បាយការកើតឡើងនៃភង្គៈ (ការបែកធ្លាយ) របស់ខន្ធទាំងឡាយដែលចុតិ ។ បទថា **"អន្តរធានំ** = ការបាត់ទៅ" ជាបទអធិប្បាយសេចក្តីមិនមានឋានៈដោយបរិយាយយ៉ាងណានីមួយ របស់ចុតិ ខន្ធដែលបែកធ្លាយ ដូចឆ្នាំងដែលបែកទៅដូច្នោះ ។ បទថា **"មច្ចុមរណំ** = ម្រឹត្យូវ គឺសេចក្តីស្លាប់" , មច្ចុអ្នកធ្វើនូវទីបំផុត ឈ្មោះថា **កាលៈ**, ការធ្វើរបស់កាលៈនោះ ឈ្មោះថា **កាលកិរិយា** (ការធ្វើកាលៈ)។ មរណៈដោយសន្មតិ ជាពាក្យដែលខ្ញុំសម្តែងហើយត្រឹមតែប៉ុណ្ណេះ ៕

## សម្តែងអំពីមរណនិទ្ទេសដោយបរមត្ថ

ឥឡូវនេះ ដើម្បីកំណត់មរណៈដោយបរមត្ថ ទើបព្រះភគវាទ្រង់ត្រាស់ថា **"ខន្ធានំ ភេទោ** = ការបែកធ្លាយនៃខន្ធ" ជាដើម ។

ពិតណាស់ ពោលដោយបរមត្ថ **ខន្ធាយេវ ភិជ្ជន្តិ** = **ខន្ធទាំងឡាយប៉ុណ្ណោះរមែងបែកធ្លាយទៅ, ន សត្តោ នាម កោចិ មរតិ** = ឈ្មោះថា **សត្វណាៗ រមែងស្លាប់**

**ទៅមិនមាន**; តែកាលបើខន្ធកំពុងបែក សត្វក៏រមែងមានវោហារថាកំពុងស្លាប់, កាលបើខន្ធបែកធ្លាយហើយ ក៏មានវោហារថា សត្វស្លាប់ហើយ; ក៏ក្នុងអធិការនេះ ការបែកធ្លាយនៃខន្ធទាំងឡាយ ដោយអំណាចនៃ**ចតុវោការភព** និង**បញ្ចវោការភព**, ការលះបង់**កឡេវរៈ** (សាកសព) ដោយអំណាចនៃឯកវោការភព ។ ម្យ៉ាងទៀត ការបែកធ្លាយនៃខន្ធទាំងឡាយ រមែងមានដោយអំណាចនៃខន្ធ ៤ (ចតុវោការភព), គប្បីជ្រាបការលះបង់សាកសពទុក ដោយអំណាចនៃបទទាំងពីរដ៏សេស ។ ព្រោះហេតុអ្វី ? ព្រោះការកើតនៃ**កឡេវរៈ** ពោលគឺរូបកាយ រមែងមានសូម្បីក្នុងភពទាំងពីរ; ម្យ៉ាងវិញទៀត ព្រោះខន្ធទាំងក្នុងចាតុម្មហារាជិកាជាដើម រមែងបែកធ្លាយទៅមែនពិត, មិនមានអ្វីត្រូវលះចោល, ព្រោះហេតុដូច្នោះ ការបែកធ្លាយនៃខន្ធទាំងឡាយ រមែងមានដោយអំណាចនៃខន្ធក្នុងចាតុម្មហារាជិកាជាដើម; ការលះបង់សាកសព រមែងមានក្នុងពួកមនុស្សជាដើម ។ ក៏ក្នុងនិទ្ទេសនេះ ព្រះសយម្ភូត្រាស់សេចក្តីស្លាប់ ដោយហេតុនៃការលះបង់រាងកាយថា **“ការលះបង់សាកសព”** ដូច្នេះ ។

ដោយបទថា **“ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ** = ការចូលទៅកាត់ផ្តាច់នូវជីវិតិន្ទ្រិយ” នេះ ព្រះភគវាទ្រង់សម្តែងថា ឈ្មោះថា ការស្លាប់របស់ខន្ធដែលជាប់ទាក់ទងដោយឥន្ទ្រិយប៉ុណ្ណោះ, ឈ្មោះថា ការស្លាប់របស់ខន្ធមិនជាប់ទាក់ទងដោយឥន្ទ្រិយរមែងមិនមាន; តែពាក្យថា **“ស្រូវងាប់, ដើមឈើងាប់”** នេះ គ្រាន់តែជាវោហារប៉ុណ្ណោះ; តែកាលបើពោលដោយអត្ថហើយ ពាក្យពោលដូច្នេះ រមែងសម្តែងដល់ការដែលសព្វវត្ថុទាំងឡាយមានស្រូវជាដើម ជារបស់អស់ទៅ សូន្យទៅមែនពិត ។

ពាក្យថា "**ឥទំ វុច្ចតិ មរណំ** = នេះហៅថា មរណៈ" សេចក្តីថា សូម្បីទាំងអស់នេះ តថាគតក៏ឱ្យឈ្មោះថា **មរណៈ** ។

មួយ៉ាងទៀត ក្នុងពាក្យថា **មរណៈ** នេះ គប្បីជ្រាបសូម្បីប្រភេទនេះ គឺ ៖

- **ខណិកមរណៈ** ស្លាប់គ្រប់ខណៈ
- **សម្មុតិមរណៈ** ស្លាប់ដោយសន្មតិ
- **សមុច្ឆេទមរណៈ** ស្លាប់អស់រលីង ។

បណ្តាមរណៈទាំងនោះ ការបែកធ្លាយនៃរូបធម៌ និងអរូបធម៌ ក្នុងបវត្តិកាល ឈ្មោះថា **ខណិកមរណៈ** ។ ការស្លាប់នេះថា លោកតិស្សៈស្លាប់, លោក**បុស្សៈ**ស្លាប់ជាដើម ឈ្មោះថា **សម្មុតិមរណៈ** ។ ការធ្វើកាលកិរិយារបស់ព្រះខីណាស្រព មិនមានបដិសន្ធិទៀត ឈ្មោះថា **សមុច្ឆេទមរណៈ** ។ តែក្នុងនិទ្ទេសនេះ ព្រះអង្គបំណងយកសម្មតិមរណៈ; សូម្បីពាក្យថា "ការស្លាប់ព្រោះការកើតជាបច្ច័យ, ការស្លាប់ដោយសេចក្តីព្យាយាម, ការស្លាប់ដោយនាទី (ភារៈរបស់ខ្លួន), ការស្លាប់ព្រោះអស់អាយុ" **ក៏ជាឈ្មោះនៃការស្លាប់ដោយសន្មតិនោះឯង** ។

**ការស្លាប់ដោយសន្មតិនេះឯង** ៖

- **ចុតិលក្ខណំ** មានការឃ្លាតចាកភព ជាលក្ខណៈ
- **វិយោគរសំ** មានការព្រាត់ប្រាសទៅ ជាកិច្ច
- **វិប្បវាសបច្ចុប្បដ្ឋានំ** មានការប្រាសចាកភពចាស់ ជាបច្ចុប្បដ្ឋាន ៕

## គប្បីជ្រាបវិនិច្ឆ័យអត្ថនៃមរណៈជាទុក្ខ

ក៏គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះថា **គប្បីជ្រាបអត្ថនៃមរណៈជាទុក្ខ** តទៅ ៖

សូម្បីមរណៈនេះ ខ្លួនឯងក៏មិនជាទុក្ខ, តែព្រះអង្គត្រាស់ថា **ជាទុក្ខ** ព្រោះវត្ថុជាទីតាំងនៃទុក្ខ; ព្រោះវេទនាមានក្នុងសរីរៈសូម្បីកើតក្នុងទីបំផុតនៃការស្លាប់ និងដុតសរីរៈ ដូចគប់ស្មៅមានភ្លើងដែលគេកាន់បញ្ច្រាស់ខ្យល់; ក្នុងវេលាដែលនិមិត្តនៃនរកជាដើមប្រាកដ ទោមនស្សដ៏ខ្លាំងក្លារមែងកើតឡើង ។

គប្បីជ្រាបមរណៈថាជាទុក្ខ ដោយវត្ថុជាទីតាំងនៃទុក្ខ សូម្បីទាំងពីរនេះដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ៖

**"ព្រោះការស្លាប់នេះ វត្ថុជាទីតាំងនៃទុក្ខណា របស់មនុស្សជិតស្លាប់ដែលជាមនុស្សលាមក ដែលឃើញនិមិត្ត មានកម្មដ៏លាមកជាដើម ដោយលំដាប់ សម្រាប់មនុស្សល្អ អ្នកមិនអាចសង្កត់សេចក្ដីប្រាសចាកវត្ថុដែលជាទីស្រឡាញ់ (គឺសត្វ និងសង្ខារដែលជាទីស្រឡាញ់) បាន សូម្បីទុក្ខដែលកើតក្នុងសរីរៈ មានរោគខ្យល់ដែលកាត់ទីត និងសរសៃជាដើម ក៏សង្កត់មិនបាន កែខៃមិនបាន ដែលមានដល់ពួកសត្វកំពុងត្រូវរោគចាក់ដោតជាធម្មតា ដោយមិនប្លែកគ្នានេះ ព្រោះហេតុដូច្នោះ មរណៈនេះ ទើបព្រះភគវាត្រាស់ថា ជាទុក្ខមែនពិត"** ៕

## សម្ដែងអំពីទុក្ខទាំង ៣ ដូចជាសត្រូវ ៣ នាក់

ន័យមួយទៀត ឈ្មោះថា ជាតិ ជរា និងមរណៈទាំងនេះ រមែងត្រាច់ស្វែងរកឱកាស ដូចបច្ចាមិត្តអ្នកសម្លាប់សត្វពួកនេះ គឺប្រៀបដូចសត្រូវ ៣ នាក់ របស់

បុរសអ្នកឃ្លាំចាំមើលឱកាស មនុស្សម្នាក់ពោលថា “យើងនឹងពោលសរសើរព្រៃឯណោះ ហើយសឹមនាំគេចូលទៅក្នុងព្រៃនោះ, ក្នុងរឿងនេះ មិនមានអ្វីដែលធ្វើបានដោយលំបាកសម្រាប់យើងទេ” ; អ្នកទី ២ ពោលថា “ក្នុងវេលាដែលខ្ញុំបាននាំមនុស្សនេះទៅ យើងនឹងវាយវាឱ្យទុព្វលភាព, ក្នុងរឿងនេះមិនមានអ្វីលំបាកសម្រាប់យើង” ។ អ្នកទី ៣ ពោលថា “កាលបើអ្នកវាយធ្វើឱ្យមនុស្សនេះអស់កម្លាំងហើយ ឈ្មោះថា យកដាវកាត់ក្បាល ចូរជានាទី (កិច្ច) របស់យើងចុះ” ។ សត្រូវទាំង ៣ នោះ លុះពោលយ៉ាងនោះហើយ ក៏ធ្វើដូច្នោះ ។

ក្នុងការឧបមានោះ ឈ្មោះថា ការគ្រាចេញចាកវង្សរបស់មិត្ត និងញាតិហើយឱ្យកើតក្នុងភពណានីមួយ ដូចវេលាដែលសត្រូវទី ១ ពោលសរសើរព្រៃហើយនាំបុរសនោះទៅក្នុងព្រៃនោះ គប្បីជ្រាបថា ជានាទីរបស់ជាតិ (ការកើត), ការដែលខន្ធកើតឡើងហើយធ្លាក់ទៅ (គឺខ្សោយកម្លាំងចុះ) ហើយធ្វើឱ្យជាអ្នកពឹងមនុស្សដទៃ នឹងមានគ្រែដេកជាដើមខាងមុខ ដូចសត្រូវទី ២ វាយធ្វើឱ្យជាអ្នកទុព្វល គប្បីជ្រាបថាជានាទីរបស់ជរា, ការឱ្យដល់សេចក្ដីអស់ជីវិត ដូចសត្រូវទី ៣ យកដាវកាត់ក្បាល គប្បីជ្រាបថា ជានាទីរបស់មរណៈដូច្នោះ ។

ប្រការមួយទៀត ក្នុងទុក្ខទាំង ៣ គប្បីជ្រាប**ជាតិទុក្ខ** ដូចការចូលកាន់ផ្លូវកន្តារ (លំបាក) ធំដែលមានទោស, គប្បីជ្រាប**ជរាទុក្ខ** ដូចភាពជាអ្នកទុព្វលដែលអត់បាយ និងទឹកក្នុងផ្លូវកន្តារនោះ ។ គប្បីជ្រាប**មរណទុក្ខ** ដូចការឱ្យដល់សេចក្ដីវិនាសដោយគ្រឿងចង្រៃតជាដើម ដល់មនុស្សទុព្វល អ្នកមានសេចក្ដីព្យាយាម ឱ្យឥរិយាបថប្រព្រឹត្តទៅ ត្រូវខ្ចាត់ចេញហើយមែនពិត ៕

## សម្ដែងអំពីសោកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិទ្ទេសនៃសោកៈ** តទៅ ៖

សភាវៈណារមែងអស់ទៅ អធិប្បាយថា រមែងវិនាសទៅ គឺរមែងកម្ចាត់ប្រយោជន៍ និងសេចក្ដីសុខ ព្រោះហេតុនោះ សភាវៈនោះ ទើបឈ្មោះថា **ព្យសនៈ** = ការវិនាស; ការវិនាសញាតិ ឈ្មោះថា **ញាតិព្យសនៈ**, អធិប្បាយថា ការអស់ញាតិ គឺការវិនាសទៅនៃញាតិដោយចោរភ័យ និងរោគភ័យជាដើម **គឺដោយការវិនាស នៃញាតិនោះ** ។

បទថា "**ផុដ្ឋស្ស** = របស់អ្នកដែលត្រូវសេចក្ដីវិនាសពាល់ត្រូវ" បានដល់របស់បុគ្គលដែលសេចក្ដីវិនាសជាន់ពន្លិចហើយ គ្របសង្កត់ហើយ គឺប្រកបព្រមហើយ; សូម្បីក្នុងពាក្យដ៏សេស ក៏ន័យនេះដែរ ។

**តែសេចក្ដីប្លែកគ្នាមានដូច្នេះ ៖**

ការវិនាសនៃភោគៈទាំងឡាយ ឈ្មោះថា **ភោគព្យសនៈ**, អធិប្បាយថា ការអស់ភោគៈ គឺការវិនាសនៃភោគៈ ដោយអំណាចនៃភ័យមានរាជភ័យ និងចោរភ័យជាដើម ។ សេចក្ដីវិនាស គឺរោគ ឈ្មោះថា **រោគព្យសនៈ**; ពិតណាស់ រោគរមែងញ៉ាំងការមិនមានរោគ ឱ្យអស់ គឺរមែងឱ្យវិនាសទៅ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **ព្យសនៈ** ។ ការវិនាសនៃសីល ឈ្មោះថា **សីលព្យសនៈ** = ការវិនាសសីល; ពាក្យថា **សីលព្យសនៈ** នេះ ជាឈ្មោះរបស់ភាពជាអ្នកទ្រុស្តសីល ។ ការអស់នូវទិដ្ឋិដែលញ៉ាំងសម្មាទិដ្ឋិឱ្យវិនាសកើតឡើង ឈ្មោះថា **ទិដ្ឋិព្យសនៈ** = វិនាសទិដ្ឋិ [១០៦] ។

---

[១០៦] សំដៅដល់ សេចក្ដីវិនាសចាកសម្មាទិដ្ឋិ ។

ម្យ៉ាងទៀត បណ្ដាសេចក្ដីវិនាសទាំង ៥ នេះ ការវិនាស ២ ខាងដើម (គឺការវិនាសញាតិ និងការវិនាសភោគទ្រព្យ) ជារបស់នៅមិនកើតឡើង,តែការវិនាស ៣ ខាងក្រោយ (គឺវិនាសដោយរោគ សីល និងទិដ្ឋិ) ជារបស់កើតឡើងហើយ គឺត្រូវត្រៃលក្ខណ៍ពាល់ត្រូវហើយ ។

ម្យ៉ាងទៀត ការវិនាស ៣ ដំបូងមិនជាកុសល មិនជាអកុសល, ការវិនាស ២ គឺសីល និងទិដ្ឋិជាអកុសល ។

បទថា "**អញ្ញតរញ្ញតរេន** = យ៉ាងណានីមួយ" បានដល់ ដោយសេចក្ដីវិនាសយ៉ាងណានីមួយ ក្នុងបណ្ដាសេចក្ដីវិនាសទាំងឡាយ មានការវិនាសចាកមិត្ត និងអាមាត្យជាដើម ដែលបុគ្គលណានីមួយកាន់យកក៏ដោយ មិនកាន់យកក៏ដោយ ។

បទថា "**សមន្នាគតស្ស** = របស់បុគ្គលអ្នកប្រកប" បានដល់ របស់អ្នកជាប់ជំពាក់ គឺអ្នកនៅមិនទាន់រួចស្រឡះ ។

បទថា "**អញ្ញតរញ្ញតរេន ទុក្ខធម្មេន** = ដោយហេតុនៃទុក្ខ យ៉ាងណានីមួយ" បានដល់ ដោយហេតុដែលកើតឡើងនៃទុក្ខ គឺសេចក្ដីសោកយ៉ាងណាមួយ ។

បទថា "**សោកោ** = សេចក្ដីសោក" ក៏ឈ្មោះថា **សេចក្ដីសោក**ដោយអំណាចនៃការសោកសៅ; ពាក្យថា **សេចក្ដីសោក**នេះ ជាបទចំពោះខ្លួន ដោយសភាពជារបស់សេចក្ដីសោក ដែលកើតឡើងហើយដោយហេតុទាំងនេះ ។ បទថា "**សោចនា** = កិរិយាដែលសោក" បានដល់ អាការរបស់សេចក្ដីសោកសៅ; ភាវៈនៃសេចក្ដីសោកសៅ ឈ្មោះថា **សោចិតត្តំ** = សភាពសោកសៅ ។

បទថា "**អន្តោ សោកោ** = ការតានតឹងខាងក្នុង" បានដល់ ការសោក

សៅខាងក្នុង ។ បទទីពីរ **“អន្តោ បរិសោកោ** = ការរីងរៃខាងក្នុង” ទ្រង់បន្ថែមបទឧបសគ្គ ។ ពិតណាស់ ការសោកសៅនោះញ៉ាំងចិត្តខាងក្នុងឱ្យរីងស្ងួត, ឱ្យស្ងួតដោយជុំវិញហើយកើតឡើង ព្រោះហេតុដូច្នោះ ទើបត្រាស់ហៅថា “ការរីងស្ងួតខាងក្នុង និងសេចក្ដីតានតឹងជុំវិញ (ក្រៀមក្រំ) ខាងក្នុង” ។

បទថា **“ចេតសោ បរិជ្ឈាយនា** = ការក្រៀមក្រំចិត្ត” បានដល់ អាការដែលដុតចិត្ត; ព្រោះសេចក្ដីសោកសៅ កាលបើកើតឡើងរមែងដុតចិត្ត រមែងឆេះចិត្តមែនពិត, រមែងញ៉ាំងបុគ្គលឱ្យថ្ងូរថា “ចិត្តរបស់ខ្ញុំក្រៀមហើយ, មិនមានអ្វីៗស្រស់ថ្លា” ដូច្នេះ ។ **មនៈ** = ចិត្ត ដែលដល់នូវសេចក្ដីទុក្ខ ឈ្មោះថា **ទុម្មនៈ** = អន់ចិត្ត, ភាវៈនៃទុម្មនៈនោះ ឈ្មោះថា **សេចក្ដីទោមនស្ស**; ឈ្មោះថា **កូនសរ** គឺសេចក្ដីសោកសៅ ដោយអត្ថថា ស្ទុះចូលទៅដោយលំដាប់ (អនុបវិដ្ឋត្ថេន) ព្រោះហេតុនោះ ទើបឈ្មោះថា **សោកសល្លៈ** = កូនសរ គឺសេចក្ដីសោក ។

ពាក្យថា **“អយំ វុច្ចតិ សោកោ** = នេះហៅថាសោកៈ” សេចក្ដីថា នេះតថាគតរមែងហៅឈ្មោះថា **សេចក្ដីសោក**; ក៏សេចក្ដីសោកនេះ ពោលដោយសេចក្ដី ក៏បានដល់ទោមនស្សវេទនាតែម្យ៉ាងប៉ុណ្ណោះ, សូម្បីកាលបើដូច្នោះ សេចក្ដីសោកនោះ គឺ ៖

- **អន្តោ និជ្ឈាយនលក្ខណោ** មានការដុតឆេះខាងក្នុងជាលក្ខណៈ
- **ចេតសោ បរិនិជ្ឈាយនរសោ** មានការដុតរោលចិត្តជាកិច្ច

**_អនុសោចនលក្ខណោ ปจฺจุปฏฺฐาโน_** មានការសោកសៅរឿយៗ ជាបច្ចុប្បដ្ឋាន[១០៧] ។

## គប្បីជ្រាបអត្ថនៃសេចក្ដីសោកជាទុក្ខ

ក៏ក្នុងខថា **គប្បីជ្រាបអត្ថនៃសេចក្ដីសោកជាទុក្ខ** នេះ សេចក្ដីថា សេចក្ដីសោកនេះ ព្រះភគវាត្រាស់ថា ជាទុក្ខ ព្រោះសេចក្ដីសោកនោះជាសភាវៈទុក្ខ និងព្រោះវត្ថុជាទីតាំងនៃសេចក្ដីទុក្ខ ។

**សួរថា** សេចក្ដីទុក្ខរបស់ណា ?

ឆ្លើយថា សេចក្ដីទុក្ខរបស់កាយ និងទុក្ខរបស់ (ចិត្ត) គឺទោមនស្សក្នុងខណៈនៃជវ័ន ។ ពិតណាស់ ដោយកម្លាំងនៃសេចក្ដីសោក ដ៏ខ្លាំងក្លាដែលមានជំងឺពក ឬបួសធំរមែងតាំងឡើងត្រង់បេះដូង ដុតរោលហើយ បណ្ដាលឱ្យបែកចេញ, ក៏លោហិតខ្មៅ រមែងហូរចេញតាមមុខដំបៅ, ទុក្ខផ្លូវកាយដ៏ខ្លាំងក្លា រមែងកើតឡើង ។ កាលបើជញ្ជឹងគិតហើយថា “ញាតិរបស់យើងប៉ុណ្ណេះអស់ទៅហើយ, ភោគៈរបស់យើងប៉ុណ្ណេះអស់ទៅហើយ” ដូច្នេះ ទោមនស្សដ៏ខ្លាំងក្លាក៏កើតឡើងបាន ។

គប្បីជ្រាបសោកនេះថាជាទុក្ខ ព្រោះវត្ថុជាទីតាំងនៃទុក្ខទាំងពីរនេះ ដោយប្រការដូច្នេះចុះ ។

**ម្យ៉ាងវិញទៀត ៖**

**_សត្តានំ ហទយំ សោកោ សល្លំ វិយ វិតុជ្ជតិ_**

---

[១០៧] ពាក្យថា ទោសចិត្តុប្បាទបទដ្ឋានា សេចក្ដីសោក មានទោសចិត្តុប្បាទ ជាបទដ្ឋាន ក្នុងទីនេះលោកមិនបានពោលទុកទេ ។

**អត្ថិតន្តោវ នានាចោ  តុសល្លោ ឧហតេ ឃុន;**
**សមាវហតិ ច  ព្យាធិជរាមរណភេទនំ**
**ទុក្ខំបិ វិវិធំ យស្មា  តស្មា ទុក្ខោតិ វុច្ចតិ ។**

**សេចក្តីសោក** រមែងចាក់ដោតហប្ញទ័យពពួកសត្វ ដូចកូនសរ រមែងដុតរោលយ៉ាងខ្លាំងក្លាថែមទៀត ដូចស្នូតូចដែលគេដុតភ្លើងបញ្ជូនទៅ; ព្រោះសោកនោះ រមែងនាំមកព្រមសូម្បីនូវទុក្ខមានប្រភេទផ្សេងៗ ដែលផ្សេងដោយព្យាធិ ជរា និងមរណៈ ព្រោះហេតុដូច្នោះ សេចក្តីសោកនោះ ទើបព្រះភគវាត្រាស់ថា ជាទុក្ខពិត ៕

## អំពីបរិទេវនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងបរិទេវនិទ្ទេស** តទៅ ៖

ក៏ឈ្មោះថា "**អាទេវៈ** = ការយំស្រែក" ព្រោះអត្ថថា ជាហេតុឱ្យសត្វបញ្ចេញសម្លេងយំដោយអាងថា "ធីតារបស់ខ្ញុំ, បុត្ររបស់ខ្ញុំ" ដូច្នេះ; ក៏ឈ្មោះថា **បរិទេវៈ** (ការខ្សឹកខ្សួល) ព្រោះអត្ថថា ជាហេតុឱ្យសត្វខ្សឹកខ្សួលដល់ធីតា និងបុត្រនោះៗ ។ ពីរៗ បទ [១០៨] ខាងមុខក្រៅពីបទទី ២ ដែលពោលនោះ ព្រះមានជោគត្រាស់ពង្រីកសេចក្ដីដោយអាការនៃបទ ២ ខាងដើមនោះឯង ។ បទថា "**វាចា**" ក៏គឺពាក្យពោល ។ ពាក្យដែលនិយាយឥតប្រយោជន៍ ឈ្មោះថា **បលាបោ** = និយាយរអ៊ូរទាំ; និយាយរអ៊ូរទាំទាល់តែគេស្អប់ ដោយអំណាចការ ពោលមួយៗ កណ្ដាលៗ (លំៗ) និងពោលទៅយ៉ាងដទៃជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **វិប្បលាបៈ** = និយាយរឿយៗ។ បទថា "**លាលប្បោ** = ការពោលញយៗ" បានដល់ការពោលដដែលៗ; អាការនៃការពោលដដែលៗ ឈ្មោះថា **លាលប្បនា** = កិរិយាដែលពោលសាំដដែលៗ ។ ភាវៈនៃកិរិយាពោលសាំដដែលៗ ឈ្មោះថា **លាលប្បិតត្តំ** = សភាពសាំដដែលៗ ។

ពាក្យថា "**អយំ វុច្ចតិ បរិទេវោ** = នេះហៅថា បរិទេវៈ" សេចក្ដីថា នេះតថាគតពោលឱ្យឈ្មោះថា **បរិទេវៈ** ។ បរិទេវៈនោះ ៖

**ទេវលាលប្បនលក្ខណោ** មានការរៀបរាប់ជាលក្ខណៈ

---

[១០៨] បានដល់ ពាក្យថា កិរិយាដែលស្រែកយំ កិរិយាខ្សឹកខ្សួល សភាពដែលយំ សភាពដែលខ្សឹកខ្សួល ។

**គុណទោសបរិកិត្តនរសោ** មានការរៀបរាប់គុណ និងទោសជាកិច្ច **សម្ភមបច្ចុប្បដ្ឋានា** មានការត្អូញត្អែរ មិនតាំងនៅមាំជាបច្ចុប្បដ្ឋាន [១០៩] ៕

## គប្បីជ្រាបអត្ថនៃបរិទេវៈជាទុក្ខ

គប្បីជ្រាបវិនិច្ឆ័យក្នុងខថា គប្បីជ្រាបអត្ថនៃបរិទេវៈជាទុក្ខ ដូចតទៅ ៖

សូម្បី**បរិទេវៈ**នេះខ្លួនឯងមិនជាទុក្ខ, តែព្រះសម្ពុទ្ធត្រាស់ថាជាទុក្ខ ព្រោះវត្ថុជាទីតាំងនៃទុក្ខកាយ និងទុក្ខ (ចិត្ត) ទោមនស្ស ។ ពិតណាស់ បុគ្គលអ្នកកំពុងខ្សឹកខ្សួល រមែងយកដៃគក់ទ្រូងរបស់ខ្លួនក៏មាន, រមែងយកដៃទាំងពីរវាយគក់ទ្រូង, រមែងយកក្បាលបោកនឹងជញ្ជាំងក៏មាន; ព្រោះហេតុនោះ ទុក្ខកាយយ៉ាងខ្លាំង ទើបកើតដល់គេបាន, គេរមែងគិតថា "ញាតិរបស់យើងប៉ុណ្ណោះអស់ហើយ វិនាសហើយ តាំងនៅមិនបានហើយ" ជាដើម, ព្រោះហេតុដូច្នោះ ទោមនស្សយ៉ាងខ្លាំងក្លាទើបកើតឡើងដល់គេ ។

គប្បីជ្រាបបរិទេវៈថាជាទុក្ខ ដោយភាពនៃវត្ថុជាទីតាំងនៃទុក្ខសូម្បីទាំងពីរនេះ ដោយប្រការដូច្នេះ ។

**ន័យម្យ៉ាងទៀត** ៖

**យំ សោកសល្លវិហតោ បរិទេវមានោ**

**កណ្ឋោដ្ឋតាលុតលសោសជមប្បសយ្ហំ**

---

[១០៩] និងពាក្យថា **ទោសចិត្តជមហាភូតបទដ្ឋានា** = មានមហាភូតរូបដែលកើតពីទោសចិត្តជាបទដ្ឋាន លោកមិនបានពោលទុកក្នុងទីនេះទេ ។

**ភិយ្យោធិមត្តមធិគច្ឆតិយេន ទុក្ខំ**
**ទុក្ខោតិ តេន ភគវា បរិទេវមាហ**

បុគ្គលអ្នកត្រូវកូនសរគឺសេចក្តីសោកចាក់
ដោតហើយ ការខ្សឹកខ្សួល មែងប្រសព្វទុក្ខ
ណា ដល់ធន់មិនបាន ដែលកើតពីត្រង់ករឹម
បបូរមាត់ផ្ទៃពិតាន យ៉ាងក្រៃលែងលើស
ប្រមាណ ដោយទុក្ខនោះ ទើបព្រះសម្ពុទ្ធ
ត្រាស់បរិទេវៈ គឺការខ្សឹកខ្សួលថាជាទុក្ខពិត ។

និទ្ទេសនៃទុក្ខ និងទោមនស្ស ប្រាកដច្បាស់ហើយ ព្រោះខ្ញុំពណ៌នាទុកក្នុងអដ្ឋកថា ធម្មសង្គហៈ (**អដ្ឋកថាអដ្ឋសាលិនី**) ក្នុងខាងក្រោយនោះឯង ។ ក៏ពួក ធម៌ ៤ មានលក្ខណៈជាដើមរបស់ទុក្ខ និងទោមនស្សទាំងនោះ ខ្ញុំបានពោលទុកក្នុងទីនោះដូចគ្នា ៕

## គប្បីជ្រាបអត្ថនៃទុក្ខជាទុក្ខជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុងខនេះថា "គប្បីជ្រាបអត្ថនៃទុក្ខថាជាទុក្ខ, និងគប្បីជ្រាបអត្ថនៃទោមនស្សថាជាទុក្ខ" តទៅ ៖

សូម្បីទុក្ខ និងទោមនស្សទាំងពីរនេះ ព្រះមានជោកត្រាស់ថាជាទុក្ខ ព្រោះខ្លួនឯងជាទុក្ខផង, វត្ថុជាទីតាំងនៃទុក្ខតាមកាយ និងតាមចិត្តផង ។ ពិតណាស់ កាលបើបុគ្គលប្រសព្វទុក្ខ ដោយទុក្ខ គឺត្រូវកាត់ដៃ កាត់ជើង ត្រចៀក ច្រមុះ ដែលដេកដាក់អំបែងចាស់ទុកខាងមុខ សូមអាហារក្នុងសាលារបស់មនុស្សអនាថា កាល

បើមានពពួកដង្កូវចេញចាកដំបៅទាំងឡាយ ទុក្ខកាយដ៏ខ្លាំងក្លា កំពុងកើត ឡើង; ទោមនស្សដ៏ខ្លាំងក្លា ក៏រមែងកើតឡើង ព្រោះឃើញមហាជនអ្នកមានសំពត់ជ្រលក់ដោយពណ៌ផ្សេងៗ ប្រដាប់បានតាមការពេញចិត្ត ហើយលេងនក្ខត្តឫក្ស ។

គប្បីជ្រាបសេចក្តីទុក្ខនៃវត្ថុជាទីតាំងនៃទុក្ខសូម្បីទាំងពីរយ៉ាងនេះសិនចុះ ។

**ម្យ៉ាងវិញទៀត ៖**

**បីឡេតិ កាយិកមិទំ ទុក្ខំ ទុក្ខញ្ច មានសំ**
**តិយ្យោ ជនយតិ យស្មា តស្មា ទុក្ខន្តិ វិសេសតោ**

ព្រោះទុក្ខផ្លូវកាយនេះ រមែងបៀតបៀន និងរមែងឱ្យកើតទុក្ខតាមចិត្តយ៉ាងក្រៃលែង ព្រោះហេតុដូច្នោះ ពាក្យថា ជាទុក្ខ ទើបមានដោយសេចក្តីផ្សេងគ្នា ។

ក៏បុគ្គលអ្នកឆ្អែតស្កប់ស្កល់ដោយទុក្ខផ្លូវចិត្ត រមែងរំសាយសក់, គក់ទ្រូង, ប្រមៀលទៅមក, លោតទម្លាក់ជ្រោះ, នាំសស្ត្រាមក, លេបថ្នាំពិស, យកខ្សែចងក, លោតចូលក្នុងគំនររងើកភ្លើង, ជាអ្នកមានសេចក្តីក្តៅក្រហាយ ដោយប្រការនោះៗ ជាអ្នកមានចិត្តក្តៅគគុក រមែងគិតដល់រឿងវិបរិតនោះៗ ។

គប្បីជ្រាបថា ទោមនស្សជាវត្ថុជាទីតាំងនៃទុក្ខ ដោយប្រការដូច្នេះ ។

**ម្យ៉ាងវិញទៀត ៖**

**បីឡេតិ យតោ ចិត្តំ កាយស្ស ច បីឡនំ សមាវហតិ**
**ទុក្ខន្តិ ទោមនស្សម្បិ ទោមនស្សំ តតោ អាហុ ឌ**

ព្រោះទោមនស្ស រមែងបៀតបៀននូវចិត្តផង រមែងនាំមកនូវសេចក្តីបៀតបៀនដល់រាងកាយផង, ព្រោះហេតុដូច្នោះ

ទើបបណ្ឌិតទាំងឡាយ ពោលនូវទោមនស្ស (នោះ) ថា ជាទុក្ខ ព្រោះតែសេចក្តីអន់ចិត្តនោះឯង ៕

## សម្តែងអំពីឧបាយាសនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិទ្ទេសនៃឧបាយាស** តទៅ ៖

ក៏ឈ្មោះថា "**អាយាស** = ការចង្អៀតចង្អល់" ដោយអត្ថថា លំបាកតានតឹង (អាសនត្ថេន); ពាក្យថា **អាយាស** នេះ ជាឈ្មោះរបស់ការលំបាកចិត្ត ដែលប្រព្រឹត្តទៅដោយអាការធ្លាក់ទឹកចិត្ត និងខ្សួលចិត្ត; ការចង្អៀតចិត្តយ៉ាងខ្លាំងក្លា ឈ្មោះថា **ឧបាយាស** = ការចង្អៀតចង្អល់; ភាវៈនៃបុគ្គលអ្នកចង្អៀតចង្អល់ ឈ្មោះថា **ឧបាយាសិតត្តំ** = សភាពចង្អៀតចង្អល់ ។

ពាក្យថា "**អយំ វុច្ចតិ ឧបាយាសោ** = នេះហៅថា ឧបាយាស" សេចក្តីថា នេះតថាគហៅឈ្មោះថា **ឧបាយាស** ។ ក៏ឧបាយាសនេះឯង ៖

**ព្យាសត្តិលក្ខណោ** មានការជាប់ក្នុងអារម្មណ៍ផ្សេងៗ ជាលក្ខណៈ

**និត្ថុននរសោ** មានការបន្ថយចិត្តជាកិច្ច

**វិសាទបច្ចុបដ្ឋានោ** មានការក្រៀមក្រំចិត្តជាបច្ចុប្បដ្ឋាន [១១០] ៕

---

[១១០] **ហទយវត្ថុបទដ្ឋានោ** = មានហទយវត្ថុជាបទដ្ឋាន (មិនបានពោលទុកក្នុងទីនេះ) ។

## គប្បីជ្រាបអត្ថនៃឧបាយាសជាទុក្ខ

គប្បីជ្រាបវិនិច្ឆ័យក្នុងខថា **គប្បីជ្រាបអត្ថនៃឧបាយាសជាទុក្ខ** នេះតទៅ ៖

**ឧបាយាសៈ** សូម្បីនេះខ្លួនឯងមិនជាទុក្ខ, តែព្រះមានព្រះភាគត្រាស់ថា ជាទុក្ខ ព្រោះជាវត្ថុជាទីតាំងនៃទុក្ខសូម្បីទាំងពីរ ។ ពិតណាស់ កាលបើបុគ្គលត្រូវព្រះ-រាជាក្រោធ ដាក់ទោស មានបុត្រ និងបងប្អូនត្រូវប្រហារចោល ខ្លួនឯងសោត ក៏ត្រូវបញ្ជាឱ្យសម្លាប់ ក៏នឹងចូលទៅកាន់ដងព្រៃព្រោះការខ្លាច ពួនសម្ងំហើយ ដល់សេចក្តីជាអ្នកក្រៀមក្រំចិត្តយ៉ាងធំមហិមា រមែងកើតទុក្ខតាមផ្លូវកាយដ៏មានកម្លាំង ព្រោះឈរជាទុក្ខ, ដេកជាទុក្ខ, អង្គុយជាទុក្ខ ។ កាលបើគិតហើយថា "ពួកញាតិរបស់យើងប៉ុណ្ណេះ, ភោគទ្រព្យប៉ុណ្ណេះវិនាសហើយ" ដូច្នេះ ទោមនស្សដ៏មានកម្លាំង ក៏រមែងកើតឡើង ។

គប្បីជ្រាបឧបាយាសៈថា ជាទុក្ខ ព្រោះវត្ថុជាទីតាំងនៃទុក្ខ សូម្បីទាំង ២ នេះ ដោយប្រការដូច្នេះ ។

**ម្យ៉ាងវិញទៀត ៖**

**ចិត្តស្ស បរិទហនា  កាយស្ស ច វិសាទនា**
**អធិមត្តំ យំ ទុក្ខម្បិ  ឧបាយាសោ ជនេតិ ទុក្ខោ**
**តតោ វុត្តោ**

ឧបាយាសៈ រមែងញុំាងទុក្ខមានប្រមាណដ៏ក្រៃលែងឯណា ឱ្យកើតឡើង ព្រោះការដុតចិត្ត និងធ្វើកាយឱ្យសៅហ្មង ព្រះភគវាត្រាស់ហៅឧបាយាសៈនោះថា ទុក្ខ ព្រោះមកអំពីទុក្ខនោះឯង ៕

## អំពីការឧបមាដោយទុក្ខ ៣ យ៉ាង

ក៏បណ្ដាទុក្ខ ៣ យ៉ាង មាន**សោកទុក**ជាដើមនេះ **សោកៈ** គប្បីជ្រាបដូចការស្ងួប្រេងជាដើម ខាងក្នុងភាជនៈប៉ុណ្ណោះ ដោយភ្លើងអន់, គប្បីជ្រាបបរិទេវៈ ដូចការសម្រិតចេញខាងក្រៅភាជនៈរបស់ប្រេងដែលស្ងួហើយ ដោយភ្លើងខ្លាំង, គប្បីជ្រាប **ឧបាយាសៈ** ដូចការចាក់ទាល់តែស្ងួតភាជនៈនោះឯង របស់ប្រេងជាដើម ដែលសល់ពីការសម្រិតទៅខាងក្រៅមិនល្មម នឹងសម្រិតទៅបាន ៕

## សម្ដែងអំពីអប្បិយសម្បយោគទុក្ខនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិទ្ទេសអប្បិយសម្បយោគទុក្ខ** តទៅ ៖

បទថា **យស្ស** កាត់បទជា **យេ + អស្ស** = ឯណា... របស់ ។ បទថា "**អនិដ្ឋា** = ដែលមិនជាទីប្រាថ្នា" បានដល់ ដែលគេមិនស្វែងរក គឺថាដែលគេស្វែងរក ឬមិនស្វែងរកក៏ដោយ, ក៏បទថា **អនិដ្ឋា** នេះ ជាឈ្មោះរបស់អារម្មណ៍ដែលមិនពេញចិត្ត ដែលមិនស្វែងរក ។

ធម៌មានរូបជាដើមឯណា រមែងមិនឈានទៅ គឺរមែងមិនចូលទៅក្នុងចិត្ត ព្រោះហេតុនោះ ធម៌មានរូបជាដើមទាំងនោះ ទើបឈ្មោះថា **អកន្តា** = មិនជាទីស្រឡាញ់ ។ ធម៌ឯណារមែងមិនគួរស្រឡាញ់, រមែងមិនញុំាងចិត្តឱ្យចម្រើន ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា **អមនាបា** = មិនជាទីពេញចិត្ត ។

ពាក្យថា **រូប** ជាដើម ជាពាក្យពង្រីកសេចក្ដីនៃសភាវៈរបស់ធម៌ទាំងនោះ ។ បុគ្គលឯណារមែងចង់គឺរមែងប្រាថ្នាវត្ថុដែលមិនមែនជាប្រយោជន៍ ព្រោះហេតុនោះ

បុគ្គលនោះ ទើបឈ្មោះថា **អនត្ថកាមា** = អ្នកបំណងការវិនាស ។ បុគ្គលណារមែងចង់ គឺរមែងប្រាថ្នាវត្ថុដែលមិនមែនប្រយោជន៍ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **អហិតកាមា** = អ្នកប៉ងទម្លាយប្រយោជន៍ ។ បុគ្គលណា រមែងចង់ គឺរមែងប្រាថ្នាសេចក្ដីមិនសប្បាយ (អផាសុកៈ) គឺការនៅជាទុក្ខ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **អផាសុកកាមា** អ្នកចង់ទម្លាយសេចក្ដីសុខ; បុគ្គលណារមែងមិនប្រាថ្នាដែនក្សេមចាកយោគៈ ៤ គឺវិវដ្ដៈដែលប្រាសចាកភ័យ, គឺរមែងចង់ រមែងប្រាថ្នាវដ្ដៈដែលមានភ័យនោះឯង ដើម្បីយោគៈ ៤ ទាំងនោះ ព្រោះហេតុនោះ បុគ្គលទាំងនោះ ទើបឈ្មោះថា **អយោគក្ខេមកាមា** = អ្នកចង់ទម្លាយដែនក្សេមចាកយោគៈ ។

ម្យ៉ាងទៀត គប្បីជ្រាបក្នុងបទទាំង ៤ មានពាក្យថា **អនត្ថកាមា** ជាដើមនេះ យ៉ាងនេះថា បុគ្គលអ្នកឈ្មោះថា **អនត្ថកាមា** = អ្នកប៉ងចំពោះការវិនាស ព្រោះមិនប្រាថ្នាចំពោះប្រយោជន៍ ពោលគឺការចម្រើនធម៌មានសទ្ធាជាដើម និងព្រោះប្រាថ្នាចំពោះវត្ថុដែលមិនមែនជាប្រយោជន៍ ពោលគឺការវិនាសនៃសទ្ធាជាដើមនោះ ៗ ឯង; ក៏ឈ្មោះថា **អហិតកាមា** = អ្នកចង់ទម្លាយប្រយោជន៍ ព្រោះមិនប្រាថ្នាចំពោះប្រយោជន៍ ដែលជាឧបាយវិធីនៃសទ្ធាជាដើមនោះឯង និងព្រោះប្រាថ្នាចំពោះវត្ថុដែលមិនមែនជាប្រយោជន៍ ដែលជាឧបាយវិធីនៃអកុសលមានការវិនាសសទ្ធាជាដើមនោះឯង ។

ក៏ឈ្មោះថា **អផាសុកកាមា** = អ្នកចង់ទម្លាយសេចក្ដីសុខ ព្រោះមិនប្រាថ្នាចំពោះការនៅជាសុខ និងព្រោះប្រាថ្នាចំពោះការនៅដោយមិនជាផាសុក ។

ក៏ឈ្មោះថា **អយោគក្ខេមកាមា** = អ្នកចង់ទម្លាយដែនក្សេម ព្រោះមិនប្រាថ្នាចំពោះការរួចចាកភ័យយ៉ាងណានីមួយ និងព្រោះប្រាថ្នាចំពោះភ័យ ។

ការទៅប្រកបព្រមគ្នា ឈ្មោះថា **សង្គតិ** = ការទៅរួម; ការមករួមគ្នា ឈ្មោះថា **សមាគមោ** = ការមករួម ។ ភាវៈដែលព្រមគ្នា ក្នុងការឈរ និងការអង្គុយជាដើម ឈ្មោះថា **សមោធានំ** = ការប្រជុំរួម ។ ការដែលធ្វើរួមគ្នានូវកិច្ចទាំងពួង ឈ្មោះថា **មិស្សីភាវោ** = ភាពជាអ្នកធ្វើរួមគ្នា ។

នេះជាយោជនា គឺខណៃនាំដោយអំណាចនៃសត្វ ។

ចំណែកយោជនាដោយអំណាចនៃសង្ខារ គប្បីកាន់យកសេចក្តីតាមដែលបានចុះ ។ ពាក្យថា “**អយំ វុច្ចតិ** = នេះហៅថា” សេចក្តីថា នេះតថាគតហៅ ថា **អប្បិយសម្បយោគទុក្ខ** ។ អប្បិយសម្បយោគទុក្ខនោះ ៖

- **អនិដ្ឋសមោធានលក្ខណោ** មានការប្រជុំចុះនូវវត្ថុដែលមិនគួរប្រាថ្នាជាលក្ខណៈ ។
- **ចិត្តវិឃាដករណរសោ** មានការធ្វើពិឃាតចិត្តជារស
- **អនត្ថភាវបច្ចុបដ្ឋានោ** មានភាវៈដែលឥតប្រយោជន៍ជាផល ។

អប្បិយសម្បយោគទុក្ខនោះ ឈ្មោះថា ជាធម៌មួយមិនមានដោយអត្ត, ព្រះភគវាត្រាស់ថា ជាទុក្ខ ព្រោះជាវត្ថុជាទីតាំងនៃទុក្ខសូម្បីទាំង ២ យ៉ាង ដល់បុគ្គលអ្នកប្រកបដោយអារម្មណ៍ ដែលមិនជាទីស្រឡាញ់តែម្យ៉ាង; ព្រោះវត្ថុទាំងឡាយដែលមិនគួរប្រាថ្នាដល់ការប្រជុំចុះហើយ រមែងញ៉ាំងទុក្ខផ្លូវកាយឱ្យកើតឡើងដោយការចាក់ ដោយការកាត់ ការពុះជាដើមខ្លះ, រមែងញ៉ាំងទុក្ខផ្លូវចិត្តឱ្យកើតឡើង

ដោយការកើតសេចក្តីភ័យតក់ស្លុតខ្លះ; ព្រោះហេតុនោះ ទើបលោកពោលថា ៖

**ទិស្វា អប្បិយេ ទុក្ខំ បឋមំ ហោតិ ចេតសិ**
**តទុបក្កមសម្ភូត- មថ កាយេ យតោ ឥធ**
**តតោ ទុក្ខទ្វយស្សាបិ វត្ថុតោ សោ មហេសិនា**
**ទុក្ខោ វុត្តោតិ វិញ្ញេយ្យោ អប្បិយេហិ សមាគមោ ។**

ព្រោះឃើញសត្វដែលមិនជាទីស្រឡាញ់ ទើបជាទុក្ខត្រង់ចិត្តមុន និងការកើតទុក្ខ ដោយសេចក្តីព្យាយាមរបស់សត្វ ដែលមិនជាទីស្រឡាញ់នោះ ក្នុងកាយ ព្រោះហេតុដូច្នោះ គប្បីជ្រាបការសមាគមជាមួយសត្វដែលមិនជាទីស្រឡាញ់នោះថា ព្រះមហាឫស្សីត្រាស់ថាជាទុក្ខ ព្រោះវត្ថុជាទីតាំងនៃទុក្ខ សូម្បីទាំង ២ ក្នុងលោកនេះឯង ៕

## សំដែងអំពីបិយវិប្បយោគទុក្ខនិទ្ទេស

និទ្ទេសនៃ**បិយវិប្បយោគទុក្ខ** គប្បីជ្រាបដោយន័យផ្ទុយគ្នានិងន័យដែលពោលហើយនោះចុះ ។ ក៏ក្នុងនិទ្ទេស ព្រះមានជោគត្រាស់ពាក្យថា “**មាតា វា** = មាតាក៏ដោយ” ជាដើម ដើម្បីទ្រង់សំម្តែងបុគ្គលអ្នកប្រាថ្នាប្រយោជន៍ដោយបំប្រួញ ។

ក្នុងព្រះបាលីនោះ មានវិគ្រោះថា ក៏ឈ្មោះថា **មាតា** ព្រោះអត្ថថា រមែងថ្នាក់ថ្នម ( **មមាយតីតិ > មាតា**) ។ ក៏ឈ្មោះថា **បិតា** = ព្រោះអត្ថថា រមែងពេញចិត្ត ( **បិយាយតីតិ > បិតា**) ។ ក៏ឈ្មោះថា **ភាតា** = បងប្អូនប្រុស ដោយអត្ថថា

រមែងឃុំគ្រង ។ ក៏ឈ្មោះថា “**ភគិនី** = បងប្អូនស្រី” ក៏ដូចគ្នា ។ ក៏ឈ្មោះថា **មិត្ត** ព្រោះអត្ថថា ប្រព្រឹត្តមេត្តា, ឬដោយអត្ថថា រាប់អាន, អធិប្បាយថា រមែងលាក់រឿងអាថ៌កំបាំងទុកខាងក្នុង ។ ក៏ឈ្មោះថា **អាមាត្យ** ព្រោះអត្ថថា រមែងជាអ្នករួមដោយអត្ថថា ជាអ្នកព្រមព្រៀងគ្នាក្នុងករណីយកិច្ចទាំងឡាយ ។ ក៏ឈ្មោះថា **ញាតិ** ព្រោះអត្ថថា រមែងដឹង ឬជ្រាបយ៉ាងនេះថា មនុស្សនេះជា មនុស្សខាងក្នុងរបស់ពួកយើង ។ ក៏ឈ្មោះថា **សាលោហិត** ព្រោះអត្ថថា ជាអ្នកសម្ពន្ធគ្នាដោយខ្សែឈាម ។

គប្បីជ្រាបបទទាំងនេះ ដោយអត្ថមានប្រការដូច្នេះឯង ។

ពាក្យថា “**អយំ វុច្ចតិ** = នេះហៅថា” សេចក្តីថា នេះយើងហៅ ឈ្មោះថា **បិយេហិវិប្បយោគទុក្ខ** ។ បិយេហិវិប្បយោគទុក្ខនេះ ៖

**-ឥដ្ឋវត្ថុវិយោគលក្ខណោ** មានការព្រាត់ប្រាសចាកវត្ថុដែលប្រាថ្នា ជាលក្ខណៈ ។

**-សោកុប្បាទនរសោ** មានការកើតឡើងនៃសេចក្តីសោកជារស

**-ព្យសនបច្ចុបដ្ឋានោ** មានការវិនាសជាបច្ចុប្បដ្ឋាន ។

បិយេហិវិប្បយោគទុក្ខនោះ ឈ្មោះថា ជាធម៌ម្យ៉ាង ដោយអត្ថថា រមែងមិនមាន, ព្រះមានជោកត្រាស់ថាជាទុក្ខ ព្រោះវត្ថុជាទីតាំងនៃទុក្ខ សូម្បីទាំងពីររបស់បុគ្គលអ្នកប្រាសចាកវត្ថុជាទីស្រឡាញ់តែម្យ៉ាង ព្រោះវត្ថុដែលគួរប្រាថ្នាទាំងឡាយ កាលបើព្រាត់ប្រាសទៅ រមែងញុំាងទុក្ខសូម្បីផ្លូវកាយឱ្យកើតឡើង ដោយសេចក្តីជាអ្នកមានសរីរៈស្គមស្គាំង និងសោះកក្រោះជាដើម, សូម្បីផ្លូវចិត្តក៏កើត

ទុក្ខ ដោយការឱ្យសោកសៅថា "សូម្បីវត្ថុដែលមានសម្រាប់ពួកយើងនោះ ក៏មិនមានឡើយ" ព្រោះហេតុនោះ លោកពោលដូច្នេះថា ៖

**ញាតិធនាទិវិយោគា សោកសរសមប្បិតា**
**វិតុជ្ជន្តិ ពាលា យតោ តតោ យំ ឧភ្ភោតិ មតោ**
**បិយវិប្បយោគោ ៗ**

ព្រោះការព្រាត់ប្រាសចាកញាតិ និងទ្រព្យជាដើម ពួកមនុស្សពាល អ្នកឆ្អែតស្កប់ស្កល់ដោយកូនសរ គឺសេចក្ដីសោកចាក់មុតហើយ ព្រោះហេតុណា ព្រោះហេតុនោះ ការព្រាត់ប្រាសចាកវត្ថុដែលជាទីស្រឡាញ់ ទើបគេស្គាល់ច្បាស់ថា **ជាទុក្ខ** ៕

## សំដែងអំពីឥច្ឆានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុង**ឥច្ឆានិទ្ទេស** (ការប្រាថ្នា) តទៅ ៖

បទថា "**ជាតិធម្មានំ** = មានការកើតជាធម្មតា" បានដល់ មានការកើតជាសភាវៈ មានការកើតជាប្រក្រតី ។ បទថា "**ឥច្ឆា ឧប្បជ្ជតិ** = ការប្រាថ្នារមែងកើតឡើង" បានដល់ តណ្ហារមែងកើតឡើង ។ សព្ទថា "**អហោ វត** = ឱហ្ន៎ !" គឺជាការប្រាថ្នា ។

ពាក្យថា "**ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ** = ខនេះមិនគប្បីសម្រេចតាមការប្រាថ្នា" សេចក្ដីថា ការមិនមកនៃជាតិ (ការកើត) ដែលមាននៅក្នុងពួកសាធុជន អ្នកលះសមុទ័យបានហើយ នឹងមាននៅលោកអ្នកបរិនិព្វាន ដែលមិនមាន

ការកើតជាធម្មតា ដែលជនទាំងឡាយប្រាថ្នាហើយយ៉ាងនេះថា "ឱហ្ន៎ សូមពួកយើងកុំមានការកើតជាធម្មតា និងសូមការកើតកុំមានដល់ពួកយើងឡើយ" នោះឈ្មោះថា រមែងមិនសម្រេចតាមសេចក្តីប្រាថ្នាបាន ព្រោះវៀរចាកមគ្គភាវនាហើយ សូម្បីបុគ្គលប្រាថ្នា ក៏មិនគប្បីសម្រេច និងព្រោះជាធម៌ គប្បីដល់ដោយមគ្គភាវនា សូម្បីដល់បុគ្គលអ្នកមិនប្រាថ្នា ។ បទថា "**ឥទម្បិ** = នេះឯង" ។ បិអក្សរសំដៅយកបទប្លែកគ្នាខាងមុខ ។ បទថា "**យម្បិច្ឆំ**" ជាដើម សេចក្តីថា កាលបើបុគ្គលប្រាថ្នាវត្ថុណាដែលមិនគប្បីបានសូម្បីដោយធម៌ណា, រមែងមិនបាននូវការប្រាថ្នាក្នុងវត្ថុដែលមិនគប្បីបាននោះ គប្បីជ្រាបថា ជាទុក្ខ ។ សូម្បីក្នុងបទ មានពាក្យថា **ដល់ពពួកអ្នកមានសេចក្តីចាស់ជាធម្មតាជាដើម** ក៏ន័យនេះដែរ ។ សេចក្តីប្រាថ្នាក្នុងវត្ថុ ដែលមិនគប្បីបានក្នុងនិទ្ទេសនេះ ព្រះភគវាត្រាស់ថា "**យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ** ប្រាថ្នាវត្ថុណាមិនបាន សូម្បីវត្ថុនោះក៏ជាទុក្ខ" ដោយប្រការដូច្នេះ ។

សេចក្តីប្រាថ្នានោះ ៖

- **អលព្ភនេយ្យវត្ថុឥច្ឆនលក្ខណា** មានការចង់បានក្នុងវត្ថុដែលមិនគប្បីបានជាលក្ខណៈ ។

- **តម្បរិយេសនរសា** មានការស្វែងរកវត្ថុនោះ ជារស

- **តេសំ អប្បត្តិបច្ចុប្បដ្ឋានា** មានការមិនបានសម្រេចនូវវត្ថុទាំងនោះ ជាបច្ចុប្បដ្ឋាន ។

ក៏ការប្រាថ្នានោះ ព្រះភគវាត្រាស់ថា ជាទុក្ខ ព្រោះវត្ថុជាទីតាំងសូម្បីនៃទុកទាំងពីរ; ពិតណាស់ មនុស្សខ្លះដែលអ្នកដទៃលើកតម្កើងថា នឹងជាព្រះរាជា; គេ

មានគណៈដែលបែងចែកស្រុក ក្រុងដាច់ស្រឡះអស់ហើយ ចូលទៅកាន់ កំពូលភ្នំ ឬជាយព្រៃ ។ ពេលនោះ ព្រះរាជាទ្រង់ជ្រាបព្រឹត្តិការណ៍នោះ ហើយទ្រង់បញ្ជាទ័ពទៅ; បុរសនោះមានបរិវារត្រូវរាជបុរសកម្ចាត់ហើយ សូម្បីខ្លួនឯងក៏ត្រូវគេប្រហារ ទើបចៀសចេញចូលទៅកាន់ចន្លោះដើមឈើ ឬចន្លោះផ្ទាំងថ្ម ។ សម័យនោះ ភ្លៀងដ៏ធំក៏តាំងឡើង, មានពពកខ្មៅងងឹត; ក្នុងខណៈនោះហ្វូងសត្វ មានស្រមោចខ្មៅ ជាដើម ក៏ឡោមព័ទ្ធគេជុំវិញ; ដោយហេតុនោះ សេចក្ដីទុក្ខតាមផ្លូវកាយដ៏មានកម្លាំង ទើបកើតឡើងដល់គេ; កាលបើគិតហើយថា "ពួកញាតិប៉ុណ្ណោះ និងភោគសម្បត្តិប៉ុណ្ណោះ វិនាសអស់ហើយ ព្រោះអាស្រ័យយើងតែម្នាក់" ដូច្នេះ ទោមនស្សដ៏មានកម្លាំងទើបកើតឡើងដល់គេ ។

ការប្រាថ្នានេះ គប្បីជ្រាបថាជាទុក្ខ ព្រោះវត្ថុជាទីតាំងនៃទុក្ខសូម្បីទាំង ២ ដោយប្រការដូច្នេះឯង ។

**ម្យ៉ាងវិញទៀត ៖**

**តំ តំ បត្ថយមានានំ តស្ស តស្ស អលាភតោ**
**យំ វិឃាតមយំ ទុក្ខំ សត្តានំ ឥធ ជាយតិ ។**
**អលព្ភនេយ្យវត្ថូនំ បត្ថនា តស្ស ការណំ**
**យស្មា តស្មា ជិនោ ទុក្ខំ ឥច្ឆិតាលាភមព្រវិ ។**

កាលបើសត្វប្រាថ្នាវត្ថុនោះៗ ហើយព្រោះមិនបានវត្ថុនោះៗ សេចក្ដីទុក្ខឯណា ដែលកើតពីការពិឃាត រមែងកើតដល់ពួកសត្វក្នុងលោកនេះ; ការប្រាថ្នានូវវត្ថុដែលមិនគប្បីបានជាហេតុនៃទុក្ខនោះ ព្រោះហេតុដូច្នោះ

ទើបព្រះជិនពុទ្ធត្រាស់ការមិនបានតាមសេចក្ដីប្រាថ្នាថា
ជាទុក្ខពិត ៕

## សង្ខេបអំពីឧបាទានក្ខន្ធនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិទ្ទេសនៃឧបាទានក្ខន្ធ** តទៅ ៖

បទថា **"សង្ខិត្តេន** = ដោយបំប្រួញ" នេះ ព្រះមានជោកសំដៅយកទេសនា ។ ពិតណាស់ អ្នកណា១ មិនអាចបំប្រួញទុក្ខបានថា ប៉ុណ្ណេះ ជាទុក្ខមួយរយ (១០០), ប៉ុណ្ណេះជាទុក្ខមួយពាន់ (១០០០), តែទេសនាអាចបំប្រួញបាន; ព្រោះហេតុដូច្នោះ កាលបើនឹងទ្រង់បំប្រួញទេសនាថា "ឈ្មោះថា **ទុក្ខ** មិនមែនអ្វីដទៃ, ដោយបំប្រួញ គឺឧបាទានក្ខន្ធ ៥ ជាទុក្ខ" ទើបត្រាស់ហើយយ៉ាងនេះ ។ សព្ទថា **"សេយ្យថីទំ"** ជានិបាត; សេចក្ដីនៃនិបាតនោះ មានអធិប្បាយថា ប្រសិនបើមានអ្នកសួរថា "ឧបានក្ខន្ធទាំងនោះ តើយ៉ាងដូចម្ដេច" ដូច្នេះ ។ សេចក្ដីនៃបទថា **"រូបូបាទានក្ខន្ធោ** = រូបូបាទានក្ខន្ធ" ជាដើម ខ្ញុំពណ៌នាទុកហើយ ក្នុងខន្ធវិភង្គឯណោះ ៕

## គប្បីជ្រាបអត្ថនៃខន្ធទាំងឡាយជាទុក្ខ

ក៏គប្បីវិនិច្ឆ័យក្នុងខថា **គប្បីជ្រាបអត្ថនៃខន្ធទាំងឡាយថាជាទុក្ខ** នេះតទៅ ៖

**ជាតិប្បភូតិកំ ទុក្ខំ យំ វុត្តំ ឥធ តាទិនា**
**អវុត្តំ យញ្ច តំ សព្វំ វិនា ឯតេ ន វិជ្ជតិ ។**
**យស្មា តស្មា ឧបាទាន- ក្ខន្ធា សង្ខេបតោ ឥមេ**

**ទុក្ខាតិ វុត្តា ទុក្ខន្តេ~ ទេសកេន មហេសិនា ៗ**

ទុក្ខព្រោះមានជាតិជាដែនកើតឯណា ដែលព្រះមានតាទិភាព (ភាពនឹងធឹង) ត្រាស់ទុកក្នុងលោកនេះ និងទុក្ខដែលមិនបានត្រាស់ទុក ទុក្ខទាំងអស់នោះ វៀរឧបាទានក្ខន្ធ ៥ ហើយរមែងមិនមានឡើយ; ព្រោះហេតុដូច្នោះ ទើប**ព្រះមហាពុទ្ធឫស្សី** អ្នកទ្រង់សម្ដែងនូវទីបំផុតនៃទុក្ខត្រាស់ដោយបំប្រួញថា ឧបាទានក្ខន្ធនេះ ជាទុក្ខពិត ។

ពិតយ៉ាងនោះមែនជាតិជាដើមបៀតបៀនហើយនូវឧបាទានក្ខន្ធ ៥ នោះឯងដោយប្រការផ្សេងៗ ដូចភ្លើងព្រៃតែងបៀតបៀនអណ្ដាតភ្លើង, ដូចគ្រឿងប្រហារតែងបៀតបៀនទីដៅ, ដូចរបោម និងមូសជាដើមតែងបៀតបៀនគោ, ដូចអ្នកច្រូតតែងបៀតបៀនស្រែ, ដូចចោរប្លន់អ្នកស្រុកតែងបៀតបៀនអ្នកស្រុក, រមែងកើតឡើងក្នុងឧបាទានក្ខន្ធ ៥ នោះឯង ដូចស្មៅ និងវល្លិជាដើម រមែងកើតឡើងលើផែនដី ដូចផ្កា ឈើ ផ្លែឈើ និងស្លឹកឈើខ្ចីជាដើម កើតឡើងត្រង់ដើមឈើដូច្នោះ ។

ក៏ទុក្ខដែលជាខាងដើមនៃឧបាទានក្ខន្ធ **គឺជាតិ**, ទុក្ខត្រង់កណ្ដាល **គឺជរា**, ក្នុងទីបំផុត **គឺមរណៈ** ។ ព្រោះសម្ដាចនៃទុក្ខមានការស្លាប់ជាទីបំផុត ទើបមានទុក្ខដុតរោលរាល **គឺសោកៈ** ព្រោះការអត់សង្កត់ គឺសេចក្ដីសោកនោះមិនបាន មានទុក្ខជាហេតុ ពោលខ្សឹកខ្សួល **គឺបរិទេវៈ** ។ បន្ទាប់មក ក៏មានទុក្ខ គឺជាទុក្ខបៀតបៀនព្រោះប្រកបដោយផោដ្ឋព្វៈ (ការពាល់ត្រូវ) និងអារម្មណ៍ដែលមិនគួរប្រាថ្នា **គឺធាតុកម្រើក** ។ ព្រោះបុថុជ្ជនអ្នកត្រូវទុក្ខតាមផ្លូវកាយនោះបៀតបៀន ដោយការ

កើតបដិឃៈក្នុងឧបាទានក្ខន្ធនោះ ក៏កើតទុក្ខដែលបៀតបៀនផ្លូវចិត្ត **គឺទោមនស្ស** ទុក្ខមានការដកដង្ហើមធំរបស់បុគ្គលអ្នកមានសេចក្ដីសៅហ្មង ដែលកើតពីការចម្រើនរបស់សោកៈជាដើម **គឺឧបាយាសៈ** ។ ទុក្ខខុសបំណងរបស់បុគ្គល អ្នកភ្លាត់ចាកមនោរថ គឺការមិនបានវត្ថុដែលខ្លួនប្រាថ្នា ។ ឧបាទានក្ខន្ធដែលបុគ្គលមានបញ្ញា ចូលទៅពិចារណាហើយ ដោយប្រការផ្សេង ៗ ដោយប្រការដូច្នេះ ឈ្មោះថា **ជាទុក្ខពិត** ។

ព្រះមានជោក ដើម្បីទ្រង់សម្ដែងដោយបំប្រួញទុក្ខដែលទ្រង់ត្រាស់សម្ដែងទុកតែគ្រប់យ៉ាង ដែលនរណា ៗ មិនអាចសម្ដែងដោយមិនសល់ជាអនេកកប្ប, សូម្បីទុក្ខទាំងអស់នោះ ក្នុងឧបាទានក្ខន្ធ ៥ យ៉ាងណានីមួយ ដូចទ្រង់បំប្រួញរសទឹកក្នុងសមុទ្រទាំងអស់មកសម្ដែងក្នុងតំណក់ទឹកតែមួយ (មានរសប្រៃ) ទើបបានត្រាស់ថា **"សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា = ដោយសង្ខេប ឧបាទានក្ខន្ធ ៥ ជាទុក្ខ"** ដូច្នេះ ៕

ចប់កថាសម្ដែងអំពីទុក្ខសច្ចនិទ្ទេស

## ពណ៌នានិទ្ទេសវារៈ

## សម្ដែងអំពីសមុទយសច្ចនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងសមុទយសច្ចនិទ្ទេស** តទៅ ៖

បទថា **"យាយំ តណ្ហា"** កាត់បទជា **យា + អយំ + តណ្ហា** = តណ្ហានេះណា ។ បទថា **"ពោនោព្ភវិកា"** មានវិគ្រោះថា ហេតុធ្វើនូវភពថ្មី ឈ្មោះថា **ពោនោព្ភវោ**, ហេតុធ្វើនូវភពថ្មីជាប្រក្រតីរបស់តណ្ហានោះ រមែងមានព្រោះហេតុនោះ ទើបតណ្ហានោះ ឈ្មោះថា **ពោនោព្ភវិកា** = ជាហេតុឱ្យកើតក្នុងភពថ្មីៗ ។ ម្យ៉ាង-

វិញទៀត តណ្ហាណារមែងឱ្យនូវភពថ្មី, រមែងប្រព្រឹត្តទៅព្រមដើម្បីភពថ្មី, រមែងកើតក្នុងភពញយៗ ព្រោះហេតុនោះ តណ្ហានោះ ទើបឈ្មោះថា **ពោនោព្ភវិកា** ។

ក៏តណ្ហានោះ ជាតួឱ្យភពថ្មីក៏មាន មិនឱ្យភពថ្មីក៏មាន, ប្រព្រឹត្តទៅព្រមដើម្បីភពថ្មីក៏មាន មិនប្រព្រឹត្តទៅព្រមដើម្បីភពថ្មីក៏មាន; សូម្បីតែអំណោយឧបនិធិ និងបដិសន្ធិដែលតណ្ហានោះឱ្យកើតឡើងហើយ; តណ្ហានោះ កាលបើឱ្យនូវភពថ្មីក្តី មិនឱ្យនូវភពថ្មីក្តី ប្រព្រឹត្តទៅដើម្បីភពថ្មីក្តី មិនប្រព្រឹត្តទៅដើម្បីភពថ្មីក្តី សូម្បីតែអំណោយឧបនិធិក្នុងបដិសន្ធិដែលខ្លួនឱ្យកើតហើយនោះ ក៏បានឈ្មោះថា **ពោនោ-ព្ភវិកា** ដូចគ្នា ។

ក៏ឈ្មោះថា **"នន្ទិរាគសហគតា** = ប្រកបដោយការត្រេកអរ រីករាយ" ព្រោះអត្ថថា ទៅព្រមជាមួយនន្ទិរាគៈ ពោលគឺ**សេចក្តីរីករាយដ៏ក្រៃលែង**; មានអធិប្បាយថា ដោយអត្ថទៅកាន់សេចក្តីជាមួយគ្នានឹងនន្ទិរាគៈនោះឯង ។ បទថា **"តត្រតត្រាភិនន្ទិនី** = ភ្លើតភ្លើននៅក្នុងអារម្មណ៍នោះៗ" បានដល់ ភាពជាអត្តាមាននៅក្នុងទីណាៗ, ក៏មានសេក្តីរីករាយយ៉ាងក្រៃលែងក្នុងទីនោះៗ, ឬថា មានការភ្លើតភ្លើនក្នុងអារម្មណ៍មានរូបារម្មណ៍ជាដើមនោះៗ, អធិប្បាយថា មានការភ្លើតភ្លើនក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ។

សព្ទថា **សេយ្យថីទំ** ជានិបាត; សេចក្តីនៃសព្ទថា **សេយ្យថីទំ** នោះ បើសិនមានពាក្យសួរថា "តណ្ហានោះ តើយ៉ាងដូចម្តេច ?" ។

បទថា **"កាមតណ្ហា"** មានវិគ្រោះថា តណ្ហាក្នុងកាម ឈ្មោះថា **កាម-តណ្ហា** ។ ពាក្យថា **កាមតណ្ហា** នេះ ជាឈ្មោះរបស់រាគៈដែលប្រកបដោយកាមគុណ

៥ ។ តណ្ហាក្នុងភព ឈ្មោះថា **ភវតណ្ហា** ។ ពាក្យថា **ភវតណ្ហា** នេះ ជាឈ្មោះរបស់រាគៈ (ការរីករាយ) ក្នុងរូបភព អរូបភព និងសេចក្តីពេញចិត្តក្នុងឈាន ដែលសហគតៈដោយសស្សតទិដ្ឋិកើតឡើងហើយ ដោយអំណាចនៃការប្រាថ្នាភព ។ តណ្ហាក្នុងវិភព ឈ្មោះថា **វិភវតណ្ហា** ។ ពាក្យថា **វិភវតណ្ហា** នេះ ជាឈ្មោះរបស់រាគៈដែលសហគតៈដោយឧច្ឆេទទិដ្ឋិ ។

ឥឡូវនេះ ព្រះភគវាដើម្បីនឹងទ្រង់សម្តែងវត្ថុជាទីតាំងនៃតណ្ហានោះ ដោយពិស្តារ ទើបត្រាស់ពាក្យជាដើមថា “**សា ខោ បនេសា** = ក៏តណ្ហានេះនុ៎ះឯង” ។ ក្នុងព្រះបាលីនោះ បទថា “**ឧប្បជ្ជតិ** = រមែងកើតឡើង” ។ បទថា “**និវិសតិ** = រមែងតាំងនៅ” បានដល់ រមែងតាំងមាំដោយអំណាចសេចក្តីប្រព្រឹត្តទៅញយៗ ។ ពាក្យថា “**យំ លោកេ បិយរូបំ សាតរូបំ** = បិយរូប និងសាតរូបណា មាននៅក្នុងលោក” សេចក្តីថា វត្ថុណាជាសភាពគួរស្រឡាញ់ និងជាសភាពឆ្ងាញ់ពិសាក្នុងលោក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យមានជាអាទិ៍ថា “**ចក្ខុំ លោកេ** = ចក្ខុ ជាបិយ-រូប និងសាតរូប ក្នុងលោក” តទៅ ៖

ពិតណាស់ សត្វទាំងឡាយអ្នកប្រកាន់មាំក្នុងចក្ខុជាដើម ដោយការប្រកាន់ខ្លួនថា របស់យើងក្នុងលោកតាំងមាំក្នុងសម្បត្តិ រមែងសម្គាល់ចក្ខុរបស់ខ្លួនជាដើមថា ជាប្រសាទ ៥ ដែលស្រស់ថ្លា ដោយទំនងការប្រកាន់យកនិមិត្ត ក្នុងស្រមោលកញ្ចក់ជាដើម ដូចសីហបញ្ជរកែវមណីដែលចាំងចេញពីវិមានមាស, រមែងសម្គាល់សោតៈ ហាក់បីដូចជាបំពង់ប្រាក់ និងដូចខ្សែសង្វារ, រមែងសម្គាល់ឃានៈ មាន

វោហារដែលបានហើយថា មានច្រមុះកោង ដូចហរតាលមូលតាំងនៅ, រមែងសម្គាល់ជិវ្ហាដ៏ទន់ឱ្យនូវរសដ៏ល្អិត ដូចសំពត់កម្ពល់ក្រហម, រមែងសម្គាល់កាយ ដូចបង្គោលសសរឈើខ្លឹម និងដូចសសរមាស, រមែងសម្គាល់ចិត្តថា ឱឡារ (គ្រោតគ្រាត) មិនដូចចិត្តរបស់ជនដទៃ, រមែងសម្គាល់រូប ដូចពណ៌មាស និងពណ៌ផ្កា កណិកាជាដើម, រមែងសម្គាល់សម្លេង ដូចសម្លេងស្រែករបស់សត្វករវិក និងហាក់បីដូចជាកំពុងភ្លើតភ្លើន នឹងសម្លេងផ្លុំរបស់ខ្លុយកែវមណីក្នុងព្រៃល្វើយ។ រមែងសម្គាល់អារម្មណ៍ គឺក្លិនជាដើមដែលកើតពីសមុដ្ឋាន ៤ ដែលខ្លួនបានចំពោះហើយថា "មនុស្សដទៃណាទៅនឹងមានអារម្មណ៍បែបនេះ" ដូច្នេះ, កាលបើជនទាំងនោះ សម្គាល់យ៉ាងនេះហើយ អាយតនៈទាំងនោះមានចក្ខាយតនៈជាដើម ក៏រមែងជាបិយរូប និងសាតរូប; កាលបើដូច្នោះ តណ្ហារបស់ជនទាំងនោះដែលនៅមិនកើតឡើង ក៏រមែងកើតឡើងក្នុងចក្ខុជាដើមនោះ និងដែលកើតឡើងហើយ ក៏រមែងតាំងមាំដោយអំណាចដែលប្រព្រឹត្តទៅញយ។; ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគមានព្រះតម្រាស់មានជាអាទិ៍ថា "**ចក្ខុំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ** = ចក្ខុជាបិយរូប សាតរូបក្នុងលោក, តណ្ហានេះ កាលបើកើតឡើង ក៏រមែងកើតឡើងត្រង់ចក្ខុនេះ" ។

ក្នុងបទទាំងនោះ បទថា "**ឧប្បជ្ជមានា** = កាលកើតឡើង" សេចក្តីថា កាលណាតណ្ហាកើតឡើង, កាលនោះក៏រមែងកើតក្នុងចក្ខុនេះឯង ។ សូម្បីក្នុងបទទាំងពួង ក៏ន័យនេះដែរ ៕

**ចប់កថាអំពីសមុទយសច្ចនិទ្ទេស**

## ពណ៌នានិទ្ទេសវារៈ

## សម្តែងអំពីនិរោធសច្ចនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិរោធសច្ចនិទ្ទេស** តទៅ ៖

ក្នុងខថា "**យោ តស្សាយេវ តណ្ហាយ** = ការថយចុះ... នៃតណ្ហានោះឯង" សេចក្តីថា កាលបើព្រះមានព្រះភាគគួរនឹងត្រាស់ថា "**យោ តស្សេវ ទុក្ខស្ស** = ការថយចុះ... ទុក្ខនោះៗ ឯង" ដូច្នេះ, តែព្រោះទុក្ខរលត់ទៅ ព្រោះការរលត់សមុទ័យមិនមែនដោយប្រការដទៃ; ដូចយ៉ាងដែលត្រាស់ទុកថា ៖

**"យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ**
**ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ**
**ឯវំបិ តណ្ហានុសយេ អនូហតេ**
**និព្វត្តតេ ទុក្ខមិទំ បុនប្បុនំ ។**

ប្រៀបដូចដើមឈើ សូម្បីត្រូវគេកាត់ហើយ
កាលបើឫសនៅមាំទាំ មិនមានឧបទ្ទវៈ ក៏រមែងដុះ
ឡើងបានទៀត យ៉ាងណា, សូម្បីទុក្ខនេះ ក៏យ៉ាង
នោះដែរ កាលបើតណ្ហានុស័យ នៅមិនទាន់បានដក
ចេញនៅឡើយ ក៏រមែងកើតឡើងញយៗ"[១១១] ។

ព្រោះហេតុដូច្នោះ កាលបើទ្រង់សម្តែងការរលត់ទុក្ខនោះ ទើបត្រាស់ទុកយ៉ាងនេះ ដើម្បីទ្រង់សម្តែងដោយរលត់សមុទ័យ; មែនពិត ព្រះតថាគតទាំងឡាយ

---

[១១១] ខុ. ធ. ។

ទ្រង់ប្រព្រឹត្តដូចសីហរាជ, ព្រះតថាគតទាំងឡាយកាលបើទ្រង់រលត់ទុក្ខ និងកាលបើទ្រង់សម្ដែងការរលត់ទុក្ខ **រមែងបដិបត្តិក្នុងហេតុ, មិនមែនក្នុងផល**; តែពួកអញ្ញតិរ្ថិយមានការប្រព្រឹត្តដូចសុនខ, ពួកគេទាំងនោះកាលបើរលត់ទុក្ខក្ដី កាលបើនឹងសម្ដែងសេចក្ដីរលត់ទុក្ខក្ដី រមែងបដិបត្តិក្នុងផលដោយការប្រកបរឿយៗ នូវសេចក្ដីព្យាយាមធ្វើខ្លួនឯងឱ្យលំបាក (អត្តកិលមថានុយោគ) និងដោយការសម្ដែងនូវការប្រកបរឿយៗ នូវសេចក្ដីព្យាយាមធ្វើខ្លួនឯងឱ្យលំបាកនោះឯង មិនបដិបត្តិក្នុងហេតុទេ ។

ព្រះសាស្ដាព្រះអង្គបដិបត្តិនៅក្នុងហេតុ ព្រោះប្រព្រឹត្តប្រៀបដូចសីហៈ ទើបត្រាស់តម្រាស់មានជាអាទិ៍ថា "**យោ តស្សាយេវ**" ។

ក្នុងព្រះបាលីនោះ បទថា "**តស្សាយេវ** = នៃតណ្ហានោះឯង" សេចក្ដីថា សភាវៈនោះណានៃតណ្ហានោះៗ ឯង ដែលព្រះអង្គទ្រង់ប្រកាសទុកក្នុងខាងក្រោយ ដោយអំណាចនៃការកើត និងការតាំងមាំ ។

បទថា "**អសេសវិរាគនិរោធោ** = ការបន្ថយ និងការរលត់ដោយមិនសល់" ជាដើម សុទ្ធតែជាវេវចនៈរបស់ព្រះនិព្វានទាំងអស់; ព្រោះអាស្រ័យព្រះនិព្វាន ទើបតណ្ហាថយចុះ រមែងរលត់ដោយមិនសល់, ព្រោះហេតុដូច្នោះ ព្រះនិព្វាននោះ ទើបព្រះមានព្រះភាគត្រាស់ថា "**តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ** = ការថយចុះ និងការរលត់ដោយមិនសល់នៃតណ្ហានោះនុ៎ះឯង" ដូច្នេះ ។ ក៏ព្រោះអាស្រ័យព្រះនិព្វានហើយ ទើបបុគ្គលឈ្មោះតណ្ហាបាន រមែងលះបង់បាន រមែងរួចបាន និងរមែងមិនជាប់ជំពាក់, ព្រោះហេតុដូច្នោះ ទើបត្រាស់ហៅព្រះនិព្វានថា "**ចាគោ**

= ការលះ, **បដិនិស្សគ្គោ** = ការលះបង់, **មុត្តិ** = ការរួច, **អនាលយោ** = ការមិនមានអាល័យ” ៕

## ធម៌ដែលជាវេវចនៈនឹងព្រះនិព្វានមាន ២៦

ការពិតព្រះនិព្វានមានតែម្យ៉ាងគត់, តែព្រះនិព្វាននោះមានឈ្មោះហៅជំនួសច្រើនជាអនេកដោយអំណាចនៃឈ្មោះ ដែលជាបដិបក្សនឹងសង្ខតធម៌ទាំងអស់; តើដូចម្ដេចខ្លះ ? គឺមានឈ្មោះជាអាទិ៍ថា ៖

‿**អសេសតោ វិរាគោ** អស់រាគៈមិនមានសល់ ‿**និរោធោ** ការរលត់

‿**ចាគោ** ការលះ ‿**បដិនិស្សគ្គោ** ការលះបង់

‿**មុត្តិ** ការរួច ‿**អនាលយោ** ការមិនមានអាល័យ

‿**រាគក្ខយោ** ការអស់រាគៈ ‿**ទោសក្ខយោ** ការអស់ទោសៈ

‿**មោហក្ខយោ** ការអស់មោហៈ ‿**តណ្ហក្ខយោ** ការអស់តណ្ហា

‿**អនុប្បាទោ** ការមិនកើតឡើង ‿**អប្បវត្តំ** ការមិនប្រព្រឹត្តទៅ

‿**អនិមិត្តំ** ការមិនមានគ្រឿងសម្គាល់ ‿**អប្បណិហិតំ** ការមិនមានទីតាំងនៅ

‿**អនាយូហនំ** ការមិនព្យាយាម ‿**អប្បដិសន្ធិ** ការមិនមានបដិសន្ធិ

‿**អប្បដិវត្តិ** ការមិនវិលត្រឡប់ ‿**អគតិ** ការមិនមានគតិ

‿**អជាតំ** ការមិនកើត ‿**អជរំ** ការមិនចាស់

‿**អព្យាធិ** ការមិនឈឺ ‿**អមតំ** ការមិនស្លាប់

‿**អសោកំ** ការមិនមានសេចក្ដីសោក ‿**អបរិទេវំ** ការមិនបរិទេវៈ

ៈ**អនុបាយាសំ** ការមិនតានតឹង ៈ**អសន្ទិលិដ្ឋ** ការមិនសៅហ្មង ។

ឥឡូវនេះ ព្រះមានព្រះភាគដើម្បីនឹងទ្រង់សម្តែងសេចក្តីមិនមាននៃតណ្ហាដែលមគ្គកាត់ហើយ សូម្បីអាស្រ័យព្រះនិព្វានហើយ ក៏ដល់ការមិនប្រព្រឹត្តទៅក្នុងវត្ថុជាទីតាំងឯណា ដែលព្រះអង្គទ្រង់សម្តែងនូវសេចក្តីកើតឡើងរបស់វាទុកក្នុងទីនោះនុ៎ះឯង ទើបត្រាស់ពាក្យថា **"សា ខោ បនេសំ** = ក៏តណ្ហានេះនោះឯង" ដូច្នេះជាដើម ។

ក្នុងព្រះតម្រាស់នោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បុរសឃើញទងឃ្លោកដុះក្នុងស្រែ ហើយគប្បីស្វែងរកឫសតាំងពីចុងហើយក៏កាត់ចេញ, ទងឃ្លោកនោះ ក៏ក្រៀមដល់សេចក្តីមិនមានបញ្ញត្តិ; បន្ទាប់មក ទងឃ្លោកក្នុងស្រែនោះ បុគ្គលក៏គប្បីពោលបានថា អន្តរធានទៅហើយ, ត្រូវបុរសទម្លាយហើយ យ៉ាងណា, តណ្ហាក្នុងអាយតនៈទាំងឡាយមានចក្ខាយតនៈជាដើម ក៏យ៉ាងនោះដែរ ដូចទងឃ្លោកក្នុងស្រែ; តណ្ហានោះត្រូវអរិយមគ្គផ្តាច់ឫសហើយព្រោះអាស្រ័យព្រះនិព្វាន ទើបដល់សេចក្តីប្រព្រឹត្តទៅមិនបាន; ក៏តណ្ហានោះ ដល់សេចក្តីប្រព្រឹត្តទៅយ៉ាងនេះ រមែងមិនប្រាកដក្នុងវត្ថុទីតាំងទាំងនោះ ដូចទងឃ្លោកក្នុងស្រែកាលមិនប្រាកដដូច្នោះ ។

ក៏ពួករាជបុរសនាំពួកចោរមកពីដងព្រៃហើយ គប្បីប្រហារជីវិតត្រង់ទ្វារទិសទក្សិណនៃនគរ, តពីនោះ នរណា១ ក៏គប្បីពោលថា ចោរក្នុងដងព្រៃស្លាប់ហើយ ឬចោរត្រូវរាជបុរសសម្លាប់ហើយ យ៉ាងណា, តណ្ហាក្នុងអាយតន មានចក្ខាយតនៈជាដើមឯណា ដែលដូចពពួកចោរក្នុងដង ព្រៃក៏យ៉ាងនោះដែរ រលត់ទៅហើយ

ព្រោះអាស្រ័យព្រះនិព្វាន ឈ្មោះថា រលត់ទៅក្នុងព្រះនិព្វានដូចពួកចោរត្រូវគេប្រហារត្រង់ទ្វារទិសទក្សិណ; ក៏តណ្ហានោះរលត់ហើយយ៉ាងនេះ ទើបមិនប្រាកដក្នុងវត្ថុទីតាំងទាំងនោះ ដូចពួកចោរមិនប្រាកដក្នុងដងព្រៃដូច្នោះ; ព្រោះហេតុនោះ កាលព្រះភគវាទ្រង់សម្តែងការរលត់តណ្ហានោះក្នុងអារម្មណ៍ មានចក្ខុជាដើមទាំងនោះៗ ឯង ទើបត្រាស់ពាក្យមានជាអាទិ៍ថា "**ចក្ខុំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ; ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ** = ចក្ខុជាបិយរូប និងសាតរូបក្នុងលោក តណ្ហានេះកាលបើនឹងលះ រមែងលះត្រង់ចក្ខុនេះ កាលបើនឹងរលត់ រមែងរលត់ត្រង់ចក្ខុនេះ" ។ ពាក្យដ៏សេសក្នុងទីទាំងពួងក៏មានសេចក្តីងាយដូចគ្នាដែរ ៕

## សម្តែងអំពីនិរោធសច្ចនិទ្ទេសចប់

# ពណ៌នានិទ្ទេសវារៈ

## សម្តែងអំពីមគ្គសច្ចនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនៃមគ្គសច្ចនិទ្ទេស** តទៅ ៖

បទថា "**អយមេវ** = នេះប៉ុណ្ណោះ" ជាពាក្យកំណត់ពិតប្រាកដ ដើម្បីបដិសេធមគ្គដទៃ ។ បទថា "**អរិយោ** = អរិយៈ" សេចក្តីថា ក៏ឈ្មោះថា **អរិយៈ** ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ដែលសម្លាប់ដោយមគ្គនោះៗ ព្រោះធ្វើភាពជាអរិយៈ និងព្រោះធ្វើការបានចំពោះនូវអរិយផល ។ អង្គ ៨ របស់មគ្គនោះ រមែងមាន ព្រោះហេតុនោះ មគ្គនោះទើបឈ្មោះថា **អដ្ឋង្គិកោ** = មានអង្គ ៨; អង្គ ៨

របស់មគ្គនេះឯង គ្រាន់ជាអង្គប៉ុណ្ណោះ ដូចសេនាមានអង្គ ៤ និងតន្ត្រីមានអង្គ ៥, ខ្វះអង្គណាមួយមិនបានឡើយ ។ ក៏ឈ្មោះថា **មគ្គ** ព្រោះអត្ថថា ដែលអ្នកត្រូវការព្រះនិព្វានរមែងស្វែងរក ឬរមែងស្វែងរកព្រះនិព្វាន ឬក៏ជាសភាវៈសម្លាប់កិលេសទាំងឡាយហើយទៅ ។ សព្ទថា **សេយ្យថីទំ** សេចក្ដីថា បើមានអ្នកសួរថា "អង្គមគ្គនោះ តើដូចម្ដេច ?" ។

ឥឡូវនេះ ព្រះសក្យមុនី កាលបើនឹងទ្រង់សម្ដែងថា មគ្គ គឺគ្រាន់តែជាអង្គនោះឯង ក្រៅពីអង្គមគ្គរមែងមិនមាន ទើបត្រាស់ថា "**សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ**" ; បណ្ដាអង្គទាំង ៨ នោះ ៖

**សម្មាទស្សនលក្ខណោ** សម្មាទិដ្ឋិ មានការឃើញដោយប្រពៃជាលក្ខណៈ

**សម្មាអភិនិរោបនលក្ខណោ** សម្មាសង្កប្បៈ មានការលើកសម្បយុត្តធម៌ឡើងដោយប្រពៃជាលក្ខណៈ ។

**សម្មាបរិគ្គហលក្ខណោ** សម្មាវាចា មានការកំណត់យកដោយប្រពៃ ជាលក្ខណៈ ។

**សម្មាសមុដ្ឋានបនលក្ខណោ** សម្មាកម្មន្តៈ មានការងារតាំងឡើងល្អ ដោយប្រពៃជាលក្ខណៈ ។

**សម្មា វោទានលក្ខណោ** សម្មាអាជីវៈ មានអាជីវៈដែលផូរផង់ដោយប្រពៃជាលក្ខណៈ ។

**សម្មាបគ្គហលក្ខណោ** សម្មាវាយាមៈ មានការព្យាយាមផ្គងទុកដោយប្រពៃជាលក្ខណៈ ។

**សម្មា ឧបដ្ឋានលក្ខណា**[១១២] សម្មាសតិ មានការប្រាកដដោយប្រពៃ ជាលក្ខណៈ ។

**សម្មាសមាធានលក្ខណោ** សម្មាសមាធិ មានការតាំងចិត្តមាំ ដោយប្រពៃជាលក្ខណៈ ។

បណ្ដាអង្គមគ្គទាំង ៨ នោះ តែគ្រប់ៗ អង្គមគ្គមានកិច្ច គឺនាទីមួយអង្គមគ្គៗ មាន ៣ ។ តើយ៉ាងណា ? គឺ**សម្មាទិដ្ឋិ** រមែងលះមិច្ឆាទិដ្ឋិ និងកិលេសដែលជាសឹកសត្រូវរបស់ខ្លួន សូម្បីដទៃៗ បាន ១, រមែងធ្វើនិរោធឱ្យប្រាកដ ១, រមែងឃើញសម្បយុត្តធម៌ទាំងឡាយ ព្រោះមិនវង្វេងដោយអំណាចនៃការកម្ចាត់មោហៈដែលបិទបាំងសម្បយុត្តធម៌នោះៗ បាន ១; សូម្បីសម្មាសង្កប្បៈជាដើម ក៏ដូចគ្នានេះដែរ រមែងលះមិច្ឆាសង្កប្បៈជាដើម, រមែងធ្វើនិរោធឱ្យជាអារម្មណ៍, តែក្នុងសម្មាសង្កប្បៈជាដើមនេះ ពេលដោយសេចក្ដីប្លែកគ្នា សម្មាសង្កប្បៈ រមែងលើកឡើងនូវសហជាតធម៌, សម្មាវាចា រមែងកំណត់យកទុកដោយប្រពៃ, សម្មាវាចា រមែងកំណត់យកទុកដោយប្រពៃ, សម្មាកម្មន្តៈ រមែងញុំាងការងារឱ្យតាំងឡើងល្អ ដោយប្រពៃ, សម្មាអាជីវៈ រមែងញុំាងអាជីវៈឱ្យផូរផង់ដោយប្រពៃ, សម្មាវាយាមៈ រមែងផ្គងទុក ដោយប្រពៃ, សម្មាសតិ រមែងប្រាកដដោយប្រពៃ, សម្មាសមាធិ រមែងតាំងមាំដោយប្រពៃ ។

---

[១១២] ពាក្យថា **ឧបដ្ឋានលក្ខណា** នេះ ចំពោះពាក្យថា ឧបដ្ឋាន មានពាក្យប្រែច្រើនយ៉ាង គឺប្រែថា មានការប្រាកដខ្លះ មានការបម្រុងខ្លះ មានការបដិបត្តិខ្លះ មានការតាំងមាំខ្លះ ។

ម្យ៉ាងវិញទៀត ធម្មតាសម្មាទិដ្ឋិនេះ ក្នុងចំណែកខាងដើម (លោកិយមគ្គ) មានខណៈផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា, ក្នុងកាលនៃមគ្គមានខណៈជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ក៏ពោលដោយកិច្ច (នាទី) រមែងបានឈ្មោះ ៤ យ៉ាង មានពាក្យជាអាទិ៍ថា **“ទុក្ខេ ញាណំ** = ដឹងក្នុងកងទុក្ខ” ។ សូម្បីក្នុងសម្មាសង្កប្បៈជាដើម ក្នុងចំណែកខាងដើមមានខណៈផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា ក្នុងកាលនៃមគ្គមានខណៈជាមួយគ្នា មានអារម្មណ៍ដូចគ្នា; បណ្តាអង្គមគ្គ ៧ មានសម្មាសង្កប្បៈជាដើមនោះ ពេលដោយកិច្ច (នាទី) សម្មាសង្កប្បៈ រមែងបាន ឈ្មោះ ៣ យ៉ាងថា **នេក្ខម្មសង្កប្បៈ** ជាដើម ។ អង្គមគ្គ ៣ មាន សម្មាវាចាជាដើម ក្នុងចំណែកខាងដើមមានខណៈផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា គឺរមែងជាវិរតិខ្លះ, ជាចេតនាខ្លះ;តែក្នុងខណៈនៃមគ្គជាវិរតិតែម្យ៉ាង ។ សូម្បីអង្គ ២ នេះ គឺសម្មាវាយាមៈ សម្មាសតិ ពោលដោយកិច្ចរមែងបានឈ្មោះ ៤ យ៉ាង ដោយអំណាចនៃសម្មប្បធាន និងសតិប្បដ្ឋាន; ចំណែកសម្មាសមាធិក្នុងចំណែកខាងដើមក្តី ក្នុងខណៈនៃមគ្គក្តី ក៏ឈ្មោះថា សម្មាសមាធិនោះដែរ ៕

## សម្តែងអំពីធម៌ ៨ យ៉ាងតាមលំដាប់

ក្នុងធម៌ទាំង ៨ តាមដែលសម្តែងមកហើយនេះ ព្រះសយម្ភូទ្រង់សម្តែងសម្មាទិដ្ឋិជាមុន ព្រោះជាធម៌មានឧបការៈច្រើនដល់ព្រះយោគីអ្នកបដិបត្តិដើម្បីពន្លុះព្រះនិព្វាន; ព្រោះសម្មាទិដ្ឋិនេះ ព្រះអង្គត្រាស់ហៅថា “ប្រទីបដែលបំភ្លឺទូទៅ គឺ

បញ្ញា (បញ្ញាបជ្ជោតោ) សត្ថា គឺបញ្ញា (បញ្ញាសត្ថំ)”[១១៣] ដូច្នេះជាដើម; ព្រោះហេតុដូច្នោះ ព្រះយោគាវចរអ្នកទម្លាយសេចក្តីងងឹត គឺអវិជ្ជាដោយសម្មាទិដ្ឋិ ពោលគឺវិបស្សនាញាណក្នុងចំណែកខាងដើមពីនេះ ហើយសម្លាប់ចោរ គឺកិលេស រមែងពន្លុះព្រះនិព្វានបានដោយមិនមានភ័យ; ដោយហេតុនោះ ទើបខ្ញុំពោលថា “ព្រះសយម្ភូទ្រង់សម្តែងសម្មាទិដ្ឋិមុន ព្រោះជាធម៌មានឧការៈច្រើនដល់ព្រះយោគី អ្នកបដិបត្តិដើម្បីពន្លុះព្រះនិព្វាន” ដូច្នេះ ។

ក៏សម្មាសង្កប្បៈ ជាធម៌មានឧបការៈច្រើនដល់សម្មាទិដ្ឋិនោះ; ព្រោះហេតុដូច្នោះ ទើបត្រាស់ទុកក្នុងលំដាប់សម្មាទិដ្ឋិនោះ; ឧបមាដូចហេរញ្ញិក (អ្នកកាន់ប្រាក់) ប្រើដៃប្តូរប្រាក់ត្រឡប់ទៅវិញទៅមក ហើយត្រួតត្រាមើលកហាបណៈដោយភ្នែក រមែងដឹងថា “កហាបណៈនេះអាក្រក់ កហាបណៈនោះល្អ” ដូច្នេះយ៉ាងណា, សូម្បីព្រះយោគាវចរ ក៏យ៉ាងនោះដែរ ប្រើវិតក្កៈត្រិះរិះហើយៗ ក្នុងកាលចំណែកខាងដើម ហើយត្រួតមើលដោយវិបស្សនាបញ្ញា ក៏នឹងជ្រាបបានថា “ធម៌ទាំងនេះជាកាមាវចរ ធម៌ទាំងនេះជារូបាវចរ” ដូច្នេះ ឬក៏ថា ឧបមាដូចជាងចាំងឈើ ប្រើកាំបិតចាំងកំណាត់ឈើធំ ដែលបុរសចាប់ត្រង់ចុងផ្លាស់ប្តូរត្រឡប់ទៅមកដោយជុំវិញឱ្យហើយ រមែងនាំទៅក្នុងការងារបានយ៉ាងណា, ព្រះយោគាវចរក៏យ៉ាងនោះដែរ កំណត់ធម៌ទាំងឡាយដែលវិតក្កៈត្រិះរិះហើយៗ ឱ្យដោយន័យមាន

---

[១១៣] អភិ. ។

ជាអាទិ៍ថា "ធម៌ទាំងនេះជាកាមាវចរ ធម៌ទាំងនេះជារូបាវចរ" ដោយបញ្ញាដូច្នេះហើយ រមែងបង្អោនទៅក្នុងការងារបាន; ដោយហេតុនោះ ទើបពោលថា "ក៏សម្មាសង្កប្បៈជាធម៌មានឧការៈច្រើនដល់សម្មាទិដ្ឋិនោះ; ព្រោះហេតុដូច្នោះ ទើបព្រះភគវាត្រាស់សម្មាសង្កប្បៈ ក្នុងលំដាប់នៃសម្មាទិដ្ឋិនោះ" ។

សម្មាសង្កប្បៈនេះ ជាធម៌មានឧបការៈច្រើនសូម្បីដល់សម្មាវាចា ដូចជាមានឧបការៈច្រើនដល់សម្មាទិដ្ឋិដែរ; ដូចយ៉ាងដែលត្រាស់ទុកថា "ម្នាលគហបតីបុគ្គលត្រិះរិះហើយ ពិចារណាហើយជាមុន ទើបបញ្ចេញវាចាខាងក្រោយ"[១១៤] ដូច្នេះ; ព្រោះហេតុដូច្នោះ ទើបព្រះអង្គត្រាស់សម្មាវាចាទុកក្នុងលំដាប់របស់សម្មា-សង្កប្បៈនោះ ។

ក៏ព្រោះជនទាំងឡាយ ចាត់ចែងហើយដោយវាចាជាមុនថា "ពួកយើងនឹងធ្វើវត្ថុនេះៗ" ដូច្នេះ ហើយទើបប្រកបការងារក្នុងលោក, ព្រោះហេតុដូច្នោះ ទើបវាចាជាធម៌មានឧបការៈដល់កាយកម្ម ព្រោះហេតុនោះ ទើបត្រាស់សម្មា-កម្មន្តៈក្នុងលំដាប់នៃសម្មាវាចានោះ ។

ក៏ព្រោះអាជីវមដ្ឋកសីល (សីលមានអាជីវៈជាទី ៨) រមែងពេញដល់បុគ្គលអ្នកលះវចីទុច្ចរិត ៤ កាយទុចរិត ៣ ញ៉ាំងសុច្ចរិតទាំងពីរឱ្យបរិបូណ៌នោះឯង, មិនមែនពេញដល់បុគ្គលក្រៅនេះទេ; ព្រោះហេតុដូច្នោះ ទើបត្រាស់សម្មាអាជីវៈក្នុងលំដាប់នៃសុចរិតទាំងពីរនោះ ។

---

[១១៤] ម. ម. ។

ព្រះភគវាដើម្បីនឹងទ្រង់សម្ដែងចំពោះបុគ្គល អ្នកមានអាជីវៈបរិសុទ្ធហើយ យ៉ាងនេះ មិនសមគួរពេញចិត្តត្រឹមតែប៉ុណ្ណេះថា "អាជីវៈរបស់យើងបរិសុទ្ធិហើយ" ដូច្នេះ ជាមនុស្សប្រមាទ ដូចមនុស្សដេកលក់, ដោយពិត គួរផ្ដើមការព្យាយាមនេះក្នុងគ្រប់ឥរិយាបថ ដូច្នេះ ទើបត្រាស់សម្មាវាយាមៈ ក្នុងលំដាប់នៃសម្មាអាជីវៈនោះ ។

តពីនោះ ដើម្បីនឹងទ្រង់សម្ដែងថា "ព្រះយោគាវចរ សូម្បីមានសេចក្ដីព្យាយាមផ្ដើមហើយ ក៏គប្បីធ្វើសតិឱ្យតាំងមាំយ៉ាងល្អក្នុងវត្ថុទាំង ៤ មានកាយជាដើម"[១១០] ទើបទ្រង់សម្ដែងសម្មាសតិ ក្នុងលំដាប់នៃសម្មាវាយាមៈនោះ ។

ក៏ព្រោះសតិតាំងមាំល្អយ៉ាងនេះហើយ ក៏នឹងត្រួតត្រាមើលគតិនៃធម៌ទាំងឡាយដែលមានឧបការៈ និងមិនមានឧបការៈដល់សម្មាសមាធិ ទើបត្រឹមតែដើម្បីតាំងចិត្តមាំក្នុងអារម្មណ៍តែមួយបាន (ឯកគ្គតា), ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ព្រះមានជោគទ្រង់សម្ដែងសម្មាសមាធិទុកក្នុងលំដាប់នៃសម្មាសតិដូច្នេះ ៕

## **សម្ដែងអំពីសម្មាទិដ្ឋិនិទ្ទេស**

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិទ្ទេសនៃសម្មាទិដ្ឋិ** តទៅ ៖

កម្មដ្ឋានក្នុងសច្ចៈ ៤ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងដោយព្រះតម្រាស់

---

[១១០] គឺ កាយ វេទនា ចិត្ត និងធម៌ ។

មានជាអាទិ៍ថា "**ទុក្ខេ ញាណំ** = ដឹងក្នុងកងទុក្ខ" ដូច្នេះ ។ បណ្ដាសច្ចៈទាំង ៤ នោះ សច្ចៈ ២ ខាងដើមជាវដ្ដៈ, សច្ចៈ ២ ខាងក្រោយជាវិវដ្ដៈ; ក្នុងសច្ចៈដែលជាវដ្ដៈ និងវិវដ្ដៈទាំងនោះ ភិក្ខុរមែងមានសេចក្ដីប្រកាន់កម្មដ្ឋានក្នុងសច្ចៈ ដែលជាវដ្ដៈ, មិនមានសេចក្ដីប្រកាន់ក្នុងសច្ចៈដែលជាវិវដ្ដៈ ។

ពិតណាស់ ព្រះយោគាវចរអ្នករៀនសច្ចៈ ២ ខាងដើម ក្នុងសំណាក់អាចារ្យ ដោយបំប្រួញយ៉ាងនេះថា "ខន្ធ ៥ ជាទុក្ខ, តណ្ហាជាសមុទ័យ" ដូច្នេះ និងដោយពិស្ដារ មានន័យជាអាទិ៍ថា "ខន្ធ ៥ តើដូចម្ដេច ?, គឺរូបក្ខន្ធ" ដូច្នេះ ហើយនិយាយ សារឡើងវិញដោយវាចាញយ១ **ទើបធ្វើកម្ម** ។ តែក្នុងសច្ចៈ ២ ក្រៅនេះ ព្រះយោគាវចររមែងធ្វើកម្មដោយការស្ដាប់យ៉ាងនេះថា "និរោធសច្ច គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត, មគ្គសច្ចៈ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត" ដូច្នេះ; កាលបើលោកធ្វើយ៉ាងនេះ រមែងចាក់ធ្លុះសច្ចៈទាំង ៤ ដោយការចាក់ធ្លុះព្រមគ្នា រមែងត្រាស់ដឹងដោយការត្រាស់ដឹងព្រមគ្នា; គឺចាក់ធ្លុះទុក្ខដោយការចាក់ធ្លុះ គឺការកំណត់ដឹង (បរិញ្ញាបដិវេធ), រមែងចាក់ធ្លុះសមុទ័យ ដោយការចាក់ធ្លុះ គឺការលះបង់ (បហានបដិវេធ), រមែងចាក់ធ្លុះនិរោធ ដោយការចាក់ធ្លុះ គឺការធ្វើឱ្យជាក់ច្បាស់ (សច្ឆិកិរិយាបដិវេធ), រមែងចាក់ធ្លុះមគ្គដោយការចាក់ធ្លុះ គឺការចម្រើន (ភាវនាបដិវេធ); រមែងត្រាស់ដឹងទុក្ខដោយការត្រាស់ដឹង គឺការកំណត់ដឹង ។ល។ រមែងត្រាស់ដឹងមគ្គដោយការត្រាស់ដឹង គឺការចម្រើន ។

ការចាក់ធ្លុះ (បដិវេធ) ដោយការរៀន ការសាកសួរ ការស្ដាប់ ការទ្រទ្រង់ និងការពិចារណាក្នុងសច្ចៈ ២ ក្នុងចំណែកខាងដើមរបស់ភិក្ខុនោះ រមែងមាន

ដោយប្រការដូច្នេះ, ក្នុងសច្ចៈ ២ ក្រោយ មានការចាក់ធ្លុះដោយការស្តាប់តែម្យ៉ាង ។ ក្នុងចំណែកដទៃទៀត រមែងមានការចាក់ធ្លុះក្នុងសច្ចៈ ៣ ដោយកិច្ច, ការចាក់ធ្លុះដោយអារម្មណ៍ រមែងមានក្នុងនិរោធ; ក្នុងការចាក់ធ្លុះដោយកិច្ច និងអារម្មណ៍ទាំងនោះ សេចក្តីដឹងដោយបដិវេធ (បដិវេធញ្ញាណ) សូម្បីទាំងអស់ជាលោកុត្តរ; សេចក្តីដឹងដោយការស្តាប់ ការទ្រទ្រង់ និងការពិចារណា ជាលោកិយខាងកាមាវចរ; ក៏មគ្គសច្ច រមែងមានបច្ចវេក្ខណៈ; ក៏យោគាវចរនេះ ក៏ជាអាទិកម្មិកបុគ្គល, ព្រោះហេតុដូច្នោះ បច្ចវេក្ខណៈ (គឺការពិចារណា) នោះ ទើបខ្ញុំមិនពោលទុកក្នុងទីនេះ ។

ម្យ៉ាងទៀត ការនឹក ការដាក់ (ផ្តោត) ចិត្ត ការធ្វើទុកក្នុងចិត្ត ការពិចារណា រមែងមិនមានដល់ភិក្ខុនេះ អ្នកកាន់យកទុកក្នុងខាងដើមថា "យើងនឹងកំណត់ដឹងទុក្ខ, នឹងលះសមុទ័យ, នឹងធ្វើនិរោធឱ្យជាក់ច្បាស់, នឹងចម្រើនមគ្គ" ដូច្នេះ; តែរមែងមានចាប់ផ្តើមពីការកំណត់កាន់យក; ចំណែកក្នុងកាលដទៃទៀត ទុក្ខរមែងជាការដែលលោកដឹងហើយដោយពិត ។ល។ មគ្គក៏រមែងជាការចម្រើនហើយដូចគ្នា ។

បណ្តាសច្ចៈទាំង ៤ នោះ សច្ចៈ ២ នឹងជាធម៌ជ្រាលជ្រៅ ព្រោះសត្វឃើញបានដោយលំបាក; សច្ចៈ ២ ក៏ឈ្មោះថា ឃើញបានដោយលំបាក ព្រោះជ្រាលជ្រៅ; ពិតមែន ទុក្ខសច្ចជារបស់ប្រាកដព្រោះកើតឡើងហើយ, រមែងដល់សូម្បីពាក្យដែលបុគ្គលគប្បីពោលថា "ទុក្ខហ្ន៎" ក្នុងវេលាដែលពាល់ត្រូវ ឬបន្លាមុតជាដើម ។ សូម្បីសមុទ័យក៏ប្រាកដដោយការកើតឡើង ដោយអំណាចនៃបុគ្គលអ្នកប្រាថ្នានឹងទំពា

ស៊ី និងបរិភោគ; ក៏សូម្បីសច្ចៈទាំង ២ នោះ ជារបស់ជ្រៅដោយការចាក់ធ្លុះជាលក្ខណៈ; ក៏សច្ចៈទាំង ២ នោះ ឈ្មោះថា **ជ្រាលជ្រៅ** ព្រោះសត្វឃើញបានលំបាកដោយប្រការដូច្នេះ ។ ការប្រកបសេចក្តីព្យាយាមដើម្បីនឹងឃើញសច្ចៈ ២ ក្រៅនេះ (និរោធ និងមគ្គ) រមែងដូចការលាដៃទៅដើម្បីចាប់ភពព្រហ្ម ដូចការលាជើងដើម្បីពាល់ត្រូវអវីចិនរក និងហាក់ដូចយកចុងរោមសត្វ ទល់ចុងរោមសត្វដែលច្រៀក ហើយទាំងរយចម្រៀក[១១៦]; សច្ចៈទាំង ២ នោះ ឈ្មោះថា ឃើញបានលំបាកព្រោះ ជ្រាលជ្រៅ ដោយប្រការដូច្នេះ ។ ពាក្យដែលព្រះមានព្រះភាគត្រាស់ថា **"ទុក្ខេ ញាណំ"** ដូច្នេះនេះ ទ្រង់សំដៅយកសេចក្តីកើតឡើងនៃញាណ ក្នុងបុព្វភាគ ដោយអំណាចនៃការរៀនជាដើមក្នុងសច្ចៈ ៤ ក៏ឈ្មោះថា ជ្រាលជ្រៅព្រោះឃើញបាន និងឈ្មោះថា ឃើញបានដោយលំបាក ព្រោះសេចក្តីជ្រាលជ្រៅដោយប្រការដូច្នេះ; តែក្នុងខណៈនៃការចាក់ធ្លុះញាណនោះ រមែងមានមួយគ្រាដូច្នេះឯង ៕

## សម្តែងអំពីសម្មាសង្កប្បនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិទ្ទេសនៃសម្មាសង្កប្បៈ** តទៅ ៖

**សង្កប្បៈ** (សេចក្តីត្រិះរិះ) ឯណា ក្រៅអំពីកាម ព្រោះហេតុនោះ ទើប

---

[១១៦] ខ្លះសម្តែងថា យកចុងរោមទ្រាយ ទល់ចុងរោមទ្រាយដែលបែងហើយជា ៧ ចំណែក ។

សង្កប្បៈនោះ ឈ្មោះថា **នេក្ខម្មសង្កប្បៈ** (សេចក្តីត្រិះរិះក្នុងការចេញចាកកាម) ។ សង្កប្បៈណា ក្រៅពីព្យាបាទ ព្រោះហេតុនោះ ទើបសង្កប្បៈនោះ ឈ្មោះថា **អព្យាបាទសង្កប្បៈ** (សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ) ។ សង្កប្បៈណា ក្រៅពីសេចក្តីបៀតបៀន ព្រោះហេតុនោះ ទើបសង្កប្បៈនោះ ឈ្មោះថា **អវិហិង្សាសង្កប្បៈ** (សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន) ។

បណ្តាសង្កប្បៈទាំង ៣ នោះ នេក្ខម្មវិតក្កៈកើតឡើង ធ្វើការកាត់ផ្លូវ គឺការទម្លាយផ្លូវជាគ្រឿងដើររបស់កាមវិតក្កៈ, អព្យាបាទវិតក្កៈកើតឡើង ធ្វើការកាត់ផ្លូវ គឺទម្លាយផ្លូវជាគ្រឿងដើររបស់ព្យាបាទវិតក្កៈ, អវិហិង្សាវិតក្កៈកើតឡើង ធ្វើការកាត់ផ្លូវ គឺទម្លាយផ្លូវជាគ្រឿងដើររបស់វិហិង្សាវិតក្កៈ ។ ម្យ៉ាងទៀត នេក្ខម្មវិតក្កៈកើតឡើងជាសត្រូវចំពោះកាមវិតក្កៈ, អព្យាបាទ និងអវិហឹង្សាវិតក្កៈកើតឡើងជាសត្រូវចំពោះព្យាបាទវិតក្កៈ និងវិហិង្សាវិតក្កៈ ។

ក្នុងវិតក្កៈទាំងនោះ ព្រះយោគាវចររមែងពិចារណាកាមវិតក្កៈ ឬសង្ខារអ្វី១ ដទៃ ដើម្បីទម្លាយផ្លូវរបស់កាមវិតក្កៈ; បន្ទាប់ពីនោះ សេចក្តីត្រិះរិះរបស់លោកដែលសម្បយុត្តដោយវិបស្សនា ក្នុងខណៈនៃវិបស្សនាក៏នឹងកើតឡើងធ្វើការកាត់ផ្លូវ គឺទម្លាយផ្លូវរបស់កាមវិតក្កៈ ដោយអំណាចនៃអង្គរបស់វិបស្សនានោះ១ (តទង្គប្បហាន), លោកខ្វល់ខ្វាយ (ចម្រើន) វិបស្សនា ក៏នឹងពន្លុះមគ្គបាន; លំដាប់នោះ សង្កប្បៈ (សេចក្តីត្រិះរិះ) ដែលសម្បយុត្ត ដោយមគ្គក្នុងខណៈនៃមគ្គ របស់លោកក៏កើតឡើងធ្វើការកាត់ផ្លូវ គឺទម្លាយគ្រឿងដើររបស់កាមវិតក្កៈ ដោយអំណាចនៃសមុច្ឆេទ ។ ម្យ៉ាងទៀត ព្រះយោគាវចររមែងពិចារណាព្យាបាទវិតក្កៈ ឬសង្ខារ

ដទៃ ដើម្បីទម្លាយផ្លូវរបស់ព្យាបាទវិតក្កៈ ឬរមែងពិចារណាវិហិង្សាវិតក្កៈ ឬក៏សង្ខារដទៃ ដើម្បីទម្លាយផ្លូវរបស់វិហិង្សាវិតក្កៈ; តពីនោះ គប្បីប្រកបពាក្យទាំងពួង ក្នុងខណៈនៃវិបស្សនារបស់លោកដោយន័យ មានក្នុងកាលមុននោះឯង ៗ

## កម្មដ្ឋានដែលជាសត្រូវចំពោះអកុសលវិតក្កៈ ៣

ម្យ៉ាងទៀត ក្នុងអារម្មណ៍កម្មដ្ឋាន ៣៨ ដែលចែកទុកក្នុងព្រះបាលី **សូម្បីកម្មដ្ឋានមួយ** ឈ្មោះថា មិនជាសត្រូវចំពោះអកុសលវិតក្កៈ ៣ មានកាមវិតក្កៈជាដើម មិនមានទេ (គឺមាន) ។ ក៏បឋមជ្ឈានក្នុងអសុភទាំងឡាយទាំងអស់នុ៎ះឯង មុនដំបូងជាសត្រូវ ចំពោះកាមវិតក្កៈដោយចំណែកមួយ, ឈានពួក ៣ ពួក ៤ (បញ្ចកន័យ) ក្នុងមេត្តា ជាបដិបក្សចំពោះព្យាបាទវិតក្កៈ, ពួក ៣ និងពួក ៤ ក្នុងករុណា ជាបដិបក្សចំពោះវិហឹង្សាវិតក្កៈ; ព្រោះហេតុដូច្នោះ កាលព្រះយោគាវចរធ្វើបរិកម្មក្នុងអសុភចូលឈាន សង្កប្បៈ (ការត្រិះរិះ) ដែលសម្បយុត្តដោយឈានក្នុងខណៈនៃសមាបត្តិ ក៏នឹងកើតជាសត្រូវចំពោះកាមវិតក្កៈដោយអំណាចនៃវិក្ខម្ភនៈ; កាលព្រះយោគាវចរធ្វើឈានឱ្យជាបាទ ហើយផ្ដើមតាំងវិបស្សនា សង្កប្បៈដែលសម្បយុត្តដោយវិបស្សនាក្នុងខណៈនៃវិបស្សនា ក៏រមែងកើតជាបដិបក្ខចំពោះកាមវិតក្កៈដោយអំណាចនៃអង្គរបស់វិបស្សនា (តទង្គប្បហាន) នោះ; កាលលោកខ្វល់ខ្វាយ (ចម្រើន) វិបស្សនាពន្លុះមគ្គហើយ សង្កប្បៈដែលសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គ ក៏កើតឡើងជាបដិបក្ខចំពោះកាមវិតក្កៈ ដោយអំណាចនៃសមុច្ឆេទប្បហាន;

សង្កប្បៈ (សេចក្តីត្រិះរិះ) ដែលកើតឡើងយ៉ាងនេះ គប្បីជ្រាបថា **នេក្ខម្មសង្កប្បៈ** នោះឯង ។

ម្យ៉ាងទៀត បណ្ឌិតគប្បីប្រកបពាក្យទាំងពួងថា "ព្រះយោគាវចរធ្វើបរិកម្មក្នុងមេត្តាភាវនា, ធ្វើបរិកម្មក្នុងករុណាភាវនា ចូលឈាន" ដូច្នេះជាដើម ដោយន័យមុននោះឯង; គប្បីជ្រាបថា សង្កប្បៈដែលកើតឡើងហើយយ៉ាងនេះ ត្រាស់ហៅថា អព្យាបាទសង្កប្បៈ និងអវិហិង្សាសង្កប្បៈ; សង្កប្បៈទាំងនេះ មាននេក្ខម្មសង្កប្បៈជាដើមដោយអាការៈយ៉ាងនេះ ឈ្មោះថា មានអារម្មណ៍ផ្សេងៗ ក្នុងចំណែកខាងដើម ព្រោះសេចក្តីដែលសង្កប្បៈទាំងនោះ កើតឡើងមានអារម្មណ៍ ផ្សេងគ្នាដោយអំណាចនៃវិបស្សនា និងឈាន; តែក្នុងខណៈនៃមគ្គ កុសលសង្កប្បៈ (សេចក្តីត្រិះរិះដែលជាកុសល) រមែងកើតឡើងជាមួយគ្នា ធ្វើអង្គនៃមគ្គឱ្យបរិបូណ៌ ព្រោះកាត់ផ្លូវដើររបស់អកុសលសង្កប្បៈ ដែលកើតឡើងក្នុងឋានៈទាំង ៣ នេះ ដោយអំណាចនៃការមិនកើតឡើងបានសម្រេច ។ នេះឈ្មោះថា **សម្មាសង្កប្បៈ**៕

## សម្តែងអំពីសម្មាវាចានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យសូម្បី **ក្នុងនិទ្ទេសនៃសម្មាវាចា** តទៅ ៖

ម្យ៉ាងទៀត ព្រោះបុគ្គលរមែងវៀរនូវមុសាវាទ ដោយចិត្តមួយដួង, រមែងវៀរបិសុណាវាចាជាដើម ដោយចិត្តមួយដួង, ព្រោះហេតុដូច្នោះ ចេតនាជាគ្រឿងវៀរចាកទាំង ៤ នេះ ទើបផ្សេងៗ គ្នាក្នុងចំណែកខាងដើម; តែក្នុងខណៈនៃមគ្គ រមែងកើតចេតនាដែលជាកុសល ពោលគឺសម្មាវាចាតែម្យ៉ាងប៉ុណ្ណោះ ដែលញុំាង

អង្គមគ្គឱ្យបរិបូរ ព្រោះកាត់ផ្លូវដើរនៃចេតនាភាពជាអ្នក (ជាហេតុ) ទ្រុស្តសីលក្នុងអកុសល ៤ យ៉ាង ពោលគឺមិច្ឆាវាចាដោយអំណាចនៃការមិនឱ្យកើតឡើង បានសម្រេច ។ **នេះឈ្មោះថា សម្មាវាចា** ៕

## អំពីសម្មាកម្មន្តនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុង**និទ្ទេសនៃសម្មាកម្មន្តៈ** តទៅ ៖

ម្យ៉ាងទៀត ព្រោះបុគ្គលរមែងវៀរចាកបាណាតិបាត ដោយចិត្តមួយដួង, រមែងវៀរចាកអទិន្នាទាន ដោយចិត្តមួយដួង, រមែងវៀរចាកកាមេសុមិច្ឆាចារ ដោយចិត្តមួយដួង, ព្រោះហេតុដូច្នោះ ចេតនាជាគ្រឿងវៀរចាកទាំង ៣ នេះ ទើបផ្សេងៗ គ្នា ក្នុងចំណែកខាងដើម; តែក្នុងខណៈនៃមគ្គ រមែងកើតកុសលចេតនា ជាគ្រឿងវៀរចាក ពោលគឺសម្មាកម្មន្តៈមួយដួងប៉ុណ្ណោះ ដែលញុំាងអង្គមគ្គឱ្យបរិបូណ៌ ព្រោះកាត់ផ្លូវដើររបស់ចេតនាជាហេតុទ្រុស្តសីលក្នុងអកុសល ៣ យ៉ាង ពោលគឺមិច្ឆាកម្មន្តៈ ដោយអំណាចនៃសេចក្តីមិនឱ្យកើតឡើងបានសម្រេច ។ **នេះឈ្មោះថា សម្មាកម្មន្តៈ**៕

## សម្តែងអំពីសម្មាអាជីវនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិទ្ទេសនៃសម្មាអាជីវៈ** តទៅ ៖

បទថា **"ឥធ"** បានដល់ ក្នុងសាសនានេះ ។ បទថា **"អរិយសាវកោ"**

បានដល់ អរិយសាវ័ករបស់ព្រះពុទ្ធ ។ បទថា **"មិច្ឆាអាជីវំ បហាយ** = លះមិច្ឆា-អាជីវៈហើយ" បានដល់ លះដាច់នូវមិច្ឆាអាជីវៈដ៏លាមក ។ បទថា **"សម្មាអាជីវេន** = ដោយសម្មាអាជីវៈ" បានដល់ អាជីវៈជាកុសលដែលព្រះពុទ្ធជាម្ចាស់ ទ្រង់សរសើរហើយ ។ បទថា **"ជីវិតំ កប្បេតិ** = ចិញ្ចឹមជីវិត" បានដល់ ញ៉ាំងសេចក្ដីប្រព្រឹត្តទៅនៃជីវិតឱ្យដំណើរទៅ ។ សូម្បីក្នុងសម្មាអាជីវៈនេះ បុគ្គលរមែងវៀរចាកការឈានកន្លងផ្លូវកាយទ្វារដោយចិត្តមួយដួង, រមែងវៀរចាកការឈានកន្លងផ្លូវវចីទ្វារដោយចិត្តមួយដួង, ព្រោះហេតុដូច្នោះ ក្នុងចំណែកខាងដើម ទើបកើតឡើងក្នុងខណៈផ្សេងៗ; តែក្នុងខណៈនៃមគ្គរមែងកើតក្នុងកុសលចេតនា ជាគ្រឿងវៀរពោលគឺសម្មាអាជីវៈមួយដួងប៉ុណ្ណោះ ដែលញ៉ាំងអង្គមគ្គឱ្យបរិបូណ៌ ព្រោះកាត់ផ្លូវដើររបស់ចេតនា ជាគ្រឿងទ្រុស្ដសីលក្នុងមិច្ឆាអាជីវៈដែលកើតឡើង ដោយអំណាចនៃកម្មបថ ៧ ក្នុងទ្វារទាំង ២ ដោយអំណាចមិនឱ្យកើតឡើងបានសម្រេច ។ **នេះឈ្មោះថា សម្មាអាជីវៈ** ៕

## សម្ដែងអំពីសម្មាវាយាមនិទ្ទេសជាដើម

និទ្ទេសនៃសម្មាវាយាម នឹងជាក់ច្បាស់ដោយអំណាចនៃការពណ៌នា តាមបទក្នុងសម្មប្បធានវិភង្គ ។ ក៏សម្មាវាយាមៈនេះរមែងបានក្នុងចិត្តផ្សេងៗ ក្នុងកាលខាងដើម; ព្រោះបុគ្គលរមែងធ្វើសេចក្ដីព្យាយាម ដើម្បីការមិនកើតឡើងនៃអកុ-សលធម៌ដ៏លាមកទាំងឡាយ ដែលមិនទាន់កើតឡើងដោយចិត្តមួយដួង, ដើម្បីលះអកុសលធម៌ដ៏លាមកដែលកើតឡើងហើយដោយចិត្តមួយដួង; ក៏ដើម្បីសេចក្ដីកើត

ឡើងនៃកុសលធម៌ ដែលនៅមិនទាន់កើតឡើងដោយចិត្តមួយដួង, ដើម្បីសេចក្តីតាំងនៅនៃកុសលធម៌ ដែលកើតឡើងហើយដោយចិត្តមួយដួង; តែក្នុងខណៈនៃមគ្គរមែងបានក្នុងចិត្តតែមួយដួងប៉ុណ្ណោះ; ព្រោះសេចក្តីព្យាយាមដែលសម្បយុត្តដោយមគ្គតែមួយប៉ុណ្ណោះ រមែងបានឈ្មោះ ៤ យ៉ាង ដោយអត្ថថា ញ៉ាំងកិច្ច ៤ យ៉ាង ឱ្យសម្រេច ។

**សូម្បីក្នុងនិទ្ទេសនៃសម្មាសតិ** ក៏នឹងមានច្បាស់ដោយអំណាចការពណ៌នាតាមបទក្នុងសតិប្បដ្ឋានវិភង្គ;ម្យ៉ាងទៀត សូម្បីសម្មាសតិនេះ ក៏រមែងបានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម; ពិតណាស់ បុគ្គលរមែងកំណត់កាយជាអារម្មណ៍ដោយចិត្តមួយដួង, រមែងកំណត់វេទនាជាដើមដោយចិត្តមួយដួងៗ, តែក្នុងខណៈនៃមគ្គ រមែងបានក្នុងចិត្តតែមួយប៉ុណ្ណោះ; ព្រោះសតិដែលសម្បយុត្តដោយមគ្គតែមួយដួងតែប៉ុណ្ណោះ រមែងបានឈ្មោះ ៤ យ៉ាង ដោយអត្ថថា ឱ្យសម្រេចកិច្ច ៤ យ៉ាង ៕

## សម្តែងអំពីសម្មាសមាធិនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងនិទ្ទេសនៃសម្មាសមាធិ** តទៅ ៖

ឈាន ៤ មានសេចក្តីផ្សេងគ្នាសូម្បីក្នុងចំណែកខាងដើម, សូម្បីក្នុងខណៈនៃមគ្គ; ក្នុងចំណែកខាងដើមផ្សេងគ្នាដោយអំណាចនៃសមាបត្តិ, ក្នុងខណៈនៃមគ្គផ្សេងគ្នាដោយអំណាចនៃមគ្គផ្សេងៗ ។ សេចក្តីពិត បឋមមគ្គរបស់បុគ្គលម្នាក់រមែង ជាធម៌ប្រកបដោយបឋមជ្ឈាន, សូម្បីមគ្គដួងទី ២ ជាដើម ក៏ជាធម៌ប្រកបដោយបឋមជ្ឈាន ឬប្រកបដោយឈានណានីមួយ មានទុតិយជ្ឈានជាដើម; បឋម-

មគ្គរបស់បុគ្គលម្នាក់ ដែលប្រកបដោយឈានណានីមួយ មានទុតិយជ្ឈានជាដើម, សូម្បីទុតិយមគ្គជាដើម ក៏ជាធម៌ប្រកបដោយឈានណានីមួយ មានទុតិយជ្ឈានជាដើម ឬប្រកបដោយបឋមជ្ឈាន ។ ដោយអាការៈយ៉ាងនេះ សូម្បីមគ្គទាំង ៤ រមែងមានបែបដូចគ្នាខ្លះ មិនមានបែបដូចគ្នាខ្លះ ឬមានបែបដូចគ្នាខ្លះ ដោយអំណាចនៃឈាន ។

**ចំណែកសេចក្ដីប្លែកគ្នារបស់មគ្គនោះ** ដោយការកំណត់ឈានជាបាទ មានដូចតទៅនេះ ៖

សម្ដែងអំពីនិយាម (ការកំណត់) មគ្គដែលមានឈានជាបាទ ជាមុនសិន កាលបើបុគ្គលអ្នកបានបឋមជ្ឈាន ចេញពីបឋមជ្ឈានហើយឃើញច្បាស់ មគ្គជាធម៌ប្រកបដោយបឋមជ្ឈាន ក៏កើតឡើង; ក៏ក្នុងមគ្គនេះ អង្គមគ្គ និងពោជ្ឈង្គ រមែងជាធម៌បរិបូណ៌មែនពិត; កាលបុគ្គលបានទុតិយជ្ឈាន ចេញពីទុតិយជ្ឈានពិចារណាឃើញច្បាស់ មគ្គប្រកបដោយទុតិយជ្ឈាន ក៏កើតឡើង,តែក្នុងមគ្គនេះ អង្គមគ្គមាន ៧; កាលបានតតិយជ្ឈាន ចេញពីតតិយជ្ឈានហើយពិចារណាឃើញច្បាស់ មគ្គប្រកបដោយតតិយជ្ឈាន ក៏កើតឡើង, តែក្នុងមគ្គនេះ អង្គមគ្គមាន ៧ ពោជ្ឈង្គមាន ៦ ។ រាប់អំពីចតុត្ថជ្ឈានរហូតដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ក៏ន័យនេះដែរ ។ ឈានដែលជាចតុក្កន័យ និងបញ្ចកន័យ រមែងកើតឡើងក្នុងអរូបភព, ក៏ឈាននោះឯងត្រាស់ហៅថា លោកុត្តរ មិនមែនជាលោកិយទេ, **សួរថា** ក្នុងអធិការនេះ តើយ៉ាងណា ? ឆ្លើយថា ក្នុងអធិការនេះ ព្រះយោគាវចរចេញចាកឈានណាមួយ បណ្ដាឈានទាំងឡាយ មានបឋមជ្ឈានជាដើម បានចំពោះសោតាបត្តិមគ្គហើយ ចម្រើន

អរូបសមាបត្តិកើតឡើងក្នុងអរូបភព, មគ្គ ៣ (ខាងដើម) របស់គេប្រកបដោយឈាននោះឯង រមែងកើតឡើងក្នុងភពនោះ; ដោយអាការយ៉ាងនេះ ឈានដែលជាបាទនោះឯង រមែងកំណត់មគ្គ ។

តែព្រះថេរៈពួកខ្លះ រមែងពោលថា "ខន្ធទាំងឡាយដែលជាអារម្មណ៍របស់វិបស្សនារមែងកំណត់" ដូច្នេះ; ពួកខ្លះពោលថា "អធ្យាស្រ័យរបស់បុគ្គល រមែងកំណត់" ដូច្នេះ, ពួកខ្លះពោលថា "វិបស្សនាដែលជាវុដ្ឋានគាមិនីរមែងកំណត់" ដូច្នេះ; បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងវាទៈរបស់ព្រះថេរៈទាំងនោះ ដោយន័យដែលខ្ញុំពោលទុកក្នុងការពណ៌នាបទភាជនិយ អំពីលោកុត្តរក្នុងចិត្តុប្បាទកណ្ឌក្នុងពេលមុននោះចុះ ។

ពាក្យថា "**អយំ វុច្ចតិ សម្មាសមាធិ** = នេះហៅថា សម្មាសមាធិ" សេចក្តីថា ឯកគ្គតា (សមាធិចិត្ត) ក្នុងឈានទាំង ៤ នេះ តថាគតហៅឈ្មោះថា **សម្មា-សមាធិ** ជាលោកិយក្នុងចំណែកខាងដើម, តែក្នុងកាលខាងក្រោយ ជាលោកុត្តរ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងមគ្គសច្ច ដោយអំណាចជាលោកិយ និងលោកុត្តរដោយប្រការដូច្នេះ ៕

## សម្តែងអំពីមគ្គដែលជាលោកិយ និងលោកុត្តរ

បណ្តាមគ្គដែលជាលោកិយ និងលោកុត្តរទាំងនោះ ក្នុងលោកិយមគ្គ អង្គមគ្គទាំងអស់ រមែងមានអារម្មណ៍យ៉ាងណានីមួយក្នុងអារម្មណ៍ទាំង ៦ តាមសមគួរ; តែក្នុងលោកុត្តរមគ្គ បញ្ញាចក្ខុ (ចក្ខុ គឺបញ្ញា) មានព្រះនិព្វានជាអារម្មណ៍

ដែលដកចេញនូវអវិជ្ជានុស័យរបស់ព្រះអរិយសាវ័ក អ្នកប្រព្រឹត្តដើម្បីចាក់ធ្លុះសច្ចៈ ៤ ជាសម្មាទិដ្ឋិ; ម្យ៉ាងទៀត ការលើកចិត្តឡើងកាន់ប្រទ្បាយ គឺព្រះនិព្វានដែលសម្បយុត្តដោយសម្មាទិដ្ឋិនោះ ហើយដកចេញនូវមិច្ឆាសង្កប្បៈ ៣ យ៉ាង របស់បុគ្គលអ្នកដល់ព្រមដោយទិដ្ឋិ **ជាសម្មាសង្កប្បៈ**, ម្យ៉ាងទៀត ចេតនាជាគ្រឿងវៀរចាកមិច្ឆាវាចា ដែលសម្បយុត្តដោយសម្មាសង្កប្បៈនោះឯង ដកឡើងនូវវចីទុច្ចរិត ៤ យ៉ាង របស់បុគ្គលអ្នកឃើញ និងត្រិះរិះ **ជាសម្មាវាចា** ។ ចេតនាជាគ្រឿងវៀរចាកកាយទុច្ចរិត ៣ យ៉ាង ដែលសម្បយុត្តដោយសម្មាវាចានោះឯង កាត់ផ្តាច់មិច្ឆា-កម្មន្តៈ របស់បុគ្គលអ្នកវៀរហើយ **ជាសម្មាកម្មន្តៈ**, ចេតនាជាគ្រឿងវៀរចាកមិច្ឆាអាជីវៈ ដែលជាធម្មជាតិផូរផង់របស់សម្មាវាចា និងសម្មាកម្មន្តៈទាំងនោះៗ ឯងជាធម៌សម្បយុត្តដោយសម្មាវាចា និងសម្មាកម្មន្តៈនោះៗ ឯង កាត់ផ្តាច់អកុសលមានការបោកបញ្ឆោតជាដើម **ជាសម្មាអាជីវៈ** ។ ម្យ៉ាងវិញទៀត វិរិយារម្ភៈ (ការប្រារព្ធព្យាយាម) របស់បុគ្គលអ្នកតាំងមាំនៅក្នុងភូមិសីល ពោលគឺ**សម្មាវាចា សម្មា-កម្មន្តៈ សម្មាអាជីវៈ**នេះ សមគួរដល់សីលនោះ សម្បយុត្តដោយសីលនោះឯង កាត់ផ្តាច់សេចក្តីខ្ជិលច្រអូស ឱ្យសម្រេចសេចក្តីមិនកើតអកុសលដែលនៅមិនទាន់កើត លះអកុសល ដែលកើតឡើងហើយ ញ៉ាំងកុសលដែលនៅមិនទាន់កើត ឱ្យកើតឡើង ដែលកើតហើយ ឱ្យតាំងនៅ **ជាសម្មាវាយាមៈ**, សេចក្តីដែលចិត្តមិនវង្វេងរបស់អ្នកព្យាយាម យ៉ាងនេះ សម្បយុត្តដោយសម្មាវាយាមៈនោះដកឡើងនូវមិច្ឆាសតិ ឱ្យសម្រេចជាកាយានុបស្សនាជាដើម ក្នុងអារម្មណ៍មានកាយជាដើម **ជាសម្មាសតិ**, សេចក្តីដែលចិត្តមានអារម្មណ៍តែមួយរបស់អ្នករក្សាចិត្ត ដែលអនុត្តរសតិចាត់ចែង

ល្អហើយ សម្បយុត្តដោយសម្មាសតិ និងដកចេញនូវមិច្ឆាសមាធិ **ជាសម្មាសមាធិ** ដោយប្រការដូច្នេះ ។ នេះជាអរិយមគ្គមានអង្គ ៨ ជាលោកុត្តរ ៕

## សម្តែងអំពីមគ្គទាំងវិជ្ជា ទាំងចរណៈជាដើម

ក៏លោកុត្តរមគ្គណា ព្រមទាំងលោកិយមគ្គដែលដល់ការរាប់ថា **ជាទុក្ខ-និរោធគាមិនីបដិបទា** (បដិបទាដែលដល់សេចក្តីរលត់ទុក្ខ) មគ្គនោះឯង **ជាវិជ្ជា និង ចរណៈ** ព្រោះសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ទ្រង់សង្គ្រោះទុកដោយវិជ្ជា, ធម៌ដ៏សេស សង្គ្រោះទុកដោយចរណៈ; ម្យ៉ាងទៀត មគ្គនោះ **ទាំងជាសមថៈ ទាំងជាវិបស្សនា** ព្រោះសេចក្តីដែលសម្មាទិដ្ឋិ និងសម្មាសង្កប្បៈទាំង ២ ពួកនេះ ទ្រង់សង្គ្រោះ ទុកដោយវិបស្សនាញាណ ធម៌ក្រៅពីនេះ សង្គ្រោះទុកដោយសមថញ្ញាណ ។ ម្យ៉ាងវិញទៀត មគ្គនោះទាំងជា **ខន្ធ ៣ និង សិក្ខា ៣** ព្រោះសេចក្តីដែលសម្មាទិដ្ឋិ និងសម្មា-សង្កប្បៈទាំង ២ ពួកនេះ ទ្រង់សង្គ្រោះដោយបញ្ញាខន្ធ; ធម៌ ៣ ក្នុងលំដាប់តពីសម្មាទិដ្ឋិ និងសម្មាសង្កប្បៈនោះ សង្គ្រោះដោយសីលក្ខន្ធ ដ៏សេសសង្គ្រោះដោយសមាធិខន្ធ និងធម៌ទាំងនោះឯង សង្គ្រោះដោយអធិបញ្ញាសិក្ខា អធិសីលសិក្ខា និង អធិចិត្តសិក្ខា ។

ព្រះអរិយសាវ័កប្រកបដោយមគ្គណា ជាអ្នកដល់ព្រមដោយវិជ្ជា និងចរណៈ ដូចបុគ្គលអ្នកដើរផ្លូវឆ្ងាយប្រកបដោយចក្ខុទាំង ២ ដែលអាចក្នុងការមើលឃើញ និង ជើងទាំង ២ ដែលអាចក្នុងការដើរ វៀរទីបំផុត ២ យ៉ាង គឺកាមសុខល្លិកានុយោគ ដោយវិបស្សនាញាណ និងអត្តកិលមថានុយោគ ដោយសមថញ្ញាណ ដើរទៅកាន់

មជ្ឈិមាបដិបទា ទម្លាយនូវកងនៃមោហៈ ដោយបញ្ញាខន្ធ នូវកងនៃទោសៈដោយសីលក្ខន្ធ នូវកងនៃលោភៈដោយសមាធិខន្ធ សម្រេចសមាបត្តិ ៣ គឺនូវបញ្ញាសម្បទាដោយអធិបញ្ញាសិក្ខា, នូវសីលសម្បទាដោយអធិសីលសិក្ខា, នូវសមាធិសម្បទាដោយអធិចិត្តសិក្ខា រមែងធ្វើឱ្យជាក់ច្បាស់នូវអមតៈ គឺព្រះនិព្វាន, ឈ្មោះថា ឈានចុះកាន់អរិយភូមិ ពោលគឺសម្មត្តនិយាម ដែលវិចិត្រដោយរតនៈ ពោលគឺពោធិបក្ខិយធម៌ ៣៧ ប្រការ ដ៏ល្អ ខាងដើម កណ្តាល និងបរិយោសាន ៕

**ពណ៌នាសុត្តន្តភាជនិយចប់**

## ពណ៌នាអំពីអភិធម្មភាជនិយ

ឥឡូវនេះ ជាលំដាប់នៃអភិធម្មភាជនិយ; ក្នុងអភិធម្មភាជនិយនោះ ព្រះមានព្រះភាគ មិនត្រាស់ថា "អរិយសច្ចទាំងឡាយ" ឡើយ ហើយត្រាស់ថា "**ចត្តារិ សច្ចានិ** = សច្ចៈ ៤" ដូច្នេះ ដើម្បីទ្រង់សម្តែងសមុទ័យ ពោលគឺធម៌ជាបច្ច័យ ដោយសព្វគ្រប់ (និប្បទេស) ។

មែនពិត កាលបើព្រះអង្គត្រាស់ថា "អរិយសច្ចៈ" ដូច្នេះ កិលេសដ៏សេស កុសលធម៌ដ៏សេស អកុសលមូល ៣ ដែលមានអាសវៈ កុសលធម៌ដ៏សេស ដែលមានអាសវៈ រមែងសង្គ្រោះមិនបាន ព្រោះថា តណ្ហាតែម្យ៉ាងប៉ុណ្ណោះ រមែងឱ្យទុក្ខតាំងឡើងក៏ទេ, សូម្បីធម៌ដ៏សេសទាំងនេះ មានកិលេសជាដើម ជាបច្ច័យ ក៏ញុំាងទុក្ខឱ្យតាំងឡើងបានដោយពិត; ព្រោះហេតុនោះ ដើម្បីទ្រង់សម្តែងសមុទ័យ ពោលគឺធម៌ជាបច្ច័យ ដោយអស់ជើងថា សូម្បីធម៌ដែលជាបច្ច័យទាំងនេះ រមែងឱ្យទុក្ខ

តាំងឡើងដូចគ្នា ទើបមិនត្រាស់ថា “អរិយសច្ចទាំងឡាយ” ឡើយ ហើយត្រាស់ថា **“ចត្តារិ សច្ចានិ”** ៕

## សម្ដែងអំពីការវិនិច្ឆ័យក្នុងនិទ្ទេសវារៈ

ក៏ក្នុងនិទ្ទេសនៃសច្ចៈទាំង ៤ នោះ ព្រះអង្គមិនបានទ្រង់សម្ដែង**ទុក្ខ**ជាមុនទេ ដើម្បីត្រូវការសម្ដែងទុក្ខនោះៗ ឯង ឱ្យយល់បានដោយងាយ ទើបលើក**ទុក្ខ-សមុទ័យ**ឡើងសម្ដែង; ព្រោះកាលបើព្រះអង្គទ្រង់សម្ដែងទុក្ខសមុទ័យហើយ ទុក្ខសច្ចដោយន័យមានជាអាទិ៍ថា “កិលេសទាំងឡាយដ៏សេស” ដូច្នេះ រមែងជាការសម្ដែងបានងាយ; **និរោធសច្ច** ក្នុងនិទ្ទេសវារៈនេះ ទ្រង់សម្ដែងដោយអាការ ៥ ដោយអំណាចនៃការលះសមុទ័យ តាមដែលត្រាស់ទុកយ៉ាងនេះថា “ការលះតណ្ហា និងការលះ កិលេសដ៏សេសក្រៅពីតណ្ហា” ដូច្នេះជាដើម ។ ចំណែកមគ្គសច្ច ក្នុងនិទ្ទេសវារនេះ ព្រះអង្គកាលបើនឹងទ្រង់សម្ដែង ក៏ទ្រង់សម្ដែងត្រឹមតែជាប្រធានន័យទេសនា ដែលចែកទុកក្នុងធម្មសង្គណី[១១៧] ដោយអំណាចនៃសោតាបត្តិមគ្គ ដែលប្រកបដោយបឋមជ្ឈាន; ក្នុងមគ្គសច្ចនោះ បណ្ឌិតគប្បីជ្រាបសេចក្ដីផ្សេងគ្នារបស់ន័យ ដែលខ្ញុំនឹងប្រកាសទុកខាងមុខ ៕

---

[១១៧] អភិ. ១ ។ [១១៨] ម. ឧ. ។

## សម្តែងអំពីបដិបទាដែលប្រកបដោយអង្គមគ្គ ៥ ជាដើម

ក៏មគ្គប្រកបដោយអង្គ ៨ ជាបដិបទាតែម្យ៉ាងប៉ុណ្ណោះក៏ទេ, តែព្រោះព្រះបាលីថា **“បុព្វេវ ខោ បនស្ស កាយកម្មំ វចីកម្មំ អាជីវោ សុបរិសុទ្ធោ ហោតិ** = ក៏កាយកម្ម វចីកម្ម និងអាជីវៈរបស់បុគ្គលនោះ បរិសុទ្ធល្អហើយ ក្នុងកាលមុនដោយពិត” [១១៨] ដូច្នេះ សូម្បីមគ្គប្រកបដោយអង្គ ៥ រមែងជាការណ៍ដែលទ្រង់សម្តែងថា ជាបដិបទាដូចគ្នា ដោយអំណាចនៃអធ្យាស្រ័យរបស់បុគ្គល, ព្រោះហេតុដូច្នោះ ដើម្បីនឹងទ្រង់សម្តែងន័យនោះ ទើបទ្រង់សម្តែងបញ្ចង្គិកវារៈ (វារៈពោលអង្គ មគ្គ ៥); ម្យ៉ាងទៀត ព្រោះមគ្គប្រកបដោយអង្គ ៨ និងអង្គ ៥ ជាបដិបទាប៉ុណ្ណោះក៏ទេ, តែសូម្បីសម្បយុត្តធម៌ទាំងឡាយលើស ៥០ ក៏ជាបដិបទាដូចគ្នា, ព្រោះហេតុដូច្នោះ ដើម្បីទ្រង់សម្តែងន័យនោះ ទើបទ្រង់សម្តែងសូម្បីសព្វសង្គាហិកវារៈ (វារៈសម្តែងអំពីធម៌ដែលសង្គ្រោះចូលជាមួយគ្នាទាំងអស់) គម្រប់ ៣; ក្នុងសព្វសង្គាហិកវារៈនោះ រមែងបាត់ពាក្យថា “ធម៌ដែលសល់សម្បយុត្ត ដោយទុក្ខនិរោធគាមិនីបដិបទា” នេះអស់ទៅ; ពាក្យដ៏សេស ក្នុងវារៈទាំពួង ដូចគ្នាមែនពិត ៗ

## សម្តែងអំពីបដិបទា ៦០.០០០ ន័យ

ក្នុងវារៈទាំង ៣ (បញ្ចង្គិកវារៈ អដ្ឋង្គិកវារៈ និងសព្វសង្គាហិកវារៈ) នោះគប្បីជ្រាបកោដ្ឋាសៈដំបូងក្នុងកោដ្ឋាសៈ ៥ របស់អដ្ឋង្គិកវារៈ មានពាក្យថា “ការលះតណ្ហា និងការលះកិលេសទាំងឡាយដ៏សេសពីតណ្ហា” ដូច្នេះជាមុន; ការអា-

ស្រ័យឈានក្នុងសោតាបត្តិមគ្គមាន ១០ ន័យ ដោយអំណាចនៃឈានដែលជាចតុក្កន័យ និងបញ្ចកន័យនីមួយៗ ២ ក្នុងឋានៈទាំង ៥ នេះ គឺ សុទ្ធិកបដិបទា សុទ្ធិសុញ្ញតា សុញ្ញតបដិបទា សុទ្ធិកអប្បណិហិតៈ និងអប្បណិហិតបដិបទា; សូម្បីក្នុងការអាស្រ័យឈានដ៏សេស ក៏យ៉ាងនេះដែរ ព្រោះហេតុនោះ ក្នុងការអាស្រ័យឈាន ២០ ន័យ ទើបជា ២០០ ន័យ ។ ២០០ ន័យនោះគុណដោយអធិបតី ៤ ជា ៨០០ ន័យ; រួមន័យសូម្បីទាំងអស់ គឺសុទ្ធិកន័យ ២០០, សាធិបតិន័យ ៨០០ ជា ១.០០០ ន័យ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ក្នុងសោតាបត្តិមគ្គ យ៉ាងណា, សូម្បីក្នុងមគ្គដ៏សេសក៏ដូច្នោះដែរ ព្រោះហេតុដូច្នោះ ទើបរួមជា ៤.០០០ ន័យ; ម្យ៉ាងវិញទៀត ក្នុងកោដ្ឋាសៈដំបូងមាន ៤.០០០ ន័យ យ៉ាងណា, សូម្បីក្នុងកោដ្ឋាសៈដ៏សេស ក៏ដូច្នោះដែរ ព្រោះហេតុនោះ ក្នុងកោដ្ឋាសៈទាំង ៥ ក្នុងអដ្ឋង្គិកវារៈទើបជា ២០. ០០០ ន័យ; ក្នុងបញ្ចង្គិកវារៈ និងក្នុងសព្វសង្គាហិកវារៈក៏ដូចគ្នាដែរ ព្រោះហេតុដូច្នោះ សូម្បីន័យទាំងអស់ ទើបព្រះសាស្ដាទ្រង់ចែកទុក **៦០.០០០ ន័យ**; តែក្នុងព្រះបាលី មានមកហើយដោយសង្ខេប; បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា **អភិធម្មភាជនិយ** នេះ មានមហាវារៈ ៣ មានកោដ្ឋាសៈ ១៥ ប្រដាប់ដោយន័យ ៦០. ០០០ ន័យ ជាធម៌ ដែលព្រះមានព្រះភាគ នាំចេញមកសម្ដែងហើយ ដោយប្រការដូច្នេះ ៕

**ពណ៌នាអំពីអភិធម្មភាជនិយចប់**

# ពណ៌នាអំពីបញ្ហាបុច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបញ្ហាបុច្ឆកៈ តទៅ ៖

បណ្ឌិតគប្បីជ្រាបសេចក្ដីដែលសច្ចៈសូម្បីទាំង ៤ ជាកុសលជាដើម ដោយទំនងនៃន័យដែលខ្ញុំពោលទុកក្នុងខន្ធវិភង្គនោះឯង; តែក្នុងអារម្មណត្តិកៈទាំងឡាយ **សមុទយសច្ច** ជាបរិត្តារម្មណ៍ដល់អ្នកត្រេកអរក្នុងកាមាវចរធម៌, ជាមហគ្គតារម្មណ៍ដល់អ្នកត្រេកអរក្នុងមហគ្គតធម៌, ជានវត្តព្វារម្មណ៍ដល់អ្នកត្រេកអរនៅក្នុងបញ្ញត្តិ **ទុក្ខសច្ច** ជាបរិត្តារម្មណ៍ដែលប្រារព្ធកាមាវចរធម៌ហើយកើតឡើង, ជាមហគ្គតា-រម្មណ៍ក្នុងកាលប្រារព្ធរូបាវចរធម៌ និងអរូបាវចរធមិហើយកើតឡើង, ជាអប្ប-មាណារម្មណ៍កើតក្នុងវេលាពិចារណាលោកុត្តរ ៩, ជានវត្តព្វារម្មណ៍ ក្នុងវេលាពិចារណាបញ្ញត្តិ ។ **មគ្គសច្ច** ជាមគ្គហេតុកៈ (មានមគ្គជាហេតុ) សូម្បីក្នុងកាលទាំងពួង ដោយអំណាចជាសហជាតហេតុ, ជាមគ្គាធិបតិក្នុងវេលាចម្រើនមគ្គធ្វើវីរិយៈ ឬវិមង្សាឱ្យជាធំ, ឈ្មោះថា នវត្តព្វធម៌ក្នុងវេលាដែលឆន្ទៈនិងចិត្តយ៉ាងណា-នីមួយជាអធិបតី ។ **ទុក្ខសច្ច** ជាមគ្គារម្មណ៍ក្នុងវេលាពិចារណាមគ្គរបស់ព្រះអរិយៈ, ជាមគ្គាធិបតី ក្នុងវេលាពិចារណាមគ្គរបស់ព្រះអរិយៈទាំងនោះដោយពិត ហើយធ្វើឱ្យធ្ងន់, ជានវត្តព្វធមិក្នុងវេលាពិចារណាធមិដ៏សេស ។

បទថា **"ទ្វេ សច្ចានិ** = សច្ចៈ ២" បានដល់ ទុក្ខសច្ច និងសមុទយសច្ច; ព្រោះសច្ចៈទាំងពីរពួកនេះ ជាអារម្មណ៍មានអតីតៈជាដើមក្នុងវេលាប្រារព្ធធមិ ដែលផ្សេងដោយអតីតៈជាដើម ហើយកើតឡើង **សមុទយសច្ចៈ** រមែងជាអារម្មណ៍ មានអារម្មណ៍ខាងក្នុងជាដើម ដល់បុគ្គលអ្នករីករាយនៅក្នុងធម៌ដែលផ្សេងដោយធម៌មាន

អជ្ឈត្តៈជាដើម, **ទុក្ខសច្ចៈ** ក្នុងវេលាជាអាកិញ្ចញ្ញាយតនៈ គប្បីជ្រាបថា ជានវត្តព្វារម្មណ៍ក៏មាន ។ ព្រោះហេតុដូច្នោះ ក្នុងបញ្ហាបុច្ឆកៈនេះ សច្ចៈពីរ (ខាងដើម) ជាលោកិយ, សច្ចៈពីរ (ខាងចុង) ជាលោកុត្តរ; ក្នុងបញ្ហាបុច្ឆកៈនេះ យ៉ាងណា, ក្នុងសុត្តន្តភាជនិយ និងអភិធម្មភាជនិយទាំង ២ សូម្បីមុនក៏យ៉ាងនោះ; ព្រោះសច្ចៈដែលជាលោកិយ និងលោកុត្តរ ព្រះសម្មាសម្ពុទ្ធត្រាស់ហើយ សូម្បីក្នុងការវណ្ណនាទាំង ៣ មានសុត្តន្តភាជនិយជាដើម; សូម្បីសច្ចវិភង្គនេះ ព្រះអង្គក៏ទ្រង់នាំចេញចែកសម្ដែងទុក ៣ បរិវដ្ដៈ ដោយប្រការដូច្នេះឯង ៕

**ចប់សច្ចវិភង្គនិទ្ទេស**

# ឥន្ទ្រិយវិភង្គនិទ្ទេស

## ពណ៌នាអំពីអភិធម្មភាជនិយ

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យ **ក្នុងឥន្ទ្រិយវិភង្គ** តពីសច្ចវិភង្គនោះតទៅ ៖

បទថា **"ពាវីសតិ = ២២"** ជាបទកំណត់ចំនួន ។ បទថា **"ឥន្ទ្រិយានិ =** ឥន្ទ្រិយទាំងឡាយ" ជាបទអធិប្បាយធម៌ដែលទ្រង់កំណត់ទុក ។ ឥឡូវនេះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្ដែងឥន្ទ្រិយទាំងនោះដោយបំប្រួញ ទើបត្រាស់ពាក្យថា **ចក្ខុន្ទ្រិយំ** = ចក្ខុន្ទ្រិយជាដើម ៕

## សម្ដែងអំពីសេចក្ដីសម្គាល់របស់ឥន្ទ្រិយ ២២

ក្នុងឥន្ទ្រិយទាំងនោះ ក៏ឈ្មោះថា **ចក្ខុន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុង

ចក្ខុទ្វារ ។ ក៏ឈ្មោះថា **សោតិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងសោតទ្វារ ។ ក៏ឈ្មោះថា **ឃានិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងឃានទ្វារ ។ ក៏ឈ្មោះថា **ជិវ្ហិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងជិវ្ហាទ្វារ ។ ក៏ឈ្មោះថា **កាយិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងកាយទ្វារ ។ ក៏ឈ្មោះថា **មនិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈដឹងអារម្មណ៍ ។ ក៏ឈ្មោះថា **ឥត្ថិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងភាពជាស្ត្រី ។ ក៏ឈ្មោះថា **បុរិសិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងភាពជាបុរស ។ ក៏ឈ្មោះថា **ជីវិតិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃការតាមថែរក្សា (អនុបាល) ។ ក៏ឈ្មោះថា **សុខិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃសេចក្តីសុខ ។ ក៏ឈ្មោះថា **ទុក្ខិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងទុក្ខលក្ខណៈ ។ ក៏ឈ្មោះថា **សោមនស្សិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃសោមនស្ស ។ ក៏ឈ្មោះថា **ទោមនស្សិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃទោមនស្ស ។ ក៏ឈ្មោះថា **ឧបេក្ខិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃឧបេក្ខា ។ ក៏ឈ្មោះថា **សទ្ធិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃការបង្អោនចិត្តជឿ ។ ក៏ឈ្មោះថា **វីរិយិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃសេចក្តីព្យាយាម ។ ក៏ឈ្មោះថា **សតិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃការប្រាកដ (របស់អារម្មណ៍) ។ ក៏ឈ្មោះថា **សមាធិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃការមិនរវើរវាយ ។ ក៏ឈ្មោះថា **បញ្ញិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃការឃើញ ។ ក៏ឈ្មោះថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងលក្ខណៈនៃការដឹងនូវការដើរទៅថា យើងនឹងដឹងទូទៅ

ដល់វត្ថុដែលមិនទាន់ដឹង (នេះជាសោតាបត្តិមគ្គ) ។ ក៏ឈ្មោះថា **អញ្ញិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាព ជាធំក្នុងការដឹងទូទៅ (នូវ) ធម៌ដែលដឹងហើយនោះឯង (ពីសោតាបត្តិផលដល់អរហត្តមគ្គ) ។ ក៏ឈ្មោះថា **អញ្ញាតាវិន្ទ្រិយ** ព្រោះអត្ថថា គ្រងភាពជាធំក្នុងភារៈជា អ្នកដឹងច្បាស់ (ក្នុងអរហត្តផល) ។

ក្នុងឥន្ទ្រិយវិភង្គនេះ វណ្ណនាឈ្មោះថា សុត្តន្តភាជនិយ ព្រះអង្គមិនបានទ្រង់កាន់យក; ព្រោះហេតុអ្វី ? ព្រោះឥន្ទ្រិយ ២២ ដោយលំដាប់នេះ មិនបានមកក្នុងព្រះសូត្រ; ព្រោះក្នុងព្រះសូត្រកន្លែងខ្លះ ទ្រង់ត្រាស់ឥន្ទ្រិយទុក ២, កន្លែងខ្លះត្រាស់ទុក ៣, កន្លែងខ្លះត្រាស់ទុក ៥; ក៏ដោយហេតុនេះ ឥន្ទ្រិយ ២២ តជាប់គ្នាដូច្នេះមិនបានមានទេ នេះជាន័យនៃអដ្ឋកថាក្នុងឥន្ទ្រិយវិភង្គជាមុនសិន ។ **ក៏ន័យម្យ៉ាងទៀត** គប្បីជ្រាបដូចតទៅនេះ ៖

ពិតណាស់ ក្នុងឥន្ទ្រិយទាំងនេះ

**អត្ថតោ លក្ខណាទីហិ កមតោ ច វិជានិយា**
**ភេទាភេទា តថា កិច្ចា ភូមិតោ ច វិនិច្ឆយំ**

គប្បីជ្រាបការវិនិច្ឆ័យដោយអត្ថ ដោយលក្ខណៈ
ជាដើម ដោយលំដាប់ ដោយសេចក្តីផ្សេងគ្នា និង
មិនផ្សេងគ្នា ដោយកិច្ច និងដោយភូមិ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយអត្ថ

បណ្តាពាក្យវិនិច្ឆ័យទាំងនោះ អត្ថនៃឥន្ទ្រិយមានចក្ខុន្ទ្រិយជាដើម ខ្ញុំប្រកាសទុកមុនហើយដោយន័យមានជាអាទិ៍ថា ក៏ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា **រមែងឃើញ** ។

តែក្នុងឥន្ទ្រិយដែលជាលោកុត្តរ ៣ ខាងក្រោយ លោកុត្តរិន្ទ្រិយ ខងំបូងព្រះមានព្រះភាគត្រាស់ថា **“អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ”** ដូច្នេះ ព្រោះសេចក្តីកើតឡើង និងព្រោះ ការព្រមព្រៀងនៃអត្ថរបស់ឥន្ទ្រិយ ដល់ព្រះអរិយៈអ្នកសម្រេចហើយក្នុងចំណែកខាងដើម យ៉ាងនេះថា **“យើងនឹងដឹងអមតបទ ឬសច្ចធម៌ ៤ ដែលនៅមិនទាន់ដឹង”** ដូច្នេះ, លោកុត្តរិន្ទ្រិយទី ២ ត្រាស់ហៅថា **អញ្ញិន្ទ្រិយ** ព្រោះសេចក្តីដឹងទូទៅ និងព្រោះការកើតព្រមនៃអត្ថរបស់ឥន្ទ្រិយ, លោកុត្តរិន្ទ្រិយទី ៣ ត្រាស់ហៅថា **អញ្ញាតាវិន្ទ្រិយ** ព្រោះសេចក្តីកើតឡើង និងព្រោះការកើតឡើងព្រមនៃអត្ថរបស់ឥន្ទ្រិយ ដល់ព្រះខីណាស្រព អ្នកដឹងច្បាស់ អ្នកមានកិច្ចនៃញាណ ក្នុងសច្ចៈ ៤ សម្រេចហើយ ។

ក៏ឈ្មោះថា **អត្ថនៃឥន្ទ្រិយនោះ តើយ៉ាងណា** ? អត្ថនៃឥន្ទ្រិយ មានសេចក្តីថាជាគ្រឿងសម្គាល់ នៃភាពជាធំ (កំពូល), អត្ថនៃឥន្ទ្រិយ មានសេចក្តីថា ដែលអ្នកជាធំសម្តែងហើយ, អត្ថនៃឥន្ទ្រិយ មានសេចក្តីថា ដែលអ្នកជាធំឃើញហើយ, អត្ថនៃឥន្ទ្រិយ មានសេចក្តីថា ដែលអ្នកជាធំប្រកាសហើយ, អត្ថនៃឥន្ទ្រិយ មានសេចក្តីថា ដែលបុគ្គលជាធំសេពហើយ សូម្បីអត្ថនៃឥន្ទ្រិយទាំងនោះ រមែងគួរតាមការសមគួរក្នុងទីនេះ ។

ពិតណាស់ ព្រះមានព្រះភាគ អ្នកជាព្រះសម្មាសម្ពុទ្ធ ឈ្មោះថា **ជាកំពូល** (ជាធំ) ព្រោះភាពជាអ្នកធំក្រៃលែងជាទីបំផុត, កម្មជាកុសល និងអកុសលឈ្មោះថា **ជាធំ** ព្រោះក្នុងកម្មទាំងឡាយ មិនមានកម្មអ្វីដែលមានភាពធំជាង; ដោយហេតុនោះឯង ក្នុងអធិការនេះ ឥន្ទ្រិយទាំងឡាយដែលកើតព្រមដោយកម្ម

រមែងសម្ដែងនូវកម្មដែលជាកុសល និងអកុសលមែនពិត, ឯឥន្ទ្រិយទាំងនោះ ដែលព្រះសម្មាសម្ពុទ្ធ អ្នកជាកំពូលទ្រង់ទូន្មានហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **ឥន្ទ្រិយ** ដោយអត្ថថា ជាគ្រឿងសម្គាល់ភាពជាធំ និងដោយអត្ថថា ជាវត្ថុដែលព្រះមានព្រះភាគជាម្ចាស់អ្នកជាធំសម្ដែងហើយ ។

ម្យ៉ាងទៀត ឥន្ទ្រិយទាំងអស់នោះឯង ដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកាសទុក និងត្រាស់ដឹងក្រៃលែងតាមសេចក្ដីពិត ព្រោះហេតុនោះ ទើបឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថថា ដែលអ្នកជាធំសម្ដែងហើយ និងព្រោះអត្ថថា ដែលអ្នកជាធំទ្រង់ឃើញហើយ; ឥន្ទ្រិយខ្លះ ព្រះមានព្រះភាគ អ្នកជាកំពូលនៃមុនីអង្គ នោះឯងសេពហើយ ដោយការសេពនូវអារម្មណ៍ និងខ្លះទៀត ក៏ទ្រង់សេពហើយដោយការសេពនូវការចម្រើន ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **ឥន្ទ្រិយ** ដោយអត្ថថា ដែលបុគ្គលអ្នកជាកំពូលសេពហើយខ្លះ; ម្យ៉ាងវិញទៀត ឥន្ទ្រិយទាំងនេះ ឈ្មោះថា **ឥន្ទ្រិយ** ដោយអត្ថថា ជាឥស្សរៈ ពោលគឺភាពជាអធិបតីខ្លះ; ដោយភាពជាអធិបតីនៃចក្ខុជាដើម សម្រេចហើយក្នុងសេចក្ដីប្រព្រឹត្តទៅនៃចក្ខុវិញ្ញាណជាដើម, ព្រោះកាលឥន្ទ្រិយទាំងនោះចាស់ក្លា ចក្ខុវិញ្ញាណជាដើមនោះក៏ចាស់ក្លា ឯកាលឥន្ទ្រិយនោះ អន់ថយ ចក្ខុវិញ្ញាណជាដើមនោះឯង ក៏អន់ថយដែរ ។

នេះជាសេចក្ដីវិនិច្ឆ័យ**ដោយអត្ថ** ក្នុងឥន្ទ្រិយនេះជាមុនសិន ៕

## សម្ដែងអំពីការវិនិច្ឆ័យដោយលក្ខណៈជាដើម

ខថា **ដោយលក្ខណៈជាដើម** មានអធិប្បាយថា បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យឥន្ទ្រិយ

មានចក្ខុន្ទ្រិយជាដើម សូម្បីដោយលក្ខណៈ (សភាវៈ) ដោយរស (កិច្ច) ដោយបច្ចុប្បដ្ឋាន (ផលដែលប្រាកដ) និងដោយបទដ្ឋាន (ហេតុជិតឱ្យកើតឡើង) ។ ក៏លក្ខណៈជាដើមនោះនៃធម៌ មានចក្ខុជាដើមនោះ ខ្ញុំពោលទុកក្នុងកាលមុន (អដ្ឋកថា អដ្ឋសាលិនី) ទាំងអស់ហើយ; ក៏ឥន្ទ្រិយ ៤ [១១៩] មានបញ្ញិន្ទ្រិយជាដើម ដោយអត្ថ បានដល់ **អមោហៈ**នោះឯង; ឥន្ទ្រិយដ៏សេសក្នុងព្រះបាលីនោះមកហើយ ដោយបំប្រួញដែរ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយលំដាប់

សូម្បីខថា **ដោយលំដាប់** នេះ ជាលំដាប់របស់ទេសនានោះឯង ។ ក្នុងលំដាប់នោះ ការបានចំពោះនូវអរិយភូមិ រមែងមានដោយការកំណត់ដឹងធម៌ដែលជាខាងក្នុង ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់សម្តែងនូវ**ចក្ខុន្ទ្រិយ**ជាដើម ដែលរាប់បញ្ចូលដោយអត្តភាពមុន ។ ក៏អត្តភាពនោះអាស្រ័យធម៌ណា, រមែងដល់ការរាប់ថា **ជាស្រី ឬជាប្រុស**, ដើម្បីទ្រង់បង្ហាញសម្តែងថា ធម៌នោះ គឺអត្តភាពនេះ បន្ទាប់ពីនោះ ទើបទ្រង់សម្តែងថា **ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ** ។ ដើម្បីឱ្យជ្រាបថា សូម្បីអត្តភាពទាំង ២ នោះ មានសេចក្តីប្រព្រឹត្តទៅជាប់ដោយជីវិតិន្ទ្រិយ បន្ទាប់ពីនោះ ទើបទ្រង់សម្តែង **ជីវិតិន្ទ្រិយ** ។ ដរាបណា ជីវិតិន្ទ្រិយនោះរស់នៅឡើយ ដរាបនោះ ការមិនចុះកាន់

---

[១១៩] ឥន្ទ្រិយ៍ ៤ គឺតាំងអំពីលេខ ១៩-២២ ។

នៃអារម្មណ៍ដែលសោយហើយ (វេទនា) ទាំងនោះក៏នៅមាន; ដើម្បីឱ្យជ្រាបថា សុខ និងទុក្ខទាំងអស់នោះយ៉ាងណាមួយដែលសោយហើយ, បន្ទាប់ពីនោះមក ទើបទ្រង់សម្ដែង**សុខិន្ទ្រិយ**ជាដើម ។

ម្យ៉ាងទៀត ដើម្បីទ្រង់សម្ដែងខបដិបត្តិថា "ធម៌ទាំងនេះ បុគ្គលគប្បីចម្រើន ដើម្បីការរលត់សុខិន្ទ្រិយ" ជាដើមនោះ បន្ទាប់មក ទើបទ្រង់សម្ដែងពាក្យថា **សទ្ធា**ជាដើម ។ ដើម្បីទ្រង់សម្ដែងសេចក្ដីមិនជាមោឃៈ នៃខបដិបត្តិថា "ដោយខបដិបត្តិនេះ ឯកធម៌រមែងប្រាកដក្នុងខ្លួនមុន" , បន្ទាប់មកទៀត ទើបទ្រង់សម្ដែង**អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ**, ព្រះអង្គទ្រង់សម្ដែង**អញ្ញិន្ទ្រិយ** ទុកតពីអនញ្ញតញ្ញស្សាមីតិន្ទ្រិយនោះ ព្រោះសេចក្ដីដែលអញ្ញិន្ទ្រិយនោះ ជាផលរបស់អនញ្ញតញ្ញស្សាមីតិន្ទ្រិយនោះៗ ឯង នឹងជាឥន្ទ្រិយដែលគប្បីចម្រើនក្នុងលំដាប់ តពីអនញ្ញតញ្ញស្សាមីតិន្ទ្រិយនោះ ។ ខាងមុខពីនេះដើម្បីឱ្យដឹងថា "ការពន្លុះឥន្ទ្រិយនេះ បានដោយភាវនា (ការចម្រើន), ក៏ឯការពន្លុះឥន្ទ្រិយនេះហើយ ឥន្ទ្រិយអ្វីៗ ដែលគប្បីធ្វើឱ្យក្រៃលែងឡើងទៅទៀត រមែងមិនមាន" ដូច្នេះ ទើបត្រាស់**អញ្ញាតាវិន្ទ្រិយ** ជាការប្រឡោមចិត្តយ៉ាងក្រៃលែងទុកចុងក្រោយមែនពិត ។ នេះជាលំដាប់ក្នុងឥន្ទ្រិយទាំងនេះ ៕

## សម្ដែងអំពីការវិនិច្ឆ័យ
## ដោយសេចក្ដីផ្សេងគ្នា និង មិនផ្សេងគ្នា

ក៏ខថា **ដោយសេចក្ដីផ្សេងគ្នា និងមិនផ្សេងគ្នា** នោះ បានដល់ ក្នុងឥន្ទ្រិយ ២២

នេះ សេចក្តីផ្សេងគ្នារមែងមានដល់ជីវិតិន្ទ្រិយតែម្យ៉ាង; ព្រោះជីវិតិន្ទ្រិយនោះ មាន ២ យ៉ាង គឺ រូបជីវិតិន្ទ្រិយ និងអរូបជីវិតិន្ទ្រិយ ។ ឥន្ទ្រិយដ៏សេសមិនផ្សេងគ្នាទេ ។

គប្បីជ្រាបវិនិច្ឆ័យដោយសេចក្តីផ្សេងគ្នា និងមិនផ្សេងគ្នា ក្នុងឥន្ទ្រិយទាំងនេះ យ៉ាងនេះ ៗ

## សំម្តែងអំពីការវិនិច្ឆ័យដោយកិច្ច

ខថា **ដោយកិច្ច** នោះ ប្រសិនបើមានអ្នកសួរថា “ កិច្ចរបស់ឥន្ទ្រិយទាំងឡាយ តើយ៉ាងណា ?” ដូច្នេះ ឆ្លើយថា គប្បីជ្រាបកិច្ចរបស់ចក្ខុន្ទ្រិយជាមុន សិន ព្រោះព្រះបាលីថា “**ចក្ខាយតនំ**[១២០] **ចក្ខុវិញ្ញាណធាតុយា តំ សម្បយុត្ត-កានញ្ច ធម្មានំ ឥន្ទ្រិយបច្ចយេន បច្ចយោ** = ចក្ខាយតនៈជាបច្ច័យដល់ចក្ខុ-វិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ ដោយអំណាចនៃឥន្ទ្រិយជាបច្ច័យ” ដូច្នេះ ចក្ខុន្ទ្រិយនោះឯង គប្បីឱ្យសម្រេច ដោយសេចក្តីជាឥន្ទ្រិយប្បច្ច័យដល់ធម៌ មានចក្ខុវិញ្ញាណជាដើម ដោយសេចក្តីជាឥន្ទ្រិយក្លា និងខ្សោយជាដើមរបស់ខ្លួន ជាការស្របតាមអាការៈរបស់ខ្លួន ពោលគឺជាសភាវៈចាស់ក្លា និងទន់ខ្សោយជាដើម នេះ **ជាកិច្ច** (របស់ចក្ខុន្ទ្រិយនោះ) ។ កិច្ចរបស់សោតៈ ឃានៈ ជិវ្ហា និងកាយិន្ទ្រិយ ក៏យ៉ាងនោះដែរ ។ តែការឱ្យសហជាតធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ជាកិច្ចរបស់មនិន្ទ្រិយ, ការតាមរក្សាសហជាតធមិ

---

[១២០] ក្នុងអភិធម្មបដ្ឋាន ប្រើពាក្យថា **ចក្ខុន្ទ្រិយំ** មិនមែនប្រើពាក្យថា **ចក្ខាយតនំ** ក្រៅពីនោះដូចគ្នា ។

ជាកិច្ចរបស់ជីវិតិន្ទ្រិយ, ការទ្រទ្រង់ទុកនូវអាការៈនៃនិមិត្ត (គ្រឿងសម្គាល់) កិរិយា អាការៈ និងឫក្សពាររបស់ស្ត្រី និងបុរស ជាកិច្ចរបស់**ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ**, ការរក្សាសហជាតធម៌ ហើយឱ្យដល់លំដាប់តាមអាការដែលគ្រោតគ្រាត (ឱឡារ) តាមភាវៈរបស់ខ្លួន ជាកិច្ចរបស់**សុខ ទុក្ខ សោមនស្ស** និង**ទោមនស្សិន្ទ្រិយ**, ការឱ្យដល់អាការមជ្ឈត្តា (ឧបេក្ខា) ដែលស្ងប់ និងប្រណីត ជាកិច្ចរបស់ឧបេក្ខិន្ទ្រិយ, ការរម្ងាប់ធម៌ដែលជាបដិបក្សចំពោះសទ្ធាជាដើម និងការឱ្យសម្បយុត្តធម៌ដល់សេចក្តីជាភាវៈមានអាការផូរផង់ជាដើម ជាកិច្ចរបស់សទ្ធិន្ទ្រិយជាដើម, ការលះសំយោជនៈ ៣ (មានទិដ្ឋិសំយោជនៈជាដើម) និងការធ្វើឱ្យសម្បយុត្តធម៌បែរមុខឆ្ពោះទៅដល់ការលះសំយោជនៈ ៣ នោះ ជាកិច្ចរបស់**អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ**, ការធ្វើឱ្យស្រាលខ្លះ (តនុករប្បហាន) នូវកាមរាគៈ ព្យាបាទៈជាដើម និងការញ៉ាំងសម្បយុត្តធម៌ឱ្យប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួន ជាកិច្ចរបស់**អញ្ញិន្ទ្រិយ**, ការលះសេចក្តីខ្វល់ខ្វាយក្នុងកិច្ចទាំងអស់ និងសេចក្តីជាបច្ច័យឱ្យសម្បយុត្តធម៌ឆ្ពោះទៅកាន់អមតៈ ជាកិច្ចរបស់**អញ្ញាតាវិន្ទ្រិយ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឥន្ទ្រិយទាំងនេះ **ដោយកិច្ច** មានប្រការដូច្នេះ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយភូមិ

ខថា **ដោយភូមិ** សេចក្តីថា បណ្តាឥន្ទ្រិយទាំងនោះ ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ និងទោមនស្សិន្ទ្រិយ **ជាកាមាវចរ**តែម្យ៉ាង, មនិន្ទ្រិយ ជីវិតិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ

វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ ជាឥន្ទ្រិយរាប់បញ្ចូលក្នុងភូមិ ៤, សោមនស្សិន្ទ្រិយ រាប់បញ្ចូលក្នុងភូមិ ៣ ដោយអំណាចនៃកាមាវចរ រូបាវចរ និងលោកុត្តរ, ឥន្ទ្រិយ ៣ ក្នុងទីបំផុត ជាលោកុត្តរតែម្យ៉ាង ។

គប្បីជ្រាបវិនិច្ឆ័យ **ដោយភូមិ** មានប្រការដូច្នេះ ។

ពិតមែន កាលបុគ្គលដឹងយ៉ាងនេះថា ៖

**“សំវេគពហុលោ ភិក្ខុ ឋិតោ ឥន្ទ្រិយសំវរេ**

**ឥន្ទ្រិយានិ បរិញ្ញាយ ទុក្ខស្សន្តំ និគច្ឆតិ ខ**

ភិក្ខុអ្នកច្រើនដោយសេចក្ដីស្លុតចិត្តតាំងនៅក្នុងឥន្ទ្រិយ-

សំវរៈ កំណត់ដឹងនូវឥន្ទ្រិយទាំងឡាយបានហើយ រមែងចូល

ដល់នូវសេចក្ដីស្ងប់នៃទុក្ខបាន” ដូច្នេះ ។

ក្នុងនិទ្ទេសវារៈគប្បីជ្រាបពាក្យទាំងពួងមានជាអាទិ៍ថា **“យំ ចក្ខុ ចតុន្នំ មហាភូតានំ** = ចក្ខុណាជាបសាទរូប អាស្រ័យមហាភូតរូប ៤” ដូច្នេះ ដោយន័យដែលពោលទុកត្រង់បទភាជនៈក្នុងធម្មសង្គណីនោះចុះ ។

ម្យ៉ាងទៀត ក្នុងនិទ្ទេសនៃឥន្ទ្រិយទាំងឡាយ មានវីរិយិន្ទ្រិយ និងសមាធិន្ទ្រិយជាដើម ព្រះអង្គមិនបានត្រាស់ពាក្យថា សម្មាវាយាមៈ មិច្ឆាវាយាមៈ សម្មាសមាធិ និងមិច្ឆាសមាធិ ជាដើមទុក; ព្រោះហេតុអ្វី ? ព្រោះជាសព្វសង្គាហិកវារៈ (វារៈសម្ដែងអំពីធម៌ដែលសង្គ្រោះចូលជាមួយគ្នាទាំងអស់); មែនពិត ឥន្ទ្រិយទាំងឡាយដែលសង្គ្រោះចូល ជាមួយគ្នាបានទាំងអស់ ព្រះមានព្រះភាគត្រាស់ទុកក្នុងឥន្ទ្រិយវិភង្គនេះ ។ ម្យ៉ាងវិញ ទៀត កាលបើយ៉ាងនេះ បណ្ដាឥន្ទ្រិយទាំង ២២ នេះ

ឥន្ទ្រិយ ១០ យ៉ាង ដែលជាលោកិយ ជាកាមាវចរតែម្យ៉ាង,ឥន្ទ្រិយ ៣ ជាលោកុត្តរ, ឥន្ទ្រិយ ៩ ជាលោកិយ និងលោកុត្តរលាយគ្នាដូច្នេះឯង ៕

**ពណ៌នាអំពីអភិធម្មភាជនិយ ចប់**

## ពណ៌នាអំពីបញ្ហាបុច្ឆកៈ

គប្បីជ្រាបការចែកសូម្បីឥន្ទ្រិយទាំងអស់ ក្នុងបញ្ហាបុច្ឆកៈថាជាកុសលជាដើម ដោយទំនងនៃន័យរបស់ព្រះបាលីនោះឯង; ម្យ៉ាងទៀត ក្នុងអារម្មណត្តិកៈទាំងឡាយ ពាក្យថា **ឥន្ទ្រិយ ៧** ជាអនារម្មណ៍នោះ ត្រាស់សំដៅយកចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ; តែជីវិតិន្ទ្រិយមិនបានមកក្នុងឋានៈនេះទេ ព្រោះលាយដោយអរូប ។

បទថា **"ទ្វិន្ទ្រិយា"** បានដល់ ឥន្ទ្រិយ ២; ពាក្យនេះត្រាស់សំដៅយកឥន្ទ្រិយ ២ គឺ សុខិន្ទ្រិយ និងទុក្ខិន្ទ្រិយ; ព្រោះឥន្ទ្រិយ ២ នោះ ជាបរិត្តារម្មណ៍ដោយចំណែកមួយ ។ ពាក្យថា **"ទោមនស្សិន្ទ្រិយំ សិយា បរិត្តារម្មណំ សិយា មហគ្គតារម្មណំ** = ទោមនស្សិន្ទ្រិយជាបរិត្តារម្មណ៍ក៏មាន, ជាមហគ្គតារម្មណ៍ក៏មាន" សេចក្ដីថា ក្នុងវេលាប្រារព្ធកាមាវចរធម៌ហើយប្រព្រឹត្តទៅ ក៏ជាបរិត្តារម្មណ៍, តែក្នុងវេលាប្រារព្ធរូបាវចរ និងអរូបាវចរ ហើយប្រព្រឹត្តទៅ ក៏ជាមហគ្គតារម្មណ៍, ឯក្នុងវេលាដែលប្រារព្ធបញ្ញត្តិហើយប្រព្រឹត្តទៅ ក៏ជានវត្តព្វារម្មណ៍ ។

ពាក្យថា **"នវិន្ទ្រិយា សិយា បរិត្តារម្មណា** = សូម្បីឥន្ទ្រិយ ៩ ជាបរិត្តារម្មណ៍ក៏មាន" នេះ ព្រះមានព្រះភាគត្រាស់សំដៅយកជីវិតិន្ទ្រិយ សោមនស្សិន្ទ្រិយ

ឧបេក្ខិន្ទ្រិយ និងឥន្ទ្រិយពួក ៥ មានសទ្ធិន្ទ្រិយជាដើម; ពិតណាស់ ជីវិតិន្ទ្រិយ សូម្បីសង្គ្រោះក្នុងរូបធម៌ ដែលមិនមានអារម្មណ៍ព្រោះលាយដោយរូប និងសង្គ្រោះដោយចំណែកដែលជាធម្មជាតិ មានអារម្មណ៍បានដោយចំណែកនៃអរូប ។

ពាក្យថា **"ចត្តារិ ឥន្ទ្រិយានិ** = ឥន្ទ្រិយ ៤" បានដល់ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ ទោមនស្សិន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយ; ព្រោះឥន្ទ្រិយទាំង ៤ នេះ មិនរួមនៅក្នុងមគ្គារម្មណត្តិកៈទេ ។

បទថា **"មគ្គហេតុកំ** = ជាមគ្គហេតុកៈ" នេះ ត្រាស់ទុកសំដៅយកហេតុដែលជាសហជាត; ក្នុងវេលាដែលវីរិយៈ ឬវិមង្សា ជាធំជាមគ្គាធិបតី, តែក្នុងវេលាដែលឆន្ទៈ ឬចិត្តជាធំ ក៏ជានវត្តព្វធម៌ ។

ពាក្យថា **"ទសិន្ទ្រិយា សិយា ឧប្បន្នា សិយា ឧប្បាទិនោ** = ឥន្ទ្រិយ ១០ ជាឧប្បន្នៈក៏មាន ជាឧប្បាទិក៏មាន" នេះ ព្រះភគវន្តត្រាស់សំដៅយករូប ឥន្ទ្រិយ ៧ និងវិបាកឥន្ទ្រិយ ៣; ឥន្ទ្រិយ ១០ ព្រមទាំងទោមនស្សិន្ទ្រិយត្រាស់ទុកខាងក្រោយ; ក្នុងឥន្ទ្រិយទាំង ១០ ពួកនោះ ទោមនស្សិន្ទ្រិយ ក្នុងវេលាដែលប្រារព្ធបញ្ញត្តិហើយប្រព្រឹត្តទៅ ក៏ជានវត្តព្វារម្មណ៍ ។ ឥន្ទ្រិយដ៏សេស សូម្បីក្នុងវេលាដែលពិចារណានិព្វាន ក៏ជានវត្តព្វារម្មណ៍ ។

ពាក្យថា **"តីណិន្ទ្រិយានិ ពហិទ្ធារម្មណានិ** = ឥន្ទ្រិយ ៣ ជាពហិទ្ធារម្មណ៍" បានដល់ ឥន្ទ្រិយ ៣ ជាលោកុត្តរិន្ទ្រិយ ។

បទថា **ចត្តារិ** បានដល់ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ និងទោមន-

ស្សិន្ទ្រិយ; ព្រោះឥន្ទ្រិយទាំង ៤ នោះ ប្រារព្ធហើយប្រព្រឹត្តទៅក្នុងអជ្ឈត្តធម៌ខ្លះ ក្នុងពហិទ្ធាធម៌ខ្លះ ។ បទថា **“អដ្ឋិន្ទ្រិយានិ = ឥន្ទ្រិយ ៨”** បានដល់ មនិន្ទ្រិយ ជីវិតិន្ទ្រិយ ឧបេក្ខិន្ទ្រិយ និងឥន្ទ្រិយពួក ៥ មានសទ្ធិន្ទ្រិយជាដើម; ក្នុងបណ្តាឥន្ទ្រិយទាំង ៨ នោះ សេចក្តីជានវត្តព្វារម្មណ៍ គប្បីជ្រាបក្នុងវេលានៃអាកិញ្ចញ្ញាយតនៈ ។

សូម្បីក្នុងបញ្ហាបុច្ឆកៈនេះ ឥន្ទ្រិយ ១០ ជាកាមាវចរ, ឥន្ទ្រិយ ៣ ជាលោកុត្តរ, ឥន្ទ្រិយ ៩ ជាឥន្ទ្រិយលាយគ្នាទាំងលោកិយ និងលោកុត្តរ ជាធម៌ដែលព្រះមានព្រះភាគត្រាស់ហើយដោយប្រការដូច្នេះ សូម្បីបញ្ហាបុច្ឆកៈនេះ ក៏ជាបរិច្ឆេទតែម្យ៉ាងជាមួយនឹងអភិធម្មភាជនិយតែប៉ុណ្ណោះ, ក៏ឥន្ទ្រិយវិភង្គនេះ ព្រះមានព្រះភាគទ្រង់នាំចេញមកចែកសម្តែងហើយជា ២ បរិវដ្ដ ដោយប្រការដូច្នេះ ៕

**ចប់ឥន្ទ្រិយវិភង្គនិទ្ទេស**

**សម្មោហវិនោទនី**

**អដ្ឋកថាព្រះអភិធម្មបិដក**

**ឈ្មោះវិភង្គបករណ៍**

**ទុតិយភាគ ៥**

**ចប់**

បោះពុម្ពលើកទី ២

រក្សាសិទ្ធិ (ហាមថតចម្លង)